# របាយការណ៍វឌ្ឍនភាព

## ស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទៅនឹងការជួញដូរមនុស្សនៅតំបន់អាស៊ាន

ការកែសម្រួលលើកទី២ - ឆ្នាំ២០១៨



**របាយការណ៍វឌ្ឍនភាព ស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹង**
**ការជួញដូរមនុស្សនៅតំបន់អាស៊ាន ការកែសម្រួលលើកទី ២**

របាយការណ៍នេះត្រូវបានគាំទ្រដោយកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានលើកទី១៨ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន
និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗ នៅទីក្រុង Putrajaya ប្រទេសម៉ាឡេស៊ី (ខែកញ្ញា ឆ្នាំ២០១៨)។

**បោះពុម្ពផ្សាយ ខែតុលា ឆ្នាំ២០១៨**

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧

រដ្ឋជាសមាជិកនៃសមាគមនេះរួមមាន ប្រទេសប្រ៊ុយណេ ដារូសាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន
សាធារណរដ្ឋសិង្ហបុរី
ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
ការិយាល័យកិច្ចការសាធារណ:
លេខាធិការដ្ឋានសមាគមអាស៊ាន
70A Jalan Sisingamangaraja
ក្រុងហ្សាការតា 12110 ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ៖ (6221) 724-3372, 726-2991
ទូរសារ៖ (6221) 739-8234, 724-3504
អ៊ីមែល៖ public@aseansec.org
គេហទំព័រអាស៊ាន៖ http://www.aseansec.org

AUSTRALIA - ASIA PROGRAM TO COMBAT TRAFFICKING IN PERSONS

ការបោះពុម្ពផ្សាយនេះទទួលការគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីអូស្ត្រាលី-អាស៊ីប្រឆាំងការជួញដូរមនុស្ស
(AATIP) គ្រប់គ្រងដោយ ក្រុមហ៊ុនខាតណូ អ៊ីមើជីង ម៉ាឃីត (អូស្ត្រាលី)។

# កំណត់សម្គាល់ស្តីអំពីការកែសម្រួលរបាយការណ៍វឌ្ឍនភាពនេះ

ការកែសម្រួលលើកទីមួយនៃ *របាយការណ៍វឌ្ឍនភាពអាស៊ានស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស* ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០១១ បន្ទាប់ពីមានសំណើពីកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC)។ ចាប់តាំងពីពេលនោះមក មានការវិវត្តន៍គួរឲ្យកត់សម្គាល់នៅក្នុង និងក្រៅតំបន់ ជាពិសេសក្រោយពេលមានការអនុម័ត *អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ* នៅខែវិច្ឆិកា ឆ្នាំ២០១៥។ កិច្ចសហប្រតិបត្តិការអាស៊ានបានកើនឡើងជាលំដាប់ និងនៅថ្នាក់ជាតិ រដ្ឋសមាជិកអាស៊ានភាគច្រើនបានឆ្លងកាត់បទពិសោធន៍ និងមានចំណេះដឹងស៊ីជម្រៅជាច្រើនក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងការវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរមនុស្ស។

ការកែសម្រួលលើកទីពីរនៃ *របាយការណ៍វឌ្ឍនភាព* នេះមានគោលបំណងស្រង់យកនូវការវិវត្តន៍ទាំងឡាយរួមមាន៖ ការធ្វើបច្ចុប្បន្នភាព និងការពង្រីកព័ត៌មានដែលបានផ្តល់ជូននៅក្នុងសំណៅដើម ដើម្បីផ្តល់ការវាយតម្លៃឲ្យទាន់ពេលវេលាទៅលើអ្វីដែលសម្រេចបាន និងការប្រឈមនានាដែលនៅមាន។

ការកែសម្រួលលើកទីមួយនៃរបាយការណ៍វឌ្ឍនភាព ត្រូវបានរៀបរៀងឡើងដោយមានការគាំទ្រដោយកម្មវិធីស្តីពីការជួញដូរមនុស្សក្នុងតំបន់អាស៊ីដែលមានការឧបត្ថម្ភមូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលី។ ការកែសម្រួលលើកទីពីរនេះត្រូវបានរៀបរៀងឡើងដោយមានជំនួយពីគម្រោងបន្ទាប់គឺ កម្មវិធីអាស៊ី-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស (AAPITP)។ សម្រាប់ការកែសម្រួលទាំងពីរលើកនេះ ព័ត៌មាន និងចំណេះដឹងស៊ីជម្រៅដ៏មានតម្លៃ ព្រមទាំងមតិត្រឡប់ទៅលើការរៀបចំសេចក្តីព្រាង ត្រូវបានផ្តល់ដោយអ្នកប្រតិបត្តិពីរដ្ឋសមាជិកអាស៊ានទាំង ១០ ប្រទេស។

រួមជាមួយការកែសម្រួលលើកទីមួយ របាយការណ៍នេះត្រូវបានបង្កើតឡើងបន្ទាប់ពីមានសំណើពីកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន។ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលីបានផ្តល់ការគាំទ្រដល់ការបង្កើតឯកសារនេះ។ ទោះជាយ៉ាងណាក្តី មតិយោបល់ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងមតិយោបល់របស់អាស៊ាន ឬរដ្ឋាភិបាលអូស្ត្រាលីទេ។

# អារម្ភកថារបស់អគ្គលេខាធិការអាស៊ានចំពោះការកែសម្រួលលើកទីមួយ



ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ តំបន់អាស៊ានបានច្របាច់បញ្ចូលគ្នាជាសមាគមមួយ និងជាអ្នកនាំមុខក្នុងការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស បណ្តារដ្ឋដែលជាសមាជិកទាំងអស់ បានបោះជំហានយ៉ាងធំធេងឆ្ពោះទៅគោលដៅរបស់អាស៊ានក្នុងបញ្ចប់និទណ្ឌភាពចំពោះជនជួញដូរ និងធានាផ្តល់ភាពយុត្តិធម៌ដល់ជនរងគ្រោះដោយសារបទល្មើសធ្ងន់ធ្ងរនេះ តាមរយៈការធ្វើការងារជាលក្ខណៈឯកត្តជន និងជាសមូហភាព ។

ក្នុងនាមជាអគ្គលេខាធិការអាស៊ាន ខ្ញុំមានមោទនភាពជាពន់ពេកសូមនាំយកជូននូវឯកសារបោះពុម្ពផ្សាយនេះគឺជា៖ *របាយការណ៍វឌ្ឍនភាពស្តីពីការ ឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស* របស់យើង។ របាយការណ៍នេះ លើកឡើងនូវសមិទ្ធិផលដែលសម្រេចបានក្នុងទសវត្សរ៍កន្លងទៅ និងពិនិត្យជារួម លើបញ្ហាប្រឈមនានាដែលនឹងអាចកើតមានឡើងនាពេលខាងមុខ។ របាយការណ៍នេះលើកឡើងនូវសមាសភាពសំខាន់ៗចំនួន ៧ នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស មានដូចជា៖

- ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ
- សមត្ថភាពស៊ើបអង្កេតរបស់អ្នកឯកទេសក្នុងការស៊ើបអង្កេតសំណុំរឿងជួញដូរ
- សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ ក្នុងការកំណត់
- អត្តញ្ញាណ និងឆ្លើយតបទៅនឹងការជួញដូរ
- សមត្ថភាពរបស់អយ្យការ និងតុលាការទាក់ទងនឹងសំណុំរឿងជួញដូរ
- ការកំណត់អត្តសញ្ញាណ ការការពារ និងការគាំទ្រជនរងគ្រោះ
- ការផ្តល់ការគាំទ្រពិសេសដល់ជនរងគ្រោះជាសាក្សី និង
- កិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិក្នុងសំណុំរឿងជួញដូរ។

សមាសភាពនីមួយៗក្នុងចំណោមសមាសភាពទាំងនេះ ស្ថិតនៅក្នុងជំពូកនីមួយៗដាច់ដោយឡែកពីគ្នា នៅក្នុងរបាយការណ៍នេះ។ ក្នុងជំពូកនីមួយៗ អ្នកនិពន្ធបានផ្តល់នូវទិដ្ឋភាពទូទៅលម្អិតនៃបទដ្ឋានពាក់ព័ន្ធដែលបានលេចឡើងតាមរយៈការរួមបញ្ចូលគ្នានូវច្បាប់ និងគោលនយោបាយនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ព្រមទាំងឧត្តមានុវត្តន៍ដែលត្រូវបានទទួលយកនៅក្នុង និងក្រៅតំបន់អាស៊ាន។ បន្ទាប់មក ជំពូកនីមួយៗពិចារណាទៅដល់វិសាលភាពដែលរដ្ឋសមាជិកអាស៊ានសម្រេចបានទៅតាមបទដ្ឋានទាំងនោះ ព្រមទាំងឧបសគ្គធំៗ និងកាលានុវត្តភាពនានា។ នៅចុងបញ្ចប់នៃជំពូកនីមួយៗ មានបញ្ជីត្រួតពិនិត្យមួយ ដែលរដ្ឋសមាជិកអាស៊ានអាចប្រើប្រាស់ ដើម្បីវាស់ស្ទង់ពីគុណភាពនៃការឆ្លើយតបរបស់ខ្លួន និងដើម្បីកំណត់អត្តសញ្ញាណនូវវិស័យនានាដែលចាំបាច់ត្រូវធ្វើការបន្ថែមទៀត។

ទិដ្ឋភាពទូទៅដោយសង្ខេបនេះបង្ហាញកាន់តែច្បាស់ថា *របាយការណ៍វឌ្ឍនភាពនេះ* គឺជាការប្រមូលផ្តុំព័ត៌មានទាំងឡាយដែលរកបានជាសាធារណៈ។ គោលបំណងនៃរបាយការណ៍នេះមានមហិច្ឆតាធំធេង៖ គឺដើម្បីពិពណ៌នា និងពិនិត្យមើលទៅលើការឆ្លើយតបនៅថ្នាក់ជាតិ និងថ្នាក់តំបន់ទៅនឹងការជួញដូរនៅតំបន់អាស៊ីអគ្នេយ៍ ដោយយោងជាក់លាក់ទៅវិធានការ និងបទដ្ឋាននានា ដែលរដ្ឋសមាជិកអាស៊ាន បានបង្កើតឡើងដោយខ្លួនឯង ឬបានទទួលយកដោយសេរី។ ខ្ញុំយល់ឃើញថា នេះជានវកម្មពិសេសមួយ និងអាចផ្តល់ជាគំរូយ៉ាងល្អសម្រាប់បណ្តាប្រទេសដ៏ទៃទៀត និងតំបន់ផ្សេងៗទៀត។

ចុងបញ្ចប់នៃរបាយការណ៍នេះ ផ្តល់នូវបុព្វហេតុដល់ក្តីសង្ឃឹមយ៉ាងធំធេង គឺថា៖ ការបញ្ជាក់អះអាងថារដ្ឋសមាជិកអាស៊ាន កំពុងបន្តនាំផ្លូវមួយទៅកាន់ការអភិវឌ្ឍន៍នូវការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស។ ទោះជាយ៉ាងណាក្តី យើងមានសិទ្ធិមានមោទភាពចំពោះសមិទ្ធិផលជាច្រើនរបស់យើងក៏ដោយ តែការសំខាន់ត្រូវទទួលស្គាល់ថា យើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ *របាយការណ៍វឌ្ឍនភាពនេះ* បញ្ជាក់ថា គេកម្រកំណត់បានអត្តសញ្ញាណ ឬចោទប្រកាន់ និងផ្តន្ទាទោសជនជួញដូរណាស់ ទាំងនៅក្នុងតំបន់យើងនេះ ក៏ដូចជាគ្រប់ទិសទីនៃពិភពលោក ។ ជនរងគ្រោះនៃការជួញដូរកម្រទទួលបានទម្រង់ណាមួយនៃយុត្តិធម៌ ឬក៏ការដោះស្រាយសម្រាប់គ្រោះថ្នាក់ផ្សេងៗ ដែលត្រូវបានប្រព្រឹត្តមកលើពួកគេណាស់។ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិមិនទាន់បានដំណើរការពេញលេញទៅតាមកាតព្វកិច្ច នៃការស៊ើបអង្កេត ការចោទប្រកាន់ និងការវិនិច្ឆ័យទៅលើបទល្មើសទាំងនេះទៅឡើយទេ ហើយកិច្ចសហប្រតិបត្តិការឆ្លងដែនទៀតសោត ក៏នៅមានកម្រិតទាបនៅឡើយ។

ក្នុងការស្វែងរកការផ្លាស់ប្តូរស្ថានភាពនេះ យើងត្រូវតែយល់ឲ្យច្បាស់ថា ការជួញដូរមនុស្សគឺមិនត្រូវឲ្យមាននៅក្នុងសង្គមអាស៊ានទេ គឺមានន័យថា៖ បុរស ស្ត្រី និងកុមារគ្រប់រូប នៅក្នុងតំបន់នេះ មានសិទ្ធិរស់នៅដោយមានសេរីភាព និងសេចក្តីថ្លៃថ្នូរ។ ខ្ញុំសូមអំពាវនាវដល់បណ្តារដ្ឋាភិបាល នៃរដ្ឋសមាជិកអាស៊ានទាំងអស់ សូមបន្តការងារដ៏ល្អរបស់ខ្លួនតទៅទៀតគឺ៖ ដើម្បីរួមគ្នា ក្នុងការឆ្លើយតបដ៏មានប្រសិទ្ធភាពពិតប្រាកដមួយ នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស។ ប្រទេសរបស់យើង សហគមន៍របស់យើង និងប្រជាជនរបស់យើងគួរទទួលបាននូវភាពល្អប្រសើរជាងនេះទៀត។



ស៊ូរីន ពិតស៊ូវាន់
អគ្គលេខាធិការអាស៊ាន ទីក្រុងហ្សាការតា ខែកក្កដា ឆ្នាំ២០១១

# អារម្ភកថារបស់ប្រធានក្រុមស្ម័គ្រចិត្តស្តីពីការជួញដូរមនុស្ស និងជាប្រធានក្រុមការងារ SOMTC ស្តីពីការជួញដូរមនុស្ស នៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ( SOMTC )

ខ្ញុំមានសេចក្តីរីករាយជាពន់ពេកសូមបង្ហាញជូននូវការកែសម្រួលលើកទីពីរនៃ *របាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស* ដែលបានធ្វើបច្ចុប្បន្នភាពលើការសិក្សាយ៉ាងទូលំទូលាយអំពីសមិទ្ធិផល និងការប្រឈមនានាដែលបានបង្កើតឡើងលើកដំបូងដោយ SOMTC នៅឆ្នាំ២០១១។

របាយការណ៍នេះផ្តល់នូវភស្តុតាងយ៉ាងរឹងមាំថា ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្សនៅតំបន់អាស៊ានបានវិវត្តតាមមធ្យោបាយសំខាន់ៗជាច្រើន។ នាពេលបច្ចុប្បន្ននេះ បណ្តារដ្ឋសមាជិកអាស៊ានទាំងអស់បានទទួលផលប្រយោជន៍ពីក្របខ័ណ្ឌគតិយុត្តិរឹងមាំ ដែលរដ្ឋទាំងអស់បានបង្កើតជាស្ថាប័ន និងប្រព័ន្ធឯកទេសភាព ដើម្បីពង្រឹងការស៊ើបអង្កេត ការចោទប្រកាន់ និងការវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរមនុស្ស។ រដ្ឋទាំងអស់បានបោះជំហានសំខាន់ៗដើម្បីកែលម្អបទពិសោធន៍របស់ជនរងគ្រោះពីការជួញដូរ តាមរយៈការពង្រឹងការការពារ និងជំនួយដល់ពួកគេ។ តំបន់របស់យើងនៅតែបន្តនាំមុខតំបន់ផ្សេងៗទៀត លើចំណុចសំខាន់ៗជាច្រើន ដូចជាយើងមានមានអ្នកជំនាញជាច្រើន នៅក្នុងកងកម្លាំងនគរបាលជាតិ។ រដ្ឋសមាជិកអាស៊ានជាច្រើន មានការវិវត្តន៍ដ៏សំខាន់នៃមុខងារឯកទេសរបស់អយ្យការ និងតុលាការ ហើយក្នុងនោះដែរ អាស៊ានជាតំបន់តែមួយគត់ ក្រៅពីតំបន់អឺរ៉ុប ដែលបានបង្កើតកិច្ចព្រមព្រៀងគតិយុត្តិរបស់ខ្លួនលើបញ្ហានេះ។ *អនុសញ្ញាអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ* ដែលបានចូលជាធរមាននៅឆ្នាំ២០១៧ បង្ហាញឱ្យឃើញពីការបញ្ជាក់អះអាងយ៉ាងច្បាស់នូវគោលបំណងរួមរបស់អាស៊ាន ក្នុងការឆ្លើយតបទៅនឹងនិទណ្ឌភាពរបស់ជនជួញដូរទទួលបាន ដែលបច្ចុប្បន្ននេះនៅមានកម្រិតខ្ពស់នៅឡើយ និងដើម្បីធានានូវយុត្តិធម៌ដល់ជនរងគ្រោះដោយសារបទល្មើសធ្ងន់ធ្ងរនេះ។

ជាការពិត នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដូចអ្វីដែលបាន បង្ហាញយ៉ាងច្បាស់ក្នុងរបាយការណ៍នេះ គឺថា យើងនៅមានគម្លាត និងភាពទន់ខ្សោយជាច្រើនដែលត្រូវឆ្លើយតប ក្នុងរដ្ឋសមាជិកនីមួយៗ និងក្នុងសហគមន៍អាស៊ានទាំងមូល ។ ក្នុងនោះការប្រឈមដែលត្រូវបានកំណត់រួមមានដូចខាងក្រោម៖

**ការធានាឲ្យបានគ្រប់គ្រាន់ លើធនធាន និងជំនាញ ៖** បទពិសោធន៍នៅក្នុងតំបន់របស់យើងបានបញ្ជាក់ថា ការឆ្លើយតបយ៉ាងខ្លាំងក្លានៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស តម្រូវឲ្យយើងមានការវិនិយោគទៅលើធនធានមនុស្សជាច្រើនថែមទៀត ក៏ដូចជាតម្រូវឲ្យមានការគាំទ្រពេញលេញ និងការបណ្តុះបណ្តាលត្រឹមត្រូវ ដល់មន្ត្រីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ នៅគ្រប់កម្រិតនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ចំណុចនេះអាចធ្វើទៅបានប្រសិនបើអ្នកធ្វើសេចក្តីសម្រេច ផ្តល់អាទិភាព និងផ្តល់ភាពជាអ្នកដឹកនាំ និងធនធានចាំបាច់សម្រាប់ការឆ្លើយតបឲ្យមានប្រសិទ្ធភាព ទៅលើការជួញដូរមនុស្ស។

**ការកំណត់គោលដៅសមស្រប និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖** ទោះបីការចោទប្រកាន់ចំពោះជនកេងប្រវ័ញ្ចមានសារៈសំខាន់ ក៏ដោយ តែចំណុចនេះមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌ផ្សេងៗឡើយ។ របាយការណ៍នេះក៏បានកត់សម្គាល់ពីហានិភ័យ នៃការអនុវត្តមិនត្រឹមត្រូវនៃច្បាប់ជួញដូរតាម រយៈការជ្រៀតជ្រែកផ្នែកនយោបាយ និងការចង់បានហួសហេតុ និងការកំណត់គោលដៅធំធេងពេកសម្រាប់ការចោទប្រកាន់ ដែលពិបាកធ្វើឱ្យវាក្លាយជាការពិតបាន។ របាយការណ៍នេះក៏ទាញនូវចំណាប់អារម្មណ៍ផ្សេងៗ ចំពោះសារៈសំខាន់ក្នុងការធានាថា ការធានាផ្នែកនីតិវិធីឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានយកមកអនុវត្ត នៅក្នុងសំណុំរឿងជួញដូរទាំងអស់។ រដ្ឋដែលពុំបានសង្កេតទៅលើបទដ្ឋានទាំងនេះ ប្រឈមនឹងហានិភ័យ នៃការធ្វើឲ្យប៉ះពាល់ដល់សុចរិតភាព និងកិត្តិយសនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ខ្លួន។ ការមិនបានបំពេញនូវលក្ខខណ្ឌទាំងនេះអាចធ្វើឲ្យបាត់បង់ការគាំទ្រពីសហគមន៍ ក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើជនជួញដូរផងដែរ។

**ការឆ្លើយតបទៅនឹងអំពើពុករលួយពាក់ព័ន្ធនឹងការជួញដូរ៖** អំពើពុករលួយ និងការសមគំនិតនៃវិស័យសាធារណៈក្នុងការជួញដូរ គឺជាបញ្ហាដែលកើតមានឡើងនៅតំបន់ជាច្រើនទូទាំងពិភពលោក និងរួមទាំងតំបន់អាស៊ានផងដែរ។ មានការវិវត្តន៍សំខាន់ដែលបានលើកឡើងតាំងពី របាយការណ៍លើកមុន ក្នុងការកំណត់ និងឆ្លើយតបទៅនឹងអំពើពុករលួយពាក់ព័ន្ធនឹងការជួញដូរ។ ទោះជាយ៉ាងណាក្តី យើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីធានាថា អំពើពុករលួយ និងការយល់ឃើញពីអំពើពុករលួយ មិនរារាំងដល់ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឧទាហរណ៍ ដូចជាការមិនលើកទឹកចិត្ត ដើម្បីឲ្យជនរងគ្រោះចូលរួមក្នុងដំណើរការចោទប្រកាន់ លើជនកេងប្រវ័ញ្ចមកលើពួកគេ ជាដើម។ របាយការណ៍ក៏បានលើកឡើងដែរពីការអនុវត្តន៍ដំណោះស្រាយ “ក្រៅផ្លូវការ” (ដែលជាទូទៅពាក់ព័ន្ធនឹងជនសង្ស័យដែលបានសងសំណងជំងឺចិត្ត ទៅជនរងគ្រោះក្រៅផ្លូវការ) ដែលបង្ហាញពីហានិភ័យធ្ងន់ធ្ងរ ទៅលើសុចរិតភាពនៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ៖ មិនត្រឹមតែជាការជំរុញឲ្យមានអំពើពុករលួយប៉ុណ្ណោះទេ តែក៏ធ្វើឲ្យប៉ះពាល់ដល់នីតិរដ្ឋ ដែលជួយសម្រួលដល់និទណ្ឌភាព និងជាការរារាំងចំពោះការផ្តល់យុត្តិធម៌ពិតប្រាកដដល់ជនរងគ្រោះផងដែរ។

**ការគោរព និងការលើកកម្ពស់សិទ្ធិរបស់ជនរងគ្រោះ៖** នៅក្នុងតំបន់នេះទាំងមូល យើងមានការបោះជំហានយ៉ាងធំធេង ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរ ព្រមទាំងការថែទាំ និងការគាំទ្រដល់ពួកគេ។ ប៉ុន្តែយើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ជាពិសេសពាក់ព័ន្ធនឹងដំណើរការ នៃការចូលរួមរបស់ជនរងគ្រោះក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ដូចបានកត់សម្គាល់នៅក្នុងរបាយការណ៍នេះគឺថា៖ *“ស្ទើរតែគ្រប់ករណីទាំងអស់ នៃបទពិសោធន៍របស់ជនរងគ្រោះនៃការជួញដូរមនុស្សក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ មានលក្ខណៈអវិជ្ជមាន។ នៅក្នុងករណីមួយចំនួន ជនរងគ្រោះបានទទួលរងព្យសនកម្មដោយផ្ទាល់ និងធ្ងន់ធ្ងរបន្ថែមទៀត ដោយសារ មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងស្ថាប័នតុលាការ។ លើសពីនេះមានការជំរុញលើកទឹកចិត្តតិចតួច ដល់ជនរងគ្រោះ ដើម្បីឲ្យពួកគេចូលរួមសហការក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចមកលើពួកគេ។ ជារឿយៗសិទ្ធិ និងការការពារ ចំពោះជនរងគ្រោះដែលមាននៅក្នុងច្បាប់ និងគោលនយោបាយ មិនអាចយកមកប្រើក្នុងការអនុវត្តន៍ជាក់ស្តែងបានទេ”*។ មានភាពចាំបាច់ជាបន្ទាន់ក្នុងការពន្លឿនវឌ្ឍនភាពក្នុងវិស័យនេះ រួមទាំងតាមរយៈការចែករំលែកឧត្តមានុវត្តន៍ដែលបានបង្កើតឡើង និងកំពុងលេចឡើងរវាងរដ្ឋសមាជិកអាស៊ានទាំងអស់។

**ការកែលម្អកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** ទោះបីមានភាពជឿនលឿនមួយចំនួននៅកម្រិតលើផ្នែកគោលនយោបាយ និងការអនុវត្តន៍ក្តីប៉ុន្តែចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធ

នឹងការជួញដូរមនុស្ស នៅតែជាករណីពិសេស ដោយសារវាមិនទាន់ក្លាយជាវិធានការច្បាប់នៅឡើយទេ។ ឧបសគ្គផ្នែកច្បាប់ និងនីតិវិធីនៅតែជាបញ្ហាសំខាន់មួយ ប៉ុន្តែបញ្ហាដែលខ្លាំងបំផុតជាងនេះទៀតនោះគឺ ពាក់ព័ន្ធនឹងឥរិយបថ និងការលើកទឹកចិត្ត ក្នុងកិច្ចសហប្រតិបត្តិការ។ នៅមានការងារជាច្រើនទៀតដែល រដ្ឋសមាជិកនីមួយៗ និងសហគមអាស៊ានចាំបាច់ត្រូវធ្វើ ដើម្បីបង្កើតបាន*វប្បធម៌*នៃកិច្ចសហប្រតិបត្តិការ និងដើម្បីបង្កើតប្រព័ន្ធមួយដែលទទួលស្គាល់ និងផ្តល់តម្លៃដល់មន្ត្រីអនុវត្តច្បាប់ និងស្ថាប័ននានា ដែលធ្វើកិច្ចសហការឆ្លងដែន ជាមួយដៃគូរបស់ពួកគេ។

ចំណុចខ្លាំងមួយក្នុងចំណោមភាពខ្លាំងជាច្រើនរបស់អាស៊ាន គឺសមត្ថភាពរបស់ខ្លួនក្នុងការបង្កើតជាសហគមឯកច្ឆ័ន្ទភាពមួយ ហើយការសម្រេចបាននូវឯកច្ឆ័ន្ទភាពនេះ នឹងអាចជំនះបាននូវរាល់បញ្ហាដែលលំបាកៗដែលកើតមានឡើង។ នៅក្នុងវិស័យជួញដូរមនុស្ស រដ្ឋសមាជិក និងសគមអាស៊ានទាំងមូល បានបង្ហាញម្តងហើយម្តងទៀតនូវសមត្ថភាពដើម្បីធ្វើការរួមគ្នា ក្នុងការបង្កើតគំនិតច្នៃប្រឌិតថ្មី និងការកែលម្អផ្សេងៗ។ ជាការពិតយើងពិតជាអបអរសាទរលើសមិទ្ធផលដែលយើងសម្រេចបានខ្លាំងណាស់ ប៉ុន្តែយើងក៏ត្រូវប្តេជ្ញាបន្តទៀត ដើម្បីឆ្លើយតបទៅនឹងបទល្មើស និងការរំលោភបំពានសិទ្ធិមនុស្ស នៃការជួញដូរមនុស្សនេះតទៅទៀត។

ក្នុងនាមសមាគមអាស៊ាន ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកប្រតិបត្តិមួយចំនួន ក្នុងរដ្ឋសមាជិកអាស៊ានទាំង ១០ ដែលបានចូលរួមចំណែកដល់ការកែសម្រួលនៃ *របាយការណ៍វឌ្ឍនភាព*នេះ តាមរយៈការចែករំលែកទាំងព័ត៌មាន និងចំណេះដឹងសំខាន់ៗទាំងឡាយ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់រដ្ឋាភិបាលអូស្ត្រាលីសម្រាប់ការគាំទ្រយូរអង្វែងដល់កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ក្នុងការអភិវឌ្ឍនូវការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស និងក្រុមការងារអនុវត្តកម្មវិធីអូស្ត្រាលី អាស៊ីប្រឆាំងការជួញដូរមនុស្ស (AAPTIP) ដែលបានដើរតួនាទីយ៉ាងសំខាន់ និងនាំមុខគេ ក្នុងការរៀបចំរបាយការណ៍នេះ និងធានានូវគុណភាពនៃរបាយការណ៍នេះ ដែលគួរឲ្យកោតសរសើរ។

Hon. Bernardo C. Florece Jr.

កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន

ប្រធានក្រុមស្ម័គ្រចិត្តស្តីពីការជួញដូរមនុស្ស

ក្រុងម៉ានីល ប្រទេសហ្វីលីពីន ខែសីហា ឆ្នាំ២០១៨

# មាតិកា


កំណត់សម្គាល់ស្ដីអំពីការកែសម្រួលរបាយការណ៍វឌ្ឍនភាពនេះ ....................................................... i
អារម្ភកថារបស់អគ្គលេខាធិការអាស៊ានចំពោះការកែសម្រួលលើកទីមួយ ............................................. ii
អារម្ភកថារបស់ប្រធានក្រុមស្នូគ្រចិត្តស្ដីពីការជួញដូរមនុស្ស និងជាប្រធានក្រុមការងារ SOMTC ស្ដីពីការជួញដូរមនុស្ស នៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) ............... iv
មាតិកា ........................................................................................................... vii
លិខិតូបករណ៍សន្ធិសញ្ញា និងមិនមែនសន្ធិសញ្ញាដែលបានយោងនៅក្នុងរបាយការណ៍វឌ្ឍនភាព....................... ix
តារាង និងប្រអប់អត្ថបទ ........................................................................................ xii
អក្សរកាត់ និងបង្រួមពាក្យ ....................................................................................... xv
សេចក្ដីសង្ខេបប្រតិបត្តិ ........................................................................................... ១
សេចក្ដីផ្ដើម ......................................................................................................១១
ជំពូកទី ១៖ ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ........................................................ ២៣
១.១ ធាតុផ្សំសំខាន់នៃក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ............................................ ២៣
១.២ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅកាន់ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ៖ ទិដ្ឋភាពនៃការកំណត់បទល្មើស ............................................................................................ ២៧
១.៣ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅកាន់ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ៖ ទិដ្ឋភាពនៃការការពារ និងការគាំទ្រជនរងគ្រោះ.......................................................................... ៤៣
១.៤ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ........................................................ ៥៦
ជំពូកទី ២៖ សមត្ថភាពស៊ើបអង្កេតឯកទេស.................................................................. ៦៣
២.១ ហេតុអ្វីត្រូវចាំបាច់មានភាពជំនាញលើមុខងារនៃការស៊ើបអង្កេត?.......................................៦៣
២.២ ធាតុផ្សំសំខាន់ៗនៃសមត្ថភាពរបស់អ្នកអនុវត្តច្បាប់ជំនាញ ........................................... ៦៥
២.៣ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅសមត្ថភាពស៊ើបអង្កេតឯកទេស......................................... ៦៩
២.៤ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត .........................................................៨៤
ជំពូកទី ៣៖ សមត្ថភាពអនុវត្តន៍ច្បាប់ជួរមុខដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព...............................១០៣
៣.១ សារៈសំខាន់ នៃការឆ្លើយតបជួរមុខយ៉ាងមានប្រសិទ្ធភាព..............................................១០៣
៣.២ ធាតុផ្សំសំខាន់ៗនៃការឆ្លើយតបជួរមុខយ៉ាងមានប្រសិទ្ធភាព........................................... ១០៤
៣.៣ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅការឆ្លើយតបរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខជួរមុខយ៉ាងមានប្រសិទ្ធភាព .......................................................................................... ១០៨
៣.៤ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ........................................................ ១១៨
ជំពូកទី ៤៖ ការឆ្លើយតបដែលរឹងមាំ និងមានព័ត៌មានគ្រប់គ្រាន់ពីអយ្យការ និងតុលាការ ...................... ១២៧

៤.១ ធាតុផ្សំសំខាន់ៗនៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពពីអយ្យការ និងតុលាការ......................១២៧
៤.២ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពពីស្ថាប័នអយ្យការ និងស្ថាប័នតុលាការ ........................................................................................ ១៣០
៤.៣ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ...................................................... ១៤៦

ជំពូកទី ៥៖ ការកំណត់អត្តសញ្ញាណជនរងគ្រោះបានឆាប់រហ័ស និងត្រឹមត្រូវការផ្ដល់ការការពារ និង ការគាំទ្រភ្លាមៗ.................................................................................... ១៦៣
៥.១ ធាតុផ្សំសំខាន់នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ................................................. ១៦៤
៥.២ វឌ្ឍនភាពរបស់អាស៊ានពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ....................................................................................... ១៦៧
៥.៣ ធាតុផ្សំសំខាន់ៗនៃការការពារ និងការគាំទ្រជនរងគ្រោះ ............................................... ១៧៨
៥.៤ វឌ្ឍនភាពរបស់អាស៊ានទាក់ទងនឹងការការពារ និងការគាំទ្រជនរងគ្រោះ ............................ ១៨៤
៥.៥ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ...................................................... ១៩១

ជំពូកទី ៦៖ ការគាំទ្រពិសេសដល់ជនរងគ្រោះជាសាក្សី..................................................២០៣
៦.១ ធាតុផ្សំសំខាន់នៃការការពារពិសេសដល់ជនរងគ្រោះជាសាក្សី........................................២០៤
៦.២ វឌ្ឍនភាពរបស់អាស៊ានទាក់ទងនឹងការគាំទ្រជនរងគ្រោះជាសាក្សី ....................................២០៨
៦.៣ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ......................................................២៣០

ជំពូកទី ៧៖ កិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព ...............................................២៤១
៧.១ កិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព៖ ទិដ្ឋភាពទូទៅ និងធាតុផ្សំគន្លឹះ ............២៤៥
៧.២ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅកិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព............២៥៥
៧.៣ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត ......................................................២៦៨

# លិខិតូបករណ៍សន្ធិសញ្ញា និងមិនមែនសន្ធិសញ្ញាដែលបានយោងនៅក្នុងរបាយការណ៍វឌ្ឍនភាព

## លិខិតូបករណ៍អន្តរជាតិ និងតំបន់

| |
|---|
| អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| អនុសញ្ញាស្តីពីការបង្ក្រាបការលក់ដូរទាសករ និងអំពើទាសភាព |
| កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| អនុសញ្ញាលេខ ២៩ របស់អង្គការពលកម្មអន្តរជាតិ៖ អនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ឬជាកាតព្វកិច្ច |
| អនុសញ្ញាលេខ ១០៥ របស់អង្គការពលកម្មអន្តរជាតិ៖ អនុសញ្ញាស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ |
| អនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ៖ អនុសញ្ញាស្តីពីការហាមឃាត់ និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ |
| អនុសញ្ញាលេខ ១៨៩ របស់អង្គការពលកម្មអន្តរជាតិ៖ អនុសញ្ញាស្តីពីការងារសមរម្យសម្រាប់ពលករធ្វើការតាមផ្ទះ |
| អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ |
| ពិធីសារទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង |
| ពិធីសារបន្ថែមទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារស្តីពីការលក់ដូរកុមារ អំពើពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ |
| សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងបញ្ហាព្រហ្មទណ្ឌ ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ានដែលមានឆន្ទៈដូចគ្នា |
| អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ |
| អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង |

# លិខិតូបករណ៍សន្ធិសញ្ញា និងមិនមែនសន្ធិសញ្ញាអន្តរជាតិ និងថ្នាក់តំបន់

| |
|---|
| សេចក្តីប្រកាសរបស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (ឆ្នាំ១៩៩៧) |
| ចក្ខុវិស័យអាស៊ានឆ្នាំ២០២០ (ឆ្នាំ១៩៩៧) |
| គោលការណ៍ និងសេចក្តីណែនាំដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស (ឆ្នាំ២០០២) |
| សេចក្តីប្រកាសរបស់អាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ឆ្នាំ២០០៤) |
| អនុស្សរណៈនៃការយល់ឃោគគ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្ស នៅក្នុងអនុតំបន់មហាទន្លេមេគង្គ (COMMIT) (ឆ្នាំ២០០៤) |
| [UNICEF] គោលការណ៍ណែនាំស្តីពីការការពារកុមាររងគ្រោះពីការជួញដូរ (ឆ្នាំ២០០៦) |
| [UNCHR] គោលការណ៍ណែនាំស្តីពីការការពារជាអន្តរជាតិ៖ ការអនុវត្តន៍មាត្រា ១ក(២) នៃអនុសញ្ញាឆ្នាំ១៩៥១ និង/ឬ ពិធីសារឆ្នាំ១៩៦៧ ពាក់ព័ន្ធនឹងឋានៈរបស់ជនភៀសខ្លួនចំពោះជនរងគ្រោះនៃការជួញដូរមនុស្សដែលស្ថិតក្នុងហានិភ័យពីការជួញដូរ (ឆ្នាំ២០០៦) |
| សេចក្តីប្រកាសរបស់អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧) |
| គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន ស្តីពីការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស (ឆ្នាំ២០០៧) |
| ផែនការសកម្មភាពរបស់អាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ឆ្នាំ២០១៥) |
| គណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) គោលការណ៍ណែនាំនៃប្រកាន់យកយេនឌ័រសម្រាប់ឆ្លើយតបទៅនឹងជនរងគ្រោះនៃការជួញដូរមនុស្សជាស្ត្រី (ឆ្នាំ២០១៦) |
| ការសម្រេចជាឯកច្ឆ័ន្ទរបស់អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ឆ្នាំ២០១៧) |

# ច្បាប់ប្រឆាំងការជួញដូរថ្នាក់ជាតិ

| | |
|---|---|
| ប្រ៊ុយណេ | *បទបញ្ជាស្តីពីការជួញដូរ និងការរត់ពន្ធមនុស្ស (ឆ្នាំ២០០៤)* [ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់ប្រ៊ុយណេ"] |
| កម្ពុជា | ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់កម្ពុជា"] |
| ឥណ្ឌូនេស៊ី | ច្បាប់លេខ ២១ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្សរបស់សាធារណរដ្ឋឥណ្ឌូនេស៊ី (ឆ្នាំ២០០៧) [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់ឥណ្ឌូនេស៊ី] |
| ឡាវ | ក្រមព្រហ្មទណ្ឌ (វិសោធនកម្មឆ្នាំ២០០៦) ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារស្ត្រី (ឆ្នាំ២០០៤) ច្បាប់ស្តីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ (ឆ្នាំ២០០៦) ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៥) [លិខិតូបករណ៍ចុងក្រោយក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្សឆ្នាំ២០១៥ របស់ឡាវ"] |
| ម៉ាឡេស៊ី | ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧) [ច្បាប់លេខ ៦៧០] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (វិសោធនកម្ម) (ឆ្នាំ២០១៥) [ច្បាប់លេខ A1500] [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់ម៉ាឡេស៊ី"] |
| មីយ៉ាន់ម៉ា | *ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៥)* [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្សរបស់មីយ៉ាន់ម៉ា"] |
| ហ្វីលីពីន | ច្បាប់សាធារណរដ្ឋលេខ ៩២០៨ ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៣<br>ច្បាប់សាធារណរដ្ឋលេខ ១០៣៦៤ ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សបន្ថែមឆ្នាំ២០១២ [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់ហ្វីលីពីន"] |
| សិង្ហបុរី | *ច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស (ឆ្នាំ២០១៤)* [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្ស របស់សិង្ហបុរី"] |
| ប្រទេសថៃ | ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥) [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះរួមគ្នាជា "ច្បាប់ជួញដូរមនុស្ស របស់ថៃ"] |
| វៀតណាម | *ច្បាប់ស្តីពីការទប់ស្កាត់ និងការបង្ក្រាបប្រឆាំងនឹងការជួញដូរមនុស្ស (ឆ្នាំ២០១១)* [ក៏ត្រូវបានយោងនៅក្នុងរបាយការណ៍នេះថាជា "ច្បាប់ជួញដូរមនុស្សរបស់វៀតណាម"] និង "LPSAHT"] |

# តារាង និងប្រអប់អត្ថបទ

## តារាង


ជំពូកទី ១៖ តារាង ១៖ គោលដៅសំខាន់ៗរបស់អាស៊ានពាក់ព័ន្ធនឹងការជួញដូរមនុស្ស

ជំពូកទី ១៖ តារាង ២៖ ACTIP - បទប្បញ្ញត្តិសំខាន់/កាតព្វកិច្ចរបស់រដ្ឋភាគី

ជំពូកទី ១៖ តារាង ៣៖ ការផ្តល់សច្ចាប័នទៅលើ UNTOC ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និងអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស

ជំពូកទី ១៖ តារាង ៤៖ បទប្បញ្ញត្តិច្បាប់ស្តីពីវិធានការពិសេសនៃការការពារ និងការគាំទ្រដល់កុមាររងគ្រោះនៃការជួញដូរ

ជំពូកទី ១៖ តារាង ៥៖ បទប្បញ្ញត្តិច្បាប់នៃសិទ្ធិទទួលបានសំណង

ជំពូកទី ២៖ តារាង ៦៖ សេចក្តីសង្ខេបនៃការឆ្លើយតបបែបឯកទេសនៅក្នុងតំបន់អាស៊ាន

ជំពូកទី ៥៖ តារាង ៧៖ វិធានការពិសេសសម្រាប់កុមាររងការជួញដូរ

ជំពូកទី ៥៖ តារាង ៨៖ ការការពារតាមផ្លូវច្បាប់ចំពោះឯកជនភាពរបស់ជនរងគ្រោះជាសាក្សី

ជំពូកទី ៧៖ តារាង ៩៖ ACTIP - បទប្បញ្ញត្តិសំខាន់/កាតព្វកិច្ចពាក់ព័ន្ធនឹងការធ្វើបត្យាប័ន

ជំពូកទី ៧៖ តារាង ១០៖ ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមករបស់រដ្ឋសមាជិកអាស៊ាន

ជំពូកទី ៧៖ តារាង ១១៖ ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមករបស់រដ្ឋសមាជិកអាស៊ានដើម្បីស្វែងរកទ្រព្យដែលបានពីបទល្មើស

ជំពូកទី ៧៖ តារាង ១២៖ រដ្ឋសមាជិកអាស៊ាន៖ ម៉ាទ្រីសនៃការរៀបចំធ្វើបត្យាប័នទ្វេភាគី

ជំពូកទី ៧៖ តារាង ១៣៖ ក្របខ័ណ្ឌគតិយុត្តិ៖ ច្បាប់ស្តីពីបត្យាប័នរបស់រដ្ឋសមាជិកអាស៊ាន

# ប្រអប់អត្ថបទ

ជំពូកទី ១៖ ប្រអប់អត្ថបទ ១៖ បទដ្ឋានស្ដីពីការមិនចោទប្រកាន់ចំពោះបទល្មើសនៅក្នុងអាស៊ាន

ជំពូកទី ១៖ ប្រអប់អត្ថបទ ២៖ ឧទាហរណ៍ពាក់ព័ន្ធនឹងការមិនចោទប្រកាន់ចំពោះបទល្មើស

ជំពូកទី ២៖ ប្រអប់អត្ថបទ ៣៖ ឧទាហរណ៍អនុវត្តន៍៖ ការធានានូវការផ្សព្វផ្សាយទូទាំងប្រទេស

ជំពូកទី ២៖ ប្រអប់អត្ថបទ ៤៖ ឧទាហរណ៍អនុវត្តន៍៖ ការផ្ដល់ធនធានដើម្បីកែលម្អគុណភាពនៃការស៊ើបអង្កេត

ជំពូកទី ២៖ ប្រអប់អត្ថបទ ៥៖ ឧទាហរណ៍អនុវត្តន៍៖ ការកែលម្អតុល្យភាពយេនឌ័រនៅក្នុងអង្គភាពឯកទេស

ជំពូកទី ២៖ ប្រអប់អត្ថបទ ៦៖ ឧទាហរណ៍អនុវត្តន៍៖ បទដ្ឋាននីតិវិធីប្រតិបត្តិសម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្សត្រូវបានប្រើប្រាស់ដើម្បីកែលម្អគុណភាពនៃការស៊ើបអង្កេតករណីជួញដូរមនុស្ស

ជំពូកទី ២៖ ប្រអប់អត្ថបទ ៧៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីនូវការបណ្ដុះបណ្ដាលដែលកែលម្អដល់ការបំពេញការងាររបស់អង្គភាពឯកទេស

ជំពូកទី ៣៖ ប្រអប់អត្ថបទ ៨៖ ឧទាហរណ៍អនុវត្តន៍៖ បទដ្ឋាននីតិវិធីប្រតិបត្តិសម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្សត្រូវបានប្រើប្រាស់ដើម្បីឆ្លើយតបការកែលម្អការមន្ត្រីអនុវត្តច្បាប់ជួរមុខ

ជំពូកទី ៣៖ ប្រអប់អត្ថបទ ៩៖ ឧទាហរណ៍អនុវត្តន៍៖ ការដោះស្រាយអំពើពុករលួយនៃការអនុវត្តន៍ច្បាប់ក្នុងការជួញដូរ

ជំពូកទី ៣៖ ប្រអប់អត្ថបទ ១០៖ ការប្រមូលព័ត៌មានសម្ងាត់ដោយភ្នាក់ងារការពារព្រំដែន

ជំពូកទី ៣៖ ប្រអប់អត្ថបទ ១១៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីនូវការបណ្ដុះបណ្ដាលមន្ត្រីនគរបាលការពារព្រំដែន

ជំពូកទី ៣៖ ប្រអប់អត្ថបទ ១២៖ គំនិតផ្ដួចផ្ដើមការបណ្ដុះបណ្ដាលមន្ត្រីអនុវត្តច្បាប់ជួរមុខនៅប្រទេសហ្វីលីពីន

ជំពូកទី ៤៖ ប្រអប់អត្ថបទ ១៣៖ សមិទ្ធផលសំខាន់ៗរបស់អាស៊ានពាក់ព័ន្ធនឹងការឆ្លើយតបរបស់ស្ថាប័នតុលាការ និងស្ថាប័នអយ្យការទៅនឹងការជួញដូរ

ជំពូកទី ៤៖ ប្រអប់អត្ថបទ ១៤៖ មុខងារអយ្យការឯកទេសនៅប្រទេសថៃ

ជំពូកទី ៤៖ ប្រអប់អត្ថបទ ១៥៖ ការបដិសេធន៍ការដោះស្រាយក្រៅផ្លូវការនៅប្រទេសមីយ៉ាន់ម៉ា និងហ្វីលីពីន

ជំពូកទី ៤៖ ប្រអប់អត្ថបទ ១៦៖ ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះនៅប្រទេសថៃ

ជំពូកទី ៥៖ ប្រអប់អត្ថបទ ១៧៖ ការអនុវត្តន៍ឧត្តមប្រយោជន៍របស់កុមារនៅក្នុងបរិបទនៃការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ

ជំពូកទី ៥៖ ប្រអប់អត្ថបទ ១៨៖ គោលការណ៍ណែនាំរបស់ ACWC ស្ដីពីការប្រកាន់យកផ្នែកយេនឌ័រ សម្រាប់ការកំណត់អត្តសញ្ញាណស្ត្រី និងកុមារីរងគ្រោះពីការជួញដូរមនុស្ស

ជំពូកទី ៥៖ ប្រអប់អត្ថបទ ១៩៖ គោលការណ៍ណែនាំរបស់អាស៊ាន/COMMIT ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ និងការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ

ជំពូកទី ៥៖ ប្រអប់អត្ថបទ ២០៖ ការការពារ និងការគាំទ្រដល់កុមាររងការជួញដូរ

ជំពូកទី ៥៖ ប្រអប់អត្ថបទ ២១៖ ការការពារជនរងគ្រោះក្នុងផែនការសកម្មភាពអាស៊ាន

ជំពូកទី ៥៖ ប្រអប់អត្ថបទ ២២៖ ការការពារ និងការគាំទ្រជនរងគ្រោះក្រោមគោលការណ៍ណែនាំរបស់ ACWC

ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៣៖ ឧទាហរណ៍អនុវត្តន៍៖ ការធានានូវសិទ្ធិរបស់ជនរងគ្រោះក្នុងការបង្ហាញវត្តមាន និងការបញ្ចេញទស្សនៈរបស់ពួកគេ

ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៤៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីក្នុងការការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សី

ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៥៖ ឧទាហរណ៍អនុវត្តន៍៖ ការការពារជនរងគ្រោះជាសាក្សីពីការគំរាមកំហែង និងការសងសឹក
ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៦៖ ឧទាហរណ៍អនុវត្តន៍៖ ការការពារសាក្សីជាកុមារនៅក្នុងតុលាការ ក្នុងសំណុំរឿងជួញដូរមនុស្ស
ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៧៖ ឧទាហរណ៍អនុវត្តន៍៖ ការប្រើប្រាស់វិធានការបង្កើតថ្មីដើម្បីជួយជនរងគ្រោះជាសាក្សីនៅក្នុងតុលាការ
ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៨៖ ឧទាហរណ៍អនុវត្តន៍៖ ការពន្លឿនការជំនុំជម្រះសំណុំរឿងជួញដូរមនុស្ស
ជំពូកទី ៦៖ ប្រអប់អត្ថបទ ២៩៖ ឧបសគ្គទូទៅចំពោះការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនរងគ្រោះក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ច
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣០៖ ការធ្វើការសម្រេចចិត្ត ថាតើត្រូវបន្តកិច្ចសហប្រតិបត្តិការច្បាប់អន្តរជាតិដោយរបៀបណា
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣១៖ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស៖ បទប្បញ្ញត្តិស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣២៖ ឧទាហរណ៍អនុវត្តន៍៖ ការប្រឈមនៃនិរន្តរភាពក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្សឆ្លងដែន
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣៣៖ ឧទាហរណ៍អនុវត្តន៍៖ វិធីសាស្ត្រដែល HSU យកមកប្រើប្រាស់ដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការដំណើរការការងារ
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣៤៖ ឧទាហរណ៍អនុវត្តន៍៖ កិច្ចសហប្រតិបត្តិការ និងការចែករំលែកទិន្នន័យ
ជំពូកទី ៧៖ ប្រអប់អត្ថបទ ៣៥៖ ឧទាហរណ៍អនុវត្តន៍៖ ការប្រើប្រាស់ជំនួយទៅវិញទៅមកក្នុងសំណុំរឿងជួញដូរមនុស្ស

# អក្សរកាត់ និងបង្រួមពាក្យ

| | |
|---|---|
| AAPTIP | កម្មវិធីអូស្ត្រាលី-អាស៊ីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស |
| ACTIP | អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ |
| ACWC | គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ |
| AMS | រដ្ឋសមាជិកអាស៊ាន |
| ARTIP | កម្មវិធីប្រឆាំងការជួញដូរមនុស្សនៅតំបន់អាស៊ី (គម្រោង) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ASEANAPOL | ប្រធាននគរបាលអាស៊ាន |
| ASEAN MLAT | សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានឆន្ទៈដូចគ្នា |
| គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិ អាស៊ាន | គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន ស្តីពីការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស |
| អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស | អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| HSU | ប្រធានអង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស |
| IOM | អង្គការអន្តរជាតិទេសន្តរប្រវេសន៍ |
| INTERPOL | ស្ថាប័ននគរបាលព្រហ្មទណ្ឌអន្តរជាតិ |
| ILO | អង្គការអន្តរជាតិខាងការងារ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| SOMTC | កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន [អាស៊ាន] |
| TIP | ការជួញដូរមនុស្ស |
| UN | អង្គការសហប្រជាជាតិ |
| UNODC | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម |
| UNTOC | អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង |

| | |
|---|---|
| គោលការណ៍ និងសេចក្ដីណែនាំរបស់ អ.ស.ប ស្ដីពីការជួញដូរ | គោលការណ៍ និងគោលការណ៍ណែនាំដែលផ្ដល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស |
| ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | ពិធីសារបង្ក្រាប ទប់ស្កាត់ និងផ្ដន្ទាទោសការជួញដូរមនុស្ស ជាពិសេសលើ ស្ដ្រី និងកុមារ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង |

# សេចក្តីសង្ខេបប្រតិបត្តិ

*របាយការណ៍វឌ្ឍនភាពអាស៊ានស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ទៅនឹងការជួញដូរមនុស្ស* ត្រូវបានបោះពុម្ពផ្សាយលើកដំបូងនៅឆ្នាំ២០១១ បន្ទាប់ពីមានសំណើពីកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC)។ ការកែសម្រួលលើកទីពីរចំពោះ *របាយការណ៍វឌ្ឍនភាព* នេះមានគោលបំណងតាមឲ្យទាន់នូវការវិវត្តន៍ចាប់តាំងពីពេលនោះមក គឺ៖ ការធ្វើបច្ចុប្បន្នភាព និងការពង្រីកព័ត៌មានដែលបានផ្តល់ជូននៅក្នុងសំណៅដើម ដើម្បីផ្តល់ការវាយតម្លៃឲ្យទាន់ពេលវេលាទៅលើអ្វីដែលសម្រេចបាន និងការប្រឈមដែលនៅមាន។

របាយការណ៍នេះបែងចែកជា ៧ ជំពូក៖ ជំពូកនីមួយៗពិនិត្យទៅលើទិដ្ឋភាព ឬសមាសធាតុមួយនៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរ។ ជំពូកនីមួយៗចាប់ផ្តើមដោយមានការពិនិត្យសង្ខេបទៅលើបទដ្ឋានពាក់ព័ន្ធដែលបានលើកឡើងតាមរយៈការរួមបញ្ចូលគ្នា នូវច្បាប់ និងគោលនយោបាយនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ព្រមទាំងឧត្តមានុវត្តន៍ដែលត្រូវបានទទួលយក។ មានការផ្តល់អាទិភាពចំពោះបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុង *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ* ដែលជាប្រភពចម្បងនៃសិទ្ធិ និងកាតព្វកិច្ចសម្រាប់បណ្តាប្រទេសនៅក្នុងតំបន់នេះ។ ជំពូកនីមួយៗក៏ផ្តល់នូវទិដ្ឋភាពនៃវឌ្ឍនភាពនៅក្នុងតំបន់អាស៊ានទាំងមូល ឆ្ពោះទៅការអនុវត្តន៍ជាក់ស្តែងនូវបទដ្ឋានទាំងនោះ ដោយមានលើកឧទាហរណ៍មកពន្យល់ផងដែរ។ ផ្នែកចុងក្រោយនៃជំពូកនីមួយៗធ្វើការសង្ខេបអំពីឧបសគ្គធំៗ និងកាលានុវត្តភាពនានាឆ្ពោះទៅការអនុវត្តន៍ជាក់ស្តែងយ៉ាងមានប្រសិទ្ធភាពនូវសមាសធាតុពាក់ព័ន្ធ។ រាល់ជំពូកទាំងអស់នៃរបាយការណ៍នេះ ត្រូវបានបញ្ចប់ដោយឧបសម្ព័ន្ធមួយ ដែលរៀបរាប់អំពីបទដ្ឋានពាក់ព័ន្ធនៅក្នុងទម្រង់ជាតារាង (“បទដ្ឋានគុណភាព”)។

របាយការណ៍នេះក៏បានបញ្ជាក់ថា មានដំណើរការវឌ្ឍនភាពធំធេងនៅក្នុងតំបន់អាស៊ាន នៅក្នុងវិស័យនៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ ការរកឃើញជាសំខាន់ៗនៅក្នុងសមាសធាតុនីមួយៗដែលត្រូវបានកំណត់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលអាចសង្ខេបបានដូចខាងក្រោម៖

**ទាក់ទងនឹងការបង្កើតច្បាប់៖** នៅក្នុងសហគមន៍អន្តរជាតិបានទទួលស្គាល់ថា ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ គឺជាសមាសធាតុដ៏សំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស (TIP)។ នាពេលបច្ចុប្បន្ននេះ រដ្ឋសមាជិកអាស៊ានទាំងអស់មានក្របខ័ណ្ឌគតិយុត្តិរឹងមាំដើម្បីកំណត់ជាបទល្មើសនូវការជួញដូរ ការពារជនរងគ្រោះ និងទប់ស្កាត់នូវការជួញដូរនាពេលអនាគត។ ជាការពិត នៅក្នុងការងារជួញដូរនេះតែម្តងដែលមានវឌ្ឍនភាពគួរអោយកត់សម្គាល់ ដែលជាចំណុចមួយ ដែលបច្ចុប្បន្ននេះនៅតែមានចន្លោះប្រហោងនៃការអនុវត្តន៍ច្បាប់ និងគោលនយោបាយ។ ជាទូទៅ ច្បាប់ជាតិឆ្លុះបញ្ចាំងពីច្បាប់ និងគោលនយោបាយអន្តរជាតិ និងតំបន់ រួមទាំងបទប្បញ្ញត្តិស្នូលនៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការជួញដូរ*។ ចំណុចនេះធានាបាននូវភាពស៊ីចង្វាក់ផ្នែកនីតិកម្មរវាងរដ្ឋសមាជិកអាស៊ាន (AMS)។ រដ្ឋសមាជិកអាស៊ានភាគច្រើនចាប់ផ្តើមបញ្ចូលច្បាប់ផ្សេងទៀត (ឧទា. ច្បាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិ និងបទដ្ឋានការងារ) នៅក្នុងក្របខ័ណ្ឌគតិយុត្តិកាន់តែទូលាយជុំវិញការជួញដូរ។

ទោះជាយ៉ាងណាក្តី វឌ្ឍនភាពពុំមានភាពស្របគ្នាទេនៅក្នុងតំបន់ ហើយនៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើនមានកាលានុវត្តភាពក្នុងការកែទម្រង់បន្ថែមទៀតទៅលើក្របខ័ណ្ឌផ្នែកនីតិកម្ម ឧទាហរណ៍ ពាក់ព័ន្ធនឹង៖ ការបញ្ជាក់បំភ្លឺនូវទិដ្ឋភាពនានានៃការកំណត់និយមន័យនៃការជួញដូរមនុស្ស ការកំណត់ជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នាចំពោះបទល្មើសដែលពាក់ព័ន្ធដូចជាការងារដោយបង្ខំ ការបញ្ជាក់ច្បាស់នូវសិទ្ធិរបស់ជនរងគ្រោះ រួមទាំងសិទ្ធិរបស់ពួកគេក្នុងការមិនត្រូវបានឃុំខ្លួន ឬចោទប្រកាន់ចំពោះបទល្មើស និង ការបញ្ជាក់នូវសិទ្ធិរបស់កុមាររងគ្រោះក្នុងការទទួលបានការការពារបន្ថែម។ ហើយក៏អាចតម្រូវឲ្យមានការពិនិត្យឡើងវិញនូវការដាក់ទណ្ឌកម្មដែរ ដើម្បីធានាថា ការផ្តន្ទាទោសដែលបានកំណត់ ផ្តល់នូវភាពបត់បែនដល់តុលាការក្នុងការផ្តន្ទាទោសឲ្យបានសមស្រប។

**ទាក់ទងនឹងសមត្ថភាពឯកទេសស៊ើបអង្កេត៖** បទពិសោធន៍នៅក្នុងតំបន់ទាំងអស់បានបញ្ជាក់ថាការជួញដូរមនុស្សគឺជាបទល្មើសស្មុគស្មាញក្នុងការស៊ើបអង្កេត ដោយតម្រូវឲ្យមានអ្នកស៊ើបអង្កេតអនុវត្តន៍ច្បាប់ដែលទទួលការបណ្តុះបណ្តាលកម្រិតខ្ពស់ និងមានការលើកទឹកចិត្ត និងទទួលបានការគាំទ្រពីអាជ្ញាធរសមស្រប និងធនធានគ្រប់គ្រាន់។ ចំពោះមូលហេតុនេះ សមត្ថភាពអនុវត្តន៍ច្បាប់ឯកទេសក្នុងការស៊ើបអង្កេតទៅលើការជួញដូរ គឺជាសមាសធាតុសំខាន់នៃការឆ្លើយតបយ៉ាងរឹងមាំ និងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្ស។ ភាពឯកទេសនៃការស៊ើបអង្កេតដែលឆ្លើយតបទៅនឹងបទល្មើសជួញដូរ ត្រូវបានបង្ហាញយ៉ាងច្បាស នៅទូទាំងតំបន់អាស៊ាន ហើយនាពេលនេះមានការទទួលស្គាល់យ៉ាងទូលំទូលាយអំពីសារៈសំខាន់ របស់វា ក្នុងចំណោមរដ្ឋសមាជិកអាស៊ានទាំងអស់។ នៅក្នុងវិស័យនេះ អាស៊ានបានបោះជំហានបន្ថែមទៀត និងលឿនជាងតំបន់ផ្សេងៗទៀតនៅទូទាំងពិភពលោក ក្នុងការទទួលស្គាល់នូវផលប្រយោជន៍ដែលទទួលបានពីភាពឯកទេស ហើយរដ្ឋសមាជិកអាស៊ានបានអនុម័តនូវគោលការណ៍នៃភាពឯកទេសនៅក្នុងការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់ទៅនឹងការជួញដូរ។ ដំណើរការប្រធានអង្គភាពឯកទេសការជួញដូរអាស៊ាន (HSU) នៅតែជាយន្តការថ្នាក់តំបន់តែមួយនៃភាពឯកទេសនេះ។

ទោះបីវឌ្ឍនភាពបានឈានមកដល់កម្រិតនេះក៏ដោយ តែនៅតែមានការប្រឈមនានា ដូចជាផ្នែករចនាសម្ព័ន្ធ និងផ្នែកប្រតិបត្តិការងារដដែល។ ក្នុងនោះ រដ្ឋសមាជិកអាស៊ានមួយចំនួន មានភាពទន់ខ្សោយ ទាក់ទងនិងអំណាច រចនាសម្ព័ន្ធ និងការផ្តល់ថវិកា នេះមានន័យថា អង្គភាពនានាមិនបានផ្តល់នូវការឆ្លើយតបដែលចាំបាច់លើករណីដែលកើតឡើង។ ប៉ុន្តែអង្គភាពឯកទេសមួយចំនួនតូចអាចរក្សាបាននូវ ក្រុមអ្នកស៊ើបអង្កេតដែលទទួលការបណ្តុះបណ្តាលពេញលេញ ដែលជាចំណុចមានឥទ្ធិពលទៅលើសមត្ថភាពរបស់ពួកគេ។ ជាងនេះទៀត ក្នុងតំបន់នេះទាំងមូល ទោះបីមានការបង្ហាញថា មានភាពជំនាញលើការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរកាន់តែច្រើន និងមានភាពប្រសើរឡើងក៏ដោយ តែចំណុចនេះវាមិនស៊ីចង្វាក់គ្នាទាំងអស់ទេ។ គុណភាពនៃការស៊ើបអង្កេតរបស់រដ្ឋសមាជិកអាស៊ានមួយចំនួន ត្រូវទទួលរងដោយកត្តាមួយចំនួន ដូចជា ភាពទន់ខ្សោយក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការមិនយកចិត្តទុកដាក់ពេញលេញលើសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ការប្រើប្រាស់ បច្ចេកទេសនៃការស៊ើបអង្កេតមុនពេលកើតហេតុតិចតួច ការមិនផ្តល់អាទិភាពផ្នែកហិរញ្ញវត្ថុ ដល់ការស៊ើបអង្កេត ការមិនមានឆន្ទៈប្រឈមនិងស៊ើបអង្កេតទៅលើករណីដែលអាចមានអំពើពុករលួយ ការទទួលយកដំណោះស្រាយ "ក្រៅផ្លូវការ" ចំពោះបណ្តឹងពីការជួញដូរ ការផ្តល់នូវតួនាទីមិនសមស្របដល់អង្គការក្រៅរដ្ឋាភិបាល និង ការប្រើប្រាស់មិនពេញលេញនូវសមត្ថភាពនៃការស៊ើបអង្កេតឆ្លងដែន។

- **ទាក់ទងនឹងសមត្ថភាពអនុវត្តន៍ច្បាប់របស់មន្ត្រីនគរបាលការពារព្រំដែន៖** ជាគោលការណ៍ “ការអនុវត្តន៍ច្បាប់ជួរមុខ” សំដៅលើភ្នាក់ងារ ឬមន្ត្រីនគរបាលមិនមែនជាអ្នកជំនាញ ដែលអាចជួបប្រទះ និង/ឬ ត្រូវបានអំពាវនាវឱ្យឆ្លើយតបនឹងករណីជួញដូរក្នុងអំឡុងពេលនៃកាតព្វកិច្ចធម្មតារបស់ពួកគេ។ ពួកគេទាំងនោះរួមមានភ្នាក់ងារ និងមន្ត្រីនៅតាមព្រំដែន និងផ្នែកអន្តោប្រវេសន៍ ហើយ ក៏អាចរាប់បញ្ចូលទាំងភ្នាក់ងារ និងមន្ត្រីដែលទទួលបន្ទុកឃ្លាំមើលការអនុវត្តន៍នានានៅក្នុងវិស័យឧស្សាហកម្ម និងវិស័យផ្សេងៗទៀតដែរ។ ភ្នាក់ងារ និងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខមានសារៈសំខាន់ ចំពោះប្រសិទ្ធភាពនៃការឆ្លើយតបជារួមទៅនឹងបទល្មើសជួញដូរ ដោយដើរតួនាទី ចម្បងក្នុងការកំណត់អត្តសញ្ញាណបទល្មើស និងផ្តល់ការឆ្លើយតបបឋមឲ្យបានពេញលេញ។ ទោះបីមានការលំបាកក្នុងការវាយតម្លៃពីការបំពេញការងារ ក្នុងចំណោមភ្នាក់ងារទាំងនោះក៏ដោយ តែរបាយការណ៍នេះនៅតែអាចផ្តល់ការសង្កេតបឋមមួយចំនួនផងដែរ ឧទាហរណ៍ របាយការណ៍នេះកត់សម្គាល់ថា អត្រានៃការកំណត់អត្តសញ្ញាណជនរងគ្រោះបានប្រសើរឡើង ដោយសារមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខមានការកើនឡើងនូវការយល់ដឹង ព្រមទាំងការកែលម្អសមត្ថភាពក្នុងការឆ្លើយតបទៅនឹងបទល្មើសប្រភេទនេះ។ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន មានការបង្ហាញមួយចំនួនអំពីភាពស៊ីចង្វាក់គ្នានៃកិច្ចសហប្រតិបត្តិការរវាងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ និងអ្នកផ្តល់សេវា ដែលជាលទ្ធផលបណ្តាលឲ្យមានការផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗដល់ជនរងគ្រោះកាន់តែប្រសើរឡើង។
- ប៉ុន្តែការរីកចម្រើននៅតែមិនស្មើគ្នាទេ ។ ឧទាហរណ៍ ទោះបីការធ្វើវិភាគទៅលើសំណុំរឿងបញ្ជាក់ថាទីភ្នាក់ងារអនុវត្តន៍ច្បាប់ពិតជាកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរក៏ដោយ តែពួកគេក៏បានកំណត់អត្តសញ្ញាណមិនត្រឹមត្រូវនូវសំណុំរឿងមិនមែនជួញដូរមួយចំនួនដែរ ដែលបង្កឲ្យមានភាពអយុត្តិធម៌ធ្ងន់ធ្ងរ។ កាន់តែធ្ងន់ធ្ងរជាងនេះទៀត អត្រានៃការកំណត់អត្តសញ្ញាណ និងការយល់ដឹង និងការស៊ើបអង្កេតឆ្លើយតបបឋម នៅមានភាពទន់ខ្សោយនៅឡើយ ដោយសារសមត្ថភាព ភ្នាក់ងារអនុវត្តន៍ច្បាប់ជួរមុខ នៅមានកម្រិត ព្រមទាំងឥរិយាបថអវិជ្ជមានចំពោះពលករទេសន្តរប្រវេសន៍ជាដើម ហើយក៏មានបញ្ហាផ្សេងៗជុំវិញការគ្រប់គ្រង និងការធ្វើផែនការផងដែរ។ ឧទាហរណ៍ ការប្រើប្រាស់នីតិវិធីប្រតិបត្តិការទៅតាមបទដ្ឋាន ដើម្បីលើកកម្ពស់នូវការឆ្លើយតបរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខឲ្យបានកាន់តែប្រសើរ និងស៊ីចង្វាក់នៅមានកម្រិតទាបនៅក្នុងតំបន់ទាំងមូល ហើយនៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ជារឿយៗពុំមានភាពច្បាស់លាស់នៅក្នុងទំនាក់ទំនងរវាងការឆ្លើយតបឯកទេសទេ ដែលបង្កឲ្យមានការប្រើប្រាស់មិនពេញលេញនូវសមត្ថភាពជំនាញ។ ផ្ទុយទៅវិញ សក្តានុពលរបស់ភ្នាក់ងារមន្ត្រីអនុវត្តច្បាប់ជួរមុខក្នុងការចែករំលែកនូវការប្រមូលព័ត៌មានសម្ងាត់ជាប្រចាំ មិនត្រូវបានទទួលស្គាល់ទេ។
- **ទាក់ទងនឹងសមត្ថភាពផ្នែកអយ្យការ និងផ្នែកតុលាការ៖** ចំពោះភ្នាក់ងារអនុវត្តន៍ច្បាប់ទោះបីជាឯកទេស ឬមន្ត្រីអនុវត្តច្បាប់ជួរមុខ មានការទទួលខុសត្រូវ ជាចម្បងក្នុងការស៊ើបអង្កេតបឋមទៅលើសំណុំរឿងជួញដូរក៏ដោយ ប៉ុន្តែស្ថាប័នអយ្យការ និងស្ថាប័នតុលាការថ្នាក់ជាតិមានតួនាទីសំខាន់ក្នុងការធានា លើការងាររបស់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការធានាថាការងារត្រូវបានអនុវត្តតាមច្បាប់ ហើយការអនុវត្តមិនត្រូវបានធ្វេសប្រហែស ឬខ្ជះខ្ជាយឡើយ។ រដ្ឋសមាជិកអាស៊ានទាំងអស់បានទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់ចៅក្រម និងព្រះរាជអាជ្ញា ហើយបានគាំទ្រដល់សកម្មភាពបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗទៀត ដែលជាលទ្ធផលនាំឲ្យមានការបង្កើតសមត្ថភាពនៅក្នុងតំបន់ ជាពិសេសពាក់ព័ន្ធនឹងការឆ្លើយតបជាមួយជនរងគ្រោះ ដើម្បីគាំទ្រដល់សុវត្ថិភាពរបស់ពួកគេក្នុងការចូលរួមដំណើរការ និងលទ្ធផលនៃការ

ជំនុំជម្រះរឿងក្ដី។ ក្នុងនោះក៏មានភាពរីកចម្រើនមួយចំនួនផងដែរ ពាក់ព័ន្ធនឹងឯកទេសភាព របស់មុខងារអយ្យការ (និង ផ្នែកតុលាការតិចតួច)។ ហើយទោះបីកិច្ចសហប្រតិបត្តិការរវាងព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតនៅតែមិនស៊ីចង្វាក់គ្នាយ៉ាងណាក៏ដោយ ក៏មានការបង្ហាញពីការកើនឡើងនូវការទទួលយកសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការទាំងនេះ ក្នុងការនាំយកសំណុំរឿងធំៗមកជំនុំជម្រះផងដែរ។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន មានការរីកចម្រើនគួរឲ្យកត់សម្គាល់លើការរៀបចំជនរងគ្រោះ មុនការជំនុំជម្រះ (រួមទាំង តាមរយៈការប្រើប្រាស់សក្ខីកម្មមុនពេលជំនុំជម្រះ) ព្រមទាំង នៅក្នុងការប្រើប្រាស់ការការពារក្នុងតុលាការ ក្នុងគោលបំណងកាត់បន្ថយឥទ្ធិពលអវិជ្ជមាន នៃការផ្ដល់សក្ខីកម្ម។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួនទៀត មានការរីកចម្រើនមួយជំហានទៀត ក្នុងការសម្រួលដល់ដំណើរការជំនុំជម្រះ។

របាយការណ៍នេះបញ្ជាក់ថា ទោះបីមានការបោះជំហានសំខាន់ៗមួយចំនួនឆ្ពោះលើការអភិវឌ្ឍន៍សមត្ថភាពយ៉ាងមានប្រសិទ្ធភាពនៅថ្នាក់ជាតិ ក្នុងការចោទប្រកាន់ និងវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរមនុស្សក៏ដោយ តែនៅមានការប្រឈមធ្ងន់ធ្ងរផ្សេងៗទៀតនៅឡើយ។ ឧទាហរណ៍ កិច្ចសហប្រតិបត្តិការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញានៅមានកម្រិតតិចតួចនៅឡើយ ក្នុងសំណុំរឿងជួញដូរមនុស្ស។ ចំណុចទាំងនេះ គឺដោយសារការប្រមូលភស្តុតាងមិនបានពេញលេញ មិនមានចំនេះដឹងល្អក្នុងវិធីសាស្ត្រស៊ើបអង្កេត ការចាប់ខ្លួនលឿនពេក ការដោះស្រាយជនរងគ្រោះមិនបានល្អ ការស្ដាប់ចម្លើយជនរងគ្រោះជាជនរងគ្រោះជាសាក្សី និងការរៀបចំចម្លើយសាក្សី មិនបានល្អ ការស៊ើបអង្កេតដែលពន្យារពេល ឬមិនគ្រប់ជ្រុងជ្រោយ និងការមិនទុកចិត្តគ្នា និងមិនគោរពគ្នា ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងមានការរៀបចំត្រឹមត្រូវនៃផ្នែកអនុវត្តន៍ច្បាប់ទៅនឹងការជួញដូរ។ ការគ្រប់គ្រងជនរងគ្រោះជាសាក្សីជា តែជាបញ្ហា (សូមមើលខាងក្រោម) និងការអូសបន្លាយកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់នៅតែជាបទដ្ឋាននៅទូទាំងតំបន់ទាំងមូល។ ជានិច្ចកាល ព្រះរាជអាជ្ញា និងចៅក្រមមិនបានចូលរួមធ្វើការវិភាគអង្គច្បាប់ និងអង្គហេតុដោយប្រុងប្រយ័ត្នទេ ចំណុចនេះនៅតែជាបញ្ហា ព្រោះវាចាំបាច់ដើម្បីធ្វើឲ្យមានយុត្តិធម៌។ ជាពិសេសនៅពេលដែលដំណើរការស៊ើបអង្កេតមានភាពទន់ខ្សោយ។

**ទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការផ្ដល់ការការពារ និងការគាំទ្រភ្លាមៗដល់ជនរងគ្រោះ៖** ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្ស តម្រូវឲ្យមានការកំណត់អត្តសញ្ញាណបឋមឲ្យបានរហ័ស និងត្រឹមត្រូវនូវបុគ្គលដែលត្រូវបានសន្មតថាជាជនរងគ្រោះ ការកំណត់អត្តសញ្ញាណផ្លូវការចំពោះជនរងគ្រោះដែលមានការបញ្ជាក់ ព្រមទាំងការផ្ដល់ការការពារ និងការគាំទ្រភ្លាមៗ ដោយភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល។ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណនេះផងដែរ របាយការណ៍បញ្ជាក់ថា មានការកើនឡើងខ្លាំង នូវចំនួនជនរងគ្រោះពីការជួញដូរដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងប្រទេសភាគច្រើននៅទូទាំងតំបន់អាស៊ាន។ ជាការសំខាន់ នាពេលនេះ អ្នកដែល*ត្រូវបាន*កំណត់អត្តសញ្ញាណថាបានទទួលរងការជួញដូរមានកាលានុវត្តភាពល្អជាងពីមុន ក្នុងការបញ្ជូនទៅសេវាគាំទ្រសមស្រប ដោយអាជ្ញាធរផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។ ពាក់ព័ន្ធនឹងការផ្ដល់ការការពារ និងការគាំទ្រជាក់ស្ដែង ភស្តុតាងមូលដ្ឋាន (ក្រៅពីច្បាប់ និងគោលនយោបាយ) នៅមានកម្រិតទាប។

ការប្រឈមពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅមានភាពធំធេងនៅឡើយ។ នៅក្នុងតំបន់នេះក៏ដូចជាតំបន់ទាំងអស់ផ្សេងទៀតដែរ ការកំណត់អត្តសញ្ញាណជនរងគ្រោះបានទាន់ពេលវេលា និងត្រឹមត្រូវនៅតែជារឿងកម្រដដែល។ ហើយនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន សំណុំរឿងដែលមិនបំពេញទៅតាមលក្ខណៈវិនិច្ឆ័យជា

ការជួញដូរតាមច្បាប់ជាតិ ឬអន្តរជាតិ (ជារឿយៗ សំណុំរឿងដែលពាក់ព័ន្ធនឹងអំពើពេស្យាចារ និងរៀបការដោយការរៀបចំ) ក៏ត្រូវបានស៊ើបអង្កេត និងចោទប្រកាន់ថាជាករណីជួញដូរមនុស្សផងដែរ។ កត្តាមួយចំនួន ដូចជា ការយល់ឃើញថាជាអំពើពុករលួយ និងអំពើសមគំនិតដែលធ្វើឲ្យជនរងគ្រោះមិនទុកចិត្ត និងរារែកក្នុងការបញ្ចេញអត្តសញ្ញាណរបស់ខ្លួន នឹងតម្រូវឲ្យមានវិធានការសម្រាប់ពេលវែង ក្នុងគោលបំណងកែលម្អ លើភាពទុកចិត្តបាន និងការអនុវត្តន៏ប្រកបដោយវិជ្ជាជីវៈរបស់ភ្នាក់ងារអនុវត្តន៍ច្បាប់។ ការដឹកនាំមិនល្អ និងឥរិយាបថមិនជួយដល់ក្រុមជនងាយរងគ្រោះ រួមមាន ពលកររទេសន្តរប្រវេសន៍ និងស្ត្រី ក៏ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការខកខានមិនបានកំណត់អត្តសញ្ញាណដែរ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរជាប្រព័ន្ធ និងស៊ីជម្រៅ។ ហើយក្នុងការអនុវត្តន៍នូវដំណោះស្រាយក្រៅផ្លូវការចំពោះ “បណ្តឹង” ស្តីពីការជួញដូរ ដែលធ្វើឲ្យអត្រានៃការកំណត់អត្តសញ្ញាណជនរងគ្រោះនៅមានកម្រិតទាប នឹងតម្រូវឲ្យមានកំណែទម្រង់ស្រដៀងគ្នាដែរនៅក្នុងវប្បធម៌ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ កត្តាផ្សេងទៀត ដូចជា កង្វះការយល់ដឹងក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ជួរមុខក៏អាច និងគួរតែដោះស្រាយបានកាន់តែងាយស្រួលដែរ រួមមាន តាមរយៈការអភិវឌ្ឍន៍សមត្ថភាព និងការអនុវត្តន៍នូវលក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណតែមួយដូចៗគ្នា។

ទោះបីមានការកែលម្អជាដុំកំភួន ក្នុងការការពារដល់សិទ្ធិជនរងគ្រោះតាមផ្លូវច្បាប់យ៉ាងណាក៏ដោយ តែមានភស្តុតាងតិចតួចដែលថា ចំណុចនេះត្រូវបានប្រែក្លាយទៅជាឧត្តមានុវត្តន៍។ និយាយឲ្យងាយយល់គឺថា៖ មានគម្លាតយ៉ាងធំធេងរវាងសិទ្ធិទទួលបានការការពារ និងជំនួយដែលផ្តល់ដល់ជនរងគ្រោះពីការជួញដូរ និង ការការពារ និងជំនួយជាក់ស្តែងដែលពួកគេទទួលបាន។ ការប្រឈមមួយចំនួន (ឧទា. ផ្នែកសមត្ថភាពនៅមានកម្រិត និងផ្នែកនីតិកម្មនៅមានភាពខ្វះខាត) ដែលមិនអាចត្រូវបានដោះស្រាយដោយផ្ទាល់ពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទេហើយក៏មានកត្តាប្រឈមផ្សេងទៀត (ឧទា. ការគាំទ្រដល់កិច្ចសហប្រតិបត្តិការ បរាជ័យក្នុងការបញ្ជូនជនរងគ្រោះ និងបុគ្គលដែលអាចជាជនរងគ្រោះ បរាជ័យក្នុងការរក្សាការសម្ងាត់ជូនជនរងគ្រោះការមិនគាំទ្រដល់ការទទួលបានសំណងជាផ្លូវការ) ស្ថិតក្នុងអំណាចរបស់មន្ត្រី និងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវដោះស្រាយ។

- **ទាក់ទងនឹងការគាំទ្រជាពិសេសដល់ជនរងគ្រោះជាសាក្សី៖** បុគ្គលដែលទទួលរងការជួញដូរ មានតួនាទីសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ប្រឆាំងនឹងជនកេងប្រវ័ញ្ចលើពួកគេ៖ ជាធម្មតាការស៊ើបអង្កេត និងការចោទប្រកាន់មានការលំបាក ហើយជួនកាលមិនអាចធ្វើបានផង ដោយពុំមានកិច្ចសហប្រតិបត្តិការ និងសក្ខីកម្មរបស់ជនរងគ្រោះ។ ហេតុនេះគួរមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធានាថា ពួកគេអាចចូលរួមបានដោយមិនមានការបង្ខិតបង្ខំ មានសុវត្ថិភាព និងផ្អែកលើព័ត៌មានពេញលេញ។ របាយការណ៍នេះបញ្ជាក់ថា មានការវិវត្តន៏ធំធេងពាក់ព័ន្ធនឹងច្បាប់ និងគោលនយោបាយ ក្នុងគោលបំណងគាំទ្រដល់ជនរងគ្រោះដែលមានតួនាទីជាសាក្សី។ ឧទាហរណ៍ នាពេលនេះ រដ្ឋសមាជិកអាស៊ានភាគច្រើនផ្តល់នូវការការពារនៃឯកជនភាពតាមផ្នែកនីតិកម្ម ដែលរឹងមាំដល់ជនរងគ្រោះជាសាក្សី ហើយភាគច្រើនក៏បានបង្កើតជាច្បាប់នូវសិទ្ធិទទួលបានការការពារពីការគំរាមកំហែងចំពោះសុវត្ថិភាពផ្លូវកាយ របស់ជន រងគ្រោះ ដោយសារសងសឹក ឬការបំភិតបំភ័យ។ បច្ចុប្បន្ននេះ ជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់ (រួមមានសក្ខីកម្មមុនការជំនុំជម្រះ) អាចយកមកប្រើប្រាស់បានយ៉ាងទូលំទូលាយ យ៉ាងហោចណាស់ ក៏មានលក្ខណៈជាគោលការណ៍ដែរ។ ហើយរដ្ឋសមាជិកអាស៊ានភាគច្រើនទទួលស្គាល់តាមរយៈច្បាប់ និងគោលនយោបាយ នូវសេចក្តីត្រូវការចាំបាច់ឲ្យមានការការពារពិសេសក្នុងតុលាការ រួមទាំងការការពារសម្រាប់កុមារដែលផ្តល់សក្ខីកម្មក្នុងពេលជំនុំជម្រះលើសំណុំរឿងជួញដូរ។

ទោះបីមានវឌ្ឍនភាពបែបនេះនៅក្នុងច្បាប់ និងគោលនយោបាយក្តី ការធានាសុវត្ថិភាព និងប្រសិទ្ធិភាពក្នុងការចូលរួមរបស់ជនរងគ្រោះធ្វើជាសាក្សី នៅតែជាការប្រឈមដ៏ធំមួយ។ ឧទាហរណ៍ ជារឿយៗជនរងគ្រោះពីការជួញដូរត្រូវបានផ្តល់សំណូក ឬបំភិតបំភ័យឲ្យនៅស្ងៀម ដោយជនជួញដូរ ឬមន្ត្រីផ្នែកព្រហ្មទណ្ឌយុត្តិធម៌។ នេះជាឧបសគ្គដ៏ធំមួយចំពោះការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរ។ វាក៏ធ្វើឲ្យប៉ះពាល់ដល់នីតិរដ្ឋ និងទំនុកចិត្តពីសហគមន៍ទៅលើសមត្ថភាពរបស់រដ្ឋក្នុងការដោះស្រាយបញ្ហានិទណ្ឌភាពរបស់ពួកឧក្រិដ្ឋជនផងដែរ។ ជារឿយៗ ការការពារតាមផ្នែកនីតិកម្មនូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលឯកជនភាព និងព័ត៌មាន មិនត្រូវបានយកមកអនុវត្តក្នុងករណីជាក់ស្តែងទេ។ ស្រដៀងគ្នាដែរ ជារឿយៗ ការអនុវត្តន៍ការការពារពិសេសក្នុងតុលាការ (រួមទាំងការការពារចំពោះកុមារដែលកំពុងផ្តល់សក្ខីកម្ម) ពុំសូវបានល្អទេ ជនរងគ្រោះជាសាក្សីជាជនបរទេសប្រឈមនឹងឧបសគ្គធំធេងដូចគ្នា។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ពួកគេត្រូវបង្ខំឱ្យនៅក្នុងប្រទេសនៃការកេងប្រវ័ញ្ច (ជារឿយៗនៅក្នុងកន្លែងស្នាក់នៅបិទជិត) ក្នុងរយៈពេលដ៏យូររហូតទាល់តែសំណុំរឿងនោះត្រូវបានបិទបញ្ចប់។ ក្នុងចំណោមរដ្ឋសមាជិកអាស៊ានដែលមានវឌ្ឍនភាព ពាក់ព័ន្ធនឹងការផ្តល់សិទ្ធិស្នាក់នៅ និងធ្វើការជាមួយជនរងគ្រោះជាសាក្សីជាជនបរទេស បង្ហាញថាមានការលំបាកក្នុងការអនុវត្តន៍ឲ្យមានប្រសិទ្ធភាព។

- **ទាក់ទងនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** យន្តការនៃកិច្ចសហប្រតិបត្តិការក្រៅផ្លូវការ ដូចជាកិច្ចសហប្រតិបត្តិការរវាងមន្ត្រីនគរបាលជាមួយមន្ត្រីនគរបាល ព្រមទាំងឧបករណ៍គតិយុត្តិ ដូចជា ការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាមធ្យោបាយដែលមានសារៈសំខាន់ ក្នុងការលុបបំបាត់នូវជម្រកដ៏មានសុវត្ថិភាពរបស់ជនល្មើស ហើយបញ្ចប់នូវនិទណ្ឌភាពដែលមានកម្រិតខ្ពស់បច្ចុប្បន្នរបស់ជនជួញដូរ។ កិច្ចសហប្រតិបត្តិការ អន្តរជាតិក៏ផ្តល់នូវកាលានុវត្តភាពក្នុងការបង្អាក់ខ្សែចង្វាក់ជួញដូរ ចាប់ពីការជ្រើសរើសមនុស្សរហូតដល់ការធ្វើ អាជីវកម្ម។ នៅក្នុងតំបន់អាស៊ាន ក្របខ័ណ្ឌគតិយុត្តិសម្រាប់កិច្ចសហប្រតិបត្តិការបែបនេះត្រូវបានអនុវត្តយ៉ាងទូលំទូលាយ តែក៏មានករណីលើកលែងមួយចំនួនដែរ។ ក៏ប៉ុន្តែ ការផ្តោះប្តូរភស្តុតាង និងព័ត៌មានឆ្លងព្រំដែននៅកម្រិតអ្នកប្រតិបត្តិជាក់ស្តែងមានតិចតួច ជាពិសេសទាក់ទងនឹងការប្រើប្រាស់ឧបករណ៍គតិយុត្តិផ្លូវការដែលអាចរកបាន។ ឧបសគ្គផ្នែកភាសា ប្រព័ន្ធយុត្តិធម៌ វិធាន និងទម្លាប់អនុវត្តន៍ខុសគ្នា និងការមិនយល់ច្បាស់ អំពីអំពើពុករលួយ និងការយល់ដឹងពីអំពើពុករលួយ កង្វះសមត្ថភាព និងកង្វះភាពទំនុកចិត្ត និងភាពជឿជាក់នៅក្នុងដំណើរការសុទ្ធតែចូលរួមចំណែកក្នុងការបរាជ័យនៃទំនាក់ទំនងការងារជាទូទៅ។ ទាក់ទងនឹងភាពជាក់លាក់នៃកិច្ចសហប្រតិបត្តិការផ្លូវការ គឺថា៖ របាយការណ៍បញ្ជាក់ថា ជាកត្តារាំងដ៏ធំមួយគឺការណ៍ដែលថា មន្ត្រីនគរបាល និងព្រះរាជអាជ្ញាមិនដឹងច្បាស់អំពីវិធាន និងនីតិវិធីដែលត្រូវយកមកអនុវត្ត នៅពេលមានករណីជួញដូរឆ្លងដែននៅក្នុងសំណុំរឿងរបស់ខ្លួន។

កិច្ចសហប្រតិបត្តិការក្រៅផ្លូវការរវាងភ្នាក់ងារអនុវត្តន៍ច្បាប់អាស៊ាននៅកម្រិត ប្រតិបត្តិការបង្ហាញនូវសញ្ញាថាមានវឌ្ឍនភាពខ្លាំងនៅក្នុងវិស័យមួយ តែនៅភាពទន់ខ្សោយនៅវិស័យមួយផ្សេងទៀត។ ភាពមិនស្មើគ្នានេះឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តខ្ពស់ផ្នែកនយោបាយចំពោះកិច្ចសហប្រតិបត្តិការនេះ និងយន្តការនានាដែលមានស្រាប់ដូចជា HSU ហើយម្យ៉ាងទៀតគឺ ពុំមានគំនិតផ្តួចផ្តើមជាក់ស្តែងដែលរឹងមាំ នៅក្នុងភ្នាក់ងារមួយចំនួន ដើម្បីធ្វើឲ្យកិច្ចសហប្រតិបត្តិការការងារក្រៅផ្លូវការក្លាយជាសកម្មភាពអនុវត្តន៍ច្បាប់ប្រចាំថ្ងៃនៅក្នុងតំបន់ទាំងមូល។ ប្រការសំខាន់គឺថា កង្វះនីតិវិធី និងការអនុវត្តន៍រឹងមាំជុំវិញកិច្ចសហប្រតិបត្តិការឆ្លងដែនដែលពុំមាននិរន្តរភាព ប្រសិនបើគ្មានការយកចិត្តទុកដាក់ឲ្យបាន

ជិតដល់ និងសកម្ម។ ឧបសគ្គនានារួមមាន ឧបសគ្គផ្នែកភាសា កង្វះចំណេះដឹងផ្នែកច្បាប់ នីតិវិធី និងអនុវត្តន៍ ឆន្ទៈ និងការអនុវត្ត របស់អ្នកស៊ើបអង្កេតឯកទេស ដែលជារឿយៗមិនយកចិត្តទុកដាក់ចំពោះករណីឆ្លងដែន នៅក្នុងសំណុំរឿងរបស់ខ្លួន ហើយផ្តោតតែទៅលើសមាសធាតុបទល្មើសក្នុងស្រុកតែប៉ុណ្ណោះ។ ទោះបីនៅពេលមានកិច្ចសហប្រតិបត្តិការក្រៅផ្លូវការត្រូវបានធ្វើឡើងក៏ដោយ តែគុណភាពរបស់វាអាចមានការប៉ះពាល់ ដោយសារភាពទន់ខ្សោយដែលបន្តមានទាក់ទងនឹងការប្រាស្រ័យទាក់ទង ការពារផ្នែក្នុងឱ្យបានទាន់ពេលវេលា និងការចែករំលែកព័ត៌មានសម្ងាត់ រវាងអ្នកស៊ើបអង្កេតនៅតាមខេត្ត និងសហការីរបស់ខ្លួននៅក្នុងអង្គភាពឯកទេសនៅថ្នាក់កណ្តាល។ ទោះបី HSU បានដើរតួនាទីយ៉ាងសំខាន់ក៏ដោយ តែសមត្ថភាពរបស់អង្គភាពនេះក្នុងការបំពេញតួនាទីជាអ្នកសម្របសម្រួលសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងដែន នៅមានកម្រិតទាបនៅឡើយ។ មានតម្រូវការចាំបាច់ពិតប្រាកដក្នុងតំបន់ ឱ្យមានមេបញ្ជាការនគរបាលជាន់ខ្ពស់ និងប្រធានភ្នាក់ងារផ្នែកចោទប្រកាន់ ដើម្បីបង្កើតជា *យន្តការ និងទំនាក់ទំនងដែលដំណើរការប្រកបដោយនិរន្តរភាព* ដើម្បីធ្វើឱ្យកិច្ចសហប្រតិបត្តិការអន្តរជាតិក្រៅផ្លូវការក្លាយជាបទដ្ឋាន មិនមែនជាករណីលើកលែងនៅក្នុងសំណុំរឿងជួញដូរអន្តរជាតិ។

## ឆ្ពោះទៅអនាគត៖ ការប្រឈម និងកាលានុវត្តភាពសំខាន់ៗ

កថាខណ្ឌខាងក្រោមព្យាយាមពិនិត្យមើលនូវនិន្នាការនានា ដែលបង្ហាញពីការប្រឈម និងកាលានុវត្តភាពសម្រាប់រដ្ឋសមាជិកអាស៊ាន នៅពេលពួកគេធ្វើការអភិវឌ្ឍន៍នូវការឆ្លើយតបកាន់តែប្រសិទ្ធភាពតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ ក្នុងចំណុចនេះ ជាការសំខាន់ត្រូវទទួលស្គាល់ថា គុណភាពនៃការឆ្លើយតបត្រូវតែឆ្លុះបញ្ចាំងដាច់ខាតនូវភាពខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលត្រូវធ្វើការឆ្លើយតប។ ប្រព័ន្ធរឹងមាំមួយដែលមានការការពារចាំបាច់ មានបុគ្គលិកជាអ្នកមានវិជ្ជាជីវៈ ដែលមានការទទួលខុសត្រូវខ្ពស់ចំពោះសកម្មភាពរបស់ខ្លួន ត្រូវដាក់ឱ្យបម្រើការឱ្យត្រូវតាមជំនាញ ដើម្បីធ្វើការឆ្លើយតបយ៉ាងរឹងមាំ និងមានប្រសិទ្ធភាពទៅនឹងបទល្មើសជួញដូរ។ ផ្ទុយទៅវិញ ប្រព័ន្ធដែលទន់ខ្សោយ ឬមិនដំណើរការដែលមិនដោះស្រាយអំពើនិទណ្ឌភាព និងមិនធានាយុត្តិធម៌នឹងគ្មានសមត្ថភាពក្នុងការឆ្លើយតបទៅនឹងការជួញដូរឱ្យបានពេញលេញទេ។ ក្នុងន័យនេះ ការពង្រឹងសមត្ថភាពផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីឆ្លើយតបទៅនឹងបទល្មើសជួញដូរត្រូវតែចាត់ទុកជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកែលម្អភាពជាវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់នៃផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។ វាក៏ជាការសំខាន់ផងដែរក្នុងការទទួលស្គាល់ថា ការកែទម្រង់ "ជាឧត្តមគតិ" ឬ "ឧត្តមានុវត្តន៍" មានគោលបំណងកែលម្អការឆ្លើយតបទៅនឹងការជួញដូរ មិនអាចសមស្របសម្រាប់គ្រប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទាំងអស់នោះទេ។ ឧទាហរណ៍ ទោះបីកិច្ចសហប្រតិបត្តិការរវាងនគរបាល និងព្រះរាជអាជ្ញាត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាជាទិដ្ឋភាពសំខាន់មួយនៃការរៀបចំសំណុំរឿង (សូមមើលខាងលើ) ក៏ដោយ តែកិច្ចសហប្រតិបត្តិការនេះតម្រូវឱ្យមានការការពារដើម្បីបញ្ចៀសការបំភិតបំភ័យពីជនសង្ស័យ និងការណែនាំឱ្យសាក្សីឆ្លើយតាមជាដើម។ ក្នុងករណីដែលពុំមានការការពារទាំងនេះទេ កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធអាចក្លាយជាឧបសគ្គ ជាជាងការលើកតម្កើងយុត្តិធម៌។

## ការកំណត់គោលដៅសមស្រប នៃការខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ

នៅទូទាំងតំបន់អាស៊ាន ក៏ដូចជាផ្នែកផ្សេងទៀតនៃពិភពលោកដែរ ការកំណត់គោលដៅនៃការខិតខំប្រឹងប្រែងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវយកមកពិនិត្យជាបន្តបន្ទាប់ និងការកែតម្រូវជាថ្មី ដើម្បីធានានូវប្រសិទ្ធភាពនៃការឆ្លើយតបជារួម។ ឧទាហរណ៍ ទោះបីមានការទទួលយកយ៉ាងធំធេងជាគោលការណ៍នូវការរីករាលដាលនៃការជួញដូរនៅក្នុងការងារដោយបង្ខំក៏ដោយ តែរដ្ឋសមាជិកអាស៊ានភាគច្រើននៅបន្តផ្តោតការខិតខំប្រឹងប្រែងរបស់ខ្លួនយ៉ាងទូលំ

ទូលាយទៅលើការជួញដូរស្ត្រី និងកុមារសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទដដែល (រួមទាំងការធ្វើអាជីវកម្មផ្លូវភេទនៅលើអ៊ិនធឺណេត) ដែលធ្វើឲ្យបាត់បង់នូវទិដ្ឋភាពធំមួយនៃការធ្វើអាជីវកម្មពាក់ព័ន្ធនឹងការជួញដូរ។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន សម្ពាធខាងក្រៅ និងខាងក្នុងឲ្យធ្វើការកែលម្អការបំពេញការងារក៏បានចូលរួមចំណែកជារបថមួយដែរនូវការពង្រីកបណ្តាញនៃការចោទប្រកាន់៖ ឧទាហរណ៍ តាមរយៈការចោទប្រកាន់ពីបទ “ការប៉ុនប៉ង” ប្រព្រឹត្តការជួញដូរ ដោយផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់ ហើយការអនុវត្តន៍នៃការចោទប្រកាន់នានាដូចជា អាពាហ៍ពិពាហ៍ដោយការរៀបចំ និងការហៅម៉ូយផ្អែកពេស្យាចារថាជាការជួញដូរ។ ការកំណត់ជាគោលដៅយ៉ាងទូលំទូលាយនៃ “ផលប្រយោជន៍ងាយៗ” (ដូចជា ឈ្មួញកណ្តាល និងអ្នកដឹកជញ្ជូន) អាចកែលម្អដល់ចំនួននៃការចោទប្រកាន់ តែជួយតិចតួចដល់ការដោះស្រាយនិទណ្ឌភាពដែលជនកេងប្រវ័ញ្ចទទួលបាន ដែលជាអ្នកទទួលផលប្រយោជន៍ធំធេងពីការជួញដូរ។ រដ្ឋសមាជិកអាស៊ានទាំងអស់នឹងទទួលបានផលប្រយោជន៍ពីការរៀបចំវាយតម្លៃជាយុទ្ធសាស្ត្រដោយផ្តោតលើ៖ (១) ការកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់នូវវិសាលភាព និងលក្ខណៈនៃបញ្ហាជួញដូរ (២) វិសាលភាពនៃការឆ្លើយតបបច្ចុប្បន្នទៅលើបញ្ហាដែលបានវាយតម្លៃ។ ការវាយតម្លៃនេះនឹងផ្តល់ជាភស្តុតាងរឹងមាំសម្រាប់កំណែទម្រង់ចាំបាច់ចំពោះវិធីសាស្ត្រ និងការអនុវត្តន៍។ វាក៏នឹងជួយគាំទ្រដល់ការអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រច្បាស់លាស់មួយសម្រាប់ការចូលរួមពីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែរ។

## ការកែលម្អចំពោះយុត្តិធម៌សម្រាប់ជនរងគ្រោះ/សាក្សីជាជនរងគ្រោះ

ស្ទើរតែពុំមានករណីលើកលែងទាល់តែសោះដែលថា បទពិសោធន៍របស់ជនរងគ្រោះពីការជួញដូរជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាបទពិសោធន៍អវិជ្ជមាន។ នៅក្នុងករណីមួយចំនួន ជនរងគ្រោះទទួលរងព្យសនកម្មដោយផ្ទាល់ និងធ្ងន់ធ្ងរដោយសារការទាក់ទងជាមួយនគរបាល ព្រះរាជអាជ្ញា និងតុលាការ។ មានការលើកទឹកចិត្តតិចតួចសម្រាប់ឲ្យជនរងគ្រោះសហការនៅក្នុងការចោទប្រកាន់ដល់ជនកេងប្រវ័ញ្ចមកលើពួកគេ។ ជារឿយៗ សិទ្ធិ និងការការពារដែលច្បាប់ និងគោលនយោបាយផ្តល់ដល់ជនរងគ្រោះមិនអាចទទួលបានក្នុងការអនុវត្តន៍ជាក់ស្តែង ដោយសារតែកង្វះប្រព័ន្ធបញ្ជូនទៅស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ដើម្បីជួយសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពដល់ការផ្តល់សេវានានា។ ការការពារតាមផ្លូវច្បាប់ដល់ជនរងគ្រោះកាន់តែរឹងមាំ និងការកែលម្អការយល់ដឹងក្នុងចំណោមមន្ត្រីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបានជួយកែលម្អស្ថានភាពនេះ តែនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើបន្ត។ ទម្លាប់អនុវត្តន៍នូវដំណោះស្រាយ “ក្រៅផ្លូវការ” (ដែលជាទូទៅពាក់ព័ន្ធនឹងជនសង្ស័យសងជំងឺចិត្តដល់ជនរងគ្រោះ) មិនមែនជាជម្រើសសមស្របដើម្បីដោះស្រាយនូវចំណុចអសកម្មនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទេ។ វាធ្វើឲ្យប៉ះពាល់ដល់នីតិរដ្ឋ ជំរុញឲ្យមានអំពើពុករលួយ និងការរារាំងដល់ការនផ្តល់យុត្តិធម៌ពិតប្រាកដដល់ជនរងគ្រោះ។

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ជនសង្ស័យ

សម្ពាធទៅលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (ជួនកាលផុយស្រួយ) ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការជួញដូរ អាចបណ្តាលឲ្យមានផ្លូវកាត់ដែលប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យគ្រប់រូបក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជួនកាល សំណុំរឿងជួញដូរនៅក្នុងតំបន់ ត្រូវបានចោទប្រកាន់យ៉ាងជោគជ័យ ដោយផ្អែកភស្តុតាងមិនគ្រប់គ្រាន់។ ជនសង្ស័យមិនទទួលបានផលប្រយោជន៍ពីសិទ្ធិទទួលបានភាពជាតំណាងផ្លូវច្បាប់ និងសួរដេញដោលអ្នកដែលចោទប្រកាន់មកលើខ្លួន។ បញ្ហានៃការកំណត់គោលដៅមិនសមរម្យ ដូចបានរៀបរាប់ខាងលើក៏អាចប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យដែរ ឧទាហរណ៍ បណ្តាលឲ្យការផ្តន្ទាទោសពីការជួញដូរចំពោះការប្រព្រឹត្តិដែលអាចត្រូវបានចាត់ទុកថាមិនដល់លក្ខណៈវិនិច្ឆ័យនៃភាពធ្ងន់ធ្ងរដែលត្រូវបានទទួលយក ឬស្របទៅនឹងធាតុផ្សំនានានៃបទល្មើសជួញដូរមនុស្សទេ។ ជួនកាល ចៅក្រមយល់ថាគាត់មានកាតព្វកិច្ច (ហើយជួនកាលត្រូវបានគេតម្រូវឱ្យធ្វើ) ធ្វើការដាក់ទោសតឹងរ៉ឹងទៅលើជនជួញដូរដែលត្រូវបានផ្តន្ទាទោស ដែលអាចត្រូវបានចាត់ទុកថាមិនសមមាត្រជាសត្យានុម័តទៅនឹងបទល្មើស។

## ការដោះស្រាយអំពើពុករលួយ

បទពិសោធន៍នៅគ្រប់តំបន់ទាំងអស់បញ្ជាក់ពីទំនាក់ទំនងរវាងការជួញដូរនិងអំពើពុករលួយ។ ក្នុងករណីធ្ងន់ធ្ងរបំផុតរួមទាំងនៅក្នុងតំបន់អាស៊ាន មន្រ្តីសាធារណៈត្រូវបានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការកេងប្រវ័ញ្ចទាក់ទងនឹងការជួញដូរ ។ មន្ត្រីសាធារណៈជួយសម្របសម្រួលក្នុកការជួញដូរដែរ ឧទាហរណ៍ តាមរយៈការការពារជនល្មើសពីការស៊ើបអង្កេត ការចោទប្រកាន់ និងការផ្តន្ទាទោសដើម។ រដ្ឋសមាជិកអាស៊ានមួយចំនួនបានបង្ហាញនូវឆន្ទៈកាន់តែច្រើនឡើងក្នុងការឆ្លើយតបទៅនឹងអំពើពុករលួយ ដែលពាក់ព័ន្ធនឹងការជួញដូរនេះ។ ក៏ប៉ុន្តែ បញ្ហានេះនៅតែមានភាពទូលំទូលាយ និងទោះបីជាមានការកំណត់យ៉ាងហ្មត់ចត់លើប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងដែលមានមហិច្ឆតាបំផុតក្នុងការកែលម្អការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ។

## ការរក្សានិរន្តរភាពក្នុងការអភិវឌ្ឍន៍សមត្ថភាព

តំបន់អាស៊ានបានទទួលផលប្រយោជន៍ជាច្រើនពីការវិនិយោគប្រកបដោយនិរន្តរភាព នូវការអភិវឌ្ឍន៍សមត្ថភាពដល់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ។ រដ្ឋសមាជិកអាស៊ានភាគច្រើនបានទទួលការគាំទ្រពីខាងក្រៅ ដើម្បីពង្រឹងស្ថាប័ន និងនីតិវិធី និងការបណ្តុះបណ្តាលដល់មន្ត្រីរបស់ខ្លួន។ ក៏ប៉ុន្តលទ្ធផលនៃនិរន្តរភាពនៅតែចោទជាបញ្ហា ឧទាហរណ៍ មានរដ្ឋសមាជិកអាស៊ានតិចតួចណាស់ដែលបែងចែកថវិការគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាល ដល់មន្ត្រីអនុវត្តន៍ច្បាប់ការពារព្រំដែន និងអ្នកស៊ើបអង្កេតឯកទេសនៃការជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ានភាគច្រើនមិនអាចផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់សម្រាប់ការស៊ើបអង្កេតលើសំណុំរឿងជួញដូរទេ ដែលមានន័យថា ជំនាញថ្មីៗ មិនបានយកទៅប្រើប្រាស់ ហើយនឹងមានសមត្ថភាពតិចតួច ដែលវាជាវិធីសាស្រ្តហួសសម័យកាល ដែលមិនមែនជាវិធីសាស្រ្តស៊ើបអង្កេតចុងក្រោយនាពេលបច្ចុប្បន្ននេះទេ។ ការផ្តល់ថវិការតិចតួច ឬគ្មានទាល់សោះដល់កិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែន ឬការដោះស្រាយបញ្ហានៃការជួញដូរពលកររដោយបង្ខំ។

## ទិន្នន័យ និងព័ត៌មានល្អប្រសើរ

របាយការណ៍នេះបានបញ្ជាក់ពីគម្លាតយ៉ាងធំធេងនៅក្នុងព័ត៌មាន និងទិន្នន័យនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមាន។ នៅក្នុងសំណុំរឿងមួយចំនួន វាសមស្របដែលថា ព័ត៌មានមួយចំនួនមិនអាចរកបានជាសាធារណៈទេ។ ក៏ប៉ុន្តែវាមានលេចឡើងថា គម្លាតព័ត៌មានកំពុងប៉ះពាល់ដល់សមត្ថភាពរបស់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការតាមដានវាយតម្លៃ និងកែលម្អការបំពេញការងាររបស់ខ្លួន។ ឧទាហរណ៍ ទោះបីព័ត៌មានស្តីពីការជួយសង្គ្រោះជនរងគ្រោះបន្ទាប់ពីការឆ្លក់ចូលអាចដាក់ឲ្យមើលភ្លាមៗបានក៏ដោយ តែជារឿយៗ វាកាន់តែមានការលំបាកក្នុងការតាមដានអ្វីដែលកើតឡើងនាពេលបន្ទាប់ ពាក់ព័ន្ធនឹងការចោទប្រកាន់ និងការផ្តន្ទាទោស។ ស្រដៀងគ្នាដែរ វាមានការលំបាកក្នុងការទទួលបានចំណេះដឹងស៊ីជម្រៅទៅលើគុណភាពនៃការចោទប្រកាន់ចំពោះការជួញដូរ លក្ខណៈ និងវិសាលភាពនៃកិច្ចសហប្រតិបត្តិការឆ្លងដែន និងបទពិសោធន៍របស់ជនរងគ្រោះនៅក្នុងដំណើរការផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។

## ធាតុសំខាន់ៗ៖ ការប្តេជ្ញាចិត្តផ្នែកនយោបាយ និងស្ថាប័ន

ដំណើរប្រតិបត្តិការរបស់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ តែងតែមានទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ។ សមត្ថភាព និងការអនុវត្តរបស់ពួកគេគឺជាអាទិភាព ឆ្លុះបញ្ចាំងពីកម្រិតនៃការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការដោះស្រាយការជួញដូរ៖ ដើម្បីបញ្ចប់និទណ្ឌភាពដែលជនជួញដូរដែលមានកម្រិតខ្ពស់នៅឡើយ និងដើម្បីធានាស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ។ ថ្នាក់ដឹកនាំនយោបាយអាចបង្ហាញពីការប្តេជ្ញាចិត្តគាំទ្រដល់ការផ្លាស់ប្តូរ និងកំណែទម្រង់នានាដែលបានលើកឡើងខាងលើ ជាពិសេសបំផុត គឺតាមរយៈការផ្តល់ឲ្យភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ នូវភាពជាអ្នកដឹកនាំ ការផ្តល់សិទ្ធក្នុងការអនុវត្តការងារ និងធនធានចាំបាច់ដើម្បីឲ្យពួកគេអាចបំពេញការងារប្រកបដោយប្រសិទ្ធភាពបាន។ ពួកគេក៏អាចជួយកំណត់អំពីការឆ្លើយតបនៅថ្នាក់ជាតិផងដែរ ដោយបញ្ជាក់អំពីតម្រូវការចាំបាច់នូវជំនាញវិជ្ជាជីវៈ សុចរិតភាព និងការទទួលខុសត្រូវខ្ពស់ នៅគ្រប់ដំណាក់កាល និងដើម្បីការពារស្ថាប័នរបស់ខ្លួនពីសម្ពាធខាងក្នុង ឬខាងក្រៅដែលអាចប៉ះពាល់ដល់គោលការណ៍ នៃតម្លៃសីលធម៌ជាមូលដ្ឋានរបស់ខ្លួន។

# សេចក្ដីផ្ដើម

## <u>អាស៊ាន និងការជួញដូរមនុស្ស</u>

បញ្ហាជួញដូរមនុស្ស (TIP) បានក្លាយជារបៀបវារៈរបស់សមាគមនៃបណ្ដាប្រជាជាតិនៅអាស៊ីអគ្នេយ៍ (អាស៊ាន) និងរដ្ឋសមាជិករបស់ខ្លួនចាប់តាំងដើមទសវត្សរ៍១៩៩០ មកម្ល៉េះ។ របាយការណ៍ដំបូងស្ដីអំពីការជួញដូរនៅក្នុងតំបន់នេះពាក់ព័ន្ធនឹងករណីស្ត្រី និងកុមារី ដែលត្រូវបានគេនាំឆ្លងកាត់ព្រំដែន ក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ និងអាពាហ៍ពិពាហ៍បែបទាសភាព។ ចាប់តាំងពីពេលនោះមក មានព័ត៌មានកាន់តែច្រើនឡើងៗអំពីលក្ខណៈ និងភាពចម្រុះនៃការជួញដូរមនុស្សនៅអាស៊ីអគ្នេយ៍។ នាពេលនេះ មានការយល់ដឹងយ៉ាងច្បាស់ថា នៅក្នុងតំបន់នេះក៏ដូចជានៅក្នុងតំបន់ទាំងអស់ផ្សេងទៀតដែរ ការជួញដូរពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចដែលជាបទល្មើសទៅលើស្ត្រី បុរស កុមារី និងកុមារា នៅក្នុងវិស័យឧស្សាហកម្ម និងមានការកំណត់រៀបចំយ៉ាងទូលំទូលាយ។ ឧទាហរណ៍ ការស៊ើបអង្កេតបានរកឃើញករណីកុមារា និងបុរសស្ថិតនៅក្នុងការងារដោយបង្ខំនៅលើទូកនេសាទ បុរស ស្ត្រី និងកុមារក្លាយជាទាសករនៅក្នុងរោងចក្រកាត់ដេរ រោងចក្រផលិតចំណីអាហារកំប៉ុង និងរោងចក្រផលិតគ្រឿងអេឡិចត្រូនិក និងការងារដោយបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើអ្នកធ្វើការតាមផ្ទះ។ ការបង្ហាញថ្មីៗពីការជួញដូរសម្រាប់ធ្វើអាជីវកម្មផ្លូវភេទ ឧទាហរណ៍ ការជួញដូរក្នុងគោលបំណងពរពោះជំនួសដោយបង្ខំ ក៏ត្រូវបានរកឃើញដែរ។ នាពេលខាងមុខ ហាក់ដូចជាលេចឡើងនូវព័ត៌មានបន្ថែមអំពីទម្រង់នៃការជួញដូរផ្សេងទៀតដែលគេពុំសូវបានដឹង ដូចជាការជួញដូរក្នុងគោលបំណងកាត់យកសរីរាង្គទៅលក់ជាដើម។

រដ្ឋសមាជិកអាស៊ានបានទទួលស្គាល់ថា ដោយសារវាជាបទល្មើសធ្ងន់ធ្ងរមកលើមនុស្ស ការជួញដូរមនុស្សនេះនឹងត្រូវបានកំណត់ជាអាទិភាពខ្ពស់ជាងគេ ហើយដោយសារជារឿយៗ ការជួញដូរមានសមាសធាតុឆ្លងដែនរឹងមាំមួយ ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពតម្រូវឲ្យមានការសម្របសម្រួល និងការសហការណ៍ឆ្លងដែន។ ចំណុចនោះត្រូវបានលើកឡើងនៅក្នុងលិខិតូបករណ៍ចម្បងៗជាច្រើនដែលរដ្ឋសមាជិកអាស៊ានទាំងអស់បានព្រមព្រៀង។ លិខិតូបករណ៍ទាំងនេះរួមមាន៖

- ចក្ខុវិស័យអាស៊ានឆ្នាំ២០២០[១] (ឆ្នាំ១៩៩៧)
- សេចក្ដីប្រកាសរបស់អាស៊ានស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន[២] (ឆ្នាំ១៩៩៧)
- សេចក្ដីប្រកាសរបស់អាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ[៣] (ឆ្នាំ២០០៤)
- សេចក្ដីប្រកាសរបស់អាស៊ានស្ដីពីការការពារនិងការលើកកម្ពស់សិទ្ធិកម្មករទេសន្តរប្រវេសន៍[៤](ឆ្នាំ២០០៧)

---

[១] សមាគមបណ្ដាប្រជាជាតិនៅអាស៊ីអគ្នេយ៍ [អាស៊ាន] *ចក្ខុវិស័យអាស៊ានឆ្នាំ២០២០* ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៧។

[២] អាស៊ាន សេចក្ដីប្រកាសស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៧។

[៣] អាស៊ាន សេចក្ដីប្រកាសរបស់អាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤។

[៤] អាស៊ាន សេចក្ដីប្រកាសស្ដីពីការការពារ និងការលើកម្ពស់សិទ្ធិកម្មករចំណាកស្រុក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧។

- គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន ស្តីពីការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស[៥] (ឆ្នាំ២០០៧) (គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន)
- សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានឆន្ទៈដូចគ្នា[៦] (ឆ្នាំ២០០៤) (ASEAN MLAT)

*តារាង ១៖ ចំណុចសំខាន់ៗរបស់អាស៊ានពាក់ព័ន្ធនឹងការជួញដូរមនុស្ស*

| | ចំណុចសំខាន់ៗ | ឥទ្ធិពល/ភាពពាក់ព័ន្ធ |
|---|---|---|
| ឆ្នាំ២០០២ | ប្រទេសហ្វីលីពីនផ្តល់សច្ចាប័នដល់ពិធីសារអ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានដំបូងដែលបានចូលរួមក្នុងពិធីសារនេះ។ [សម្គាល់៖ ពិធីសារ (តាមរយៈលិខិតូបករណ៍មេរបស់វា គឺអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង) តម្រូវឲ្យរដ្ឋត្រូវធ្វើកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេត និងចោទប្រកាន់ការជួញដូរមនុស្ស។ ពិធីសារនេះក៏អាចយកមកប្រើជាមូលដ្ឋានគតិយុត្តិសម្រាប់ MLA និងការធ្វើបត្យាប័នផងដែរ] |
| ឆ្នាំ២០០៣ | ប្រទេសឡាវផ្តល់សច្ចាប័នដល់ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីពីរដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០០៤ | ការអនុម័តសេចក្តីប្រកាសរបស់អាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ | ជាលិខិតូបករណ៍ដំបូងនៅទូទាំងអាស៊ានដែលឆ្លើយតបទៅនឹងការជួញដូរមនុស្ស៖ ការជួញដូរដែលបានរកឃើញ គឺជាបញ្ហាមួយដែលប៉ះពាល់ដល់រដ្ឋទាំងអស់នៅក្នុងតំបន់ ហើយរដ្ឋបានប្តេជ្ញាចិត្តធ្វើកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការជួញដូរ ដោះស្រាយជាមួយជនល្មើស និងការពារជនរងគ្រោះ |
| ឆ្នាំ២០០៤ | ប្រទេសមីយ៉ាន់ម៉ាចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីបីដែលបានចូលរួមក្នុងពិធីសារនេះ |

[៥] អាស៊ាន ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស៖ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន ខែមិថុនា ឆ្នាំ២០០៧ [តទៅនេះហៅថា គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន]។

[៦] សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានឆន្ទៈដូចគ្នា ចុះថ្ងៃទី២៩ ខែវិច្ឆិកាឆ្នាំ២០០៤ ធ្វើនៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី [តទៅនេះហៅថា ASEAN MLAT]។

| | ចំណុចសំខាន់ៗ | ឥទ្ធិពល/ភាពពាក់ព័ន្ធ |
|---|---|---|
| ឆ្នាំ២០០៤ | ការអនុម័តសន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានឆន្ទៈដូចគ្នា | ជាលិខិតូបករណ៍ដែលមានចំណងគតិយុត្តិដែលតម្រូវឲ្យរដ្ឋសមាជិក (គិតមកត្រឹមឆ្នាំ២០១៥ គឺរដ្ឋសមាជិកអាស៊ានទាំងអស់) ធ្វើសកម្មភាពសហប្រតិបត្តិការជាច្រើន ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមក។ សន្ធិសញ្ញានេះគ្របដណ្តប់ទៅបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរទាំងអស់ (និងសំណុំរឿងជួញដូរទាំងអស់)។ |
| ឆ្នាំ២០០៧ | SOMTC អនុម័ត គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន ស្តីពីការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស | លិខិតូបករណ៍ដំបូងដែលដឹកនាំដោយ SOMTC ស្តីពីការជួញដូរមនុស្ស៖ ទទួលស្គាល់ពីតម្រូវការចាំបាច់ឲ្យមានកិច្ចសហប្រតិបត្តិការ រវាងរដ្ឋសមាជិកអាស៊ាន និងបានរៀបចំនូវគោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋាន សម្រាប់នគរបាល និងនគរបាលក្រៅផ្លូវការ (កិច្ចសហប្រតិបត្តិការ ព្រមទាំងការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក។ |
| ឆ្នាំ២០០៧ | ប្រទេសកម្ពុជាចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីបួនដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០០៩ | ប្រទេសឥណ្ឌូនេស៊ី និងប្រទេសម៉ាឡេស៊ីចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីប្រាំ និងទីប្រាំមួយដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០១០ | SOMTC អនុម័ត សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស | ជាសាកល នេះជាប្រភពទូលំទូលាយដំបូងស្តីពីប្រធានបទនេះ ចាប់ពីពេលនោះមក ត្រូវបានយកទៅប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុង និងក្រៅតំបន់ |
| ឆ្នាំ២០១២ | ប្រទេសវៀតណាម ចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីប្រាំពីរដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០១៣ | ប្រទេសថៃចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីប្រាំបីដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០១៥ | ចាប់ផ្តើមការងារបង្កើត និងរៀបចំគម្រោងខ្លីនៃកម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស | ការបង្កើត និងរៀបចំគម្រោងខ្លីដឹកនាំដោយការិយាល័យអគ្គអយ្យការថៃ ដោយសហការជាមួយប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឥណ្ឌូនេស៊ី |

| | ចំណុចសំខាន់ៗ | ឥទ្ធិពល/ភាពពាក់ព័ន្ធ |
|---|---|---|
| ឆ្នាំ២០១៥ | ប្រទេសសិង្ហបុរីចូលជាសមាជិកនៃពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ | រដ្ឋសមាជិកអាស៊ានទីប្រាំបួនដែលបានចូលរួមក្នុងពិធីសារនេះ |
| ឆ្នាំ២០១៥ | អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ACTIP) ត្រូវបានអនុម័ត ដោយប្រមុខរដ្ឋអាស៊ាន | លិខិតូបករណ៍ដែលមានចំណងគតិយុត្តិដំបូងរបស់អាស៊ានស្តីពីការជួញដូរ៖ |
| ឆ្នាំ២០១៦ | ACTIP ចូលជាធរមាន បន្ទាប់ពីការផ្តល់សច្ចាប័នរបស់ប្រទេសកម្ពុជា សិង្ហបុរី ថៃ វៀតណាម មីយ៉ាន់ម៉ា និង ហ្វីលីពីន | អនុសញ្ញាបញ្ជាក់អំពីកាតព្វកិច្ចសហប្រតិបត្តិការ (និងការអនុវត្តន៍ AMLAT) នៅក្នុងសំណុំរឿងជួញដូរ និងបញ្ចូលបទប្បញ្ញត្តិទូលំទូលាយស្តីពីការធ្វើបត្យាប័ន។ អាចយកមកប្រើប្រាស់ជាមូលដ្ឋានគតិយុត្តិរវាងរដ្ឋភាគីនៅក្នុងសំណុំរឿងជួញដូរមនុស្ស |
| ឆ្នាំ២០១៧ | ប្រទេសឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងវៀតណាមផ្តល់សច្ចាប័នដល់ ACTIP | គិតមកត្រឹមចុងឆ្នាំ២០១៧ រដ្ឋចំនួនប្រាំបួនក្នុងចំណោមរដ្ឋសមាជិកទាំងដប់បានផ្តល់សច្ចាប័នដល់ ACTIP |

នៅខែវិច្ឆិកា ឆ្នាំ២០១៥ ប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលនៃរដ្ឋសមាជិកអាស៊ានបានអនុម័ត *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ* (អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ) ជាលិខិតូបករណ៍ដែលមានចំណងគតិយុត្តិ ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការទប់ស្កាត់ការជួញដូរ ការចោទប្រកាន់ចារី និងធានាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ។ ផែនការសកម្មភាពមួយអមជាមួយនឹងអនុសញ្ញានេះ រៀបរាប់អំពីជំហានជាក់លាក់នានាដែលរដ្ឋសមាជិកត្រូវធ្វើដោយឡែកពីគ្នា និងរួមគ្នា។

នៅក្នុងបុព្វកថា *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* អះអាងនូវគោលការណ៍ និងការធានាជាច្រើនដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រធានបទនៃរបាយការណ៍នេះគឺ៖

- ទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋសមាជិកអាស៊ានជាកត្តាចាំបាច់ដល់ការស៊ើបអង្កេត ការចោទប្រកាន់ និងការលុបបំបាត់ជម្រកសុវត្ថិភាពសម្រាប់ចារី និងជនសមគំនិតនៃការជួញដូរមនុស្សដោយជោគជ័យ និង ផ្តល់ការការពារ និងជំនួយយ៉ាងមានប្រសិទ្ធភាពដល់ជនរងគ្រោះ។
- ទទួលស្គាល់ថា ការជួញដូរមនុស្សបណ្តាលមកពីកត្តាជាច្រើន រួមមាន អំពើពុករលួយក្នុងរដ្ឋាភិបាល ភាពក្រីក្រ អស្ថិរភាពផ្នែកសេដ្ឋកិច្ច ប្រព័ន្ធច្បាប់ពុំមានប្រសិទ្ធភាព ឧក្រិដ្ឋកម្មដែលមានការចាត់តាំង និង តម្រូវការដែលជំរុញឲ្យមានការកេងប្រវ័ញ្ចមនុស្សរាល់ទម្រង់ទាំងអស់ ដែលនាំទៅរកការជួញដូរ។ និង
- យល់ឃើញថា រដ្ឋសមាជិកអាស៊ានទាំងអស់ ដោយមិនគិតថាជាប្រទេសប្រភព ប្រទេសឆ្លងកាត់ ឬប្រទេសគោលដៅ សុទ្ធតែមានការទទួលខុសត្រូវរួម និងមានគោលដៅរួមក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ចោទប្រកាន់ និងផ្តន្ទាទោសដល់ជនល្មើសនៃការជួញដូរមនុស្ស និង ការការពារ និងជួយដល់ជនរងគ្រោះនៃការជួញដូរមនុស្ស។

តារាងខាងក្រោមរៀបរាប់នូវបទប្បញ្ញត្តិចម្បងៗនៃ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ*។

***តារាង ២៖ ACTIP - បទប្បញ្ញត្តិសំខាន់ៗ/កាតព្វកិច្ចរបស់រដ្ឋភាគី***

| អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្សជាពិសេស ស្ត្រី និងកុមារ<br>បទប្បញ្ញត្តិសំខាន់ៗ/កាតព្វកិច្ចរបស់រដ្ឋភាគី |
|---|

| | |
|---|---|
| គោលបំណងរបស់អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្សរួមមាន៖ | |
| ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរ ដោយយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រី និងកុមារ និង ធានានូវការផ្តន្ទាទោសប្រកបដោយយុត្តិធម៌ និង មានប្រសិទ្ធភាពដល់ជនជួញដូរ ដើម្បីការពារ និងជួយដល់ជនរងគ្រោះពីការជួញដូរនេះ ដោយគោរពយ៉ាងពេញលេញនូវសិទ្ធិមនុស្សរបស់ពួកគេ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋភាគី ដើម្បីបំពេញទៅតាមកម្មវត្ថុទាំងនោះ | មាត្រា ១ |
| កាតព្វកិច្ចសំខាន់ៗរបស់រដ្ឋភាគីនៃអនុសញ្ញាអាស៊ានរួមមាន៖ | |
| **"ការជួញដូរមនុស្ស"** **ត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌ**ដូចមានកំណត់និយមន័យនៅក្នុងអនុសញ្ញា ហើយផ្តល់នូវការផ្តន្ទាទោសធ្ងន់ធ្ងរនៅក្នុងសំណុំរឿងមួយចំនួន រួមមាន នៅពេលដែលបទល្មើសពាក់ព័ន្ធនឹងជនរងគ្រោះដែលងាយរងគ្រោះ ឬរបួសស្នាមធ្ងន់ធ្ងរ ឬការស្លាប់ ឬ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តដោយមន្ត្រីសាធារណៈ | មាត្រា ៥ |
| **អំពើពុករលួយ និងការរារាំងដល់យុត្តិធម៌ត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌ**ដែលពាក់ព័ន្ធនឹងការជួញដូរ ដូចជាការផ្តល់ ឬទទួលសំណូក ការបំភិតបំភ័យសាក្សី/មន្ត្រីសាធារណៈ | មាត្រា ៨, ៩ |
| ត្រូវបង្កើតជាគោលការណ៍ណែនាំ**ថ្នាក់ជាតិ ឬនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានត្រឹមត្រូវ** និងដើម្បីគោរពដល់សេចក្តីសម្រេចចិត្តរបស់រដ្ឋភាគីផ្សេងទៀតពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ | មាត្រា ១៤(១&២) |
| ត្រូវពិចារណា**អនុញ្ញាតឲ្យជនរងគ្រោះបន្តស្ថិតនៅក្នុងប្រទេសរបស់ខ្លួន** ទោះជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នដោយពិចារណាទៅលើកត្តាមនុស្សធម៌ និងក្តីមេត្តា | មាត្រា ១៤(៤) |
| ត្រូវផ្តល់**សុវត្ថិភាពផ្លូវកាយ**ដល់ជនរងគ្រោះនៅក្នុងដែនដី | មាត្រា ១៤(៥) |
| ត្រូវការពារ**ឯកជនភាព និងអត្តសញ្ញាណ**ជនរងគ្រោះទៅតាមវិសាលភាពដែលមានកំណត់ក្នុងច្បាប់ជាតិ | មាត្រា ១៤(៦) |
| ត្រូវពិចារណា**មិនឲ្យជនរងគ្រោះទទួលខុសត្រូវ**ចំពោះការប្រព្រឹត្តិអំពើខុសច្បាប់នានាដែលពាក់ព័ន្ធដោយផ្ទាល់ដល់ការជួញដូរពួកគេ | មាត្រា ១៤(៧) |
| មិនត្រូវឃុំខ្លួន ឬដាក់ពន្ធនាគារដល់ជនរងគ្រោះដោយមិនសមហេតុផល | មាត្រា ១៤(៨) |
| ត្រូវផ្តល់ព័ត៌មានដល់ជនរងគ្រោះនូវសិទ្ធិដែលពួកគេទទួលបានការការពារ ជំនួយ និងការគាំទ្រ | មាត្រា ១៤(៩) |
| ត្រូវផ្តល់ការថែទាំ និងការគាំទ្រដល់ជនរងគ្រោះរួមមាន ផ្ទះសម្បែង ការប្រឹក្សាយោបល់ និងព័ត៌មានជំនួយវេជ្ជសាស្ត្រ ផ្លូវចិត្ត និងសម្ភារៈ និងការងារ ការអប់រំ និងការបណ្តុះបណ្តាល និង បែងចែកថវិកាសមរម្យដល់ការថែទាំ និងការគាំទ្រជនរងគ្រោះ | មាត្រា ១៤(១), ១៤(១៤) |

| | |
|---|---|
| ត្រូវធានាថាច្បាប់ផ្ដល់លទ្ធភាពដល់ជនរងគ្រោះក្នុងការទទួលបាន**សំណង**ចំពោះព្យសនកម្មដែលបានទទួលរង | មាត្រា ១៤(១៣) |
| រដ្ឋភាគីនៃប្រទេសដើមត្រូវផ្ទៀងផ្ទាត់សញ្ជាតិរបស់ជនរងគ្រោះ ចេញឯកសារចាំបាច់ និងទទួលយកត្រឡប់ទៅវិញដោយមិនពន្យារពេល ការវិលត្រឡប់ទៅវិញត្រូវធ្វើឡើងដោយគិតដល់សុវត្ថិភាពរបស់ជនរងគ្រោះ និងស្ថានភាពនៃកិច្ចដំណើរការនីតិវិធីច្បាប់ រដ្ឋដើម និងរដ្ឋគោលដៅត្រូវបង្កើតកម្មវិធីធ្វើមាតុភូមិនិវត្តន៍ និងជួយក្នុងការធ្វើសមាហរណកម្មរបស់ជនរងគ្រោះ | មាត្រា ១៤(១១)<br>មាត្រា ១៥ |
| ត្រូវធានាថា**អាជ្ញាធរអនុវត្តច្បាប់ និងអយ្យការមានជំនាញ និងចំណេះដឹងសមស្រប** រួមទាំង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះ និងត្រូវផ្ដល់ការបណ្ដុះបណ្ដាលសម្រាប់គោលបំណងនេះផង | មាត្រា ១៦(១), (៦) |
| ត្រូវសហការក្នុងការជំរុញឲ្យសាក្សីជាជនរងគ្រោះបានវិលត្រឡប់ដោយស្ម័គ្រចិត្តទៅការប្រទេសគោលដៅដើម្បីផ្ដល់សក្ខីកម្ម ឬសហការតាមមធ្យោបាយផ្សេងទៀត | មាត្រា ១៦(៥) |
| ត្រូវ**ការពារសាក្សីជាជនរងគ្រោះពីការបំភិតបំភ័យ** និងការបៀតបៀន និង ផ្ដន្ទាទោសចំពោះការប្រព្រឹត្តបែបនោះ | មាត្រា ១៦(៧) |
| ត្រូវផ្ដល់ឲ្យគ្នាទៅវិញទៅមកនូវវិធានការយ៉ាងទូលំទូលាយបំផុតនៃ**ជំនួយផ្នែកច្បាប់ទៅវិញទៅមក** អនុលោមតាម AMLAT | មាត្រា ១៨ |
| ត្រូវបង្កើតឲ្យបទល្មើសជួញដូរមនុស្សទាំងអស់ជា**បទល្មើសដែលអាចធ្វើបត្យាប័នបាន**នៅក្នុងច្បាប់ជាតិ និងតាមរយៈសន្ធិសញ្ញាទ្វេភាគី និងត្រូវ**សហការ**នៅពេលមានសំណើសុំធ្វើបត្យាប័ន | មាត្រា ១៩ |
| ត្រូវ**សហការរវាងគ្នានិងគ្នាដើម្បីបង្កើនប្រសិទ្ធភាពនៃសកម្មភាពអនុវត្តន៍ច្បាប់** រួមទាំង តាមរយៈការ ផ្លាស់ប្ដូរព័ត៌មាន និងការឆ្លើយតបទៅនឹងសំណួរ និងសំណើសុំជំនួយនានា និង ត្រូវសហការបន្ថែមទៀតក្នុង**គោលបំណងរឹបអូសទ្រព្យ**ដែលបានពីបទល្មើសជួញដូរមនុស្ស | មាត្រា ២០ |

ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា បញ្ហានៃការជួញដូរមនុស្សពាក់ព័ន្ធនឹងវិស័យជាច្រើននៃការងាររបស់អាស៊ាន។ ហេតុនេះ ស្ថាប័ននយោបាយ និងបច្ចេកទេសផ្សេងៗគ្នាជាច្រើនមានភាពពាក់ព័ន្ធនឹងបញ្ហានេះ នៅក្នុងពេលវេលាខុសៗគ្នា។ ឧទាហរណ៍ គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) បានបង្កើតគោលការណ៍ណែនាំស្ដីពីការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តិចំពោះស្ត្រី និងកុមាររងគ្រោះពីការជួញដូរដែលមានភាពពាក់ព័ន្ធខ្ពស់ទៅនឹងតួនាទីរបស់ពួកគេនៅក្នុងដំណើរការផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។

ក៏ប៉ុន្តែ ក្នុងរយៈកាលមួយទសវត្សរ៍កន្លងមក រដ្ឋសមាជិកអាស៊ានបានផ្ដល់ជាពិសេស និងយ៉ាងជោគជ័យបំផុតទៅលើការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ ដោយមានការណែនាំពីក្របខ័ណ្ឌដែលត្រូវបានបង្កើតឡើងដោយ *សេចក្ដីប្រកាសអាស៊ានស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន* (ឆ្នាំ១៩៩៧) និង *សេចក្ដីប្រកាសអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ* (ឆ្នាំ២០០៤) កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ស្ដីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) បាននាំមុខលើបញ្ហាជួញដូរនៅក្នុងអាស៊ាន។ SOMTC បានគ្រប់គ្រងការរៀបចំតាក់តែង *អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស* និងផែនការសកម្មភាពអមជាមួយអនុសញ្ញានេះ និងបាននាំមុខក្នុងការសម្របសម្រួលការងាររបស់ស្ថាប័នអាស៊ានពាក់ព័ន្ធដែលបានចូលរួមក្នុងការអនុវត្តន៍លិខិតូបករណ៍ទាំងនេះ។

# សាវតារ និងគោលបំណងនៃរបាយការណ៍វឌ្ឍនភាព

នៅឆ្នាំ២០០៦ តាមរយៈ SOMTC អាស៊ានបានបោះពុម្ពផ្សាយការសិក្សាអំពីការឆ្លើយតបទៅនឹងការជួញដូរមនុស្ស នៅក្នុងតំបន់អាស៊ានលើកដំបូងរបស់ខ្លួន[៧]។ របាយការណ៍នេះបានកត់ត្រានូវវឌ្ឍនភាពសំខាន់ តែតិចតួចនៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ និងនីតិវិធី។ អត្ថបទដែលធ្វើបច្ចុប្បន្នភាពទៅលើរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០០៨[៨]។ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ការពិភាក្សាតាមរយៈ SOMTC បានកំណត់អំពីតម្រូវការចាំបាច់ ក្នុងការបន្តចែករំលែកព័ត៌មានអំពីរបៀបដែលរដ្ឋសមាជិកអាស៊ានឆ្លើយតបទៅនឹងការជួញដូរមនុស្ស។ ការពិភាក្សាក៏បានគូសបញ្ជាក់នូវតម្រូវការចាំបាច់ក្នុងការបោះជំហានហួសពីការរៀបរាប់នៅក្នុងច្បាប់ និងគោលនយោបាយ និងឆ្ពោះទៅការពិចារណាកាន់តែលម្អិតអំពីការអនុវត្តន៍នូវច្បាប់ និងគោលនយោបាយទាំងនោះនៅក្នុង និងរវាងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងតំបន់អាស៊ាន។

នៅឆ្នាំ២០០៩ SOMTC បានអនុម័តនូវសំណើមួយដើម្បីរៀបចំរបាយការណ៍ស្តីពីឧត្តមានុវត្តន៍ និងបទពិសោធន៍ដែលទទួលបាននៅក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងការវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរនៅក្នុងតំបន់អាស៊ាន។ សំណើនោះបានកត់សម្គាល់ថា ការស្រាវជ្រាវនឹងស្នើសុំឱ្យកំណត់អត្តសញ្ញាណនូវឧត្តមានុវត្តន៍ និងបទពិសោធន៍ដែលទទួលបាន ពាក់ព័ន្ធនឹងធាតុផ្សំសំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស ដែលត្រូវបានរកឃើញដោយអាស៊ាន និងរដ្ឋសមាជិករបស់ខ្លួន។ សំណើនេះបានកត់សម្គាល់ថា សម្រាប់គោលបំណងនៃការស្រាវជ្រាវ "ឧត្តមានុវត្តន៍" នឹងត្រូវបានកំណត់ អនុលោមតាមគោលនយោបាយអាស៊ាន ដែលជាកម្មវត្ថុនៃការបញ្ចប់និទណ្ឌភាពរបស់ជនល្មើស និងធានាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ទន្ទឹមនឹងការគោរពសិទ្ធិមនុស្ស។ ការស្រាវជ្រាវដំបូងដែលបានធ្វើឡើងក្នុងឆ្នាំ២០១០ បានបញ្ជាក់ថា ព័ត៌មានអំពីឧត្តមានុវត្តន៍ និងបទពិសោធន៍ដែលទទួលបានមានភាពកម្រ ទាក់ទងនឹងធាតុផ្សំភាគច្រើននៃធាតុផ្សំដែលត្រូវបានកំណត់អត្តសញ្ញាណនៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ លើកលែងតែវាពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ និងនីតិវិធី ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាពនៃព័ត៌មានដែលអាចរកបានក៏មានការលំបាកក្នុងការផ្ទៀងផ្ទាត់ជារឿយៗដែរ។ ហេតុនេះ មានការសម្រេចធ្វើការកែសម្រួលនូវវិធីសាស្ត្រដើម និងផ្តើមទៅលើការកំណត់អត្តសញ្ញាណនៃចរន្តជាទូទៅនៅក្នុងតំបន់វិញ និងមានពន្យល់ជាឧទាហរណ៍ជាក់ស្តែងពីរដ្ឋសមាជិកអាស៊ានជាក់លាក់ ក្នុងករណីដែលមាន។ វិធីសាស្ត្រនេះបានជូនជាព័ត៌មានដល់ការកែសម្រួលលើកទីមួយទៅលើ *របាយការណ៍វឌ្ឍនភាពអាស៊ាន*។

ជាផ្នែកនៃយុទ្ធសាស្ត្រទូលំទូលាយរបស់ខ្លួនជុំវិញការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពទៅលើ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* SOMTC បានអនុម័តនូវការរៀបចំសំណៅធ្វើបច្ចុប្បន្នភាពនៃ *របាយការណ៍វឌ្ឍនភាព* នៅឆ្នាំ២០១៧។

---

[៧] អាស៊ាន ការឆ្លើយតបរបស់អាស៊ានទៅនឹងការជួញដូរមនុស្ស៖ ការបញ្ចប់និទណ្ឌភាពសម្រាប់ជនជួញដូរ និងការធានាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ (អាស៊ាន ឆ្នាំ២០០៦) [តទៅនេះហៅថា ការឆ្លើយតបរបស់អាស៊ានទៅនឹងការជួញដូរមនុស្ស (ឆ្នាំ២០០៦)]

[៨] អាស៊ាន ការឆ្លើយតបរបស់អាស៊ានទៅនឹងការជួញដូរមនុស្ស៖ ការបញ្ចប់និទណ្ឌភាពសម្រាប់ជនជួញដូរ និងការធានាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ចំណុចបន្ថែម និងបច្ចុប្បន្នភាព (អាស៊ាន ឆ្នាំ២០០៧)។

## វិធីសាស្ត្រនៃការស្រាវជ្រាវ និងប្រភពទិន្នន័យ

ព័ត៌មានដែលបានបង្ហាញនៅក្នុងការកែសម្រួលលើកទីមួយនៃរបាយការណ៍វឌ្ឍនភាពត្រូវបានដកស្រង់ចេញពីប្រភពមួយចំនួន រួមមាន៖

- ឯកសារសាធារណៈដូចជាច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងគោលនយោបាយ។
- ករណីសិក្សានៃការស៊ើបអង្កេត និងការចោទប្រកាន់នាពេលបច្ចុប្បន្នដែលផ្តល់ដោយរដ្ឋសមាជិកអាស៊ានសម្រាប់គោលបំណងរបាយការណ៍វឌ្ឍនភាព។ ការសម្ភាសន៍ជាមួយមន្ត្រីនៃរដ្ឋសមាជិកអាស៊ាន ដើម្បីបន្ថែមព័ត៌មានទៅលើករណីសិក្សា។
- ទិន្នន័យ និងព័ត៌មានផ្សេងទៀតដែលចងក្រងដោយគម្រោងប្រឆាំងការជួញដូរមនុស្សនៅតំបន់អាស៊ី (ARTIP) តាមរយៈសកម្មភាពតាមដាន និងវាយតម្លៃដែលធ្វើឡើងពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១។

ការធ្វើបច្ចុប្បន្នភាពចំពោះរបាយការណ៍វឌ្ឍនភាព ត្រូវបានធ្វើឡើងតាមរយៈការពិនិត្យយ៉ាងយកចិត្តទុកទៅលើប្រភពស្រដៀងគ្នា តែដោយមិនទទួលបានផលប្រយោជន៍ពីការវិភាគលម្អិតទៅតាមប្រទេសនីមួយៗទេ។ ក៏ប៉ុន្តែ មានការពិគ្រោះយោបល់ជាមួយអ្នកប្រតិបត្តិនៅក្នុងរដ្ឋសមាជិកអាស៊ានទាំង ១០ ដើម្បីកំណត់អត្តសញ្ញាណនៃ៖ (១) ការផ្លាស់ប្តូរច្បាប់ គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងដែលបានរាយការណ៍ពីមុនៗ និង (២) ឧទាហរណ៍នៃឧត្តមានុវត្តន៍/ការបង្កើតថ្មីដែលបានដាក់បញ្ចូល។

ពាក់ព័ន្ធនឹងការកែសម្រួលលើកទីមួយ លទ្ធផលព័ត៌មានត្រូវបានពិនិត្យឡើងវិញទល់នឹង**លក្ខណៈវិនិច្ឆ័យ**មួយចំនួនដែលត្រូវបានទទួលយកជាទូទៅថាបង្ហាញអំពីធាតុផ្សំសំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ លក្ខណៈវិនិច្ឆ័យទាំងនេះ ដែលត្រូវបានធ្វើសង្ខេបនៅផ្នែកទីមួយនៃជំពូកនីមួយៗ និងពន្យល់ពេញលេញនៅក្នុងឧបសម្ព័ន្ធនៃជំពូកនីមួយៗ (ជា "បទដ្ឋានគុណភាព") ផ្អែកទៅលើលិខិតូបករណ៍គតិយុត្តិ និងគោលនយោបាយអន្តរជាតិ និងថ្នាក់តំបន់ និង ការអនុវត្តន៍វិជ្ជាជីវៈជាក់ស្តែងដែលមានការបញ្ជាក់ត្រឹមត្រូវ (ទាំងនៅក្នុង និងខាងក្រៅតំបន់អាស៊ាន)។ ពួកគេបានឆ្លុះបញ្ចាំងនូវគោលការណ៍ និងកាតព្វកិច្ចនានាដែលបានរៀបរាប់នៅក្នុងលិខិតូបករណ៍ធំធេងដូចជា៖ *អនុសញ្ញាអាស៊ានប្រឆាំងអំពើពុករលួយ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង*[៩] (ឆ្នាំ២០០៣) (UNTOC) និង *ពិធីសារបង្ក្រាប ទប់ស្កាត់ និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ*[១០] នៃអនុសញ្ញានោះ (ឆ្នាំ២០០៣) (ពិធីសារ អ.ស.ប. ប្រឆាំងការជួញដូរ) និង

---

[៩] *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង* ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ ឯកសារ អ.ស.ប A/RES/55/25 (ឧបសម្ព័ន្ធ I) ចូលជាធរមាននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ [តទៅនេះហៅថា *UNTOC*]។

[១០] ពិធីសារបង្ក្រាប ទប់ស្កាត់ និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ ឯកសារ អ.ស.ប A/RES/55/25 (ឧបសម្ព័ន្ធ II) ចូលជាធរមាននៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣ [តទៅនេះហៅថា ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ]។

*គោលការណ៍ និងគោលការណ៍ណែនាំដែលផ្ដល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស*[១១] (ឆ្នាំ២០០២) (គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប ប្រឆាំងការជួញដូរ)។

## ចំណុចខ្លាំង និងការកម្រិតនៃការស្រាវជ្រាវ

នៅក្នុងតំបន់នេះ ក៏ដូចជាតំបន់ទាំងអស់ផ្សេងទៀតដែរ កង្វះព័ត៌មានដែលអាចជឿជាក់បាន និងស៊ីចង្វាក់អំពីការជួញដូរមនុស្ស រួមទាំងវិសាលភាពនៃបញ្ហា និងវិធីនានាដែលរដ្ឋបានឆ្លើយតបទៅនឹងបញ្ហានេះ។ ឧបសគ្គដែលបានជួបប្រទះជារឿយៗរួមមាន កង្វះការយល់ដឹងរួមពាក់ព័ន្ធនឹងលក្ខណៈនៃបញ្ហា ទំនាក់ទំនងមិនល្អរវាងភ្នាក់ងារ ពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យ គម្លាតនៅក្នុងការប្រមូលទិន្នន័យ ការរាយការណ៍មិនពេញលេញ ឬការរាយការណ៍លើសការពិតពីការជួញដូរ ដែលបណ្ដាលឲ្យមានការលើកឡើងទ្វេដង និង កង្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលនឹងជួយសម្រួលដល់ការប្រមូលទិន្នន័យ។

ការស្រាវជ្រាវសម្រាប់កែសម្រួលទៅលើរបាយការណ៍វឌ្ឍនភាព ក្នុងគោលបំណងកាត់បន្ថយបញ្ហាទាំងនេះទៅតាមលទ្ធភាពដែលមាន ដោយសំអាងទៅលើប្រភពព័ត៌មាននានាដែលបានលើកឡើងខាងលើ ត្រូវបានផ្ទៀងផ្ទាត់ តាមរយៈកិច្ចពិភាក្សាលម្អិតជាមួយអ្នកប្រតិបត្តិ។ គុណភាព និងបរិមាណនៃព័ត៌មានដែលអាចរកបានជាសាធារណៈស្ដីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ទៅនឹងការជួញដូរមនុស្សនៅក្នុងតំបន់បានកែលម្អយ៉ាងធំធេងក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ ឧទាហរណ៍ នៅឆ្នាំ២០១៦ គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ធ្វើការពិនិត្យឡើងវិញទៅលើការឆ្លើយតបថ្នាក់ជាតិទៅនឹងការជួញដូរមនុស្ស ដោយផ្ដោតជាពិសេសទៅលើជនរងគ្រោះ *ទល់នឹង* កាតព្វកិច្ចដែលបានលើកឡើងនៅក្នុង*អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរ*[១២]។ ទិដ្ឋភាពរបស់ទស្សនាវដ្ដី ACWC Regional Review ជាពិសេសពាក់ព័ន្ធនឹងក្របខណ្ឌគតិយុត្តិថ្នាក់ជាតិ និងការប្រព្រឹត្តិចំពោះជនរងគ្រោះជាសាក្សី ត្រូវបានយកមកប្រើប្រាស់ក្នុងការចងក្រងរបាយការណ៍នេះ។

ទោះបីមានការកែលម្អនៅក្នុងព័ត៌មានដែលរកបានក៏ដោយ តែនៅបន្តមានការប្រឈមក្នុងការបង្ហាញរូបភាពច្បាស់លាស់នៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរ។ ឧទាហរណ៍ នៅក្នុងបរិបទជាក់លាក់នៃរបាយការណ៍៖

- ព័ត៌មាននៅលើសំណុំរឿងមានការលំបាកនឹងទទួលបាន ជួនកាលដោយសារសំណុំរឿងទាំងនោះមានលក្ខណៈរសើប មិនត្រូវបានរាយការណ៍ជាសាធារណៈ ឬលាក់បាំងតាមវិធីផ្សេងទៀត។ ទោះបីអាចរកបានក៏ដោយ តែព័ត៌មានស្ដីពីសំណុំរឿងនានាមិនសូវស៊ីជម្រៅ និងមិនសូវមានគុណភាព និងកម្រមានការផ្ទៀងផ្ទាត់ដោយប្រភពឯករាជ្យ។

---

[១១] ឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស *អនុសាសន៍ស្ដីពីគោលការណ៍ និងគោលការណ៍ណែនាំ ស្ដីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស* ដែលបានដាក់ជូនក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឯកសារ អ.ស.ប E/2002/68/Add.1 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ [តទៅនេះហៅថា *គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប ប្រឆាំងការជួញដូរ*]។

[១២] គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ ការពិនិត្យថ្នាក់តំបន់ទៅលើច្បាប់ គោលនយោបាយ និងការអនុវត្តន៍ជាក់ស្ដែងនៅអាស៊ាន ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ ការគ្រប់គ្រង និងការប្រព្រឹត្តិចំពោះជនរងគ្រោះនៃការជួញដូរ ជាពិសេស ស្ត្រី និងកុមារ (ឆ្នាំ២០១៦) (“ការពិនិត្យថ្នាក់តំបន់របស់ ACWC”)។

- ព័ត៌មាន “អនុវត្តន៍” ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះត្រូវបានផ្តល់យ៉ាងទូលំទូលាយដោយមន្ត្រី និងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ។ ព័ត៌មានមិនបានស្វែងរក ឬទទួលបានពីតួអង្គ និងដៃគូសំខាន់ផ្សេងទៀត ដូចជាជនរងគ្រោះ ឬភ្នាក់ងារគាំទ្រជនរងគ្រោះ។ គេមិនអាចទទួលបានរូបភាពពេញលេញ និងត្រឹមត្រូវអំពីរបៀបដែលភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ កំពុងឆ្លើយតបទៅនឹងការជួញដូរដោយគ្មានព័ត៌មានពីប្រភពទាំងនោះ ដែលបញ្ចូលទៅក្នុងដំណើរប្រតិបត្តិការរបស់ខ្លួន ទោះបីវាមិនមែនជាផ្នែកនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ។ នោះជាការកម្រិតសំខាន់ទៅលើការយល់ដឹងនាពេលបច្ចុប្បន្នអំពីរបៀបនៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរដែលដំណើរការជាក់ស្តែងនៅក្នុងតំបន់។
- រដ្ឋសមាជិកអាស៊ានមួយចំនួនមានភាពស្ទាក់ស្ទើរក្នុងការទទួលយកបានរិះគន់ដែលអាចមាន ដោយចែករំលែកព័ត៌មានស្តីពីប្រតិបត្តិការនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិរបស់ខ្លួន។

សរុបជារួម ទិន្នន័យដែលរបាយការណ៍វឌ្ឍនភាពនេះមកយកសំអាង នៅតែមិនទាន់ពេញលេញ និងមិនទាន់ល្អឥតខ្ចោះនៅឡើយ។ ទិន្នន័យនេះមិនគួរយកមកប្រើប្រាស់ធ្វើជាមូលដ្ឋានតែមួយគត់ ដើម្បីធ្វើការសន្និដ្ឋានរឹងមាំ និងមានការបញ្ជាក់ត្រឹមត្រូវអំពីគុណភាពនៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនោះទេ។ ក៏ប៉ុន្តែ របាយការណ៍វឌ្ឍនភាពពិតជាបានលើកឡើងនូវ “ព័ត៌មានល្អបំផុតដែលអាចរកបាន” នៅក្នុងវិធីមួយដែលអនុញ្ញាតឲ្យអាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនធ្វើការសន្និដ្ឋានបឋម និងដោយប្រុងប្រយ័ត្នអំពីការអនុវត្តន៍ជាក់ស្តែងនាពេលបច្ចុប្បន្ន ព្រមទាំង ផ្តល់នូវការណែនាំនាពេលអនាគត។

## រចនាសម្ព័ន្ធនៃរបាយការណ៍វឌ្ឍនភាព

របាយការណ៍វឌ្ឍនភាព ត្រូវបានរៀបចំជាសមាសធាតុសំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរចំនួន ៧ ចំណុចរួមមាន៖

១. ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ

២. សមត្ថភាពស៊ើបអង្កេតឯកទេស

៣. សមត្ថភាពអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព

៤. សមត្ថភាពអយ្យការ និងតុលាការរឹងមាំ និងមានព័ត៌មានគ្រប់គ្រាន់ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព

៥. ការកំណត់អត្តសញ្ញាណជនរងគ្រោះឆាប់រហ័ស ត្រឹមត្រូវ និង ការផ្តល់ការការពារ និងការគាំទ្រភ្លាមៗ

៦. ការគាំទ្រពិសេសដល់ជនរងគ្រោះជាសាក្សី

៧. ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអន្តរជាតិ

ជំពូកនីមួយៗលើកឡើងនូវសមាសធាតុមួយគឺ៖ ដោយចាប់ផ្តើមដោយមានការពិនិត្យសង្ខេបទៅលើបទដ្ឋានពាក់ព័ន្ធដែលបានលេចឡើងតាមរយៈការរួមបញ្ចូលគ្នានូវច្បាប់ និងគោលនយោបាយនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ព្រមទាំងឧត្តមានុវត្តន៍ដែលត្រូវបានទទួលយក។ មានការផ្តល់អាទិភាពចំពោះបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុង *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ* ដែលជាប្រភពចម្បងនៃសិទ្ធិ និងកាតព្វកិច្ចសម្រាប់បណ្តាប្រទេសនៅក្នុងតំបន់នេះ។ ជំពូកនីមួយៗផ្តល់នូវទិដ្ឋភាពនៃវឌ្ឍនភាពនៅក្នុងតំបន់អាស៊ានឆ្ពោះ

ទៅការអនុវត្តន៍ជាក់ស្តែងនូវបទដ្ឋានទាំងនោះ ដោយមានលើកឧទាហរណ៍មកពន្យល់ផងដែរ[១៣]។ ផ្នែកចុងក្រោយនៃជំពូកនីមួយៗធ្វើការសង្ខេបអំពីឧបសគ្គធំៗ និងកាលានុវត្តភាពនានាឆ្ពោះទៅការអនុវត្តន៍ជាក់ស្តែងយ៉ាងមានប្រសិទ្ធភាពនូវសមាសធាតុពាក់ព័ន្ធ។ ជំពូកទាំងអស់បញ្ចប់ទៅដោយមានឧបសម្ព័ន្ធមួយដែលរៀបរាប់អំពីបទដ្ឋានពាក់ព័ន្ធនៅក្នុងទម្រង់ជាតារាង (“បទដ្ឋានគុណភាព”)។

[១៣] ជាទូទៅមានការបង្ហាញអត្តសញ្ញាណប្រទេសដែលលើកជាឧទាហរណ៍។ ប៉ុន្តែ នៅពេលមានបញ្ហារសើប ឬអ្នកស្រាវជ្រាវមិនអាចទទួលបានការបញ្ជាក់ជាផ្លូវការអំពីស្ថានភាព ឬព្រឹត្តិការណ៍ណាមួយ ប្រទេសពាក់ព័ន្ធនោះនឹងមិនត្រូវបានបញ្ចេញឈ្មោះទេ។

# ជំពូកទី ១៖ ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ

សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយគឺជាធាតុផ្សំមួយយ៉ាងសំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ ជំពូកនេះចាប់ផ្តើមដោយលើកឡើងនូវធាតុផ្សំសំខាន់នានានៃក្របខ័ណ្ឌនេះ ដែលត្រូវបានដកស្រង់ចេញពី *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ពិធីសារអង្គការសហប្រជាជាតិប្រឆាំងការជួញដូរ* និងការអនុវត្តន៍ជាក់ស្តែងនានាដែលត្រូវបានទទួលយកយ៉ាងទូលំទូលាយ។ បន្ទាប់មក នឹងពិចារណាអំពីវឌ្ឍនភាពនៅក្នុងតំបន់អាស៊ានឆ្ពោះទៅការសម្រេចបានទៅតាមបទដ្ឋានទាំងនេះ។ ជំពូកនេះនឹងបញ្ចប់ដោយមានការវិភាគខ្លីមួយអំពីការប្រឈម និងកាលានុវត្តភាពនាពេលអនាគត។ ឧបសម្ព័ន្ធនៃជំពូកនេះផ្តល់នូវតារាង "បញ្ជីពិនិត្យ" អំពីបទដ្ឋាននៃគុណភាពសម្រាប់ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយជុំវិញការជួញដូរមនុស្ស។

## ១.១ ធាតុផ្សំសំខាន់នៃក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ

**ការកំណត់ជាបទល្មើសឲ្យបានពេញលេញចំពោះការជួញដូរមនុស្ស** និងបទល្មើសពាក់ព័ន្ធផ្សេងទៀត ត្រូវបានទទួលស្គាល់ថាជាធាតុផ្សំមូលដ្ឋាននៃក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ ដោយផ្តល់ជាមូលដ្ឋានសម្រាប់កិច្ចខិតខំប្រឹងប្រែងនានាក្នុងគោលបំណងបញ្ចប់និទណ្ឌភាពសម្រាប់ជនជួញដូរ និងធានាផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះ។ ដើម្បីសម្រេចតាមគោលបំណងនេះ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ានពន្យល់ច្បាស់ត្រង់ចំណុចនេះថា៖ "រាល់ទម្រង់នៃការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធទាំងអស់គួរត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌជាក់លាក់ អនុលោមតាមបទដ្ឋានអន្តរជាតិជាធរមាន"[១៤]។

រដ្ឋដែលជាភាគី *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* UNTOC និងពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្សមានកាតព្វកិច្ចគតិយុត្តិជាអន្តរជាតិក្នុងការកំណត់ជាបទល្មើស នូវរាល់ទិដ្ឋភាពទាំងអស់នៃការជួញដូរមនុស្សដែលត្រូវបានកំណត់និយមន័យដោយច្បាប់អន្តរជាតិ[១៥]។ កាតព្វកិច្ចកំណត់ជាបទល្មើសនូវការជួញដូរមនុស្សក៏អាចកើតឡើងតាមរយៈកិច្ចព្រមព្រៀងគតិយុត្តិផ្សេងទៀតដែរ ដូចជាសន្ធិសញ្ញាសិទ្ធិមនុស្សជាដើម។ ការកំណត់ជា

---

[១៤] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ក.១។

[១៥] ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៥។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៥(១)។

បទល្មើសមានប្រសិទ្ធភាពអាចសម្រេចទៅបានតាមរយៈការអនុម័តច្បាប់ប្រឆាំងការជួញដូរពិសេស ឬវិសោធនកម្មចំពោះច្បាប់ដែលមានស្រាប់ ជាពិសេសជាងគេគឺក្រមព្រហ្មទណ្ឌដែលពាក់ព័ន្ធ។

នៅពេលធ្វើវិសោធនកម្មច្បាប់របស់ខ្លួន រដ្ឋពុំចាំបាច់មានកាតព្វកិច្ចបង្កើតជាថ្មីនូវនិយមន័យគតិយុត្តិជាអន្តរជាតិ ដែលស្មុគស្មាញដែលមានចែងក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និងនៅក្នុងលិខិតូករណ៍ផ្សេងទៀតទេ។ ប៉ុន្តែ ចំណុចមូលដ្ឋានមួយចំនួនរបស់**និយមន័យអាស៊ាន/និយមន័យអន្តរជាតិ**នឹងចាំបាច់ត្រូវតែបញ្ចូល ដើម្បីបំពេញទៅតាមកាតព្វកិច្ចនៃការកំណត់ជាបទល្មើស។ ច្បាប់ដែលមិនបែងចែកដាច់ពីគ្នារវាងការជួញដូរកុមារ និងការជួញដូរមនុស្សពេញវ័យសម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ ឬដែលត្រឹមតែកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការជួញដូរស្ត្រី និងកុមារ នឹងបំពេញទៅតាមបទដ្ឋានគតិយុត្តិជាអន្តរជាតិទេ។

ជាការពាក់ព័ន្ធផងដែរដែលត្រូវគូសបញ្ជាក់ នូវចំណុចសំខាន់បី នៃនិយមន័យអាស៊ាន/និយមន័យអន្តរជាតិ។ ទីមួយ និយមន័យនេះពុំតម្រូវឱ្យត្រូវកើតមានការកេងប្រវ័ញ្ចទេ៖ វាមានន័យគ្រប់គ្រាន់ដែលថា វាមានចេតនាក្នុងធ្វើអាជីវកម្ម[១៦]។ ទីពីរ "ការព្រមព្រៀង" របស់ជនរងគ្រោះមិនផ្លាស់ប្តូរការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើសទេ[១៧]។ ទីបី ការជួញដូរមនុស្សមិនតម្រូវឱ្យមានធាតុផ្សំឆ្លងដែនទេ៖ រដ្ឋត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការជួញដូរមនុស្សដែលកើតឡើងនៅក្នុងព្រំដែនរបស់ខ្លួន ព្រមទាំងការជួញដូរមនុស្សឆ្លងកាត់ព្រំដែន[១៨]។

កាតព្វកិច្ចនៃការកំណត់ជាបទល្មើសព្រហ្មទណ្ឌបានលាតសន្ធឹងទៅដល់**ការប៉ុនប៉ង** និង**ការសមគំនិត** នៅក្នុង (ការរៀបចំ ការដឹកនាំ ឬជាជនសមគំនិត) បទល្មើសជួញដូរមនុស្ស[១៩]។ លក្ខណៈនៃបាតុភូតជួញដូរមនុស្សធ្វើឱ្យវាមានភាពសំខាន់ជាពិសេសដែលថា ការទទួលខុសត្រូវចំពោះបទល្មើសជួញដូរមនុស្ស (រួមទាំង ការទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលមានចែងក្នុងច្បាប់ជាតិ) គ្របដណ្តប់ទាំងទៅលើ**រូបវន្តបុគ្គល និងនីតិបុគ្គល**[២០]។ នីតិបុគ្គលនៅក្នុងបរិបទនេះអាចបញ្ចូលក្រុមហ៊ុនពាណិជ្ជកម្ម និងសាជីវកម្មដែលប្រតិបត្តិការក្នុងវិស័យនានាដូចជា ទេសចរណ៍ ការធ្វើដំណើរ ការកំសាន្ត បដិសណ្ឋារកិច្ច ការជ្រើសរើសពលករ ការសុំកូន និងការផ្តល់សេវាសុខាភិបាលជាដើម។

ដូចបានគូសបញ្ជាក់ដោយគោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន ក្របខ័ណ្ឌគតិយុត្តិរឹងមាំនឹងសម្រេចបានហួសពីបទល្មើសជួញដូរ ដើម្បីធានាថា **បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស**ក៏ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែក និងពេញលេញដែរ។ បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សរួមមាន ទាសភាព និងសេវភាព ការងារដោយបង្ខំ ការងារដោយធ្វើអាជីវកម្ម ពលកម្មកុមារ ការធ្វើអាជីវកម្មផ្លូវភេទមនុស្ស រួមមានការធ្វើអាជីវកម្មពីអំពើពេស្យាចារចំពោះអ្នកដទៃ ការជ្រើសរើសមនុស្សដោយខុសច្បាប់ ការបញ្ចាំខ្លួនដោះបំណុល ការកេងប្រវ័ញ្ចក្នុងការងារ ការកេងប្រវ័ញ្ចផ្លូវភេទផ្នែកពាណិជ្ជកម្មទៅលើកុមារ ការបញ្ចាំខ្លួនដោះបំណុល និងអាពាហ៍ពិពាហ៍

---

[១៦] ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៣។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ២(ក)។

[១៧] ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៣។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ២(ខ)។

[១៨] UNTOC មាត្រា ៣៤(២)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ២(ជ)។

[១៩] សូមមើល UNTOC មាត្រា ៥។ ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៥(២)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៥(២)។

[២០] *UNTOC* មាត្រា ១០។

ដោយបង្ខំ[២១]។ បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សក៏រួមបញ្ចូលផងដែរនូវការបំពារបំពានដែលមានលក្ខណៈនៃវិធីសាស្ត្ររបស់ជនជួញដូរ ដូចជា ព្យសនកម្មទៅលើផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត និងការដកហូតសេរីភាពជាដើម។ បទពិសោធន៍នៅក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងទៀតបង្ហាញថា ជួនកាល ការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើបទល្មើសដែលមានការបង្កើត និងយល់ដឹងប្រសើរទាំងនេះ មានភាពងាយស្រួលជាង និងមានប្រយោជន៍ជាងបទល្មើសជួញដូរដែលស្មុគស្មាញ និងចំណាយធនធានច្រើន។

ក្របខណ្ឌគតិយុត្តិរឹងមាំនឹងផ្តល់**ការផ្តន្ទាទោស**ដែលពិចារណា និងមានសមាមាត្រទៅនឹងស្ថានទម្ងន់នៃបទល្មើស[២២]។ បទដ្ឋានអន្តរជាតិដែលត្រូវបានទទួលយកជាទូទៅសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌដែល "មានប្រសិទ្ធភាព សមាមាត្រ និងធ្វើឱ្យរៀងចាល"។ ច្បាប់អន្តរជាតិ និងក្នុងតំបន់តម្រូវថា ទណ្ឌកម្មសម្រាប់ការជួញដូរ ការផ្តន្ទាទោសឃាត់ខ្លួនដលអាចនាំឱ្យមានការធ្វើបត្យាប័ន[២៣]។ ក្នុងករណីជួញដូរពាក់ព័ន្ធនឹងនីតិបុគ្គល (ក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម អង្គការសប្បុរសធម៌ ។ល។) នីតិបុគ្គលក៏គួរស្ថិតក្រោមការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ និងមិនមែនព្រហ្មទណ្ឌដែលមានប្រសិទ្ធភាព សមាមាត្រ និងធ្វើឱ្យរៀងចាលដែរ រួមមានទណ្ឌកម្មផ្នែកហិរញ្ញវត្ថុជាដើម[២៤]។ កង្វះទណ្ឌកម្មពេញលេញអាចធ្វើឱ្យទន់ខ្សោយដល់សមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការដោះស្រាយការជួញដូរ និងអាចធ្វើឱ្យខូចខាតដល់ប្រសិទ្ធភាពនៃនីតិវិធីកិច្ចសហប្រតិបត្តិការអន្តរជាតិ ដូចជា ការធ្វើបត្យាប័នជាដើម ផ្ទុយទៅវិញ នៅក្នុងករណីមួយចំនួន ការផ្តន្ទាទោសជ្រុលពេក ឬទាបពេកអាចមិនស្របទៅនឹងលក្ខខណ្ឌនៃភាពសមាមាត្រ ទៅនឹងភាពស្មុគស្មាញនៃបទល្មើសជួញដូរ និងកម្រិតខ្ពស់នៃការសមគំនិតក្នុងចំណោមជនល្មើស។

ក្របខ័ណ្ឌគតិយុត្តិគួរបង្កើតនូវ**យុត្តាធិការ**ឱ្យបានទូលំទូលាយបំផុតតាមតែអាចធ្វើបាន ទៅលើការជួញដូរ និងបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ជម្រកសុវត្ថិភាពសម្រាប់ជនជួញដូរ ដោយធានាថាគ្រប់ផ្នែកទាំងអស់នៃបទល្មើសអាចត្រូវបានផ្តន្ទាទោសនៅពេលវាកើតឡើង។ វិធានជាមូលដ្ឋាននៅក្នុងចំណុចនេះ ដូចមានចែងនៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* និង UNTOC មានដូចខាងក្រោម[២៥]។

- រដ្ឋត្រូវបាន*តម្រូវ*ឱ្យបង្កើតយុត្តាធិការទៅលើបទល្មើសជួញដូរ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីនៃរដ្ឋនោះ ឬនៅលើនាវាដែលបង្ហូតទង់ជាតិរបស់រដ្ឋនោះ ឬនៅលើយន្តហោះដែលចុះបញ្ជីតាមច្បាប់របស់រដ្ឋនោះ (គោលការណ៍ទឹកដី)[២៦]។

---

២១ UNTOC មាត្រា ១០។

២២ UNTOC មាត្រា ១១(១)។ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ក.១។

២៣ UNTOC មាត្រា ១៦(៩)។

២៤ UNTOC មាត្រា ១០(៤)។

២៥ កត់សម្គាល់ផងដែរថា s 9 របស់ហ្វីលីពីន RA No. 9208 ចែងថា៖ "បណ្តឹងអាជ្ញាដែលកើតឡើងពីការរំលោភបំពានច្បាប់នេះត្រូវដាក់នៅពេលបទល្មើសបានប្រព្រឹត្តរួច ឬនៅពេលមានធាតុផ្សំណាមួយរបស់វាបានកើតឡើង ឬនៅពេលដែលជនរងការជួញដូរស្ថិតនៅក្នុងពេលមានការប្រព្រឹត្តិបទល្មើសដែលថា តុលាការដែលបណ្តឹងអាជ្ញាបានដាក់ពីដំបូងត្រូវមានយុត្តាធិការដកចេញពីតុលាការផ្សេងទៀត"។

២៦ UNTOC មាត្រា ១៥(១)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០(១)។

- រដ្ឋ*អាច*អនុវត្តយុត្តាធិការទៅលើបទល្មើសជួញដូរ នៅពេលដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅខាងក្រៅយុត្តាធិការទឹកដីរបស់រដ្ឋនោះប្រឆាំងនឹងជនជាតិណាម្នាក់របស់ខ្លួន (គោលការណ៍សញ្ជាតិអកម្ម)[២៧]។
- រដ្ឋ*អាច*អនុវត្តយុត្តាធិការទៅលើបទល្មើសជួញដូរ នៅពេលដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅខាងក្រៅយុត្តាធិការទឹកដីរបស់រដ្ឋនោះដោយជនជាតិណាម្នាក់របស់ខ្លួន (គោលការណ៍សញ្ជាតិ)[២៨]។
- រដ្ឋ*អាច*អនុវត្តយុត្តាធិការទៅលើបទល្មើសជួញដូរ នៅពេលដែលបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅខាងក្រៅយុត្តាធិការទឹកដីរបស់រដ្ឋនោះតែមានទំនាក់ទំនងទៅនឹងបទល្មើសធ្ងន់ធ្ងរ និងការសម្អាតប្រាក់ដែលមានផែនការប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋនោះ[២៩]។
- រដ្ឋ*ត្រូវ*បង្កើតយុត្តាធិការទៅលើបទល្មើសជួញដូរ នៅពេលដែលជនល្មើសមានវត្តមាននៅលើទឹកដីរបស់រដ្ឋនោះ ហើយរដ្ឋនោះមិនធ្វើបត្យាប័នជនល្មើសដោយមូលហេតុសញ្ជាតិ (គោលការណ៍ធ្វើ បត្យាប័ន ឬចោទប្រកាន់)[៣០]។

ការកាត់បន្ថយ ឬការលុបបំបាត់ជម្រកសុវត្ថិភាពសម្រាប់ជនជួញដូរ និងទ្រព្យសម្បត្តិរបស់ពួកគេ តម្រូវ ឲ្យមានការគាំទ្របន្ថែមផ្នែកនីតិកម្ម សម្រាប់**ជំនួយផ្នែកច្បាប់ទៅវិញទៅមក** ជាដំណើរការផ្លូវការមួយដែលជួយដល់កិច្ចសហប្រតិបត្តិការស៊ើបអង្កេត និងតុលាការឆ្លងកាត់ព្រំដែន ដើម្បីកំណត់អត្តសញ្ញាណ កំណត់ទីកន្លែង ចាប់និងផ្ទេរជនសង្ស័យ ភស្តុតាង និងព្រទ្យដែលបានពីបទល្មើស[៣១]។ អំណាចនៃ**ការធ្វើបត្យាប័ន**ពាក់ព័ន្ធនឹងបទល្មើសជួញដូរ និងបទល្មើសពាក់ព័ន្ធនឹងការជួញដូរគួរតែត្រូវបានបញ្ចូលជាក់លាក់ទៅក្នុងក្របខ័ណ្ឌគតិយុត្តិជាតិ និងនៅក្នុងលក្ខខណ្ឌយោងនៃសន្ធិសញ្ញាធ្វើបត្យាប័នដែលរដ្ឋជាភាគី[៣២]។

ទិដ្ឋភាពផ្សេងទៀតនៃក្របខ័ណ្ឌគតិយុត្តិដែលពាក់ព័ន្ធនឹងត្រូវបានលើកឡើងនៅផ្នែកផ្សេងទៀតនៃរបាយការណ៍វឌ្ឍនភាពនេះ។ ចំណុចទាំងនេះពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃ**ការការពារ និងការគាំទ្រដល់ជនរងគ្រោះ**តាមការកំណត់របស់ច្បាប់ (ជំពូកទី ៥) រួមមាន **ការទទួលបានសំណង** (ជំពូកទី ៤ និង ៦) **ការការពារតាមផ្លូវច្បាប់សម្រាប់ជនរងគ្រោះធ្វើជាសាក្សី** (ជំពូកទី ៦) និងប្រព័ន្ធសម្រាប់**កិច្ចសហប្រតិបត្តិការស៊ើបអង្កេត និងតុលាការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព** (ជំពូកទី ៧)។

---

[២៧] UNTOC មាត្រា ១៥(២)(ក)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០(២)(ក)។

[២៨] UNTOC មាត្រា ១៥(២)(ខ)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០(២)(ខ)។

[២៩] UNTOC មាត្រា ១៥(២)(គ)។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០(២)(គ)។

[៣០] UNTOC មាត្រា ១៦(១០)។ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ក.៤, វគ្គ ២ ខ.១។ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០(៣)។

[៣១] សូមមើល អាស៊ាន សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស (ការកែសម្រួលលើកទី២ អាស៊ាន ឆ្នាំ២០១៨) [តទៅនេះហៅថា សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស (ឆ្នាំ២០១៨)]។

[៣២] សូមមើលបន្ថែម សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ឆ្នាំ២០១៨។

# ១.២ ឧត្តមភាពរបស់អាស៊ានឆ្ពោះទៅកាន់ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ៖ ទិដ្ឋភាពនៃការកំណត់បទល្មើស

វដ្ឋសមាជិកអាស៊ានទាំងអស់បានបោះជំហានឆ្ពោះទៅបង្កើតក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយជុំវិញការជួញដូរមនុស្ស។ ការពិត នៅក្នុងវិស័យនេះតែម្តងដែលមានវឌ្ឍនភាពធំធេងជាងគេ។ ចំណុចនេះសំខាន់ ដោយសារក្របខ័ណ្ឌគតិយុត្តិគឺជាមូលដ្ឋានគ្រឹះ ដើម្បីស្ថាបនាគោលនយោបាយជាក់ស្តែង និងការឆ្លើយតបក្នុងប្រតិបត្តិការ។

## វឌ្ឍនភាពទាក់ទងនឹងការផ្តល់សច្ចាប័ន នៃសន្ធិសញ្ញាអន្តរជាតិសំខាន់ៗ

នៅក្នុងតំបន់អាស៊ាន មានការទទួលយក និងអនុវត្តន៍កាន់តែច្រើនឡើងនូវក្របខ័ណ្ឌគតិយុត្តិអន្តរជាតិដែលគ្រប់គ្រងការឆ្លើយតបទៅរាល់ទម្រង់នៃឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង ហើយជាពិសេសទៅទៀត ទៅនឹងការជួញដូរមនុស្ស។ នៅឆ្នាំ២០១៨ វដ្ឋសមាជិកអាស៊ានទាំង ១០ ក្លាយជាភាគីនៃ UNTOC។ វដ្ឋសមាជិកអាស៊ានចំនួន ៩ បានផ្តល់សច្ចាប័នទៅលើពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស។ ក្នុងចំណោមវដ្ឋសមាជិកអាស៊ានដែលក្លាយជាភាគីនៃពិធីសារនេះ ភាគច្រើនបានធ្វើវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការអនុវត្តន៍កាតព្វកិច្ចនានាដែលមានចែងនៅក្នុងសន្ធិសញ្ញានោះ បញ្ចូលទៅក្នុងច្បាប់ជាតិ។

ការអនុវត្តន៍ពេញលេញចំពោះកាតព្វកិច្ចនៅក្នុងសន្ធិសញ្ញាទាំងនេះ នឹងធានាថា វដ្ឋសមាជិកអាស៊ាននីមួយៗ មានហេដ្ឋារចនាសម្ព័ន្ធគតិយុត្តិចាំបាច់ ដើម្បីគាំទ្រដល់ការឆ្លើយតបនៅថ្នាក់ជាតិទៅនឹងការជួញដូរមនុស្ស ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសនេះ។

*តារាង ៣៖ ការផ្តល់សច្ចាប័នទៅលើ UNTOC ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និងអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងការជួញដូរមនុស្ស*

| វដ្ឋសមាជិកអាស៊ាន | UNTOC | ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស | អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស |
|---|---|---|---|
| ប្រ៊ុយណេ | √ | X | X |
| កម្ពុជា | √ | √ | √ |
| ឥណ្ឌូនេស៊ី | √ | √ | √ |
| ឡាវ | √ | √ | √ |
| ម៉ាឡេស៊ី | √ | √ | √ |
| មីយ៉ាន់ម៉ា | √ | √ | √ |
| ហ្វីលីពីន | √ | √ | √ |
| សិង្ហបុរី | √ | √ | √ |
| ថៃ | √ | √ | √ |
| វៀតណាម | √ | √ | √ |

## វឌ្ឍនភាពទាក់ទងនឹងកំណែទម្រង់ច្បាប់

សម្រាប់ប្រទេសភាគច្រើន ការផ្ដល់សច្ចាប័នទៅលើពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និង *អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស* តម្រូវឲ្យមានការពិនិត្យយ៉ាងលម្អិត និងយកចិត្តទុកដាក់ទៅលើច្បាប់ជាតិជាច្រើន ដើម្បីធានាឲ្យស្របគ្នាទាំងស្រុង។ នៅក្នុងតំបន់អាស៊ាន រដ្ឋសមាជិកអាស៊ានទាំងអស់បានដំណើរការពិនិត្យនេះ និងបានបង្កើតច្បាប់ប្រឆាំងការជួញដូរមនុស្សជាក់លាក់។ ប្រទេសហ្វីលីពីនជារដ្ឋសមាជិកអាស៊ានដំបូងគេដែលបានបញ្ចូលច្បាប់ប្រឆាំងការជួញដូរមនុស្សជំនាញ (ឆ្នាំ២០០៣) បន្ទាប់មកគឺប្រទេសប្រ៊ុយណេ (បទបញ្ជា) ក្នុងឆ្នាំ២០០៤ និងប្រទេសមីយ៉ាន់ម៉ាក្នុងឆ្នាំ២០០៥[៣៣]។

នៅឆ្នាំបន្ទាប់ៗមកទៀតរដ្ឋាភិបាលកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ថៃបានបញ្ចប់ការពិនិត្យដែលចំណាយពេលយូរ និងយ៉ាងលម្អិតទៅលើច្បាប់ជាតិរបស់ខ្លួនស្ដីពីការជួញដូរមនុស្ស និងបានបង្កើតច្បាប់ថ្មីស្ដីពីបញ្ហានេះ។ ប្រទេសវៀតណាមបានអនុម័តច្បាប់ថ្មីប្រឆាំងការជួញដូរមនុស្សនៅដើមឆ្នាំ២០១១ ហើយ *ច្បាប់ស្ដីពីការទប់ស្កាត់ការជួញដូរមនុស្ស*របស់សិង្ហបុរីបានចូលជាធរមានអនុវត្តន៍នៅខែមីនា ឆ្នាំ២០១៥។ ប្រទេសថៃ និងម៉ាឡេស៊ីបានកែប្រែច្បាប់របស់ខ្លួននៅឆ្នាំនោះដែរ។ នៅពេលរៀបរៀងរបាយការណ៍នេះ ប្រទេសមីយ៉ាន់ម៉ាកំពុងដំណើរការបញ្ចប់សំណៅកែប្រែនៃច្បាប់ឆ្នាំ២០០៥ របស់ខ្លួន។

ច្បាប់ប្រឆាំងការជួញដូរមនុស្សនៅថ្នាក់ជាតិភាគច្រើនក្នុងតំបន់នេះមានភាពទូលំទូលាយ៖ ដោយពង្រីកវិសាលភាពហួសពីការកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដើម្បីដោះស្រាយបញ្ហានានាដូចជា ការគាំទ្រជនរងគ្រោះ/សាក្សី និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក៏ប៉ុន្តែ ច្បាប់ជាតិមួយចំនួននៅតែផ្ដោតបែបចង្អៀតនៅឡើយ ឧទាហរណ៍ ច្បាប់ទាំងនោះមិនបានបញ្ជាក់អំពីសិទ្ធិដែលជនរងគ្រោះនៃការជួញដូរមនុស្សត្រូវទទួលបាននោះទេ។

## វឌ្ឍនភាពទាក់ទងនឹងនិយមន័យដូចគ្នានៃការជួញដូរមនុស្ស[៣៤]

ក្នុងអំឡុងពេលរៀបចំរបាយការណ៍វឌ្ឍនភាពពីមុន រដ្ឋសមាជិកអាស៊ានមួយចំនួន តែមិនទាំងអស់ទេ បានបញ្ចូលនិយមន័យនៃការជួញដូរមនុស្សទៅក្នុងច្បាប់ជាតិរបស់ខ្លួន ដែលឆ្លុះបញ្ចាំងជាទូទៅនូវនិយមន័យតាមច្បាប់អន្តរជាតិ។ សព្វថ្ងៃនេះ ដូចដែលនឹងបង្ហាញនៅក្នុងសេចក្ដីសង្ខេបខាងក្រោម និងនៅក្នុងឧបសម្ព័ន្ធ ១ គឺថា មានកម្រិតដូចគ្នាខ្ពស់ជាងមុនរវាងនិយមន័យនៅក្នុងច្បាប់ និងនិយមន័យដែលមានចែងនៅក្នុងពិធីសារប្រឆាំងការជួញដូរមនុស្ស និង*អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស*។

ផ្នែក ៤ នៃ*បទបញ្ជាស្ដីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស (ឆ្នាំ២០០៤)* របស់**ប្រទេសប្រ៊ុយណេ** បានបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពាក់ព័ន្ធនឹង "ជនណាដែលជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្ដល់ជម្រក ឬទទួលជនណាម្នាក់ ឬច្រើននាក់ក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ច តាមមធ្យោបាយមួយ ឬច្រើនដូចតទៅ៖ (ក) គំរាមកំហែង (ខ) ប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខំ (គ) ចាប់ពង្រត់ (ឃ) ក្លែងបន្លំ (ង) បោកបញ្ឆោត (ច) ប្រើប្រាស់អំណាច

---

[៣៣] សូមមើលបន្ថែម ការឆ្លើយតបរបស់អាស៊ានទៅនឹងការជួញដូរមនុស្ស (ឆ្នាំ២០០៦)។

[៣៤] ផ្នែកនេះលើកឡើងនៅក្នុង ACWC *ការពិនិត្យថ្នាក់តំបន់* (ឆ្នាំ២០០៦)។

ឬតួនាទីនៃភាពរងគ្រោះទាំងបំពាន (ឆ) ផ្តល់ ឬទទួលប្រាក់ ឬផលប្រយោជន៍ផ្សេងទៀត ដើម្បីសម្រេចឲ្យបានការព្រមព្រៀងពីជនណាម្នាក់ដែលមានអំណាចគ្រប់គ្រងទៅលើជនម្នាក់ទៀត"។ ការកេងប្រវ័ញ្ចត្រូវបានកំណត់និយមន័យអនុលោមតាម*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* ដើម្បីបញ្ចូល៖ "រាល់ទម្រង់ទាំងអស់នៃការធ្វើអាជីវកម្មផ្លូវភេទ (រួមទាំងសេវភាពផ្លូវភេទ និងការកេងប្រវ័ញ្ចចំពោះអំពើពេស្យាចាររបស់ជនម្នាក់ទៀត) ការងារដោយបង្ខំ ឬសេវាដោយបង្ខំ អំពើទាសភាព ឬទម្លាប់អនុវត្តន៍ស្រដៀងនឹងទាសភាព សេវភាព និងការកាត់យកសរីរាង្គ" ជាដើម។ ផ្នែក ៥ កំណត់នូវនិយមន័យដែលមានធាតុផ្សំចំនួនពីរ នៃការជួញដូរកុមារ ដែលស្របទៅនឹង*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស*។ ច្បាប់នេះចែងបន្ថែម នៅផ្នែក ៦ នូវបទល្មើសមួយទៀតគឺ "ការកេងប្រវ័ញ្ចចំពោះជនដែលរងការជួញដូរមនុស្ស" ដែលលេចចេញ ក្នុងគោលបំណងធានាថា បុគ្គលដែលអាចចូលរួមក្នុងការកេងប្រវ័ញ្ចចុងក្រោយ (ឧទាហរណ៍ ចៅកែផ្ទះបន ឬរោងចក្រ) ក៏នឹងទទួលខុសត្រូវព្រហ្មទណ្ឌដែរ[៣៥]។ *ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង (Cap 219)* ក៏បានបង្កើតឡើងនូវបទល្មើសជាច្រើនដែរដែលទាក់ទងនឹងការជួញដូរកុមារ និងមនុស្សវ័យក្មេង។

នៅឆ្នាំ២០០៨ **ប្រទេសកម្ពុជា**បានអនុវត្តច្បាប់ថ្មីមួយគឺ *ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ* ដើម្បីដោះស្រាយគម្លាតនៅក្នុងច្បាប់ពីមុនៗរបស់ខ្លួនស្តីពីការជួញដូរមនុស្ស។ ច្បាប់ថ្មីនេះមានបទល្មើសថ្មីៗជាច្រើន ដែលភាគច្រើនជាបទល្មើសនៃដំណើរការ ឬព្រឹត្តិការណ៍ជួញដូរធំៗ។ ពុំមានភាពច្បាស់លាស់ថាតើមានលក្ខខណ្ឌឬទេដើម្បីបង្ហាញអំពីធាតុផ្សំទាំងបីនេះនៃបទល្មើសជួញដូរមនុស្ស រួមមាន ធាតុផ្សំសំខាន់គឺ "អំពើធ្វើអាជីវកម្ម"។ ភាពមិនច្បាស់លាស់នេះបណ្តាលឲ្យមានបញ្ហានៅពេលអនុវត្តច្បាប់ថ្មីស្តីពីការជួញដូរមនុស្សរបស់ប្រទេសកម្ពុជា។ នៅឆ្នាំ២០១០ មានករណីជាច្រើនដែលច្បាប់នេះត្រូវបានយកមកប្រើប្រាស់ដើម្បីចោទប្រកាន់បុគ្គលនានាចំពោះអំពើនានាដែលមិនអាចចាត់ទុកថាជា "ការជួញដូរមនុស្ស" ទៅតាម*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* (ឧទាហរណ៍ ការសុំកូនដែលមានការព្រមព្រៀង និងមិនមែនជាការកេងប្រវ័ញ្ចចំពោះកុមារ)។ បញ្ហាទាំងនេះត្រូវបានយកមកទាញចំណាប់អារម្មណ៍ដល់មន្ត្រីពាក់ព័ន្ធ ហើយបន្ទាប់មកក្រសួងយុត្តិធម៌បានចេញគោលការណ៍ណែនាំអនុវត្តដោយបញ្ជាក់ថា ខុសពីនិយមន័យដែលមានធាតុផ្សំចំនួនបីរបស់*ពិធីសារ*៖

> *ច្បាប់ [ឆ្នាំ២០០៨] ... មានគោលបំណងបែងចែករវាងអំពើទាំងនេះជាបទល្មើសផ្សេងៗគ្នា៖ ហេតុនេះជំពូកទី ២ នៃច្បាប់នេះខុសពីបទល្មើសនៃការវះកាត់យកសរីរាង្គដោយខុសច្បាប់ ការជ្រើសរើសមនុស្សដោយខុសច្បាប់ ការលក់ ការទិញ ឬការដូរមនុស្ស ការដឹកជញ្ជូនជនរងគ្រោះនៃការជួញដូរមនុស្ស និងការទទួលជនរងគ្រោះពីការជួញដូរមនុស្ស។ ច្បាប់នេះចែងដោយឡែកពីជំហានីមួយៗនៃនិយមន័យនៃការជួញដូរមនុស្សនៅក្នុងពិធីសារ Palermo ដោយចែងឲ្យមានបទល្មើសខុសៗគ្នា និងការផ្តន្ទាទោសខុសៗគ្នា[៣៦]។*

---

[៣៥] នៅឆ្នាំ២០១២ សំណុំរឿងដំបូងដែលត្រូវបានចោទប្រកាន់ទៅតាមបទបញ្ញានេះពាក់ព័ន្ធនឹងអ្នកធ្វើការតាមផ្ទះដែលរងការបំពានរាងកាយដោយចៅកែរបស់ខ្លួន។ តុលាការកំពូលបានច្រានចោលសំណុំរឿងនោះថាមិនមែនជាបទល្មើសជួញដូរមនុស្សទេ ដោយសំអាងថា "ការធ្វើអាជីវកម្ម" ត្រូវតែកើតឡើងចាប់តាំងពីដំណាក់កាលដំបូងមកនៅពេលជនរងគ្រោះត្រូវបានជើសរើស។ នៅក្នុងសំណុំរឿងនេះ ទោះបីមានការធ្វើអាជីវកម្មជាក្រោយក៏ដោយ តែការជ្រើសរើសមិនមែនធ្វើអាជីវកម្មត្រូវបានសន្និដ្ឋានថាមិនពេញលេញដើម្បីបង្ហាញថាជាបទល្មើសជួញដូរមនុស្សនោះទេ។

[៣៦] កំណត់ពន្យល់សម្រាប់ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។

ច្បាប់លេខ ២១ ក្នុងឆ្នាំ ២០០៧ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស របស់**ប្រទេសឥណ្ឌូនេស៊ី**បានកំណត់និយមន័យនៃការជួញដូរមនុស្សថាជា៖

> *... អំពើនានានៃការជ្រើសរើស ដឹកជញ្ជូន ផ្តល់ជម្រក ឬទទួលជនណាម្នាក់ តាមមធ្យោបាយគំរាមកំហែង ឬបំពានដោយប្រើកម្លាំង ចាប់ជម្រិត ការចាក់សោរឃុំក្នុងបន្ទប់ ការក្លែងបន្លំ ការបំភាន់ ការប្រើប្រាស់អំណាចដោយបំពាន ឬការបំពានលើតួនាទីដែលងាយរងគ្រោះ ការបញ្ចាំខ្លួនដោះបំណុល ឬដើម្បីផ្តល់ប្រាក់ ឬផលប្រយោជន៍ ដើម្បីទទួលបានការព្រមព្រៀងពីជនដែលគ្រប់គ្រងជនផ្សេងទៀតដែលបានលើកឡើង ទោះបីជាបានប្រព្រឹត្តនៅក្នុងប្រទេសក្តី ឬឆ្លងដែនក្តី ដោយមានចេតនាធ្វើអាជីវកម្ម ឬបណ្តាលឲ្យមានការធ្វើអាជីវកម្មលើមនុស្សផ្សេងទៀត។*

ទោះបីការបង្កើតនិយមន័យនេះខុសពីបន្តិចបន្តួចទៅនឹងនិយមន័យដែលបានលើកឡើងនៅក្នុង*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* និង *អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* វាពិតជាបង្កើតនូវធាតុផ្សំចំនួនបីនៃអំពើនេះ សកម្មភាព មធ្យោបាយ និងគោលបំណង។ ច្បាប់នេះមិនបានចែងច្បាស់ ពាក់ព័ន្ធនឹងមធ្យោបាយនានាដែលចាំបាច់ នៅក្នុងសំណុំរឿងជួញដូរកុមារទេ។

*ច្បាប់ព្រហ្មទណ្ឌ*របស់**ប្រទេសឡាវ** (ឆ្នាំ២០០៥) បានកំណត់ជាបទល្មើសនូវការជួញដូរមនុស្ស ដែលត្រូវបានកំណត់និយមន័យថាជា "ការជ្រើសរើស ការផ្លាស់ទីកន្លែង ការផ្ទេរ ការផ្តល់ជម្រក ឬការទទួលជនណាម្នាក់នៅក្នុងប្រទេស ឬឆ្លងកាត់ព្រំដែន តាមមធ្យោបាយក្លែងបន្លំ គំរាមកំហែង ប្រើកម្លាំង ការបញ្ចាំខ្លួនដោះបំណុល ឬតាមមធ្យោបាយផ្សេងទៀត [និងការប្រើប្រាស់ជននោះនៅក្នុង] ការងារដោយបង្ខំ អំពើពេស្យាចារ រូបភាពអាសអាភាស ឬរូបភាពអ្វីផ្សេងទៀតដែលប្រឆាំងនឹងប្រពៃណីដ៏ល្អរបស់ជាតិ ឬការកាត់យកសរីរាង្គកាយជាច្រើន ឬក្នុងគោលបំណងខុសច្បាប់ផ្សេងទៀត" (មាត្រា ១៣៤)។ វិសោធនកម្មឆ្នាំ២០០៦ បានហាមឃាត់នូវរាល់ទម្រង់នៃការជួញដូរមនុស្សទាំងអស់ និងមានចែងអំពីទោសទណ្ឌចំពោះពិរុទ្ធជនជួញដូរ។ ជាងនេះទៀត ការជួញដូរស្ត្រី និងកុមារត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុង*ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារស្ត្រី (ឆ្នាំ២០០៤)* ដែលប្រើប្រាស់និយមន័យដូចគ្នានៃការជួញដូរមនុស្សដែលមានចែងនៅក្នុង*ក្រមព្រហ្មទណ្ឌ* ដោយមានភាពខុសគ្នាមួយចំនួន តែមិនអនុវត្តចំពោះការជួញដូរបុរសទេ។ ច្បាប់ទាំងពីរកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការប្រព្រឹត្តិជាជនសមគំនិតចំពោះបទល្មើសជួញដូរមនុស្ស។ នាពេលថ្មីៗនេះ រដ្ឋាភិបាលប្រទេសឡាវបានអនុម័ត*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០១៥)* ដែលកំណត់អំពីនិយមន័យមួយនៃការជួញដូរមនុស្ស ដែលស្របទៅនឹងនិយមន័យអន្តរជាតិ។

ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ឆ្នាំ២០០៧ របស់**ប្រទេសម៉ាឡេស៊ី** (ច្បាប់លេខ៦៧០ ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០១០ និងចុងក្រោយតាមរយៈច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (វិសោធនកម្ម) ឆ្នាំ២០១៥) កំណត់ជាបទល្មើសនូវការជួញដូរ និងបានកំណត់និយមន័យរបស់វាជាទូទៅអនុលោមតាមនិយមន័យបីផ្នែកដែលមានចែងនៅក្នុងពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស (សកម្មភាព មធ្យោបាយ និងគោលបំណង)។ និយមន័យនេះបញ្ជាក់អំពីភាពមិនពាក់ព័ន្ធនៃការព្រមព្រៀង និងកត់សម្គាល់បន្ថែមនូវភាពមិនពាក់ព័ន្ធនៃការផ្លាស់ទីកន្លែង ដើម្បីបង្ហាញជាបទល្មើសជួញដូរមនុស្សទេ។ ធាតុផ្សំទីបីនៃនិយមន័យនេះគឺ ការធ្វើអាជីវកម្ម ត្រូវបានកំណត់និយមន័យថា "រាល់ទម្រង់ទាំងអស់នៃការធ្វើអាជីវកម្មផ្លូវភេទ ការងារដោយបង្ខំ ឬសេវាកម្មដោយបង្ខំ អំពើទាសភាព ឬការអនុវត្តន៍ជាក់ស្តែងស្រដៀងនឹងអំពើទាសភាព សេវភាព សកម្មភាពខុសច្បាប់នានា ឬ ការកាត់យកសរីរាង្គមនុស្ស"។

*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៥)* របស់**ប្រទេសមីយ៉ាន់ម៉ា** ជាទូទៅធ្វើទៅតាមនិយមន័យបីផ្នែករបស់ *ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* ដែលមានការកែប្រែតិចតួច។ ច្បាប់នេះកំណត់និយមន័យការជួញដូរមនុស្សថាជា "ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការលក់ ការទិញ ការឲ្យខ្ចី ការជួល ការផ្តល់ជម្រក ឬការទទួលមនុស្សក្រោយពេលប្រព្រឹត្ត ... ការគំរាមកំហែង ការប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខំ ការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការប្រើប្រាស់អំណាច ឬតួនាទីនៃភាពងាយរងគ្រោះដោយបំពាន និងការផ្តល់ ឬការទទួលប្រាក់កម្រៃដើម្បីទទួលបានការព្រមព្រៀងពីជនម្នាក់ទៀត ក្នុងគោលបំណងធ្វើអាជីវកម្មទៅលើជនណាម្នាក់ដោយមាន ឬគ្មានការព្រមព្រៀងពីជននោះ"។ ការកេងប្រវ័ញ្ចត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់អនុលោមតាម *ពិធីសារ*។ ច្បាប់នេះមិនមាននិយមន័យដោយឡែកចំពោះការជួញដូរកុមារទេ។ នាពេលបច្ចុប្បន្ន ប្រទេសមីយ៉ាន់ម៉ាកំពុងពិនិត្យទៅលើច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ខ្លួន។

នៅឆ្នាំ២០១២ **ប្រទេសហ្វីលីពីន**បានអនុម័តច្បាប់ RA លេខ. ១០៣៦៤ ដែលគេហៅម្យ៉ាងទៀតថាជា *ច្បាប់ពង្រីកវិសាលភាពប្រឆាំងការជួញដូរមនុស្សឆ្នាំ២០១២*។ ច្បាប់ដែលបានធ្វើវិសោធនកម្មនេះបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើនានាដូចជា **ការទទួល ការជួល ការផ្តល់ ការឲ្យ ការផ្ទេរ ការរក្សាទុក និងការស្នើ**។ ច្បាប់នេះក៏បានកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើនានាដែលបង្កើតជាការប៉ុនប៉ងជួញដូរមនុស្ស និងបានកំណត់ពីការទទួលខុសត្រូវរបស់ជនសមគំនិត និងចារីបន្ទាប់បន្សំដែរ។ ច្បាប់នេះបានបង្កើតជាទោសទណ្ឌចំពោះការប្រើជនដែលរងការជួញដូរមនុស្សពី "ការបម្រើសេវាសហគមន៍រយៈពេល ៦ ខែ និងពិន័យជាប្រាក់ចំនួន ៥០.០០០ ប៉េសូ" រហូតដល់ "ជាប់ពន្ធនាគារពី ៦ ឆ្នាំ ដល់ ១២ ឆ្នាំ និងរងការពិន័យជាប្រាក់ចាប់ពី ៥០.០០០ ប៉េសូ រហូតដល់ ១០០.០០០ ប៉េសូ"។

*ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស(ឆ្នាំ២០១៤)* របស់**ប្រទេសសិង្ហបុរី** (PHT Act) បានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការជួញដូរមនុស្សដោយចម្លងនូវនិយមន័យនៃ "ការជួញដូរមនុស្ស" ដែលមានចែងនៅក្នុងពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និង*អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស*។ ផ្នែក ៣ នៃច្បាប់ PHT Act មានចែងដូចខាងក្រោម៖

> *ជនណាជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់ជម្រក ឬទទួលបុគ្គលណាម្នាក់ (ក្រៅពីកុមារ) តាមមធ្យោបាយ (ក) គំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ (ខ) ការចាប់ពង្រត់ (គ) ការក្លែងបន្លំ ឬការបោកបញ្ឆោត (ឃ) ការប្រើប្រាស់អំណាចទាំងបំពាន (ង) ការប្រើប្រាស់តួនាទីនៃភាពងាយរងគ្រោះរបស់បុគ្គលនោះ ឬ (ច) ការផ្តល់ ឬការទទួលពីជនម្នាក់ទៀតដែលគ្រប់គ្រងទៅលើបុគ្គលនោះ នូវលុយកាក់ ឬផលប្រយោជន៍ផ្សេងទៀត ដើម្បីធានាថា មានការព្រមព្រៀងពីជនម្នាក់ទៀត ក្នុងគោលបំណងធ្វើអាជីវកម្ម (ទោះបីនៅក្នុងប្រទេសសិង្ហបុរី ឬនៅទីកន្លែងផ្សេងទៀត) ទៅលើបុគ្គលនោះ ត្រូវមានពិរុទ្ធពីបទល្មើស។*

និយមន័យនេះរួមមានធាតុផ្សំនីមួយៗក្នុងចំណោមធាតុផ្សំទាំងបីដែលមានចែងនៅក្នុង*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* (សកម្មភាព មធ្យោបាយ និងគោលបំណង) សម្រាប់ជនរងគ្រោះជាមនុស្សពេញវ័យ។ ផ្នែកពាក់ព័ន្ធក៏ធ្វើតាម*ពិធីសារ*ដែរ ក្នុងការបង្ហាញថា ចាំបាច់ត្រូវមានធាតុផ្សំតែពីរទេ (សកម្មភាព និងគោលបំណង) ដើម្បីបង្ហាញពីបទល្មើសជួញដូរកុមារ។ និយមន័យនេះក៏បានបញ្ជាក់បន្ថែមពីភាពមិនពាក់ព័ន្ធនៃការព្រមព្រៀង នៅពេលមានមធ្យោបាយដែលមានចែងក្នុងច្បាប់ត្រូវបានយកមកប្រើប្រាស់។ ជាការសំខាន់គឺថា ច្បាប់ស្តីពីជួញដូរមនុស្សរបស់ប្រទេសសិង្ហបុរី ក៏បានបញ្ចូលនិយមន័យនៃទស្សនាទានសំខាន់ដែលបានប្រើប្រាស់នៅក្នុងនិយមន័យការជួញដូរមនុស្សដែរ។

ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ប្រទេសថៃ**បច្ចុប្បន្នត្រូវបានអនុម័តនៅឆ្នាំ២០០៨ ហើយនាពេលថ្មីៗនេះត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០១៥។ និយមន័យការជួញដូរដែលមានចែងនៅក្នុង*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* មានលំនាំស្របយ៉ាងជិតស្និទ្ធទៅនឹងនិយមន័យដែលមានធាតុផ្សំបីរបស់*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* តែមានភាពខុសគ្នាតែនៅក្នុងធាតុផ្សំ នៃគោលបំណងប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងធាតុផ្សំ "ការកេងប្រវ័ញ្ច" ត្រូវបានកំណត់ថាជា "ការស្វែងរកផលប្រយោជន៍ពីអំពើពេស្យាចារ ការផលិត និងការចែកចាយសម្ភារៈអាសអាភាស ទម្រង់ផ្សេងទៀតនៃការធ្វើអាជីវកម្មផ្លូវភេទ អំពើទាសភាព ការដែលធ្វើឲ្យជនម្នាក់ទៀតក្លាយជាអ្នកសុំទាន ការងារដោយបង្ខំ ឬសេវាកម្មដោយបង្ខំ ការកាត់យកសរីរាង្គដោយបង្ខំក្នុងគោលបំណងជួញដូរ ឬការអនុវត្តន៍ជាក់ស្តែងស្រដៀងគ្នាផ្សេងទៀតដែលបណ្តាលឲ្យមានការជំរិតដោយបង្ខំ ដោយមិនគិតដល់ការព្រមព្រៀងរបស់ជននោះឡើយ"។ ភាពខុសគ្នាសំខាន់ៗជាមួយ*ពិធីសារ*នៅក្នុងចំណុចនេះគឺថា៖ ការបញ្ចូលទម្រង់បន្ថែមនៃការធ្វើអាជីវកម្ម (រូបភាពអាសអាភាស ការដែលធ្វើឲ្យជនម្នាក់ទៀតក្លាយជាអ្នកសុំទាន ការអនុវត្តន៍ជាក់ស្តែងដែលបណ្តាលឲ្យមានការជំរិតដោយបង្ខំ) ការលុបចោលនូវទម្រង់មួយចំនួន (ការអនុវត្តន៍ជាក់ស្តែងស្រដៀងអំពើទាសភាព សេវភាព) ការបញ្ចូលច្បាស់លាស់នូវធាតុផ្សំមធ្យោបាយនៅក្នុងទម្រង់មួយចំនួន (ការកាត់យកសរីរាង្គ ការអនុវត្តន៍ជាក់ស្តែងដែលបណ្តាលឲ្យមានការជំរិតដោយបង្ខំ) និងការបញ្ចូលបទប្បញ្ញត្តិស្តីពីការព្រមព្រៀង ("ដោយមិនគិតដល់ការព្រមព្រៀង") នៅក្នុងធាតុផ្សំនៃការធ្វើអាជីវកម្ម ជាជាងភ្ជាប់ទៅនឹងធាតុផ្សំ "សកម្មភាព"។ ក្រៅពីនេះ ឃ្លារួម "ឬការអនុវត្តន៍ជាក់ស្តែងស្រដៀងគ្នាផ្សេងទៀតដែលបណ្តាលឲ្យមានការជំរិតដោយបង្ខំ" ត្រូវបានយកមកប្រើជំនួស "រួមមាន"។

*ច្បាប់ដែលបានធ្វើវិសោធនកម្ម*បានចូលជាធរមានចាប់តាំងពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ មកម្ល៉េះ។ *ច្បាប់នីតិវិធីព្រហ្មទណ្ឌប្រឆាំងការជួញដូរមនុស្ស*ត្រូវបានអនុម័ត និងចុះផ្សាយនៅក្នុងរាជកិច្ចនៅខែមិថុនា ឆ្នាំ២០១៦ ហើយនាពេលនេះបានចូលជាធរមានឡើយ។ គួរកត់សម្គាល់ថា ការផ្លាស់ប្តូរទាំងនេះមិនប៉ះពាល់ដល់និយមន័យការជួញដូរមនុស្សនៅក្នុងច្បាប់ឆ្នាំ២០០៨ ទេ។ ក៏ប៉ុន្តែ បច្ចុប្បន្នគេកំពុងធ្វើការសិក្សាទៅលើនិយមន័យកាន់តែទូលំទូលាយនៃពាក្យសំខាន់មួយចំនួន រួមមាន "ការងារដោយបង្ខំ" និង "ទាសភាពបំណុល"។

*ក្រមព្រហ្មទណ្ឌ*នៅប្រទេស**វៀតណាម** ដែលកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការជួញដូរមនុស្ស ត្រូវបានធ្វើវិសោធនកម្មលើកដំបូងនៅឆ្នាំ២០០៩ ហើយបន្ថែមទៀតនាពេលថ្មីៗនេះនៅឆ្នាំ២០១៥។ វិសោធនកម្មទាំងនេះត្រូវបានធ្វើឡើងដើម្បីលើកឡើងនូវផលវិបាកមួយចំនួនដែលកើតឡើងពាក់ព័ន្ធនឹងច្បាប់ឯកទេសថ្មីស្តីពីការជួញដូរមនុស្ស របស់វៀតណាម ដែលនឹងពិភាក្សាបន្ថែមទៀតនៅខាងក្រោម។ ជាលើកដំបូង *ក្រមព្រហ្មទណ្ឌ (ឆ្នាំ១៩៩៩)* បានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការជួញដូរទៅលើស្ត្រី និងកុមារ។ វិសោធនកម្មដែលបានចូលជាធរមាននៅឆ្នាំ២០០៩ បានពង្រីកបទល្មើសចំពោះ "ការជួញដូរមនុស្ស"។ វិសោធនកម្មឆ្នាំ២០១៥ បានបន្ថែមបទប្បញ្ញត្តិស្តីពីបទល្មើសជួញដូរមនុស្សដោយពិពណ៌នាការជួញដូរមនុស្ស ជាពិសេសរៀបរាប់ថាជាអំពើនានាដែលត្រូវបានចាត់ទុកថាជាការជួញដូរស្របទៅនឹងនិយមន័យដែលមានចែងនៅក្នុង*ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ*។ ក៏ប៉ុន្តែ *ក្រមព្រហ្មទណ្ឌ (ឆ្នាំ២០១៥)* កំណត់និយមន័យការជួញដូរមនុស្សជាន័យទូលាយជាង*ពិធីសារ*។ ហេតុនេះ ឥរិយាបថនៃការផ្ទេរ ឬទទួលមនុស្សសម្រាប់ប្រគល់ ឬទទួលប្រាក់ ទ្រព្យសម្បត្តិ ឬផលប្រយោជន៍ជាសម្ភារៈផ្សេងទៀត ដោយមាន ឬគ្មានគោលបំណងធ្វើអាជីវកម្ម ត្រូវផ្តន្ទាទោសជាការជួញដូរមនុស្សអនុលោមទៅតាម*ក្រមព្រហ្មទណ្ឌ*។ វិសោធនកម្មចំពោះ*ក្រមព្រហ្មទណ្ឌ*ចំណុចទាំងនេះបានចូលជាធរមាននៅខែមករា ឆ្នាំ២០១៨។

មាត្រា ៣ នៃ *ច្បាប់ស្ដីពីការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០១១)* របស់**ប្រទេសវៀតណាម** មិនបានកំណត់និយមន័យការជួញដូរមនុស្សទេ គ្រាន់តែរៀបរាប់នូវ "អំពើត្រូវបានហាមឃាត់" មួយចំនួនដែលរួមមាន "ការជួញដូរមនុស្សដូចមានចែងនៅក្នុង ... ក្រមព្រហ្មទណ្ឌ" និង "ការជ្រើសរើស ការដឹកជញ្ជូន ការផ្ដល់ជម្រក ការផ្ទេរ ឬការទទួលមនុស្សសម្រាប់គោលបំណងធ្វើអាជីវកម្មផ្លូវភេទ ការងារដោយបង្ខំ ការកាត់យកសរីរាង្គ ឬ "គោលបំណងយ៉ាងអមនុស្សធម៌ផ្សេងទៀត"។ ទោះបីពុំមានធាតុផ្សំ "មធ្យោបាយ" ត្រូវបានរៀបរាប់បញ្ចូលទៅក្នុងបទប្បញ្ញត្តិនៃ "អំពើត្រូវបានហាមឃាត់" ក៏ដោយ តែនិយមន័យដែលបានផ្ដល់សម្រាប់ការធ្វើអាជីវកម្មផ្លូវភេទ និងការងារដោយបង្ខំបានបញ្ចូលធាតុផ្សំកម្លាំង និងការបង្ខិតបង្ខំ (មាត្រា ២)។ ក៏ប៉ុន្តែ ហាក់ដូចជាពុំមានតម្រូវឲ្យមានកម្លាំង ការបង្ខិតបង្ខំ ឬមធ្យោបាយផ្សេងទៀតសម្រាប់អំពើកាត់យកសរីរាង្គ ឬ សម្រាប់ "គោលបំណងយ៉ាងអមនុស្សធម៌" ផ្សេងទៀតទេ ដែលពុំមានកំណត់ជានិយមន័យឡើយ។ ជាងនេះទៀត ពុំមានចែងអំពីទោសទណ្ឌចំពោះ "អំពើត្រូវបានហាមឃាត់" ទាំងនេះ ឬចំនួន ១០ ផ្សេងទៀតដែលបញ្ចូល "ការរើសអើងមកលើជនរងគ្រោះ" និងការបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងជនរងគ្រោះទេ។

## វឌ្ឍនភាពទាក់ទងនឹងការគ្របដណ្ដប់ទៅលើបទល្មើសដែលពាក់ព័ន្ធ

ក្របខ័ណ្ឌគតិយុត្តិជាធរមាន ជុំវិញការជួញដូរមនុស្សជាទូទៅមានភាពទូលំទូលាយជាងច្បាប់ឯកទេសផ្នែកជួញដូរមនុស្ស។ ឧទាហរណ៍ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ បទល្មើសមួយចំនួនពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដូចជា អំពើទាសភាព ការវាយប្រហារ ការវាយប្រហារផ្លូវភេទ អំពើពេស្យាចារដោយបង្ខំ ពលកម្មកុមារ និងការធ្វើអាជីវកម្មផ្លូវភេទទៅលើកុមារត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា និងយ៉ាងពេញលេញ ដែលផ្ដល់ជាមូលដ្ឋានបន្ថែម និងផ្សេងទៀតសម្រាប់ការចោទប្រកាន់ពីបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ច្បាប់ការងារចែងនូវការការពារសំខាន់ៗយ៉ាងហោចណាស់សម្រាប់ក្រុមជនរងគ្រោះនៃការជួញដូរមនុស្សមួយចំនួន គឺអ្នកដែលធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ ដែលជាអកុសល ពួកគេអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងការការពារទាំងនេះ។ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ ក្រមព្រហ្មទណ្ឌហាមឃាត់ និងដាក់ទោសចំពោះអំពើជាច្រើនដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងច្បាប់ជុំវិញការការពារកុមារដែលចែង បន្ថែមនូវមូលដ្ឋានសម្រាប់ចោទប្រកាន់ជនកេងប្រវ័ញ្ច និងការការពារជនរងគ្រោះ។

**អំពើទាសភាព**គឺជាបទល្មើសព្រហ្មទណ្ឌនៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន (**ប្រទេសប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ**)។ លើកលែងតែប្រទេសហ្វីលីពីន ទោះបី "អំពើទាសភាព" មិនត្រូវបានកំណត់និយន័យក្នុងច្បាប់ព្រហ្មទណ្ឌទាំងនេះក្ដី តែមានការរំពឹងថា បទល្មើសព្រហ្មទណ្ឌនេះឆ្លុះបញ្ចាំងជាទូទៅនូវនិយមន័យនៃអំពើទាសភាពនៅក្នុង*អនុសញ្ញាបង្ក្រាបជំនួញទាសករ និងអំពើទាសភាព* ឆ្នាំ១៩២៦ ដែលចែងថា ៖ "អំពើទាសភាពគឺជាឋានៈ ឬលក្ខខណ្ឌរបស់មនុស្សម្នាក់ដែលស្ថិតក្រោមអំណាចទាំងអស់ផ្សេងទៀត ដែលភ្ជាប់ទៅនឹងសិទ្ធិនៃភាពជាម្ចាស់កម្មសិទ្ធិដែលត្រូវបានគេយកមកអនុវត្ត"[៣៧]។ សាលាក្ដីអន្តរជាតិ និងតុលាការជាតិបានទទួលស្គាល់ថា និយមន័យនេះបញ្ចូលយ៉ាងហោចណាស់នូវទម្រង់មួយចំនួននៃការជួញដូរមនុស្ស។ គេអាចនិយាយបានថា អំពើទាសភាពនឹងក្លាយជាបទ

[៣៧] *អនុសញ្ញាបង្ក្រាបជំនួញទាសករ និងអំពើទាសភាព* ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩២៦ 60 LNTS 253 ចូលជាធរមាននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩២៧ មាត្រា ១(១)។

ល្មើសសំខាន់មួយទៀតនាពេលអនាគត ដោយសារទម្រង់ធ្ងន់ធ្ងរមួយចំនួននៃការជួញដូរមនុស្សត្រូវបានចាត់ទុកថាស្រប ទៅនឹងលក្ខណៈវិនិច្ឆ័យបន្ថែមដ៏ខ្ពស់នេះ[៣៨]។

អំពើ**ការងារដោយបង្ខំ** (ដោយមិនគិតដល់ថាតើ វាជាផ្នែកនៃដំណើរការជួញដូរមនុស្ស ឬយ៉ាងណា) មិនត្រូវបាន កំណត់ជាបទល្មើសព្រហ្មទណ្ឌយ៉ាងទូលំទូលាយទេ។ **ប្រទេសកម្ពុជា សិង្ហបុរី ថៃ** និង**វៀតណាម** មានច្បាប់ដែល ហាមឃាត់ ឬកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការងារដោយបង្ខំ។ ក៏ប៉ុន្តែ ទោះបីការងារដោយបង្ខំត្រូវបានហាម ឃាត់ក៏ដោយ តែទោសទណ្ឌដែលយកមកប្រើប្រាស់ មានកម្រិតទាបពេកបើធៀបទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនេះ។ ចំណុចនេះអាចបង្កើតឲ្យមានការភាន់ច្រឡំ ជាពិសេសនៅពេល *ការជួញដូរមនុស្ស*សម្រាប់បទល្មើសការងារដោយបង្ខំ អាចនាំឲ្យមានទោសទណ្ឌធ្ងន់ធ្ងរ។ ឧទាហរណ៍ នៅក្នុងច្បាប់ចម្បងស្តីពីការជួញដូរមនុស្សរបស់**កម្ពុជា** គឺ*ច្បាប់ស្តីពី ការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ* "ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេង ប្រវ័ញ្ច"[៣៩] (ដែលគ្របដណ្តប់ទៅលើការជ្រើសរើសសម្រាប់ការងារដោយបង្ខំ) បណ្តាលឲ្យមានទោសទណ្ឌជាប់ ពន្ធនាគារយ៉ាងហោចពី ៧ ឆ្នាំរហូតដល់ ២០ ឆ្នាំ។ ផ្ទុយទៅវិញ បទល្មើសនៅក្នុងច្បាប់ការងារ ការជួលមនុស្សឲ្យធ្វើ ការដើម្បីដោះបំណុល (ស្ថានភាពដែលបង្កើតជាទាសភាពបំណុល) បែរជាទទួលរងការផាកពិន័យបន្តិចបន្តួចទៅ វិញ[៤០]។ នៅ**ប្រទេសវៀតណាម** *ក្រមព្រហ្មទណ្ឌ*បានហាមឃាត់ការជួញដូរមនុស្ស និងការងារដោយបង្ខំ ហើយ*ក្រម ការងារ* បានហាមឃាត់ដោយឡែកនូវការប្រើប្រាស់ការងារដោយបង្ខំ និងការធ្វើបាបដល់កម្មករ។ បទល្មើសនៅក្នុង *ក្រមព្រហ្មទណ្ឌ*នាំឲ្យមានទោសទណ្ឌធ្ងន់ធ្ងរជាងបទល្មើសនៅក្នុង*ក្រមការងារ* (ដែលត្រឹមតែអនុវត្តចំពោះនិយោជិត ជាប់កិច្ចសន្យាប៉ុណ្ណោះ ដោយមិនបានចែងពីការការពារចំពោះកម្មករនៅក្នុងវិស័យនានាដែលផ្តល់ការងារមិនផ្លូវការ តាមរយៈកិច្ចសន្យាជាលាយលក្ខណ៍អក្សរ)។ ឧទាហរណ៍ទាំងនេះ និងឧទាហរណ៍ផ្សេងទៀតបង្ហាញពីតម្រូវការចាំ បាច់ចំពោះ រដ្ឋសមាជិកអាស៊ានមួយចំនួនដើម្បីធានាថា ច្បាប់ថ្មីៗស្តីពីការជួញដូរមនុស្សគួរតែស៊ីសង្វាក់ទៅនឹងច្បាប់ ពាក់ព័ន្ធនានា រួមទាំងស្តីពីស្តីពីការងារដោយបង្ខំផងដែរ។

ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើនបានបញ្ចូលបទល្មើសបន្ទាប់បន្សំនានា ជាជំនួយដល់បទល្មើសជួញដូរ មនុស្ស ដូចជាការសម្រួល ឬបានទទួលប្រយោជន៍ពីបទល្មើសជួញដូរ។ ឧទាហរណ៍ ច្បាប់ស្តីពីការជួញដូរមនុស្សរបស់ **ប្រទេសម៉ាឡេស៊ី** (មាត្រា ៦៧០) កំណត់ជាបទល្មើសព្រហ្មទណ្ឌនូវ "ការផ្តល់ការសម្ភារៈបរិក្ខារ" និង "ការផ្តល់សេវា" សម្រាប់គោលបំណងនៃការជួញដូរមនុស្ស និងការធ្វើឯកសារធ្វើដំណើរ ឬឯកសារអត្តសញ្ញាណក្លែងក្លាយក្នុងគោល បំណងនៃការជួញដូរមនុស្ស[៤១]។ ស្រដៀងគ្នាដែរ *ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស ឆ្នាំ២០១៤* របស់**ប្រទេសសិង្ហបុរី**

---

[៣៨] នៅឆ្នាំ២០០៧ ប្រវត្តិគតិយុត្តិត្រូវបានបង្កើតឡើងនៅ**ប្រទេសថៃ** នៅពេលដែលច្បាប់ប្រឆាំងអំពើទាសភាពរបស់ប្រទេសនោះត្រូវបានយក មកអនុវត្តជាលើកដំបូងប្រឆាំងនឹងជនជាតិថៃមួយរូបដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៧ ឆ្នាំពីបទធ្វើឲ្យកុមារថៃម្នាក់ទៅជា ទាសករ។ សារព័ត៌មានក្នុងស្រុកបានរាយការណ៍ថា ជនល្មើសបានទទួលការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៣ ឆ្នាំកន្លះបន្ថែមទៀត ចំពោះការបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរទៅលើឈ្នួលបម្រើរបស់គាត់ដែលមិនគ្រប់អាយុ និង បានបង្គាប់ឲ្យបង់ប្រាក់ពិន័យចំនួន ២០០.០០០ បាតទៅឲ្យជនរងគ្រោះជាការជួសជុលសំណង។ Sanitsuda Ekachai "ការបញ្ចាំមនុស្សដោះបំណុល" នៅក្នុង *កាសែតបាងកកប៉ុស្តិ៍* ចុះ ផ្សាយ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៧។

[៣៩] ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នស/រកម/០២០៨/០០៥ (ឆ្នាំ២០០៨) (កម្ពុជា) មាត្រា ១២។

[៤០] *ច្បាប់ការងារ* (ឆ្នាំ២០០៧) (កម្ពុជា) មាត្រា ១៦, ៣៧០។

[៤១] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (ច្បាប់លេខ ៦៧០) (ម៉ាឡេស៊ី) ផ្នែក ២០, ២១ និង ១៨។

បានចែងថា ជនណាម្នាក់នឹងមានពិរុទ្ធភាពពីបទជំរុញឲ្យមានបទល្មើសជួញដូរមនុស្ស ប្រសិនបើជននោះផ្តល់ការណែនាំដល់ជនម្នាក់ទៀតឲ្យប្រព្រឹត្តបទល្មើស ឬ ផ្តល់ ឬ រៀបចំទម្រង់នានានៃការផ្តល់ប្រាក់កាស ការដឹកជញ្ជូន ជម្រក ទីកន្លែងស្នាក់នៅ ឬមធ្យោបាយផ្សេងទៀត ដោយមានចេតនាសម្រួលដល់ការជួញដូរមនុស្ស។ បទល្មើសបន្ទាប់បន្សំទាំងនេះមានសារៈសំខាន់ ដោយសារវាអនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះជនដែលជួយ ឬគាំទ្រដល់បទល្មើសជួញដូរមនុស្ស។ បទល្មើសបន្ទាប់បន្សំស្រដៀងគ្នាក៏ត្រូវបានរកឃើញផងដែរនៅក្នុងច្បាប់**កម្ពុជា ហ្វីលីពីន** និង**ថៃ**។

## វឌ្ឍនភាពទាក់ទងនឹងការកំណត់ជាបទល្មើសព្រហ្មទណ្ឌនៃការសម្អាតប្រាក់នៅក្នុងសំណុំរឿងជួញដូរមនុស្ស

*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* តម្រូវឲ្យរដ្ឋភាគីត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការសម្អាតទ្រព្យដែលបានមកពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង រួមមាន ការជួញដូរមនុស្សជាដើម[៤២]។ ក្របខ័ណ្ឌគតិរបស់រដ្ឋសមាជិកអាស៊ានជាច្រើន គាំទ្រដល់ការចោទប្រកាន់នូវបទល្មើសសម្អាតប្រាក់ដែលពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស។ នៅ**ប្រទេសឡាវ** ការជួញដូរមនុស្សត្រូវបានបញ្ជាក់ច្បាស់ថាជាបទល្មើសមួយដែលយក*ក្រឹត្យស្តីពីការសម្អាតប្រាក់* យកមកអនុវត្ត។ នៅ**ប្រទេសថៃ** *ច្បាប់ប្រឆាំងការជួញដូរមនុស្ស ព.ស ២៥៥១* (ឆ្នាំ២០០៨) បានចែងជាពិសេសថា រាល់បទល្មើសសំខាន់ៗទាំងអស់នៅក្រោយច្បាប់នោះគឺជាបទល្មើសនានានៅក្រោម*ច្បាប់ប្រឆាំងការសម្អាតប្រាក់ ព.ស ២៥៤២* (ឆ្នាំ១៩៩៩)[៤៣]។ នៅឆ្នាំ២០១៥ ថៃបានធ្វើវិសោធនកម្មច្បាប់ប្រឆាំងការលាងលុយរបស់ខ្លួនដើម្បីអាចឲ្យមន្ត្រីប្រឆាំងការលាងលុយធ្វើការបង្កកទ្រព្យសម្បត្តិ ដោយមានដីកាពីតុលាការក្នុងអំឡុងពេលស៊ើបអង្កេតការជួញដូរមនុស្ស និងផ្តល់ផ្នែកណាមួយនៃទ្រព្យសម្បត្តិដែលត្រូវបានចាប់យកធ្វើជាការជួសជុលសំណងដល់ជនរងគ្រោះ។ **ប្រទេសកម្ពុជា**បានអនុម័តនូវបទល្មើសសម្អាតប្រាក់ជាទ្រង់ទ្រាយធំដែលអាចអនុវត្តចំពោះបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សភាគច្រើន[៤៤]។ នៅ**ប្រទេសហ្វីលីពីន** *ច្បាប់ប្រឆាំងការសម្អាតប្រាក់ឆ្នាំ២០០១* ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់សាធារណរដ្ឋលេខ ១០៦៣៥ នៅឆ្នាំ២០១៣ ដើម្បីបញ្ចូលការជួញដូរមនុស្សជាបទល្មើសសំខាន់។

នៅ**ប្រទេសម៉ាឡេស៊ី** *ច្បាប់ប្រឆាំងសកម្មភាពសម្អាតប្រាក់ ប្រឆាំងសកម្មភាពផ្តល់ហិរញ្ញវត្ថុ និងទ្រព្យដល់ភេរវកម្មដោយខុសច្បាប់ឆ្នាំ២០០១* [ច្បាប់លេខ ៦១៣] អនុវត្តចំពោះបទល្មើសធ្ងន់ធ្ងរនានា បទល្មើសធ្ងន់ធ្ងរនៅបរទេស ឬសកម្មភាពខុសច្បាប់នៅបរទេស[៤៥]។ និយមន័យនៃពាក្យទាំងនេះយោងទៅបញ្ជីបទល្មើសធ្ងន់ធ្ងរដែលបញ្ចូលនៅក្នុង

---

[៤២] អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៧។

[៤៣] ច្បាប់ប្រឆាំងការជួញដូរមនុស្ស ព.ស ២៥៥១ (ឆ្នាំ២០០៨) (ថៃ) ផ្នែក ១៤។

[៤៤] នៅកម្ពុជា មាត្រា ៤៤៨ នៃ*ក្រមព្រហ្មទណ្ឌ*បានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការសម្អាតប្រាក់។ បទប្បញ្ញត្តិនោះមុនបានរៀបរាប់ជាក់លាក់នូវបទល្មើសសំខាន់ទេ តែគ្រាន់តែចែងថា វាជាអំពើខុសច្បាប់ដែលលាក់បំពួន លាក់បាំង ឬវិនិយោគទៅលើផលិតផលដោយផ្ទាល់ ឬដោយប្រយោលជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម ក្នុងគោលបំណង "ផ្តល់ការគាំទ្រ" ដល់ក្រុមឧក្រិដ្ឋជន។

[៤៥] ច្បាប់ប្រឆាំងសកម្មភាពសម្អាតប្រាក់ ប្រឆាំងសកម្មភាពផ្តល់ហិរញ្ញវត្ថុ និងទ្រព្យដល់ភេរវកម្មដោយខុសច្បាប់ឆ្នាំ២០០១ (ច្បាប់លេខ ៦១៣) (ម៉ាឡេស៊ី) ផ្នែក ២។

បញ្ជីឯកសារបន្ថែមនៃច្បាប់នោះ។ នាពេលថ្មីៗនេះ បទល្មើសជួញដូរមនុស្សថ្មីៗរបស់ម៉ាឡេស៊ីត្រូវបានបញ្ចូលទៅក្នុងបញ្ជីឯកសារបន្ថែមនោះដែរ។

នៅ**ឥណ្ឌូនេស៊ី** *ច្បាប់ពាក់ព័ន្ធនឹងការទប់ស្កាត់ និងការលុបបំបាត់ឧក្រិដ្ឋកម្មសម្អាតប្រាក់* (ច្បាប់លេខ ៨ ឆ្នាំ២០១០ នៅត្រង់មាត្រា ២ ចំណុច ១) ចែងថា ការជួញដូរមនុស្សជាបទល្មើសសំខាន់[៤៦]។

នៅ**ប្រទេសមីយ៉ាន់ម៉ា** បទល្មើស "ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មផ្លូវភេទ រួមមានការធ្វើអាជីវកម្មផ្លូវភេទទៅលើកុមារ ត្រូវបានបញ្ចូលជាពិសេសទៅក្នុងបញ្ជីបទល្មើសសំខាន់នៅក្រោម*ច្បាប់ប្រឆាំងការសម្អាតប្រាក់*[៤៧]។ ទោះបីការជួញដូរមិនត្រូវបានរួមបញ្ចូលជាពិសេសក៏ដោយ តែបញ្ជីបទល្មើសបានបញ្ចូល "ការប្រព្រឹត្តបទល្មើសនានាដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារអប្បបរមាចាប់ពីមួយឆ្នាំឡើងទៅ អនុលោមតាមច្បាប់រដ្ឋជាធរមាន" ដែលនឹងបញ្ចូលការជួញដូរមនុស្សនេះ។

នៅ**ប្រទេសសិង្ហបុរី** បទល្មើសជួញដូរមនុស្ស នៅក្រោមច្បាប់ស្តីពីការជួញដូរមនុស្សរបស់សិង្ហបុរីត្រូវបានរៀបរាប់ជាបទល្មើសធ្ងន់ធ្ងរនៅក្រោម *ច្បាប់ស្តីពីអំពើពុករលួយ ការជួញដូរគ្រឿងញៀន និងបទល្មើសធ្ងន់ធ្ងរផ្សេងទៀត (ការរឹបអូសជាប្រយោជន៍)*។ បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សផ្សេងទៀតនៅក្រោមធម្មនុញ្ញស្តីពីស្ត្រី និងក្រមព្រហ្មទណ្ឌក៏ត្រូវបានចាត់ទុកជាបទល្មើសធ្ងន់ធ្ងរដែរ។ ចំណុចនេះមានន័យថា អាជ្ញាធរអាចទទួលបានបញ្ជាឲ្យរឹបអូសនូវប្រយោជន៍ដែលបានមកពីអំពើព្រហ្មទណ្ឌពាក់ព័ន្ធនឹងបទល្មើសទាំងនេះ។

នៅ**ប្រទេសវៀតណាម** អនុលោមតាមមាត្រា ៣២៣ នៃ*ក្រមព្រហ្មទណ្ឌ* ការផ្តល់ឲ្យស្របច្បាប់នូវប្រាក់កាស និងទ្រព្យសម្បត្តិដែលទទួលបានតាមរយៈការប្រព្រឹត្តិបទល្មើសនានា ឬប្រើប្រាស់ប្រាក់កាលនោះ និង/ឬ ទ្រព្យសម្បត្តិដើម្បីដំណើរការសកម្មភាពពាណិជ្ជកម្ម ឬ សកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត តាមរយៈប្រតិបត្តិការហិរញ្ញវត្ថុ និង/ឬ វិស័យធនាគារ ឬ ប្រតិបត្តិការផ្សេងទៀត។ ក៏ប៉ុន្តែ ដូចបានកត់សម្គាល់ខាងលើ មិនទាន់មានភាពច្បាស់លាស់ថាតើច្បាប់របស់វៀតណាមគ្របដណ្តប់ទៅលើធាតុផ្សំទាំងអស់នៃដំណើរការជួញដូរ ដូចមានកំណត់នៅក្នុងពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ ឬយ៉ាងណានោះទេ។

## វឌ្ឍនភាពទាក់ទងនឹងច្បាប់ដែលសម្រួលដល់ការស្វែងរកទ្រព្យដែលបានពីបទល្មើស

ក្របខ័ណ្ឌគតិយុត្តិរឹងមាំជុំវិញការជួញដូរនឹងគាំទ្រដល់ការកំណត់អត្តសញ្ញាណយ៉ាងមានប្រសិទ្ធភាព និងការចាប់យកទ្រព្យដែលបានពីបទល្មើសជួញដូរ។ ចំណុចនេះតម្រូវឲ្យច្បាប់ត្រូវឆ្លើយតបទៅតាមជំហាននានាដូចខាងក្រោមនៅក្នុងដំណើរការស្វែងរកប្រាក់កាសទាំងនោះ៖

- ទីមួយ ទ្រព្យដែលបានពីបទល្មើសត្រូវធ្វើការតាមដាន និងកំណត់អត្តសញ្ញាណ

[៤៦] ច្បាប់ពាក់ព័ន្ធនឹងការទប់ស្កាត់ និងការលប់បំបាត់ឧក្រិដ្ឋកម្មសម្អាតប្រាក់ (ច្បាប់លេខ ៨ ឆ្នាំ២០១០) (ឥណ្ឌូនេស៊ី) មាត្រា ២ ចំណុច (១L)។

[៤៧] *ច្បាប់ប្រឆាំងការសម្អាតប្រាក់* (ច្បាប់លេខ ១១/២០១៤) (មីយ៉ាន់ម៉ា)។

- នៅពេលរកឃើញ ទ្រព្យទាំងនេះនឹងត្រូវបានបង្កកភ្លាម (ប្រសិនបើជាប្រាក់ ឬវត្ថុដាក់ធានា) ឬ ត្រូវចាប់យក (ប្រសិនបើជាទ្រព្យជាក់ស្តែង) ដើម្បីបញ្ចៀសនូវការជំលៀសចេញ ឬការដកចេញនៅទ្រព្យទាំងនោះ
- ជាទូទៅចំនុចនេះនឹងត្រូវបានអនុវត្តតាមច្បាប់រយៈពេលវែង និងដំណើរការតាមលំដាប់លំដោយនៃទ្រព្យដែលបានរឹបអូសពីបទល្មើស
- នៅពេលដែលជំហានទាំងនេះត្រូវបានប្រកាន់យកជាផ្នែកនៃដំណើរការសហប្រតិបត្តិការអន្តរជាតិ អាចប្រកាន់យកជំហានផ្សេងទៀតពាក់ព័ន្ធនឹងការបញ្ជូនទ្រព្យសម្បត្តិត្រឡប់ទៅកាន់ប្រទេសដាក់សំណើ[៤៨]។

*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* តម្រូវឲ្យរដ្ឋភាគីត្រូវអនុម័តយកវិធានការចាំបាច់ដើម្បីជួយឲ្យពួកគេអាចធ្វើអត្តសញ្ញាណ តាមដាន បង្កក រឹបអូស និងចាប់យកនូវៈ (១) ទ្រព្យដែលបានពីបទល្មើសជួញដូរ ឬទ្រព្យសម្បត្តិដែលមានតម្លៃស្របទៅនឹងតម្លៃនៃប្រាក់កាសនេះ និង (២) ទ្រព្យសម្បត្តិ បរិក្ខា ឬមធ្យោបាយផ្សេងទៀតដែលបានប្រើប្រាស់ ឬកំណត់ឲ្យប្រើប្រាស់នៅក្នុងបទល្មើសនានាដែលគ្របដណ្តប់ដោយអនុសញ្ញានេះ[៤៩]។

រដ្ឋសមាជិកអាស៊ានភាគច្រើនមានច្បាប់ដែលគ្របដណ្តប់ទៅលើទិដ្ឋភាព *មួយចំនួន*នៃការស្វែងរកទ្រព្យបានមកពីបទល្មើស ទាំងជាផ្នែកនៃនីតិវិធីព្រហ្មទណ្ឌ តាមរយៈច្បាប់នៃការសម្អាតប្រាក់ ឬជាផ្នែកពិសេសនៅក្រោមច្បាប់ស្តីពីការជួញដូរមនុស្សថ្នាក់ជាតិ។ ឧទាហរណ៍ ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ឥណ្ឌូនេស៊ី**បានចែងជាពិសេសថា អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងចៅក្រម "ត្រូវមានសិទ្ធិអំណាចចេញបញ្ជាដល់អ្នកផ្តល់សេវាផ្នែកហិរញ្ញវត្ថុនានាធ្វើការរឹបអូសទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ជនដែលរងការសង្ស័យ ឬត្រូវបានចោទប្រកាន់ពីអំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស"[៥០]។

ទោះជាយ៉ាងណាក្តី ជាទូទៅ ក្របខ័ណ្ឌគតិយុត្តិជាធរមានពុំពេញលេញទេ។ ឧទាហរណ៍ ច្បាប់ស្តីពីការជួញដូរមនុស្សនៅ**កម្ពុជា**ចែងឲ្យរឹបអូសប្រាក់កាសបានមកពីបទល្មើសជួញដូរ បន្ទាប់ពីមានការផ្តន្ទាទោស តែមិនបានចែងនូវបទប្បញ្ញត្តិនានាសម្រាប់ការបង្ក ឬរឹបអូសមុននឹងទៅដល់ចំណុចនេះទេ។ វិធានការសម្រាប់ការបង្កក ឬរឹបអូសមុនពេលផ្តន្ទាទោសមានចែងនៅក្នុងច្បាប់ប្រឆាំងការសម្អាតប្រាក់ តែមានតែកិច្ចដំណើរការនីតិវិធីចំពោះបទល្មើសសម្អាតប្រាក់ប៉ុណ្ណោះ។ ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ម៉ាឡេស៊ី** (ផ្នែក ៣៦) ចែងឲ្យមានការបាត់បង់សិទ្ធិគ្រប់គ្រងលើវត្ថុនានាដែលរឹបអូសបាន ក្នុងអំឡុងពេលអនុវត្តដីកាឆែកឆេរ ទោះបីគាត់ត្រូវបានផ្តន្ទាទោស ឬមិនផ្តន្ទាទោសក៏ដោយ តែមិនបង្កក រឹបអូស និងការបាត់បង់សិទ្ធិលើទ្រព្យផ្សេងទៀតបានពីបទល្មើសនោះឡើយ។ *ច្បាប់ប្រឆាំងសកម្មភាពសម្អាតប្រាក់ប្រឆាំងសកម្មភាពផ្តល់ហិរញ្ញវត្ថុ និងលុយកាក់ដល់ភេរវកម្មដោយខុសច្បាប់ឆ្នាំ២០០១* [ច្បាប់លេខ ៦១៣] របស់ម៉ាឡេស៊ី បានអនុញ្ញាតបន្ថែមទៀត ឲ្យធ្វើការបង្កក ចាប់យក និងការបាត់បង់សិទ្ធិគ្រប់គ្រងលើទ្រព្យ តែនៅកិច្ចដំណើរ

---

[៤៨] សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការច្បាប់អន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទំព័រ ៩២។

[៤៩] អនុសញ្ញាអ៊ាសានប្រឆាំងការជួញដូរមនុស្ស មាត្រា ១៧។

[៥០] ការបកប្រែក្រៅផ្លូវការ ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស (ឥណ្ឌូនេស៊ី) មាត្រា ៣២។

ការនីតិវិធីសម្រាប់បទល្មើសសម្អាតប្រាក់ប៉ុណ្ណោះ[៥១]។ ច្បាប់ស្តីពីការជួញដូរមនុស្សបច្ចុប្បន្ននៅ**ប្រទេសមីយ៉ាន់ម៉ា** មិនបានចែងអំពីដំណើរការកំណត់អត្តសញ្ញាណ បង្កក ឬចាប់យក ឬរឹបអូសទ្រព្យផ្សេងទៀតបានពីបទល្មើសទេ។

## វឌ្ឍនភាពពាក់ព័ន្ធនឹងការអនុវត្តចំពោះការជួញដូរមនុស្សនៅក្រៅដែនដី[៥២]

ការអះអាងដោយរដ្ឋសមាជិកអាស៊ានអំពីយុត្តាធិការ ទៅលើការប្រព្រឹត្តិការជួញដូរមនុស្ស ដែលកើតឡើងនៅក្រៅដែនដីរបស់ខ្លួន ជាការសំខាន់ដែលត្រូវអនុញ្ញាតឱ្យភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌជាតិធ្វើការចោទប្រកាន់នូវសំណុំរឿងឆ្លងដែន ដែលកើតឡើងមួយផ្នែកនៅក្នុងយុត្តាធិការរបស់ខ្លួន (ឧទាហរណ៍ នៅពេលការជ្រើសរើសបានធ្វើឡើងនៅក្នុងរដ្ឋសមាជិកអាស៊ានមួយ តែការធ្វើអាជីវកម្មជាក់ស្តែងធ្វើឡើងនៅក្នុងរដ្ឋសមាជិកអាស៊ានមួយទៀត)។ ដំណើរការនេះក៏ជួយសម្រួលដល់សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន នៅពេលដែលរដ្ឋស្នើសុំមានច្បាប់ដែលចែងឱ្យមានការពង្រីកវិសាលភាពយុត្តាធិការនៅក្នុងកាលៈទេសៈជាច្រើន និងមានលក្ខខណ្ឌតម្រូវនៃបទល្មើសព្រហ្មទណ្ឌទ្វេ។

បទប្បញ្ញត្តិស្តីពីការធ្វើបត្យាប័ននៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* ត្រូវបានតាក់តែងឡើងជាពិសេសដើម្បីបំពេញបន្ថែមបទប្បញ្ញត្តិស្តីពីការធ្វើបត្យាប័ននៅក្នុងច្បាប់ជាតិ។ អនុសញ្ញា*តម្រូវ*ឱ្យរដ្ឋភាគីត្រូវបង្កើតយុត្តាធិការទៅលើសំណុំរឿងជួញដូរមនុស្ស៖

- នៅពេលបទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីរបស់រដ្ឋភាគី ឬនៅលើនាវាដែលបង្ហូតទង់ជាតិរបស់រដ្ឋភាគីនោះ (ដូចជានាវានេសាទជាដើម) ឬ នៅលើយន្តហោះដែលឈ្មោះបញ្ជីនៅក្នុងរដ្ឋភាគីនោះ
- នៅពេលជនល្មើសដែលរងការចោទប្រកាន់ មានវត្តមាននៅលើទឹកដី ហើយរដ្ឋភាគីមិនធ្វើបត្យាប័នជននោះដោយផ្អែកតែទៅលើមូលហេតុតែមួយគត់គឺថា ជននោះមានសញ្ជាតិរបស់រដ្ឋខ្លួន

រដ្ឋភាគីនៃអនុសញ្ញា*អាច* បង្កើតយុត្តាធិការទៅលសំណុំរឿងជួញដូរមនុស្ស៖

- នៅពេលបទល្មើសជួញដូរមនុស្សត្រូវបានប្រព្រឹត្តមកលើជនជាតិនៃរដ្ឋភាគីនោះ
- នៅពេលបទល្មើសជួញដូរមនុស្សត្រូវបានប្រព្រឹត្ត*ដោយ*ជនជាតិនៃរដ្ឋភាគីនោះ
- នៅពេលដែលបទល្មើសជួញដូរមនុស្សត្រូវបានប្រព្រឹត្តនៅក្រៅទឹកដីនៃ ដែលមានការប្រព្រឹត្តិនូវបទល្មើសធ្ងន់ធ្ងរមួយនៅលើទឹកដី រួមមានការលាងលុយកាក់ដែលបានមកពីការជួញដូរមនុស្ស[៥៣]។

នៅក្នុងតំបន់អាស៊ាន រដ្ឋសមាជិកអាស៊ានជាច្រើន រួមមាន **ប្រទេសប្រ៊ុយណេ កម្ពុជា ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន** និង**ថៃ** បានបញ្ចូលបទប្បញ្ញត្តិជាក់លាក់ស្តីពីយុត្តាធិការនៅក្នុងច្បាប់ជួញដូរមនុស្សរបស់ខ្លួន ដើម្បីធានាថា បទ

---

[៥១] ច្បាប់ប្រឆាំងសកម្មភាពសម្អាតប្រាក់ ប្រឆាំងសកម្មភាពផ្តល់ហិរញ្ញវត្ថុ និងទ្រព្យដល់ភេរវកម្មដោយខុសច្បាប់ឆ្នាំ២០០១ (ច្បាប់លេខ ៦១៣) (ម៉ាឡេស៊ី) ផ្នែក ៤៤(១), ៤៥(១), ៥០(១), ៥១(១), ៥៥(១)។

[៥២] សម្រាប់ព័ត៌មានបន្ថែមស្តីពីទិដ្ឋភាពនេះ សូមមើល ជំពូកទី ៧ និង *សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស* (សូមមើលការកែសម្រួលលើកទីពីរ ឆ្នាំ២០១៨)។

[៥៣] អនុសញ្ញាអ៊ាសានប្រឆាំងការជួញដូរមនុស្ស មាត្រា ១០។

ប្បញ្ញត្តិទាំងនេះអាចអនុវត្តក្រៅទឹកដីនៅក្នុងកាលៈទេសៈមួយចំនួនបាន។ ឧទាហរណ៍ ផ្នែក ១១ នៃ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស*របស់**ថៃ** បានចែងឲ្យមានយុត្តាធិការសាកល មានន័យថា ជនណាក៏ដោយដែលប្រព្រឹត្តបទល្មើសជួញដូរមនុស្សនៅក្នុង ឬខាងក្រៅប្រទេសថៃត្រូវទទួលខុសត្រូវចំពោះទោសទណ្ឌនៅក្នុងប្រទេសថៃក្រោមច្បាប់នេះ។ ផ្នែក ៤ នៃ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧)* [ច្បាប់លេខ ៦៧០] របស់ **ម៉ាឡេស៊ី** ចែងថា បទល្មើសនានានៅក្នុងច្បាប់នោះមានការអនុវត្តន៍នៅក្រៅទឹកដី ដើម្បីបញ្ចូលចំណុចនានាដូចជា បទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋម៉ាឡេស៊ី និងអ្នកស្នាក់នៅអចិន្ត្រៃយ៍ជាជនជាតិម៉ាឡេស៊ីនៅទីកន្លែងផ្សេងទៀតខាងក្រៅ ឬឆ្ងាយពីដែនកំណត់របស់ម៉ាឡេស៊ី (ជំពូកទី ១៧)។ នៅ**ប្រទេសឡាវ** និង**វៀតណាម** *ក្រមព្រហ្មទណ្ឌ* បានបញ្ចូលបទប្បញ្ញត្តិដែលហាក់ដូចជាអនុញ្ញាតឲ្យធ្វើការចោទប្រកាន់ចំពោះការជួញដូរមនុស្ស ឬ ការប្រព្រឹត្តិពាក់ព័ន្ធនឹងការជួញដូរមនុស្សនៅខាងក្រៅទឹកដី នៅក្នុងកាលៈទេសៈមួយចំនួនបាន[៥៤]។ ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**សិង្ហបុរី** ចែងថា បទល្មើសជួញដូរមនុស្ស ត្រូវបានប្រព្រឹត្ត ដោយមិនគិតដល់ថាតើជាការជួញដូរមនុស្សដែលបានធ្វើឡើងមួយផ្នែកនៅក្នុង និងមួយផ្នែកនៅខាងក្រៅប្រទេសសិង្ហបុរីទេ ដោយហេតុថា អំពើនឹងបង្កើតជាបទល្មើសជួញដូរមនុស្ស ប្រសិនបើប្រព្រឹត្តិទាំងស្រុងនៅក្នុងប្រទេសសិង្ហបុរី[៥៥]។

ពុំមានបទប្បញ្ញត្តិណាមួយដែលនឹងអនុញ្ញាតឲ្យអនុវត្តក្រៅទឹកដី ទៅលើបទល្មើសជួញដូរមនុស្សនៅក្នុងច្បាប់ជាតិរបស់**ឥណ្ឌូនេស៊ី**ទេ។ ចំណុចនេះកម្រិតសមត្ថភាពរបស់ឥណ្ឌូនេស៊ីក្នុងការចោទប្រកាន់អំពើដែលបានប្រព្រឹត្តពីយុត្តាធិការមួយទៅយុត្តាធិការមួយទៀត ឬដោយពលរដ្ឋរបស់ខ្លួននៅខាងក្រៅទឹកដីរបស់ខ្លួន។ ក៏ប៉ុន្តែ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា មាត្រា ៥ នៃ *ក្រមព្រហ្មទណ្ឌ* ឥណ្ឌូនេស៊ីពិតជាជួយដល់អាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌឥណ្ឌូនេស៊ី ក្នុងការចោទប្រកាន់ពលរដ្ឋដែលបានប្រព្រឹត្តបទល្មើសជួញដូរមនុស្សនៅខាងក្រៅឥណ្ឌូនេស៊ីដែរ។

## វឌ្ឍនភាពទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ និងនីតិបុគ្គលផ្សេងទៀត

អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ការចូលរួមរបស់ស្ថាប័នឯកជនដូចជា ក្រុមហ៊ុន សមាគមន៍ និងនីតិបុគ្គលផ្សេងទៀតទៅក្នុងការជួញដូរមនុស្សមានការរៀបចំជាឯកសារត្រឹមត្រូវ។ នៅក្នុងរដ្ឋសមាជិកអាស៊ាន ការជួញដូរមនុស្ស និងការងារដោយបង្ខំត្រូវបានរកឃើញនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់នៃក្រុមហ៊ុននេសាទ ព្រមទាំងរោងចក្រផលិតសម្លៀកបំពាក់ និងគ្រឿងអេឡិចត្រូនិក[៥៦]។ មានការត្រួតពិនិត្យកាន់តែច្រើនឡើងៗទៅលើការធ្វើអាជីវកម្មនៅក្នុង "ការងារខ្សែចង្វាក់ផ្គត់ផ្គង់"៖ បណ្តាញទីភ្នាក់ងារ និងក្រុមហ៊ុនដែលរៀបចំការជ្រើសរើសពលករទេសន្តរប្រវេសន៍សម្រាប់ការងារនៅក្នុង និងខាងក្រៅតំបន់[៥៧]។

---

៥៤ *ក្រមព្រហ្មទណ្ឌ* (ឡាវ) មាត្រា ៤។ *ក្រមព្រហ្មទណ្ឌ* (វៀតណាម) មាត្រា ៦(១)។ *ក្រមព្រហ្មទណ្ឌ* (សិង្ហបុរី) មាត្រា ៣។

៥៥ ច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរមនុស្សឆ្នាំ២០១៤ (សិង្ហបុរី) ផ្នែក ៣។

៥៦ សូមមើលឧទាហរណ៍ Verite ការងារដោយបង្ខំនៅក្នុងការផលិតគ្រឿងអេឡិចត្រូនិកនៅម៉ាឡេស៊ី (ឆ្នាំ២០១៥)។ អង្គការពលកម្មអន្តរជាតិ ការអនុវត្តន៍ជាក់ស្តែងផ្នែកការងារ និងលក្ខខណ្ឌធ្វើការនៅក្នុងវិស័យនេសាទថៃ (ឆ្នាំ២០១៣)។

៥៧ សូមមើលឧទាហរណ៍ អង្គការពលកម្មអន្តរជាតិ ការកំណត់បទបញ្ញត្តទៅលើការជ្រើសរើសពលករដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងជំរុញការធ្វើចំណាកស្រុកយ៉ាងត្រឹមត្រូវ (ឆ្នាំ២០១៥)។

ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្ស តម្រូវថា ក្រុមហ៊ុន និងនីតិបុគ្គលផ្សេងទៀតត្រូវទទួលខុសត្រូវចំពោះការធ្វើអាជីវកម្មទៅលើបុគ្គលដែលស្ថិតក្រោមសិទ្ធិអំណាច និងការគ្រប់គ្រងរបស់ខ្លួន។ *អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្សមនុស្ស* មិនបានចែងជាក់លាក់ទៅលើទិដ្ឋភាពនេះទេ។ ក៏ប៉ុន្តែ រដ្ឋសមាជិកអាស៊ានដែលជាភាគីនៃ *អនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង* និង *ពិធីសារប្រឆាំងការជួញដូរមនុស្ស* តម្រូវឱ្យធានាថា ការកំណត់ជាបទល្មើសព្រហ្មទណ្ឌត្រូវបានពង្រីកទៅដល់ស្ថាប័នឯកជនដូចជាសាជីវកម្មជាដើម[៥៨]។

បើទោះបីជាមិនទាន់មានភាពស្របគ្នានៅទូទាំងរដ្ឋសមាជិកអាស៊ានទាំងអស់ក៏ដោយ តែនាពេលនេះ ច្បាប់ពាក់ព័ន្ធនៅក្នុងប្រទេសជាច្រើនរួមមាន **ប្រទេសប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី** និង**ថៃ** បានអនុវត្តការជួញដូរមនុស្សដែលត្រូវបានប្រព្រឹត្តនៅក្រោម ការគ្រប់គ្រងរបស់ក្រុមហ៊ុន សមាគម អង្គការសប្បុរសធម៌ និងនីតិបុគ្គលផ្សេងទៀតផងដែរ។ ឧទាហរណ៍ *ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៣* របស់**ប្រទេសហ្វីលីពីន**ចែងថា ប្រសិនបើជនល្មើសជាមនុស្សនៅក្នុងសាជីវកម្ម ក្រុមហ៊ុនដៃគូ ក្លឹប អាគារ ឬមន្ត្រីតុលាការ ទោសព្រហ្មទណ្ឌត្រូវដាក់ទៅលើម្ចាស់ ប្រធាន ដៃគូ អ្នកគ្រប់គ្រង និង/ឬមន្ត្រីទទួលខុសត្រូវផ្សេងទៀតដែលបានចូលរួមក្នុងការប្រព្រឹត្តិបទល្មើស ឬអ្នកដែលបានអនុញ្ញាតដោយបានដឹង ឬមិនបានទប់ស្កាត់មិនឱ្យបទល្មើសនោះកើតឡើង[៥៩]។ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស(ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* របស់**ប្រទេសថៃ** (ផ្នែក ៥៣) មានបទប្បញ្ញត្តិ ស្រដៀងគ្នា។

ច្បាប់ជួញដូរមនុស្សឆ្នាំ២០០៧ របស់**ប្រទេសម៉ាឡេស៊ី**គ្រាន់តែយោងទៅ "ជនណាក៏ដោយ" ដែលជួញដូរមនុស្សក្នុងគោលបំណងធ្វើអាជីវកម្ម។ ក៏ប៉ុន្តែ ការបកស្រាយច្បាប់បញ្ជាក់ថា "ជនណាក៏ដោយ" អាចបញ្ចូលនីតិបុគ្គលផងដែរ[៦០]។ *ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស(ឆ្នាំ២០១៤)* របស់**ប្រទេសសិង្ហបុរី**បានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការជួញដូរមនុស្ស ហើយអំពើចូលដៃប្រព្រឹត្តដោយ "ជនណាក៏ដោយ" និង ផ្នែក ២ នៃ *ច្បាប់ស្ដីពីការបកស្រាយច្បាប់*របស់សិង្ហបុរីកំណត់ជាក់លាក់ថា "ជន" រួមមានក្រុមហ៊ុន ឬសមាគម ឬក្រុមមនុស្ស សាជីវកម្ម ឬមិនមែនជាក្រុម[៦១]។ នៅ**ប្រទេសប្រ៊ុយណេ** បទបញ្ជាប្រឆាំងការជួញដូរមនុស្ស ចែងថា មន្ត្រី/ដៃគូនៃក្រុមហ៊ុន សង្គម ឬស្ថាប័នផ្សេងទៀត "ត្រូវចាត់ទុកថាមានពិរុទ្ធភាពនៃបទល្មើសនេះ លុះត្រាតែបង្ហាញថា បទល្មើសនោះត្រូវបានប្រព្រឹត្តដោយគ្មានការព្រមព្រៀង ឬសមគំនិត ហើយថា គាត់បានចាត់វិធានការទាំងអស់យ៉ាងយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការប្រព្រឹត្តិបទល្មើសទៅតាមអ្វីដែលគាត់គួរធ្វើ ដោយពិចារណាទៅលើលក្ខណៈនៃមុខងាររបស់គាត់នៅក្នុងសមត្ថភាពនោះ និងទៅលើគ្រប់កាលៈទេសៈទាំងអស់"[៦២]។

បញ្ហានៃការទទួលខុសត្រូវនៃកិច្ចសហការមិនត្រូវបានលើកឡើងជាក់លាក់ នៅក្នុងនីតិកម្មរបស់រដ្ឋសមាជិកអាស៊ានទាំងបីទេ រួមមាន **ប្រទេសឡាវ មីយ៉ាន់ម៉ា** និង**វៀតណាម**។

---

៥៨ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង មាត្រា ១០។

៥៩ ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៣ (ប្រទេសហ្វីលីពីន) ផ្នែក ១០(ង)។

៦០ ច្បាប់ស្ដីពីការបកស្រាយច្បាប់ឆ្នាំ១៩៤៨ និងឆ្នាំ១៩៦៧ (ច្បាប់លេខ ៣៨៨) (ប្រទេសម៉ាឡេស៊ី) ផ្នែក ៣។

៦១ *ច្បាប់ស្ដីពីការបកស្រាយច្បាប់* (ប្រទេសសិង្ហបុរី) ផ្នែក ២ និយមន័យនៃពាក្យ "ជន" និង "ភាគី"។

៦២ ផ្នែក ១៤ បទបញ្ជាប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធ (ឆ្នាំ២០០៤)។

## វឌ្ឍនភាពទាក់ទងនឹងការកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើពុករលួយពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការរារាំងយុត្តិធម៌

*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* តម្រូវឱ្យរដ្ឋភាគីត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវរាល់ទម្រង់ទាំងអស់នៃអំពើសូកប៉ាន់ និងអំពើពុករលួយពាក់ព័ន្ធនឹងការជួញដូរមនុស្ស (មាត្រា ៨)។ រដ្ឋភាគីក៏ត្រូវកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការរារាំងយុត្តិធម៌ដែរ នោះគឺថា៖

- ការប្រើប្រាស់កម្លាំងរូបកាយ ការគំរាមកំហែង ការបំភិតបំភ័យ ឬការសន្យា ការផ្តល់ ឬការឱ្យប្រយោជន៍ហួសប្រមាណដើម្បីឱ្យផ្តល់សក្ខីកម្មក្លែងក្លាយ ឬការជ្រៀតជ្រែកទៅក្នុងការផ្តល់សក្ខីកម្ម ឬការបង្ហាញភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តិបទល្មើស។
- ការប្រើកម្លាំងរូបកាយ ការគំរាមកំហែង ឬការបំភិតបំភ័យដើម្បីជ្រៀតជ្រែកទៅក្នុងការអនុវត្តន៍តួនាទីផ្លូវការរបស់តុលាការ ឬមន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស[៦៣]។

នៅពេលកំណត់ជាបទល្មើសព្រហ្មទណ្ឌនៃការជួញដូរមនុស្ស រដ្ឋភាគីក៏ត្រូវតែកំណត់ទោសទណ្ឌធ្ងន់ធ្ងរនៅក្នុងកាលៈទេសៈមួយចំនួនរួមមាន៖ “នៅពេលបទល្មើសត្រូវបានប្រព្រឹត្តិដោយមន្ត្រីសាធារណៈ នៅក្នុងពេលបំពេញភារកិច្ចសាធារណៈរបស់ខ្លួន”[៦៤]។ រដ្ឋសមាជិកអាស៊ានមួយចំនួន (ឧទា. **ប្រទេសថៃ**) បានបង្កើត ជាបទល្មើសមានស្ថានទម្ងន់ដែលបណ្តាលឱ្យមានទោសទណ្ឌធ្ងន់ធ្ងរចំពោះការជួញដូរមនុស្សពាក់ព័ន្ធ នឹងមន្ត្រីសាធារណៈ។

## វឌ្ឍនភាពទាក់ទងនឹងសន្ធិសញ្ញា និងច្បាប់ជាតិ ដែលគាំទ្រកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស

ឧបករណ៍ចម្បងចំនួនពីរ នៃកិច្ចសហប្រតិបត្តិការផ្លូវច្បាប់អន្តរជាតិ គឺជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន។ ជំនួយផ្នែកច្បាប់ទៅវិញទៅមក គឺជាដំណើរការដែលរដ្ឋប្រើដើម្បីផ្តល់ និងទទួលជំនួយជាផ្លូវការពីរដ្ឋាភិបាលមួយទៅរដ្ឋាភិបាលមួយទៀតនៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។ ដោយសារបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សជាធម្មតាពាក់ព័ន្ធនឹងសកម្មភាពរបស់ប្រទេសពីរ ឬច្រើន ជាការសំខាន់ដែលមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌមានសមត្ថភាពធ្វើសហប្រតិបត្តិការឆ្លងដែនក្នុងការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។

សន្ធិសញ្ញា ទោះបីជា ទ្វេភាគី ឬពហុភាគីក៏ដោយ ក៏អាចផ្តល់មូលដ្ឋានគតិយុត្តិសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមករវាងរដ្ឋភាគីនានានៃសន្ធិសញ្ញាទាំងនោះដែរ។ ក្នុងចំណុចនេះ ជាការសំខាន់ដែលថារដ្ឋសមាជិកអាស៊ានទាំង ១០ គឺជាភាគីនៃ ASEAN MLAT។ ASEAN MLAT អនុវត្តចំពោះ “បញ្ហាព្រហ្មទណ្ឌ”[៦៥] ដែលអាចលាតសន្ធឹងទៅដល់កម្រិតទូលំទូលាយនៃបទល្មើសព្រហ្មទណ្ឌ រួមទាំងការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ។ *អនុសញ្ញាអាស៊ានស្តីពី*

---

[៦៣] អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៩។

[៦៤] អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៥(៣)(ឆ)។

[៦៥] ASEAN MLAT មាត្រា ១(១)។ សូមមើលបន្ថែម សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទំព័រ ៣៦-៣៨។

*ការប្រឆាំងការជួញដូរ* បញ្ជាក់អំពីសារៈសំខាន់ នៃជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្ស និងភាពពាក់ព័ន្ធនៃ ASEAN AMLAT ជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការនេះ។ ក្រៅពីនេះ រដ្ឋសមាជិកអាស៊ានភាគច្រើន មានច្បាប់ជាតិរបស់ខ្លួនផ្ទាល់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលអាចយកមកអនុវត្តទៅលើសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងដំណើរការបញ្ចប់ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលនឹងអនុវត្តចំពោះសំណុំរឿងជួញដូរមនុស្ស។ ពុំមានច្បាប់ជាក់លាក់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅ**ប្រទេសឡាវ** និង**ហ្វីលីពីន**ទេ។ ចំណុចនេះពុំចាំបាច់មានន័យថា ជំនួយផ្នែកច្បាប់ទៅវិញទៅមក មិនអាចអនុវត្តបាននៅក្នុងប្រទេសទាំងនេះទេ។ ក៏ប៉ុន្តែ វាមានន័យថា ប្រទេសណាដែលចង់ចូលរួមក្នុងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាមួយរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនេះ នឹងត្រូវពឹងផ្អែកលើមូលដ្ឋានគតិយុត្តិផ្សេងទៀតជំនួសសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនេះ៖ ឧទាហរណ៍ AMLAT របស់អាស៊ាន UNTOC ឬការធានានូវគោលការណ៍បដិភាទ។

ដូចជំនួយផ្នែកច្បាប់ទៅវិញទៅមកដែរ មូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នអាចរកបាននៅក្នុងសន្ធិសញ្ញា និង/ឬច្បាប់ជាតិ[៦៦]។ បច្ចុប្បន្ននេះពុំមានសន្ធិសញ្ញាអាស៊ានស្តីពីការធ្វើបត្យាប័នយ៉ាងទូលំទូលាយទេ។ ក៏ប៉ុន្តែ នាពេលនេះរដ្ឋសមាជិកអាស៊ានភាគច្រើនជារដ្ឋភាគី UNTOC ដែលអាចផ្តល់មូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នរវាងរដ្ឋភាគីនៅក្នុងសំណុំរឿងជួញដូរមនុស្សបាន។ ក្រៅពីនេះ នាពេលនេះ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* ប្រតិបត្តិការរវាងរដ្ឋភាគីជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័ន នៅក្នុងសំណុំរឿងជួញដូរមនុស្ស។ បទប្បញ្ញត្តិលម្អិតនៃអនុសញ្ញានេះត្រូវបានលើកឡើងនៅក្នុងជំពូកទី ៧ នៃរបាយការណ៍នេះ។

រដ្ឋសមាជិកអាស៊ានភាគច្រើន មានច្បាប់ជាតិស្តីពីការធ្វើបត្យាប័នដែលអាចអនុញ្ញាតឲ្យធ្វើបត្យាប័នចំពោះជនសង្ស័យនៅក្នុងសំណុំរឿងជួញដូរមនុស្ស ដែលស្ថិតក្នុងបុរេលក្ខខណ្ឌមួយចំនួន គឺពាក់ព័ន្ធនឹងបទល្មើសដែលនាំឲ្យមានទោសទណ្ឌជាការឃុំខ្លួនអប្បបរមា។ ស្ថានភាពនេះមាននៅក្នុង**ប្រទេសប្រ៊ុយណេ កម្ពុជា ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី ថៃ មីយ៉ាន់ម៉ា** និង**វៀតណាម**។ ច្បាប់ជាតិមានសារៈសំខាន់ដោយសារវាចែងជាទូទៅលម្អិតនូវបុរេលក្ខខណ្ឌ និងនីតិវិធីនានាដែលអនុញ្ញាតនៅក្នុងសំណើសុំធ្វើបត្យាប័ន។

ទោះបីរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១១ បានកត់សម្គាល់អំពីគម្លាត និងភាពទន់ខ្សោយនានា នៅក្នុងតំបន់ក៏ដោយ តែគម្លាតទាំងនេះត្រូវបានបំពេញយ៉ាងធំធេងសម្រាប់បណ្តារដ្ឋដែលជាភាគី *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស*។ ច្បាប់ គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងជុំវិញជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ននឹងលើកយកពិភាក្សាបន្ថែមទៀតនៅក្នុងជំពូកទី ៧។

---

[៦៦] សូមមើលបន្ថែម ជំពូកទី ៥ "ការធ្វើបត្យាប័ន" នៅក្នុង សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទំព័រ ១០៧-១៤៤។

# ១.៣ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅកាន់ក្របខ័ណ្ឌគតិយុត្តិរឹងមាំ និងទូលំទូលាយ៖ ទិដ្ឋភាពនៃការការពារ និងការគាំទ្រជនរងគ្រោះ

ច្បាប់អន្តរជាតិ និងច្បាប់តំបន់តាមរយៈ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* អះអាងច្បាស់ថា ជនរងគ្រោះពីការជួញដូរមនុស្សមានសិទ្ធិមួយចំនួនដែលរដ្ឋត្រូវតែតម្កល់។ ក្នុងចំណុចនេះ មានការពិចារណាពាក់ព័ន្ធជាច្រើន រួមមាន៖ សេចក្តីត្រូវការរបស់ជនរងគ្រោះនៃការជួញដូរមនុស្សត្រូវទទួលបានការការពារ និងការគាំទ្រភ្លាមៗ (រួមមានជម្រកស្នាក់នៅបន្ទាន់ ជំនួយផ្នែកសុខាភិបាល ព័ត៌មាន និងដំបូន្មានផ្នែកច្បាប់ឯករាជ្យ) ការការពារពីការចោទប្រកាន់ចំពោះបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការការពារពីការឃុំខ្លួនតាមអំពើចិត្ត សិទ្ធិទទួលបានសំណង និងការការពារឲ្យបានប្រសើរសម្រាប់ជនរងគ្រោះជាជនរងគ្រោះជាសាក្សី[៦៧]។ ចំណុចទាំងនេះត្រូវបានយកមកពិចារណាដោយសង្ខេបនៅខាងក្រោម។ គួរកត់សម្គាល់ថា ជំពូកទី ៥ និង ៦ ផ្តល់នូវការពិភាក្សាលម្អិតបន្ថែមទៀតស្តីពីសិទ្ធិ និងសិទ្ធិទទួលបានរបស់ជនរងគ្រោះ និងជនរងគ្រោះជាសាក្សី ។

## វឌ្ឍនភាពទាក់ទងនឹងការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះ

មាត្រា ១៤ នៃ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* អះអាងនូវសិទ្ធិមួយចំនួន ដែលរដ្ឋភាគីត្រូវផ្តល់ដល់ជនរងគ្រោះពីការជួញដូរមនុស្ស រួមមាន៖

- សិទ្ធិទទួលបានសុវត្ថិភាពផ្លូវកាយ
- សិទ្ធិទទួលបានឯកជនភាព និងការការពារអត្តសញ្ញាណ
- សិទ្ធិទទួលបានព័ត៌មាន និង
- សិទ្ធិទទួលបានវិធានគាំទ្រមួយចំនួនរួមមាន ផ្ទះសម្បែង ជំនួយសុខាភិបាល ផ្លូវចិត្ត និងសម្ភារៈ។

ច្បាប់នៅ**ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន** និង**ថៃ** ផ្តល់យ៉ាងច្បាស់ដល់ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់នូវសិទ្ធិទទួលបានការការពារ និងការគាំទ្រភ្លាមៗ។ វិធានការស្រដៀងគ្នាត្រូវបានរកឃើញនៅក្នុងឯកសារ

---

[៦៧] សម្រាប់ការពិនិត្យទៅលើលក្ខណៈ និងវិសាលភាពនៃកាតព្វកិច្ចរបស់រដ្ឋទាក់ទិននឹងវិស័យនីមួយៗក្នុងចំណោមវិស័យទាំងនេះ សូមមើល Anne T. Gallagher *ច្បាប់ជួញដូរមនុស្សអន្តរជាតិ* (Cambridge University Press ឆ្នាំ២០១០) ជាពិសេសនៅត្រង់ជំពូកទី ៥។ សូមមើលផងដែរ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស [OHCHR] *សេចក្តីអធិប្បាយចំពោះគោលការណ៍ និងគោលការណ៍ណែនាំដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស* (អង្គការសហប្រជាជាតិ ឆ្នាំ ២០១០) អាចរកបាននៅលើគេហទំព័រ៖ http://www.ohchr.org/Documents/Publications/Commentary_Human_Trafficking_en.pdf [តទៅនេះហៅថា *សេចក្តីអធិប្បាយចំពោះគោលការណ៍ និងគោលការណ៍ណែនាំដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស*]។

គោលនយោបាយរបស់**ប្រទេសកម្ពុជា**ដែលពុំមានកម្លាំងជាច្បាប់[៦៨]។ ឧទាហរណ៍ នៅ**ប្រទេសហ្វីលីពីន** *ច្បាប់ប្រឆាំងការជួញដូរមនុស្ស*ផ្តល់នូវសេវាកម្មមួយចំនួនដែលមានសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស រួមមានជម្រកបន្ទាន់ និងផ្ទះសម្បែង ការពិគ្រោះយោបល់ សេវាផ្នែកច្បាប់ឥតគិតថ្លៃ សេវាសុខាភិបាល និងចិត្តសាស្ត្រ ជីវភាពរស់នៅ និងការបណ្តុះបណ្តាលជំនាញ និងការអប់រំសម្រាប់កុមារ[៦៩]។ ការផ្តល់ស្រដៀងគ្នាក៏មានចែងក្នុងច្បាប់នៅ**ប្រទេសឥណ្ឌូនេស៊ី** និង**ថៃ** និងនៅក្នុងគោលនយោបាយនៅ**កម្ពុជា**។

ខណៈពេលដែលនិន្នាការនៅក្នុងតំបន់ទាក់ទងនិងបញ្ហាបុរសជាជនរងគ្រោះ (និង/ឬជនរងគ្រោះពីការធ្វើអាជីវកម្មដែលមិនមែនផ្លូវភេទ) មានសិទ្ធិទទួលបានជំនួយតិចតួចក៏ដោយ តែបញ្ហានេះកំពុងមានការប្រែប្រួលច្រើន។ ឧទាហរណ៍ ច្បាប់ថ្មីនៅ**ប្រទេសឡាវ**បានបង្កើនជំនួយ ដល់ជនរងគ្រោះនៃការជួញដូរមនុស្សទាំងអស់ ដែលពីមុនជួយតែស្ត្រី និងកុមារតែប៉ុណ្ណោះ ។ ច្បាប់នៅ**ប្រទេសមីយ៉ាន់ម៉ា** ពិតជាមានចែងពីការប្រព្រឹត្តិពិសេសចំពោះស្ត្រី កុមារ និងជនរងគ្រោះ "យុវវ័យ" រួមមាន "ការរៀបចំជាពិសេសសម្រាប់សំណងចំពោះព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ"[៧០] រួមទាំងការងារបណ្តុះបណ្តាលជំនាញជំនាញវិជ្ជាជីវៈ ការពិនិត្យសុខភាព និងការព្យាបាលដោយមានការព្រមព្រៀងពីពួកគេ។ ជំពូកទី VII នៃច្បាប់ប្រឆាំងការជួញដូរមនុស្សរៀបរាប់អំពីការទទួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធ ទាក់ទងនឹងការធ្វើមាតុភូមិនិវត្តន៍ សមាហរណកម្ម និងការស្តារនីតិសម្បទាចំពោះជនរងគ្រោះនៃការជួញដូរផងដែរ ជំនួយទាំងនោះ រួមមានជម្រកបណ្តោះអាសន្ន ការព្យាបាលសុខភាព និងការផ្តល់ភាពតំណាងផ្លូវច្បាប់ដល់ជនរងគ្រោះក្នុងការដាក់បណ្តឹងទាមទារសំណងចំពោះព្យសនកម្ម[៧១]។

បើតាម*ច្បាប់ស្តីពីការទប់ស្កាត់ និងការបង្ក្រាបការជួញដូរមនុស្ស*របស់**ប្រទេសវៀតណាម** (ឆ្នាំ២០១១) ជនរងគ្រោះពីការជួញដូរមនុស្សទទួលបានការគាំទ្រនូវសេចក្តីត្រូវការចាំបាច់ (ដូចជាសំឡីអនាម័យសម្រាប់ស្ត្រីរងគ្រោះ) និងការចំណាយលើការធ្វើដំណើរ សុខាភិបាល បញ្ហាផ្លូវចិត្ត និងផ្លូវច្បាប់។ ជនរងគ្រោះជាជនជាតិវៀតណាម ឬអ្នកស្នាក់នៅអចិន្ត្រៃយ៍ក៏មានសិទ្ធិទទួលបានជំនួយបន្ថែមទៀតដូចជាការសិក្សាអប់រំ និងការបណ្តុះបណ្តាលជំនាញជំនាញវិជ្ជាជីវៈ និងផ្តល់ការងារ និងការគាំទ្របឋមនូវប្រាក់កម្ចីសម្រាប់ធ្វើវិនិយោគ ការគាំទ្រក៏បានផ្តល់ដល់ជនរងគ្រោះនៃការជួញដូរ និងសាច់ញាតិពួកគេដែរ[៧២]។ ក្រៅពីនេះ វៀតណាមក៏បានបង្កើតគោលការណ៍ណែនាំ[៧៣] និងផ្តល់ការណែនាំស្តីពីការបង្កើត និងដំណើរការជម្រកស្នាក់នៅ/មជ្ឈមណ្ឌលគាំទ្រជនរងគ្រោះ និងសេវាគាំទ្រផ្សេងទៀតដល់ជនរងគ្រោះពីការជួញដូរមនុស្សផងដែរ។

---

[៦៨] ប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្ស លេខ ៨៥៧ S.V.Y (ឆ្នាំ២០០៩) (កម្ពុជា)។

[៦៩] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៣ (ប្រទេសហ្វីលីពីន) ផ្នែក ២៣។

[៧០] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (ច្បាប់លេខ ៥/២០០៥) (មីយ៉ាន់ម៉ា) ផ្នែក ១៦(ង)។

[៧១] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (២៥/២០០៥) (មីយ៉ាន់ម៉ា) ផ្នែក ១៩។

[៧២] គោលការណ៍ណែនាំរបស់វៀតណាមស្តីពីការផ្តល់មូលដ្ឋាននានាដែលកំណត់អំពីជនរងគ្រោះដែលរងការជួញដូរមនុស្ស និងការការពារសុវត្ថិភាពសម្រាប់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ (ក្រឹត្យលេខ ៦២/២០១២/ND-CP)។

[៧៣] (ក្រឹត្យលេខ ០៩/២០១៣/ND-CP ផ្តល់ការណែនាំស្តីពីរបៀបអនុវត្តមាត្រាមួយចំនួនដែលមានចែងក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស។

ច្បាប់ស្តីពីការជួញដូរមនុស្សនៅ**ប្រទេសប្រ៊ុយណេ**មិនបានកំណត់ជាក់លាក់នូវកាតព្វកិច្ចចំពោះរដ្ឋ ដើម្បីផ្តល់ឲ្យជនរងគ្រោះនូវការការពារ និងការគាំទ្រភ្លាមៗទេ។ ក៏ប៉ុន្តែ ច្បាប់គាំទ្រដូចជា*ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង* ពិតជាផ្តល់នូវជំនួយដល់កុមារដែលប្រឈមនឹងហានិភ័យក្នុងករណីនេះ។

ផ្នែកខាងក្រោមគូសបញ្ជាក់នូវវិស័យជាក់លាក់ដែលមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ពាក់ព័ន្ធនឹងការអះអាងផ្នែកច្បាប់ ឬការការពារនូវសិទ្ធិមូលដ្ឋានរបស់ជនរងគ្រោះ។ គួរកត់សម្គាល់ថា ព័ត៌មានលម្អិតបន្ថែមស្តីពីការការពាររបស់រដ្ឋសមាជិកអាស៊ានទៅលើសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានលើកឡើងនៅជំពូកទី ៥៖ *ការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានរហ័ស និងត្រឹមត្រូវ៖ ការផ្តល់ការការពារ និងការគាំទ្រភ្លាមៗ* និងជំពូកទី ៦៖ *ការគាំទ្រពិសេសដល់ជនរងគ្រោះជាសាក្សី* ។

## វឌ្ឍនភាពពាក់ព័ន្ធនឹងការការពារកុមាររងគ្រោះនៃការជួញដូរមនុស្ស

ដូចដែលមានបង្ហាញនៅក្នុងតារាងខាងក្រោម ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់រដ្ឋសមាជិកអាស៊ានភាគច្រើន (តែមិនទាំងអស់) ចែងពីវិធានការជាក់លាក់នៃការការពារ និងការគាំទ្រសម្រាប់ជនរងគ្រោះកុមារ។ ក្រៅពីនេះ សិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សជាកុមារ ជាទូទៅត្រូវបានការពារតាមរយៈច្បាប់នានានៅខាងក្រៅក្របខណ្ឌនៃការជួញដូរមនុស្ស។

*តារាង ៤៖ បទប្បញ្ញត្តិច្បាប់ស្តីពីវិធានការពិសេសនៃការការពារ និងការគាំទ្រដល់កុមាររងគ្រោះនៃការជួញដូរមនុស្ស*

| កំណត់សម្គាល់ | |
|---|---|
| ប្រ៊ុយណេ | ច្បាប់ប្រឆាំងការជួញដូរមនុស្សមិនចែងអំពីវិធានការពិសេសនៃការការពារ និងការគាំទ្រកុមាររងគ្រោះពីការជួញដូរមនុស្សទេ។ ក៏ប៉ុន្តែ *ច្បាប់ស្តីពីការការពារស្ត្រី និងកុមារី* និង*ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង* ពិតជាមានចែងនូវការការពារ និងជម្រក ដែលត្រូវបានកំណត់ដោយអាជ្ញាធរ។ |
| កម្ពុជា | ច្បាប់ប្រឆាំងការជួញដូរមនុស្សមិនដោះស្រាយបញ្ហាទាំងនេះទេ តែក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធអនុញ្ញាតឲ្យមានសិទ្ធិទទួលបានព័ត៌មាន និងរក្សាការសម្ងាត់ ការសន្មតអំពីអាយុ ជម្រកមានសុវត្ថិភាព និងល្អសម្រាប់កុមារ ច្បាប់នៃការស្នាក់នៅ ជំនួយផ្នែកច្បាប់ និងលើកឡើងអំពីគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារ។ |
| ឥណ្ឌូនេស៊ី | ច្បាប់ប្រឆាំងការជួញដូរមនុស្សផ្តល់ឲ្យមានការគាំទ្រ និងការការពារជាឧត្តមប្រយោជន៍របស់កុមារនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់។ ការគាំទ្របន្ថែមសម្រាប់ជំនួយផ្នែកច្បាប់ ការការពារ និងការរក្សាការសម្ងាត់ត្រូវបានផ្តល់នៅក្នុងច្បាប់ស្តីពីការការពារកុមារ។ |
| ឡាវ | ច្បាប់ប្រឆាំងការជួញដូរមនុស្សចែងឲ្យមានការគាំទ្រ និងការការពារដល់ជនរងគ្រោះ ជាពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ជំនួយផ្នែកច្បាប់ ការការពារ ជម្រក ព័ត៌មាន និងការរក្សាការសម្ងាត់។ ក៏ប៉ុន្តែ វាមិនជាក់លាក់សម្រាប់កុមាររងគ្រោះទេ។ អនុលោមតាម*ច្បាប់ស្តីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ (ឆ្នាំ២០០៦)* កុមាររងគ្រោះត្រូវបានអនុញ្ញាតឲ្យមានការការពារពិសេស និងបុព្វសិទ្ធិនៅក្នុងកិច្ចដំណើរការនីតិវិធី រួមមាន សិទ្ធិទទួលការការពារឯកជនភាព "វិធានការបន្ទាន់" ចំពោះការការពារ និងជំនួយ ជំនួយផ្នែកអប់រំ សុខាភិបាល និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ការធ្វើសមាហរណកម្ម។ |
| ម៉ាឡេស៊ី | ច្បាប់ប្រឆាំងការជួញដូរមនុស្សមិនចែងនូវវិធានការពិសេសនៃការការពារ ឬការគាំទ្រដល់កុមាររងគ្រោះនៃការជួញដូរមនុស្សទេ ទោះបី*ច្បាប់ស្តីពីការផ្តល់ភស្តុតាងរបស់សាក្សីជាកុមារ ឆ្នាំ២០០៧* |

| | |
|---|---|
| | [ច្បាប់លេខ ៦៧៦] ចែងអំពីការអនុវត្តន៍នូវវិធានការពិសេសពាក់ព័ន្ធនឹងសាក្សីជាកុមារនៅក្នុងកិច្ចដំណើរការនីតិវិធី[៧៤] ក៏ដោយ។ ម៉ាឡេស៊ីក៏ផ្តល់ផ្ទះសម្បែងដល់កុមាររងគ្រោះដែរ ដោយដាក់ដាច់ដោយឡែកពីគ្នារវាងកុមារា និងកុមារី ដែលពួកគេអាចទទួលបានការថែទាំ ការការពារ និងការគាំទ្រ ដោយផ្អែកលើគោលការណ៍ណែនាំនៃកន្លែងស្នាក់នៅនោះ។ |
| មីយ៉ាន់ម៉ា | ច្បាប់ប្រឆាំងការជួញដូរមនុស្សចែងនូវការការពារដល់ជនរងគ្រោះដែលងាយរងគ្រោះ រួមមានកុមារ និងយុវជន ទោះបីវាមិនមានចែងអំពីវិធានការក្នុងការសម្រេចនូវការការពារនោះក៏ដោយ។ គោលការណ៍ឧត្តមប្រយោជន៍ដើម្បីជួយកុមារមានចែងនៅក្នុងច្បាប់ស្តីពីកុមារ និងគោលការណ៍ណែនាំថ្នាក់ជាតិ។ |
| ហ្វីលីពីន | កុមារបានទទួលការការពារ និងជំនួយពិសេសរួមមាន សិទ្ធិទទួលបានព័ត៌មាន និងរក្សាការសម្ងាត់ ការគោរពអត្តសញ្ញាណវប្បធម៌របស់កុមារ និងការមិនរើសអើង និងគោលការណ៍ឧត្តមប្រយោជន៍នៅក្រោមក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយហើយក៏មានច្បាប់ និងវិធានពិសេសដែលចែងជាពិសេសសម្រាប់កុមារដែរ ដូចជា *ច្បាប់សាធារណរដ្ឋលេខ ៧៦១០* ដែលស្គាល់ថាជា *ច្បាប់ស្តីពីការពារពិសេសដល់កុមារប្រឆាំងនឹងការបំពាន ការធ្វើអាជីវកម្ម និងការរើសអើងទៅលើកុមារ* និង *វិធានស្តីពីការពិនិត្យលើសាក្សីជាកុមារ*។ |
| សិង្ហបុរី | ច្បាប់ប្រឆាំងការជួញដូរមនុស្សចែងនូវ ការការពារចំពោះឯកជនភាពរបស់កុមាររងគ្រោះ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ *ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង*ក៏មានចែងនូវលទ្ធភាពដែលកុមាររងការជួញដូរមនុស្សបានទទួលការស្នាក់នៅ ក្នុងទីកន្លែងសុវត្ថិភាពមួយ ឬនៅកន្លែងថែទាំ និងការការពារបណ្តោះអាសន្ន ឬ ត្រូវបានបញ្ជូនទៅកន្លែង ថែទាំសមរម្យ។ |
| ថៃ | ទោះបីច្បាប់ប្រឆាំងការជួញដូរមនុស្សមិនបានចែងឱ្យមានវិធានការពិសេសនៃការការពារ និងការគាំទ្រក៏ដោយ តែ*ក្រមនីតិវិធីព្រហ្មទណ្ឌ* និង *ច្បាប់ស្តីពីការការពារកុមារ* មានចែងនូវវិធានការពិសេសសម្រាប់ការការពារកុមារ និងឯកជនភាពរបស់ពួកគេ នៅក្នុងដំណើរការកំណត់អត្តសញ្ញាណ និងកិច្ចដំណើរការនីតិវិធីច្បាប់ រួមមាន ពាក់ព័ន្ធនឹងការផ្តល់ភស្តុតាង។ |
| វៀតណាម | ក្រៅពីច្បាប់ប្រឆាំងការជួញដូរមនុស្ស *ក្រមព្រហ្មទណ្ឌ*មានចែងនូវការការពារ និងបុព្វសិទ្ធិសម្រាប់កុមាររងគ្រោះនៅក្នុងការស៊ើបអង្កេត និងដំណើរការជំនុំជម្រះ ទោះបីមិនមានបទប្បញ្ញត្តិដែលដកកុមារចេញពីការចូលរួមក្នុង "ការស្ទួតទល់" ជាមួយជនល្មើសក៏ដោយ។ គួរកត់សម្គាល់ថាក្របខ័ណ្ឌគតិយុត្តិវៀតណាមចាត់ទុកកុមារ គឺជាមនុស្សដែលមានអាយុក្រោម ១៦ ឆ្នាំ។ |

## វឌ្ឍនភាពទាក់ទងនឹងការការពារដោយច្បាប់ចំពោះជនរងគ្រោះពេញវ័យរួចផុតពីការឃុំខ្លួន[៧៥]

អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ចែងថា៖

> *ភាគីនីមួយៗត្រូវពិចារណាមិនចោទប្រកាន់ឱ្យជនរងគ្រោះនៃការជួញដូរមនុស្ស ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ឬរដ្ឋបាលចំពោះអំពើខុសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើទាំងនោះគ្មានទំនាក់ទំនង*

---

[៧៤] ម៉ាឡេស៊ីរាយការណ៍ថា ឧត្តមប្រយោជន៍របស់កុមារគឺជាគោលការណ៍ណែនាំពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះកុមាររងគ្រោះ រួមមានការជួញដូរមនុស្ស។

[៧៥] ព័ត៌មានដកស្រង់ចេញពី *ទស្សនាវដ្តី ACWC Regional Review* (ឆ្នាំ២០១៦) ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយអ្នកប្រតិបត្តិ។

*ដោយផ្ទាល់ទៅនឹងការជួញដូរមនុស្សទេ ដោយស្ថិតក្រោមច្បាប់ វិធាន បទបញ្ជា និងគោលនយោបាយ និងនៅក្នុងសំណុំរឿងសមស្រប។*

**មាត្រា ១៤(៧)**

*ភាគីនីមួយៗមិនត្រូវឃុំឃាំង ឬដាក់ក្នុងពន្ធនាគារដោយមិនសមហេតុផល ចំពោះបុគ្គលដែលអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលសម្រាប់ការជួញដូរមនុស្ស។*

**មាត្រា ១៤(៩)**

ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើនបង្កើត ឬប្រមើលមើលអំពីទម្រង់ជាច្រើននៃការឃុំខ្លួន/ការឃាត់ខ្លួនជនរងគ្រោះពីការជួញដូរមនុស្ស ជាពិសេស នៅក្នុងជម្រកបណ្តោះអាសន្ន។ ចំណុចនេះត្រូវបាន ឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋសមាជិក។ ឧទាហរណ៍ ដូចបានលើកឡើងខាងលើ អនុស្សរណៈរវាង**ប្រទេសថៃ** និង**កម្ពុជា** និងអនុស្សរណៈរវាង**ប្រទេសថៃ** និង**វៀតណាម**សុទ្ធតែចែងថា ទោះបីបុគ្គលដែលរងការជួញដូរ/ស្ត្រីដែលរងការជួញដូរមនុស្ស "មិនត្រូវបានឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលជន អន្តោប្រវេសន៍" មុនពេលធ្វើមាតុភូមិនិវត្តន៍ពួកគេ តែពួកគេគួរស្ថិតនៅក្រោមការថែទាំ ពីក្រសួង សេវាកម្មសង្គមពាក់ព័ន្ធ ដែលទទួលខុសត្រូវផ្តល់ជម្រក និងការការពារអនុលោមទៅតាមគោលនយោបាយជាតិ[៧៦]។ អនុស្សរណៈរវាង**ប្រទេសថៃ** និង**មីយ៉ាន់ម៉ា** បានពង្រីកការហាមឃាត់ដល់ការឃុំខ្លួននៅក្នុងមជ្ឈមណ្ឌល ជនអន្តោប្រវេសន៍ ដើម្បីបញ្ចូលកន្លែងឃុំខ្លួនអនុវត្តច្បាប់ ទោះបីនៅរក្សាបទប្បញ្ញត្តិដែលតម្រូវឱ្យរងគ្រោះត្រូវដាក់នៅក្រោមការថែទាំរបស់ភ្នាក់ងារសេវាសង្គមដែលពាក់ព័ន្ធក៏ដោយ[៧៧]។

ទោះបីច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ប្រទេសប្រ៊ុយណេ**មិនបានលើកឡើងពីជម្រក ឬការឃុំខ្លួនក្តី តែនៅក្រោម*ច្បាប់ស្តីពីការការពារចំពោះស្ត្រី និងកុមារី* ស្ត្រី និងកុមារីដែលត្រូវបានចាត់ទុកថាទទួល "រងគ្រោះផ្នែកសីលធម៌" ឬ អ្នកដែលត្រូវបានចាត់ទុកថារងការធ្វើបាប និងត្រូវការការពារ អាចត្រូវបានឃុំខ្លួននៅក្នុង "កន្លែងមានសុវត្ថិភាព"។ ច្បាប់នេះក៏អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចបង្កើតវិធានសម្រាប់ថែទាំ ឃុំខ្លួន ថែរក្សា និងអប់រំដល់ស្ត្រី និងកុមារដែលជាប់ឃុំផងដែរ។ ពុំមានការរាយការណ៍ពីពេលដែលច្បាប់នេះត្រូវបានយកមកប្រើទេ។ អនុលោមតាម*ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង* ជនរងគ្រោះអាយុក្រោម ១៨ ឆ្នាំអាចស្នាក់នៅក្នុងមន្ទីរសុខុមាលភាពដើម្បីសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។

ច្បាប់ស្តីពីការការពារ និងការអភិវឌ្ឍន៍ចំពោះស្ត្រី និងកុមារ របស់**ប្រទេសឡាវ** អះអាងអំពីសិទ្ធិរបស់ (ស្ត្រី និងកុមារ) ជនរងគ្រោះពីការជួញដូរមនុស្ស "មិនត្រូវបានចោទប្រកាន់ និងឃុំខ្លួនដោយការចោទប្រកាន់អំពីការជួញដូរស្ត្រី និងកុមារ អំពើពេស្យាចារ [ឬ] អន្តោប្រវេសន៍ខុសច្បាប់នោះទេ"[៧៨]។ ច្បាប់នេះមិនបានបញ្ជាក់ច្បាស់ថាតើជនរងគ្រោះអាចត្រូវបានឃុំខ្លួនចំពោះមូលហេតុផ្សេងទៀត ឬយ៉ាងណាទេ។ ច្បាប់ស្តីពីការជួញដូរមនុស្ស ឆ្នាំ២០១៥ បានពង្រីកដល់ការការពារជនរងគ្រោះពីការជួញដូរមនុស្សគ្រប់រូប។ រដ្ឋាភិបាលរាយការណ៍ថា ការអនុវត្តន៍ជាក់ស្តែងបច្ចុប្បន្នគឺ

---

[៧៦] អនុស្សរណៈរវាងប្រទេសថៃនិងកម្ពុជា មាត្រា ៦។ អនុស្សរណៈរវាងប្រទេសថៃនិងវៀតណាម មាត្រា ៦។ សម្រាប់បទប្បញ្ញត្តិស្របគ្នាជាទូទៅ សូមមើល អនុស្សរណៈរវាងប្រទេសថៃនិងមីយ៉ាន់ម៉ា នៅត្រង់មាត្រា ៨។

[៧៧] អនុស្សរណៈរវាងប្រទេសថៃនិងមីយ៉ាន់ម៉ា មាត្រា ៨។

[៧៨] ច្បាប់ស្តីពីការការពារ និងការអភិវឌ្ឍន៍ចំពោះស្ត្រី និងកុមារ (ឆ្នាំ២០០៤) មាត្រា ២៥។

ដើម្បីរក្សាទុកជនរងគ្រោះដែលត្រូវវិលត្រឡប់នៅក្នុងជម្រកក្នុងរយៈពេល ៧ ថ្ងៃ ដើម្បីពិនិត្យសុខភាព និងផ្តល់ជំនួយនានា។

អនុលោមតាម*ច្បាប់ទប់ស្កាត់ការជួញដូរមនុស្សឆ្នាំ២០១៤* របស់ប្រទេសសិង្ហបុរី គេអាចផ្តល់ជំនួយដល់ជនរងគ្រោះដែលរងការជួញដូរ រួមទាំងការផ្តល់ជម្រកបណ្តោះអាសន្ន និងសេវាពិគ្រោះយោបល់។

នៅ**ប្រទេសម៉ាឡេស៊ី** ច្បាប់ពាក់ព័ន្ធផ្តល់អំណាចដល់អាជ្ញាធរក្នុងការឃាត់ខ្លួនជនណាម្នាក់ជាបណ្តោះអាសន្ន ដោយសង្ស័យថា ជននោះទទួលរងការជួញដូរ និងបញ្ជូនទៅឲ្យចៅក្រមរដ្ឋបាលក្នុងរយៈពេល ២៤ ម៉ោងក្នុងគោលបំណងទទួលបានដីកាការពារបណ្តោះអាសន្ន។ ដីកាការពារបណ្តោះអាសន្នអនុញ្ញាតឲ្យឃាត់ខ្លួនបណ្តោះអាសន្ន ដល់មន្ត្រីទទួលបន្ទុកការពារ និងដាក់នៅក្នុងមណ្ឌលរយៈពេល ២១ ថ្ងៃ ក្នុងគោលបំណងបើកការស៊ើបអង្កេត និងសាកសួរព័ត៌មាន[៧៩]។ ខបញ្ញត្តិមួយទៀតលើកឡើងថា គោលបំណងនៃការឃាត់ខ្លួនគឺដើម្បីផ្តល់ការថែទាំ និងការពារ[៨០]។ វិសោធនកម្មឆ្នាំ២០១៥ ចំពោះច្បាប់ស្តីពីការជួញដូរមនុស្សបានកាត់បន្ថយនូវរយៈពេល ដែលថាជនរងការជួញដូរមនុស្សដែលជាជនជាតិម៉ាឡេស៊ី អាចត្រូវបានដាក់នៅកន្លែងទីជម្រកពីរយៈពេល ២ ឆ្នាំមកត្រឹម ៣ ខែវិញ។ ចំណែកឯ ថិរវេលាដែលអ្នកមិនមែនជាជនជាតិម៉ាឡេស៊ីអាចត្រូវបានឃុំខ្លួនមានរយៈពេល ៣ ខែ។ វិសោធនកម្មក៏បានចែងផងដែរថា ជនដែលរងការជួញដូរមនុស្ស រួមទាំង ជនបរទេសផង *អាច*បានទទួលការអនុញ្ញាតឲ្យ "ធ្វើដំណើរ ឬធ្វើការងារដោយសេរី ចូលរួម ឬទាក់ទងធ្វើការងារវិជ្ជាជីវៈណាមួយក្នុងពេលអនុវត្តដីកាការពារបណ្តោះអាសន្ន ឬដីកាការពារ"[៨១]។ ក៏ប៉ុន្តែ រដ្ឋពុំមានកាតព្វកិច្ចទាក់ទងនឹងចំណុចនេះទេ។ វាជាការពាក់ព័ន្ធក្នុងការកត់សម្គាល់ថា ច្បាប់មានចែងពីបទប្បញ្ញត្តិចំពោះជនណាដែលបានគេចខ្លួនចេញពីកន្លែងទីជម្រក ត្រូវបានបញ្ជូនត្រឡប់ទៅវិញ ឬដាក់នៅក្នុងថិរវេលាដែលស្មើនឹងថិរវេលាដែលគាត់បានគេចខ្លួនដោយខុសច្បាប់នោះ[៨២]។

*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* របស់**ប្រទេសថៃ** បានផ្តល់អំណាចដល់អាជ្ញាធរ ក្នុងការឃាត់ខ្លួនបណ្តោះអាសន្ន ដល់ជនដែលសង្ស័យដោយសមហេតុផលថាបានទទួលរងការជួញដូរមនុស្ស ក្នុងរយៈពេលមិនឲ្យលើសពី ២៤ ម៉ោងទេ (ក្នុងករណីពិសេស អាចពន្យារបានរហូតដល់ ៧ ថ្ងៃ) និងមិនត្រូវដាក់ក្នុងបន្ទប់ឃុំខ្លួន ឬពន្ធនាគារទេ[៨៣]។ ហាក់ដូចជាពុំតម្រូវឲ្យមានការព្រមព្រៀងពីជននោះទេ ចំពោះការឃាត់ខ្លួនបណ្តោះអាសន្ននេះ។ ក៏ប៉ុន្តែ ផ្នែកបន្ទាប់នៃច្បាប់ដដែលនេះហាក់ដូចជាអនុញ្ញាតឲ្យឃុំខ្លួនដោយគ្មានពេលកំណត់ ដោយចែងថាជនរងការជួញដូរមនុស្ស*អាចត្រូវបានដាក់នៅក្នុងការថែទាំនៅទីជម្រកបឋម ឬមណ្ឌលសុខុមាលភាពរបស់រដ្ឋាភិបាល ឬឯកជនបាន*[៨៤]។ ទោះបីច្បាប់ចែងថា គំនិតដែលថាជនរងការជួញដូរមនុស្សគឺមានទំនាក់ទំនងជាមួយសិទ្ធិទទួលបានការការពារក្តី តែពុំមានភាពច្បាស់លាស់ ថាតើត្រូវផ្តល់ទម្ងន់ទៅលើគំនិតរបស់ជនរងការជួញដូរមនុស្ស

[៧៩] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនចំណាកស្រុកឆ្នាំ២០០៧ (ម៉ាឡេស៊ី) ផ្នែក ៤៤។ វិសោធនកម្មឆ្នាំ២០១៥ ទៅលើផ្នែក ៤៤។

[៨០] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនចំណាកស្រុកឆ្នាំ២០០៧ (ម៉ាឡេស៊ី) ផ្នែក ៥១(៣)(ក)។

[៨១] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនចំណាកស្រុក (វិសោធនកម្ម) ឆ្នាំ២០១៥ (ម៉ាឡេស៊ី) ផ្នែកថ្មី ៥១ក។

[៨២] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនចំណាកស្រុកឆ្នាំ២០១៥ (ម៉ាឡេស៊ី) ផ្នែក ៥៥។

[៨៣] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៨ (ថៃ) ផ្នែក ២៩។

[៨៤] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៨ (ថៃ) ផ្នែក ៣៣។

ហើយថាតើ ចំណុចនេះលាតសន្ធឹងទៅដល់សិទ្ធិបដិសេធការការពារ ឬយ៉ាងណាទេ[៨៥]។ ការិយាល័យអន្តោប្រវេសន៍ថៃ បានរាយការណ៍ថា ការកំណត់គោលនយោបាយតឹងរ៉ឹង ក្នុងការស្តាប់ចម្លើយជនអន្តោប្រវេសន៍ នៅក្នុងមន្ទីរឃុំឃាំងជនអន្តោប្រវេសន៍រង់ចាំការធ្វើនិរទេស ដើម្បីតាមដានជាថ្មីទៅលើជនរងគ្រោះនៃការជួញដូរមនុស្ស[៨៦]។

ច្បាប់ និងគោលនយោបាយនៃការជួញដូរមនុស្សរបស់រដ្ឋសមាជិកអាស៊ានផ្សេងទៀតមិនសំដៅដល់ការឃុំខ្លួនជនរងគ្រោះ។ នៅ**ប្រទេសហ្វីលីពីន** *គោលការណ៍ណែនាំស្តីពីការការពារសិទ្ធិស្រ្តីដែលរងការជួញដូរមនុស្ស* មានចែងពីការឃុំខ្លួន។ ឧទាហរណ៍ មុនពេលកំណត់អត្តសញ្ញាណ "ស្រ្តីរងការជួញដូរមនុស្សមិនគួរត្រូវបានឃុំខ្លួន ឬដាក់នៅក្នុងមន្ទីរឃុំឃាំងជនអន្តោប្រវេសន៍ ឬទម្រង់ផ្សេងទៀតនៃការឃាត់ខ្លួន ដោយដកហូតសេរីភាពរបស់ពួកគេ" ទេ។ គោលការណ៍ណែនាំចែងបន្ថែមថា ស្រ្តីរងការជួញដូរមនុស្សមិនគួរឃុំនៅក្នុងមណ្ឌលជនអន្តោប្រវេសន៍/នគរបាល ជំរុំឃោធា ឬការឃាត់ខ្លួនឯកជន របស់មន្រ្តីអនុវត្តន៍ច្បាប់/មន្រ្តីសុខាភិបាល/សុខុមាលភាពសង្គម មុនពេលបញ្ជូនទៅទីជម្រកដែលមានការអនុញ្ញាតនោះឡើយ។ មន្រ្តីអនុវត្តន៍ច្បាប់មានភារកិច្ចផ្តល់ទីកន្លែងដល់ជនដែលសង្ស័យថាជាជនរងគ្រោះ ជាការឃាត់ខ្លួនបណ្តោះអាសន្ននៅក្នុងការិយាល័យសុខុមាលភាពសង្គម និងការអភិវឌ្ឍន៍នៅមូលដ្ឋាន ឬ ស្ថាប័នមណ្ឌលនានាដែលទទួលបានអនុញ្ញាត ឬមានអាជ្ញាប័ណ្ណ ក្នុងគោលបំណងការពារជនរងការជួញដូរមនុស្ស ក្រោយពេលជួយសង្គ្រោះ។

*ច្បាប់ស្តីពីអន្តោប្រវេសន៍លេខ ៦ ឆ្នាំ២០១១* និង *បទបញ្ជារដ្ឋាភិបាលលេខ ៣១ ឆ្នាំ២០១៣* របស់**ប្រទេសឥណ្ឌូនេស៊ី**សំដៅដល់ជនរងគ្រោះដែលស្នាក់នៅក្នុងជម្រកបណ្តោះអាសន្នមុនពេលធ្វើមាតុភូមិនិវត្តន៍ តែមិនបញ្ជាក់ច្បាស់អំពីលក្ខណៈនៃការជម្រកស្នាក់នៅ និងថាតើជនរងគ្រោះអាចចាកចេញបាន ឬយ៉ាងណាទេ ប្រសិនបើគេចង់។ *កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង បណ្តាភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស*របស់**ប្រទេសកម្ពុជា** បានយោងយ៉ាងទូលំទូលាយទៅដល់ជម្រកស្នាក់នៅ ដោយរៀបរាប់លម្អិតអំពីលក្ខខណ្ឌដែលត្រូវយកមកអនុវត្តចំពោះជម្រកស្នាក់នៅដែលផ្តល់ដល់ជនរងគ្រោះនៃការជួញដូរមនុស្ស។ *គោលការណ៍ណែនាំ*អះអាងថា៖ "ជនរងគ្រោះដែលស្នាក់នៅក្នុងជម្រកត្រូវផ្តល់ការយល់ព្រមរបស់ខ្លួនជាមុន ឬការព្រមព្រៀងពីអាណាព្យាបាលរបស់ខ្លួន ដើម្បីស្ថិតនៅក្នុងជម្រក ព្រមទាំងត្រូវមានការព្រមព្រៀងជាមុនពីទីជម្រកនោះ"[៨៧]។ *ក្រឹត្យស្តីពីការកំណត់អត្តសញ្ញាណ និងការការពារជនរងគ្រោះដែលរងការជួញដូរមនុស្ស* របស់**ប្រទេសវៀតណាម** ដែលណែនាំដល់ការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ខ្លួន បានចែងច្បាស់ថា ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ មានសិទ្ធិបដិសេធមិនទទួលការការពារ។ ក៏ប៉ុន្តែ ប្រសិនបើជនរងគ្រោះបដិសេធ ជននោះត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់ខ្លួនផ្ទាល់[៨៨]។

---

[៨៥] សូមមើល *ការសិក្សា UNIAP* ទំព័រ ៣៣។

[៨៦] កិច្ចខិតខំប្រឹងប្រែងធំៗរបស់រាជរដ្ឋាភិបាល ដើម្បីលុបបំបាត់ការជួញដូរមនុស្សក្នុងឆ្នាំ២០១៤ ទំព័រ ១៤៣។

[៨៧] កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង បណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស មាត្រា ៦៣។

[៨៨] ក្រឹត្យលេខស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដែលរងការជួញដូរមនុស្ស និងការការពារសុវត្ថិភាពរបស់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ (ប្រទេសវៀតណាម) មាត្រា ៣។

# វឌ្ឍនភាពទាក់ទងនឹងការការពារដោយច្បាប់រួចផុតពីការចោទប្រកាន់ ចំពោះស្ថានភាពពាក់ព័ន្ធនឹងបទល្មើស

ជាទូទៅច្បាប់ និងគោលនយោបាយអាស៊ាន បដិសេធនឹងការចោទប្រកាន់ជនរងគ្រោះពីការជួញដូរមនុស្សចំពោះស្ថានភាពពាក់ព័ន្ធបទល្មើស ដូចជា ការចូលដោយខុសច្បាប់ ការស្នាក់នៅដោយខុសច្បាប់ និងការងារដោយខុសច្បាប់។ តារាងខាងក្រោមដែលដកចេញពីទស្សនាវដ្តី ACWC Regional Review ឆ្នាំ២០១៦ បានលើកឡើងនូវបទប្បញ្ញត្តិពាក់ព័ន្ធនានា។

*ប្រអប់អត្ថបទ ១៖ បទដ្ឋានស្តីពីការមិនចោទប្រកាន់ចំពោះបទល្មើសនៃឋានៈនៅក្នុងអាស៊ាន*

ភាគីនីមួយៗមិនត្រូវពិចារណាដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ឬរដ្ឋបាល ដល់ជនរងគ្រោះពីការជួញដូរមនុស្សចំពោះអំពើខុសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើទាំងនោះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការជួញដូរមនុស្ស ទៅតាមបញ្ញត្តិនៅក្នុងច្បាប់ជាតិ វិធាន បទបញ្ជា និងគោលនយោបាយ និងនៅក្នុងករណីសមស្រប។

ប្រភព៖ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១៤(៧)

ជនរងគ្រោះមិនគួរត្រូវបានឃុំខ្លួន ចោទប្រកាន់ យកទៅជំនុំជម្រះ ចំពោះបទល្មើសនានាដែលពួកគេអាចបានប្រព្រឹត្តជាលទ្ធផលផ្ទាល់ ឬភ្លាមៗពីការរងការជួញដូរមនុស្ស។

ប្រភព៖ *គោលការណ៍ណែនាំ* ACWC ៣.៦.១

ទៅតាមវិសាលភាពទូលំទូលាយតាមតែអាចធ្វើទៅបាន ជនរងគ្រោះពីការជួញដូរមិនគួរត្រូវបានចោទប្រកាន់ យកទៅជំនុំជម្រះពាក់ព័ន្ធនឹងបទល្មើសដែលពួកគេបានប្រព្រឹត្តជាផលវិបាកផ្ទាល់ពីស្ថានភាពរបស់ខ្លួនក្នុងនាមជាជនរងគ្រោះពីការជួញដូរមនុស្សទេ។

ប្រភព៖ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន ផ្នែកទី១ គ.២

ជនរងគ្រោះនៃការជួញដូរមនុស្សត្រូវចាត់ទុកជាជនរងគ្រោះ មិនមែនជាជនរំលោភបំពាន ឬជនល្មើសនៃច្បាប់អន្តោប្រវេសន៍ទេ។ ហេតុនេះ ... ជនរងគ្រោះពីការជួញដូរមនុស្សមិនត្រូវបានចោទប្រកាន់ដោយភាគីណាមួយពីបទចូលដោយខុសច្បាប់ ឬចេញដោយខុសច្បាប់ពីប្រទេស ឬពីបទល្មើសផ្សេងទៀតដែលបានកើតឡើងជាផលវិបាកដោយផ្ទាល់នៃការជួញដូរមនុស្សទេ។

ប្រភព៖ អនុស្សរណៈរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា មាត្រា ៨

ជនរងការជួញដូរ [ស្ត្រី និងកុមារដែលរងការជួញដូរ] ត្រូវបានចាត់ទុកជាជនរងគ្រោះ មិនមែនជាជនរំលោភបំពាន ឬជនល្មើសចំពោះច្បាប់អន្តោប្រវេសន៍ទេ។ ហេតុនេះ ... ជនរងការជួញដូរ [ស្ត្រី និងកុមាររងការជួញដូរ] មិនត្រូវបានចោទប្រកាន់ពីបទចូលដោយខុសច្បាប់ទៅក្នុងនោះទេ។

ប្រភព៖ អនុស្សរណៈរវាងប្រទេសថៃ និងកម្ពុជា មាត្រា ៦ អនុស្សរណៈរវាងប្រទេសថៃ និងវៀតណាម មាត្រា៦។

នាពេលនេះ ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន រួមមាន **ប្រទេសឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន** និង**ថៃ** មានចែងជាក់លាក់ថា ជនរងគ្រោះពីការជួញដូរ មិនត្រូវបានចោទប្រកាន់ចំពោះអំពើព្រហ្មទណ្ឌដែលបានប្រព្រឹត្តជាផ្នែកនៃដំណើរការជួញដូរទេ។

### *ប្រអប់អត្ថបទ ២៖ ឧទាហរណ៍ពាក់ព័ន្ធនឹងការមិនចោទប្រកាន់ចំពោះបទល្មើស*

ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់**ប្រទេសឥណ្ឌូនេស៊ី**ចែងថា៖

ជនរងគ្រោះ/ដែល/ប្រព្រឹត្តអំពើព្រហ្មទណ្ឌ ក្រោយពេលរងការបង្ខំពីជនដែលត្រូវបានផ្តន្ទាទោសពីអំពីជួញដូរមិនត្រូវរងការដាក់ទណ្ឌកម្មឡើយ[៨៩]។

ច្បាប់ពាក់ព័ន្ធរបស់**ប្រទេសម៉ាឡេស៊ី**មានផ្នែកមួយមានចំណងជើងថា “និទណ្ឌកម្មពីការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ” ដែលនៅក្នុងផ្នែកនេះ គេរកឃើញមានបទប្បញ្ញត្តិដូចខាងក្រោម៖

ជនដែលរងការជួញដូរមិនត្រូវទទួលរងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ពាក់ព័ន្ធនឹង៖

(ក) ការចូលដោយខុសច្បាប់ទៅក្នុងប្រទេសទទួល ឬប្រទេសឆ្លងកាត់

(ខ) រយៈពេលនៃការស្នាក់នៅដោយខុសច្បាប់របស់គាត់នៅក្នុងប្រទេសទទួល ឬប្រទេសឆ្លងកាត់ ឬ

(គ) អំពើសញ្ញាបេក្ខរបស់គាត់ ឬមានឯកសារសម្រាប់ធ្វើដំណើរ ឬអត្តសញ្ញាណក្លែងក្លាយដែលគាត់បានទទួល ឬដែលគេផ្តល់ឲ្យគាត់ ក្នុងគោលបំណងចូលទៅកាន់ប្រទេសទទួល ឬប្រទេសឆ្លងកាត់

នៅពេលដែលអំពើទាំងនេះជាផលវិបាកផ្ទាល់នៃការជួញដូរមនុស្សដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្ត[90]។

ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៥ របស់**ប្រទេសម៉ាឡេស៊ី** s១៣(a) ចែងថា៖

> ...មិនត្រូវចាត់វិធានការប្រឆាំងនឹងជនរងគ្រោះដែលរងការជួញដូរមនុស្ស ពីបទល្មើសនានានៅក្នុងច្បាប់នេះទេ។

នៅក្នុងផ្នែកមានចំណងជើងថា “ការការពារផ្លូវច្បាប់ចំពោះជនរងការជួញដូរមនុស្ស" ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់**ប្រទេសហ្វីលីពីន**ចែងថា៖

> *ជនរងគ្រោះការជួញដូរមនុស្សត្រូវទទួលបានការទទួលស្គាល់ថាជាជនរងគ្រោះពីការជួញដូរមួយ ឬច្រើន ហើយហេតុនេះមិនត្រូវទទួលរងទណ្ឌកម្មចំពោះបទល្មើសដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការជួញដូរដែលមានចែងក្នុងច្បាប់នេះ ឬ ការធ្វើតាមបញ្ជារបស់ជនជួញដូរមនុស្សដែលពាក់ព័ន្ធនឹងបទល្មើសនេះទេ។*

---

[៨៩] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់ការជួញដូរមនុស្ស មាត្រា ១៨។

[៩០] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (ច្បាប់លេខ ៦៧០) (ប្រទេសម៉ាឡេស៊ី) ផ្នែក ២៥។

ច្បាប់ប្រឆាំងអំពីជួញដូរមនុស្ស(ឆ្នាំ២០០៨) និងវិសោធនកម្ម(លេខ ២) (ឆ្នាំ២០១៥) របស់**ប្រទេសថៃ** ចែងថា៖

*លុះត្រាតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ បើមិនដូច្នោះទេ មន្ត្រីស៊ើបអង្កេតត្រូវបានរារាំងមិនឱ្យចាត់ដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនរងការជួញដូរ ពីបទល្មើសនៃការចូល ចាកចេញ ឬរស់នៅក្នុងព្រះរាជាណាចក្រថៃដោយគ្មានការអនុញ្ញាតទៅតាមច្បាប់អន្តោប្រវេសន៍ ការផ្តល់ព័ត៌មានក្លែងក្លាយដល់មន្ត្រី ការក្លែង ឬការប្រើប្រាស់ឯកសារធ្វើដំណើរការក្លែងក្លាយទៅតាមក្រមព្រហ្មទណ្ឌ បទល្មើសនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់ និងការបង្ក្រាបអំពើពេស្យាចារ ជាពិសេសទៅការទាក់ទង ការលួងលោម ការណែនាំ និងការ ទាក់ទងមនុស្សក្នុងគោលបំណងប្រព្រឹត្តអំពើពេស្យាចារ និងការប្រមូលគ្នានៅកន្លែងពេស្យាចារ សម្រាប់គោលបំណងប្រព្រឹត្តអំពើពេស្យាចារ ឬបទល្មើសជាជនបរទេសដែលធ្វើការដោយគ្មានការអនុញ្ញាតនៅក្រោមច្បាប់ស្តីពីការងាររបស់ជនបរទេស*[៩១]។

ច្បាប់នៅក្នុង**ប្រទេសប្រ៊ុយណេ កម្ពុជា សិង្ហបុរី** និង**វៀតណាម**មិនមានចែងអំពីចំណុចនេះទេ។ រដ្ឋាភិបាលសិង្ហបុរីបានកត់សម្គាល់ថា ក្នុងការសម្រេចថាជនរងគ្រោះពីការជួញដូរមនុស្សគួរត្រូវបានចោទប្រកាន់ចំពោះបទល្មើសណាមួយ អាជ្ញាធរសិង្ហបុរីនឹងពិចារណាទៅលើលក្ខណៈនៃបទល្មើស និងថាតើ មានភស្តុតាងច្បាស់លាស់ដែលថាជនរងគ្រោះត្រូវបានបង្ខំឱ្យប្រព្រឹត្តបទល្មើសដែលជាផលវិបាកផ្ទាល់នៃភាពជាជនរងគ្រោះពីការជួញដូរមនុស្ស ឬយ៉ាងណា។

[៩១] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៨ (ប្រទេសថៃ) ផ្នែក ៤១។

## វឌ្ឍនភាពទាក់ទងនឹងការទទួលស្គាល់ផ្នែកច្បាប់នូវសិទ្ធិទទួលបានសំណង

អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរថែងថា៖

*ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនមានវិធាននានាដែលផ្តល់ឲ្យជនរងគ្រោះនៃការជួញដូរមនុស្ស នូវលទ្ធភាពក្នុងការទទួលបានសំណងចំពោះព្យសនកម្មដែលបានទទួលរង។*

**មាត្រា ១៤(១៣)**

*រដ្ឋភាគីត្រូវធ្វើទំនាក់ទំនងទៅកាន់ជនរងគ្រោះពីការជួញដូរមនុស្ស ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងពេលវេលាសមស្រប ព័ត៌មានស្តីពីលក្ខណៈនៃការការពារ ជំនួយ និងការគាំទ្រដែលពួកគេមានសិទ្ធិទទួលបាន ទៅតាមច្បាប់ជាតិ និងទៅតាមអនុសញ្ញានេះ។*

**មាត្រា ១៤(៩)**

លិខិតូបករណ៍ជាច្រើនស្តីពីគោលនយោបាយរបស់អាស៊ាន បានអះអាងអំពីសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការទទួលបានសំណង។ ឧទាហរណ៍ *គោលការណ៍ណែនាំរបស់ ACWC ស្តីពីការប្រកាន់យកផ្នែកយេនឌ័រ* បានដាក់ការទទួលខុសត្រូវដល់ព្រះរាជអាជ្ញាក្នុងស្នើសុំសំណងដល់ជនរងគ្រោះក្នុងករណីដែលមាន (នៅត្រង់ចំណុច ៣.៦.៩)។ *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ក៏បានលើកឡើងអំពីសំណងដល់ជនរងគ្រោះដែរ។

មានវឌ្ឍនភាពធំធេងនៅក្នុងតំបន់អាស៊ានពាក់ព័ន្ធនឹងការទទួលស្គាល់តាមផ្លូវច្បាប់ នូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណង។ នៅក្នុងករណីមួយចំនួន ដូចជានៅ**ប្រទេសថៃ** សិទ្ធិនេះត្រូវបានកំណត់ជាកាតព្វកិច្ចរបស់រដ្ឋក្នុងការដើរតួនាទី នៅពេលជនរងការជួញដូរមនុស្សមានសិទ្ធិទទួលបានសំណង និងបានសម្តែងនូវឆន្ទៈក្នុងការទាមទារ។ ទោះបី*ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស*របស់**ប្រទេសសិង្ហបុរី**មិនបានលើកឡើងនូវសំណងសម្រាប់ជនរងគ្រោះក៏ដោយ តែបញ្ញត្តិច្បាប់ផ្សេងទៀតក៏មានដែរ។ ឧទាហរណ៍ តុលាការអាចបញ្ជាឲ្យផ្តល់សំណងដល់ជនរងគ្រោះទៅតាម*ក្រមនីតិវិធីព្រហ្មទណ្ឌ*។

នៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត សិទ្ធិរបស់ជនរងការជួញដូរមនុស្សក្នុងការទទួលបានសំណងដូចជាសំណងជួសជុលជាដើម ពុំមានចែងច្បាស់លាស់ទេ ផ្ទុយទៅវិញចំណុចនេះត្រូវបានដកស្រង់ពី*កាតព្វកិច្ចរបស់ជនជួញដូរមនុស្ស ដែលត្រូវផ្តល់សំណងបដិទានដល់ជនរងគ្រោះរបស់ខ្លួន*។ ឧទាហរណ៍ ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ ២០០៨ របស់**ប្រទេសកម្ពុជា**បានចែងថា ជនណាទទួលនូវផលប្រយោជន៍ពីអំពើដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស ត្រូវទទួលខុសត្រូវលើសំណងបដិទានចំពោះ “ផលប្រយោជន៍ដោយគ្មានហេតុផលស្របច្បាប់” (ជំពូកទី ៧ មាត្រា ៤៦)។ ជនរងគ្រោះ (រងគ្រោះពីអំពើពាក់ព័ន្ធនឹងការជួញដូរមនុស្ស) អាចទាមទារសំណងចំពោះព្យសនកម្មបន្ថែមបាន ហើយបានទទួលអាទិភាពពាក់ព័ន្ធនឹងការទាមទារសំណង និងសំណងបដិទាន។ នៅក្នុងចំណុចនេះ ការទាមទាររបស់ពួកគេបានទទួលអាទិភាព ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនានាដែលត្រូវបានរឹបអូសដោយរដ្ឋ (មាត្រា ៤៧)។ *អនុក្រឹត្យស្តីពីការគ្រប់គ្រងនៃការបញ្ជូនពលករកម្ពុជាទៅបរទេសតាមរយៈភ្នាក់ងារជ្រើសរើសពលករឯកជន* បានចែងអំពីលទ្ធភាពដែលភ្នាក់ងារជ្រើសរើសពលករជាអ្នកបង់ប្រាក់កក់ ដែលនឹងយកមកប្រើប្រាស់ដើម្បីដោះស្រាយបញ្ហានានាដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពលករ។ ចំណុចនេះពុំច្បាស់ថាតើ ប្រភពថវិការនេះត្រូវបានយកមកប្រើប្រាស់ដើម្បីផ្តល់សំណងដល់ជនរងគ្រោះពីការជួញដូរមនុស្ស ឬយ៉ាងណាទេ។

នៅ**ប្រទេសឡាវ** មាត្រា ២៥(៤) នៃ*ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារចំពោះស្ត្រី*បានអះអាងអំពីសិទ្ធិរបស់ស្ត្រីរងគ្រោះពីការជួញដូរមនុស្ស ក្នុងការស្នើសុំសំណង។ ចំណុចផ្សេងទៀតនៅក្នុងច្បាប់នេះបានអះអាងថា ជនល្មើសត្រូវបានតម្រូវឱ្យផ្តល់សំណងដល់ជនរងគ្រោះសម្រាប់ការចំណាយនានាដូចជា ការចំណាយពាក់ព័ន្ធនឹងការថែព្យាបាលព្យសនកម្មផ្លូវចិត្ត ការធ្វើដំណើរ និងការស្នាក់នៅ (មាត្រា ២៧)។ ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០១៥ របស់ឡាវបានអះអាងនូវសិទ្ធិរបស់ជនរងគ្រោះ (បុរស និងស្ត្រី) ក្នុងការទាមទារសំណងពីជនល្មើស។

នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន សិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការទទួលបានសំណងពុំច្បាស់ ឬពុំមានចែងតែម្តង។ ឧទាហរណ៍ ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់**ប្រទេសមីយ៉ាន់ម៉ា** មិនបានផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងការទទួលបានការដោះស្រាយទេ។ ផ្ទុយទៅវិញ ច្បាប់នេះតម្រូវឱ្យមានសកម្មភាពមួយចំនួនពីអាជ្ញាធរដែលត្រូវបានបង្កើតឡើងនៅក្រោមច្បាប់នេះ ដែលលើកឡើងថា ជនរងគ្រោះមួយចំនួន (ស្ត្រី កុមារ និងយុវជន) មានសិទ្ធិទទួលបានសំណងចំពោះព្យសនកម្មដែលបង្កដោយជនល្មើសចំពោះការជួញដូរមនុស្ស។

នៅ**ប្រទេសហ្វីលីពីន** មានច្បាប់ទូទៅមួយ ដែលគ្រប់គ្រងការផ្តល់សំណងចំពោះព្យសនកម្មទៅលើជនរងគ្រោះពីបទឧក្រិដ្ឋ ឬបទល្មើសដែលត្រូវបានផ្តន្ទាទោសទៅតាមក្រមព្រហ្មទណ្ឌដែលបានធ្វើវិសោធនកម្ម និងច្បាប់ពិសេសផ្សេងៗទៀតដូចជា ច្បាប់ប្រឆាំងការជួញដូរមនុស្សជាដើម។ *ក្រមរដ្ឋប្បវេណីហ្វីលីពីន* មានជំពូកជាច្រើនដែលលើកឡើងអំពីព្យសនកម្មនានាដូចជា ព្យសនកម្មជាក់ស្តែង ផ្លូវចិត្ត តូចតាច ល្មម ឬមធ្យម។ ជំពូកទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ផ្តល់សំណង ចំពោះព្យសនកម្ម នៅក្នុងសំណុំរឿងព្រហ្មទណ្ឌទាំងអស់ ដោយឈរលើគោលការណ៍ថា "មនុស្សទាំងអស់ដែលទទួលខុសត្រូវព្រហ្មទណ្ឌក៏ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីដែរ"។ ផ្នែក ១៤ នៃ RA លេខ ៩២០៨ ចែងឱ្យមានការរឹបអូស និងការបាត់បង់សិទ្ធិលើទ្រព្យដែលបានពីបទល្មើសជួញដូរមនុស្ស។ ប្រសិនបើទ្រព្យសម្បត្តិដោយឡែករបស់ជនជាប់ចោទមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងការផ្តល់សំណងចំពោះព្យសនកម្មទេ គេអាចគិតទៅដល់តុល្យភាពពីទ្រព្យដែលបានរឹបអូស និងបាត់បង់សិទ្ធិបាន។

នៅ**ប្រទេសវៀតណាម** ច្បាប់ប្រឆាំងការជួញដូរមនុស្សចែងនូវសិទ្ធិនានារបស់ជនរងគ្រោះ ទាំងជនជាតិវៀតណាម និងជនបរទេស រួមមានសិទ្ធិទទួលបានសំណងព្រមទាំងសិទ្ធិទទួលបានការពិគ្រោះយោបល់ផ្នែកច្បាប់ និងជំនួយ ដើម្បីទាមទារសំណងចំពោះព្យសនកម្មដែលបង្កឡើងដោយការជួញដូរមនុស្ស។ ការទទួលបានសំណងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌក៏ត្រូវបានធានានៅក្នុង*ក្រមព្រហ្មទណ្ឌ*របស់វៀតណាមដែរ។

នៅ**ប្រទេសប្រ៊ុយណេ** ផ្នែក ១៩ *នៃបទបញ្ជាប្រឆាំងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស* ចែងថា នៅពេលមានការកំណត់ការពិន័យជាប្រាក់ បន្ទាប់ពីមានការចោទប្រកាន់ដោយជោគជ័យនៅក្នុងសំណុំរឿងជួញដូរមនុស្ស បន្ទាប់ពីមានសំណើសុំពីព្រះរាជអាជ្ញាសាធារណៈ ប្រសិនបើតុលាការយល់ឃើញថាជាការសមរម្យ តុលាការអាចណែនាំថា ប្រាក់ពិន័យទាំងអស់ ឬមួយផ្នែកត្រូវយកមកផ្តល់ជាសំណងដល់ជនរងការជួញដូរមនុស្ស។ ទោះបីមានការបង្កើតមូលនិធិទៅតាមច្បាប់នោះក៏ដោយ តែសំណងមិនត្រូវបានចែងកំណត់ជាគោលបំណងដែលត្រូវយកថវិកាពីមូលនិធិនោះមកប្រើប្រាស់ទេ។ សិទ្ធិទទួលបានសំណង ដែលអាចយកមកប្រើដោយជនរងការជួញដូរមនុស្ស ក៏មាននៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ*ដែរ។

ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់**ប្រទេសម៉ាឡេស៊ី** និង**សិង្ហបុរី**មិនបានយោងជាក់លាក់នូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការដោះស្រាយទេ។ ក៏ប៉ុន្តែ វិសោធនកម្មឆ្នាំ២០១៥ ចំពោះច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់

**ប្រទេសម៉ាឡេស៊ី** បានបញ្ចូលបទប្បញ្ញត្តិដល់តុលាការ ឲ្យបង្គាប់ជនជួញដូរដែលត្រូវបានផ្តន្ទាទោស ផ្តល់នូវចំនួនទឹកប្រាក់ណាមួយ ដែលកំណត់ដោយតុលាការ ធ្វើជាមធ្យោបាយផ្តល់សំណងដល់ជនរងការជួញដូរមនុស្ស។ នៅក្នុងករណីពុំមានការផ្តន្ទាទោសពីបទល្មើសជួញដូរមនុស្ស តុលាការនៅតែអាចបញ្ជាឲ្យចុងចោទបង់ជាប្រាក់ឈ្នួលដែរ[៩២]។ ផ្នែក ៣៥៩ នៃ *ក្រមនីតិវិធីព្រហ្មទណ្ឌ*របស់**ប្រទេសសិង្ហបុរី**បានចែងឲ្យតុលាការពិចារណាថាគួរ ឬមិនគួរចេញបញ្ជា ឲ្យផ្តល់សំណងបាន បន្ទាប់ពីផ្តន្ទាទោសជនណាម្នាក់ពីបទល្មើសណាមួយ ចំណុចនេះរួមទាំងបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ បញ្ជានេះត្រូវធ្វើឡើងក្នុងករណីសមស្រប។ បញ្ជាឲ្យផ្តល់សំណងក៏នឹងមិនប៉ះពាល់ដល់សិទ្ធិដោយឡែកក្នុងការទទួលបានសំណងរដ្ឋប្បវេណីដែរ។

*តារាង ៥៖ បទប្បញ្ញត្តិច្បាប់នៃសិទ្ធិទទួលបានដំណោះស្រាយ*

| | សម្គាល់ |
|---|---|
| ប្រ៊ុយណេ | ក្របខ័ណ្ឌគតិយុត្តិជុំវិញការជួញដូរមនុស្សមិនបានផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបានដំណោះស្រាយ តែលទ្ធភាពតាមផ្លូវច្បាប់ក្នុងការផ្តល់សំណងតាមរយៈប្រាក់ពិន័យដែលមានស្រាប់។ |
| កម្ពុជា | សិទ្ធិមិនត្រូវបានផ្តល់យ៉ាងច្បាស់ទេ តែត្រូវបានសន្និដ្ឋានតាមរយៈកាតព្វកិច្ចរបស់ជនជួញដូរមនុស្សក្នុងការផ្តល់សំណងបដិទានដល់ជនរងគ្រោះ។ គោលការណ៍ណែនាំផ្លូវការស្តីពីការការពារសិទ្ធិរបស់កុមាររងការជួញដូរមនុស្សចែងថា កុមាររងការជួញដូរគួរទទួលបានសំណងរដ្ឋប្បវេណីពីចារី តាមរយៈប្រព័ន្ធតុលាការ។ ក្នុងការអនុវត្តន៍ជាក់ស្តែង សំណងបដិទានត្រូវបានកម្រិតដោយការតម្រូវរបស់ច្បាប់ដែលថា សំណងត្រូវបានផ្តល់តែក្រោយពេលបញ្ចប់នូវការផ្តន្ទាទោសដាក់ពន្ធនាគារ ចំពោះជនល្មើសដែលរកឃើញពិរុទ្ធភាពប៉ុណ្ណោះ។ |
| ឥណ្ឌូនេស៊ី | សិទ្ធិទទួលបានសំណង ត្រូវបានផ្តល់ដល់ជនរងគ្រោះនៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស។ |
| ឡាវ | សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណង អនុវត្តចំពោះជនរងគ្រោះទាំងអស់ រួមទាំងស្ត្រី និងកុមាររងគ្រោះ លើកលែងតែករណីដែលសំណុំរឿងត្រូវបានកំណត់ថាជាការរំលោភបំពានទៅលើច្បាប់ការងារ។ |
| ម៉ាឡេស៊ី | វិសោធនកម្មឆ្នាំ២០១៥ ទៅលើច្បាប់ប្រឆាំងការជួញដូរមនុស្សអនុញ្ញាតឲ្យតុលាការបង្គាប់ឲ្យជនជួញដូរមនុស្សដែលរកឃើញពិរុទ្ធភាព ត្រូវផ្តល់សំណងដល់ជនរងគ្រោះ ឬប្រាក់ឈ្នួលក្នុងករណីពុំមានការផ្តន្ទាទោស។ |
| មីយ៉ាន់ម៉ា | លើកឡើងដោយប្រយោលថា ជនរងគ្រោះអាចមានសិទ្ធិស្របច្បាប់ក្នុងការទទួលសំណង ចំពោះព្យសនកម្មពីការខូចខាត តែមិនបានចែងច្បាស់លាស់ទេ។ |
| ហ្វីលីពីន | ពុំមានបទប្បញ្ញត្តិជាក់លាក់នៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្សទេ ទោះបី *ក្រមរដ្ឋប្បវេណីរបស់ហ្វីលីពីន* ត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ផ្តល់សំណងចំពោះព្យសនកម្មនៅក្នុងសំណុំរឿងព្រហ្មទណ្ឌទាំងអស់។ |

[៩២] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើរត់ពន្ធជនចំណាកស្រុក (វិសោធនកម្ម) ឆ្នាំ២០១៥* (ម៉ាឡេស៊ី) ផ្នែក ៦៦ក និង ៦៦ខ ថ្មី។ ប្រទេសម៉ាឡេស៊ីរាយការណ៍ថា នៅឆ្នាំ២០១៧ មានសំណុំរឿងចំនួន ៣ ដែលបានប្រើប្រាស់បទប្បញ្ញត្តិទាំងនេះដោយជោគជ័យ។

| | |
|---|---|
| សិង្ហបុរី | ពុំមានបទប្បញ្ញត្តិជាក់លាក់នៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស ទោះបីច្បាប់ផ្សេងទៀតតម្រូវឱ្យតុលាការពិចារណាថាតើ គួរឬមិនគួរបង្គាប់ឱ្យផ្តល់សំណង បន្ទាប់ពីរកឃើញពិរុទ្ធភាពរបស់ជនណាម្នាក់ពីបទល្មើសណាមួយ រួមទាំងបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ |
| ថៃ | ព្រះរាជអាជ្ញាសាធារណៈ ត្រូវបានតម្រូវឱ្យធ្វើការទាមទារសំណង ក្នុងនាមជនរងគ្រោះ។ សិទ្ធិទទួលបានសំណងចំពោះព្យសនកម្មត្រូវបានផ្តល់នៅតាមច្បាប់ប្រឆាំងការជួញដូរមនុស្ស *ក្រមនីតិវិធីព្រហ្មទណ្ឌ* និង *ព្យសនកម្មចំពោះការខូចខាត និងសំណង និងការចំណាយសម្រាប់ជនជាប់ចោទ នៅក្នុងបទច្បាប់ស្តីពីបទល្មើសព្រហ្មទណ្ឌ* (ឆ្នាំ២០០១)។ |
| វៀតណាម | បានផ្តល់នៅក្នុងច្បាប់ប្រឆាំងការជួញដូរមនុស្ស និង *ក្រមព្រហ្មទណ្ឌ* |

### វឌ្ឍនភាពទាក់ទងនឹងការពង្រឹងការការពារចំពោះជនរងគ្រោះជាសាក្សី

នាពេលបច្ចុប្បន្នច្បាប់នៅរដ្ឋសមាជិកអាស៊ានភាគច្រើនបានបញ្ចូលបទប្បញ្ញត្តិសម្រាប់ការការពារជនរងគ្រោះដែលផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី។ បញ្ហានេះត្រូវបានពិភាក្សាលម្អិតនៅក្នុងជំពូកទី ៥។

## ១.៤ ការប្រឈម និងភាពនុវត្តភាពនាពេលអនាគត

រដ្ឋសមាជិកអាស៊ានទាំងអស់ បានបង្ហាញវឌ្ឍនភាពយ៉ាងធំធេងក្នុងការបង្កើតក្របខ័ណ្ឌគតិយុត្តិជាតិរបស់ខ្លួនជុំវិញការជួញដូរមនុស្ស។ នៅក្នុងវិស័យនេះហើយដែលមានការបោះជំហ៊ានខ្លាំងជាងគេ។ អាស៊ានទទួលបានពិន្ទុខ្ពស់ពាក់ព័ន្ធនឹងសូចនាករសំខាន់ បើធៀបជាមួយតំបន់ផ្សេងទៀត ជាពិសេសពាក់ព័ន្ធនឹងអត្ថិភាពនៃច្បាប់ប្រឆាំងការជួញដូរមនុស្សនៅថ្នាក់ជាតិ និងនិយមន័យតាមផ្លូវច្បាប់ដែលស្របទៅនឹងបទដ្ឋានអន្តរជាតិ[៩៣]។ ក៏ប៉ុន្តែ វឌ្ឍនភាពមិនស្របគ្នាទេនៅក្នុងតំបន់ទាំងមូល ដូចដែលបានកត់សម្គាល់នៅក្នុងផែនការសកម្មភាពអាស៊ាន (ឆ្នាំ២០១៥)[៩៤] ការប្រឈមសំខាន់ៗនៅតែមានសម្រាប់ប្រទេសទាំងអស់ ដោយសារពួកធ្វើការរៀបរៀងក្របខ័ណ្ឌគតិយុត្តិដែលគាំទ្រដល់ការឆ្លើយតបរឹងមាំ និងយ៉ាងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្ស។

- ទស្សនាវដ្តី ACWC Regional Review បានផ្តល់អនុសាសន៍ទូទៅដូចខាងក្រោម ពាក់ព័ន្ធនឹងការពង្រឹងក្របខ័ណ្ឌគតិយុត្តិជុំវិញការជួញដូរមនុស្ស។

---

[៩៣] សូមមើលបន្ថែម ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម [UNODC] *របាយការណ៍ជាសាកលស្តីពីការជួញដូរមនុស្ស* (UNODC ឆ្នាំ២០១៦)។

[៩៤] ផែនការសកម្មភាពអាស៊ានស្តីពីការជួញដូរមនុស្ស មាត្រា xx (“ការប្រឈមរួមក្នុងចំណោមរដ្ឋសមាជិកអាស៊ាន រួមមាន… មានច្បាប់សមរម្យដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព”)។

| អនុសាសន៍ | |
|---|---|
| ១.១ | រដ្ឋសមាជិកអាស៊ានអាចពិចារណាពិនិត្យឡើងវិញទៅលើច្បាប់របស់ខ្លួន ទាក់ទងនឹងនិយមន័យនៃការជួញដូរមនុស្ស ក្នុងគោលបំណងធានាថា អាចពិចារណាពិនិត្យពាក្យពេចន៍ដែលយកមកប្រើប្រាស់នៅក្នុងនិយមន័យនេះត្រូវបានកំណត់យ៉ាងច្បាស់ ស្របទៅនឹងបទដ្ឋានអន្តរជាតិ/អាស៊ាន។ |
| ១.២ | រដ្ឋសមាជិកអាស៊ានអាចពិចារណាពិនិត្យឡើងវិញទៅលើក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិរបស់ខ្លួន ដើម្បីធានាថា បទល្មើសបន្ទាប់បន្សំពាក់ព័ន្ធត្រូវបានគ្របដណ្ដប់យ៉ាងពេញលេញ ដោយផ្ដល់ដល់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌនូវជម្រើសពេញលេញជាច្រើនដើម្បីស្វែងរកអ្នកពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ |
| ១.៣ | រដ្ឋសមាជិកអាស៊ានអាចពិចារណាពិនិត្យឡើងវិញទៅលើក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិរបស់ខ្លួន ដើម្បីធានាថា ច្បាប់មានចែងគ្រប់គ្រាន់នូវការកំណត់ទោសទណ្ឌផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីទៅលើសាជីវកម្ម និងនីតិបុគ្គលផ្សេងៗទៀត ចំពោះការជួញដូរមនុស្ស ព្រមទាំង បទល្មើសបន្ទាប់បន្សំពាក់ព័ន្ធផ្សេងទៀត។ |

ទស្សនាវដ្ដី ACWC Regional Review ក៏បានផ្ដល់អនុសាសន៍ជាក់លាក់ទាក់ទងនឹងការពង្រឹងក្របខ័ណ្ឌគតិយុត្តិជុំវិញ៖ ការការពារកុមាររងគ្រោះ ការទទួលបានសំណង ការមិនឃុំឃាំង និងការមិនចោទប្រកាន់។

ការសង្កេតជាក់លាក់ដូចខាងក្រោមគាំទ្រ និងពង្រីកនូវវិសាលភាពទៅអនុសាសន៍ទាំងនោះដូចជា៖

- រដ្ឋសមាជិកអាស៊ានតិចតួចដែលមិនទាន់បានធ្វើបែបនេះ គួរតែពិចារណាចូលជាភាគីសន្ធិសញ្ញាសំខាន់នានារួមមាន ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស និង *អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរ*។ ការមិនចូលរួមឱ្យបានពេញលេញរបស់រដ្ឋសមាជិកអាស៊ានទៅក្នុងលិខិតូបករណ៍ទាំងនេះ ជាឧបសគ្គដល់ការអភិវឌ្ឍន៍នូវបទដ្ឋានរួមក្នុងតំបន់ ហើយក៏អាចប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋសមាជិកអាស៊ានដែរ។
- រដ្ឋសមាជិកអាស៊ានមួយចំនួនមិនទាន់បានបញ្ចូល ឱ្យបានពេញលេញនូវនិយមន័យតាមផ្លូវច្បាប់នៃការជួញដូរមនុស្សដែលត្រូវបានទទួលយកជាអន្តរជាតិ ទៅក្នុងក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិរបស់ខ្លួន។ ចំណុចនេះអាចនាំឱ្យមានការយល់ដឹងមិនស៊ីចង្វាក់គ្នាអំពីបទល្មើស "ជួញដូរមនុស្ស" ដែលធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងតំបន់ស្ដីពីបញ្ហានេះ។
- នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ក្របខ័ណ្ឌគតិយុត្តិ មិនបានកំណត់ជាបទល្មើសព្រហ្មទណ្ឌឱ្យបានពេញលេញ និងដាច់ដោយឡែកចំពោះ បទល្មើសដែលទាក់ទងនឹងការជួញដូរមនុស្ស ឬកំណត់ទោសទណ្ឌឱ្យបានសមរម្យចំពោះបទល្មើសពាក់ព័ន្ធទាំងនេះ។ ចំណុចនេះបង្កជាបញ្ហាជាពិសេសទាក់ទងនឹងការងារដោយបង្ខំ។
- នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ក្របខ័ណ្ឌគតិយុត្តិមិនបានគាំទ្រដល់ការចោទប្រកាន់ពាក់ព័ន្ធនឹងការជួញដូរមនុស្សឱ្យបានពេញលេញ នៅក្នុងវិស័យនានាដូចជា ការស្វែងរកទ្រព្យដែលបានពីបទល្មើស។ គម្លាត និងចំណុចខ្សោយផ្នែកច្បាប់ ទាក់ទងនឹងការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមកក៏រារាំងដល់ការចោទប្រកាន់ដែរ ហើយអាចបន្តជាជម្រកដ៏មានសុវត្ថិភាពចំពោះជនជួញដូរមនុស្ស និងទ្រព្យរបស់ពួកគេ។

- រដ្ឋសមាជិកអាស៊ានជាច្រើននៅមិនទាន់បញ្ចូលការការពារឲ្យបានពេញលេញដល់ជនរងគ្រោះនៃការជួញដូរមនុស្ស ទៅក្នុងច្បាប់របស់ខ្លួនទេ។ ឧទាហរណ៍ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការការពារ និងការគាំទ្រភ្លាមៗមិនត្រូវបានការពារនៅក្នុងច្បាប់ទេ។
- នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ច្បាប់ពាក់ព័ន្ធមិនបានទទួលស្គាល់គោលការណ៍អន្តរជាតិសំខាន់ដែលថា ជនរងគ្រោះនៃការជួញដូរមនុស្សមិនគួរត្រូវបានចាប់ខ្លួន ចោទប្រកាន់ ឬឃុំខ្លួនដោយសារពួកគេបានទទួលរងការជួញដូរមនុស្ស ឬផលវិបាកនៃបទល្មើសដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការណ៍ដែលពួកគេរងការជួញដូរមនុស្សនោះទេ។
- ការទទួលស្គាល់ដោយច្បាប់នូវតម្រូវការចាំបាច់របស់កុមាររងការជួញដូរមនុស្ស និងសិទ្ធិដែលពួកគេទទួលបាន ពុំមានភាពស្មើគ្នានៅក្នុងតំបន់នេះទាំងមូល។

| បញ្ជីត្រួតពិនិត្យជំពូកទី ១៖<br>ក្របខ័ណ្ឌគតិយុត្តិទូលំទូលាយស្របទៅតាមបទដ្ឋានអន្តរជាតិ | |
|---|---|
| ១ | បទដ្ឋានគតិយុត្តិទូលំទូលាយស្របទៅតាមបទដ្ឋានអន្តរជាតិ |
| ១.១ | រដ្ឋបានផ្តល់សច្ចាប័ន/ចូលជាភាគីនៃកិច្ចព្រមព្រៀងគតិយុត្តិអន្តរជាតិចម្បងៗពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងបានបញ្ចូលនូវបទប្បញ្ញត្តិសំខាន់ទៅក្នុងច្បាប់ជាតិ |
| ១.១.១ | រដ្ឋបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ រួមមាន៖<br>• អនុសញ្ញាអាស៊ានស្តីពីការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ<br>• អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង<br>• ពិធីសារអង្គការសហប្រជាជាតិបង្ក្រាប ទប់ស្កាត់ និងផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ<br>• កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ<br>• កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌<br>• អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC)<br>• ពិធីសារ CRC ស្តីពីការលក់កុមារ អំពើពេស្យាចារកុមារ និង រូបអាសអាភាសកុមារ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ<br>• អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ<br>• អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ<br>• អនុសញ្ញាលេខ ២៩ របស់ ILO ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច<br>• អនុសញ្ញាលេខ ១០៥ របស់ ILO ស្តីពីការលុបបំបាត់ការងារដោយបង្ខំ អនុសញ្ញាលេខ ១៨២ របស់ ILO អនុសញ្ញាស្តីពីការហាមឃាត់ និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ |
| ១.១.២ | រដ្ឋបានបញ្ចូលបទប្បញ្ញត្តិសំខាន់ៗនៃសន្ធិសញ្ញានានាដែលខ្លួនជាភាគី ទៅក្នុងច្បាប់ជាតិ។ |
| ១.២ | ក្រមព្រហ្មទណ្ឌជាតិបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនូវការជួញដូរមនុស្សគ្រប់ទម្រង់ទាំងអស់ និងចែងនូវទោសទណ្ឌសមស្រប អនុលោមទៅតាមបទដ្ឋានអន្តរជាតិ |
| ១.២.១ | បទល្មើសជួញដូរមនុស្ស (ជាទូទៅ ត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់អន្តរជាតិ) ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌជាក់លាក់។ |
| ១.២.២ | ច្បាប់ចែងឲ្យដាក់ទោសទណ្ឌមានប្រសិទ្ធិភាព មានសមាមាត្រ និងដែលធ្វើឲ្យរាងចាល។ |
| ១.៣ | រាល់ការជួញដូរមនុស្សទាំងអស់ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌពេញលេញ និងដាច់ដោយឡែកពីគ្នា នៅក្នុងក្រមព្រហ្មទណ្ឌជាតិ |
| ១.៣.១ | សមាសធាតុ និងបទល្មើសពាក់ព័ន្ធនានាដូចខាងក្រោម ត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងក្រមព្រហ្មទណ្ឌជាតិ ហើយច្បាប់ចែងឲ្យមានការផ្តន្ទាទោសមានប្រសិទ្ធិភាព មានសមាមាត្រា និងដែលធ្វើឲ្យរាងចាល ទាក់ទងទៅនឹងបទល្មើសនីមួយៗដូចជា៖<br>• អំពើទាសភាព និងសេវភាព |

| បញ្ជីត្រួតពិនិត្យជំពូកទី ១៖<br>ក្របខ័ណ្ឌគតិយុត្តិទូលំទូលាយស្របទៅតាមបទដ្ឋានអន្តរជាតិ | |
|---|---|
| | • ការងារដោយបង្ខំ<br>• ការងារដោយកេងប្រវ័ញ្ច<br>• ពលកម្មកុមារ<br>• ការកេងប្រវ័ញ្ចផ្នែកជំនួញផ្លូវភេទមកលើកុមារ<br>• ការបញ្ចាំខ្លួនដោះបំណុល<br>• អាពាហ៍ពិពាហ៍ដោយបង្ខំ<br>• ការកេងប្រវ័ញ្ចផ្លូវភេទ រួមទាំង ការកេងប្រវ័ញ្ចដោយអំពើពេស្យាចារចំពោះអ្នកដទៃ<br>• រួមគំនិត ប៉ុនប៉ង ឬ ជួញ និងជំរុញឲ្យមានបទល្មើសជួញដូរមនុស្ស<br>• បង្កើត និង/ឬ ចូលរួមនៅក្នុងក្រុមឧក្រិដ្ឋកម្មដែលមានការចាត់តាំង ក្នុងគោលបំណងប្រព្រឹត្តបទល្មើសជួញដូរមនុស្ស<br>• បទល្មើសសម្អាតប្រាក់ ទាក់ទងនឹងទ្រព្យដែលបានពីបទល្មើសជួញដូរមនុស្ស<br>• បទល្មើសពុករលួយដោយមន្ត្រីសាធារណៈដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស |
| ១.៤ | ក្រមព្រហ្មទណ្ឌជាតិគាំទ្រនូវការស៊ើបអង្កេត និងការចោទប្រកាន់ពាក់ព័ន្ធនឹងការជួញដូរមនុស្សដែលរឹងមាំ និងមានប្រសិទ្ធភាព |
| ១.៤.១ | ការជួញដូរមនុស្សត្រូវបានបញ្ចូលទៅក្នុងបទល្មើសសំខាន់នៅក្នុងច្បាប់នានាដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានការចាត់តាំង និងការសម្អាតប្រាក់ |
| ១.៤.២ | ក្របខណ្ឌគតិយុត្តិអាចជួយឲ្យធ្វើការតាមដាន ចាប់យក និងរឹបអូសទ្រព្យដែលបានមកពីបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស និង ការចាប់យក និងការបាត់បង់សិទ្ធិលើមធ្យោបាយនានានៃបទល្មើស។ |
| ១.៤.៣ | ក្របខ័ណ្ឌគតិយុត្តិជួយឲ្យមានជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងសំណុំរឿងជួញដូរមនុស្ស។ |
| ១.៥ | ការជួញដូរមនុស្សស្ថិតក្នុងយុត្តាធិការជាតិដែលធំធេងបំផុត |
| ១.៥.១ | រដ្ឋបង្កើត និងអនុវត្តយុត្តាធិការទៅលើរូបវ័ន្តបុគ្គល និងនីតិបុគ្គលទាក់ទងនឹងបទល្មើសជួញដូរដែលបានប្រព្រឹត្តនៅក្នុងយុត្តាធិការទឹកដីរបស់ខ្លួន (សូមមើលផងដែរ IQS ៧)។ |
| ១.៥.២ | រដ្ឋបង្កើត និងអនុវត្តយុត្តាធិការទៅលើបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សដែលបានប្រព្រឹត្ត និងប្រឆាំងនឹងជនជាតិរបស់ខ្លួននៅបរទេស។ |
| ១.៥.៣ | បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សត្រូវបានចាត់ទុកជាបទល្មើសដែលអាចធ្វើបត្យាប័នបាន ក្រោមសន្ធិសញ្ញា និងច្បាប់ជាតិដែលពាក់ព័ន្ធ។ |
| ១.៥.៤ | នៅពេលបត្យាប័នត្រូវបានបដិសេធ ដោយមូលហេតុសញ្ជាតិ ឬមូលហេតុមានសុពលផ្សេងទៀត រដ្ឋអនុវត្តយុត្តាធិការសកម្ម និងបញ្ជូនកិច្ចដំណើរការនីតិវិធីពីប្រទេសដែលស្នើសុំ។ |
| ១.៦ | ជនរងគ្រោះទទួលបានការការពារ និងការគាំទ្រតាមផ្លូវច្បាប់ |

| បញ្ជីត្រួតពិនិត្យជំពូកទី ១៖<br>ក្របខ័ណ្ឌគតិយុត្តិទូលំទូលាយស្របទៅតាមបទដ្ឋានអន្តរជាតិ | |
|---|---|
| ១.៦.១ | ក្របខណ្ឌគតិយុត្តិផ្តល់ឲ្យជនរងគ្រោះនៃការជួញដូរមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណ នូវសិទ្ធិទទួលបានការការពារ និងការគាំទ្រចាំបាច់ដោយឥតលក្ខខណ្ឌ ដើម្បីបំពេញទៅតាមសេចក្តីត្រូវការចាំបាច់ភ្លាមៗ ក្រោយពេលរកឃើញអត្តសញ្ញាណពួកគេជាផ្លូវការក្តី ឬបណ្តោះអាសន្នក្តី (សូមមើលផងដែរ IQS ៥.២)។ |
| ១.៦.២ | ជនរងគ្រោះដែលបានរកឃើញអត្តសញ្ញាណ ដែលកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងនាមជនរងគ្រោះជាសាក្សី បានទទួលការការពារ និងការគាំទ្រតាមផ្លូវតុលាការ និងជាក់ស្តែងសមស្រប (សូមមើលផងដែរ IQS ៥)។ |
| ១.៦.៣ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ដល់ជនរងគ្រោះនៃការជួញដូរមនុស្សនូវសិទ្ធិទទួលបានដំណោះស្រាយព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាលចំពោះព្យសនកម្មដែលបានប្រព្រឹត្តមកលើពួកគេ រួមទាំង សំណងបដិទាន និងសំណងជួសជុល។ |
| ១.៦.៤ | ក្របខ័ណ្ឌគតិយុត្តិចែងថា ជនរងគ្រោះនៃការជួញដូរមនុស្សមិនត្រូវរងការចោទប្រកាន់ចំពោះអំពើខុសច្បាប់នានាដែលពួកគេបានប្រព្រឹត្តជាផលវិបាកដោយផ្ទាល់អំពីស្ថានភាពពួកគេជាមនុស្សរងការជួញដូរមនុស្ស ឬនៅពេលពួកគេរងការបង្ខិតបង្ខំឲ្យប្រព្រឹត្តអំពើទាំងនេះ។ |

# ជំពូកទី ២៖ សមត្ថភាពស៊ើបអង្កេតឯកទេស

នាពេលបច្ចុប្បន្ន មានការទទួលស្គាល់យ៉ាងទូលំទូលាយថា បទល្មើសជួញដូរមនុស្សតម្រូវឱ្យមានការឆ្លើយតបដែលមានឯកទេស ជាពិសេសបំផុតពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេតបទល្មើសជួញដូរ។ នៅក្នុងតំបន់អាស៊ាន ការទទួលស្គាល់នោះត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ តាមរយៈ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* ដែលតម្រូវឱ្យភាគីត្រូវ៖

អនុម័តនូវវិធានការទាំងនេះជាការចាំបាច់ដើម្បីធានាថា អាជ្ញាធរមានសមត្ថកិច្ចដែលឆ្លើយតបនឹងការជួញដូរមនុស្សត្រូវមានជំនាញ និងចំណេះដឹងក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការការពារជនរងគ្រោះពីការជួញដូរមនុស្ស ហើយក្នុងករណីសមស្រប ត្រូវចាត់តាំងអង្គភាព ឬអាជ្ញាធរឯកទេសសម្រាប់គោលបំណងនេះ **(មាត្រា ១៦(១))**

ជំពូកនេះចាប់ផ្តើមដោយពន្យល់ពីមូលហេតុដែលការឆ្លើយតប តាមរយៈការស៊ើបអង្កេតឯកទេសមានសារៈសំខាន់ និងគូសបញ្ជាក់អំពីធាតុផ្សំសំខាន់ (ឬ "បទដ្ឋាននៃគុណភាព") នៃការឆ្លើយយ៉ាងប្រសិទ្ធភាព និងសមស្របទៅតាមឯកទេស។ បន្ទាប់មក វានឹងពិចារណាអំពីវឌ្ឍនភាពនៅក្នុងតំបន់អាស៊ាន ឆ្ពោះទៅសម្រាប់ឱ្យបានបទដ្ឋានទាំងនេះ ដោយផ្តោតជាពិសេសទៅលើការអភិវឌ្ឍន៍ចាប់តាំងពីការកែសម្រួលឆ្នាំ២០១១ ទៅលើ*របាយការណ៍វឌ្ឍនភាពអាស៊ាន*។ ជំពូកនេះបញ្ចប់ដោយមានការធ្វើវិភាគខ្លីមួយទៅលើការប្រឈម និងកាលានុវត្តភាពនាពេលអនាគត។ ឧបសម្ព័ន្ធនៃជំពូកនេះមានផ្តល់ជាតារាង "បញ្ជីត្រួតពិនិត្យ" បទដ្ឋាននៃគុណភាពសម្រាប់សមត្ថភាពអនុវត្តន៍ច្បាប់ឯកទេសដើម្បីស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។

## ២.១ ហេតុអ្វីត្រូវចាំបាច់មានភាពជំនាញលើមុខងារនៃការស៊ើបអង្កេត?

បទពិសោធន៍នៅក្នុងតំបន់ទាំងអស់ បានបញ្ជាក់ថា ការជួញដូរមនុស្ស ជាបទល្មើសស្មុគស្មាញក្នុងការស៊ើបអង្កេត ដោយតម្រូវឱ្យមាន**អ្នកស៊ើបអង្កេតអនុវត្តន៍ច្បាប់ជំនាញ**ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានការលើកទឹកចិត្ត ដែលត្រូវបានគាំទ្រដោយអំណាច និងធនធានសមស្រប។ សម្រាប់ហេតុផលនេះ សមត្ថភាពអនុវត្តន៍ច្បាប់ឯកទេស ដើម្បីស៊ើបអង្កេតទៅលើការជួញដូរមនុស្សគឺជាធាតុផ្សំសំខាន់នៃការឆ្លើយតបរឹងមាំ និងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។

នាពេលបច្ចុប្បន្ន ការអនុវត្តន៍ជាក់ស្តែងជាអន្តរជាតិទទួលស្គាល់ថា ភ្នាក់ងារអនុវត្តន៍ច្បាប់ត្រូវមានការ**រៀបចំមានសិទ្ធិអំណាច** និង**ទទួលថវិកា**ជាលក្ខណៈមួយដែលអាចជួយពួកគេឲ្យអាចឆ្លើយតបយ៉ាងសមរម្យទៅនឹងបទល្មើសជួញដូរមនុស្សបាន។ តាមឆ្លើយតបនៃការអនុវត្តន៍ច្បាប់គួរគិតគូរទៅនឹងភាពស្មុគ្រស្មាញនៃបាតុភូតជួញដូរមនុស្ស និងការប្រែប្រួលធំដុំ និងស្មុគ្រស្មាញ ដែលបានជួបប្រទះក្នុងអំឡុងពេលស៊ើបអង្កេតទៅលើបទល្មើសនេះ។ ការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការផ្តល់ភាពជំនាញ គឺជាផ្តល់នៃការឆ្លើយយ៉ាងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្សត្រូវបានបញ្ជាក់ជាថ្មី។ ឧទាហរណ៍ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន បានចែងថា៖

> *សមត្ថភាពក្នុងការដាក់ពង្រាយអ្នកស៊ើបអង្កេតជំនាញដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ មានចំណេះដឹង និងមានបច្ចេកទេសពេញលេញដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្ស មានសារៈសំខាន់ចំពោះការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស*[៥៥]។

ដូចបានលើកឡើងខាងលើ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស និងផែនការសកម្មភាពអាស៊ានក៏បានអះអាងអំពីតម្លៃនៃភាពឯកទេសនេះដែរ។

ភាពឯកទេសនៃមុខងារស៊ើបអង្កេត ផ្តល់នូវ**សារប្រយោជន៍**ជាក់ស្តែង។ វាផ្តល់នូវការបង្កើតជាក្រុមអ្នកស៊ើបអង្កេតវិជ្ជាជីវៈដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ដើម្បីធ្វើការស៊ើបអង្កេតប្រកបដោយជោគជ័យទៅលើ បញ្ហាដែលស្មុគ្រស្មាញ ដែលចំណាយពេលច្រើន និងមានលក្ខណៈរសើប។ ហេតុនេះហើយ ចំណុចនេះក៏ពង្រឹងបាននូវសមត្ថភាពស៊ើបអង្កេតជារួមរបស់ភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងមូលដែរ។ វាជំរុញនូវការអនុវត្តន៍នូវទម្លាប់ និងនីតិវិធីស៊ើបអង្កេតដែលមានការរៀបចំត្រឹមត្រូវ និងទៅតាមបទដ្ឋាន។ វាផ្តល់ដល់ជនបង្គោលនូវការស៊ើបអង្កេតពាក់ព័ន្ធនឹងការជួញដូរមនុស្ស ទាំងថ្នាក់ជាតិ តំបន់ និងជាសកល។

ដោយហេតុថា ភាពឯកទេសនៃការឆ្លើយតបត្រូវបានកំណត់យ៉ាងត្រឹមត្រូវ ហើយថា វាដំណើរការនៅក្នុងលក្ខណៈវិនិច្ឆ័យ និងនីតិវិធីប្រតិបត្តិការដែលមានតម្លាភាព ដែលមានលក្ខណៈបើកចំហឲ្យធ្វើការត្រួតពិនិត្យនោះភាពឯកទេសនៃការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ក៏អាចជួយដោះស្រាយ**អំពើពុករលួយ និងភាពស្មុគ្រស្មាញ**នៃវិស័យសាធារណៈក្នុងការជួញដូរមនុស្សផងដែរ ដែលវាជាបញ្ហាកំពុងបន្តកើតឡើងនៅក្នុងប្រទេសជាច្រើននៅទូទាំងពិភពលោក រួមទាំងរដ្ឋសមាជិកអាស៊ានមួយចំនួនផង។

ក៏ប៉ុន្តែ ភាពឯកទេសមិនមែនកើតឡើងដោយគ្មាន**ហានិភ័យ**នោះទេ។ ឧទាហរណ៍ បើគ្មានការពិនិត្យតាមដានការបំពេញការងារ និងការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្នចំពោះការស្ថាបនាទំនាក់ទំនង ភាពឯកទេសអាចនាំឲ្យមានការបង្កើតជាភាពផ្តាច់មុខដែលគ្មានប្រយោជន៍ ដែលមិនបានទទួលប្រយោជន៍ពីជំនាញ និងធនធានពីខាងក្រៅ និងរវាងភ្នាក់ងារទៅភ្នាក់ងារមួយទៀត ដែលបង្កើតជាផ្នែកសំខាន់នៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពជារួម។ ទោះបី ភាពឯកទេសដែលមានការគ្រប់គ្រងត្រឹមត្រូវអាចជួយដោះស្រាយអំពើពុករលួយពាក់ព័ន្ធនឹងការជួញដូរមនុស្សក៏ដោយ តែបើគ្មានការត្រួតពិនិត្យឯករាជ្យ វាក៏អាចធ្វើឲ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរដែរ ដោយផ្តោតទៅលើការទទួលខុសត្រូវសម្រាប់

---

[៥៥] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១៖ ផ្នែក ២។

ប្រភេទបទល្មើសតែមួយ និងមានថវិកាច្រើន ជាមួយនឹងក្រុមបុគ្គលិកតូចដែលពុំមានក្រុមសីលធម៌នៅក្នុងអង្គភាពមួយ។ លុះត្រាតែមានការគ្រប់គ្រងសមរម្យ បើមិនដូច្នោះទេ អង្គភាពឯកទេសដែលគ្មានការត្រួតពិនិត្យអាចនឹងគេងប្រវ័ញ្ចដោយផ្ដៀតកាលានុវត្តភាពប្រព្រឹត្តអំពើពុករលួយ និង/ឬ លាក់បាំងការបំពានដំណើរការតាមផ្លូវច្បាប់ មិនមែនប្រឈមនឹងបញ្ហានេះទេ។

ការគ្រប់គ្រងយ៉ាងសមរម្យទៅលើហានិភ័យទាំងនេះនឹងតម្រូវឱ្យមានសកម្មភាពមួយចំនួន រួមមាន៖ (១) ការបង្កើតគោលនយោបាយ និងនីតិវិធីច្បាប់ច្បាស់លាស់សម្រាប់អង្គភាពឯកទេស ដែលរួមមានការកំណត់អត្តសញ្ញាណ និងការអនុវត្តន៍តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ និងមានតម្លាភាពរបស់អង្គភាពនោះ (២) ការអនុវត្តន៍បទដ្ឋាននៃនីតិវិធីប្រតិបត្តិការដែលមានតម្លាភាព (៣) ការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើបុគ្គលិក និងទិន្នផលរបស់អង្គភាព (៤) ការត្រួតពិនិត្យផ្នែកតុលាការយ៉ាងជិតស្និទ្ធិទៅលើការចោទប្រកាន់ទាំងអស់ដែលកើតចេញពីការស៊ើបអង្កេតរបស់អង្គភាព ដើម្បីថាវាស្របទៅនឹងបទដ្ឋានច្បាប់ និងវិជ្ជាជីវៈ និង ជាចំណុចសំខាន់ជាងគេ (៥) ការតាមដានដោយឯករាជ្យទៅលើការបំពេញការងាររបស់អង្គភាព។ ធាតុផ្សំនៃការតាមដានដោយឯករាជ្យនេះគួររួមមានពីរកម្រិតគឺ៖ អធិការកិច្ចដោយអង្គភាពតាមដានឯករាជ្យ*នៅក្នុង*ភ្នាក់ងារអនុវត្តន៍ច្បាប់ ដូចជាការិយាល័យបទដ្ឋានវិជ្ជាជីវៈ និងអធិការកិច្ចឯករាជ្យទីពីរធ្វើឡើងដោយស្ថាប័នខាងក្រៅពីភ្នាក់ងារអនុវត្តន៍ច្បាប់ ដើម្បីពង្រឹងនិងផ្ទៀងផ្ទាត់ការត្រួតពិនិត្យផ្ទៃក្នុង។

ចុងក្រោយ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា អង្គភាពស៊ើបអង្កេតឯកទេសគឺជាភ្នាក់ងារអនុវត្តន៍ច្បាប់ដែលរឹងមាំ ឬទន់ខ្សោយគឺអាស្រ័យទៅលើភ្នាក់ងារអនុវត្តន៍ច្បាប់ដែលគ្រប់គ្រងអង្គភាពទាំងនោះ។ ទោះបីអង្គភាពដែលមានធនធានគ្រប់គ្រាន់ មានមន្ត្រីមានសមត្ថភាព និងវិជ្ជាជីវៈក៏នឹងត្រូវបាត់បង់ឥទ្ធិពលរបស់ខ្លួនដែរ ប្រសិនបើស្ថាប័នគ្រប់គ្រងគ្មានការរៀបចំត្រឹមត្រូវ គ្មានការលើកទឹកចិត្ត គ្មានសីលធម៌វិជ្ជាជីវៈ និងគ្មានលក្ខណៈវិជ្ជាជីវៈ ដូចគ្នានេះដែរផលប៉ះពាល់ និងប្រសិទ្ធភាពនៃអង្គភាពតូចបំផុតអាចមានឥទ្ធិពលធំធេងបាន ប្រសិនបើអង្គភាពនោះស្ថិតក្នុងស្ថាប័ននគរបាលរឹងមាំ និងមានសមត្ថភាព។

# ២.២ ធាតុផ្សំសំខាន់ៗនៃសមត្ថភាពរបស់អ្នកអនុវត្តច្បាប់ជំនាញ

ការបង្កើតអង្គភាពឯកទេសជួញដូរ គឺជាចំណុចចម្បង នៃការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងតំបន់អាស៊ាន។ ទោះបីអាចមានគំរូរចនាសម្ព័ន្ធជាច្រើនសម្រាប់អង្គភាពឯកទេសក៏ដោយ ក៏បទពិសោធន៍សកលបច្ចុប្បន្នបង្ហាញថា ដើម្បីឱ្យមានប្រសិទ្ធភាព គេគួរបង្ហាញនូវលក្ខណៈរួមចំនួន ៥

## អាណត្តិការងារ និងរចនាសម្ព័ន្ធ

ដើម្បីឱ្យមានប្រសិទ្ធភាព អង្គភាពឯកទេសត្រូវ**បានទទួលអាណត្តិការងារ**ជាការឆ្លើយតបនៃការស៊ើបអង្កេតអនុវត្តន៍ច្បាប់ចម្បងទៅនឹងការជួញដូរ។ ដើម្បីឱ្យមានកម្រិតធំធេង លក្ខណៈនិងវិសាលភាពនៃអាណត្តិការងារ នឹងកំណត់អំពីរចនាសម្ព័ន្ធរបស់អង្គភាពឯកទេស។ មាន “គំរូ” រួមចំនួន ៣ គឺ៖

- គំរូទី ១៖ អង្គភាពឯកទេសត្រូវបានរៀបចំរចនាសម្ព័ន្ធ មានអាណត្តិការងារ និងមានអំណាចធ្វើការ *ស៊ើបអង្កេតទៅលើការជួញដូរទាំងអស់*នៅក្នុងប្រទេស ឬ
- គំរូទី ២៖ អង្គភាពឯកទេសត្រូវបានរៀបចំរចនាសម្ព័ន្ធ មានអាណត្តិការងារ និងមានអំណាចធ្វើការ *ស៊ើបអង្កេតទៅលើការជួញដូរមួយចំនួន* (ដូចជាសំណុំរឿងឆ្លងដែន ឬស្មុគស្មាញជាពិសេស ឬសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារ ឬក្រុមឧក្រិដ្ឋកម្មដែលមានការចាត់តាំង) បំពេញតួនាទីជាអ្នកត្រួតពិនិត្យពាក់ព័ន្ធ នឹងការស៊ើបអង្កេតទាំងអស់ផ្សេងទៀតដែលធ្វើឡើងដោយសហការីមិនឯកទេស ឬ
- គំរូទី ៣៖ អង្គភាពឯកទេសត្រូវបានរៀបចំ រចនាសម្ព័ន្ធ មានអាណត្តិការងារ និងមានអំណាចត្រឹមតែជា *តួនាទីត្រួតពិនិត្យ* និងពុំធ្វើការស៊ើបអង្កេតដោយខ្លួនឯងទេ។

ទោះបីជម្រើសនីមួយៗក្នុងចំណោមជម្រើសទាំងនេះផ្តល់នូវលទ្ធភាពនៃការរៀបចំការឆ្លើយតបបែបជំនាញដែលអាចសម្រេចបានក៏ដោយ តែគំរូទី ១ មានសក្តានុពលក្នុងការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពជាងគេ។ ការមិនអាចផ្តល់អាណត្តិការងារ ដល់អង្គភាពឯកទេសជាការឆ្លើយតបតាមរយៈការស៊ើបអង្កេតតែមួយគត់សម្រាប់សំណុំរឿងជួញដូរទាំងអស់ ឬ យ៉ាងហោចណាស់ ដើម្បីធានាថា អង្គភាពអនុវត្តន៍ច្បាប់មិនឯកទេសទាំងអស់នឹងជូនដំណឹងទៅអង្គភាពឯកទេសនូវសំណុំរឿងពាក់ព័ន្ធនឹងការជួញដូរទាំងអស់ដែលបុគ្គលិករបស់ខ្លួនកំពុងដោះស្រាយ ដោយកាត់បន្ថយសក្តានុពលនៃភាពឯកទេសក្នុងការផ្តល់នូវបទដ្ឋាននៃការស៊ើបអង្កេតដែលត្រូវបានយកចិត្តទុកដាក់ស្របគ្នា និងនៅទូទាំងប្រទេស។ វាក៏បណ្តាលឲ្យមានហានិភ័យប្រតិបត្តិការធ្ងន់ធ្ងរនៃកិច្ចខិតខំប្រឹងប្រែងត្រួតគ្នា តាមរយៈកង្វះការសម្របសម្រួល[៥៦]។

ទិដ្ឋភាពផ្សេងទៀតនៃរចនាសម្ព័ន្ធ និងអាណត្តិការងាររបស់អង្គភាពឯកទេសក៏ពាក់ព័ន្ធនឹងប្រសិទ្ធភាពដែរ។ ជាពិសេសបំផុតគឺ៖

- អាណត្តិការងារគួរធានាថា អង្គភាពឯកទេសមានកាតព្វកិច្ចឆ្លើយតបទៅនឹងសំណុំរឿងជួញដូរផ្ទាល់មុខ ដើម្បីឲ្យបុគ្គលិកពុំមានការទទួលខុសត្រូវស៊ើបអង្កេតផ្សេងទៀត ។ ប្រសិនបើការទទួលខុសត្រូវចំពោះសំណុំរឿងជួញដូរគ្រាន់តែបន្ថែមទៅលើប្រភេទស៊ើបអង្កេតផ្សេងទៀត ដូចជា ឧក្រិដ្ឋកម្មដែលមានការចាត់តាំង ឬបទល្មើសប្រឆាំងនឹងស្ត្រី និងកុមារ ការគំរាមកំហែងពិតប្រាកដ គឺថា ការបំពេញទៅតាមតម្រូវនៃការស៊ើបអង្កេតនឹងរារាំងមិនឲ្យអ្នកស៊ើបអង្កេត ក្នុងអង្គភាពបំពេញទៅតាមការទទួលខុសត្រូវរបស់ខ្លួនឲ្យបានសមស្រប ពាក់ព័ន្ធនឹងសំណុំរឿងជួញដូរ។
- អាណត្តិការងារគួរតែតម្រូវឲ្យមន្ត្រីអនុវត្តន៍ច្បាប់ទាំងអស់ដែលមកពីភ្នាក់ងារគ្រប់គ្រងអង្គភាពនោះ ព្រមទាំងមកពីភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងអស់ផ្សេងទៀត ធ្វើការរាយការណ៍ឲ្យបានទាន់ពេលវេលានូវសំណុំរឿងជួញដូរទាំងអស់ទៅកាន់អង្គភាពឯកទេស។ បើគ្មានធាតុផ្សំនេះទេ គេមិនអាចវាស់វែងឲ្យបានត្រឹមត្រូវ

---

[៥៦] ការកែសម្រួលឆ្នាំ២០១១ នៃ*របាយការណ៍វឌ្ឍនភាពអាស៊ាន* បានកត់សម្គាល់នូវសំណុំរឿងមួយដែលអង្គភាពជំនាញរបស់រដ្ឋសមាជិកអាស៊ានមួយបានធ្វើការស៊ើបអង្កេតទៅលើសំណុំរឿងការធ្វើអាជីវកម្មផ្នែកការងារដើម្បីគ្រាន់តែឲ្យដឹងថា ក្រោយពេលអូសបន្លាយមួយរយៈ ទីភ្នាក់ងារស៊ើបអង្កេតមួយទៀត (ក្រោមក្រសួងមួយទៀត) កំពុងស៊ើបអង្កេតដំណាលគ្នា និងស្របគ្នាទៅលើសំណុំរឿងដដែលនោះ ដោយគ្មានការសម្របសម្រួល ឬកិច្ចសហប្រតិបត្តិការអ្វីទាំងអស់។

នូវស្ថានភាពជួញដូរទាំងមូលនៅថ្នាក់ជាតិ ឬមិនអាចអនុវត្តការឆ្លើយទៅនឹងស្ថានភាពនោះឲ្យបានសមស្រប ទៅតាមបទដ្ឋាន និងមានការសម្របសម្រួលនៅទូទាំងប្រទេសបានទេ។

- ប្រសិនបើគំរូអង្គភាព បញ្ចូលតួនាទីត្រួតពិនិត្យទៅលើដំណើរការសំណុំរឿងដែលស៊ើបអង្កេតដោយសហការីមិនឯកទេស ជាការសំខាន់គឺថា តួនាទីនេះមិនត្រូវបានចាត់ទុកថាជា "ទីប្រឹក្សា" ទេ តែជាកាតព្វកិច្ចចំពោះសហការីមិនឯកទេសតែប៉ុណ្ណោះ។ វិធីសាស្ត្រជា "ទីប្រឹក្សា" ធ្វើឲ្យមានគ្រោះថ្នាក់ដល់ការអនុវត្តន៍នៅទូទាំងប្រទេសនូវការឆ្លើយតបនៃការស៊ើបអង្កេតដែលមានបទដ្ឋានវិជ្ជាជីវៈ និងកើនឡើងនូវភាពមិនស៊ីចង្វាក់ផ្នែកប្រតិបត្តិការ។
- សមត្ថភាពនៃការឆ្លើយតបពិតប្រាកដនៅទូទាំងប្រទេសត្រូវបានតម្រូវចំពោះអង្គភាពឯកទេស ដើម្បីធានាថា ៖ (១) វាអាចមានប្រតិកម្មទៅនឹងការប្រឈមចម្រុះដែលលេចឡើងដោយការវិវត្តន៍ជាបន្តបន្ទាប់នៃបទល្មើសប្រភេទនេះ និង (២) វាជាការឆ្លើយតបពិតប្រាកដទៅនឹងតម្រូវការនៃការអនុវត្តន៍ច្បាប់នៅថ្នាក់មូលដ្ឋាន និងតំបន់ និងសហការីពីភ្នាក់ងារជាច្រើនទៀត។ សរុបមក ប្រសិទ្ធភាពតម្រូវថា ការឆ្លើយតបបែបឯកទេសត្រូវតែមានសមត្ថភាពកំណត់អត្តសញ្ញាណ វាយតម្លៃ និងដោះស្រាយការប្រឈមនៃការជួញដូរនៅថ្នាក់ជាតិ ហើយក្នុងពេលដំណាលគ្នានោះធ្វើការពិគ្រោះយោបល់ និងសហការជាមួយដៃគូនៅមូលដ្ឋាន ដើម្បីរៀបចំការឆ្លើយតបឲ្យមានប្រសិទ្ធភាពតាមតែអាចធ្វើទៅបាន។

វិធីសាស្ត្រនៃការជួញដូរអាចមានភាពខុសគ្នាយ៉ាងខ្លាំងនៅតាមកន្លែងខុសៗគ្នានៅក្នុងប្រទេសដដែលនោះ ហើយរូបភាពដែលបានឃើញនៅតាមទីក្រុង ឬទីប្រជុំជនអាចមិនឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវទៅនឹងអ្វីដែលកំពុងកើតឡើងនៅតាមខេត្តនោះទេ។ ដោយមិនគិតដល់រចនាសម្ព័ន្ធរបស់វា អង្គភាពឯកទេសណាក៏ដោយនឹងមិនអាចចៀសផុតពីការប្រមូលផ្តុំគ្នាទៅលើការផ្តោត និងវិធីសាស្ត្ររបស់វាទេ។ លុះត្រាតែបង្កើតឲ្យមានយន្តការដើម្បីធានានូវការពិគ្រោះយោបល់ និងការបញ្ចូលនៅថ្នាក់មូលដ្ឋាន និងរវាងភ្នាក់ងារនានាបញ្ចូលទៅក្នុងគំរូនោះ បើមិនដូច្នោះទេ វាមានហានិភ័យដែលថា អង្គភាពកណ្តាលនឹងដាច់ឆ្ងាយពីប្រតិបត្តិការជាក់ស្តែងនៅតាមមូលដ្ឋាន ដែលធ្វើឲ្យប៉ះពាល់ដល់ការផ្សព្វផ្សាយ និងភាពពាក់ព័ន្ធរបស់វា។

## ការទទួលបានអំណាចសមស្រប

អង្គភាពឯកទេសដែលមានប្រសិទ្ធភាពនឹងទទួលបានអំណាចក្នុងការពិនិត្យ និងប្រើប្រាស់ និង/ឬត្រួតពិនិត្យការប្រើប្រាស់អំណាចគតិយុត្តិ និងនីតិវិធីទាំងអស់ដែលមាន ដើម្បីធ្វើការស៊ើបអង្កេតទៅលើការជួញដូរ ដោយអនុវត្តនូវបច្ចេកទេសស៊ើបអង្កេត ក្រោយពេលកើតហេតុ មុនពេលកើតហេតុ និងបង្អាក់ការកើតឡើងនៃបទល្មើស។ កម្រិតនៃអំណាចនេះមានសារៈសំខាន់ ដើម្បីធានាថា ការឆ្លើយតបបែបឯកទេសអាចប្រើប្រាស់មធ្យោបាយស៊ើបអង្កេតយ៉ាងទូលំទូលាយដែលប្រយុទ្ធប្រឆាំងនឹងជនជួញដូរ។ ការត្រួតពិនិត្យនេះក៏អាចផ្តល់នូវការការពារបន្ថែម ប្រឆាំងនឹងការប្រើអំណាចមិនត្រឹមត្រូវដោយការអនុវត្តន៍ច្បាប់នៅមូលដ្ឋានដែរ។ កម្រិតទូលំទូលាយនៃអំណាចស៊ើបអង្កេតនេះនៅតែមានសារៈសំខាន់ មិនគិតដល់របៀបរៀបចំរចនាសម្ព័ន្ធជាក់ស្តែងនៃគំរូអង្គភាពឯកទេសទេ។

## ការផ្តល់ថវិកាគ្រប់គ្រាន់ និងជាបន្តបន្ទាប់

ការផ្តល់ថវិកាគ្រប់គ្រាន់ និងជាបន្តបន្ទាប់គឺជាលក្ខណៈទីបីនៃការឆ្លើយតបបែបជំនាញដែលដំណើរការយ៉ាងសមរម្យ។ ការស៊ើបអង្កេតយ៉ាងជោគជ័យទៅលើសំណុំរឿងជួញដូរ ទោះបីប្រើប្រាស់បច្ចេកមុនពេលកើតហេតុ ឬក្រោយពេលកើតហេតុក៏ដោយ តែវាកម្របានឆាប់រហ័ស ឬចំណាយអស់តិចតួចនោះទេ។ កម្រិតនៃការទទួលថវិការដែលផ្តល់ដល់អង្គភាពឯកទេស ត្រូវតែគ្រប់គ្រាន់ សម្រាប់បុគ្គលិក និងបំពាក់នូវបរិក្ខារដល់អង្គភាពនោះ ព្រមទាំងការចំណាយនៅក្នុងការស៊ើបអង្កេតករណីស្មុគស្មាញ។ អង្គភាពសកម្មទំនងជាធ្វើកិច្ចសហការជាមួយប្រទេសផ្សេងទៀតដែលអាចមានន័យថា សមត្ថភាពផ្នែកភាសា (ឧទា. ភាសាអង់គ្លេស) ជាការសំខាន់។

ជាអកុសល សម្ពាធពីខាងក្រៅទៅលើរដ្ឋ ដើម្បីឲ្យ "ឃើញថាកំពុងធ្វើអ្វីម្យ៉ាង" អំពីការជួញដូរអាចបណ្តាលឲ្យមានការបង្កើតនូវស្ថាប័នដែលទន់ខ្សោយ ឬគ្រាន់តែជាការលម្អ ដែលពុំមានធនធានជាមូលដ្ឋានដែលចាំបាច់ដើម្បីបំពេញទៅតាមបន្ទុកការងាររបស់ខ្លួន។ ជាធម្មតា ការទទួលថវិការ មន្ត្រីបំពេញការងារ និងអនាគតនៃរចនាសម្ព័ន្ធផុយស្រួយបែបនេះ ពុំមានភាពរឹងមាំទាល់តែសោះ។ គុណភាពនៃលទ្ធផលស៊ើបអង្កេតទាបគឺជាផលវិបាកនៃកង្វះសមត្ថភាព រួមជាមួយបញ្ហាសីលធម៌ទាប ដែលបណ្តាលឲ្យមានការឆ្លើយតបបែបជំនាញដែលមានការរៀបចំ ការផ្តល់ធនធាន និងការគ្រប់គ្រងមិនសមរម្យ។

## បទដ្ឋាននីតិវិធីប្រតិបត្តិការ ការត្រួតពិនិត្យ និងការគ្រប់គ្រង

ភាពស្មុគស្មាញ និងភាពរសើបនៃការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរ តម្រូវឱ្យអ្នកស៊ើបអង្កេតឯកទេសត្រូវប្រតិបត្តិការនៅក្រោម និងបំពេញយ៉ាងដាច់ខាត ទៅតាមបទដ្ឋាននីតិវិធីប្រតិបត្តិការ ដែលស្របទៅនឹងច្បាប់ និងនីតិវិធី ដែលគ្រប់គ្រងសកម្មភាពស៊ើបអង្កេតរបស់ពួកគេ។ នៅគ្រប់ដំណាក់កាលទាំងអស់ នីតិវិធីទាំងនេះ និងការកត់ត្រានៃការអនុវត្តន៍ចំពោះបទដ្ឋានទាំងនេះ គួរតែដាក់ជូនដល់ថ្នាក់លើនៅក្នុងអង្គភាពឯកទេស អ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងសេវាកម្មផ្នែកនគរបាល និងអង្គភាពអធិការកិច្ចឯករាជ្យ (រួមមាន តាមរយៈការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ)។ ការមិនធ្វើតាមបទដ្ឋាននីតិវិធីប្រតិបត្តិការនឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងដាក់ទណ្ឌកម្មដែលអាចមាន។ អ្នកដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមានដោយសារសកម្មភាពរបស់អង្គភាពឯកទេស គួរតែអាចស្នើសុំ និងទទួលបានដំណោះស្រាយ រួមមាន តាមរយៈយន្តការបណ្តឹងផ្លូវការផងដែរ។

## ការបណ្តុះបណ្តាល

ភាពស្មុគស្មាញ និងភាពរសើបនៃការស៊ើបអង្កេត ទៅលើសំណុំរឿងជួញដូរ ក៏តម្រូវផងដែរឲ្យមានជំនាញបច្ចេកទេសកម្រិតខ្ពស់។ ជាធម្មតា ចំណុចនេះអាចទទួលបានតែតាមរយៈការបណ្តុះបណ្តាលផ្នែកស៊ើបអង្កេតជំនាញប៉ុណ្ណោះ។ ជាកម្រិតអប្បរមា អ្នកស៊ើបអង្កេតឯកទេសត្រូវតែមានសមត្ថភាពធ្វើការស៊ើបអង្កេតក្រោយពេលកើតហេតុ និងអាចកំណត់អត្តសញ្ញាណជនរងគ្រោះយ៉ាងត្រឹមត្រូវ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ ទទួលស្គាល់ និងគ្រប់គ្រងការប៉ះទង្គិចផ្លូវចិត្ត និងបញ្ហាវប្បធម៌ ធ្វើការស្តាប់ចម្លើយដែលមានលក្ខណៈរសើបជាមួយជនរងគ្រោះពេញវ័យ និងកុមារ ប្រមូលភស្តុតាងស្របគ្នា ធានាដល់ការគាំទ្រ និងការការពារចំពោះសាក្សី និង ចូលរួមក្នុងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ អង្គភាពឯកទេសក៏គួរតម្រូវឲ្យមានសមត្ថភាពស៊ើបអង្កេតមុនពេលកើតហេតុ ដែលរួមមានការប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់ ការឃ្លាំមើលមនុស្ស និងការឃ្លាំមើលប្រកបដោយបច្ចេកទេស ប្រតិបត្តិការបង្កប់ខ្លួន និង

“ការទិញសាកល្បង” ការប្រមូលវត្ថុដែលស្ថិតក្រោមការគ្រប់គ្រង និងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុស្របគ្នា ដែលធ្វើឡើងតាមរយៈការបណ្ដុះបណ្ដាល។

## ២.៣ ឧត្តមភាពរបស់អាស៊ានឆ្ពោះទៅសមត្ថភាពស៊ើបអង្កេតឯកទេស

ភាពឯកទេសនៃការឆ្លើយតាមរយៈការស៊ើបអង្កេតទៅនឹងបទល្មើសជួញដូរមនុស្ស ត្រូវបានបង្កើតឡើងយ៉ាងល្អនៅទូទាំងតំបន់អាស៊ានទាំងមូល ហើយនាពេលបច្ចុប្បន្ននេះមានការទទួលស្គាល់យ៉ាងទូលំទូលាយនូវសារៈសំខាន់ របស់វាក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។ ឧទាហរណ៍ *ផែនការសកម្មភាពអាស៊ាន* អំពាវនាវឲ្យរដ្ឋសមាជិកអាស៊ានបង្កើតក្រុមអនុវត្តន៍ច្បាប់ជំនាញ និងការស៊ើបអង្កេតលឿន[៩៧]។ នៅក្នុងវិស័យនេះ អាស៊ានបានឈានមុខគេ និងលឿនជាងតំបន់ផ្សេងទៀតនៅទូទាំងពិភពលោក ហើយរដ្ឋសមាជិកអាស៊ានបានទទួលស្គាល់យ៉ាងច្បាស់នូវផលប្រយោជន៍ដែលទទួលបានពីភាពឯកទេសនេះ។ ហេតុនេះ បណ្ដារដ្ឋទាំងនោះបានបង្ហាញប្រតិកម្ម និងបានអនុម័តនូវគោលការណ៍នៃភាពឯកទេសនៅក្នុងការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ទៅនឹងការជួញដូរ និងបានបង្កើតគំរូអង្គភាពឯកទេសជាច្រើន។

*តារាង ៦៖ សេចក្ដីសង្ខេបនៃការឆ្លើយតបឯកទេសនៅក្នុងតំបន់អាស៊ាន*

| រដ្ឋសមាជិកអាស៊ាន | ការឆ្លើយតបឯកទេស |
|---|---|
| ប្រ៊ុយណេ | អង្គភាពស៊ើបអង្កេតការជួញដូរមនុស្ស នាយកដ្ឋានស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ កងកម្លាំងនគរបាលភូមិន្ទប្រ៊ុយណេ |
| កម្ពុជា | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ឥណ្ឌូនេស៊ី | អង្គភាព IV/អង្គភាពប្រឆាំងការជួញដូរ អនុនាយកដ្ឋានទី ៣ នៃអគ្គនាយដ្ឋានបទល្មើសព្រហ្មទណ្ឌទូទៅ ផ្នែកស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ នគរបាលជាតិឥណ្ឌូនេស៊ី |
| ឡាវ | នាយកដ្ឋានប្រឆាំងការជួញដូរ អគ្គនាយកដ្ឋាននគរបាល |
| ម៉ាឡេស៊ី | អង្គភាព ATIPSOM D៧(C) នគរបាលភូមិន្ទម៉ាឡេស៊ី |
| មីយ៉ាន់ម៉ា | ផ្នែកប្រឆាំងការជួញដូរមនុស្ស ក្រុមការងារប្រឆាំងការជួញដូរ និងក្រុមការពារកុមារ កងកម្លាំងនគរបាលមីយ៉ាន់ម៉ា |
| ហ្វីលីពីន | មជ្ឈមណ្ឌលស្ត្រី និងកុមារ នគរបាលជាតិហ្វីលីពីន និងផ្នែកប្រឆាំងការជួញដូរមនុស្ស (AHTRAD) ការិយាល័យស៊ើបអង្កេតជាតិ ក្រុមប្រឹក្សាអន្តរភ្នាក់ងារប្រឆាំងការជួញដូរ |
| សិង្ហបុរី | ផ្នែកព្រហ្មទណ្ឌជំនាញ នាយកដ្ឋានស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ កងកម្លាំងនគរបាលសិង្ហបុរី និងក្រុមការងារពិសេស ផ្នែកគ្រប់គ្រងពលករបរទេស ក្រសួងពលករ |

[៩៧] ផែនការសកម្មភាពអាស៊ាន វគ្គ IV.C.(l)។

| | |
|---|---|
| ថៃ | ផ្នែកប្រឆាំងការជួញដូរមនុស្ស នគរបាលភូមិន្ទថៃ និងផ្នែកបទល្មើសជួញដូរ នាយកដ្ឋានស៊ើបអង្កេតពិសេស ក្រសួងយុត្តិធម៌ |
| វៀតណាម | អង្គភាពទី ៦ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ (C៤៥) អគ្គនាយកដ្ឋាននគរបាល ក្រសួងសន្តិសុខសាធារណៈ |

អាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនបានកត់ត្រានូវសមិទ្ធិផលសំខាន់ៗផ្សេងទៀតពាក់ព័ន្ធនឹងភាពឯកទេសនៃការឆ្លើយតបនៃការអនុវត្តន៍ច្បាប់។ ឧទាហរណ៍៖

- ការបង្កើតវេទិកាតំបន់តែមួយក្នុងពិភពលោក (**ប្រធានអង្គភាពឯកទេសការជួញដូរ - HSU - ដំណើរការ**) ដោយនាំមកចូលរួមជាមួយគ្នានូវអង្គភាពស៊ើបអង្កេតឯកទេស ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាន និងព័ត៌មានសម្ងាត់។ ការសម្របសម្រួលឆ្លងដែនរវាងថ្នាក់ដឹកនាំអង្គភាពឯកទេសទាំងនោះ បានបន្តអភិវឌ្ឍតាមរយៈដំណើរការប្រធានអង្គភាពឯកទេសការជួញដូរ ដែលនាពេលនេះធ្វើឡើងនៅក្រោមការឧបត្ថម្ភនៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែន។ គួរកត់សម្គាល់ថា *ផែនការសកម្មភាពអាស៊ាន* បានអំពាវឲ្យរដ្ឋសមាជិកអាស៊ានទាំងអស់ពង្រឹងយន្តការ HSU[៥៨]។
- ការបញ្ចប់**កម្មវិធីបណ្តុះបណ្តាល**ជាស៊េរីសម្រាប់អ្នកស៊ើបអង្កេតឯកទេសក្នុងតំបន់ និងប្រធានអង្គភាពឯកទេស។
- **ការបណ្តុះបណ្តាលអ្នកស៊ើបអង្កេតឯកទេស**កម្រិតខ្ពស់ និងទ្រង់ទ្រាយធំនៅទូទាំងតំបន់ ដោយបង្កើនការផ្តោតទៅលើការបញ្ចូលកម្មវិធីបណ្តុះបណ្តាលទៅក្នុងស្ថាប័នជាតិ។
- ការបង្កើត និងអនុម័ត**បទដ្ឋាននីតិវិធីប្រតិបត្តិការ**គំរូសម្រាប់ការស៊ើបអង្កេតទៅលើការជួញដូរ។ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន គំរូបទដ្ឋាននីតិវិធីប្រតិបត្តិការ ត្រូវយកទៅកែច្នៃសម្រាប់ប្រើប្រាស់នៅថ្នាក់ជាតិ។

## វឌ្ឍនភាពទាក់ទងនឹងរចនាសម្ព័ន្ធ និងអាណត្តិការងារ

មានភាពខុសគ្នាយ៉ាងធំធេងរវាងរដ្ឋសមាជិកអាស៊ានទាក់ទងនឹងរចនាសម្ព័ន្ធនៃការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ជំនាញរបស់ខ្លួន រួមមាន ភាពខុសគ្នាពាក់ព័ន្ធនឹងអាណត្តិការងារ និងអំណាច។ នៅក្នុងតំបន់ទាំងមូល គេរកឃើញភាពខុសគ្នានៅក្នុង "គំរូ" នីមួយៗក្នុងចំណោមគំរូទាំង ៣ ដែលបានបង្ហាញខាងលើ។ ឧទាហរណ៍ ការឆ្លើយតបឯកទេសរបស់**ប្រទេសថៃ** ពាក់ព័ន្ធនឹងភ្នាក់ងារចំនួន ២ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស (ATPD) នៃនគរបាលភូមិន្ទថៃ (RTP) ទទួលបន្ទុកស៊ើបអង្កេតភាគច្រើន ចំណែកឯនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) នៅក្នុងក្រសួងយុត្តិធម៌ ទទួលបន្ទុកស៊ើបអង្កេតសំណុំរឿងធំៗ។

ទាំង**ប្រទេសថៃ** និង**វៀតណាម** បានបង្កើតអង្គភាពឯកទេសដែលទទួលអាណត្តិការងារឆ្លើយតបទៅនឹងរបាយការណ៍ស្តីពីបទល្មើសជួញដូរនៅរដ្ឋធានី ហើយក៏អាចទទួល និងធ្វើសកម្មភាពទៅលើសំណុំរឿងដែលបានបញ្ជូនមកពីនគរបាលខេត្ត និងតំបន់ដែរ។ ក៏ប៉ុន្តែ បទពិសោធន៍នៅក្នុងតំបន់បានបញ្ជាក់ពីសារៈសំខាន់ នៃនីតិវិធីលម្អិតដែលគ្រប់គ្រងដំណើរការបញ្ជូនសំណុំរឿងទៅអង្គភាពឯកទេស។ នៅពេលពុំមាននីតិវិធីទាំងនេះ មានហានិភ័យមួយគឺ

[៥៨] ផែនការសកម្មភាពអាស៊ាន វគ្គ IV.D(a)

ថា អង្គភាពមិនអាចបំពេញការងារគ្រប់គ្រងឯកទេស និងផ្តល់ការណែនាំទៅលើការបើកការស៊ើបអង្កេតដែលបានធ្វើឡើងដោយសហការីមិនមែនជំនាញបានទេ។ ការឆ្លើយតបឯកទេសរបស់ថៃក៏បានបែងចែកភ្នាក់ងារ ជា២ផងដែរគឺៈ អង្គភាពឯកទេសជួញដូរនៅក្នុងនគរបាលភូមិន្ទថៃ និងនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) នៅក្នុងក្រសួងយុត្តិធម៌។ DSI ទទួលខុសត្រូវស៊ើបអង្កេតទៅលើការជួញដូរជាក់លាក់រួមទាំងសំណុំរឿងធំៗ។

នៅ**ប្រទេសវៀតណាម** នគរបាលមូលដ្ឋានត្រូវផ្តល់ស្ថិតិស្តីពីបទល្មើសជួញដូរទៅអង្គភាពឯកទេសមជ្ឈិមរៀងរាល់ ៦ ខែម្តង។ ក្រៅពីនេះ អង្គភាពទីប្រឹក្សានគរបាលថ្នាក់ខេត្ត ត្រូវប្រមូលព័ត៌មានពីទីភ្នាក់ពាក់ព័ន្ធទាំងអស់ផ្សេងទៀត ហើយរាយការណ៍អំពីស្ថាប័នជួញដូរនៅក្នុងតំបន់របស់ខ្លួន ទៅការិយាល័យអចិន្ត្រៃយ៍ទទួលបន្ទុកផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្សប្រចាំត្រីមាស។ នៅប្រទេសថៃ គិតមកត្រឹមឆ្នាំ២០១០ នីតិវិធីត្រូវបានដាក់ឱ្យអនុវត្តដើម្បីឱ្យនគរបាលនៅក្នុងតំបន់ ខេត្ត និងមូលដ្ឋានត្រូវរាយការណ៍ពីសំណុំរឿងជួញដូរទៅនាយកមជ្ឈមណ្ឌលការការពារកុមារ និងស្ត្រី និងផ្នែកប្រឆាំងការជួញដូរមនុស្ស ហើយសំណុំរឿងទាំងនេះត្រូវបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យពាក់ព័ន្ធក្នុងរយៈពេល ៣ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រទេសឥណ្ឌូនេស៊ី** និង**ហ្វីលីពីន**បានបង្កើតអង្គភាពឯកទេសដែលមានជំនួយបន្ថែមពីអង្គភាពតូចៗ (រួមមានការិយាល័យស្ត្រី និងកុមារ) នៅតាមតំបន់នានា។ ជម្រើសផ្នែករចនាសម្ព័ន្ធនេះមានអត្ថប្រយោជន៍ក្នុងការពង្រីកវិសាលភាពរបស់អង្គភាពឯកទេសទៅដល់តំបន់ផ្សេងនៅក្នុងប្រទេសទាំងនេះ ដែលពុំមានអ្នកតំណាងអង្គភាព។ ក៏ប៉ុន្តែវាអាចមានជាគុណវិបត្តិមួយចំនួនដែរ។ ជាធម្មតា មន្ត្រីនៅក្នុងការិយាល័យស្ត្រី និងកុមារត្រូវធ្វើការស៊ើបអង្កេតទៅលើបទល្មើសប្រភេទស្មុគស្មាញជាច្រើន ដូចជា អំពើហិង្សាក្នុងគ្រួសារ និងការវាយប្រហារផ្លូវភេទ ហេតុនេះ ពួកគេប្រឈមនឹងហានិភ័យ ដោយមិនអាចផ្តល់តុល្យភាព រវាងតម្រូវការចាំបាច់នានាដើម្បីផ្តល់ការចាប់អារម្មណ៍ខ្ពស់ទៅលើសំណុំរឿងជួញដូរមនុស្ស។ ជាធម្មតា ការិយាល័យនៅតាមខេត្តពុំមានធនធានគ្រប់គ្រាន់ ទោះបីមុនពេលបទល្មើសជួញដូរមនុស្សទៅក្នុងអាណត្តិការងាររបស់ពួកគេក៏ដោយ។ ហេតុនេះ ពួកគេមិនអាចមានសមត្ថភាពចាំបាច់ដើម្បីធ្វើការស៊ើបអង្កេត លើការជួញដូរមនុស្សដែលស្មុគស្មាញបានទេ។ ក្រៅពីនេះ ដោយសារការិយាល័យទាំងនេះផ្តោតតែទៅលើស្ត្រី និងកុមារនោះ មន្ត្រីដែលបម្រើការងារនៅការិយាល័យទាំងនេះពុំមានធនធាន ការបណ្តុះបណ្តាល ឬផ្តោតលើការឆ្លើយតបទៅនឹងបទល្មើសជួញដូរពាក់ព័ន្ធនឹងបុរសឡើយ។

នៅ**ប្រទេសហ្វីលីពីន** ការិយាល័យទទួលបន្ទុកបទល្មើសមកលើកុមារតាមអ៊ិនធឺណេត (ICAC) ត្រូវបានបង្កើតឡើងនៅក្រោមមជ្ឈមណ្ឌលការពារស្ត្រី និងកុមារ (WCPC) បានបង្កើតជាដៃគូជាមួយបេសកកម្មយុត្តិធម៌អន្តរជាតិ។ ការិយាល័យ ICAC ត្រូវបានបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ WCPC និងផ្តល់ភាពឯកទេសដល់ការស៊ើបអង្កេតទៅលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រព័ន្ធអនឡាញ។ ចំណុចនេះខុសពីការគ្របដណ្តប់កាន់តែ “ទូទៅ” របស់ក្រុមប្រឆាំងឧក្រិដ្ឋកម្មបច្ចេកវិទ្យា PNP (ACG) ដែលមានឯកទេសទៅលើបទល្មើសអនឡាញទាំងអស់ “ដើម្បីធ្វើប្រតិបត្តិការល្អិតល្អន់ និងមាននិរន្តរភាពប្រឆាំងនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យាដោយក្រុមឧក្រិដ្ឋជនដែលមានការចាត់តាំង ក្រុមមានអង្គការចាត់តាំង បុគ្គលល្បីឈ្មោះ ដែលប្រើប្រាស់ឧបករណ៍ពាក់ព័ន្ធនឹងអ៊ិនធឺណេត និងកុំព្យូទ័រជាសមាសធាតុចម្បងនៅក្នុងសកម្មភាពល្មើសរបស់ខ្លួន (ពីគេហទំព័រ ACG)”។ ការិយាល័យ ICAC សហការជាមួយ ACG នៅពេលមានតម្រូវការ។

**ប្រទេសកម្ពុជា** និង**ឡាវ** ក៏បានបង្កើតអង្គភាពឯកទេសកណ្តាលដែរ ដោយមានជំនួយបន្ថែមពីបណ្តាញអង្គភាពឯកទេសនៅតាមខេត្តនីមួយៗ។ នៅ**ប្រទេសឡាវ** អង្គភាពឯកទេសកណ្តាលទទួលខុសត្រូវការងារស៊ើបអង្កេតបទល្មើស

ជួញដូរទាំងអស់ដែលបានរាយការណ៍នៅថ្នាក់ជាតិ។ អង្គភាពនៅតាមខេត្តទទួលខុសត្រូវការងារជាអង្គភាពបង្គោលសម្រាប់បញ្ហាទាំងអស់ពាក់ព័ន្ធនឹងការជួញដូរ រួមទាំងការស៊ើបអង្កេតផងដែរ។ អង្គភាពនៅតាមខេត្តទាំងនោះ ជាអ្នករាយការណ៍ទៅអង្គភាពឯកទេសកណ្តាល។ ក្នុងការអនុវត្តន៍ជាក់ស្តែង បទល្មើសជួញដូរទាំងអស់ដែលបាន រាយការណ៍ ហាក់ដូចជាត្រូវបានបញ្ជូនទៅតាមផ្នែក នៅតាមខេត្តដើម្បីធ្វើការស៊ើបអង្កេត ចំណែកឯកអង្គភាពឯកទេសកណ្តាល ជាអ្នកធ្វើការស៊ើបអង្កេតទៅលើសំណុំរឿងស្មុគ្រស្មាញ ឬឆ្លងដែន។

នៅ**ប្រទេសកម្ពុជា** ក៏ដូចជានៅប្រទេសឡាវដែរ មានអង្គភាពឯកទេសកណ្តាលមួយ នៅរាជធានីភ្នំពេញ ដែលមានជំនួយបន្ថែមពីអង្គភាពតូចៗនៅតាមខេត្តនីមួយៗ។ អង្គភាពថ្នាក់ខេត្តអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងបាន ហើយអង្គភាពកណ្តាល (មានមូលដ្ឋាននៅភ្នំពេញ) អាចផ្តល់ដំបូន្មានដល់អង្គភាពនៅតាមខេត្តទាំងនោះបានតាមការណែនាំរបស់អគ្គស្នងការ អង្គភាពកណ្តាលអាចទទួលខុសត្រូវចំពោះសំណុំរឿងដែលកំពុងដំណើរការដោយអង្គភាពថ្នាក់ខេត្តបាន។ គុណវិបត្តិមួយចំនួនប្រព័ន្ធនៅកម្ពុជាដែលមានអង្គភាពឯកទេសកណ្តាល និងអង្គភាពតូចៗនៅតាមខេត្តនៅក្នុងបណ្តុំ និងការរៀបចំគឺថា មេបញ្ជាការនៅតាមខេត្ត ត្រូវរាយការណ៍មកស្នងការនគរបាលខេត្ត មិនមែនរាយការណ៏មកនាយកអង្គភាពឯកទេសកណ្តាលទេ។ ពេលខ្លះយូរៗម្តង ចំណុចនេះបង្កការលំបាកដោយសារមានអាទិភាពបញ្ច្រាសគ្នា។

**ប្រទេសមីយ៉ាន់ម៉ា** មានវិធីសាស្ត្រនៃបណ្តាញស្រដៀងគ្នាដែរ ដែលអង្គភាពឯកទេសកណ្តាលមួយដែលគាំទ្រដល់ក្រុមការងារប្រឆាំងការជួញដូរថ្នាក់ស្រុក និង អង្គភាពការពារកុមារ។ ក៏ប៉ុន្តែ អង្គភាពឯកទេសកណ្តាល និងអង្គភាពថ្នាក់ស្រុកពុំមានសិទ្ធិអំណាចដំណើរការ ឬគ្រប់គ្រងការស៊ើបអង្កេតទៅលើការជួញដូរទេ។ នាពេលនេះ ដោយមានការអភិវឌ្ឍន៍នាពេលថ្មីៗនេះ និងការផ្តល់សច្ចាប័នដល់ "គោលការណ៍ណែនាំកិច្ចសហប្រតិបត្តិការស៊ើបអង្កេតលើការជួញដូរមនុស្ស" ដោយប្រធាននគរបាល ដំបូន្មានរបស់អង្គភាពឯកទេស និងការគ្រប់គ្រងការស៊ើបអង្កេត (រួមទាំងការគាំទ្រដល់ជនរងគ្រោះ) ត្រូវបានផ្តល់នៅថ្នាក់ស្រុក ទៅដល់អ្នកស៊ើបអង្កេតនៅថ្នាក់មូលដ្ឋាន។ ជាងនេះទៀត នគរបាលផ្នែកប្រឆាំងការជួញដូរមនុស្ស អាចជួយរាល់សំណុំរឿងជួញដូរមនុស្សទាំងអស់ អនុលោមទៅតាមការណែនាំថ្មីរបស់ប្រធាននគរបាល នៃកងកម្លាំងនគរបាលមីយ៉ាន់ម៉ា។

### *ប្រអប់អត្ថបទ ៣៖ ឧទាហរណ៍អនុវត្តន៍៖ ការធានានូវការផ្សព្វផ្សាយទូទាំងប្រទេស*

អង្គភាពប្រឆាំងការជួញដូរជំនាញភាគច្រើនបានបោះជំហានដើម្បីនូវការផ្សព្វផ្សាយទូទាំងប្រទេស។ នៅក្នុងប្រទេសមួយចំនួន ដូចជា**ប្រទេសឡាវ** យន្តការនានាដែលបានបង្កើតឡើងក្រោមច្បាប់ប្រឆាំងការជួញដូរជាតិ មានការទទួលខុសត្រូវពិសេសនៅក្នុងចំណុចនេះ។ នៅ**ប្រទេសឥណ្ឌូនេស៊ី** បុគ្គលិកមកពីអង្គភាពប្រឆាំងការជួញដូរជាតិនៅក្រុងហ្សាការតា ត្រូវបានដាក់ពង្រាយនៅទូទាំងប្រទេសទៅតាមការចាំបាច់។ **ប្រទេសមីយ៉ាន់ម៉ា** បានបង្កើតបណ្តាញក្រុមការងារប្រឆាំងការជួញដូរនៅទូទាំងប្រទេស។ នៅ**ប្រទេសប្រ៊ុយណេ** អ្នកស៊ើបអង្កេតឯកទេសបានធ្វើដំណើរជាប្រចាំទៅតាមស្រុក ដើម្បីផ្តល់ការណែនាំដល់មន្ត្រីជួរមុខ។

ក៏ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង ការផ្តល់ការឆ្លើយតបតាមរយៈការស៊ើបអង្កេតពិតប្រាកដនៅទូទាំងប្រទេសគឺជាការប្រឈមដែលបន្តមានចំពោះរដ្ឋសមាជិកអាស៊ានទាំងអស់ ដោយសារធនធាន និងការកំហិតផ្សេងទៀត។

នៅ**ប្រទេសសិង្ហបុរី** ការទទួលខុសត្រូវក្នុងការស៊ើបអង្កេតទៅលើបទល្មើសជួញដូរ មានការចែកដាច់ពីគ្នា អនុលោមទៅតាមលក្ខណៈនៃការកេងប្រវ័ញ្ច។ អង្គភាពឯកទេសមួយនៅក្នុងកងកម្លាំងនគរបាលសិង្ហបុរី ធ្វើការស៊ើបអង្កេតទៅលើសំណុំរឿងកេងប្រវ័ញ្ចផ្លូវភេទ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត ចំណែកក្រុមការងារពិសេសរបស់ក្រសួងពលករបង្កើតការអនុវត្តន៍ច្បាប់ប្រឆាំងនឹងការជួញដូរក្នុងការងារ។ អ្នកស៊ើបអង្កេតដែលស្ថិតនៅអង្គភាពទាំងនោះននឹងដោះស្រាយសំណុំរឿងជួញដូរមនុស្ស នៅពេលមានករណីកើតមានឡើង។

ផ្នែកស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌរបស់កងកម្លាំងនគរបាលភូមិន្ទ**ម៉ាឡេស៊ី**មានអង្គភាពឯកទេសផ្នែកប្រឆាំងការជួញដូរ (អង្គភាព ATIPSOM) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨។ អង្គភាពនេះស្ថិតនៅក្នុងផ្នែក D៧ ដែលដោះស្រាយឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង រួមមាន ក្រុមជើងអ្នកលេង និងបទល្មើសបន្ទាប់បន្សំផ្សេងទៀតក្រៅការជួញដូរ និងការរត់ពន្ធជនទេសន្តរប្រវេសន៍។ អង្គភាពនេះទទួលខុសត្រូវជួយសង្គ្រោះជនរងគ្រោះពីការជួញដូរ ចាប់ខ្លួនចារី ស៊ើបអង្កេត និងទប់ស្កាត់សកម្មភាពជួញដូរមនុស្ស និងរត់ពន្ធជនទេសន្តរប្រវេសន៍។

**ប្រទេសប្រ៊ុយណេ**បានរាយការណ៍ថា ខ្លួនបានបង្កើតអង្គភាពស៊ើបអង្កេតការជួញដូរមនុស្ស (HTU) នៅក្នុងកងកម្លាំងនគរបាលភូមិន្ទប្រ៊ុយណេនៅឆ្នាំ២០១១។ អង្គភាពនេះមានឯកទេសក្នុងការស៊ើបអង្កេតលើសំណុំរឿងជួញដូរមនុស្សនៅប្រទេសប្រ៊ុយណេ អនុលោមតាមបទបញ្ជាស្តីពីការជួញដូរ និងការរត់ពន្ធមនុស្ស (ឆ្នាំ២០០៤)។ អង្គភាពទទួលការបញ្ជូនពីភ្នាក់ងារផ្សេងទៀត ដោយតាមដានសូចនាករនៃការជួញដូរ នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងអំពើពេស្យាចារ ការមិនបង់ប្រាក់ឈ្នួល កម្មករដែលរត់ចេញពីកន្លែងធ្វើការ ឬការបំពារបំពានរាងកាយចំពោះកម្មករ។ សំណុំរឿងនានាដែលមានធាតុផ្សំការជួញដូរមនុស្សត្រូវបានបញ្ជូនទៅអង្គភាព ឬនាយកដ្ឋានផ្សេងទៀត។ បន្ទាប់មក អង្គភាពនេះនឹងវិភាគទៅលើការរកឃើញ និងសម្រេចថាតើ សំណុំរឿងនេះត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់ HTU ឬយ៉ាងណា។ ប្រសិនបើស្ថិតក្នុងសមត្ថកិច្ចរបស់អង្គភាពនេះ អង្គភាពនេះអាចដំណើរការស៊ើបអង្កេតបន្ថែមទៀត ឬបញ្ជូនសំណុំរឿងនេះទៅការិយាល័យអគ្គមេធាវី។ បើមិនស្ថិតក្នុងសមត្ថកិច្ចរបស់អង្គភាពនេះទេ សំណុំរឿងនេះនឹងត្រូវបញ្ជូនត្រឡប់ទៅអង្គភាព ឬនាយកដ្ឋានដើមវិញ។

លើកលែងតែប្រទេសប្រ៊ុយណេមួយ គំរូនៅរដ្ឋសមាជិកអាស៊ានទាំងអស់ដែលបានរៀបរាប់ខាងលើមានសមត្ថភាពក្នុងការផ្តល់នូវការឆ្លើយតបឯកទេសនៅទូទាំងប្រទេសទៅនឹងបទល្មើសជួញដូរក្នុងកម្រិតមួយ ដែលមានវិសាលភាពតិចតួច។ ក៏ប៉ុន្តែ វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា កត្តាភូមិសាស្ត្រគឺជាទិដ្ឋភាពនៃធាតុផ្សំនេះ។ សារៈសំខាន់ ជាពិសេសគឺថា តើការឆ្លើយតបមានការពិភាក្សា ឬឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការអនុវត្តច្បាប់នៅមូលដ្ឋាន និងរវាងភ្នាក់ងារច្រើន ឬយ៉ាងណា។ ច្បាស់ណាស់ រដ្ឋសមាជិកអាស៊ានទាំងនោះដែលពឹងផ្អែកតែទៅលើអង្គភាពកណ្តាលដែលអាចទៅដល់ភូមិសាស្ត្រទំហំតូចដើម្បីផ្តល់ការឆ្លើយតប មិនទំនងដូចជាមានរចនាសម្ព័ន្ធដើម្បីជួយសម្រួលដល់ការពិគ្រោះយោបល់ជាទៀងទាត់ និងទៅដល់មូលដ្ឋាន ដើម្បីធានាឲ្យមានការឆ្លើយបវិញនោះទេ។

គំរូបច្ចុប្បន្នដែលអនុវត្តនៅប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ និងហ្វីលីពីនហាក់ដូចជាមានសក្តានុពលខ្ពស់ជាងគេក្នុងការទៅដល់ទីតាំងភូមិសាស្ត្រ និងវិធីសាស្ត្រដែលបត់បែន ដោយសាររចនាសម្ព័ន្ធ និងអាណត្តិការងារនៃគំរូរបស់ខ្លួនធ្វើឲ្យពួកគេមានវត្តមាន និងតួនាទីនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានបាន។ ក៏ប៉ុន្តែ ទោះបីនៅតាមប្រទេសទាំងនេះក្រីតែវិសាលភាពដែលពួកគេធ្វើការពិគ្រោះយោបល់ជាទៀងទាត់ជាមួយសហការីនៅមូលដ្ឋាន និងដៃគូភ្នាក់ងារជាច្រើនផ្សេងទៀត ជាពិសេសភ្នាក់ងារដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះ នៅតែពុំមានភាពច្បាស់លាស់នៅឡើយ។

## វឌ្ឍនភាពទាក់ទងនឹងអំណាចសមស្រប

មានភាពខុសគ្នាសំខាន់ៗនៅក្នុងក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីនៅក្នុងអង្គភាពឯកទេសនៅតំបន់អាស៊ានដែលកំពុងប្រតិបត្តិការ។ ចំណុចនេះមានឥទ្ធិពលទៅលើលក្ខណៈនៃអំណាចក្នុងការស៊ើបអង្កេតរបស់អង្គភាពឯកទេស។ ពាក់ព័ន្ធនឹងការស៊ើបអង្កេត មុនពេលកើតហេតុ ក្របខ័ណ្ឌគតិយុត្តិនៅថ្នាក់ជាតិដែលពាក់ព័ន្ធអាចនាំឲ្យមានភាពខុសគ្នាជាខ្លាំង។ ឧទាហរណ៍មិនមែនគ្រប់រដ្ឋសមាជិកអាស៊ានទាំងអស់សុទ្ធតែអាចអនុវត្តទៅតាមផ្លូវច្បាប់នូវបច្ចេកទេសនានាដែលត្រូវបានកំណត់ថា មានប្រយោជន៍ចំពោះការស៊ើបអង្កេតមុនពេលកើតហេតុនៅក្នុងសំណុំរឿងជួញដូរមនុស្សនោះទេ។ មានតែនៅក្នុង**ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ** និង**វៀតណាម**ប៉ុណ្ណោះដែលអង្គភាពឯកទេស (ស្ថិតក្រោមការកំហិតតឹងរ៉ឹង និងដំណើរការអនុម័តយល់ព្រមមួយចំនួន) ត្រូវបានផ្តល់អំណាចនៅក្នុងប្រតិបត្តិការឃ្លាំមើល និងប្រតិបត្តិបង្កប់ខ្លួន[៩៩]។

ចំពោះបញ្ហាពាក់ព័ន្ធអង្គភាពឯកទេសទាំងអស់ មិនសុទ្ធតែបានទទួលអំណាចស្របច្បាប់ ឬទៅតាមនីតិវិធីដើម្បីប្រើប្រាស់បច្ចេកទេសទិញសាកល្បងនោះទេ[១០០]។ វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ជាពិសេស ភាពទន់ខ្សោយ ឬមិនមានការកែលម្អ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ បច្ចេកទេសទាំងនេះ អាចមានការលំបាកក្នុងការគ្រប់គ្រងបែបវិជ្ជាជីវៈ និងក្រមសីលធម៌។ ក៏ប៉ុន្តែ នៅពេលដែលរៀបចំបានត្រឹមត្រូវ ប្រតិបត្តិការទិញសាកល្បង បង្ហាញនូវការចំណាយតិច មានហានិភ័យទាប ដែលធានាបាននូវភស្តុតាងមានគុណភាពខ្ពស់ប្រឆាំងនឹងជនសង្ស័យច្រើននាក់។ អង្គភាពឯកទេសដែលមិនអាចអនុវត្តបច្ចេកទេសនេះបាន ឬដែលពុំមានសមត្ថភាពសក្តិសមនឹងយកការទិញសាកល្បងមកប្រើ មិនត្រូវបានអនុញ្ញាតឲ្យប្រើនូវមធ្យោបាយមួយក្នុងការចំណោមមធ្យោបាយមានប្រសិទ្ធភាពបំផុតក្នុងការប្រមូលសក្ខីកម្មរបស់ជនរងគ្រោះ និងផ្តល់នូវធាតុផ្សំសំខាន់នៃការជួញដូរ និងបទល្មើសពាក់ព័ន្ធនានា។

ការកម្រិតផ្នែកគតិយុត្តិក៏អាចរារាំងដល់ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុផងដែរ។ រដ្ឋសមាជិកអាស៊ានភាគច្រើនបានបង្កើតនូវវេទិកាគតិយុត្តិចាំបាច់ដើម្បីគាំទ្រដល់ការស៊ើបអង្កេតផ្នែកហរិញ្ញវត្ថុ ទៅលើសំណុំរឿងជួញដូរ។ ក៏ប៉ុន្តែ អង្គភាពឯកទេសជាច្រើនពុំបានទទួលអំណាចក្នុងការប្រើប្រាស់វេទិកានោះទេ។ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ជាការទទួលខុសត្រូវផ្តាច់មុខរបស់អង្គភាពអនុវត្តន៍ច្បាប់មួយដោយឡែក ដូចជាអង្គភាពស៊ើបអង្កេតបទល្មើសផ្នែកហិរញ្ញវត្ថុ ឬ នៅក្រោមការទទួលខុសត្រូវរបស់ស្ថាប័នមួយដែលដាច់ចេញពីនគរបាលទាំងស្រុង។ ទោះបីចំណុចនេះ ធានានូវភាពឯកទេសក្នុងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុក៏ដោយ តែការចែកដាច់ពីគ្នានៃមុខងារក៏អាចកាត់បន្ថយសមត្ថភាពរួម និងប្រសិទ្ធភាពរបស់អង្គភាពឯកទេសដែរ។ ចំណុចនេះដោយសារការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពបំផុតគឺការស៊ើបអង្កេតដែលធ្វើឡើងស្របគ្នា និងដំណាលគ្នា ទៅនឹងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌចម្បង។ នៅពេលដែលនាយកដ្ឋានដាច់ដោយឡែកមួយ បានទទួលភារកិច្ចឲ្យធ្វើ

---

[៩៩] គួរកត់សម្គាល់ថា មន្ត្រីនៃអង្គភាពប្រឆាំងការជួញដូរកម្ពុជាត្រូវបានផ្តល់អំណាចក្នុងការធ្វើប្រតិបត្តិការឃ្លាំងមើលបាន ដោយកំណត់ថាត្រូវធ្វើនៅទីកន្លែងសាធារណៈ។ ក្រមព្រហ្មទណ្ឌកម្ពុជាហាមឃាត់ការថតសំឡេងសន្ទនា ឬរូបភាពជនសង្ស័យដោយសម្ងាត់នៅទីកន្លែងឯកជន (មាត្រា ៣០១ និង ៣០២)។

[១០០] ប្រតិបត្តិការទិញសាកល្បងពាក់ព័ន្ធទៅនឹងមន្ត្រីអនុវត្តន៍ច្បាប់ក្លែងធ្វើជាអតិថិជន ដើម្បីប្រមូលភស្តុតាងនៃបទល្មើស។ នៅក្នុងបរិបទជួញដូរ ការទិញសាកល្បងដែលត្រូវរៀបចំផែនការ និងគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នអាចជាវិធីស្របច្បាប់ក្នុងការប្រមូលភស្តុតាងអំពីអង្គហេតុដែលជនសង្ស័យពិតជាកំពុងលក់ ឬផ្តល់ការលក់មនុស្សណាម្នាក់ ឬសេវាកម្មរបស់ពួកគេ។

ការស៊ើបអង្កេតទៅលើផ្នែកហិរញ្ញវត្ថុនៃការស៊ើបអង្កេតដែលពាក់ព័ន្ធនឹងការជួញដូរ ការស៊ើបអង្កេតនោះអាចរងផលប៉ះពាល់ដោយប្រកួតប្រជែងនូវតម្រូវការចាំបាច់ និងពុំមានការសម្របសម្រួលគ្នាជាមុន។ អង្គភាពប្រឆាំងការជួញដូរមួយចំនួនព្យាយាមដោះស្រាយបញ្ហាទាំងនេះ ឧទាហរណ៍ ដោយរៀបចំនូវអ្នកស៊ើបអង្កេតទៅលើបទល្មើសហិរញ្ញវត្ថុគាំទ្រ ដើម្បីជួយនៅក្នុងសំណុំរឿងជួញដូរមនុស្សជាក់លាក់។

## វឌ្ឍនភាពទាក់ទងនឹងការផ្តល់ថវិកាគ្រប់គ្រាន់ និងជាបន្តបន្ទាប់

ដូចបានកត់សម្គាល់ខាងលើ ការឆ្លើយតបនៃការស៊ើបអង្កេតឯកទេសទៅនឹងការជួញដូរមនុស្សតម្រូវឱ្យមានការផ្តល់ថវិកាសមរម្យ។ នេះជាការជាចាំបាច់ដើម្បីទប់ទល់ការចំណាយមូលដ្ឋានដូចជា ប្រាក់បៀវត្សរ៍ ការស្នាក់នៅ និងបរិក្ខារ និងការចំណាយពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេត។ ជាទូទៅ នៅក្នុងតំបន់ទាំងមូល ធនធានដែលបានផ្តល់ដល់អង្គភាពឯកទេសមានការកើនឡើងជាលំដាប់។ ឧទាហរណ៍ នៅ**ប្រទេសមីយ៉ាន់ម៉ា** ក្រសួងកិច្ចការតាមផ្ទះបានពង្រឹងការឆ្លើយតបឯកទេសនៃការបង្កើតផ្នែកប្រឆាំងការជួញដូរមនុស្ស (ATIPD) ដែលទទួលខុសត្រូវស៊ើបអង្កេត និងមានថវិកាដែលត្រូវបានអនុម័តប្រចាំឆ្នាំ។ ក្រៅពីនេះ ក្រុមការងារស៊ើបអង្កេតថ្មីៗត្រូវបានបង្កើតឡើង ហើយមន្ត្រីមួយចំនួនត្រូវបានចាត់តាំងទៅកាន់សំណុំរឿងជួញដូរ មានចំនួនជាងពីរដងលើសពីរបាយការណ៍មុន។

នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ថវិកាដែលផ្តល់ដល់ការឆ្លើយតបឯកទេសមានភាពគ្រប់គ្រាន់ដើម្បីចំណាយទៅលើប្រាក់បៀវត្សរ៍ និងការចំណាយផ្សេងៗ តែមិនមែនការស៊ើបអង្កេតទេ។ នៅប្រទេសផ្សេងទៀត អ្នកស៊ើបអង្កេតតម្រូវចំណាយថវិកាផ្ទាល់ខ្លួន ទៅលើការចំណាយក្នុងការងារ និងទទួលបានការសងមកវិញនៅពេលក្រោយ ប្រសិនបើជនសង្ស័យត្រូវបានចាប់ខ្លួន។ អង្គភាពឯកទេសមួយចំនួននៅក្នុងតំបន់ពឹងផ្អែកទៅលើការគាំទ្រពីម្ចាស់ជំនួយខាងក្រៅ មិនត្រឹមតែការទិញសម្ភារបរិក្ខាប៉ុណ្ណោះទេ តែជាពិសេសផ្តោត ទៅលើការចំណាយប្រតិបត្តិការជាក់លាក់ទៀតផង។ ឧទាហរណ៍ អង្គភាពមួយចំនួនស្នើសុំការគាំទ្រហិរញ្ញវត្ថុពីស្ថានទូតបរទេស ដែលបញ្ជូនសំណុំរឿងឱ្យពួកគេស៊ើបអង្កេត។ ការពិភាក្សាជាមួយបុគ្គលិកអង្គភាពឯកទេស ក្នុងរយៈពេលជាច្រើន បានបញ្ជាក់ថា អ្នកប្រតិបត្តិជាច្រើនយល់ឃើញថា ពួកគេពុំមានបុគ្គលិកគ្រប់គ្រាន់នៅក្នុងអង្គភាពរបស់ខ្លួន ហើយថាប្រាក់បៀវត្សរ៍សម្រាប់អ្នកស៊ើបអង្កេត និងក្តីសង្ឃឹមថានឹងទទួលការតម្លើងឋានៈ ពុំគ្រប់គ្រាន់ ដែលជាការលើកទឹកចិត្តដល់ពួកគេឱ្យស្ថិតនៅក្នុងអង្គភាពឯកទេសទេ។ កង្វះធនធានបែបនេះធ្វើឱ្យអង្គភាពទាំងមូល ស្ថិតក្នុងហានិភ័យនៃការឆ្លើយតបឯកទេស និងធ្វើឱ្យមានការលំបាកជាខ្លាំងដល់អង្គភាពក្នុងការបំពេញទៅតាមភារកិច្ចរបស់ខ្លួន។

ប្រភពធនធានគឺមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងគុណភាពនៃការស៊ើបអង្កេត។ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវបច្ចេកទេសស៊ើបអង្កេត ក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ ដែលចាំបាច់ដើម្បីធានាដល់គុណភាពនៃភស្តុតាង តម្រូវឱ្យមានសម្ភារៈបរិក្ខានានាដូចជា បន្ទប់ស្តាប់ចម្លើយ បរិក្ខាបច្ចេកទេសដើម្បីគាំទ្រដល់ការថតសំឡេងស្តាប់ចម្លើយ និងឧបករណ៍ឃ្លាំមើលដោយសម្ងាត់សម្រាប់ប្រតិបត្តិការមុនពេលកើតហេតុ។ នៅក្នុងតំបន់អាស៊ាន មានឧទាហរណ៍ជាក់ស្តែងមួយចំនួនដែលអង្គភាពឯកទេសបានប្រើប្រាស់នូវបរិក្ខាទាំងនេះយ៉ាងល្អ។

*ប្រអប់អត្ថបទ ៤៖ ឧទាហរណ៍អនុវត្តន៍៖ ការផ្តល់ធនធានដើម្បីកែលម្អគុណភាពនៃការស៊ើបអង្កេត*

នៅឆ្នាំ២០១៦ ក្រុមប្រឹក្សាអន្តរភ្នាក់ងារប្រឆាំងការជួញដូរ (IACAT) របស់**ប្រទេសហ្វីលីពីន** ចាប់ផ្តើមលើកកម្ពស់ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ស្របទៅនឹងបច្ចេកទេសស៊ើបអង្កេតផ្សេងទៀត។ ចំណុចនេះបានបញ្ចូលការបង្កើតសៀវភៅពន្យល់អំពីការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ (FI)។

នៅ**ប្រទេសឥណ្ឌូនេស៊ី** នគរបាលជាតិឥណ្ឌូនេស៊ីបានផ្តល់ទីកន្លែងសម្រាប់ស្តាប់ចម្លើយជនរងគ្រោះ នៅក្នុងការិយាល័យអង្គភាពឯកទេសរបស់ខ្លួននៅទីក្រុងហ្សាការតា ព្រមទាំងនៅក្នុងការិយាល័យផ្នែកស្ត្រី និងកុមារនៅថ្នាក់ខេត្ត និងស្រុក។ សម្ភារៈបរិក្ខានៅហ្សាការតា ទោះបីជាមិនទំនើបដូចបន្ទប់ស្តាប់ចម្លើយជនរងគ្រោះនៅប្រទេសថៃក្តី តែបរិក្ខានេះត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យបរិយាកាសស្តាប់ចម្លើយកាន់តែមានភាពសក្តិសមសម្រាប់ជនរងគ្រោះ។ ត្បិតតែវាមិនមែនជាផ្នែកសំខាន់ក៏ពិតមែនទេ តែការបំពាក់ទៅដោយគ្រឿងសង្ហារឹមមានផាសុកភាព និងការរៀបចំដែលធ្វើឱ្យជនរងគ្រោះមានអារម្មណ៍មិនសូវភ័យខ្លាច និងដើម្បីធានានូវឯកជនភាព និងរក្សាការសម្ងាត់ គឺជាការសំខាន់។

**ប្រទេសមីយ៉ាន់ម៉ា** បានធ្វើការកែលម្អគុណភាព និងបរិមាណធនធានមនុស្សសម្រាប់ស៊ើបអង្កេតទៅលើបទល្មើសជួញដូរ។ នាពេលបច្ចុប្បន្ននេះ មានមន្ត្រីរាប់រយនាក់ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាល និងដាក់ពង្រាយ។

នៅ**ប្រទេសថៃ** នាពេលថ្មីៗនេះ នគរបាលភូមិន្ទថៃបានបង្កើតក្រុមអ្នកជំនាញផ្នែកជួញដូរមនុស្សចល័ត ដើម្បីកែលម្អគុណភាពនៃការស៊ើបអង្កេត។ ក្រុមនោះផ្តល់ការបង្រៀន និងការគាំទ្រផ្សេងទៀតដល់ការស៊ើបអង្កេតនៅទូទាំងប្រទេស។

អង្គភាពឯកទេសប្រឆាំងការជួញដូរ ត្រូវការប្រើប្រាស់បរិក្ខាបច្ចេកទេសថតសំឡេងដូចជា ម៉ាស៊ីនថតវីដេអូ កាមេរ៉ាបង្កប់ ឧបករណ៍ថតសំឡេង។ បរិក្ខាប្រភេទនេះមានសារៈសំខាន់ ជាពិសេសដើម្បីគាំទ្រដល់វិធីសាស្ត្រ នៃការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមុនពេលកើតហេតុ។ ក៏ប៉ុន្តែ បរិក្ខារបែបនេះមិនអាចរកបាននៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន។ ហេតុនេះ អ្នកស៊ើបអង្កេតនៅក្នុងករណីមួយចំនួនពឹងផ្អែកលើជនស៊ីវិលក្នុងការផ្តល់កាមេរ៉ា និងឧបករណ៍ស្តាប់សំឡេងសម្រាប់ប្រើប្រាស់ ក្នុងពេលប្រតិបត្តិការទិញសាកល្បង។

ឧទាហរណ៍ ការស៊ើបអង្កេតនាពេលថ្មីនៅក្នុងតំបន់ ពាក់ព័ន្ធនឹងការប្រើប្រាស់បរិក្ខា សោតទស្សន៍ដែលខ្ចីពីស្ថានីយ៍ទូរទស្សន៍ និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដើម្បីថតសកម្មភាពប្រតិបត្តិការទិញសាកល្បង។ ជារឿយៗជនស៊ីវិលដែលផ្តល់បរិក្ខាត្រូវមានវត្តមានក្នុងពេលប្រតិបត្តិការទិញសាកល្បង ដើម្បីដំណើរការបរិក្ខានោះ។ វត្តមាន និងការចូលរួមរបស់ពួកគេនៅកន្លែងប្រមូលភស្តុតាងសម្ងាត់ ដែលមានលក្ខណៈរសើប មានហានិភ័យផ្នែកសុវត្ថិភាព។ វាក៏អាចធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃភស្តុតាង ហើយការពិតនៃប្រតិបត្តិការទាំងមូលផងដែរ។ អង្គភាពឯកទេសផ្នែកជួញដូរ គួរទទួលបានបរិក្ខាបច្ចេកទេសឃ្លាំមើល និងថតសកម្មភាពឱ្យបានសមរម្យ ដើម្បីកុំឱ្យពួកគេត្រូវពឹងផ្អែកលើជនស៊ីវិលក្នុងពេលប្រតិបត្តិការប្រមូលភស្តុតាងដែលមានលក្ខណៈរសើប ហើយនិងអាចមានគ្រោះថ្នាក់ផងដែរ។

## វឌ្ឍនភាពទាក់ទងនឹងសមភាពយេនឌ័រ

នៅគ្រប់តំបន់ទាំងអស់នៅទូទាំងពិភពលោក ស្ត្រីនៅតែបន្តមានចំនួនតិចតួចក្នុងតួនាទីប្រតិបត្តិការនៅក្នុងការអនុវត្តន៍ច្បាប់។ ប៉ុន្តែចំណុចនោះកំពុងមានការប្រែប្រួលយ៉ាងសន្សឹមៗ។ ឧទាហរណ៍ នៅក្នុងអាស៊ាន តុល្យភាពយេនឌ័រនៅក្នុងអង្គភាពឯកទេសរបស់រដ្ឋសមាជិកមានការកែលម្អគួរឲ្យកត់សម្គាល់។ **ប្រទេសថៃ**បានរាយការណ៍ថាមានការកើនឡើងចំនួនមន្ត្រីជាស្ត្រីដែលទទួលការចាត់តាំងទៅក្នុងអង្គភាពឯកទេសរបស់ខ្លួន។ មន្ត្រីទាំងនេះដើរតួនាទីយ៉ាងសកម្មនៅក្នុងការស៊ើបអង្កេត រួមមាន ការស៊ើបអង្កេតទៅបុគ្គលដែលអាចជាជនរងគ្រោះនៃការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ។ នាពេលបច្ចុប្បន្ន នៅ**ប្រទេសហ្វីលីពីន** មជ្ឈមណ្ឌលការពារស្ត្រី និងកុមារមានស្ត្រីចំនួន ៥០% និងបុរស ៥០%។

នៅ**ប្រទេសមីយ៉ាន់ម៉ា** នាពេលបច្ចុប្បន្ន ផ្នែកប្រឆាំងការជួញដូរមនុស្សមានស្ត្រី ២៣% និង បុរស ៧៧% ហើយអង្គភាពការពារកុមារមានស្ត្រី ៦០% និងបុរស ៤០%។

**នគរបាលជាតិកម្ពុជា**ក៏មានការប្រែប្រួលយ៉ាងធំធេងដែរចំពោះឋានន្តរស័ក្តិ និងការចូលរួមរបស់មន្ត្រីជាស្ត្រីនៅក្នុងអង្គភាពប្រឆាំងការជួញដូរ។ ក្រមសីលធម៌ផ្នែកយេនឌ័រត្រូវបានយកមកប្រើប្រាស់នៅទូទាំងប្រទេស ដោយផ្តល់គោលការណ៍ណែនាំដល់បុគ្គលិក ក្នុងគោលបំណងលើកកម្ពស់សមភាពយេនឌ័រក្នុងចំណោម នគរបាលជាបុរស និងស្ត្រី និង លុបបំបាត់ការរើសអើងយេនឌ័រ ក៏ដូចជានៅពេលទំនាក់ទំនងជាមួយជនរងគ្រោះ ជនសង្ស័យ សាក្សី និងសាធារៈណជនទូទៅ។ ក្រៅពីនេះ ការបង្ហាត់បង្រៀនជាបន្តដល់មន្ត្រីជាស្ត្រី អំពីភារកិច្ចប្រតិបត្តិការពេញលេញបានបង្កើនការទទួលបានកាលានុវត្តភាពក្នុងការតម្លើងឋានៈដល់ពួកគេផងដែរ។

*ប្រអប់អត្ថបទ ៥៖ ឧទាហរណ៍អនុវត្តន៍៖ ការកែលម្អតុល្យភាពយេនឌ័រនៅក្នុងអង្គភាពឯកទេស*

> **នៅប្រទេសកម្ពុជា** មន្ត្រីនគរបាលជាស្ត្រីចំនួនពីរភាគបី (៧៥ រូប) ដែលកំពុងបំពេញការងារនៅក្នុងអង្គភាពប្រឆាំងការជួញដូរទទួលបានការបណ្តុះបណ្តាលទៅលើជំនាញស៊ើបអង្កេតជាមូលដ្ឋាន និងការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។ មន្ត្រី ២២ រូបក្នុងចំណោមមន្ត្រីទាំងនោះបានឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលជាច្រើនក្នុងការអភិវឌ្ឍន៍ជំនាញ។ ពីមុនមក មន្ត្រីទាំងនេះភាគច្រើនត្រូវបានកម្រិតឲ្យបំពេញភារកិច្ចតែផ្នែករដ្ឋបាលប៉ុណ្ណោះ តែនៅពេលបច្ចុប្បន្ន ពួកគេជាច្រើនបានទទួលការអនុញ្ញាតឲ្យបំពេញភារកិច្ចប្រតិបត្តិការយ៉ាងទូលំទូលាយ។
>
> **នៅប្រទេសហ្វីលីពីន** មន្ត្រីជាស្ត្រី ១៤ រូបនៃ WCPC បានចាត់តាំងសហការីមានបទពិសោធន៍ ធ្វើជាអ្នកណែនាំដើម្បីជួយអភិវឌ្ឍជំនាញ និងចំណេះដឹងដល់ពួកគេ។ នាពេលបច្ចុប្បន្ន កម្មវិធីបង្ហាត់បង្រៀនគឺជាផ្នែកនៃប្រព័ន្ធគ្រប់គ្រងការបំពេញការងារនៅ WCPC។
>
> នៅប្រទេសហ្វីលីពីន នាពេលបច្ចុប្បន្ននេះ ផ្នែកប្រឆាំងការជួញដូរមនុស្ស (AHTRAD) របស់ការិយាល័យស៊ើបអង្កេតជាតិត្រូវបានដឹកនាំដោយស្ត្រី។
>
> **នៅប្រទេសមីយ៉ាន់ម៉ា** មានការផ្លាស់ប្តូរគោលនយោបាយដើម្បីធានាឲ្យមន្ត្រីជាស្ត្រីអាចចូលរួមក្នុងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរ។ ការបញ្ចូលមន្ត្រីជាស្ត្រីថ្មីៗទៅក្នុងក្រុមការងារប្រឆាំងការជួញដូរ (ATTFs) បានក្លាយជាទៅជាកម្មវិធីបង្ហាត់បង្រៀនដែលស្រដៀងទៅនឹងកម្មវិធីបណ្តុះបណ្តាលនៅប្រទេសកម្ពុជាដែរ។ ក្រៅពីនេះ មន្ត្រីជាស្ត្រីបានទទួលការបណ្តុះបណ្តាលស្តីពីជំនាញភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង និងដោះស្រាយបញ្ហាបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ។
>
> **នៅប្រទេសថៃ** មន្ត្រីស៊ើបអង្កេតជាស្ត្រីដែលបំពេញការងារនៅក្នុងអង្គភាពឯកទេសផ្នែកជួញដូររបស់នគរបាលភូមិន្ទថៃ បានបង្កើតសមាគមន៍មួយ ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ខ្លួន និងផ្តល់នូវវិធីសាស្ត្រផ្នែកវិញ្ញោចយេនឌ័រចំពោះបទល្មើសជួញដូរ។ សមាគមន៍នេះបានស្វែងរក និងទទួលបានការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពពីអង្គការនានាពីខាងក្រៅ។ នាពេលបច្ចុប្បន្នមានស្ត្រីនគរបាលចំនួន ៦០ រូបដែលបានបំពេញការសិក្សាកម្រិតអនុបណ្ឌិតត្រូវបានដាក់ពង្រាយជាមន្ត្រីស៊ើបអង្កេត ជារៀងរាល់ឆ្នាំ។ នាពេលបច្ចុប្បន្ន អង្គភាពឯកទេសគ្រប់គ្រងដោយមន្ត្រីនគរបាលជាស្ត្រី ដែលមានឋានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯក។

## វឌ្ឍនភាពពាក់ព័ន្ធនឹងបទដ្ឋាននីតិវិធីប្រតិបត្តិការ

បទដ្ឋាននីតិវិធីប្រតិបត្តិការរួមមានការណែនាំលម្អិតជាលាយលក្ខណ៍អក្សរ ដោយផ្អែកលើក្របខណ្ឌគតិយុត្តិ គោលនយោបាយ និងនីតិវិធីពាក់ព័ន្ធ ដែលផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវការណែនាំជាជំហានៗស្តីពីរបៀបដំណើរការស៊ើបអង្កេតទៅលើការជួញដូរ។

មានការទទួលស្គាល់យ៉ាងទូលំទូលាយថា បទដ្ឋាននីតិវិធីប្រតិបត្តិការមានតួនាទីយ៉ាងសំខាន់ក្នុងការបញ្ញត្តិ និងធានានូវការបំពេញការងារយ៉ាងមានប្រសិទ្ធភាពរបស់នគរបាលនៅគ្រប់វិស័យទាំងអស់ រួមទាំងការស៊ើបអង្កេតទៅលើការជួញដូរផងដែរ។ ក្រៅពីផ្តល់ដល់អ្នកស៊ើបអង្កេតនូវការណែនាំលម្អិតច្បាស់លាស់ ទាក់ទងនឹងសកម្មភាពស៊ើបអង្កេតសំខាន់ៗទាំងអស់ បទដ្ឋាននីតិវិធីប្រតិបត្តិការបង្កើតជាគំរូមួយចំនួនដែលអ្នកគ្រប់គ្រងអង្គភាពឯកទេសអាចត្រួត

ពិនិត្យទៅលើសកម្មភាពរបស់អ្នកស៊ើបអង្កេតម្នាក់ៗ និងវាយតម្លៃទៅលើគុណភាពនៃការស៊ើបអង្កេតធៀបទៅនឹងលក្ខខណ្ឌតម្រូវអប្បបរមា។

នៅទូទាំងតំបន់អាស៊ានទាំងមូល និងក្រោមការឧបត្ថម្ភនៃដំណើរការ HSU មានវឌ្ឍនភាពជាខ្លាំងពាក់ព័ន្ធនឹងការអភិវឌ្ឍន៍បទដ្ឋាននីតិវិធីប្រតិបត្តិការទូទៅលើការជួញដូរជាក់លាក់ ដូចដែលលើកឡើងនៅខាងក្រោម។ បទដ្ឋាននីតិវិធីប្រតិបត្តិការទាំងនេះត្រូវបានតាក់តែងឡើងដើម្បីផ្តល់នូវលទ្ធផលនៃការស៊ើបអង្កេតស៊ីចង្វាក់ និងមានគុណភាពខ្ពស់។ ក៏ប៉ុន្តែ ការអនុវត្តន៍ដំណាក់កាលទីពីរនៃដំណើរការនេះ គឺការសម្របនៅថ្នាក់ជាតិ និងការអនុវត្តន៍យ៉ាងហ្មត់ចត់នូវនីតិវិធីទាំងនេះ មិនទាន់សម្រេចបាននៅឡើយទេ។ ការវាយតម្លៃទៅលើការអនុវត្តន៍ជាក់ស្តែងផ្នែកប្រតិបត្តិការស៊ើបអង្កេតក្នុងចំណោមអង្គភាពឯកទេសនានាបញ្ជាក់ថា គុណភាពនៃការស៊ើបអង្កេតមានកម្រិតទាប ដែលមិនអាចទទួលយកបាន ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលដៅនៃភាពជំនាញ។ ដូចដែលនឹងពិភាក្សាខាងក្រោម ភាពទន់ខ្សោយខ្លាំងនៃការស៊ើបអង្កេតត្រូវបានលើកឡើងនៅក្នុងបទដ្ឋាននីតិវិធីប្រតិបត្តិការទូទៅរបស់ HSU។ ការអនុវត្តន៍បទដ្ឋាននីតិវិធីប្រតិបត្តិការដែលមានការគ្រប់គ្រងនៅថ្នាក់ជាតិនឹងមានដំណើរការឆ្ពោះទៅការដោះស្រាយបញ្ហាតឹងតែង និងឧបសគ្គធំៗ ចំពោះប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាព របស់អង្គភាពឯកទេសក្នុងតំបន់នេះ។

បទដ្ឋាននីតិវិធីប្រតិបត្តិការទូទៅ មានគោលបំណងសម្របទៅតាមបរិបទនៅថ្នាក់ជាតិ សម្រាប់ការប្រើប្រាស់នៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ តាមរយៈការកែសម្រួលដែលឆ្លុះបញ្ចាំងក្របខ័ណ្ឌគតិយុត្តិ និងប្រតិបត្តិការជាក់ស្តែងរបស់ប្រទេសនីមួយៗ។

នៅ**ប្រទេសកម្ពុជា** នាពេលថ្មីៗនេះ នគរបាលជាតិបានបញ្ចប់ការរៀបរៀងសេចក្តីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់អង្គភាពឯកទេស ដោយប្រើសេចក្តីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការអាស៊ាន ជាចំណុចចាប់ផ្តើម។ **ប្រទេសឥណ្ឌូនេស៊ី**បានបង្កើតគោលការណ៍ណែនាំជាប្រព័ន្ធនៅទូទាំងប្រទេស ដែលបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារនានា ដែលជួយសម្របសម្រួលសកម្មភាពរបស់នគរបាល ព្រះរាជអាជ្ញា និងចៅក្រមនៅសំណុំរឿងព្រហ្មទណ្ឌទាំងអស់ រួមទាំងសំណុំរឿងដែលពាក់ព័ន្ធនឹងការជួញដូរ ទោះបីមិនមានបទដ្ឋាននីតិវិធីប្រតិបត្តិការក៏ដោយ។

នាពេលថ្មីៗ **ប្រទេសថៃ**កំពុងបង្កើតគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងសំណុំរឿងជួញដូរមនុស្សសម្រាប់មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៅក្នុងជួរនគរបាលភូមិន្ទថៃ ដែលអាចពង្រីកទៅជានាយកដ្ឋានស៊ើបអង្កេតពិសេសផងដែរ។ **ប្រទេសមីយ៉ាន់ម៉ា** បានបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់អង្គភាពឯកទេសរបស់ខ្លួន។ ប្រធាននគរបាលបានអនុម័តនូវការអនុវត្តន៍នីតិវិធីទាំងនោះនាពេលដ៏ខ្លីខាងមុខ។

នៅ**ប្រទេសហ្វីលីពីន** នគរបាលជាតិហ្វីលីពីន (PNP) បានអនុម័តបទដ្ឋាននីតិវិធីប្រតិបត្តិការដែលបានកែប្រែៈ *ការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស* (ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦) (បទដ្ឋាននីតិវិធីប្រតិបត្តិការស្តីពីការជួញដូរមនុស្ស) ដែលមានវិធាន និងនីតិវិធីមួយចំនួនដែលមន្ត្រី PNP ទាំងអស់ត្រូវតែអនុវត្តតាម ក្នុងពេលដំណើរការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។

*ប្រអប់អត្ថបទ ៦៖ ឧទាហរណ៍អនុវត្តន៍៖ បទដ្ឋាននីតិវិធីប្រតិបត្តិការ ត្រូវបានប្រើប្រាស់ដើម្បីកែលម្អគុណភាពនៃការស៊ើបអង្កេតលើការជួញដូរមនុស្ស*

> អង្គភាពឯកទេសរបស់រដ្ឋសមាជិកអាស៊ានជាច្រើន បានបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការដើម្បីគ្រប់គ្រងការស៊ើបអង្កេតលើការជួញដូរមនុស្ស។ បទដ្ឋាននីតិវិធីប្រតិបត្តិការរបស់**ប្រទេសឥណ្ឌូនេស៊ី**បញ្ចូលនូវបទប្បញ្ញត្តិសំខាន់ស្តីពីជនរងគ្រោះ ដោយគ្របដណ្តប់ទៅលើការកំណត់អត្តសញ្ញាណ និងការផ្តល់ការគាំទ្រ។ *កំណត់សម្គាល់ណែនាំស្តីពីការគ្រប់គ្រងសំណុំរឿងលើការជួញដូរ*របស់**ប្រទេសថៃ** (និងសៀវភៅណែនាំអម) ផ្តោតទៅលើការគ្រប់យ៉ាងមានប្រសិទ្ធភាពទៅលើសំណុំរឿងជួញដូរមនុស្ស ដោយប្រើប្រាស់គំរូមន្ត្រីស៊ើបអង្កេតជាន់ខ្ពស់ (SIO)។ បទដ្ឋាននីតិវិធីប្រតិបត្តិការរបស់**ប្រទេសមីយ៉ាន់ម៉ា**បានបញ្ចូលនីតិវិធីស៊ើបអង្កេតទូទៅ ដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះការជួញដូរ ការស្តាប់ចម្លើយសាក្សីដើម្បីប្រមូលភស្តុតាង នីតិវិធីស៊ើបអង្កេតក្រោយពេលកើតហេតុ និងនីតិវិធីនៃការចាប់ខ្លួន។

នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីធានាថា អង្គភាពស៊ើបអង្កេតឯកទេសដំណើរការស្របទៅនឹងបទដ្ឋាននីតិវិធីប្រតិបត្តិការ។ ការអភិវឌ្ឍន៍ទាំងនេះមានសារៈសំខាន់ ជាខ្លាំង។ បទដ្ឋាននីតិវិធីប្រតិបត្តិការ (SOPs) មិនទាន់ក្លាយជាផ្នែកនៃវប្បធម៌ប្រតិបត្តិការរបស់នគរបាលទេ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន។ មូលហេតុរបស់បញ្ហានេះមិនទាន់មានភាពច្បាស់លាស់ទេ តែបទពិសោធន៍ជាច្រើនបញ្ជាក់ថា ការអនុវត្តបទដ្ឋាននីតិវិធីប្រតិបត្តិការឲ្យបានស៊ីចង្វាក់គ្នា នាំឲ្យការងាររបស់នគរបាលកាន់តែមានលក្ខណៈជាវិជ្ជាជីវៈ និងកែលម្អនូវការទទួលខុសត្រូវរបស់បុគ្គលនិងស្ថាប័នផងដែរ។ ចំណុចនេះបង្ហាញថា ការអភិវឌ្ឍន៍ និងការអនុវត្តន៍បទដ្ឋាននីតិវិធីប្រតិបត្តិការ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន យ៉ាងហោចណាស់ក៏បានចូលរួមចំណែកក្នុងការកែលម្អការបំពេញការងាររបស់អង្គភាពឯកទេសនិងគុណភាពនៃការស៊ើបអង្កេតលើការជួញដូរមនុស្សដែរ។

## វឌ្ឍនភាពទាក់ទងនឹងការបណ្តុះបណ្តាល

មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការស៊ើបអង្កេតទៅលើការជួញដូរ តម្រូវឲ្យមានចំណេះដឹងជំនាញផ្នែកបទល្មើស និងចំណេះដឹង ជំនាញ និងឥរិយាបថសមរម្យ ដើម្បីគ្រប់គ្រងជនរងគ្រោះ ជនសង្ស័យ និងភស្តុតាងក្នុងពេលស៊ើបអង្កេត ពេលសវនាការ និងក្រោយពេលជំនុំជម្រះ។ ជារឿយៗ អង្គភាពឯកទេស នឹងត្រូវចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ហេតុនេះចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលក្នុងការធ្វើកិច្ចសហប្រតិបត្តិការនេះ។ អ្នកស៊ើបអង្កេតឯកទេសក៏គួរតែមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតនានាមុនពេលកើតហេតុ រួមទាំង ការប្រមូល និងការគ្រប់គ្រងព័ត៌មានសម្ងាត់ ការឃ្លាំមើល និងបច្ចេកទេស ប្រតិបត្តិការបង្កប់ខ្លួន និងការទិញសាកល្បង ការគ្រប់គ្រង និងការដឹកជញ្ជូន និងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដែលស្របគ្នា។

អាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនលេចធ្លោជាងគេក្នុងការទទួលស្គាល់នូវសារៈសំខាន់ ដើម្បីធានាថា បុគ្គលិកអង្គភាពឯកទេសបានទទួលការបណ្តុះបណ្តាលពេញលេញ និងសមស្រប។ តាមរយៈ SOMTC រដ្ឋសមាជិកអាស៊ានបានធ្វើការអភិវឌ្ឍ ដាក់ឲ្យដំណើរការនូវគម្រោងសាកល្បង និងអនុម័តនូវសម្ភារៈបណ្តុះបណ្តាលមួយចំនួនសម្រាប់អ្នកស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរ ដែលមានកម្មវិធីបណ្តុះបណ្តាលចំនួន ៦ ខុសៗគ្នា។ លើកលែងតែវគ្គមូលដ្ឋាន

សម្រាប់មន្ត្រីការពារព្រំដែន កម្មវិធីផ្សេងទៀតមានគោលបំណងជាក់លាក់ដើម្បីបំពេញទៅតាមតម្រូវនៃការបណ្តុះបណ្តាល ដល់អ្នកស៊ើបអង្កេតឯកទេស។

## កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់បុគ្គលិកអង្គភាពឯកទេស




*កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់អ្នកស៊ើបអង្កេតឯកទេស៖ ការស៊ើបអង្កេតក្រោយពេលកើតហេតុ* គឺជាកម្មវិធីបណ្តុះបណ្តាលល្អិតល្អន់ និងអន្តរកម្មរយៈពេល ២ សប្តាហ៍។ កម្មវិធីនេះបង្កើតឡើងដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញរបស់អ្នកស៊ើបអង្កេតឯកទេសផ្នែកជួញដូរ ដើម្បីប្រើប្រាស់នូវបច្ចេកទេសស៊ើបអង្កេតជាច្រើន ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតក្រោយពេលកើតហេតុ ទៅលើសំណុំរឿងជួញដូរ។ វគ្គនេះត្រូវបានដំណើរការសាកល្បងនៅក្នុងរដ្ឋសមាជិកអាស៊ានចំនួន ៧ ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៨ ដែលកម្មវិធីសិក្សាត្រូវបានគាំទ្រដល់ SOMTC នៅខែមិថុនា ឆ្នាំ២០០៨។ គិតមកត្រឹមខែមករា ឆ្នាំ២០១៨ វគ្គនេះបានបណ្តុះបណ្តាលដល់អ្នកស៊ើបអង្កេតចំនួន ៨០៥ រូប នៅក្នុងរដ្ឋសមាជិកអាស៊ានចំនួន ៩ (ស្ត្រី ២៥៩ រូប និងបុរស ៥៤៦ រូប)។

*កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់អ្នកស៊ើបអង្កេតឯកទេស៖ ការស៊ើបអង្កេតមុនពេលកើតហេតុ* គឺជាកម្មវិធីបណ្តុះបណ្តាលល្អិតល្អន់ និងអន្តរកម្មរយៈពេល ៥ ថ្ងៃ។ កម្មវិធីនេះបង្កើតឡើងដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញរបស់អ្នកស៊ើបអង្កេតឯកទេសផ្នែកជួញដូរដែលមានការយល់ដឹងចំពោះការស៊ើបអង្កេតក្រោយពេលកើតហេតុរួចហើយ ដើម្បីប្រើប្រាស់នូវបច្ចេកទេសស៊ើបអង្កេតជាច្រើនដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតមុនពេលកើតហេតុទៅលើសំណុំរឿងជួញដូរ។ វគ្គនេះត្រូវបានដំណើរការសាកល្បងចំនួន ៣ លើកដល់អ្នកប្រតិបត្តិការជានគរបាល និងគ្រូបណ្តុះបណ្តាលចំនួន ៧៥ រូបមកពីរដ្ឋសមាជិកអាស៊ានចំនួន ៦ មុនពេលទទួលបានការគាំទ្រដល់

SOMTC នៅខែតុលា ឆ្នាំ២០១០។ គិតមកត្រឹមខែមករា ឆ្នាំ២០១៨ វគ្គនេះបានបណ្តុះបណ្តាលដល់អ្នកស៊ើបអង្កេតមកពីរដ្ឋសមាជិកអាស៊ានចំនួន ៦ (ស្ត្រី ២៨ រូប និងបុរស ៤៧ រូប)។

*កម្មវិធីបណ្តុះបណ្តាលអាស៊ាន ស្តីពីការជួញដូរមនុស្សសម្រាប់មេបញ្ជាការអង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស* ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩ ហើយវគ្គនេះបានដំណើរការសាកល្បងចំនួន ៣ លើកនៅឆ្នាំ២០១០ ដល់មេបញ្ជាការអង្គភាពចំនួន ៧៣ រូប។ កម្មវិធីសិក្សាដែលបានកែប្រែចុងក្រោយត្រូវបានទទួលការគាំទ្រដោយ SOMTC នៅខែតុលា ឆ្នាំ២០១០។ គិតមកត្រឹមខែមករា ឆ្នាំ២០១៨ វគ្គបានបណ្តុះបណ្តាលដល់មេបញ្ជាការ/អ្នកស៊ើបអង្កេតចំនួន ២៣០ រូប នៅក្នុងរដ្ឋសមាជិកអាស៊ានចំនួន ៥ (ស្ត្រី ៥៩ រូប និងបុរស ១៧១ រូប)។

*កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុនៅក្នុងសំណុំរឿងជួញដូរមនុស្ស* ជាកម្មវិធីអន្តរកម្មដែលមានរយៈពេលពី ៣ ទៅ ៥ ថ្ងៃសម្រាប់អ្នកស៊ើបអង្កេតឯកទេស និងព្រះរាជអាជ្ញា បច្ចុប្បន្ន និងអនាគតដែលមានការទទួលខុសត្រូវក្នុងដំណើរការសំណុំរឿងជួញដូរ។ វគ្គនេះត្រូវបានបង្កើតឡើងដើម្បីជួយដល់សិក្ខាកាមក្នុងការពង្រឹងសមត្ថភាពផ្នែកជួញដូរមនុស្សជំនាញរបស់ខ្លួនដែលមានស្រាប់ តាមរយៈការអនុវត្តន៍នូវបច្ចេកទេសស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុជាគោលដៅ ដើម្បីធានានូវការរឹបអូសទ្រព្យដែលបានពីបទល្មើសជួញដូរមនុស្ស ការបាត់បង់សិទ្ធិលើឧបករណ៍ប្រព្រឹត្តបទល្មើស ហើយក្នុងករណីចាំបាច់ ដើម្បីធានានូវការចោទប្រកាន់ឲ្យបានជោគជ័យចំពោះបទល្មើសពាក់ព័ន្ធនឹងការលាងលុយ។ កម្មវិធីនេះត្រូវបានដំណើរការសាកល្បងចំនួន ២ លើកនៅប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ហើយត្រូវបានគាំទ្រដោយ SOMTC នៅខែមិថុនា ឆ្នាំ២០១៦។ មកទល់នឹងពេលនេះ កម្មវិធីនេះត្រូវបានបណ្តុះបណ្តាលចំនួន ៦ លើកនៅ**ប្រទេសឥណ្ឌូនេស៊ី** និង**ហ្វីលីពីន** ដែលមានសិក្ខាកាមរួមមាន អ្នកស៊ើបអង្កេតចំនួន ១០៩ រូប ព្រះរាជអាជ្ញាចំនួន ២៦ រូប ចៅក្រមចំនួន ១១ រូប មន្ត្រីអង្គភាពព័ត៌មានសម្ងាត់ផ្នែកហិរញ្ញវត្ថុចំនួន ៨ រូប និង មន្ត្រីរដ្ឋាភិបាលចំនួន ៥ រូប (ស្ត្រី ៨៨ រូប និងបុរស ៨០ រូប)។ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា កន្លងមក ទោះបីកម្មវិធីនេះរៀបចំធ្វើតែនៅប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីនក្តី (ដោយសារវេទិកាច្បាប់ និងរចនាសម្ព័ន្ធស៊ើបអង្កេតនៅប្រទេសទាំងពីរផ្តល់កាលានុវត្តភាពល្អបំផុត ក្នុងការទទួលបានលទ្ធផលវិជ្ជមានស្តីពីការវិនិយោគលើការបណ្តុះបណ្តាល) តែកម្មវិធីបណ្តុះបណ្តាលទូទៅត្រូវបានរៀបចំ ដើម្បីសម្របសម្រួលដល់ការសម្របនៅថ្នាក់ជាតិសម្រាប់រដ្ឋសមាជិកអាស៊ានទាំងអស់។

*កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការស៊ើបអង្កេតឆ្លងដែននៅក្នុងសំណុំរឿងជួញដូរមនុស្ស* ជាកម្មវិធីអន្តរកម្មដែលមានរយៈពេល ៥ ថ្ងៃ ដែលផ្តល់ដល់អ្នកស៊ើបអង្កេតឯកទេស និងព្រះរាជអាជ្ញា បច្ចុប្បន្ន និងអនាគតនៅក្នុងរដ្ឋសមាជិកអាស៊ានដែលមានការទទួលខុសត្រូវដំណើរការសំណុំរឿងជួញដូរឆ្លងដែរ។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានផ្តល់រួមគ្នាដល់អ្នកប្រតិបត្តិមកពីវិស័យផ្សេងៗគ្នាជាច្រើន មកពីរដ្ឋសមាជិកអាស៊ានចំនួន ២ ក្នុងពេលតែមួយ និងត្រូវបានបង្កើតឡើងដើម្បីជួយឲ្យសិក្ខាកាមអាចកំណត់បាន និងវិភាគទៅលើការប្រឈមផ្នែកច្បាប់ នីតិវិធី និងប្រតិបត្តិការជាសំខាន់នានា ដែលពួកគេនឹងប្រឈម នៅពេលធ្វើការនៅកម្រិតឆ្លងដែន និងដើម្បីអភិវឌ្ឍសមត្ថភាពពួកគេដើម្បីឆ្លើយតបទៅនឹងការប្រឈមទាំងនោះ។ កម្មវិធីបណ្តុះបណ្តាលនេះបានដំណើរការសាកល្បងចំនួន ៣ លើក និងត្រូវបានគាំទ្រដល់ SOMTC នៅខែមិថុនា ឆ្នាំ២០១៦។ គិតមកដល់ចុងឆ្នាំ២០១៧ កម្មវិធីបណ្តុះបណ្តាលនេះបានផ្តល់ដល់សិក្ខាកាមសរុបរួមមាន អ្នកស៊ើបអង្កេតឯកទេសចំនួន ១១៦ រូប ព្រះរាជអាជ្ញាចំនួន ៤៤ រូប និងមន្ត្រីរដ្ឋាភិបាលចំនួន ៦ រូប (ស្ត្រី ៤៥ រូប និងបុរស ១២១ រូប) មកពី**ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ** និង**វៀតណាម**។

កម្មវិធីបណ្តុះបណ្តាលនីមួយៗក្នុងចំណោមកម្មវិធីបណ្តុះបណ្តាលទាំង ៥ នៅអាស៊ាន សម្រាប់អ្នកស៊ើបអង្កេតឯកទេសត្រូវបានបង្កើតឡើងដើម្បីឱ្យពួកគេអាចសម្របទៅនឹងក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីនៅថ្នាក់ជាតិ ព្រមទាំងទៅនឹងបរិបទមូលដ្ឋានផងដែរ។ ទោះបីវគ្គបណ្តុះបណ្តាលពីដំបូងៗត្រូវបានផ្តល់ដោយគ្រូបង្គោលអន្តរជាតិក៏ដោយ តែនាពេលបច្ចុប្បន្ននេះ ការកសាងសមត្ថភាពនៅថ្នាក់ជាតិ គឺត្រូវបណ្តុះបណ្តាលដោយអ្នកប្រតិបត្តិឯកទេស ដែលមានបទពិសោធន៍នៅមូលដ្ឋាន ដើម្បីផ្តល់នូវការបណ្តុះបណ្តាលនេះ ឧទាហរណ៍ ពាក់ព័ន្ធនឹងកម្មវិធី*ស្តីពីការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុនៅក្នុងសំណុំរឿងជួញដូរមនុស្ស* *និងកិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែននៅក្នុងសំណុំរឿងជួញដូរមនុស្ស* មានកម្មវិធីបណ្តុះបណ្តាលជាងពាក់កណ្តាលត្រូវបានធ្វើឡើងដោយអ្នកប្រតិបត្តិជំនាញពីវិស័យជាច្រើនដែលស្ថិតនៅមូលដ្ឋាន។

មកទល់នឹងពេលបច្ចុប្បន្ននេះ វគ្គជំនាញត្រូវបានផ្តល់ជូនអ្នកប្រតិបត្តិនៅ**ប្រទេសឡាវ ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន វៀតណាម**។ ការបណ្តុះបណ្តាលកម្មវិធីសម្រាប់គ្រូបង្គោលសម្រាប់វគ្គសិក្សាការស៊ើបអង្កេតក្រោយពេលកើតហេតុត្រូវបានធ្វើឡើងនៅ**ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ថៃ វៀតណាម** និង**ហ្វីលីពីន**។ គេរំពឹងថា អ្នកប្រតិបត្តិនៅមូលដ្ឋានដែលទើបតែទទួលការបណ្តុះបណ្តាលថ្មីៗនៅក្នុងប្រទេសទាំង ៦ នេះនឹងបន្តផ្តល់វគ្គស្តីពីការស៊ើបអង្កេតក្រោយពេលកើតហេតុទៅដល់សហការីរបស់ខ្លួននាពេលអនាគត។ នៅ**ប្រទេសថៃ** សិក្ខាកាមមួយរូប ត្រូវបានចាត់តាំងជាគ្រូបង្គោលស្តីពីការជួញដូរមនុស្ស សម្រាប់នគរបាលភូមិន្ទថៃ រួមទាំងនៅសាលាបណ្ឌិត្យសភានគរបាលផងដែរ។ នៅ**ប្រទេសកម្ពុជា** មានមន្ត្រីនគរបាលជាស្ត្រីចំនួន ៧៥ រូបបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេល ២ សប្តាហ៍ស្តីពីការស៊ើបអង្កេតជាមូលដ្ឋាន និងការស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស។ ភាគច្រើននៃមន្ត្រីនគរបាលទាំងនេះត្រូវបានដាក់ពង្រាយទៅ ATUs នៅទូទាំងប្រទេស។ ស្ទើរតែមួយភាគបីនៃអ្នកស៊ើបអង្កេតជាស្ត្រីទាំងនេះក៏បានចូលរួមក្នុងកម្មវិធីគ្រូបង្គោលមួយ ដើម្បីបង្កើនជំនាញស៊ើបអង្កេតលើការជួញដូរមនុស្សរបស់ខ្លួនដែរ។ នៅ**ប្រទេសមីយ៉ាន់ម៉ា** មន្ត្រីនគរបាលជាស្ត្រីចំនួន ៥០ រូបបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេល ២ សប្តាហ៍ស្តីពីការស៊ើបអង្កេតជាមូលដ្ឋាន និងការស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស។ ភាគច្រើននៃមន្ត្រីនគរបាលទាំងនេះត្រូវបានដាក់ពង្រាយនៅតាមអង្គភាព ATTF នៅទូទាំងប្រទេស។ ចំនួនពាក់កណ្តាលនៃសិក្ខាកាមដែលបានចូលរួមវគ្គ បណ្តុះបណ្តាលបានក្លាយជាផ្នែកនៃវគ្គគ្រូបង្គោលទៀងទាត់ ដែលពួកគេចូលរួមសម្របសម្រួលជាមួយអ្នកស៊ើបអង្កេតជាន់ខ្ពស់ និងព្រះរាជអាជ្ញាដែលមានបទពិសោធន៍ ក្នុងការបណ្តុះបណ្តាល។ វគ្គគ្រូបង្គោលស្រដៀងគ្នាក៏ត្រូវបានរៀបចំឡើងសម្រាប់មេបញ្ជាការអង្គភាព ATTF មកពីទីតាំង“ចំណុចក្តៅ នៃការជួញដូរមនុស្ស ”។

*ប្រអប់អត្ថបទ ៧៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីនូវការបណ្តុះបណ្តាលដែលកែលម្អដល់ការបំពេញការងាររបស់អង្គភាពឯកទេស*

**ប្រទេសឥណ្ឌូនេស៊ី**បានរាយការណ៍ថា ការបណ្តុះបណ្តាលសម្រាប់អ្នកស៊ើបអង្កេតឯកទេសជួញដូរមនុស្ស ធ្វើឱ្យសំណុំរឿងមានការកើនឡើង ជាពិសេស សំណុំរឿងពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងការចូលរួមរបស់ស្ថាប័នសាជីវកម្មទៅក្នុងបទល្មើសជួញដូរ។

# ២.៤ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត

ផ្នែកមុនបានបញ្ជាក់ថា វឌ្ឍនភាពដ៏សំខាន់ត្រូវបានធ្វើឡើងនៅក្នុងតំបន់អាស៊ាន ពាក់ព័ន្ធនឹងភាពឯកទេសនៃការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ទៅនឹងការជួញដូរ។ ការបង្កើតរចនាសម្ព័ន្ធជំនាញ នៅបណ្តារដ្ឋសមាជិកអាស៊ានស្ទើរតែទាំងអស់ បានបង្ហាញពីកម្រិតកើនឡើង នៃការបំពេញការងារ នៅក្នុងការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់ វិធានការសំខាន់មួយចំនួន នៃនិរន្តរភាពរយៈពេលវែង។

ស្របទៅនឹងដំណើរការ HSU ដោយមានការឧបត្ថម្ភនៅក្រោមរចនាសម្ព័ន្ធ SOMTC បានបញ្ចូលជាបណ្តើរៗនូវធនធានសម្រាប់ការបណ្តុះបណ្តាលនៅអាស៊ាន ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ និងការអនុម័តនៅថ្នាក់ជាតិ និងការប្រើប្រាស់បទដ្ឋាននីតិវិធីប្រតិបត្តិការទូទៅ យ៉ាងហោចណាស់មាននៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួនដែរ បង្ហាញពីវិសាលភាពដែលរដ្ឋជាសមាជិកអាស៊ានបានផ្លាស់ប្តូរគោលជំហរ លើគំនិតនៃការឆ្លើយតបពិសេសនៃការងារជួញដូររបស់ពួកគេ។

ទោះបីមានវឌ្ឍនភាពកម្រិតនេះក៏ដោយ តែនៅមានការប្រឈមផ្នែករចនាសម្ព័ន្ធ និងប្រតិបត្តិការនៅឡើយ។ ចំណុចសំខាន់បំផុត ជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ការបង្កើតអង្គភាពឯកទេស *មិន*ដូចទៅនឹងការមានសមត្ថភាពឯកទេសក្នុងការស៊ើបអង្កេតទៅលើការជួញដូរទេ។ យ៉ាងហោចណាស់នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ចំណុចខ្សោយនៅក្នុងអាណត្តិការងារ រចនាសម្ព័ន្ធ ការផ្តល់ថវិកា និងសមត្ថភាព មានន័យថា អង្គភាពទាំងនោះមិនទាន់បានផ្តល់ការឆ្លើយតបដែលចាំបាច់នោះទេ។ ជាងនេះទៀត នៅក្នុងតំបន់ទាំងមូល ទោះបីមានសញ្ញាណថា ភាពឯកទេសធ្វើឲ្យការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមានចំនួនច្រើនជាងមុន និងកាន់តែប្រសើរឡើងក្តី តែចំណុចនេះមិនទាន់ស៊ីចង្វាក់គ្នានៅឡើយទេ។

ការប្រឈម និងកាលានុវត្តភាពជាក់លាក់ ត្រូវបានយកមកពិចារណានៅក្នុងក្របខ័ណ្ឌនៃលក្ខណ:មូលដ្ឋានចំនួន ៥ របស់អង្គភាពឆ្លើយតបឯកទេសដែលប្រកបដោយប្រសិទ្ធភាព ដោយពិចារណាបន្ថែមទៅលើការប្រឈមនៃការធានាឲ្យមានតុល្យភាពយេនឌ័រសមរម្យនៅក្នុងអង្គភាពផងដែរ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងរចនាសម្ព័ន្ធ និងអាណត្តិការងារ

ភាពទន់ខ្សោយផ្នែកនីតិវិធីជាឧបសគ្គដល់សមត្ថភាពរបស់អង្គភាពក្នុងការឆ្លើយតប នៃការសម្របសម្រួល និងភាពស៊ីចង្វាក់គ្នាទូទាំងប្រទេស។ ជំហាននានាដូចខាងក្រោម ដែលគួរពិចារណា ដើម្បីដោះស្រាយនូវចំណុចខ្សោយទាំងនេះ

ក្នុងករណីចាំបាច់ គួរមានការពង្រឹងអាណត្តិការងារនៃភាពឯកទេស ដើម្បីឲ្យអង្គភាពនេះធ្វើការទទួលខុសត្រូវទូទាំងប្រទេស ក្នុងការស៊ើបអង្កេត លើសំណុំរឿងជួញដូរទាំងអស់។ បទពិសោធន៍ប្រតិបត្តិការបង្ហាញថា នៅពេលសមត្ថភាពនគរបាល និងការបំពេញការងារមានភាពខ្លាំងក្លា ហើយនៅពេលមានការប្តេជ្ញាចិត្តនៅថ្នាក់ដឹកនាំកម្រិតខ្ពស់ក្នុងការដោះស្រាយការជួញដូរមនុស្សនេះ វាគឺជារចនាសម្ព័ន្ធគំរូល្អបំផុត ដើម្បីសម្រេចបាននូវគោលដៅ ដែលបានលើកឡើងខាងលើ។

នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ដែលអង្គភាពជួញដូរមិនអាច ឬមិនសក្តិសមនឹងទទួលបានការទុកចិត្តចំពោះការទទួលខុសត្រូវលើសំណុំរឿងជួញដូរមនុស្ស នៅទូទាំងប្រទេសបាន គេនៅតែអាចចាត់វិធានការជាជំហ៊ានបានដដែល ក្នុងការកែលម្អ ការសម្របសម្រួល និងការសហការគ្នា។ ឧទាហរណ៍ នៅពេលដែលអាចអនុវត្តបាន និងសមស្រប៖

- អាចពង្រឹងអាណត្តិការងាររបស់អង្គភាពដើម្បីតម្រូវថា រាល់ភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងអស់ត្រូវជូនដំណឹងឲ្យបានទាន់ពេលវេលា ដល់អង្គភាពឯកទេសនូវការចោទប្រកាន់ពីការជួញដូរមនុស្សទាំងអស់ដែលបានរាយការណ៍ដល់ពួកគេ។ បើគ្មានធាតុផ្សំនេះទេ កម្រិតចាំបាច់នៃការគ្រប់គ្រងឯកទេសខាងលើមិនអាចយកមកអនុវត្តជាសាកលបានទេ ហើយអង្គភាពឯកទេសនឹងមិនអាចវាយតម្លៃឲ្យបានត្រឹមត្រូវនូវទំហំ និងលក្ខខណៈនៃបញ្ហានៅថ្នាក់ជាតិបានទេ។
- អាចពង្រឹងអាណត្តិការងាររបស់អង្គភាពដើម្បីតម្រូវថា រាល់ការស៊ើបអង្កេតផ្នែកជួញដូរនីមួយៗ ដែលធ្វើឡើងដោយមន្ត្រីមិនឯកទេសនៅគ្រប់ទីកន្លែង នៅទូទាំងប្រទេសត្រូវស្ថិតក្រោមការ***ត្រួតពិនិត្យដោយអង្គភាពឯកទេស***។
- អាចពង្រឹងអាណត្តិការងាររបស់អង្គភាពដើម្បីតម្រូវថា ***តួនាទីជាអ្នកត្រួតពិនិត្យខាងលើគឺជាកាតព្វកិច្ច*** មិនមែនជាប្រឹក្សាយោបល់ទេ នៅគ្រប់ទីភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងអស់ ដើម្បីធានានូវការអនុវត្តន៍នៅទូទាំងប្រទេស នូវបទដ្ឋាននីតិវិធីប្រតិបត្តិការជាក់លាក់ និងដកចេញនូវហានិភ័យនៃការឆ្លើយតបនៃការស៊ើបអង្កេតដែលមិនស៊ីចង្វាក់គ្នា។
- នៅពេលមិនទាន់មានអង្គភាពឯកទេស គេអាចពង្រឹងអាណត្តិការងាររបស់អង្គភាពដើម្បីធានាថា អង្គភាពឯកទេសអាច***ផ្តោតផ្តាច់មុខតែទៅលើការជួញដូរមនុស្ស និងការធ្វើអាជីវកម្មដែលពាក់ព័ន្ធប៉ុណ្ណោះ***។ ប្រការនេះបញ្ចៀសនូវហានិភ័យនៃការប្រុងប្រយ័ត្ន និងសមត្ថភាពរបស់អង្គភាព ត្រូវបានរំខាន ដោយតម្រូវឱ្យមានផ្នែកស៊ើបអង្កេតចម្រុះ និងមានការប្រជែងគ្នាផងដែរ។

ក្នុងករណីជាច្រើនមានចន្លោះប្រហោងយ៉ាងច្រើន បបើគ្មានការទំនាក់ទំនងរវាង អង្គភាពអ្នកឯកទេសថ្នាក់កណ្តាល និងថ្នាក់ខេត្ត និងនិងមូលដ្ឋានទេនោះ។ ចំណុចនេះគួរស្ថិតក្នុងការកំណត់របស់បទដ្ឋាននីតិវិធីប្រតិបត្តិការជាក់លាក់សម្រាប់អង្គភាពឯកទេស ដោយបញ្ចូលនូវ៖ (១) បញ្ជីដៃគូទីភ្នាក់ងារនៅតាមខេត្ត និងមូលដ្ឋានដែលមានតួនាទីក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនោះ និងដែលអាចពិគ្រោះយោបល់ជាមួយបាន (២) រៀបចំកំណត់កម្មវិធីប្រជុំពិគ្រោះយោបល់ (៣) ឯកភាពគ្នាទៅលើក្របខ័ណ្ឌនៃប្រធានបទដែលគួរយកមកពិគ្រោះយោបល់ (៤) ការណែនាំស្តីពីរបៀបរៀបចំ និងផ្តល់ថវិកាដល់ការពិគ្រោះយោបល់។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងអំណាចសមស្រប

ដូចបានពន្យល់លម្អិតខាងលើ មានភាពខុសគ្នាយ៉ាងធំធេងនៅក្នុងចំណោម រដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងអំណាចរបស់ពួកគេ និងសមត្ថភាព ក្នុងការស៊ើបអង្កេតទៅលើការជួញដូរប្រកបដោយប្រសិទ្ធភាព។ រដ្ឋសមាជិកអាស៊ានទាំងអស់នឹងទទួលបានប្រយោជន៍ពីការពិនិត្យទៅលើអំណាចរបស់ខ្លួន ក្នុងការបំពេញភារកិច្ចដែលពួកគេត្រូវធ្វើ។ ការពិនិត្យបែបនេះអាចពិចារណាដោយប្រុងប្រយ័ត្នដូចខាងក្រោម

ទាក់ទងនឹងអំណាចស៊ើបអង្កេត ក្នុងករណីចាំបាច់ គេត្រូវចាត់វិធានការដើម្បីធានាថា អាណត្តិការងាររបស់អង្គភាពឯកទេស នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ អាចជួយឲ្យពួកគេប្រើប្រាស់បានយ៉ាងពេញលេញនូវបច្ចេកទេសស៊ើបអង្កេត ក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ។ ការពង្រឹងអាណត្តិការងារដើម្បីបញ្ចូលយ៉ាងពេញលេញនូវបច្ចេកទេសស៊ើបអង្កេតក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ មិនអាចតម្រូវឲ្យមានការប្រែប្រួលស្មុគស្មាញ និងចំណាយពេលយូរទៅលើច្បាប់ និងនីតិវិធីទេ។ ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗបំផុតមួយចំនួន ដូចជា វិធីសាស្ត្រនៃការកត់ត្រា ការស្តាប់ចម្លើយសាក្សី និងការប្រើប្រតិបត្តិការទិញសាកល្បង ជារឿយៗច្បាប់ជាតិពុំមានចែងទេ ហើយបច្ចេកទេសទាំងនេះមិនត្រូវបានអនុញ្ញាត ឬត្រូវបានហាមឃាត់ជាក់ស្តែងតែម្តង។ នៅពេលមានស្ថានភាពបែបនេះ អង្គភាពឯកទេសគួរស្វែងយល់អំពីទស្សនៈអ្នកច្បាប់ជាមុនសិន ពាក់ព័ន្ធនឹងការប្រមើលមើលពីប្រតិកម្មរបស់តុលាការ ប្រសិនបើបច្ចេកទេសនេះត្រូវបានយកមកប្រើក្នុងការប្រមូលភស្តុតាង (ដោយសារការប្រឈមប្រហែលមិនធំធេងដូចរូបភាពខាងក្រៅ)។

ទាក់ទងនឹងបច្ចេកទេសស៊ើបអង្កេតមុនពេលកើតហេតុ ប្រទេសជាច្រើននៅក្នុងតំបន់នឹងបានទទួលប្រយោជន៍ពីការពិនិត្យ និងប្រមូលផ្តុំច្បាប់ ដែលគ្រប់គ្រងការប្រើបច្ចេកទេសទាំងនេះ ដើម្បីពង្រឹងការការពារដល់សិទ្ធិពលរដ្ឋ និងផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវភាពកាន់តែច្បាស់ និងច្បាស់លាស់នៅពេលប្រើប្រាស់បច្ចេកទេសឆ្នក់ចូល។ នៅក្នុងសំណុំរឿងមួយចំនួន ច្បាប់ពុំបានចែងច្បាស់លាស់ទេ ហេតុនេះនាំឱ្យមានការយល់ដឹងស្រពិចស្រពិល ដែលនាំឲ្យមានភាពយល់មិនច្បាស់លាស់ក្នុងចំណោមអ្នកស៊ើបអង្កេត។ ភាពមិនច្បាស់លាស់នេះក្លាយជាការរារាំង ឧទាហរណ៍ ដូចជាមន្ត្រីមិនប្រើប្រាស់បច្ចេកទេសទាំងនេះតែម្តង ឬប្រើប្រាស់បច្ចេកទេសមិនបានត្រឹមត្រូវ។

គួរតែពិចារណាដល់ទំនាក់ទំនងរវាងអាណត្តិការងារ និងរចនាសម្ព័ន្ធ។ ដើម្បីបង្កើនប្រសិទ្ធភាពដល់អង្គភាពឯកទេស គួរពិចារណាដល់ការរៀបចំរចនាសម្ព័ន្ធអង្គភាពតាមវិធីមួយដែលផ្តល់ឲ្យពួកគេនូវព័ត៌មានសម្ងាត់ និងសមត្ថភាពក្នុងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ។ និយាយម្យ៉ាងទៀតគឺថា នូវព័ត៌មានសម្ងាត់ និងសមត្ថភាពក្នុងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុរបស់អង្គភាពឯកទេសគួរតែមានការ “ភាពឯកទេសផ្ទៃក្នុង” ឲ្យបានច្រើនទៅតាមលទ្ធភាព។ ចំណុចនេះកាត់បន្ថយការពឹងផ្អែករបស់អង្គភាពទៅលើស្ថាប័នផ្សេងទៀតដែលអាចមានអាទិភាពខុសៗគ្នា។ គួរធានាឲ្យបាននូវចំណុចនេះ ឧទាហរណ៍ តាមរយៈការចាត់តាំងមន្ត្រីមួយរូបពីភ្នាក់ងារមួយទៀត។ ប្រសិនបើមិនអាចធានាបានភាពជំនាញផ្ទៃក្នុងទេ យ៉ាងហោចណាស់អង្គភាពឯកទេសគួរតែអាចស្នើសុំការចាត់តាំងជនបង្គោលណាម្នាក់មកពីទីភ្នាក់ងារស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដែលពាក់ព័ន្ធ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការផ្តល់ថវិកា

មកដល់ចំណុចនេះ មានរដ្ឋសមាជិកអាស៊ានតិចតួចនឹងយល់ឃើញថា ពួកគេមានធនធានហិរញ្ញវត្ថុ បុគ្គលិក និងបរិក្ខាគ្រប់គ្រាន់ក្នុងការបំពេញការងាររបស់ខ្លួនឲ្យបានសមរម្យ។ កង្វះធនធាននាំឲ្យប៉ះពាល់ដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពផង និងដល់សមត្ថភាពស៊ើបអង្កេតផង។ នៅក្នុងគំរូទាំងនោះ ដែលការឆ្លើយតបឯកទេស ជាផ្នែកមួយរបស់នាយកដ្ឋាន ដែលមានភារកិច្ចស៊ើបអង្កេតទូលំទូលាយ អង្គភាពផ្នែកជួញដូរមិនមានការបែងចែកថវិកាដោយឡែក និងជាក់លាក់ដើម្បីដំណើរការប្រតិបត្តិការរបស់ខ្លួន ហើយត្រូវពឹងផ្អែកទៅលើផ្នែកនៃថវិកាដែលបានបែងចែកដល់នាយកដ្ឋានទាំងមូលវិញ។ ចំណុចនេះអាចមានឥទ្ធិពលធ្វើឲ្យថមថយដល់ការឆ្លើយតបទៅនឹងការជួញដូរ ដោយសារមានតម្រូវការចាំបាច់ច្រើនពេកទៅលើធនធានដែលមាន។ ពាក់ព័ន្ធនឹងការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់ជា

សកល ថវិកាគឺជាកត្តាសម្រេចចុងក្រោយចំពោះអ្វីដែលអាចសម្រេចបាន ហើយបញ្ហានេះនឹងចាំបាច់ត្រូវតែយកមកដោះស្រាយ ប្រសិនបើចង់ឲ្យគំនិតផ្តួចផ្តើមផ្នែកជំនាញលូតលាស់រីកចម្រើន។ ជាការសំខាន់ដែលត្រូវអនុវត្តដោយផ្អែកលើភាពប្រាកដនិយម និងសភាពជាក់ស្តែង ចំពោះបញ្ហានេះ និងទទួលស្គាល់ការពិតដែលថា នឹងមានឱនភាពពាក់ព័ន្ធនឹងធនធាន៖ ការប្រឈមចំពោះអង្គភាពឯកទេស គឺស្វែងរកវិធីសាស្ត្រដែលអាចបង្កើតអ្វីដែលអាចសម្រេចបានជាអតិបរមា ជាមួយអ្វីដែលមាន។ បញ្ហានានាដូចខាងក្រោមដែលគួរយកមកពិចារណា

ដោយមិនគិតដល់ទំហំថវិកាដែលមាន ជំហានដំបូងគួរតែជាការសម្រេចចិត្ត ជាគោលការណ៍ដើម្បីធានាថា ការឆ្លើយតបឯកទេស ត្រូវបានផ្តល់ដោយការបែងចែកថវិកាដោយឡែកដែលមិនធ្វើឲ្យប៉ះពាល់ដល់តម្រូវការស៊ើបអង្កេតផ្សេងទៀត។ ចំណុចនេះមានសារៈសំខាន់ ជាពិសេសទាក់ទងនឹងគំរូប្រមូលផ្តុំដែលការឆ្លើយតបត្រូវបានផ្តល់ជាផ្នែករបស់នាយកដ្ឋានធំ។ ជំហានទីពីរគួរតែជាការប៉ាន់ស្មានចំពោះការបែងចែកថវិកាប្រចាំឆ្នាំដល់អង្គភាព។ គួរពិចារដល់ថវិកា សរុប សម្រាប់ផ្នែកអនុវត្តន៍ច្បាប់រួម និងមិនបញ្ចូលនូវការប៉ាន់ស្មានពីការផ្តល់ថវិកាបន្ថែម ដែលអាចមានពីប្រភពខាងក្រៅនោះឡើយ ដោយសារប្រភពទាំងនេះកម្រ ផ្តល់ជាលក្ខណៈពេលមធ្យម និងពេលវែងណាស់។ ផ្អែកលើការគណនានេះ ជំហានទីបីគួរតែជាការពិនិត្យទៅលើអាណត្តិការងាររបស់អង្គភាព ដើម្បីធានាថាការទទួលខុសត្រូវរបស់អង្គភាពឆ្លុះបញ្ចាំងនឹងទំហំធនធានដែលមាន។ វាអាចជាការចាំបាច់ដែលត្រូវធ្វើការផ្លាស់ប្តូរជាខ្លាំង ចំពោះកាតព្វកិច្ចដែលនឹងធ្វើឲ្យប៉ះពាល់ដល់មហិច្ឆតារួមនៃភាពជំនាញ តែគួរតែពិចារណាផ្តោតទៅលើការទទួលខុសត្រូវដែលទំនងជាមិនអាចសម្រេចបានជាមួយធនធានដែលមាន។

ការពិនិត្យគួរតែស្វែងរកតុល្យភាពរវាងថវិកា និងអាណត្តិការងារ ដើម្បីធានាថា បុគ្គលិកដែលមានឯកទេសគ្រប់គ្រាន់អាចទទួលថវិកាដើម្បីបំពេញទៅតាមអាណត្តិការងាររបស់អង្គភាពប្រកបដោយវិជ្ជាជីវៈ។

ផ្អែកលើការកែសម្រួលទៅលើអាណត្តិការងាររបស់អង្គភាព ដើម្បីឆ្លុះបញ្ចាំងទៅនឹងតថភាពជាក់ស្តែងនៃធនធានដែលមាន លក្ខខណ្ឌស្តីពីបុគ្គលិក និងបរិក្ខាររបស់អង្គភាព គួរសម្រួលទៅតាមកម្រិតដែលគ្រប់គ្រាន់ដើម្បីបំពេញទៅតាមអាណត្តិការងារ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងបុគ្គលិក រួមទាំងបញ្ហាយេនឌ័រផងដែរ

នៅពេលជាមួយគ្នានឹងការពិនិត្យ និងសម្រួលកម្រិតបុគ្គលិកឲ្យស្របទៅនឹងថវិកានោះ គេគួរឆ្លៀតឱកាស ពិនិត្យទៅលើបញ្ហាគ្រប់គ្រងបុគ្គលិកនៅក្នុងអង្គភាពឯកទេស។ ប្រព័ន្ធនៃការប្តូរវេនបុគ្គលិកស៊ើបអង្កេត និងគ្រប់គ្រងនៅក្នុងរដ្ឋសមាជិកអាស៊ាន ដំណើរការទៅតាមគោលការណ៍មូលដ្ឋានមួយក្នុងចំណោមគោលការណ៍មូលដ្ឋាននានា ដែលជាមូលដ្ឋាននៃភាពជំនាញ គឺថាភាពឯកទេសបង្កើតជាក្រុមអ្នកប្រតិបត្តិការដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ដែលអាចគ្រប់គ្រងការស៊ើបអង្កេតក្នុងករណីស្មុគ្រស្មាញបាន។ ប្រព័ន្ធប្តូរវេនបច្ចុប្បន្នគឺផ្ទុយនឹងផលិតភាព ពីព្រោះអ្នកប្រតិបត្តិនៅក្នុងអង្គភាពជាច្រើនចំណាយពេលមិនគ្រប់គ្រាន់ នៅក្នុងអង្គភាពដើម្បីឲ្យពួកគេអាចទទួលបានកម្រិតជំនាញ និងបទពិសោធន៍លើសំណុំរឿងដែលចាំបាច់បានឡើយ។

នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ជាទូទៅការប្តូរវេនបុគ្គលិក ត្រូវបានចាត់ទុកថាជាមធ្យោបាយក្នុងការកាត់បន្ថយអំពើពុករលួយ ដោយសារថា ហានិភ័យនៃអំពើពុករលួយកើនឡើង ប្រសិនបើបុគ្គលិកមួយរូប ស្ថិតនៅកន្លែងមួយ

យូរពេក។ ទោះបីចំណុចនេះអាចយល់បានក្តី តែមានទទ្ទីករណ៍ថា វិធីសាស្ត្របង្វិលវេននេះ ធ្វើឱ្យមានការយល់ច្រឡំ ព្រោះថាការបង្វិលវេនមានផលបអវិជ្ជមានលើប្រសិទ្ធិភាពនៃការស៊ើបអង្កេត ជាជាងផលវិជ្ជមានទៅលើអំពើពុករលួយ។។ ផ្ទុយទៅវិញ វាធ្វើឱ្យភាពឯកទេសត្រូវថយចុះដោយសារការផ្លាស់ប្តូរញឹកញយពេក ហានិភ័យនៃអំពើពុករលួយគួរតែត្រូវបានចាត់ទុលថាជាការប្រឈមផ្នែកគ្រប់គ្រង ហើយដែលត្រូវដោះស្រាយតាមវិធីនៃការអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួន និងជាបន្តបន្ទាប់នូវបទដ្ឋាននីតិវិធីប្រតិបត្តិការ ដែលបង្កើតឡើងជាពិសេស ដើម្បីកាត់បន្ថយឱកាសនៃអំពើពុករលួយ។

បទដ្ឋាននីតិវិធីប្រតិបត្តិការផ្តល់ឱ្យអ្នកគ្រប់គ្រងនូវឧបករណ៍គោលដៅមួយដែលអាចធ្វើការវាស់វែងបានដើម្បីធ្វើការវិនិច្ឆ័យ និងកំណត់បញ្ហាផ្សេងៗ ដូចជាការប្រព្រឹត្តអំពើពុករលួយ និងការរំលោភបំពានអំណាចអាចត្រូវបានកំណត់ និងដោះស្រាយបញ្ហាទាំងនោះបាន។ កង្វះខាតបទដ្ឋាននីតិវិធីប្រតិបត្តិការ និងការមិនអនុវត្តតាមបទដ្ឋាននីតិវិធីប្រតិបត្តិការ ដែលមានស្រាប់ គឺជាបញ្ហាបន្តកើតមានសម្រាប់រដ្ឋសមាជិកអាស៊ានមួយចំនួន ដែលគួរត្រូវបានទទួលស្គាល់ និងយកមកដោះស្រាយ។

ដោយសារតម្រូវការចាំបាច់ក្នុងការកសាងភាពឯកទេសនៅក្នុងការស៊ើបអង្កេតឯកទេស អង្គភាពគួរបង្កើតឡើងនូវគោលការណ៍គ្រប់គ្រងបុគ្គលិក នៅក្នុងអង្គភាពឯកទេសដែលថា អ្នកប្រតិបត្តិការងារ និងអ្នកគ្រប់គ្រងគួរស្ថិតនៅក្នុងអង្គភាពនេះយ៉ាងហោចណាស់ឱ្យបានពី ៣ ទៅ ៥ ឆ្នាំដែរ។ ភ្នាក់ងារអនុវត្តន៍ច្បាប់នឹងទទួលបានប្រយោជន៍ពីការផ្លាស់ប្តូរនេះ ដោយសារជំនាញស៊ើបអង្កេតដែលត្រូវបានអភិវឌ្ឍនៅក្នុងអំឡុងពេលនេះនឹងក្លាយជាធនធានសម្រាប់ភ្នាក់ងារជារួម នៅពេលដែលបុគ្គលិកម្នាក់ៗត្រូវបានចាត់តាំងទៅកាន់កន្លែងថ្មី នាពេលបន្ទាប់។

ដូចបានលើកឡើងខាងលើ មានវឌ្ឍនភាពមួយចំនួន ក្នុងការធានានូវតុល្យភាពយេនឌ័រនៅក្នុងអង្គភាពស៊ើបអង្កេតឯកទេស។ ក៏ប៉ុន្តែ ស្ត្រីនៅតែមានតំណាងតិចតួច នៅតាមអង្គភាពឯកទេសនានា នៅក្នុងតំបន់អាស៊ាន ជាពិសេសទាក់ទងនឹងតួនាទីស៊ើបអង្កេត។ ទោះបីមានឧទាហរណ៍ នៅក្នុងនគរបាលភូមិន្ទថៃដែលស្ត្រីបំពេញតួនាទីក្នុងដឹកនាំប្រតិបត្តិការក្តី ដមន្ត្រីស្ត្រីភាគច្រើននៅតែបន្តបំពេញការងារជាអ្នកស៊ើបអង្កេត ជាជាងធ្វើកាងារដឹកនាំប្រតិបត្តិការ ហើយក្នុងនាមជាអ្នកស៊ើបអង្កេត ស្ត្រីនៅតែបន្តបំពេញកាងារក្នុងផ្នែកការងារការិយាល័យ ការងាររដ្ឋបាល ជាជាងចូលរួមដោយផ្ទាល់ក្នុងតួនាទីជាអ្នកប្រតិបត្តិការស៊ើបអង្កេត។ ប្រការគួរឱ្យកត់សម្គាល់គឺថា នៅក្នុងតំបន់ទាំងមូល មានស្ត្រីតិចតួចណាស់ ដែលកាន់តំណែងជាន់ខ្ពស់បំផុតនៅក្នុងអង្គភាពប្រឆាំងការជួញដូរ និងនៅក្នុងវិស័យនគរបាលជាទូទៅ។ ជាងនេះទៀត ដោយសារមានប្រវត្តិដ៏យូរអង្វែងដែលស្ត្រីមានភាពជាតំណាងទាបនៅក្នុងវិស័យអនុវត្តន៍ច្បាប់នោះ មន្ត្រីជាស្ត្រីដែលមានឋានន្តរស័ក្តិខ្ពង់ខ្ពស់ ពុំមានប្រវត្តិជាអ្នកជំនាញស៊ើបអង្កេតទេ ហើយសង្គមជាទូទៅ នៅតែមានទស្សនៈដែលផ្តល់តម្លៃទាបចំពោះតួនាទី និងការទទួលខុសត្រូវរបស់នគរបាលស្ត្រីផងដែរ។

ការធ្វើឱ្យមានតុល្យភាពយេនឌ័រ មិនមែនគ្រាន់តែបង្កើនចំនួនរបស់ស្ត្រី ឬការចាត់តាំងឱ្យកាន់សំណុំរឿងជួញដូរ ឬនៅក្នុងអង្គភាពផ្ទៃក្នុង ដែលមានស្ត្រីច្រើនលើសលប់នោះទេ គឺមានន័យថាអង្គភាព ត្រូវដោះស្រាយនូវបទល្មើសទាំងឡាយណាដែលប៉ះពាល់ដល់ស្ត្រី និងកុមារជាចាំបាច់។ បទពិសោធន៍នៅក្នុងតំបន់នេះ និងតំបន់ផ្សេងទៀតបញ្ជាក់ថា វិធីសាស្ត្រទាំងនេះជារឿយៗឆ្លុះបញ្ចាំងនូវបរាជ័យនៃការគ្រប់គ្រងជាន់ខ្ពស់ផ្នែកអនុវត្តន៍ច្បាប់ ក្នុងការផ្តល់អាទិភាពដល់បទល្មើសជួញដូរ។ ចំណុចទាំងនេះក៏ទំនងជាបណ្តាលឱ្យរចនាសម្ព័ន្ធមានភាពទន់ខ្សោយ មានធនធានមិនគ្រប់គ្រាន់ និងបាត់បង់កាលានុវត្តភាពនៅក្នុងភ្នាក់ងារអនុវត្តន៍ច្បាប់ធំ។

វិធីសាស្ត្រទាំងនេះក៏បន្តឱ្យមានការសន្មតដែលមិនមានប្រយោជន៍ និងការប្រកាន់ផ្នត់គំនិតជុំវិញការជួញដូរដែរ ឧទាហរណ៍ ជនរងគ្រោះនៃការជួញដូរមានចំនួនច្រើនលើសលប់ជាស្ត្រី និងកុមារ មានតែមន្ត្រីជាស្ត្រីតែមួយរូបគត់ដែលអាច ឬគួរ ដោះស្រាយនូវបទល្មើសទាំងនោះបាន។ ស្រដៀងគ្នាដែរ ការរួមបញ្ចូលអង្គភាពផ្នែកជួញដូរជាមួយអង្គភាពផ្នែកហិង្សាក្នុងគ្រួសារ និងរំលោភផ្លូវភេទ ជាការបញ្ជូនសារយ៉ាងច្បាស់ តែមិនត្រឹមត្រូវថា ការជួញដូរជាបទល្មើសធ្វើអាជីវកម្មផ្លូវភេទ។ ចំណុចនេះបង្កឱ្យមានភាពរុំរ៉ៃនៃការកំណត់អត្តសញ្ញាណមិនត្រឹមត្រូវនូវទម្រង់ផ្សេងទៀតនៃការជួញដូរ ជាពិសេសបំផុតគឺការជួញដូរសម្រាប់ការងារដោយបង្ខំ។ តថភាពជាក់ស្តែងនៅក្នុងតំបន់ ក៏ដូចជានៅតំបន់ផ្សេងទៀតដែរ គឺថា ការជួញដូរប៉ះពាល់ដល់បុរស ស្ត្រី និងកុមារី ហើយថាការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរតម្រូវឱ្យមានការឆ្លើយតបដែលឆ្លុះបញ្ចាំងតថភាពជាក់ស្តែងនៃបទល្មើស។

ដំណើរការនៃការកែលម្អ និងពង្រឹងអាណត្តិការងារ ដែលបានស្នើឡើងខាងលើអាចផ្តល់កាលានុវត្តភាពដ៏មានតម្លៃសម្រាប់អ្នកគ្រប់គ្រង និងមេបញ្ជាការអង្គភាពឯកទេស ធ្វើការពិនិត្យទៅលើទម្រង់នៃការងារផ្នែកយេនឌ័រដើម្បីធានាថា ពួកគេ៖ (១) ចៀសវាងបាននូវភាពអតុល្យភាពរវាងស្ត្រី និងបុរស និង (២) វាមិនមែនគ្រាន់តែជាការធានាថាត្រូវតែមានតុល្យភាពរវាងភេទនោះទេ តែវាចាំបាច់ឆ្លុះបញ្ចាំងនូវការទទួលខុសត្រូវរបស់អង្គភាព បច្ចេកទេសស៊ើបអង្កេត និងតថភាពជាក់ស្តែងនៃបទល្មើស។ ការប្រឈមមួយទៀតគឺដើម្បីធានានូវតុល្យភាពយេនឌ័ររបស់បុគ្គលិកដែលទទួលបានបណ្តុះបណ្តាល ដែលនឹងត្រូវដាក់ពួកគេឱ្យត្រូវចំជំនាញ ដែលការងារពួកគេបានបណ្តុះណ្តាល ដើម្បីទទួលបានលទ្ធផលស៊ើបអង្កេតដែលមានគុណភាពខ្ពស់។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងបទដ្ឋាននីតិវិធីប្រតិបត្តិការ

នៅដំណាក់កាលនេះ ដំណើរការអភិវឌ្ឍន៍ ដើម្បីឆ្លើយតបទៅនិងការងារស៊ើបអង្កេតឯកទេសបញ្ហានៃបទដ្ឋាននីតិវិធីប្រតិបត្តិការជារឿងសំខាន់ណាស់។ ភាពទន់ខ្សោយផ្នែកប្រតិបត្តិការជាច្រើនដែលបានលើកឡើងខាងលើ អាចដោះស្រាយបានតាមរយៈការបង្កើត និង*ការអនុវត្តន៍ឱ្យបានខ្លាំងក្លា* នូវបទដ្ឋាននីតិវិធីប្រតិបត្តិការដែលត្រូវបានបង្កើតឡើងជាពិសេស ដើម្បីគ្រប់គ្រង និងកែលម្អដំណើរការស៊ើបអង្កេត ផ្នែកជួញដូរ ព្រមទាំង*ការតាមដាន និងពិនិត្យ*យ៉ាងយកចិត្តទុកដាក់ទៅលើការអនុវត្តន៍នេះ តាមរយៈអភិបាលកិច្ចផ្ទៃក្នុងឱ្យសមស្រប និងសវនកម្មឯករាជ្យ។

ដូចដែលបានកត់សម្គាល់ខាងលើ នាពេលបច្ចុប្បន្ន បទដ្ឋាននីតិវិធីប្រតិបត្តិការនៅទូទាំងអាស៊ានត្រូវបានបង្កើតឡើង អង្គភាពឯកទេសទាំងឡាយដែលមិនទាន់ធ្វើបានបង្កើត គួរតែពិចារណាប្រើប្រាស់បទដ្ឋាននីតិវិធីប្រតិបត្តិការអាស៊ានឆ្នាំ២០១១ (ទូទៅ) ធ្វើជាក្របខ័ណ្ឌសម្រាប់បង្កើតសំណៅដែលសម្របទៅនឹងប្រទេសរបស់ខ្លួន។ វាជាការសំខាន់ដែលថា ការប្រកាន់ខ្ជាប់ តាមគោលដៅ និងជំហ៊ាននៃការស៊ើបអង្កេតដែលបានរៀបរាប់ នៅក្នុងបទដ្ឋាននីតិវិធីប្រតិបត្តិការ តាមសំណៅថ្នាក់ជាតិ វាធ្វើឱ្យក្លាយជាកាតព្វកិច្ចសម្រាប់អ្នកប្រតិបត្តិទាំងអស់ ទោះបីជាពួកគេជាសមាជិក ក្នុងអង្គភាពឯកទេស ឬមិនមែនឯកទេសក៏ដោយ។ បើមិនមាន ការកំណត់ជាកាតព្វកិច្ចទេ វាពិតមានការលំបាកណាស់ក្នុងការឆ្លើយតប តាមរយៈការស៊ើបអង្កេតដែលមានគុណភាពខ្ពស់តាមបទដ្ឋាននៅទូទាំងប្រទេស និងដើម្បីឱ្យមេបញ្ជាការអង្គភាពឯកទេសត្រូវធានានូវការអនុវត្តន៍តាម។

ចុងក្រោយ ការតាក់តែងបញ្ចប់បទដ្ឋាននីតិវិធីប្រតិបត្តិការ ជាសំណៅនៅថ្នាក់ជាតិ គួរសំដៅដល់ការពិនិត្យទៅលើកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្ន ដើម្បីធានាថា នីតិវិធីទាំងនេះត្រូវបានបញ្ចូលយ៉ាងពេញលេញទៅក្នុងកម្មវិធីពាក់ព័ន្ធ

និងបង្កើតជាចំណុចស្នូលនៃកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន។ វាក៏ជាការសំខាន់ដែលត្រូវធានាឱ្យ មានការពិនិត្យទៅលើយន្ត នៃការគ្រប់គ្រង និងការត្រួតពិនិត្យ ដើម្បីធានាថាយន្តការទាំងនេះអាចដំណើរការមុខងារបានតាមទីតិវិធីប្រតិបត្តិ។

# ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងគុណភាពនៃការស៊ើបអង្កេត

សម្រាប់របាយការណ៍វឌ្ឍនភាពឆ្នាំ២០១១ ព័ត៌មានស្តីពីការប្រឈម ទាក់ទងនឹងគុណភាពនៃការស៊ើបអង្កេត ផ្អែកលើការវិភាគលម្អិតទៅលើការជ្រើសរើសសំណុំរឿង ដែលត្រូវបានស៊ើបអង្កេត ដោយអង្គភាពឯកទេសនៅក្នុងតំបន់អាស៊ាន ដោយមានការបំពេញបន្ថែម ដោយការធ្វើសម្ភាសន៍ របស់អ្នកស៊ើបអង្កេតឯកទេស និងព្រះរាជអាជ្ញា ដែលបានចូលរួមក្នុងសំណុំរឿងជាក់លាក់។ ទោះបី រដ្ឋសមាជិកអាស៊ានភាគច្រើនមានការវិវត្តន៍ច្រើនក្តី តែបញ្ហាចម្បង ផ្នែកប្រតិបត្តិការ ដែលត្រូវបានកំណត់នៅឆ្នាំ២០១១ ហាក់ដូចជានៅតែបន្តមានតាមទម្រង់មួយចំនួនដដែល។ ចំណុចទាំងនោះរួមមានដូចខាងក្រោម៖

## បញ្ហាក្នុងការធ្វើផែនការ និងការគ្រប់គ្រងការស៊ើបអង្កេត

អង្គភាពឯកទេសមួយចំនួន មានការចង្អុលបង្ហាញថាមិនមានជំនាញគ្រប់គ្រាន់ក្នុងការធ្វើផែនការ ការដឹកនាំ និងការគ្រប់គ្រងការស៊ើបអង្កេតទៅលើការជួញដូរដែលកំពុងដំណើរការនោះទេ។ ចំណុចនេះអាចមានឥទ្ធិពល ជាអវិជ្ជមានទៅលើគុណភាព នៃការឆ្លើយតបនៅក្នុងសកម្មភាពស៊ើបអង្កេតមួយដែលសំខាន់ និងមានទំនាក់ទំនងគ្នា។ វាជាការពាក់ព័ន្ធដែលត្រូវកត់សម្គាល់ដែលថា ការបណ្តុះបណ្តាលមេបញ្ជាការអង្គភាពឯកទេសនៅ**ប្រទេសមីយ៉ាន់ម៉ា** និង**ឥណ្ឌូនេស៊ី** ទំនងជាធ្វើមានភាពប្រសើរឡើងក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការវាយតម្លៃហានិភ័យ នៃការស៊ើបអង្កេត។

## ការផ្តោតមិនពេញលេញទៅលើការវាយតម្លៃ ការកំណត់ទីកន្លែង និងការជួយសង្គ្រោះជនរងគ្រោះដែលស្ថិតក្នុងការប្រវញ្ចនៅឡើយ

ការពិនិត្យទៅលើប្រវត្តិនៃសំណុំរឿងដែលមានក្នុងអង្គភាពឯកទេសប្រឆាំងការជួញដូរ នៅឆ្នាំ២០១១ បានបង្ហាញថា មានការយកចិត្តទុកដាក់តិចតួចណាស់ លើការស៊ើបអង្កេតបន្ថែមទៀតពីលទ្ធភាព ដែលជនរងគ្រោះ ស្ថិតក្នុងស្ថានភាពកេងប្រវញ្ចនៅឡើយ និងការចាត់វិធានការសមស្រប ដើម្បីយកពួកគេចេញពីព្យសនកម្មនេះ។ បើតាមទស្សនៈមនុស្សធម៌ ចំណុចនេះមានន័យថា ជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរស្ថិតក្នុងស្ថានភាពនៃព្យសនកម្មដដែល តែបើតាមទស្សនៈនៃការស៊ើបអង្កេត ចំណុចនេះឆ្លុះបញ្ចាំងនូវការបាត់បង់កាលានុវត្តភាពក្នុងការស្វែងរក និងយកជនរងគ្រោះចេញពីព្យសនកម្ម និងប្រមូលភស្តុតាងបន្ថែម ដើម្បីឆ្លុះបញ្ចាំងនូវទំហំផ្ទាល់នៃបទល្មើស។ នៅក្នុងទិដ្ឋភាពនេះមិនមានភាពប្រសើរឡើងទេ ពាក់ព័ន្ធ នៃការឆ្លើយតបឯកទេស ចាប់តាំងពី*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ មក។

## ការបង្កើតកម្មវត្ថុមិនសមស្រប

នៅក្នុងករណីមួយចំនួន ការចាប់ខ្លួនជនសង្ស័យគឺជាអាទិភាពធំ ដោយមិនគិតដល់សុវត្ថិភាពរបស់ជនរងគ្រោះ ហើយជារឿយៗបញ្ហានេះបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរធ្លាក់ទៅលើជនរងគ្រោះ។ នៅក្នុងសំណុំរឿងផ្សេងទៀត វាបានបាត់បង់កាលានុវត្តភាពក្នុងការពង្រីកការស៊ើបអង្កេត និងការស្វែងរកជនរងគ្រោះបន្ថែម។ ចំណែកឯក្នុងសំណុំរឿងផ្សេងទៀត ការសម្រេចចិត្តតែមួយ ក្នុងការបង្ហាញពិរុទ្ធភាពជាអាទិភាព នៃការស៊ើបអង្កេត បណ្តាលឱ្យមន្ត្រីស៊ើបអង្កេតមើលរំលងនូវភស្តុតាង ដែលចង្អុលពីភាពគ្មានទោសរបស់ជនសង្ស័យ។

## ការប្រើប្រាស់បទដ្ឋាននីតិវិធីប្រតិបត្តិការ នីតិវិធីនៃការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យមិនពេញលេញ

ការវិភាគទៅលើសំណុំរឿងពីដំបូងបានបង្ហាញថា មានការប្រើប្រាស់មិនពេញលេញ នូវនីតិវិធីនៃការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ នៅក្នុងដំណើរការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។ ឱនភាពនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងចំណុចខាងលើ ដោយពាក់ព័ន្ធនឹងការមិនបានកំណត់អត្តសញ្ញាណជនរងគ្រោះបន្ថែមទៀតដែលរងផលប៉ះពាល់ដោយសារបទល្មើសជួញដូរដែលបានរាយការណ៍។ ប្រសិនបើនីតិវិធីវាយតម្លៃហានិភ័យស្តង់ដារត្រូវបានអនុវត្តជាប្រចាំ ជាពិសេសទាក់ទងនឹងជនរងគ្រោះ នោះវានឹងមិនមានករណីជាច្រើន ដែលក្នុងនោះការឆ្លើយតបនៃការស៊ើបអង្កេតបានបរាជ័យក្នុងការផ្តួចផ្តើមកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងរក និងយកជនរងគ្រោះចេញ ពីគ្រោះថ្នាក់ដែលមិនគិតពីយុត្តាធិការដែលពួកគេអាចស្ថិតនៅ ។

## ចម្លើយរបស់ជនរងគ្រោះ និងជនសង្ស័យមានគុណភាពទាប

នៅក្នុងការស៊ើបអង្កេតក្រោយពេលកើតហេតុ ចម្លើយរបស់ជនរងគ្រោះជាធាតុផ្សំដ៏មានសារៈសំខាន់ បំផុតនៅក្នុងការចោទប្រកាន់។ ក្នុង*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ បានបង្ហាញថា នៅក្នុងសំណុំរឿងមួយចំនួនធំ ចម្លើយរបស់សាក្សីជាជនរងគ្រោះមិនមានចំណុចចាំបាច់លម្អិតណាមួយដែលមានតម្លៃជាភស្តុតាង ដើម្បីបង្ហាញពីធាតុផ្សំចាំបាច់ក្នុងសំណុំរឿងទេ។ ជាងនេះទៀត ពួកគេមិនបានកំណត់អត្តសញ្ញាណត្រឹមត្រូវលើជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿងនៃបទល្មើសទេ។ ពួកគេមានតួនាទីឬចង្អុលបង្ហាញពីកាលានុវត្តភាព ក្នុងការធានាស្វែងរកនូវភស្តុតាងបំពេញបន្ថែមបើទោះបីព័ត៌មានមួយចំនួន ដែលពួកគេបានទទួលនៅពេលសម្ភាសជាមួយជនរងគ្រោះក៏ដោយ។ មានភស្តុតាងមួយចំនួន បង្ហាញថាការបណ្តុះបណ្តាលអ្នកស៊ើបអង្កេតឯកទេស អំពីបច្ចេកទេសស្តាប់ចម្លើយជនរងគ្រោះ បានធ្វើឱ្យមានភាពប្រសើរឡើង នូវគុណភាពចម្លើយរបស់សាក្សី។ បញ្ហាស្រដៀងគ្នានេះដែរ បានកើតឡើងនៅក្នុងការសួរចម្លើយជនសង្ស័យ ដែលផ្នែកខ្លះនៅតែពឹងផ្អែកទៅលើចម្លើយសារភាពដែលអាចទាញយកបាន តាមរយៈវិធីសាស្ត្រដែលមិនឆ្លុះបញ្ចាំងនូវការអនុវត្តន៍បែបវិជ្ជាជីវៈ និងក្រមសីលធម៌របស់នគរបាល។

## ការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេតមិនបានពេញលេញលើគ្រប់ទិដ្ឋភាពទាំងអស់ដែលមាននៅក្នុងសំណុំរឿងនីមួយៗ

នៅគ្រប់តំបន់ទាំងអស់ រួមទាំងអាស៊ានផង ការយកចិត្តទុកដាក់តិចតួចចំពោះការខិតខំប្រឹងប្រែង លើការងារស៊ើបអង្កេតគឺជាបញ្ហាមួយដ៏រ៉ាំរ៉ៃ។ ឧទាហរណ៍ អ្នកស៊ើបអង្កេតកម្រស្វែងរកការកំណត់អត្តសញ្ញាណ ឬចាត់វិធានការបន្ថែម ទៅលើជនសង្ស័យ ដែលហួសពីក្របខ័ណ្ឌជាតិនោះទេ។ បញ្ហារាលដាលមួយទៀតគឺការផ្តោតជ្រុលពេកទៅលើ “បញ្ហាងាយៗពេក” ដូចជា អ្នកដឹកជញ្ជូន អ្នកជ្រើសរើស និងឈ្មួញកណ្តាល។ ចំណុចនេះមានន័យថា អ្នកដែលចូលរួមក្នុងការកេងប្រវ័ញ្ចដោយផ្ទាល់ ហើយអ្នកដែលបានទទួលផលប្រយោជន៍ពីប្រតិបត្តិការជួញដូរ ជារឿយៗតែងតែរួចផុតពីការស៊ើបអង្កេត និងការចាប់ខ្លួន។ ស្ត្រីដែលត្រូវបានចាប់ខ្លួនចំពោះបទល្មើសជួញដូរ មានអត្រាខ្ពស់ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន រួមមាន **ប្រទេសមីយ៉ាន់ម៉ា** និង**ហ្វីលីពីន ចំណុចនេះ**បង្ហាញថា ការកំណត់ជាគោលដៅលើជនល្មើសនៅមានកម្រិតទាប និងនៅតែជាបញ្ហាចាក់ឫសនៅឡើយ។

## ការផ្តោតមិនពេញលេញទៅលើការកំណត់អត្តសញ្ញាណនៃបណ្តាញឧក្រិដ្ឋជនដែលមានការចាត់តាំង

នៅបន្តមានការប្រឈមនៅក្នុងតំបន់ទាំងមូល ក្នុងការកំណត់អត្តសញ្ញាណបណ្តាញឧក្រិដ្ឋជនដែលមានការចាត់តាំង ទាំងតាមរយៈការស្តាប់យកចម្លើយលម្អិតពេញលេញពីសាក្សីជាជនរងគ្រោះ ឬតាមរយៈវិធីសាស្ត្រស៊ើបអង្កេតផ្សេងទៀត។ ចំណុចនេះបង្ហាញពីការបាត់បង់ កាលានុវត្តភាព ដោយសាររដ្ឋសមាជិកអាស៊ានភាគច្រើនមានច្បាប់ដែលចែងអំពីទោសទណ្ឌ ជាស្ថានទម្ងន់ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជនដែលមានការចាត់តាំង។ បទដ្ឋាននិយមន័យនៃពាក្យ "ក្រុមឧក្រិដ្ឋជនដែលមានការចាត់តាំង" តម្រូវឲ្យក្រុមរួមមានគ្នាចាប់ពី ៣ នាក់ឡើង ដែលជាស្ថានភាពកើតមាននៅក្នុងសំណុំរឿងជួយដូរច្រើនសន្ធឹកសន្ធាប់។ ការមិនបានធានាថា ចម្លើយរបស់ជនរងគ្រោះ និងការស៊ើបអង្កេតផ្ទុះបញ្ជាំងឲ្យបានសមរម្យនូវអត្ថិភាពនៃស្ថានទម្ងន់នេះ តំណាងពីកាលានុវត្តភាពដែលបាត់បង់ដ៏ធំធេង។

## ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតមុនពេលកើតហេតុមិនពេញលេញ

វិធីសាស្ត្រស៊ើបអង្កេតមុនពេលកើតហេតុមានប្រសិទ្ធភាព ដោយសារវាបានប្រយោជន៍ពីភាពទន់ខ្សោយរបស់ជនជួញដូរ ដែលត្រូវបានបង្កើតឡើងដោយភាពអាចមើលឃើញបានពីវិធីសាស្ត្ររបស់ពួកគេ និងផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវមធ្យោបាយស៊ើបអង្កេតតាមវិធីមួយទៀត ដែលយកឈ្នះឱនភាពនៃព័ត៌មានដែលបណ្តាលមកពីការសហការរបស់ជនរងគ្រោះក្នុងនាមជាសាក្សីមានកម្រិតទាប។ ជាងនេះទៀត បច្ចេកទេសទាំងនេះអនុញ្ញាតឲ្យអ្នកស៊ើបអង្កេតអាចសម្លឹងមើលបានជ្រៅទៅក្នុងរចនាសម្ព័ន្ធឧក្រិដ្ឋជនដើម្បីកំណត់អំពីរបៀបរៀបចំ តួនាទីលម្អិត របៀបរៀបចំហិរញ្ញវត្ថុ និងថាតើ មានជនរងគ្រោះបន្ថែមក្រៅពីរងគ្រោះដែលឃើញទាំងនោះ ឬទេ។

ទោះបីមានកំណើនក្នុងការដាក់ពង្រាយបច្ចេកទេសស៊ើបអង្កេតមុនពេលកើតហេតុ ដែលបានជ្រើសរើសក៏ដោយ តែនៅមានការស៊ើបអង្កេតមុនពេលកើតឡើង ដែលមានតម្រុយពីព័ត៌មានសម្ងាត់សុទ្ធសាធ ដែលត្រូវផ្តួចផ្តើម និងដំណើរការដោយអង្គភាពឯកទេសនៅក្នុងរដ្ឋសមាជិកអាស៊ាន។ កម្រិតជាក់ស្តែងនៃការប្រើប្រាស់បច្ចេកទេសដែលមាននៅក្នុងឧទាហរណ៍ដ៏ច្រើនសន្ធឹកសន្ធាប់សបានគាំទ្រដល់ការស៊ើបអង្កេតមុនពេលកើតហេតុ ដើម្បីធានានូវភស្តុតាងស្របគ្នានៃចម្លើយរបស់សាក្សី។ នៅក្នុងសំណុំរឿងភាគច្រើននៅក្នុងតំបន់ ការស៊ើបអង្កេតចាប់ផ្តើមដោយមានពាក្យបណ្តឹង ឬការកំណត់អត្តសញ្ញាណអ្នកដែលអាចជាជនរងគ្រោះ ហើយបន្ទាប់មកមានការចាប់ខ្លួនភ្លាមៗចំពោះជនសង្ស័យដែលគេអាចរកឃើញតួនាទីយ៉ាងងាយ។ ហេតុនេះ ការស៊ើបអង្កេតនៅពេលបន្ទាប់បានធ្វើឡើងនៅក្នុងបរិយាកាសដែលអ្នករៀបចំចម្បងនៃសកម្មភាពជួញដូរបានដឹងច្បាស់ពីការពាក់ព័ន្ធរបស់នគរបាល ហើយវាមានឥទ្ធិពលយ៉ាងធំធេងទៅលើវិសាលភាពដែលអ្នកស៊ើបអង្កេតអាចប្រមូលភស្តុតាងប្រឆាំងនឹងពួកគេបាន។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ការអនុវត្តន៍ជាក់ស្តែងនេះត្រូវបានរារាំងដោយច្បាប់ និងមានការលំបាកក្នុងការផ្លាស់ប្តូរ។ ក៏ប៉ុន្តែ វាជាការសំខាន់ដែលទទួលស្គាល់ថា ឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះបានកម្រិតយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថភាពស៊ើបអង្កេតផ្នែកអនុវត្តន៍ច្បាប់ទៅលើសំណុំរឿងជួញដូរ។ វិធីសាស្ត្ររបស់នគរបាលក្នុងការស៊ើបអង្កេតមុនពេលកើតហេតុដែលត្រូវបានយកមកអនុវត្តក្នុងវិធីមួយដែលមិនធ្វើឲ្យជនរងគ្រោះ ឬអ្នកដែលអាចជាជនរងគ្រោះ ស្ថិតក្នុងហានិភ័យនៃព្យសនកម្មបន្ថែមទៀត និងផ្តល់កាលានុវត្តភាពសំខាន់ដើម្បីធានាភស្តុតាងដែលមានសារៈសំខាន់ ចាំបាច់សម្រាប់ការចោទប្រកាន់ចំគោលដៅ និងមានប្រសិទ្ធភាព។

## ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុមិនត្រូវបានផ្តល់អាទិភាព

ដោយមិនគិតដល់ភាពលំបាកលើផ្នែករចនាសម្ព័ន្ធដែលមានចំពោះការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ វាជារឿងកម្រដែលអង្គភាពឯកទេសក្នុងរដ្ឋសមាជិកអាស៊ាន ដែលមានឱកាសការអនុវត្តបច្ចេកទេស នៃការប្រមូលភស្តុតាងស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ។ មកទល់នឹងសព្វថ្ងៃនេះ អង្គភាពឯកទេសប្រឆាំងការជួញដូរមានការស៊ើបអង្កេតតិចតួចដែលបានបញ្ចូលសមាសធាតុស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុទាំងនៅក្នុងដំណាក់កាលធ្វើផែនការ ឬដំណាក់កាលអនុវត្តការឆ្លើយតាមរយៈការស៊ើបអង្កេត។ ការអនុវត្តនេះនឹងអាចផ្លាស់ប្តូរបាន។ ឧទាហរណ៍ នៅ**ប្រទេសថៃ** នាពេលបច្ចុប្បន្ននេះ មន្ត្រីប្រឆាំងការសម្អាតប្រាក់រំពឹងថាបានចូលរួមជាប្រចាំក្នុងការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។ នគរបាលជាតិ**ឥណ្ឌូនេស៊ី** ដោយសហការជាមួយមជ្ឈមណ្ឌលផ្នែកផ្តល់ព័ត៌មាន និងផ្នែកវិភាគប្រតិបត្តិការហិរញ្ញវត្ថុ (INTRAC) នាពេលថ្មីៗនេះបានបង្កើតនូវគោលការណ៍ណែនាំ*សម្រាប់អ្នកស៊ើបអង្កេត* ជាមូលដ្ឋាន ក្នុងគោលបំណងគាំទ្រដល់ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ នៅក្នុងសំណុំរឿងជួញដូរមនុស្ស។ គោលការណ៍ណែនាំនេះពន្យល់ពីមូលហេតុដែលការស៊ើបអង្កេតទាំងនេះមានសារៈសំខាន់ ហើយក៏គ្របដណ្តប់ទៅលើ “ពេលវេលា” និង “របៀប” នៃការអនុវត្តផងដែរ។ នៅ**ប្រទេសមីយ៉ាន់ម៉ា** ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងសំណុំរឿងជួញដូរមនុស្សត្រូវបានស៊ើបអង្កេតរួមគ្នា ដោយមានការចូលរួមរវាងផ្នែកប្រឆាំងការជួញដូរមនុស្ស និងផ្នែកប្រឆាំងបទល្មើសផ្នែកហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ប្រធាននគរបាល។

ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ទោះបីនៅក្នុងបណ្តារដ្ឋសមាជិកអាស៊ានដែលដំណើរការរឹបអូសទ្រព្យត្រូវបានធ្វើឡើងដោយស្ថាប័នផ្សេងក៏ដោយ តែអង្គភាពឯកទេសនៅតែមានភារកិច្ចក្នុងការធ្វើផែនការ និងធានាស្វែងរកភស្តុតាង ដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងផលប្រយោជន៍ពីក្រុមជួញដូរមនុស្ស តែវាមិនត្រូវបានបញ្ចូលជាប្រចាំទៅក្នុងការឆ្លើយតបតាមរយៈការស៊ើបអង្កេតទេ។ និយាយជារួមមានភស្តុតាងមួយចំនួនដែលបញ្ជាក់ពីការផ្លាស់ប្តូរនេះ ចាប់តាំងពីឆ្នាំ២០១១មក ដោយការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុមានកាន់តែច្រើន ដែលបានធ្វើឡើងនៅក្នុងប្រទេសមួយចំនួន។ តែអ្វីដែលសំខាន់គឺសមត្ថភាពរបស់អ្នកស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស នៅក្នុងវិស័យនេះមានកម្រិតទាប ហើយភាគច្រើន ពួកគេរាយការណ៍ថា ពួកគេកម្របានទទួលការគាំទ្រពីស្ថាប័នដែលទទួលខុសត្រូវបទល្មើសផ្នែកហិរញ្ញវត្ថុណាស់។ ប្រការសំខាន់គឺថា ការកំណត់ជាគោលដៅចំពោះជនល្មើស លើបទល្មើសហិរញ្ញវត្ថុនេះនៅមានចំនួនតិចនៅឡើយ ដែលជាទូទៅឱកាសក្នុងការស្វែងរកទ្រព្យដែលបានពីបទល្មើសក៏នៅមានចំនួនតិចតួចដដែល។

## ការពុំមានឆន្ទៈ ក្នុងការប្រឈមនិងស៊ើបអង្កេតករណីអំពើពុករលួយដែលអាចធ្វើទៅបាន

នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក មានទំនាក់ទំនងយ៉ាងរឹងមាំរវាងការជួញដូរ និងអំពើពុករលួយក្នុងវិស័យសាធារណៈ។ ជួនកាល មន្ត្រីចូលរួមដោយផ្ទាល់ក្នុងការកេងប្រវ័ញ្ច ឬការសម្របសម្រួល។ ពួកគេអាចទទួលបានប្រាក់កម្រៃចំពោះការមិនស៊ើបអង្កេត មិនចោទប្រកាន់ និងមិនផ្តន្ទាទោសចារីនៃអំពើកេងប្រវ័ញ្ច។ តំបន់អាស៊ានក៏ដូចជាតំបន់ផ្សេងទៀតដែរ ហើយមានការកត់ត្រានៅក្នុងសំណុំរឿងជាច្រើនពីការសមគំនិតរបស់មន្ត្រីក្នុងករណីជួញដូរមនុស្ស។ សំណុំរឿងទាំងនេះកម្រនឹងត្រូវគេយកមកស៊ើបអង្កេតបន្តណាស់ រួមទាំងអង្គភាពឯកទេសផងដែរ។ កង្វះសកម្មភាពក្នុងការដោះស្រាយអំពើពុករលួយនៅក្នុងការជួញដូរមនុស្សគឺជាបរាជ័យមួយ ដោយមន្ត្រីមិនបំពេញភារកិច្ច និងបន្ថែមហានិភ័យដល់កិត្តិនាមជាសាធារណៈរបស់អង្គភាពឯកទេស។ ទោះជាយ៉ាងណាក៏មានសញ្ញាណនៃវឌ្ឍនភាពមួយចំនួន

ឧទាហរណ៍ ការចាប់ខ្លួនមន្ត្រីពុករលួយល្បីឈ្មោះដែលពាក់ព័ន្ធនឹងការជួញដូរនៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន រួមមាន **ប្រទេសថៃ ហ្វីលីពីន** និង**មីយ៉ាន់ម៉ា**។

## ការទទួលយកការដោះស្រាយ "មិនផ្លូវការ"

នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន មានការប៉ះពាល់ដល់ ការកែលម្អទៅលើចំនួន និង គុណភាពនៃការស៊ើបអង្កេតលើការជួញដូរមនុស្ស ឬត្រូវបានលុបចោលតែម្តង ដោយមានការកើនឡើងនូវការទទួលយកការដោះស្រាយ "មិនផ្លូវការ" ដែលជាទូទៅ ពាក់ព័ន្ធនឹងការណ៍ដែលជនសង្ស័យបង់សំណងដល់ជនរងគ្រោះ (ហើយជួនកាលដល់នគរបាលផងដែរ)។ យុត្តិធម៌មិនផ្លូវការបែបនេះគឺមិនមែនជាយុត្តិធម៌ទាល់តែសោះ។ វាធ្វើឱ្យអាប់ឱនដល់នីតិរដ្ឋ ជំរុញឱ្យមានអំពើពុករលួយកាន់តែច្រើន ហើយជាការរាំងស្ទះមួយដល់ដំណើរការនៃការផ្តល់យុត្តិធម៌ពិតប្រាកដដល់ជនរងគ្រោះ។

## ការផ្តល់តួនាទីមិនសមរម្យដល់អង្គការក្រៅរដ្ឋាភិបាលក្នុងការអនុវត្តការងារ

រដ្ឋសមាជិកអាស៊ានមួយចំនួន មានទិន្នាការមួយដោយផ្តល់ឱកាសឱ្យអង្គការក្រៅរដ្ឋាភិបាលនូវតួនាទីធំធេងពេកក្នុងការស៊ើបអង្កេតលើករណីជួញដូរមនុស្ស ជាស្ថាប័នឆ្លើយតបជំនាញ។ មានឧទាហរណ៍ បានលើកឡើងជាច្រើន អំពីករណីដែលអង្គការក្រៅរដ្ឋាភិបាលត្រូវបានអនុញ្ញាតឱ្យអនុវត្ត ហើយជួនការត្រូវបានជំរុញយ៉ាងសកម្ម ក្នុងការដឹកនាំសកម្មភាពដែលជាធម្មតា ការងារនេះជាតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដូចជា ការឃ្លាំមើល និងប្រមូលទិន្នន័យ ជាដើម។ ចំណុចនេះធ្វើឱ្យប៉ះពាល់ដល់សកម្មភាពរបស់មន្ត្រីនគរបាល ហើយក្នុងករណីមួយចំនួន អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់ជនរងគ្រោះថែមទៀតផង។ ជាងនេះទៀត មានការកត់ត្រាពីករណីមួយចំនួនដែលអង្គការក្រៅរដ្ឋាភិបាលបានចូលរួមក្នុងការជំរុញឱ្យមន្ត្រីនគរបាលធ្វើសកម្មភាពខុសច្បាប់ ដូចជាបើកប្រតិបត្តិការនៅក្នុងប្រទេសមួយទៀតដោយគ្មានកិច្ចព្រមព្រៀងផ្លូវការរបស់អាជ្ញារបស់ប្រទេសនោះ ហើយករណីខ្លះអង្គការក្រៅរដ្ឋាភិបាលាបានដាក់សម្ពាធមិនសមរម្យទៅលើមន្ត្រីថ្នាក់ទាប ដើម្បីផ្តល់ឱ្យពួកគេទទួលបាននូវព័ត៌មានមានលក្ខណៈរសើបដល់ប្រតិបត្តិការ ឬពាក់ព័ន្ធនឹងសំណុំរឿង។ ភ្នាក់ងារអនុវត្តន៍ច្បាប់ត្រូវទទួលស្គាល់ថា ពួកគេត្រូវទទួលខុសត្រូវពេញលេញនៅក្នុងដំណើរការស៊ើបអង្កេត ហើយថា ការទទួលយកជំនួយប្រតិបត្តិការពីភាគីខាងក្រៅទំនងជាមិនសមរម្យ និងធ្វើឱ្យមានការខូចខាត ហើយអាចនាំឱ្យមានការល្មើសច្បាប់ថែមទៀតផង។

## ការប្រើប្រាស់សមត្ថភាពកិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែនមិនពេញលេញ

អង្គភាពឯកទេសទាំងអស់នៅតំបន់អាស៊ាន មានសមត្ថភាពបំពេញមុខងារនានាដែលពាក់ព័ន្ធដល់ការស៊ើបអង្កេតឆ្លងដែន រួមមាន៖ ការផ្លាស់ប្តូរព័ត៌មានសម្ងាត់ដោយផ្អែកលើសំណុំរឿង ការកំណត់អត្តសញ្ញាណ ទីកន្លែង និងការជួយសង្គ្រោះជនរងគ្រោះ ការកំណត់អត្តសញ្ញាណ និងការស៊ើបអង្កេតទៅលើជនសង្ស័យនៅក្នុងយុត្តាធិការផ្សេង ការកំណត់អត្តសញ្ញាណ និងការធានាសម្ភារភស្តុតាង និង/ឬ ទ្រព្យនានាដែលស្ថិតក្នុងយុត្តាធិការផ្សេង។ ចំណុចទាំងអស់នេះមានសក្តានុពលដើម្បីធ្វើផែនការ និងអនុវត្តការស៊ើបអង្កេតរួមគ្នា។ ក៏ប៉ុន្តែ ដូចដែលនឹងពិភាក្សាបន្ថែមនៅក្នុងជំពូកទី ៧ គឺថា ដោយមានករណីលើកលែងមួយចំនួន អ្នកស៊ើបអង្កេតឯកទេសមិនមានការពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការឆ្លងដែនញឹកញាប់នោះទេ។ មានសញ្ញាច្បាស់លាស់មួយចំនួន នៃការកែលម្អនៅក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ហើយកិច្ចសហប្រតិបត្តិការបច្ចុប្បន្ននេះ កំពុងមានការកើនឡើង ហើយវាកំពុងនាំទៅរកលទ្ធផលជាក់ស្តែង និងសំខាន់ៗ។ ក៏ប៉ុន្តែ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីឱ្យទិដ្ឋភាពដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ

ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ក្លាយជាផ្នែកនៃប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពឯកទេស។ ឧបសគ្គដែលមានចំពោះកិច្ចសហប្រតិបត្តិការនេះរួមមាន៖ បញ្ហាភាសា បញ្ហាឋានៈ និងឋានន្តរស័ក្តិរបស់មន្ត្រីពាក់ព័ន្ធ មន្ត្រីម្នាក់ៗមិនមានឆន្ទៈក្នុង កិច្ចសហប្រតិបត្តិការមិនផ្លូវការ ដោយពួកគេមានការព្រួយបារម្ភអំពីបែបបទ ឬនីតិវិធីសមស្រប ភាពពុំមានឆន្ទៈក្នុងការសហការស៊ើបអង្កេតទៅលើសំណុំរឿងដែលពាក់ព័ន្ធនឹងអំពើពុករលួយរបស់មន្ត្រី/ការសមគំនិត ពុំមានផលប្រយោជន៍ និងមិនមានរង្វាន់លើកទឹកចិត្តសម្រាប់កិច្ចសហប្រតិបត្តិការ និងផលវិបាកអវិជ្ជមានចំពោះការមិនទទួលបាននៃកិច្ចសហការលើការស៊ើបអង្កេតឆ្លងដែន។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការបណ្តុះបណ្តាល

មានភ្នាក់ងារអនុវត្តន៍ច្បាប់តិចតួចណាស់នៅតំបន់អាស៊ាន ដែលអាចផ្តល់ការបណ្តុះបណ្តាលដល់អ្នកស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្សបាន។ ចំណុចនេះមានន័យថា មន្ត្រីដែលកំពុងស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្ស រួមទាំងអ្នកដែលពាក់ព័ន្ធនឹងអង្គភាពឯកទេសផង ពុំមានចំណេះដឹង ឬឥរិយាបថសមស្រប និងជំនាញដែលចាំបាច់ សម្រាប់ការស៊ើបអង្កេតទៅលើករណីស៊ើបអង្កេតដែលមានលក្ខណៈស្មុគស្មាញទាំងនេះទេ។ មានឧបសគ្គជាក់លាក់មួយចំនួនដែលមានលើកឡើងដូចខាងក្រោម៖

- **សមត្ថភាពបណ្តុះបណ្តាលផ្ទៃក្នុងនៅមានកម្រិតទាប៖** នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ការបណ្តុះបណ្តាលការស៊ើបអង្កេតឯកទេសត្រូវបានផ្តល់ដោយស្ថាប័នពីក្រៅ ដោយសារភ្នាក់ងារអនុវត្តន៍ច្បាប់ភាគច្រើនមិនមានកម្មវិធីដើម្បីទទួលបាននូវការរៀនសូត្របន្ត និងការអភិវឌ្ឍន៍ដល់មន្ត្រីអនុវត្តន៍ច្បាប់ ហេតុនេះពួកគេពុំមានសមត្ថភាព និងធនធានដើម្បីការបណ្តុះបណ្តាលការស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្សដល់បុគ្គលិករបស់ខ្លួនបានទេ។
- **អត្រានៃការផ្លាស់ប្តូរបុគ្គលិកមានកម្រិតខ្ពស់៖** ភ្នាក់ងារអនុវត្តន៍ច្បាប់ភាគច្រើន នៅអាស៊ានបានអនុវត្តកម្មវិធីប្តូរវេន និងតម្លើងតួនាទី ឋានៈបុគ្គលប្រចាំឆ្នាំ។ ចំណុចនេះមានន័យថា បុគ្គលិកដែលទទួលការបណ្តុះបណ្តាលថ្មីៗត្រូវបានផ្ទេរពីអង្គភាពឯកទេស ឬត្រូវបានតម្លើងឋានៈចេញពីអង្គភាពនោះ មុនពេលពួកគេមានឱកាសក្នុងការយកចំណេះដឹង និងជំនាញដែលទទួលបានថ្មីៗមកអនុវត្ត ដោយស៊ើបអង្កេតទៅលើសំណុំរឿងជាក់ស្តែង។ ជាធម្មតា ពួកគេត្រូវបានជំនួសដោយបុគ្គលិកថ្មីដែលមិនធ្លាប់ទទួលការបណ្តុះបណ្តាលដើម្បីស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្សទេ ហេតុនេះ ហើយបានជាពួកគេពុំមានចំណេះដឹង និងជំនាញឯកទេសដើម្បីស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្សឱ្យមានប្រសិទ្ធភាពបាននេះទេ។

ទោះបីជាយ៉ាងណា ក៏មានវឌ្ឍនភាពមួយចំនួនទាក់ទងនឹងការបណ្តុះបណ្តាញជំនាញនេះដែរ។ ឧទាហរណ៍ **ប្រទេសហ្វីលីពីន** ទទួលបានជោគជ័យក្នុងការបង្កើតកម្មវិធីបណ្តុះបណ្តាលការស៊ើបអង្កេតឯកទេសសម្រាប់មជ្ឈមណ្ឌលការការពារស្ត្រី និងកុមារ។ កម្មវិធីនេះបង្កើតឡើងដោយសារ *កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់អ្នកស៊ើបអង្កេតឯកទេស* (ទាំងការស៊ើបអង្កេតក្រោយពេលកើតហេតុ និងការស៊ើបអង្កេតមុនពេលកើតហេតុ)។ បច្ចុប្បន្ននេះ កម្មវិធីនេះត្រូវបានច្របាច់បញ្ចូលទៅក្នុងកម្មវិធីសាលាអភិវឌ្ឍន៍ផ្នែកការស៊ើបអង្កេត និងការស្រាវជ្រាវ (SIDD)។ ដោយមានជំនួយពីខាងក្រៅ ដែលគ្រូបង្គោលត្រូវបានទទួលការបណ្តុះបណ្តាលដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាលឯកទេសទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ប្រការសំខាន់គឺថា មានការបោះជំហ៊ានសំខាន់ៗមួយចំនួនដើម្បីធានានូវនិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការងារនេះ។ នាពេលនេះ កម្មវិធីនេះជាផ្នែកមួយនៃការបណ្តុះ

បណ្តុះបណ្តាលរបស់ SIDD និងបានទទួលថវិកាតាមរយៈការបែងចែកថវិកាប្រចាំឆ្នាំ ក្រោមថវិកាសម្រាប់ការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិហ្វីលីពីន។

នៅ**ប្រទេសកម្ពុជា** និង**មីយ៉ាន់ម៉ា** ការបណ្តុះបណ្តាលផ្លូវការដែលផ្តល់ពីខាងក្រៅស្តីពីការជួញដូរមនុស្សត្រូវបានបំពេញបន្ថែម ដោយវគ្គបង្រៀនទៀងទាត់ជាមួយអ្នកស៊ើបអង្កេត និងមេបញ្ជាការ ដោយផ្តល់ឱកាសដល់ពួកគេក្នុងការពិភាក្សាអំពីបញ្ហានានាដែលពួកគេបានជួបប្រទះ ក្នុងការអនុវត្ត និងអ្វីដែលពួកគេបានរៀនសូត្រ និងការដោះស្រាយនូវការយល់ច្រឡំ ឬគម្លាតផ្នែកចំណេះដឹង និងជំនាញ របស់ពួកគេ។ ក៏ប៉ុន្តែ និរន្តរភាពនៃកម្មវិធីនៅមានកម្រិតទាប ហើយដោយសារដែលបញ្ហានានាដូចជាការប្តូរវេនបុគ្គលិក ដូចបានលើកឡើងខាងលើ មានការរំពឹងថា ឥទ្ធិពលនៃអន្តរាគមន៍ទាំងនេះនឹងត្រូវបានកាត់បន្ថយនាពេលខាងមុខ។

ជារួមបទពិសោធន៍នៅក្នុងតំបន់ និងកន្លែងផ្សេងទៀតបញ្ជាក់អំពីសារៈសំខាន់ នៃការបណ្តុះបណ្តាល ក្នុងការបង្កើតជំនាញដែលចាំបាច់ ដល់ការស៊ើបអង្កេតទៅលើការជួញដូរឲ្យមានប្រសិទ្ធភាព។ ភ្នាក់ងារអនុវត្តន៍ច្បាប់នានានៅក្នុងតំបន់ត្រូវបានជំរុញឲ្យអភិវឌ្ឍសមត្ថភាពផ្ទៃក្នុងរបស់ពួកគេ ដើម្បីផ្តល់ការបណ្តុះបណ្តាលលើការស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស និងធ្វើផែនការ និងថវិកាសម្រាប់ផ្តល់ដល់ការបណ្តុះបណ្តាលនេះ ដល់មន្ត្រីស៊ើបអង្កេតឯកទេសដែលទើបត្រូវបានតែងតាំងថ្មីៗ រួមទាំងមន្ត្រីដែលស្ថិតនៅក្នុងអង្គភាពស្រាប់ ដែលមិនទាន់បានទទួលការបណ្តុះបណ្តាល។ ផែនការរក្សាទុកបុគ្គលិកសម្រាប់អ្នកស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស គួរត្រូវបានយកចិត្តទុកដាក់ ដើម្បីអនុញ្ញាតឲ្យពួកគេស្ថិតនៅក្នុងអង្គភាពបានយ៉ាងហោចណាស់ពី ៣ ទៅ ៥ ឆ្នាំ ដើម្បីឱ្យពួកគេមានឱកាសពេញលេញក្នុងការអនុវត្តការងារ និងទទួលបានការតម្លើងឋានៈតួនាទី នៅក្នុងអង្គភាព។

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| លេខយោង | បទដ្ឋានគុណភាព |
| ២ | សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់បញ្ចូលឲ្យមានអង្គភាពស៊ើបអង្កេតឯកទេសប្រឆាំងការជួញដូរ (SU) |
| ២.១ | អង្គភាពឯកទេសមានអាណត្តិការងារ និងអំណាចសមរម្យក្នុងការស៊ើបអង្កេតទៅលើការជួញដូរឲ្យមានប្រសិទ្ធភាព |
| ២.១.១ | អង្គភាពឯកទេសត្រូវបានបង្កើតឡើងជារចនាសម្ព័ន្ធអចិន្ត្រៃយ៍នៅក្នុងភ្នាក់ងារអនុវត្តន៍ច្បាប់ពាក់ព័ន្ធ។ |
| ២.១.២ | អង្គភាពឯកទេសគឺជាអ្នកឆ្លើយតបបឋមនៃការស៊ើបអង្កេតប្រឆាំងការជួញដូរ នៅក្នុងរចនាសម្ព័ន្ធភ្នាក់ងារអនុវត្តន៍ច្បាប់។ ចំពោះអាណត្តិការងារពាក់ព័ន្ធ ជួយឲ្យដំណើរនូវគំរូណាមួយក្នុងចំណោមគំរូនៃការឆ្លើយតបឯកទេសទាំង ៣ ខាងក្រោម ដូចជា៖<br>• គំរូទី ១៖ អង្គភាពឯកទេសមានសិទ្ធិគតិយុត្តិផ្តាច់មុខ និងពេញលេញពីរដ្ឋាភិបាល (ហើយក្នុងករណីចាំបាច់) ដើម្បីធ្វើការស៊ើបអង្កេត ទៅលើការជួញដូរទាំងអស់ដែលបានធ្វើឡើងនៅក្នុងប្រទេស និងទទួលបានអំណាចប្រើប្រាស់គ្រប់គ្រាន់ក្នុងការស៊ើបអង្កេតទាំងក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ។<br>• គំរូទី ២៖ អង្គភាពឯកទេសទទួលបានអាណត្តិការងារ ដើម្បីបើកការស៊ើបអង្កេតជាក់លាក់ជាច្រើន ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀង ដែលគ្របដណ្តប់ទៅលើសំណុំរឿងផ្សេងៗ ដូចជា សំណុំរឿងពាក់ព័ន្ធនឹងកុមារ ឬសំណុំរឿងដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង/អំពើពុករលួយក្នុងវិស័យសាធារណៈ និងបំពេញតួនាទីបន្ថែមផ្នែកគ្រប់គ្រង និងទីប្រឹក្សាទៅលើការស៊ើបអង្កេតទៅលើការជួញដូរទាំងអស់ផ្សេងទៀតនៅក្នុងប្រទេស។<br>• គំរូទី ៣៖ អង្គភាពឯកទេសទទួលបានអាណត្តិការងារបំពេញមុខងារផ្នែកគ្រប់គ្រង និងផ្តល់ការប្រឹក្សាពាក់ព័ន្ធនឹងសំណុំរឿងជួញដូរទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេស តែមិនធ្វើការស៊ើបអង្កេតដោយខ្លួនឯងទេ។ |
| ២.១.៣ | ចំពោះករណីដែលមិនយកតាមគំរូណាមួយដែលបានជ្រើសរើស អង្គភាពឯកទេសមានកាតព្វកិច្ច ផ្តល់ការឆ្លើយតបឯកទេសទៅលើតែសំណុំរឿងជួញដូរប៉ុណ្ណោះ ហើយមិនទទួលខុសត្រូវចំពោះការស៊ើបអង្កេតនៃទម្រង់ណាផ្សេងទៀត នៃការស៊ើបអង្កេតឡើយ។ |
| ២.១.៤ | ប្រសិនបើជម្រើសដែលបានជ្រើសរើសសម្រាប់ការឆ្លើយតបជំនាញជាតួនាទីផ្នែកគ្រប់គ្រងសម្រាប់អង្គភាពឯកទេស ដូចបានលើកឡើងនៅក្នុងគំរូទី ២ និង ទី ៣ ខាងលើ ពេលនោះអំណាចរបស់អង្គភាពឯកទេស គឺគ្រប់គ្រងដំណើរការស៊ើបអង្កេតទៅលើការជួញដូរ ដែលធ្វើឡើងដោយអង្គភាពអនុវត្តន៍ច្បាប់ដែលមិនឯកទេស ដែលគួរទទួលបានអាណត្តិការងារនេះ ហើយមិនត្រឹមតែជាទីប្រឹក្សានោះទេ។ |
| ២.១.៥ | ចំពោះករណីដែលមិនយកតាមគំរូណាមួយដែលបានជ្រើសរើស អាណត្តិការងាររបស់អង្គភាពឯកទេសតម្រូវឲ្យភ្នាក់ងារអនុវត្តន៍ច្បាប់ទាំងអស់ត្រូវ ជូនដំណឹងឲ្យបានទាន់ពេលវេលាដល់អង្គភាពឯកទេសនូវការចោទប្រកាន់ការជួញដូរទាំងអស់ ដែលបានរាយការណ៍នៅក្នុងប្រទេស និងចែករំលែកនូវព័ត៌មានសម្ងាត់ផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធ ស្តីពីបទល្មើសជួញដូរ។ |
| ២.២ | អង្គភាពឯកទេសផ្តល់នូវការឆ្លើយតបតាមរយៈការស៊ើបអង្កេតឯកទេសនៅទូទាំងប្រទេស |
| ២.២.១ | អង្គភាពឯកទេសផ្តល់នូវការឆ្លើយតបតាមវិធីមួយក្នុងចំណោមវិធីទាំង ៣ ដែលបានលើកឡើងនៅក្នុងចំណុច ២.១.២ ខាងលើ។ |

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| ២.២.២ | ទាក់ទងនឹងគំរូទាំងបីខាងលើ ត្រូវមាននីតិវិធីក្នុងការយកមកអនុវត្តដើម្បីធានាឲ្យមានការពិគ្រោះយោបល់ជាទៀងទាត់រវាងអង្គភាពឯកទេស និងដៃគូថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន និង មន្ត្រីដែលមិនមែនជានគរបាលយុត្តិធម៌ រួមមានដូចជា បុគ្គលិកគាំទ្រជនរងគ្រោះ មន្ត្រីអធិការកិច្ចការងារ មន្ត្រីទិដ្ឋការ និងមន្ត្រីផ្នែកកុងស៊ុល ដើម្បីធានាថាការឆ្លើយតបរបស់អង្គភាពឯកទេស បានឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ |
| ២.៣ | អង្គភាពឯកទេសត្រូវមានថវិកាគ្រប់គ្រាន់ និងជាបន្តបន្ទាប់ |
| ២.៣.១ | អង្គភាពឯកទេសត្រូវដាក់បញ្ចូលគម្រោងថវិការជាក់លាក់ ក្នុងការកំណត់ថវិកាប្រចាំឆ្នាំ ដែលត្រូវធ្វើការបែងចែកថវិកានេះដាច់ដោយឡែក។ |
| ២.៣.២ | ការបែងចែកថវិកាសម្រាប់អង្គភាពឯកទេសត្រូវឲ្យស្របនឹងអាណត្តិការងារ និងការទទួលខុសត្រូវ និងបន្ទុកការងាររបស់ខ្លួន។ |
| ២.៣.៣ | ការបែងចែកថវិកាផ្តល់នូវធនធានហិរញ្ញវត្ថុ មនុស្ស និងបច្ចេកទេសដើម្បីបំពេញការងារដូចខាងក្រោម៖<br>• ការចាត់តាំងការងារ និងប្រាក់បំណាច់របស់បុគ្គលដែលមានជំនាញគ្រប់គ្រាន់ ចំពោះបន្ទុកការងារដែលបានរាយការណ៍ និងការប៉ាន់ស្មាន។ និង<br>• ធនធានគ្រប់គ្រាន់ដើម្បីធ្វើការ ស៊ើបអង្កេត ទៅលើការជួញដូរទាំងក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ។ |
| ២.៤ | អង្គភាពឯកទេសប្រតិបត្តិការនៅក្នុងបទដ្ឋាននីតិវិធីប្រតិបត្តិការទូលំទូលាយដែលស្របទៅនឹងបទដ្ឋានអន្តរជាតិ |
| ២.៤.១ | អង្គភាពឯកទេសត្រូវធ្វើការនៅក្នុងបទដ្ឋាននីតិវិធីប្រតិបត្តិការទូលំទូលាយ ដែលស្របទៅនឹងបទដ្ឋានអន្តរជាតិ ស្របទៅនឹងច្បាប់របស់ប្រទេស និងស្ថិតក្រោមការត្រួតពិនិត្យរបស់ស្ថាប័នតុលាការ។ ភាពស្របទៅនឹងការណែនាំដែលមាននៅក្នុងបទដ្ឋាននីតិវិធីប្រតិបត្តិការ ត្រូវបានកំណត់ជាកាតព្វកិច្ច ហើយអង្គភាពឯកទេសត្រូវធានាថា ការអនុវត្តន៍ទៅតាមនីតិវិធីដូចៗគ្នា ទាក់ទងនឹងការស៊ើបអង្កេតនានាដែលធ្វើឡើងដោយបុគ្គលក្នុងអង្គភាពមិនមែនឯកទេស ដោយក្នុងនោះអង្គភាពឯកទេសដើរតួនាទីជាអ្នកគ្រប់គ្រងលើការអនុវត្តការងារនេះ។ ក្នុងកម្រិតអប្បបរមា នីតិវិធីទាំងនេះគួរគ្របដណ្តប់ទៅលើប្រធានបទនានាដូចខាងក្រោម៖ |
| ២.៤.១.១ | ការធ្វើផែនការ និងការគ្រប់គ្រងការស៊ើបអង្កេត៖ បទដ្ឋាននីតិវិធីប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជាអប្បបរមានូវចំណុចមួយចំនួនដូចខាងក្រោម៖<br>• ការធ្វើផែនការស៊ើបអង្កេត៖ ការធ្វើសេចក្តីព្រាង និងការអនុវត្តន៍ផែនការស៊ើបអង្កេតលម្អិតសម្រាប់ការស៊ើបអង្កេតក្រោយពេលកើតហេតុ និងមុនពេលកើតហេតុ ត្រូវមាននៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ រួមទាំង ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដំណាលគ្នា និងស្របគ្នាផងដែរ។<br>• កិច្ចសហប្រតិបត្តិការ រវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា៖ ត្រូវមានបែបបទក្នុងការជូនដំណឹងជាមុនចំពោះព្រះរាជអាជ្ញានៅពេលចាប់ផ្តើមការស៊ើបអង្កេតទៅលើការជួញដូរទាំងអស់ និងវិធានការកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធនាពេលបន្តបន្ទាប់ទៀត។<br>• ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ៖ ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យនានា ទាក់ទងនឹងទម្រង់ទាំងអស់ នៃការស៊ើបអង្កេតទៅលើការជួញដូរ។ |

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| | • នីតិវិធីនៃការចាប់ខ្លួន ការឆែកឆេរ និងការចាប់យក ដែលគ្របដណ្តប់ទៅលើ៖ (១) ការយកជនរងគ្រោះដោយស្របច្បាប់ និងមានសុវត្ថិភាពចេញពីគ្រោះថ្នាក់ (២) ការចាប់ខ្លួនជនសង្ស័យដោយតាមស្របច្បាប់ និងមានសុវត្ថិភាព (៣) ការចាប់យកដោយស្របច្បាប់នូវសម្ភារភស្តុតាងទាំងអស់ដែលពាក់ព័ន្ធនិងបទល្មើស។<br>• ត្រូវចាំបាច់អនុលោមស្របទៅនឹងសិទ្ធិរបស់ជនដែលត្រូវបានចាប់ខ្លួន៖ សិទ្ធិទាក់ទងនឹងនីត្យានុកូលភាពអង្គហេតុ និងមូលដ្ឋានសម្រាប់ចាប់ខ្លួន សិទ្ធិនៅស្ងៀម និងមានមេធាវី និង សិទ្ធិទាក់ទងនឹងការស្រាវជ្រាវរកទ្រព្យសម្បត្តិ។<br>• ប្រព័ន្ធគ្រប់គ្រងសំណុំរឿង៖ ការផ្តល់សំណុំរឿងជាសម្ងាត់ ទូលំទូលាយ និងមានការទទួលខុសត្រូវ ដោយរៀបរាប់លម្អិតអំពើសកម្មភាពស៊ើបអង្កេតទាំងអស់ដែលឲ្យមានការត្រួតពិនិត្យពីតុលាការថាសមស្រប។ និង<br>• នីតិវិធីប្រាស្រ័យទាក់ទងការងារផ្ទៃក្នុង និងជាអន្តរជាតិ៖ រាល់ការប្រាស្រ័យទាក់ទងការងារផ្ទៃក្នុង និងឆ្លងដែនទាំងអស់ ត្រូវតែធ្វើឡើងស្របច្បាប់ ត្រឹមត្រូវ មានសុវត្ថិភាព មានការទទួលខុសត្រូវ និងមានការគ្រប់គ្រង។ |
| ២.៤.១.២ | ការស៊ើបអង្កេតក្រោយពេលកើតហេតុ៖ បទដ្ឋាននីតិវិធីប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាជាអប្បបរមានូវចំណុចនានាដូចខាងក្រោម៖<br>• ដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនជនរងគ្រោះទៅផ្នែកពាក់ព័ន្ធ៖ ដែលរួមមានជាអប្បបរមាគឺការវាយតម្លៃរួមគ្នាទៅលើសូចនាករនៃការជួញដូរ និងការឆ្លើយតបរបស់មនុស្សម្នាក់ក្នុងពេលសម្ភាសន៍ នៅពេលវាយតម្លៃថាតើ ជននោះជាជនរងគ្រោះនៃការជួញដូរ ឬយ៉ាងណា និងស្របទៅនឹងច្បាប់ជាតិ សិទ្ធិទទួលបានពេលវេលាក្នុងការវិលត្រឡប់ទៅរកសភាពដើម និងការពិចារណាឡើងវិញ។<br>• ការការពារ និងគាំទ្រជនរងគ្រោះ ដែលរួមមាន ដូចជាការរៀបចំភ្នាក់ងារជាច្រើន ដើម្បីសម្របសម្រួលដល់ការបញ្ជូនជនរងគ្រោះជាជនជាតិរបស់ខ្លួន ឬជនបរទេសឱ្យបានវិលត្រឡប់ទៅប្រទេសខ្លួនវិញដោយសុវត្ថិភាព ដោយមិនគិតអំពីថាតើ ពួកគេជ្រើសរើសសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬអត់ រួមនឹងការគាំទ្រដល់ការទទួលបានទិដ្ឋាការសមរម្យ ដើម្បីជួយដល់ជនរងគ្រោះដែលសហការ និងមិនសហការ ដើម្បីបានស្នាក់នៅក្នុងប្រទេសដែលប្រព្រឹត្តបទល្មើសក្នុងករណីដែលហានិភ័យ នៃការធ្វើមាតុភូមិនិវត្តន៍មិនអាចគ្រប់គ្រងបាន។<br>• សិទ្ធិរបស់ជនរងគ្រោះ និងជំនួយដល់ជនរងគ្រោះ ត្រូវធានានូវការឆ្លើយតបភ្លាមៗទៅនឹងបញ្ហាបន្ទាន់ផ្នែកសុខភាព ព័ត៌មានបានទាន់ពេលវេលាស្តីពីសិទ្ធិ និងការទទួលខុសត្រូវ និង ព័ត៌មាន និងការទទួលបានវិធានការជំនួយដែលមាន។<br>• ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ ដោយផ្តល់អាទិភាពដល់ជនរងគ្រោះ ៣ ប្រភេទគឺ៖ (១) ជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះ ឬដែលបានគេចខ្លួន (២) អ្នកដែលស្ថិតក្នុងស្ថានភាពកេងប្រវ័ញ្ច (៣) ជនដែលប្រឈមនឹងហានិភ័យភ្លាមៗនៃការទទួលរងការជួញដូរទៅក្នុងស្ថានភាពកេងប្រវ័ញ្ច។<br>• ការស្តាប់ចម្លើយសាក្សីជាជនរងគ្រោះ ដោយប្រើប្រាស់វិធីសាស្ត្រនៃភ្នាក់ងារច្រើនដែលអាចធ្វើបាន និងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ “មិនបង្កព្យសនកម្ម”។ |

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| | • ការការពារជាក់ស្តែងដល់សាក្សីជាជនរងគ្រោះ ដោយធានាផ្តល់នូវព័ត៌មានត្រឹមត្រូវ និងទទួលបានវិធានការការពារដែលមាន ដោយមានការព្រមព្រៀងពីជនរងគ្រោះ និងការវាយតម្លៃហានិភ័យ ទាំងនៅមុនពេលជំនុំជម្រះ ក្នុងពេលជំនុំជម្រះ និងក្រោយពេលជំនុំជម្រះទៅលើសំណុំរឿង។ និង<br>• ការការពារពីតុលាការដល់សាក្សីជាជនរងគ្រោះ ដោយពិភាក្សាយ៉ាងល្អិតល្អន់ជាមួយព្រះរាជអាជ្ញា ដោយធានារក្សាការសម្ងាត់នៃអត្តសញ្ញាណក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីទាំងមូល ការអនុវត្តន៍នូវវិធានការរៀបចំការជំនុំជម្រះ និងការទទួលបានជម្រើសនៃការផ្តល់សក្ខីកម្មគាំទ្រដល់សាក្សីដែលមាន។ |
| ២.៤.១.៣ | ការស៊ើបអង្កេតមុនពេលកើតហេតុ៖ បទដ្ឋាននីតិវិធីប្រតិបត្តិការ ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជាអប្បបរមានូវចំណុចនានាដូចខាងក្រោម៖<br>• ការប្រមូល និងការគ្រប់គ្រងព័ត៌មានសម្ងាត់៖ ការប្រមូលឲ្យបានត្រឹមត្រូវ និងមានការទទួលខុសត្រូវ ការវាយតម្លៃ និងការគ្រប់គ្រងរាល់សម្ភារនៃព័ត៌មានសម្ងាត់ទាំងអស់។<br>• ប្រតិបត្តិការឃ្លាំមើលដោយប្រើមនុស្ស និងបច្ចេកទេស៖ រាល់សកម្មភាពឃ្លាំមើលទាំងអស់ត្រូវតែស្របច្បាប់ ជាចាំបាច់ និងមានសមាមាត្រ មានការកត់ត្រា និងគ្រប់គ្រង និងស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ និងត្រូវពិចារណាដល់បញ្ហាសន្តិសុខជាចម្បង។<br>• ប្រតិបត្តិការបង្កប់ខ្លួន និងការទិញសាកល្បង៖ ការប្រើប្រាស់វិធីសាស្ត្រទាំងនេះត្រូវតែស្របច្បាប់ជាចាំបាច់ និងមានសមាមាត្រ មានកំណត់ត្រា ការគ្រប់គ្រង និងស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការជាចាំបាច់ ដែលត្រូវធានា និងការពារដល់អត្តសញ្ញាណរបស់មន្ត្រីដែលបង្កប់ខ្លួន។ និង<br>• ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដំណាលគ្នា និងស្របគ្នា៖ ចាំបាច់ផ្តោតទៅលើការអនុវត្តន៍នៃអំណាចស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុស្របច្បាប់ និងមានការគ្រប់គ្រង និងស្វែងរកទ្រព្យ រួមទាំងវតម្រូវឱ្យមាន ដីការឹបអូស និងដីកាស្តីពីការបាត់បង់សិទ្ធិគ្រប់គ្រងលើមធ្យោបាយនៃបទល្មើសនៅក្នុងសំណុំរឿងទាំងអស់ដែលសមស្រប ក្នុងអំឡុងពេលស៊ើបអង្កេតទាំងមូល។ |
| ២.៤.១.៤ | ប្រប្រព្រឹត្តិកម្មចំពោះកុមាររងគ្រោះ៖ បទដ្ឋាននីតិវិធីប្រតិបត្តិការត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជាអប្បបរមានូវចំណុចនានាដូចខាងក្រោម៖<br>• យុទ្ធសាស្ត្រដើម្បីដោះស្រាយភាពរងគ្រោះពិសេស និងសេចក្តីត្រូវការរបស់កុមាររងគ្រោះ។<br>• ដំណើរការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ជាពិសេស ការសន្មត់ពីអាយុ និងឋានៈជាជនរងគ្រោះ។<br>• ការវាយតម្លៃដែលធ្វើឡើងដោយភ្នាក់ងារផ្សេងៗទៅលើកុមាររងគ្រោះ និងត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ "ឧត្តមប្រយោជន៍" ទាក់ទងនឹងសកម្មភាព និងសេចក្តីសម្រេចចិត្តទាំងអស់ដែលមានឥទ្ធិពលលើកុមារ។<br>• អនុវត្តយ៉ាងតឹងរ៉ឹងនូវនីតិវិធីដែលមានស្រាប់ ពាក់ព័ន្ធនឹងការចាត់តាំងអាព្យាបាល បណ្តោះអាសន្នសម្រាប់កុមាររងគ្រោះនៅក្នុងករណីដែលអាចធ្វើបាន។<br>• បែបបទ និងនីតិវិធីសម្រាប់ស្តាប់ចម្លើយសាក្សីជាកុមាររងគ្រោះ។ និង<br>• វិធានការសុវត្ថិភាព និងគាំទ្រដល់កុមាររងគ្រោះ។ |

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| ២.៤.២ | ក្នុងការបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការ អង្គភាពឯកទេសកំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃសកម្មភាពពុករលួយ និងការសមគំនិត និងធានាថា បទដ្ឋាននីតិវិធីប្រតិបត្តិការមានបញ្ចូលយន្តការដើម្បីកំណត់អត្តសញ្ញាណ វាយតម្លៃ និងកាត់បន្ថយហានិភ័យ។ |
| ២.៤.៣ | បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ការស៊ើបអង្កេតក្រោយពេលកើតហេតុ រួមមាន កិច្ចព្រមព្រៀងសហប្រតិបត្តិការជាលាយលក្ខណ៍អក្សរជាមួយភ្នាក់ងារគាំទ្រជនរងគ្រោះដែលពាក់ព័ន្ធ ស្តីពីការប្រព្រឹត្តិចំពោះជនរងគ្រោះ សាក្សីជាជនរងគ្រោះ និង ការចែករំលែកព័ត៌មាន។ |
| ២.៤.៤ | ការអនុវត្តន៍បទដ្ឋាននីតិវិធីប្រតិបត្តិការត្រូវបានគ្រប់គ្រង និងស្ថិតក្រោមការតាមដាន។ សុពលភាពនៃបទដ្ឋាននីតិវិធីប្រតិបត្តិការ និងប្រសិទ្ធភាពនៃការអនុវត្តន៍បទដ្ឋានទាំងនេះត្រូវយកមកពិនិត្យជាប្រចាំ។ |
| ២.៥ | អង្គភាពឯកទេសមានសមត្ថភាពពេញលេញទាក់ទងនឹង ចំណេះដឹង និងជំនាញបច្ចេកទេស ដើម្បីអនុវត្តបទដ្ឋាននីតិវិធីប្រតិបត្តិការ និងធ្វើការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព |
| ២.៥.១ | ការបណ្តុះបណ្តាល ជំនាញ យេនឌ័រ និងប្រវត្តិរូបផ្នែកជាតិពន្ធុរបស់បុគ្គលិកអង្គភាពឯកទេសផ្តល់នូវសមត្ថភាពក្នុងការអនុវត្តនូវបច្ចេកទេសស៊ើបអង្កេតឯកទេសដូចខាងក្រោម៖ |
| ២.៥.២ | ការធ្វើផែនការ និងការគ្រប់គ្រងស៊ើបអង្កេត៖ អង្គភាពឯកទេសមានសមត្ថភាពពេញលេញដើម្បីអនុវត្តនូវបច្ចេកទេសស៊ើបអង្កេតដូចខាងក្រោម៖<br>• រៀបចំសេចក្តីព្រាង និងអនុវត្តផែនការស៊ើបអង្កេតក្នុងស្រុក និងឆ្លងដែន។<br>• រៀបចំសេចក្តីព្រាង និងអនុវត្តការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុស្របគ្នា។<br>• នីតិវិធីនៃការចាប់ខ្លួន និង ការស្រាវជ្រាវ និងរឹបអូស។<br>• ការអនុវត្តន៍ស្របនឹងសិទ្ធិរបស់ជនសង្ស័យ។<br>• ការគ្រប់គ្រងសំណុំរឿង។<br>• នីតិវិធីប្រាស្រ័យទាក់ទងការងារផ្ទៃក្នុង និងអន្តរជាតិ។<br>• ការប្រាស្រ័យទាក់ទងការងារ និងការសម្របសម្រួលជាមួយភ្នាក់ងារគាំទ្រជនរងគ្រោះ។ និង<br>• ការប្រាស្រ័យទាក់ទងការងារ និងការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដូចជា អធិការកិច្ចការងារ អន្តោប្រវេសន៍ និងអាជ្ញាធរព្រំដែន អ្នកជំនាញវិជ្ជាជីវៈសុខាភិបាល ។ល។ |
| ២.៥.៣ | ការស៊ើបអង្កេតក្រោយពេលកើតហេតុ៖ អង្គភាពឯកទេសមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តបច្ចេកទេសស៊ើបអង្កេតដូចខាងក្រោម៖<br>• នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ រួមមាន ការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និង សិទ្ធិទទួលបានពេលវេលាក្នុងការវិលត្រឡប់ទៅរកសភាពដើម និងការពិនិត្យមើលការអនុវត្តការងារឡើងវិញ។<br>• សិទ្ធិរបស់ជនរងគ្រោះ ការមិនរើសអើង និងជំនួយដល់ជនរងគ្រោះ ជាពិសេស ការទទួលបានសំណង។<br>• ការវាយតម្លៃហានិភ័យ និង ការគ្រប់គ្រងហានិភ័យ។<br>• ការស្តាប់ចម្លើយសាក្សីជាជនរងគ្រោះដើម្បីប្រមូលភស្តុតាង និងមានក្រមសីលធម៌។<br>• ការកំណត់អត្តសញ្ញាណ និងការស្វែងរកភស្តុតាងស៊ីចង្វាក់គ្នា។ |

| ជំពូកទី ២៖ សមត្ថភាពផ្នែកអនុវត្តន៍ច្បាប់ជំនាញដើម្បីស៊ើបអង្កេតទៅលើការជួញដូរ | |
|---|---|
| | • ការគ្រប់គ្រងជនរងគ្រោះដែលធ្វើជាសាក្សី។ និង<br>• វិធានការការពារសាក្សីជាជនរងគ្រោះ (តាមការអនុវត្តជាក់ស្តែង និងតាមផ្លូវតុលាការ) និងការគាំទ្រ។ |
| ២.៥.៤ | ការស៊ើបអង្កេតមុនពេលកើតហេតុ៖ អង្គភាពឯកទេសមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តបច្ចេកទេសស៊ើបអង្កេតដូចខាងក្រោម៖<br>• ប្រតិបត្តិការឃ្លាំមើលដោយប្រើមនុស្ស និងបច្ចេកទេស។<br>• ប្រតិបត្តិការបង្កប់ខ្លួន និងទិញសាកល្បង។<br>• ធ្វើការស៊ើបអង្កេតទៅលើការសម្អាតប្រាក់។<br>• ការប្រមូល ការវាយតម្លៃ និងការផ្សព្វផ្សាយព័ត៌មានសម្ងាត់នៃការជួញដូរ។ និង<br>• ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដំណាលគ្នា និងស្របគ្នា។ |
| ២.៥.៥ | កុមាររងគ្រោះ៖ អង្គភាពឯកទេសមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តបច្ចេកទេសស៊ើបអង្កេតដូចខាងក្រោម៖<br>• ភាពងាយរងគ្រោះពិសេស និងតម្រូវការចាំបាច់របស់កុមាររងគ្រោះ។<br>• ដំណើរការកំណត់អត្តសញ្ញាណ និងបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ជាពិសេស ការសន្មតពីអាយុ និងឋានៈជាជនរងគ្រោះ។<br>• ការវាយតម្លៃផ្សេងៗទៅលើកុមាររងគ្រោះដោយភ្នាក់ងារមួយចំនួន និងត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ "ឧត្តមប្រយោជន៍"។<br>• សិទ្ធិកុមារ និងអាណាព្យាបាលបណ្តោះអាសន្ន។<br>• ការស្តាប់ចម្លើយកុមាររងគ្រោះធ្វើជាសាក្សី រួមទាំង ភស្តុតាងដែលថតជាវីដេអូផង។<br>• វិធានការសុវត្ថិភាព និងការគាំទ្រដល់កុមាររងគ្រោះ។ និង<br>• ជម្រើសផ្តល់សក្ខីកម្ម និងវិធានការការពារតាមផ្លូវតុលាការផ្សេងទៀតសម្រាប់កុមារ។ |

# ជំពូកទី ៣៖ សមត្ថភាពអនុវត្តន៍ច្បាប់ជួរមុខដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព

នៅក្នុងបរិបទនៃការជួញដូរមនុស្ស ពាក្យថា “ការអនុវត្តន៍ច្បាប់ជួរមុខ” ជាគោលការណ៍ សំដៅដល់ទីភ្នាក់ងារ និងមន្ត្រីនគរបាលមិនមែនជំនាញ ដែលអាចជួបប្រទះ និង/ឬ ត្រូវបានកោះហៅឲ្យទៅធ្វើការឆ្លើយតបទៅនឹងសំណុំរឿងជួញដូរមនុស្ស នៅពេលពួកគេកំពុងបំពេញភារកិច្ចជាធម្មតា។ ពាក្យនេះរួមបញ្ចូលទាំងទីភ្នាក់ងារ និងមន្ត្រីការពារព្រំដែន និងមន្ត្រីផ្នែកអន្តោប្រវេសន៍ ហើយក៏អាចពង្រីកទៅដល់ទីភ្នាក់ងារ និងមន្ត្រីដែលទទួលបន្ទុកតាមដានការអនុវត្តន៍ទៅតាមច្បាប់ការងារ វិស័យនេសាទ។ល។

ភ្នាក់ងារ និងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខមានសារៈសំខាន់ ចំពោះប្រសិទ្ធភាពនៃការឆ្លើយតបជារួមទៅនឹងបទល្មើសជួញដូរ ដោយដើរតួនាទីចម្បងក្នុងការកំណត់អត្តសញ្ញាណបទល្មើស និងផ្តល់ការឆ្លើយតបបឋមឲ្យបានពេញលេញ។ នៅគ្រប់ប្រទេសទាំងអស់ ពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងផ្តល់នូវការឆ្លើយតបមុនគេបំផុតយ៉ាងពេញលេញ លើបទល្មើសជួញដូរ។ នៅក្នុងប្រទេសដែលពុំមានសមត្ថភាពជំនាញ គឺមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខជាអ្នកទទួលខុសត្រូវក្នុងការធានាថា បទល្មើសជួញដូរមនុស្សត្រូវបានស៊ើបអង្កេតឲ្យពេញលេញ និងទាន់ពេលវេលា។ នៅពេលមានអ្នកស៊ើបអង្កេតឯកទេសលើការជួញដូរមនុស្ស មន្ត្រីរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខនឹងដើរតួនាទីគាំទ្រយ៉ាងសំខាន់។ សរុបមក នៅក្នុងបរិបទជួញដូរមនុស្ស សេចក្តីត្រូវការឲ្យមានធាតុផ្សំផ្នែកអនុវត្តន៍ច្បាប់ជួរមុខចំពោះការឆ្លើយតបបទល្មើស ដែលមិនអាចខ្វះបាន។

## ៣.១ សារៈសំខាន់ នៃការឆ្លើយតបជួរមុខយ៉ាងមានប្រសិទ្ធភាព

បទពិសោធន៍នៃសំណុំរឿងពីជុំវិញពិភពលោកបានបញ្ជាក់ថា សូម្បីតែនៅក្នុងបណ្តាប្រទេសដែលបានបង្កើតអង្គភាពឯកទេសហើយក៏ដោយ ក៏សំណុំរឿងជួញដូរជាច្រើន ត្រូវបានយកចិត្តទុកដាក់ និងអនុវត្តមុនគេដល់មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខដែរ មិនថា ពួកគេជានគរបាល មន្ត្រីការពារព្រំដែន ឬមន្ត្រីអន្តោប្រវេសន៍ ឬ មន្ត្រីគយ ឬអធិការការងារទេ។ ហេតុនេះ គឺមន្ត្រីទាំងនេះដែលជារឿយៗត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងពេលវេលាសំខាន់ៗជាមុន ចំពោះការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស រហូតទាល់តែអ្នកស៊ើបអង្កេតឯកទេសចូលមកកាន់សំណុំរឿងបន្ត។ ចំណុចទាំងនេះពាក់ព័ន្ធនឹងកាតព្វកិច្ចចម្បងៗដូចជា ការកំណត់ទីកន្លែង ការកំណត់អត្តសញ្ញាណ និងការយកជនរងគ្រោះចេញពីគ្រោះថ្នាក់ ការកំណត់ទីកន្លែង និងការចាប់ខ្លួនជនសង្ស័យ និងការធានានូវការកំណត់អត្តសញ្ញាណ និងការចាប់យក

ភស្តុតាងដែលមានតម្លៃ។ នៅក្នុងវិស័យស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ សកម្មភាពដែលត្រូវធ្វើក្នុងរយៈពេល ២៤ ម៉ោង ក្រោយពេលរកឃើញបទល្មើសនឹងមានឥទ្ធិពលយ៉ាងធំធេងទៅលើភាពជោគជ័យនៃការស៊ើបអង្កេត។

នៅក្នុងប្រទេស និងស្ថានភាពមួយចំនួន ទីភ្នាក់ងារ និងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ ក៏អាចតម្រូវឲ្យទទួលខុសត្រូវពេញលេញចំពោះការស៊ើបអង្កេតទៅលើការជួញដូរដែរ។ ចំណុចនេះកើតឡើងនៅពេលពុំមានសមត្ថភាពឆ្លើយតបឯកទេសនៅក្នុងប្រទេសណាមួយ។ វាក៏អាចកើតឡើងនៅក្នុងស្ថានភាពដែលអង្គភាពឆ្លើយតបជំនាញពុំមានអាណត្តិការងារ ការគ្របដណ្តប់ទៅលើភូមិសាស្ត្រ ឬធនធានដើម្បីស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរទាំងអស់។

វាក៏ជាការសំខាន់ផងដែរដែលទទួលស្គាល់ថា ជារឿយៗ ទីភ្នាក់ងារ និងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខត្រូវបានដាក់ជាពិសេស ដើម្បីចែករំលែកយ៉ាងសំខាន់ដល់ការប្រមូលព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ។ ជារឿយៗ ការជួញដូរត្រូវបានលាក់បាំង ក៏ប៉ុន្តែ ទម្រង់ផ្សេងទៀតនៃការជួញដូរអាចមើលឃើញច្បាស់ជាង ដោយកើតឡើងនៅក្នុងវិស័យឧស្សាហកម្ម និងសហគមន៍ដែលមានរៀបចំត្រឹមត្រូវ។ សកម្មភាពរបស់ជនជួញដូរ និងជនរងគ្រោះអាចត្រូវបានមើលឃើញ និងនិយាយក្នុងចំណោះសហគមន៍មូលដ្ឋាន។ មន្ត្រីជួរមុខ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសហគមន៍អាចស្ថិតក្នុងចំណុចប្រសើរជាសហការីជំនាញរបស់ខ្លួន ក្នុងការធានាបាននូវព័ត៌មានសំខាន់អំពីស្ថានភាពជាក់លាក់ និងធ្វើការឆ្លើយសមស្រប និងមានប្រសិទ្ធភាព។

## ៣.២ ធាតុផ្សំសំខាន់ៗនៃការឆ្លើយតបជួរមុខយ៉ាងមានប្រសិទ្ធភាព

នាពេលនេះ មានការព្រមព្រៀងយ៉ាងទូលំទូលាយដែលមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ *ទាំងអស់* នៅក្នុងប្រទេស *ទាំងអស់* យ៉ាងហោចណាស់ពួកគេតម្រូវឲ្យមានចំណេះដឹងមូលដ្ឋាននៃការជួញដូរមនុស្ស និងការណែនាំមួយចំនួនពាក់ព័ន្ធនឹងរបៀបទទួលស្គាល់ និងឆ្លើយតបទៅនឹងរឿងនោះ។

បទពិសោធន៍ប្រតិបត្តិការទូលំទូលាយបានគូសបញ្ជាក់នូវចំណុចនានាដូចខាងក្រោម ជាការសំខាន់ទៅនឹងការឆ្លើយតបនៃការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខយ៉ាងមានប្រសិទ្ធភាព៖

- បទដ្ឋាននីតិវិធីប្រតិបត្តិការច្បាស់លាស់ដែលផ្តល់នូវការណែនាំជាជំហានៗទាក់ទងនឹងការទទួលខុសត្រូវស៊ើបអង្កេតរបស់ពួកគេ
- សមត្ថភាពប្រើប្រាស់នីតិវិធីទាំងនេះដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និងស្របទៅនឹងការទទួលខុសត្រូវស៊ើបអង្កេតពីដំបូងរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព
- សមត្ថភាពប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់
- ការបណ្តុះបណ្តាលគ្រប់គ្រាន់ ចំគោលដៅ និងស្របនឹងតួនាទី។

ធាតុផ្សំទាំងនេះមានទំនាក់ទំនងរវាងគ្នានឹងគ្នា និងឯករាជ្យ ហើយចំណុចទាំង ៤ ត្រូវតែដោះស្រាយ ប្រសិនបើធាតុផ្សំនៃការអនុវត្តន៍ច្បាប់នៃការឆ្លើយតប គឺត្រូវគាំទ្រអង្គភាពឯកទេស និងមានប្រសិទ្ធភាពសមស្របទៅតាមសិទ្ធិរបស់ខ្លួន។ ចំណុចនីមួយៗនឹងលើកយកមកពិចារណាលម្អិតដូចខាងក្រោម។

## បទដ្ឋាននីតិវិធីប្រតិបត្តិការ

ជំពូកមុនបានពន្យល់អំពីសារៈសំខាន់ របស់បទដ្ឋាននីតិវិធីប្រតិបត្តិការចំពោះការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ឯកទេសទៅនឹងការជួញដូរ។ ចំណុចនេះក៏ជាការពិតដែរចំពោះការឆ្លើយតបជួរមុខ។ បទដ្ឋាននីតិវិធីប្រតិបត្តិការលើការជួញដូរជាក់លាក់គឺជាមូលដ្ឋានគ្រឹះដែលត្រូវស្ថាបនាសមត្ថភាពជួរមុខ និងការបំពេញការងារយ៉ាងមានប្រសិទ្ធភាព។ វាជាការសំខាន់ដែលថា បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់មន្ត្រី និងភ្នាក់ងារជួរមុខត្រូវស៊ីចង្វាក់ និងបន្ថែមទៅលើនីតិវិធីជាធរមានផ្នែកឯកទេសរបស់អង្គភាពឯកទេស។ ហេតុនេះ នៅពេលមានអង្គភាពឯកទេសប្រឆាំងការជួញដូរ បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ការឆ្លើយតបជួរមុខគួរតែត្រូវបានបង្កើតឡើង ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពឯកទេស។

បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ទីភ្នាក់ងារ និងមន្ត្រីជំនាញត្រូវដោះស្រាយនូវហានិភ័យជាក់ស្តែងដោយសារអំពើពុករលួយ និងការបំពានអំណាចនៅក្នុងវិស័យនេះ។ ចំណុចនេះនឹងតម្រូវឱ្យមានមិនត្រឹមតែការកំណត់អត្តសញ្ញាណ និងការវាយតម្លៃទៅលើលក្ខណៈ និងកម្រិតនៃអំពើពុករលួយ និងហានិភ័យផ្សេងទៀតទេ តែក៏ទៅលើភាពជាក់លាក់នៃយន្តការដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យទាំងនោះដែរ។ វចនាសម្ព័ន្ធដែលបានកំណត់ក៏ត្រូវតែពង្រឹងផងដែរ តាមរយៈរបៀបរបបគ្រប់គ្រងរឹងមាំ ដើម្បីធានាថា បទដ្ឋានដែលបានបង្កើតឡើងដើម្បីកាត់បន្ថយហានិភ័យដែលមានមកជាមួយ។ បទដ្ឋាននីតិវិធីប្រតិបត្តិការដែលគ្មានការគ្រប់គ្រង នឹងមិនសម្រេចបានទៅតាមគោលបំណងរបស់វាទេ។

## ការកសាងសមត្ថភាពមន្ត្រីជួរមុខ

អ្នកប្រតិបត្តិជួរមុខ ទោះបីពួកគេជាមន្ត្រីនគរបាល មន្ត្រីការពារព្រំដែន ឬមន្ត្រីអន្តោប្រវេសន៍ ឬអធិការការងារក៏ដោយ ពួកគេគួរមានចំណេះដឹង និងសមត្ថភាពក្នុងការអនុវត្តន៍កាតព្វកិច្ចស្នូលនៃការស៊ើបអង្កេតបឋមទាំង ៣ គឺ៖ (១) ការកំណត់ទីកន្លែង ការកំណត់អត្តសញ្ញាណ និងការយកជនរងគ្រោះចេញពីគ្រោះថ្នាក់ (២) ការកំណត់ទីកន្លែង និង (ដោយត្រូវបានផ្តល់អំណាច) ការចាប់ខ្លួនជនសង្ស័យ និង (៣) ការធានារកភស្តុតាងដែលពាក់ព័ន្ធ។ បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខគួរផ្តល់នូវការណែនាំផ្នែកនីតិវិធីលម្អិតទៅលើចំណុចនានាដូចខាងក្រោម៖

### នីតិវិធីពាក់ព័ន្ធនឹងជនរងគ្រោះ (សូមមើលបន្ថែម ជំពូកទី ៤)

- *វិធីសាស្ត្រនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ៖* វិធីសាស្ត្រទាំងនេះគួរតែត្រូវបានដឹកនាំ ដើម្បីធានាឱ្យបាននូវការកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរឱ្យបានរហ័ស និងត្រឹមត្រូវតាមដែលអាចធ្វើទៅបាន។ ការកំណត់អត្តសញ្ញាណជនរងគ្រោះ គួរផ្អែកទៅលើការវាយតម្លៃទៅព័ត៌មានទល់នឹងសូចនាករជួញដូរមនុស្សមួយចំនួន រួមជាមួយការវាយតម្លៃព័ត៌មានដែលជនរងគ្រោះបានផ្តល់ ក្នុងពេលស្តាប់ចម្លើយ (សូមមើលដ្យាក្រាមខាងក្រោម)។

- *នីតិវិធីបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ៖* នីតិវិធីទាំងនេះគួរត្រូវបានដឹកនាំ ដើម្បីធានាដល់សុវត្ថិភាពរបស់ជនរងគ្រោះ និងការទទួលបានការស្នាក់នៅបឋមដែលមានសុវត្ថិភាព ជំនួយ និងព័ត៌មានស្ដីពីសិទ្ធិតាមច្បាប់ តាមជម្រើស និងការទទួលខុសត្រូវ។
- *បញ្ហាជនរងគ្រោះ៖* បញ្ហាទាំងនេះគួរតែត្រូវបានដឹកនាំ ដើម្បីធានាថា មន្ត្រីជួរមុខមានការយល់ដឹងជាមូលដ្ឋានអំពីបទពិសោធន៍របស់ជនរងគ្រោះ ការប៉ះទង្គិចផ្លូវចិត្តពីព្រឹត្តិការណ៍ទាំងនេះ ឧបសគ្គក្នុងការប្រាស្រ័យទាក់ទងគ្នា ដែលអាចកើតមានឡើង និងឥទ្ធិពលនៃកត្តាទាំងនេះទៅលើឆន្ទៈរបស់ជនរងគ្រោះក្នុងការសហការ។ ចំណេះដឹងនេះជាការចាំបាច់សម្រាប់កាតព្វកិច្ចជួរមុខទាំងអស់ រួមទាំងការសម្ភាសន៍ជនរងគ្រោះ ឬអ្នកដែលគិតថាជាជនរងគ្រោះនៃការជួញដូរ។

## នីតិវិធីពាក់ព័ន្ធនឹងជនសង្ស័យ

- *ការកំណត់អត្តសញ្ញាណជនសង្ស័យ៖* ចំណុចនេះ គួរផ្អែកលើបណ្ដឹង/ភស្តុតាងពីជនរងគ្រោះ ឬសាក្សីផ្សេងទៀតដែលមានជាមូលដ្ឋានសម្រាប់ការសង្ស័យ *តាមការបញ្ជាក់ដំបូង*។
- *ប្រតិបត្តិការចាប់ខ្លួន និងចាប់យកវត្ថុ៖* ប្រតិបត្តិការទាំងនេះ គួរតែត្រូវបានណែនាំច្បាស់លាស់ ដើម្បីធានាដល់ការចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យទាំងអស់ដែលបានរកឃើញ និងទីកន្លែង និងការចាប់យកភស្តុតាងពាក់ព័ន្ធទាំងអស់តាមច្បាប់។
- *សិទ្ធិរបស់ជនសង្ស័យ៖* សិទ្ធិទាំងនេះ គួរតែត្រូវបានចង្អុលបង្ហាញឱ្យបានច្បាស់ ដើម្បីធានាថា សិទ្ធិទាំងអស់ទាក់ទងនឹងការចាប់ខ្លួន ការឆែកឆេរ ការសម្ភាសន៍ និងការឃុំខ្លួនត្រូវបានអនុវត្តតាមយ៉ាងពេញលេញ និងទាន់ពេលវេលា។

## នីតិវិធីពាក់ព័ន្ធនឹងភស្តុតាង

- *ការរក្សាទុកទីកន្លែងកើតហេតុ៖* ចំណុចទាំងនេះគួរតែត្រូវបានណែនាំត្រឹមត្រូវ ដើម្បីធានានូវការរក្សាទុកទីកន្លែងកើតហេតុ ដើម្បីជួយដល់ការពិនិត្យជាក់ស្ដែង កោសលវិច័យ និងរូបថត។
- *ការកំណត់អត្តសញ្ញាណ និងការចាប់យកភស្តុតាងមានតម្លៃ៖* ចំណុចទាំងនេះគួរតែត្រូវបានណែនាំ ដើម្បីធានាថា ភស្តុតាងមានតម្លៃត្រូវបានទទួលស្គាល់ និងធានាសុវត្ថិភាព។
- *ការជូនដំណឹងបានទាន់ពេលវេលាដល់អង្គភាពឯកទេសនូវសំណុំរឿងជួញដូរទាំងអស់៖* ចំណុចទាំងនេះគួរតែត្រូវបានណែនាំ ដើម្បីធានាថា ព័ត៌មានលម្អិតពាក់ព័ន្ធស្ដីពីការចោទប្រកាន់ពីការជួញដូរទាំងអស់ និងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើនោះ រួមជាមួយព័ត៌មានអំពីប្រតិបត្តិការត្រូវបានធ្វើឡើងទាន់ពេលវេលា និងបញ្ជូនយ៉ាងមានសុវត្ថិភាពទៅផ្នែកពាក់ព័ន្ធនៃអង្គភាពឯកទេស។

វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា នៅពេលដែលមន្ត្រីជួរមុខត្រូវ ឬអាចទទួលខុសត្រូវចំពោះដំណើរការស៊ើបអង្កេតទាំងមូល ការអភិវឌ្ឍន៍សមត្ថភាពត្រូវតែពង្រីក (បទដ្ឋាននីតិវិធីប្រតិបត្តិការពាក់ព័ន្ធក៏ត្រូវពង្រីកដែរ) ដើម្បីបញ្ចូលការស្ដាប់ចម្លើយសាក្សីជាជនរងគ្រោះ និងសួរចម្លើយជនរងគ្រោះដើម្បីប្រមូលភស្តុតាង ព្រមទាំងកាតព្វកិច្ចរបស់ខ្លួនផ្សេងទៀតក្នុងការស៊ើបអង្កេត។

## សមត្ថភាពប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់នៃការជួញដូរ

ដូចបានកត់សម្គាល់ខាងលើ មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខមានតួនាទីសំខាន់ក្នុងការប្រមូលព័ត៌មានសម្ងាត់ដើម្បីគាំទ្រដល់ការស៊ើបអង្កេតទៅលើការជួញដូរ ហើយក្នុងការផ្ទេរព័ត៌មានសម្ងាត់នៃការជួញដូរទៅឲ្យសហការីជំនាញរបស់ខ្លួននៅពេលមានសមត្ថភាពឯកទេស។ ចំណុចនេះនឹងកែលម្អយ៉ាងធំធេងទៅភាពស៊ីជម្រៅនៃចំណេះដឹង និងការយល់ដឹងរបស់អង្គភាពឯកទេសទៅនឹងស្ថានភាពជួញដូរ។ រូបភាពដែលផ្តល់ដោយព័ត៌មានសម្ងាត់ដែលមន្ត្រី អនុវត្តច្បាប់ជួរមុខប្រមូលបាន នឹងជួយដល់អង្គភាពឯកទេសក្នុងការកែលម្អយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងស្ថានភាពជួញដូរនៅមូលដ្ឋាន និងចុងក្រោយបង្កើនកម្រិតនៃការកម្រិតអត្តសញ្ញាណជនរងគ្រោះ និងជនកេងប្រវ័ញ្ច។

ដើម្បីបំពេញតួនាទីនេះឲ្យបានពេញលេញ មន្ត្រីជួរមុខត្រូវអភិវឌ្ឍសមត្ថភាពដើម្បីទទួលស្គាល់នូវសូចនាករនៃការជួញដូរ។ ពួកគេក៏ត្រូវយល់ដឹងផងដែរអំពីបែបបទមួយចំនួនដូចជា៖ (១)ប្រមូល និងតាមដានព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ (២) កត់ត្រា វាយតម្លៃ និងគ្រប់គ្រងនូវព័ត៌មានសម្ងាត់នោះ និង (៣) ផ្សព្វផ្សាយសម្ភារដែលបានវាយតម្លៃ ឲ្យបានទាន់ពេលវេលា និងមានសុវត្ថិភាព ឧទាហរណ៍ តាមរយៈការផ្ទេរទៅឲ្យសហការីអង្គភាពឯកទេសប្រឆាំងការជួញដូរ និង/ឬ ភ្នាក់ងារពាក់ព័ន្ធមួយទៀត ឬ មូលដ្ឋានទិន្នន័យ។

## ការបណ្តុះបណ្តាលពេញលេញ និងចំគោលដៅដល់តួនាទីជួរមុខ

មន្ត្រីអនុវត្តន៍ច្បាប់ទាំងអស់គួរតែមានចំណេះដឹងជាមូលដ្ឋានអំពីបទល្មើសជួញដូរមនុស្ស។ ពួកគេគួរមានចំណេះដឹងជាមូលដ្ឋាននេះឲ្យបានពេញលេញ ដើម្បីអនុញ្ញាតឲ្យមន្ត្រីអនុវត្តន៍ច្បាប់ទាំងឡាយអាចកំណត់អំពីស្ថានភាព ឬអាចមានស្ថានភាពជួញដូរមនុស្ស និងផ្តល់នូវការឆ្លើយតបដំបូងភ្លាមៗ។ ឧទាហរណ៍ ចំណុចនេះនឹងពាក់ព័ន្ធដល់ការបណ្តុះបណ្តាល ដើម្បីធានាថា មន្ត្រីអាចទទួលស្គាល់សំណុំរឿងជួញដូរ កំណត់អត្តសញ្ញាណជនរងគ្រោះ និងយកពួកគេទៅកាន់កន្លែងសុវត្ថិភាព ទន្ទឹមនឹងចាប់ខ្លួនជនសង្ស័យ យល់ដឹងពីឥទ្ធិពលនៃការប៉ះទង្គិចផ្លូវចិត្ត និងអាចអនុវត្តន៍ការយល់ដឹងនោះនៅក្នុងការងាររបស់ខ្លួនជាមួយជនរងគ្រោះ។ ដោយសារមន្ត្រីមួយចំនួនធំនឹងធ្វើការទៅលើសំណុំរឿងជួញដូរ វាជាការសំខាន់ដែលថា មន្ត្រីដែលបានជ្រើសរើស និងមន្ត្រីកំពុងបម្រើការងារនៅក្នុងលំដាប់ប្រតិបត្តិការទាំងអស់ត្រូវទទួលបានការបណ្តុះបណ្តាលទាំងនេះ។ ដើម្បីសម្រេចតាមគោលបំណងនោះ កម្មវិធីបណ្តុះបណ្តាលនានាសម្រាប់មន្ត្រីជួរមុខគួរតែបញ្ចូលជាផ្លូវការទៅក្នុងកម្មវិធីសិក្សារបស់ស្ថាប័នបណ្តុះបណ្តាលដែលពាក់ព័ន្ធ។ គ្រូប្រចាំស្ថាប័នបណ្តុះបណ្តាលគួរទទួលបានការបណ្តុះបណ្តាលដើម្បីផ្តល់ការបណ្តុះបណ្តាល វាយតម្លៃ ហើយក្នុងករណីចាំបាច់ ត្រូវធ្វើបច្ចុប្បន្នភាពអំពីប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលផងដែរ។

ការជួញដូរជាបទល្មើសស្មុគស្មាញ ហើយការស៊ើបអង្កេតក៏មានភាពស្មុគស្មាញដូចគ្នាដែរ។ មន្ត្រីរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខដែលអាចចូលរួមលើសពីការឆ្លើយតបនៅដំណាក់កាលដំបូងតម្រូវឲ្យទទួលការបណ្តុះបណ្តាលដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការជួញដូរ និងក្លាយជាគោលដៅជាក់លាក់ចំពោះការទទួលខុសត្រូវរបស់ខ្លួន។ ការបណ្តុះបណ្តាលនេះគួរធ្វើឡើងក្នុងគោលបំណងបំពាក់ដល់មន្ត្រីនូវកម្រិតចំណេះដឹង និងជំនាញអនុវត្តន៍ដែលចាំបាច់សម្រាប់ពួកគេក្នុងការបំពេញតួនាទីរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព។

# ៣.៣ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅការឆ្លើយតបរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខជួរមុខយ៉ាងមានប្រសិទ្ធភាព

ដូចបានកត់សម្គាល់នៅក្នុងជំពូកខាងលើ ភាពឯកទេសនៃការឆ្លើយតបនៃការស៊ើបអង្កេតទៅនឹងបទល្មើសជួញដូរត្រូវបានបង្កើតយ៉ាងល្អនៅក្នុងតំបន់អាស៊ានទាំងមូល។ វាពុំមានភាពងាយស្រួលក្នុងការវាស់ស្ទង់នូវស្ថានភាព និងការអនុវត្តន៍ជាក់ស្តែងនៅក្នុងតំបន់ នៅពេលនិយាយដល់វិសាលភាព និងគុណភាពនៃការឆ្លើយតបរបស់មន្ត្រីជួរមុខ ដោយសារវាពុំមានការរៀបចំរចនាសម្ព័ន្ធបានល្អ និងមិនមានការផ្សព្វផ្សាយឱ្យទូលំទូលាយ។ ចំណុចនេះធ្វើឲ្យការប្រមូលព័ត៌មានដែលជឿជាក់បាន ជាពិសេសព័ត៌មានអំពីលក្ខណៈប្រតិបត្តិការ កាន់តែមានការលំបាក។ ហេតុនេះ ព័ត៌មានស៊ីជម្រៅខាងក្រោម ជាការតំណាងនូវភាពជាក់លាក់នៃការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់ជួរមុខទៅនឹងការជួញដូរនៅក្នុង រដ្ឋសមាជិកអាស៊ាន។ ព័ត៌មានដែលបានត្រូវបានរៀបចំ និងមានធាតុផ្សំសំខាន់ៗ ដែលបានរៀបរាប់នៅក្នុងផ្នែកមុន ដោយមានព័ត៌មានបន្ថែមស្តីពីវិធានការដើម្បីដោះស្រាយអំពើពុករលួយ និងការសមគំនិតពាក់ព័ន្ធនឹងការជួញដូរ។

## វឌ្ឍនភាពទាក់ទងនឹងបទដ្ឋាននីតិវិធីប្រតិបត្តិការ និងការគ្រប់គ្រងសំណុំរឿង

បទដ្ឋាននីតិវិធីប្រតិបត្តិការដែលទាក់ទងជាទូទៅទៅនឹងការអនុវត្តន៍ជាក់ស្តែងនៃការអនុវត្តន៍ច្បាប់ នៅមិនទាន់បានប្រើប្រាស់រួមគ្នានៅក្នុងរដ្ឋសមាជិកអាស៊ាននៅឡើយទេ។ ហេតុនេះ វាមិនមែនជាការភ្ញាក់ផ្អើលទេដែលរដ្ឋសមាជិកអាស៊ានមួយចំនួនតូចបានផ្តើមបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការ ក្នុងគោលបំណងជួយដល់មន្ត្រីជួរមុខ ដើម្បីចែករំលែកការងារនៅក្នុងសំណុំរឿងជួញដូរឲ្យមានប្រសិទ្ធភាព។ ដូចបានកត់សម្គាល់នៅជំពូកមុន មានវឌ្ឍនភាពសំខាន់ៗទាក់ទងនឹងការបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការជាក់លាក់របស់អាស៊ានសម្រាប់អ្នកស៊ើបអង្កេត។ ដំណើរការសម្រួលបទដ្ឋាននីតិវិធីប្រតិបត្តិការទាំងនោះឲ្យក្លាយទៅជានីតិវិធីពាក់ព័ន្ធរបស់ជាតិ ទើបតែចាប់ផ្តើមនាពេលថ្មីៗនេះទេ។ ឧទាហរណ៍នាពេលថ្មីៗនេះ បញ្ហាការឆ្មាំព្រំដែននៅ**ប្រទេសវៀតណាម** បានអនុម័តបទដ្ឋាននីតិវិធីប្រតិបត្តិការ ដែលគ្របដណ្តប់ទៅលើការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរនៅក្នុងយុត្តាធិការរបស់ខ្លួន។

*ប្រអប់អត្ថបទ ៨៖ ឧទាហរណ៍អនុវត្តន៍៖ បទដ្ឋាននីតិវិធីប្រតិបត្តិការ ត្រូវបានប្រើប្រាស់ដើម្បីកែលម្អការឆ្លើយតបនៅរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ*

**ប្រទេសម៉ាឡេស៊ី**បានរាយការណ៍ថា បទដ្ឋាននីតិវិធីប្រតិបត្តិការកំពុងយកមកប្រើប្រាស់ដើម្បីកែលម្អការឆ្លើយតបនៅជួរមុខ តាមរយៈ “បទដ្ឋាននីតិវិធីប្រតិបត្តិការ នៃការចោទប្រកាន់” “បទដ្ឋាននីតិវិធីប្រតិបត្តិការ នៃការអនុវត្តន៍ច្បាប់” និង “បទដ្ឋាននីតិវិធីប្រតិបត្តិការនៃជម្រកស្នាក់នៅ”។

**ប្រទេសមីយ៉ាន់ម៉ា**បានរាយការណ៍ថា បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់អង្គភាពឯកទេសរបស់ខ្លួនត្រូវបានបង្កើតឡើងរួចរាល់ហើយ។ ក្រុមការងារប្រឆាំងការជួញដូរកំពុងអនុវត្តបទដ្ឋាននីតិវិធីប្រតិបត្តិការ នោះ។

នៅ**ប្រទេសហ្វីលីពីន** ចៅក្រមត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនទៅលើសំណុំរឿងជួញដូរទៅក្រុមប្រឹក្សាអន្តរភ្នាក់ងារប្រឆាំងការជួញដូរ (IACAT) នៃក្រសួងយុត្តិធម៌ ជាផ្នែកនៃប្រព័ន្ធគ្រប់គ្រងសំណុំរឿង ដើម្បីធានាតាមដានយ៉ាងត្រឹមត្រូវឲ្យមានតម្លាភាព និងការទទួលខុសត្រូវ។

ការគ្រប់គ្រងសំណុំរឿងបានរឹងមាំជួយកែលម្អប្រសិទ្ធភាពនៃការស៊ើបអង្កេតទៅលើការជួញដូរ។ នៅក្នុងអង្គភាពឯកទេស មានវឌ្ឍនភាពមួយចំនួនក្នុងការបង្កើត និងអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងសំណុំរឿង។ ក៏ប៉ុន្តែ ជាទូទៅចំណុចទាំងនេះមិនត្រូវបានធ្វើសាជាថ្មីនៅថ្នាក់មន្ត្រីជួរមុខទេ។ នៅក្នុងតំបន់មួយនៃ**ប្រទេសថៃ** RTP រាយការណ៍ថា ខ្លួនកំពុងដាក់ឲ្យដំណើរការសាកល្បង នូវការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងសម្រាប់សំណុំរឿងជួញដូរមនុស្ស ដើម្បីឲ្យមានការទទួលខុសត្រូវកាន់តែខ្ពស់ និងពង្រឹងការស៊ើបអង្កេត។ នៅឆ្នាំ២០១៤ ប្រទេសវៀតណាម បានដំណើរការមូលដ្ឋានទិន្នន័យនៅទូទាំងប្រទេសដើម្បីតាមដានសំណុំរឿងជួញដូរ។

## វឌ្ឍនភាពទាក់ទងនឹងការដោះស្រាយអំពើពុករលួយ និងការសមគំនិតពាក់ព័ន្ធនឹងការជួញដូរ នៅក្នុងភ្នាក់ងារអនុវត្តន៍ច្បាប់ជួរមុខ

មានការយល់ដឹងកាន់តែច្រើនឡើងនៅក្នុងអាស៊ាន អំពីទំនាក់ទំនងរវាងការជួញដូរ និងអំពើពុករលួយក្នុងវិស័យសាធារណៈ។ *ផែនការសកម្មភាពអាស៊ាន*ឆ្នាំ២០១៥ បានអំពាវនាវឲ្យរដ្ឋសមាជិកអាស៊ានទាំងអស់អនុវត្តដូចខាងក្រោម៖

> ធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសដល់មន្ត្រីសាធារណៈពុករលួយដែលបានចូលរួមក្នុងការជួយសម្រួលការជួញដូរមនុស្ស និងលើកកម្ពស់គោលនយោបាយមិនអត់ឱននិងប្រឆាំងដាច់ខាតនឹងមន្ត្រីពុករលួយទាំងនោះ។

ពុំមានរដ្ឋសមាជិកអាស៊ានណាមួយ (លើកលែងតែ**ប្រទេសថៃ** សូមមើលបន្ថែមខាងក្រោម) បានបង្កើតនីតិវិធីជាក់លាក់ដើម្បីកាត់បន្ថយ និងដោះស្រាយអំពើពុករលួយ និងការបំពានអំណាចពាក់ព័ន្ធនឹងការជួញដូរនោះ ទាំងជាលក្ខណៈទូទៅ ឬកាន់តែជាក់លាក់ទៅទៀត ទាក់ទងនឹងមន្ត្រីជួរមុខ។ ចំណុចបង្កជាបញ្ហាដល់ការទំនួលខុសត្រូវ ដែលបង្កជាបញ្ហាដល់ទំនុកចិត្តពីសាធារណជនទៅលើការអនុវត្តន៍ច្បាប់ជុំវិញបញ្ហាជួញដូរ។ ចំណុចនេះជាបញ្ហាកង្វល់ជាពិសេស ដោយសារអង្គការក្រៅរដ្ឋាភិបាល (NGOs) និងប្រភពផ្សេងទៀតបានលើកឡើងនូវការព្រួយបារម្ភអំពីករណីជាច្រើនដែលពាក់ព័ន្ធនឹងទម្លាប់ពុករលួយ និងការបំពានអំណាចដោយផ្ទាល់ទៅលើក្រុមងាយរងគ្រោះជាងគេទៅនឹងការកេងប្រវ័ញ្ច ដូចជាពលករទេសន្តរប្រវេសន៍មិនប្រក្រតី អ្នកប្រកបរបរផ្លូវភេទ និងពលករនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

រដ្ឋសមាជិកអាស៊ានភាគច្រើនបានយ៉ាងហោចណាស់ បានចាត់វិធានការមួយចំនួនដើម្បីកាត់បន្ថយអំពើពុករលួយ និងការបំពានអំណាចនៅក្នុងការអនុវត្តន៍ច្បាប់។ ក៏ប៉ុន្តែ ដោយមានករណីលើកលែងក្នុងការអនុវត្តន៍ជាក់ស្តែងមួយចំនួនតូច ដូចលើកឡើងខាងក្រោម វិធានការទាំងនេះត្រូវបានកំហិតយ៉ាងទូលំទូលាយត្រឹមតែការកំណត់បទដ្ឋានទូទៅ។ ឧទាហរណ៍ នគរបាលជាតិ**ឥណ្ឌូនេស៊ី** ត្រូវប្រតិបត្តិការក្រោយបទបញ្ជាលម្អិតដែលតម្រូវឲ្យប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងនូវគោលការណ៍សិទ្ធិមនុស្សមួយចំនួន ហើយហាមឃាត់យ៉ាងច្បាស់ចំពោះអំពើពុករលួយ ការទទួលសំណូក និង

ការបំពានសិទ្ធិអំណាច[១០១]។ នៅ**ប្រទេសហ្វីលីពីន** *ក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានសីលធម៌នគរបាលជាតិ* ផ្តល់ជាឧទាហរណ៍មួយទៀតពីការរៀបចំនគរបាលក្នុងគោលបំណងធានានូវឥរិយាបថប្រកបដោយសីលធម៌ពីសមាជិករបស់ខ្លួន តាមរយៈការប្រើប្រាស់ក្រមសីលធម៌។ រដ្ឋសមាជិកអាស៊ានមួយគឺ**ប្រទេសថៃ** បានបោះជំហានឆ្ងាយជាងនេះទៅទៀត ក្នុងការព្យាយាមដោះស្រាយបញ្ហាពុករលួយនៅក្នុងបរិបទនៃការជួញដូរ៖ ការចេញដីកាថ្នាក់ក្រសួងឲ្យបើកការស៊ើបអង្កេត និងឆ្លើយតបទៅនឹងមន្ត្រីរដ្ឋាភិបាលដែលអាចចូលរួមក្នុងការជួញដូរ (វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការចូលរួមរបស់មន្ត្រីសាធារណៈទៅក្នុងសំណុំរឿងជួញដូរមនុស្ស ព.ស ២៥៥៨)។

ទោះបីមានការទទួលស្គាល់នូវភាពធំធេងនៃកិច្ចខិតខំប្រឹងប្រែងនេះក៏ដោយ តែវាជាសំខាន់ដែលត្រូវលើកឡើងថា បទបញ្ជា ក្រមសីលធម៌ និងដីកាក្រសួងនឹងមានប្រសិទ្ធិភាពដូចគ្នានឹងការតាមដាន និងការអនុវត្តន៍នូវរចនាសម្ព័ន្ធដែលត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់លិខិតូបករណ៍ទាំងនោះ

*ប្រអប់អត្ថបទ ៩៖ ឧទាហរណ៍អនុវត្តន៍៖ ការដោះស្រាយអំពើពុករលួយនៃការអនុវត្តន៍ច្បាប់ក្នុងការជួញដូរ*

| |
|---|
| នៅ**ប្រទេសហ្វីលីពីន** ការិយាល័យអន្តោប្រវេសន៍ បានកែប្រែទម្រង់បែបបទចេញដំណើរដើម្បីកាត់បន្ថយឆន្ទានុសិទ្ធិដែលមន្ត្រីអន្តោប្រវេសន៍មាន ហើយកាត់បន្ថយនូវការសមគំនិត និងភាពស្មុគស្មាញទាក់ទងនឹងការកំណត់អត្តសញ្ញាណជនដែលអាចជាជនរងគ្រោះពីការជួញដូរមនុស្ស។ |

## វឌ្ឍនភាពទាក់ទងនឹងការកសាងសមត្ថភាពផ្នែករបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ

មានការបោះជំហានតូចដែលសំខាន់ឆ្ពោះទៅការអភិវឌ្ឍន៍សមត្ថភាព របស់មន្ត្រីអនុត្តច្បាប់ជួរមុខ នៃរដ្ឋសមាជិកអាស៊ាន ដើម្បីបំពេញទៅតាមការទទួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងបទល្មើសជួញដូរ។ សេចក្តីសង្ខេបខាងក្រោមនេះពិចារណាដល់វឌ្ឍនភាពនេះ ទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ និងការឆ្លើយតបបឋម។

### ការកំណត់អត្តសញ្ញាណជនរងគ្រោះ

ការកំណត់អត្តសញ្ញាណជនរងគ្រោះនឹងត្រូវលើកឡើងលម្អិតនៅក្នុងជំពូក ៥។ ចំណុចនេះសង្ខេបអំពីការអភិវឌ្ឍន៍ដែលមានលក្ខណៈពិសេសចំពោះភ្នាក់ងារអនុវត្តន៍ច្បាប់។

វាជាការលំបាកដើម្បីឲ្យទទួលបាននូវទិន្នន័យមូលដ្ឋាន ដែលអាចជឿជាក់បាន ស្តីពីអត្រានៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ទល់នឹងវឌ្ឍនភាពដែលអាចវាស់ស្ទង់ដោយត្រឹមត្រូវបាន។ ក៏ប៉ុន្តែ ការវិភាគសំណុំរឿងបញ្ជាក់ថាមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខនៅក្នុងតំបន់អាស៊ាន កំពុងកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរកាន់តែត្រឹមត្រូវជាងមុន ជាក់ស្តែងបើប្រៀបធៀបជាមួយស្ថានភាពដែលបានរាយការណ៍នៅក្នុង*របាយការណ៍វឌ្ឍនភាព* ការកែសម្រួលឆ្នាំ

[១០១] សូមមើលបទបញ្ជាលេខ ៨ ឆ្នាំ២០០៩ ចេញដោយប្រធាននគរបាលជាតិឥណ្ឌូនេស៊ី ពាក់ព័ន្ធនឹងការអនុវត្តន៍គោលការណ៍ និងបទដ្ឋានសិទ្ធិមនុស្ស ក្នុងការបំពេញភារកិច្ចរបស់នគរបាលជាតិឥណ្ឌូនេស៊ី។

២០១១ ។ ការកែលម្អនេះអាចឆ្លុះបញ្ចាំងនូវ ការកើនឡើងនៃការយល់ដឹងរបស់មន្ត្រីអនុវត្តន៍ច្បាប់ ព្រមទាំង សមត្ថភាពក្នុងការឆ្លើយតបទៅនឹងបទល្មើសប្រភេទនេះ។

រដ្ឋសមាជិកអាស៊ានមួយចំនួនទៀតបានបង្កើត និងកំពុងអនុវត្តនូវវិធីសាស្ត្រកំណត់អត្តសញ្ញាណជនរងគ្រោះ។ ឧទាហរណ៍ នៅ**ប្រទេសថៃ** *បញ្ជីត្រួតពិនិត្យបឋមសម្រាប់កំណត់អត្តសញ្ញាណជនរងការជួញដូរ* ត្រូវបានបញ្ចូលនៅក្នុងសម្ភារដែលផលិតដោយគណៈកម្មាធិការប្រឆាំងការជួញដូរមនុស្សគឺៈ *វិសាលភាព និងធាតុផ្សំនៃការកំណត់អត្តសញ្ញាណជនរងការជួញដូរ*។ បញ្ជីត្រួតពិនិត្យ និងព័ត៌មានគាំទ្រ ផ្តល់ការណែនាំជាមូលដ្ឋានពីរបៀបថាតើបុគ្គលណាម្នាក់អាចរងការជួញដូរ ឬយ៉ាងណា និងជំហ៊ាននានាដែលត្រូវប្រកាន់យកនៅពេលមានការសម្រេចចិត្តបែបនេះ។ អត្ថបទបោះពុម្ពផ្សាយនេះត្រូវបានចែកចាយដល់ភ្នាក់ងារអនុវត្តន៍ច្បាប់ ទីភ្នាក់ងាររដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល នៅទូទាំងប្រទេស។ អត្ថបទនេះត្រូវបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១៥។

ស្រដៀងគ្នានេះដែរ នៅ**ប្រទេសសិង្ហបុរី** អង្គភាពនគរបាលបានបង្កើត "ប័ណ្ណស្តីពីការជួញដូរមនុស្ស" ដែលមានធាតុផ្សំគន្លឹះនៃការជួញដូរ ដែលត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់អន្តរជាតិ និងបានរៀបរាប់នូវសូចនាករចំនួន ១២ ដើម្បីជួយមន្ត្រីជួរមុខ ក្នុងការវាយតម្លៃថាតើ សំណុំរឿងមួយបំពេញទៅតាមធាតុផ្សំនៃការជួញដូរមនុស្ស ដែរឬទេ។ "ប័ណ្ណស្តីពីការជួញដូរមនុស្ស" ក៏មានបញ្ចូលនូវព័ត៌មានលម្អិតសម្រាប់ទាក់ទងរបស់មន្ត្រីនៅក្នុងផ្នែកព្រហ្មទណ្ឌជំនាញ នៃនាយកដ្ឋានស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ដែលស៊ើបអង្កេតទៅលើសំណុំរឿងគេងប្រវ័ញ្ចផ្លូវភេទពាក់ព័ន្ធនឹងការជួញដូរ។ នៅ**ប្រទេសមីយ៉ាន់ម៉ា** បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ដឹកនាំអង្គភាពឯកទេសនៅក្នុងដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះដែលរងការជួញដូរ សិទ្ធិ និងជំនួយដល់ជនរងគ្រោះ ការការពារជាក់ស្តែង និងតាមផ្លូវតុលាការដល់សាក្សីជាជនរងគ្រោះ ការស្តាប់ចម្លើយសាក្សីជាជនរងគ្រោះដើម្បីប្រមូលភស្តុតាង និងអនុសាសន៍ដើម្បីលើកកម្ពស់សមភាពយេនឌ័រទាក់ទងនឹងបញ្ហាយេនឌ័រសម្រាប់សេចក្តីណែនាំនៃផ្នែកប្រឆាំងការជួញដូរមនុស្សក៏រួមទាំងសេវាគាំទ្រ សម្រាប់សាក្សីជាជនរងគ្រោះដែលរងការជួញដូរ និងសាធារណជនដោយគ្មានការរើសអើងយេនឌ័រឡើយ។

គោលការណ៍ណែនាំស្តីពីលំដាប់លំដោយ នីតិវិធី និងការសហការក្នុងការតាមដាន ការកំណត់អត្តសញ្ញាណ ការទទួល និងការបញ្ជូនជនរងគ្រោះដែលរងការជួញដូរត្រឡប់ទៅវិញរបស់**ប្រទេសវៀតណាម** លើកឡើងនូវនីតិវិធីដែលភ្នាក់ងាររដ្ឋាភិបាលត្រូវអនុវត្តតាម ដើម្បីកំណត់អត្តសញ្ញាណផ្ទៀងផ្ទាត់ និងទទួលជនរងគ្រោះដែលរងការជួញដូរនៅក្នុង ឬឆ្លងកាត់ប្រទេស។ នៅ**ប្រទេសហ្វីលីពីន** សៀវភៅស្តីពីការអនុវត្តន៍ច្បាប់ និងការចោទប្រកាន់សំណុំរឿងជួញដូរមនុស្ស ត្រូវបានបង្កើត និងគាំទ្រដល់ដៃគូទាំងអស់នៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌចម្បង។ ផ្នែកស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះមានគោលបំណងជាពិសេសដល់មន្ត្រីអនុវត្តន៍ច្បាប់ទាំងអស់។ ដូចបានកត់សម្គាល់ ដោយមានឧទាហរណ៍មួយចំនួនក្នុងចំណោមឧទាហរណ៍ទាំងនេះនឹងត្រូវយកមកពិចារណាលម្អិត នៅក្នុងជំពូកទី ៥ ខាងក្រោម។

រដ្ឋសមាជិកអាស៊ានទាំងអស់ ក៏ដូចជាប្រទេសទាំងអស់នៅក្នុងពិភពលោកដែរ គឺកំពុងបន្តប្រឈមទៅនឹងការធានានូវការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវ។ ការវិភាគសំណុំរឿងបង្ហាញថា នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ច្បាប់ដែលមានភាពច្របូកច្របល់ ឬការភាន់ច្រឡំក្នុងការបកស្រាយច្បាប់ បន្តធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការឆ្លើយតបរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ ទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ឧទាហរណ៍ ស្ថានភាព ឬបទល្មើសនានាដែលអាចប្រដូច ការជួញដូរនៅក្នុងទិដ្ឋភាពមួយចំនួន (ឧទាហរណ៍ ដោយសារពួកគេពាក់ព័ន្ធនឹងជនទេសន្តរប្រវេសន៍ខុសច្បាប់ ឬបុគ្គលដែលធ្វើការនៅក្នុងវិស័យ

ឧស្សាហកម្មដែលត្រូវបានហាមឃាត់ ឬធ្វើដំណើរឆ្លងកាត់ព្រំដែនអន្តរជាតិ) ត្រូវបានកំណត់អត្តសញ្ញាណដោយមិនត្រឹមត្រូវថាជាការជួញដូរនោះទេ។

សំណុំរឿងដែលជាក់ស្តែងជាសំណុំរឿងជួញដូរ ក៏ហាក់ដូចជាត្រូវបានមើលរំលង ឬកំណត់អត្តសញ្ញាណខុសផងដែរ។ ការភាន់ច្រឡំនេះមានផលវិបាកធ្ងន់ធ្ងរដូចជា៖ បុគ្គលដែលមិនមែនជាជនរងគ្រោះ ឬចារីនៃបទល្មើសជួញដូរធ្ងន់ធ្ងរ អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះ ឬជាចារីទៅវិញ ជនរងគ្រោះនៃការជួញដូរដែលគួរត្រូវបានកំណត់អត្តសញ្ញាណ និងយកចេញពីគ្រោះថ្នាក់ បែរជាទុកឲ្យស្ថិតក្នុងស្ថានភាពកេងប្រវ័ញ្ច និង ធ្វើឱ្យបាត់បង់ ឱកាសក្នុងការស្វែងរក និងស៊ើបអង្កេតអ្នកប្រព្រឹត្តបទល្មើសវិញ។ ការកំណត់អត្តសញ្ញាណមិនត្រឹមត្រូវគឺជាបញ្ហាសំខាន់ដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ធ្ងន់ធ្ងរ និងរំលោភបំពានសិទ្ធិមនុស្ស។ ហេតុនេះ វាតម្រូវឲ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ និងជាបន្តបន្ទាប់ដោយរដ្ឋសមាជិកអាស៊ានទាំងអស់។

បច្ចុប្បន្ននេះកំពុងមានការទទួលស្គាល់នូវសារៈសំខាន់ នៃការតាមដានឧស្សាហកម្មដែលជាកន្លែងងាយរងគ្រោះសម្រាប់ការជួញដូរ វាគឺជាយុទ្ធសាស្ត្រមួយ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះជាមូលដ្ឋាន ទោះបីមានភាពយឺតយ៉ាវបន្តិចបន្តួចក្តី។ ឧទាហរណ៍ ទាំង**ប្រទេសថៃ** និង**ម៉ាឡេស៊ី** បានទទួលស្គាល់នូវសារៈសំខាន់ នៃអធិការកិច្ចការងារ និងតម្រូវការចាំបាច់ឲ្យបង្កើនចំនួនអធិការកិច្ច ចាប់ពីកម្រិតទាបឡើងមក។

## ការបញ្ជូនជនរងគ្រោះ

ដូចបានកត់សម្គាល់ខាងលើ ជារឿយៗ មន្ត្រីអនុវត្តច្បាប់ជួរមុខ មានវត្តមានមុនគេនៅកន្លែងកើតហេតុនៃការជួញដូរ។ ហេតុនេះ ជាការសំខាន់ដែលថា ពួកគេជាអ្នកទទួលខុសត្រូវភ្លាមៗ ចំពោះការការពារ និងការគាំទ្រដល់ជនរងគ្រោះ យ៉ាងហោចណាស់រហូតទាល់តែសំណុំរឿងនេះត្រូវបានបញ្ជូនជាផ្លូវការទៅឲ្យអង្គភាពឯកទេស (ប្រសិនបើអាច) និង/ឬ រហូតទាល់តែជនរងគ្រោះត្រូវបានបញ្ជូនទៅទីភ្នាក់គាំទ្រសមស្រប។ មន្ត្រីអនុវត្តច្បាប់ជួរមុខ មិនគួរមានអារម្មណ៍ ឬយល់ថាត្រូវបានបង្ខំឲ្យទទួលខុសត្រូវក្នុងការផ្តល់ជំនួយ និងព័ត៌មានទាំងអស់ ដែលជនរងគ្រោះមានសិទ្ធិទទួលបាននោះទេ។ ការទទួលខុសត្រូវរបស់ពួកគេ ត្រូវបានកំហិតត្រឹមតែការចាត់វិធានការចាំបាច់ភ្លាមៗដើម្បីធានាថាជនរងគ្រោះបានទទួលសិទ្ធិទាំងអស់របស់ខ្លួន*តាមរយៈ* ការបញ្ជូនទៅកាន់សេវាគាំទ្រដែលអាចមានឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព តែប៉ុណ្ណោះ។

ការវិភាគសំណុំរឿងបញ្ជាក់ថា នៅក្នុងតំបន់អាស៊ាន មានឧទាហរណ៍ដែលមន្ត្រីអនុវត្តច្បាប់ជួរមុខបំពេញកាតព្វកិច្ចទាំងនេះយ៉ាងមានប្រសិទ្ធភាព ជួនកាលតាមវិធីសាស្ត្ររបស់ខ្លួនដើម្បីផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗដល់ជនរងគ្រោះពីការជួញដូរ ចេញពីធនធានខ្លួនផ្ទាល់ នៅពេលមិនមានវិធានការគាំទ្រផ្សេងទៀត។ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះនៅ**ប្រទេសថៃ** និង**ហ្វីលីពីន** ដែលបានយោងខាងលើ ក៏បញ្ចូលនូវការណែនាំស្តីពីសកម្មភាពនៃការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ដែលត្រូវបានប្រកាន់យកដោយអ្នកប្រតិបត្តិពីភ្នាក់ងារជាច្រើន ក្រោយពេលដែលបុគ្គលម្នាក់ត្រូវបានកំណត់ថារងការជួញដូរ។

ក៏ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង ការភាន់ច្រឡំជុំវិញការកំណត់អត្តសញ្ញាណជនរងគ្រោះទំនងជាលាតសន្ធឹងដល់ការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធទៀត។ ឧទាហរណ៍ ជារឿយៗ ពុំមានការបញ្ជាក់អំពីតួនាទីរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ អនុវត្តច្បាប់ជួរមុខពាក់ព័ន្ធនឹងជនរងគ្រោះដែលពួកគេមានជួបប្រទះ និងពុំមានការណែនាំផ្នែកនីតិវិធីច្បាស់លាស់ជាជំហ៊ានៗដល់ពួកគេ នៅពេលបុគ្គលម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះនៃការជួញដូរ។

ការពុំមានភាពច្បាស់លាស់នេះ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងអវត្តមាននៃបទដ្ឋាននីតិវិធីប្រតិបត្តិការនៃការជួញដូរជាក់លាក់ សម្រាប់មន្ត្រីរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ។ **ប្រទេសវៀតណាម**កំពុងធ្វើបច្ចុប្បន្នលើគោលការណ៍ណែនាំសម្រាប់ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធក្នុងការជួញដូរផ្នែកការងារ ក៏ប៉ុន្តែមិនទាន់បានបញ្ចប់នៅឡើយទេ។

នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន មានការបង្ហាញពីកំណើននៃសហប្រតិបត្តិការរវាងមន្ត្រីអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ និងអ្នកផ្តល់សេវា។ ឧទាហរណ៍ នៅ**ប្រទេសឥណ្ឌូនេស៊ី** នគរបាលមូលដ្ឋានបានសហការជាមួយភ្នាក់ងាររដ្ឋាភិបាលដែលចូលរួមក្នុងការគាំទ្រជនរងគ្រោះ ដើម្បីជួយជនរងគ្រោះ ដោយសារការជួញដូរ ដើម្បីឲ្យពួកគេបានវិលត្រឡប់ទៅផ្ទះសម្បែងវិញយ៉ាងមានសុវត្ថិភាព។

## ការឆ្លើយតបតាមរយៈការស៊ើបអង្កេតបឋម

របាយការណ៍នេះបានកត់សម្គាល់រួចហើយនូវសំណុំរឿងដែលមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ បានកំណត់មិនត្រឹមត្រូវនូវស្ថានភាពនានាថា ជាសំណុំរឿងជួញដូរ៖ ការចាប់ខ្លួនបុគ្គលមួយចំនួនដែលមិនបានប្រព្រឹត្តិការជួញដូរ។ ជាទូទៅព័ត៌មានអំពីកំហុសឆ្គងទាំងនេះ ត្រូវបានលេចឡើងតែនៅដំណាក់កាលជំនុំជម្រះ ឬនៅពេលដែលព័ត៌មានលម្អិតរបស់សំណុំរឿងត្រូវបានបើកចំហជាសាធារណៈ ឬមានការត្រួតពិនិត្យពីខាងក្រៅ។ និន្នាការនេះអនុវត្តចំពោះទិដ្ឋភាពផ្សេងទៀតនៃការឆ្លើយតបជួរមុខ៖ ជាទូទៅពុំមានព័ត៌មានលម្អិត និងដែលអាចផ្ទៀងផ្ទាត់បាន ស្តីពីការឆ្លើយតបតាមរយៈការស៊ើបអង្កេតបឋម ដែលប្រកាន់យកដោយមន្ត្រីអនុវត្តច្បាប់ជួរមុខនៅក្នុងតំបន់អាស៊ាន។ ជាក់ស្តែង ជាញឹកញយបំផុតគឺមន្ត្រីមិនមែនជំនាញជាអ្នកឆ្លើយតបតាមរយៈការស៊ើបអង្កេតបឋម ទៅនឹងសំណុំរឿងជួញដូរនៅក្នុងតំបន់នេះ។ ការពុំមានព័ត៌មានរឹងមាំធ្វើឲ្យមានការលំបាកក្នុងការវាយតម្លៃអំពីកម្រិត នៃភាពត្រឹមត្រូវចំពោះវិសាលភាព និងគុណភាពនៃការឆ្លើយតបមន្ត្រីអនុវត្តច្បាប់ជួរមុខបានទេ។

វាសមហេតុសមផលក្នុងការសន្មតថា ការលំបាក និងឧបសគ្គនៅក្នុងការឆ្លើយតបតាមរយៈការស៊ើបអង្កេតបឋម ដែលត្រូវបានបញ្ចេញដោយការពិនិត្យលើសំណុំរឿងដែលកាន់ដោយអ្នកឯកទេស និងត្រូវបានពិចារណានៅក្នុងផ្នែក ២.៤. នៃជំពូកខាងលើ ក៏ជាកត្តាមួយនៃការឆ្លើយតបដែលធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់ជួរមុខដែរ។ ទាក់ទងនឹងចំនុចនេះ ការលំបាក និងការប្រឈមទាំងនោះអាចត្រូវបានសង្ខេបដូចខាងក្រោម៖

- ពុំមានការជូនដំណឹងឲ្យបានទាន់ពេលវេលា និងពិគ្រោះយោបល់រវាងផ្នែកអនុវត្តន៍ច្បាប់ជាមួយព្រះរាជអាជ្ញា
- ផ្តោតមិនពេញលេញទៅលើការកំណត់អត្តសញ្ញាណ និងកំណត់ទីកន្លែងជនរងគ្រោះដែលស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ចនៅឡើយ និងយកពួកគេចេញពីគ្រោះថ្នាក់
- ខកខានមិនបានធ្វើការវាយតម្លៃហានិភ័យ និងគ្រប់គ្រងហានិភ័យ
- ចម្លើយបឋមរបស់ជនរងគ្រោះមានគុណភាពទាប ពុំមានការពន្យល់លម្អិតពេញលេញដើម្បីកំណត់អត្តសញ្ញាណបទល្មើសនានា និងធាតុផ្សំនៃភស្តុតាង
- ខកខានមិនបានកំណត់អត្តសញ្ញាណជនសង្ស័យទាំងអស់ដែលពាក់ព័ន្ធ ជាពិសេស ជនល្មើសលំដាប់ខ្ពស់ និងជនល្មើសនៅក្រៅដែនដី
- ខកខានមិនបានកំណត់អំពីទំនាក់ទំនងរវាងជនល្មើសដែលបង្កើតជាក្រុមឧក្រិដ្ឋជនដែលមានការចាត់តាំង

- ខកខានមិនបានកំណត់អត្តសញ្ញាណ និងដោះស្រាយករណីនៃអំពើពុករលួយ
- ការប្រើយុត្តិធម៌ "ក្រៅផ្លូវការ" ដូចជាអនុញ្ញាតឲ្យជនសង្ស័យ "ជួសជុលសំណង" ដល់ជនរងគ្រោះ និងបញ្ចៀសការចោទប្រកាន់

ចំណុចខ្សោយទាំងនេះកើតមានជាធម្មតានៅក្នុងការឆ្លើយតបតាមរយៈការស៊ើបអង្កេតបឋម ដោយមិនគិតថាតើមន្ត្រីអនុវត្តច្បាប់ជួរមុខ ឬអ្នកស៊ើបអង្កេតឯកទេសបានចូលរួម ឬយ៉ាងណានោះទេ។ ក៏ប៉ុន្តែ នៅក្នុងស្ថានភាពដែលមន្ត្រីអនុវត្តច្បាប់ជួរមុខត្រូវទទួលខុសត្រូវចំពោះការស៊ើបអង្កេតទាំងមូល ការលំបាក និងឧបសគ្គទាំងនេះទំនងជាកើនឡើងថែមទៀត។

## វឌ្ឍនភាពទាក់ទងនឹងសមត្ថភាពប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ

រដ្ឋសមាជិកអាស៊ានភាគច្រើនមិនទាន់បានចាប់ផ្តើមអភិវឌ្ឍសមត្ថភាពទីភ្នាក់ងារ និងមន្ត្រីអនុវត្តច្បាប់ជួរមុខរបស់ខ្លួនក្នុងការប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរទេ។ ការពិត មានតម្រូវការចាំបាច់ក្នុងការបន្តស្ថាបនាសមត្ថភាពក្នុងការប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់របស់អង្គភាពឯកទេសប្រឆាំងការជួញដូរនៅក្នុងតំបន់។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន គំនិតផ្តួចផ្តើមតិចតួចមួយចំនួនកំពុងត្រូវបានដំណើរការដើម្បីកែលម្អសមត្ថភាពលើព័ត៌មានសម្ងាត់។ ក៏ប៉ុន្តែ គំនិតផ្តួចផ្តើមទាំងនេះហាក់ដូចជាផ្តោតតែទៅលើមុខងារអនុវត្តន៍ច្បាប់ជាទូទៅ ហើយមិនទាន់បានតម្រង់ទិសជាក់លាក់ទៅរកការជួញដូរទេ។

ឧទាហរណ៍ នៅ**ប្រទេសថៃ** កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយចំណុចខ្វះខាតនៅក្នុងការប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់បានបញ្ចូល សេចក្តីផ្តើមនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានតាមនៅក្នុងកុំព្យូទ័រ ដែលមានសមត្ថភាពប្រមូលព័ត៌មានស្តីពីវិស័យនានាដែលពាក់ព័ន្ធនឹងជនសង្ស័យ ជនរងគ្រោះ និងវិធីសាស្ត្រប្រព្រឹត្តបទល្មើស។ ប្រព័ន្ធនេះពាក់ព័ន្ធទៅគ្រប់វិស័យនៃបទល្មើសទាំងអស់ ហេតុនេះអាចប្រើប្រាស់បានសម្រាប់តែការគ្រប់គ្រងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរប៉ុណ្ណោះ។ ក្រៅពីនេះ ការអនុវត្តន៍កំពុងបង្ហាញថាមានការប្រឈម ដោយសារបញ្ហាផ្លូវច្បាប់ និងភ័ស្តុភារមួយចំនួន។

រដ្ឋសមាជិកអាស៊ានជាច្រើន (រួមទាំង **ប្រទេសឥណ្ឌូនេស៊ី ថៃ** និង**វៀតណាម**ផង) បានតម្លើងប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងព័ត៌មានសម្ងាត់ដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ។ ប្រព័ន្ធកុំព្យូទ័រនេះប្រមូលផ្តុំព័ត៌មាន និងព័ត៌មានសម្ងាត់មកពីស្ថាប័ននគរបាលជាច្រើន ហើយអាចប្រើប្រាស់ជាឧបករណ៍ដើម្បីវិភាគ និងបង្កើតព័ត៌មានសម្ងាត់ និង គ្រប់គ្រងការស៊ើបអង្កេត។ ក៏ប៉ុន្តែ ជាថ្មីម្តងទៀត ឧបករណ៍ទាំងនេះជាទូទៅមានភាពធំធេងពេកមិនអាចផ្តល់ និងអនុវត្តន៍ដើម្បីផ្តល់ប្រយោជន៍ជាដុំកំភួនដល់ព័ត៌មាន និងព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរនោះទេ។ **ប្រទេសឥណ្ឌូនេស៊ី**រាយការណ៍ថា នៅឆ្នាំ២០១៧ នគរបាលជាតិបានអនុម័តនូវប្រព័ន្ធស៊ើបអង្កេតអេឡិចត្រូនិក។ តាមរយៈប្រព័ន្ធនេះ អ្នកស៊ើបអង្កេតរំពឹងថានឹងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវវឌ្ឍនភាព និងលទ្ធផលនៃការស៊ើបអង្កេត សម្រាប់ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌទាំងអស់រួមទាំងពាក់ព័ន្ធនឹងការជួញដូរមនុស្សផងដែរ។ នៅពុំទាន់មានព័ត៌មាននៅឡើយទេ ពីរបៀបដែលប្រព័ន្ធនេះដំណើរការជាក់ស្តែង។

*ប្រអប់អត្ថបទ ១០៖ ការប្រមូលព័ត៌មានសម្ងាត់ដោយភ្នាក់ងារមន្ត្រីអនុវត្តច្បាប់ជួរមុខ*

នៅ**ប្រទេសមីយ៉ាន់ម៉ា** ភ្នាក់ងារអនុវត្តច្បាប់ជួរមុខមួយចំនួនដូចជា ATTF ក្រុមតាមដាន ។ល។ កំពុងប្រមូលព័ត៌មានសម្ងាត់ និងព័ត៌មាន តាមរយៈអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសហគមន៍មូលដ្ឋាន។ ជាលទ្ធផល មានមនុស្សដែលអាចជាជនរងគ្រោះនៃការជួញដូរចំនួន ១៩០ នាក់ត្រូវបានជួយសង្គ្រោះ ហើយ អ្នកជួញដូរ/ឈ្មួញកណ្ដាលចំនួន ២៩២ នាក់ត្រូវបានចាប់ខ្លួននៅឆ្នាំ២០១៧-២០១៨។

នៅ**ប្រទេសហ្វីលីពីន** មនុស្សម្នាក់ដែលបានប្រើប្រាស់បណ្ដាញសង្គម (Facebook) ដើម្បីផ្សព្វផ្សាយផ្ដល់សេវាផ្លូវភេទដោយកុមារីក្មេងៗត្រូវបានចាប់ខ្លួន តាមរយៈប្រតិបត្តិការដាក់អន្ទាក់ដែលបានធ្វើឡើងដោយផ្នែកឧក្រិដ្ឋកម្មបច្ចេកវិទ្យា នៃការិយាល័យស៊ើបអង្កេតជាតិ (NBI)។ ដោយគ្រាន់តែផែកមើលនៅលើបណ្ដាញនោះ ភ្នាក់ងារ NBI បានកត់សម្គាល់អំពីប្រវត្តិរូបមួយនៅលើ Facebook ដែលផ្ដល់ពាណិជ្ជកម្មអំពីសេវាផ្លូវភេទ ហើយប្រការនេះបានធ្វើឲ្យគាត់ផ្ដួចផ្ដើមរៀបចំប្រតិបត្តិការដាក់អន្ទាក់ភ្លាមដែរ។ ក្រោយមក ចារីត្រូវបានផ្ដន្ទាទោសស្មើនឹងការជួញដូរ។

សរុបមក នៅមានកាលានុវត្តភាពជាច្រើនក្នុងការកែលម្អការបំពេញការងាររបស់មន្ត្រី និងភ្នាក់ងារអនុវត្តច្បាប់ជួរមុខ ទាក់ទងនឹងព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ។ ដូចបានកត់សម្គាល់ខាងលើ ដើម្បីឲ្យអាចកើតឡើងបានមន្ត្រីអនុវត្តច្បាប់ជួរមុខត្រូវអភិវឌ្ឍសមត្ថភាព ដើម្បីយល់ដឹងនូវសូចនាករនៃការជួញដូរ។ ពួកគេក៏ត្រូវតែយល់ពីរបៀប៖ (១) ប្រមូល និងតាមដានព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ (២) កត់ត្រា វាយតម្លៃ និងគ្រប់គ្រងព័ត៌មានសម្ងាត់នោះ និង (៣) ផ្សព្វផ្សាយសម្ភារដែលបានវាយតម្លៃឲ្យបានទាន់ពេល និងមានសុវត្ថិភាព ឧទាហរណ៍ តាមរយៈការផ្ទេរទៅសហការីនៅអង្គភាពឯកទេសប្រឆាំងការជួញដូរ និង/ឬ ភ្នាក់ងារពាក់ព័ន្ធមួយទៀត ឬមូលដ្ឋានទិន្នន័យ។ កង្វះជំនាញ និងចំណេះដឹងនៅក្នុងវិស័យទាំងនេះកើតឡើងដោយសារពុំមាននីតិវិធីជាជំហានៗ។

## វឌ្ឍនភាពទាក់ទងនឹងការបណ្ដុះបណ្ដាលមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ

ការបណ្ដុះបណ្ដាលជាវិស័យមួយ ដែលមានគោលបំណងបង្កើនសមត្ថភាពរបស់មន្ត្រីអនុវត្តន៍ច្បាប់ ជួរមុខ ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងបទល្មើសជួញដូរ ដែលមានវឌ្ឍនភាពជាច្រើនបំផុតនៅក្នុងតំបន់អាស៊ាន។ ធ្វើការតាមរយៈ SOMTC និងដំណើរការ HSU រដ្ឋសមាជិកអាស៊ានបានបង្កើត និងដាក់ឲ្យដំណើរការសាកល្បងនូវ*កម្មវិធីបណ្ដុះបណ្ដាលអាស៊ានស្ដីពីការជួញដូរមនុស្សសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ* ។ កម្មវិធីនេះត្រូវបានអនុម័តជាផ្លូវការដោយ SOMTC នៅឆ្នាំ២០០៩។ វាមានគោលបំណងដើម្បីកែលម្អ ការយល់ដឹងរបស់មន្ត្រីអនុវត្តន៍ច្បាប់ ជួរមុខអំពីបទល្មើសជួញដូរ និងដើម្បីផ្ដល់ឲ្យពួកគេនូវចំណេះដឹង និងជំនាញចាំបាច់ដើម្បីធ្វើការឆ្លើយតបលើកដំបូងឲ្យមានប្រសិទ្ធភាព។ កម្មវិធីនេះគ្របដណ្ដប់ទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះ ការការពារ និងការគាំទ្រជនរងគ្រោះ ការធ្វើផែនការ និងបើកប្រតិបត្តិការការជួយសង្គ្រោះជនរងគ្រោះ និងចាប់ខ្លួនជនសង្ស័យ ធានា និងថែរក្សាភស្តុតាងពាក់ព័ន្ធនឹងការជួញដូរ និងការប្រមូលព័ត៌មានសម្ងាត់។ កម្មវិធីនេះត្រូវបានដាក់ដំណើរការសាកល្បងនៅក្នុងរដ្ឋសមាជិកអាស៊ានចំនួន ៧ និងនៅក្នុងតំបន់។ មកទល់នឹងពេលបច្ចុប្បន្ននេះ កម្មវិធីនេះត្រូវបានបណ្ដុះបណ្ដាលដល់មន្ត្រីអនុវត្តច្បាប់ជួរមុខ អាស៊ានចំនួនជាង ៣.៥០០ នាក់ហើយ។

កម្មវិធីត្រូវបានបង្កើតឡើងសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ*ទាំងអស់* ដែលអាចចូលរួមនៅក្នុងសំណុំរឿងជួញដូរ។ ហេតុនេះ ការបណ្តុះបណ្តាលជាទៀងទាត់ និងទូលំទូលាយមានសារសំខាន់ដើម្បីធានានូវការកសាង និងរក្សាបុគ្គលិកដែលទទួលការបណ្តុះបណ្តាលក្នុងចំនួនគ្រប់គ្រាន់។ ការបណ្តុះបណ្តាលគួរត្រូវបានធ្វើឡើងតាមរយៈស្ថាប័នបណ្តុះបណ្តាលនគរបាលជាតិ។ ចំណុចនេះជួយដល់ការធានាអំពីនិរន្តរភាពនៃកម្មវិធី និងផ្តល់កាលានុវត្តភាពល្អបំផុតដល់ការសម្របនៅថ្នាក់ជាតិ ដើម្បីឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរច្បាប់ គោលនយោបាយ និងវិធីសាស្ត្រ។

រដ្ឋសមាជិកអាស៊ានជាច្រើនបានបោះជំហ៊ានឆ្ពោះទៅរៀបចំជាស្ថាប័ន នូវកម្មវិធីដែលគាំទ្រដោយអាស៊ាន ដោយការបង្កើតជាក្រុមគ្រូបង្គោលនគរបាលជាតិ។ ឧទាហរណ៍ នៅ**ប្រទេសឡាវ** និង**កម្ពុជា** គ្រូបង្គោលនគរបាលបានធ្វើការបណ្តុះបណ្តាលនៅទូទាំងប្រទេស។ គ្រូបង្គោលជាតិនៅ**ប្រទេសឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ** និង**វៀតណាម** បានផ្តល់ការបណ្តុះបណ្តាលផ្នែកជួរមុខដល់មន្ត្រីនគរបាល មន្ត្រីអន្តោប្រវេសន៍ ឆ្មាំព្រំដែន និងមន្ត្រីគយ។ វគ្គបណ្តុះបណ្តាលទាំងនេះភាគច្រើនត្រូវបានធ្វើឡើងនៅថ្នាក់ខេត្ត ឬថ្នាក់ស្រុក (ជារឿយៗត្រូវបានកំណត់ជាចំនុច "ក្តៅ") ដើម្បីជួយដល់មន្ត្រីអនុវត្តន៍ច្បាប់ជាច្រើន រួមទាំងមន្ត្រីដែលនឹងជួបប្រទះការជួញដូរនៅពេលបំពេញភារកិច្ចជាធម្មតា ដើម្បីឲ្យទទួលបានការបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្សជាលើកដំបូង។

## ប្រអប់អត្ថបទ ១១៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីនូវការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ជួរមុខ

នៅ**ប្រទេសមីយ៉ាន់ម៉ា** មន្ត្រីអនុវត្តច្បាប់ជួរមុខដូចជានគរបាលព្រំដែន មន្ត្រីអន្តោប្រវេសន៍ អធិការការងារ ។ល។ បានទទួលការបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតការជួញដូរមនុស្ស ការបណ្តុះបណ្តាលអំពីដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបណ្តុះបណ្តាលពីការស៊ើបអង្កេតទៅឯកសារក្លែងក្លាយ ជាប្រចាំ។

បណ្ឌិត្យសភាតុលាការ**ហ្វីលីពីន** (PHILJA) ជាស្ថាប័នអប់រំរបស់តុលាការកំពូល បានមើលឃើញអំពីសារៈសំខាន់ នៃវិធីសាស្ត្រច្រើនវិស័យក្នុងការរៀបចំការបណ្តុះបណ្តាល។ សម្រាប់ការបណ្តុះបណ្តាលចៅក្រមក្នុងការដោះស្រាយ និងឆ្លើយតបទៅនឹងការជួញដូរមនុស្ស ពួកគេបានបញ្ចូលព្រះរាជអាជ្ញា មន្ត្រីអនុវត្តន៍ច្បាប់ និងមន្ត្រីសង្គមកិច្ច។ មេរៀនមួយចំនួនក៏ផ្តោតទៅលើលទ្ធផល ច្រើនជាងការប្រភេទនៃការបង្រៀនធម្មតា។

ស្ថាប័នបណ្តុះបណ្តាលនគរបាលជាតិនៅក្នុងរដ្ឋសមាជិកអាស៊ានចំនួន ៥ (**កម្ពុជា ឡាវ ហ្វីលីពីន ថៃ វៀតណាម**) មានបង្កើតកម្មវិធីបណ្តុះបណ្តាល ដោយផ្អែកលើកម្មវិធីរបស់អាស៊ាន ដែលផ្តល់ ឬនឹងផ្តល់ដល់នគរបាលដែលបានជ្រើសរើសថ្មី/សិស្សនគរបាលថ្មីថ្មោងនូវការយល់ដឹងជាមូលដ្ឋាននៃបទល្មើសជួញដូរមនុស្ស និងធាតុផ្សំស្នូលនៃការឆ្លើយតបជួរមុខយ៉ាងមានប្រសិទ្ធភាព។ នាពេលបច្ចុប្បន្ន សិស្សនគរបាលថ្មីថ្មោងទាំងអស់នៅប្រទេសថៃបានទទួលការបណ្តុះបណ្តាលឯកទេសស្តីពីការជួញដូរមនុស្ស ជាផ្នែកនៃការបណ្តុះបណ្តាលទៅតាមបទដ្ឋានរបស់ខ្លួន។ នៅ**ប្រទេសវៀតណាម** ស្ថាប័នបណ្តុះបណ្តាលនគរបាលសំខាន់ចំនួន ២ និងនាយកដ្ឋាននគរបាលព្រហ្មទណ្ឌមជ្ឈិម និងទីបញ្ជាការឆ្មាំព្រំដែនបានទទួលការគាំទ្រឲ្យបង្កើត និងធ្វើបច្ចុប្បន្នភាពទៅលើកម្មវិធីបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស សម្រាប់នគរបាលព្រហ្មទណ្ឌរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ និងឆ្មាំព្រំដែន និងអ្នកស៊ើបអង្កេត។ វិទ្យាស្ថានបណ្តុះបណ្តាលនគរបាលជាតិនៅ**ប្រទេសមីយ៉ាន់ម៉ា** បានបញ្ចូលការជួញដូរទៅក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់មន្ត្រីបំពេញការងារ ទោះបីគេពុំដឹងច្បាស់តើការបណ្តុះបណ្តាលនេះនឹងធ្វើឡើងនៅពេលណា របៀបណា ឬញឹកញាប់យ៉ាង

ណានេះទេ។ វគ្គនេះត្រូវបានវាយការណ៍ថា ដើម្បីដោះស្រាយ៖ គ្រប់គ្រងប្រតិបត្តិការចាប់ខ្លួន ការឆែកឆេរ និងចាប់យក គ្រប់គ្រងឧក្រិដ្ឋកម្មឆ្លងដែន បទប្បញ្ញត្តិគតិយុត្តិនៃច្បាប់ពាក់ព័ន្ធនឹងការជួញដូរ និយមន័យនៃការជួញដូរមនុស្ស និង ទិដ្ឋភាពបទូទៅនៃការឆ្លើយតបថ្នាក់ជាតិទៅនឹងការជួញដូរ។ នៅ**ប្រទេសហ្វីលីពីន** កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ បានច្របាច់បញ្ចូលនូវកម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ជួរមុខអាស៊ានទៅក្នុងកម្មវិធីរបស់ខ្លួន និងផ្តល់ការបណ្តុះ បណ្តាលដល់មន្ត្រីអនុវត្តច្បាប់ជួរមុខ ជាផ្នែកនៃផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់ខ្លួនផងដែរ។

រដ្ឋសមាជិកអាស៊ានមួយចំនួនកំពុងផ្តល់ការបណ្តុះបណ្តាលឯកទេស ដល់មន្ត្រីអនុវត្តច្បាប់មិនមែនជំនាញ ដោយមានគោលដៅកែលម្អទិដ្ឋភាពនៃការឆ្លើយតបទៅនឹងការជួញដូរ។ ឧទាហរណ៍ នៅ**ប្រទេសឥណ្ឌូនេស៊ី** ការបណ្តុះ បណ្តាលបានផ្តល់ដោយប្រើប្រាស់ច្បាប់ស្តីពីការសម្អាតប្រាក់ ដើម្បីកំណត់អត្តសញ្ញាណ និងរឹបអូសទ្រព្យរបស់ជន ជួញដូរ។ **ឥណ្ឌូនេស៊ី** និង**ហ្វីលីពីន** បានបោះជំហានឆ្ពោះទៅពង្រីកកម្មវិធីបណ្តុះបណ្តាលហួសពីភ្នាក់ងារអនុវត្តច្បាប់ ក្នុងប្រទេស ឧទាហរណ៍ ដើម្បីបញ្ចូលមន្ត្រីកុងស៊ុលដែលមានទីតាំងនៅក្នុងស្ថានទូតនៅបរទេស ជាក្រុមដែលមាន តួនាទីសំខាន់ក្នុងការកំណត់ និងផ្តល់ជំនួយបឋមដល់ជនរងគ្រោះនៃការជួញដូរ។ ព័ត៌មានបន្ថែមស្តីពីគំនិតផ្តួចផ្តើម បណ្តុះបណ្តាលនៅហ្វីលីពីននឹងលើកយកមករៀបរាប់នៅក្នុងប្រអប់អត្ថបទខាងក្រោម។ រដ្ឋាភិបាល**ថៃ**បានគាំទ្រដល់ ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ជួរមុខជាទ្រង់ទ្រាយធំ រួមទាំង អធិការកិច្ចការងារ និងមន្ត្រីនាវាជើងទឹកផងដែរ។

*ប្រអប់អត្ថបទ ១២៖ គំនិតផ្តួចផ្តើមការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ជួរមុខនៅប្រទេសហ្វីលីពីន*

ក្រុមប្រឹក្សាអន្តរភ្នាក់ងារប្រឆាំងការជួញដូរហ្វីលីពីន (IACAT) បានត្រួតពិនិត្យនូវការផលិតសម្ភារបណ្តុះ បណ្តាល និងសម្ភារគាំទ្រជាច្រើនសម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខ និងមន្ត្រីផ្សេងទៀត ក្នុងគោលបំណងកែលម្អ គុណភាព និងភាពស៊ីចង្វាក់នៃការឆ្លើយតបតាមរយៈយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស រួមមាន៖

- ផ្នែកកេងប្រវ័ញ្ចនៅក្នុងការងារនៃការជួញដូរមនុស្ស៖ សៀវភៅសម្រាប់អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា អធិការកិច្ចការងារ និងអ្នកផ្តើលសេវា (ឆ្នាំ២០១៣)
- សៀវភៅស្តីពីផ្នែកសម្អាតប្រាក់នៃការជួញដូរមនុស្ស (ខែកក្កដា ឆ្នាំ២០១៧)
- គោលការណ៍ណែនាំស្តីពីប្រព័ន្ធបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការជួញដូរមនុស្ស ជាពិសេសសំណុំ រឿងជួញដូរការងារ (សេចក្តីសម្រេចលេខ ០០៦) ខែមីនា ឆ្នាំ២០១៧

អង្គភាពឯកទេសនៅក្នុងភ្នាក់ងារនគរបាលជាតិ ចូលរួមផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ជួរមុខកាន់ តែកើនឡើង។ ឧទាហរណ៍ នៅ**ប្រទេសមីយ៉ាន់ម៉ា** អង្គភាពឯកទេសបានផ្តល់នូវការបណ្តុះបណ្តាលមូលដ្ឋាន និងពេលធ្វើ ការដល់នគរបាល។ អង្គភាពឯកទេសនៅ**ប្រទេសថៃ** ចូលរួមជារឿយៗក្នុងការបណ្តុះបណ្តាលមន្ត្រីសាធារណៈរួមទាំង ផ្នែកអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខផងដែរ។

# ៣.៤ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត

ផ្នែកមុនបានបញ្ជាក់ថា មានវឌ្ឍនភាពសំខាន់នៅតំបន់អាស៊ាន ទាក់ទងនឹងការអភិវឌ្ឍន៍នូវការឆ្លើយតបយ៉ាងរឹងមាំ និងមានប្រសិទ្ធភាពទៅនឹងការជួញដូរ។ ទោះបីមិនបានដឹងពីអត្រាការកំណត់អត្តសញ្ញាណជនរងគ្រោះដោយមន្ត្រីជួរមុខអនុវត្តច្បាប់ក៏ដោយ តែគេដឹងច្បាស់ថា ជនរងគ្រោះនៃការជួញដូរមួយចំនួនពិតជាត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីអនុវត្តច្បាប់ជួរមុខមែន។ ចំណុចនេះហាក់ដូចជាឆ្លុះបញ្ចាំងនូវការផ្តោតទៅលើនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធដែលមាននៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ព្រមទាំងការយកចិត្តទុកដាក់យ៉ាងធំធេង ទៅលើបណ្តុះបណ្តាលពីការយល់ដឹងសម្រាប់ក្រុមនេះ។ ក៏មានវឌ្ឍនភាពធំធេងផងដែរក្នុងការបង្កើនចំណេះដឹង និងជំនាញដល់មន្ត្រីអនុវត្តច្បាប់ជួរមុខ ដើម្បីឆ្លើយតបទៅនឹងការជួញដូរក្នុងតំបន់យ៉ាងមានប្រសិទ្ធភាព។

*កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ* បានត្រួសត្រាយផ្លូវឆ្ពោះទៅកែលម្អការយល់ដឹងរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ និងផ្តល់ឲ្យពួកគេនូវចំណេះដឹង និងជំនាញដើម្បីធ្វើការឆ្លើយតបបឋមទៅនឹងបទល្មើសយ៉ាងមានប្រសិទ្ធភាព។ នៅក្នុងតំបន់អាស៊ាន នាពេលបច្ចុប្បន្ន មានមន្ត្រីអនុវត្តច្បាប់ជួរមុខរាប់ពាន់នាក់ បានទទួលការបណ្តុះបណ្តាលនេះ ហើយនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន គេបានបោះជំហ៊ានបញ្ចូលកម្មវិធីនេះទៅក្នុងកម្មវិធីបណ្តុះបណ្តាល និងស្ថាប័នថ្នាក់ជាតិ។ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ក៏មានវឌ្ឍនភាពទាក់ទងនឹងប្រព័ន្ធកត់ត្រា ការវិភាគ និងការគ្រប់គ្រងព័ត៌មានសម្ងាត់ដែរ។ នៅពេលបញ្ហានៃការចាប់ផ្តើមត្រូវបានដោះស្រាយរួចហើយ ប្រព័ន្ធទាំងនេះគួរផ្តល់នូវវេទិកាជារចនាសម្ព័ន្ធដែលអាចបង្កើតសមត្ថភាពព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរបាន។

វឌ្ឍនភាពនេះមានភាពធំធេង តែនៅមានជាផ្នែកៗ និងមិនស្មើគ្នាដែរ។ ទោះបីការវិភាគសំណុំរឿងបញ្ជាក់ថាទីភ្នាក់អនុវត្តន៍ច្បាប់ ពិតជាបានកំណត់អត្តសញ្ញាណជនរងគ្រោះនៃការជួញដូរបានមែន តែពួកគេក៏កំណត់អត្តសញ្ញាណខុសនៅក្នុងសំណុំរឿងមិនមែនជួញដូរមួយចំនួនផងដែរ ដែលបណ្តាលឲ្យមានភាពអយុត្តិធម៌ធ្ងន់ធ្ងរ។ ចំណុចនេះបង្ហាញថា នៅមានគម្លាតធំធេងរវាងលក្ខខណ្ឌនៃការឆ្លើយតបការអនុវត្តច្បាប់ជួរមុខរឹងមាំ និងមានប្រសិទ្ធភាព និងសមត្ថភាពជាក់ស្តែង។ សរុបមក នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ ការប្រឈម និងកាលានុវត្តភាពនឹងលើកយកមកពិចារណាលម្អិតនៅខាងក្រោម ដែលមានចំណងជើងចំនួន ៤ ដែលត្រូវបានរៀបចំនៅក្នុងផ្នែកមុនៗ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងបទដ្ឋាននីតិវិធីប្រតិបត្តិការ

ពាក់ព័ន្ធនឹងការឆ្លើយតបឯកទេស ចំណុចខ្សោយសំខាន់ៗជាច្រើនដែលបានរកឃើញខាងលើអាចដោះស្រាយបាន យ៉ាងហោចណាស់នៅក្នុងករណីទីមួយ តាមរយៈការបង្កើត និង*ការអនុវត្តន៍ខ្ជាប់ខ្ជួន* នៃបទដ្ឋាននីតិវិធីប្រតិបត្តិការដែលត្រូវកំណត់ឲ្យបានជាក់លាក់ដើម្បីគ្រប់គ្រង និងកែលម្អដំណើរការឆ្លើយតបផ្នែកការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខទៅនឹងការជួញដូរ។ ដើម្បីឲ្យមានប្រសិទ្ធភាពនីតិវិធីប្រតិបត្តិការត្រូវយកមកអនុវត្តនៅក្នុងរចនាសម្ព័ន្ធមួយដែលពិនិត្យតាមដាន និងលើកកម្ពស់ការអនុវត្តន៍ជាទៀងទាត់នៃនីតិវិធីទាំងនោះ។

បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខគួរ៖

- ត្រូវបាន**បង្កើតឡើងរួមគ្នា**ជាមួយអង្គភាពឯកទេសប្រឆាំងការជួញដូរ នៅពេលមានអង្គភាពទាំងនេះ និងគួរធ្វើឡើងក្នុងគោលបំណងសម្របសម្រួលតួនាទី និងការទទួលខុសត្រូវ។
- ផ្តល់**ការណែនាំច្បាស់លាស់ស្តីពីនីតិវិធីនៃការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ និងការប្រាស្រ័យទាក់ទងការងារ** ដោយធានាថា មន្ត្រីអនុវត្តច្បាប់ជួរមុខដឹងច្បាស់ថាត្រូវជូនដំណឹងទៅអ្នកណា និងដោយមធ្យោបាយអ្វី។
- ស្វែងរកការកាត់បន្ថយកាលានុវត្តភាពចំពោះ**អំពើពុករលួយ និងការបំពានអំណាច** និងបញ្ជាក់ច្បាស់នូវនីតិវិធី និងជំហាននានាដែលត្រូវប្រកាន់យកនៅក្នុងស្ថានភាពដែលការប្រព្រឹត្តិអំពើពុករលួយ និងការបំពានអំណាចត្រូវបានលាតត្រដាងក្នុងអំឡុងពេលស៊ើបអង្កេត។
- ត្រូវបានបង្កើតឡើងជា**កាតព្វកិច្ច** សម្រាប់ភ្នាក់ងារ និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលកំពុងបំពេញការងារ ឬដែលរំពឹងថានឹងបំពេញកាតព្វកិច្ចពាក់ព័ន្ធ។ ប្រសិនបើអាណត្តិ/សមត្ថភាពរបស់អង្គភាពឯកទេសតម្រូវឱ្យមន្ត្រី ឬទីភ្នាក់ងារអនុវត្តច្បាប់ជួរមុខត្រូវទទួលខុសត្រូវរួមចំពោះការស៊ើបអង្កេតនានា បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ការឆ្លើយតបឯកទេសគួរតែអាចអនុវត្តបាន។
- ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីបណ្តុះបណ្តាលទាំងអស់ និងការកសាងសមត្ថភាពសម្រាប់ការឆ្លើយតបរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងសមត្ថភាពជួរមុខ

ទោះបីមានការអភិវឌ្ឍន៍សំខាន់ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះក៏ដោយ តែសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខក្នុងការដោះស្រាយឱ្យមានប្រសិទ្ធភាពជាមួយនឹងការជួញដូរ នៅតែមានកម្រិត ក្នុងតំបន់អាស៊ានទាំងមូល។ មានការងារជាច្រើនទៀតដែលត្រូវធ្វើ មុនពេលដែលមន្ត្រី និងភ្នាក់ងារជួរមុខអាចបំពេញទៅតាមការទទួលខុសត្រូវសំខាន់របស់ពួកគេឱ្យបានពេញលេញ ក្នុងនាមជាអ្នកឆ្លើយតបបឋមទៅនឹងបទល្មើសជួញដូរ។ ការប្រឈម និងកាលានុវត្តភាពពាក់ព័ន្ធនឹងសមត្ថភាពនឹងត្រូវរៀបរាប់ដោយសង្ខេបដូចខាងក្រោម ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ និងការឆ្លើយតបបឋម។

**ពង្រីកវិសាលភាពនៃទស្សនាទាន "ជួរមុខ"៖** នៅក្នុងការកែសម្រួលលើកទីមួយនៃរបាយការណ៍វឌ្ឍនភាព មានការយល់ដឹងជាទូទៅអំពីទស្សនាទាន "ការអនុវត្តន៍ច្បាប់ជួរមុខ" សំដៅដល់មន្ត្រីនគរបាល ហើយក៏ប្រហែលសំដៅដល់ទីភ្នាក់ងារ និងមន្ត្រីអន្តោប្រវេសន៍ដែរ។ មកទល់នឹងសព្វថ្ងៃនេះ ទស្សនាទាននេះត្រូវបានយល់យ៉ាងច្បាស់ថា លក្ខណៈនៃបញ្ហាជួញដូរតម្រូវថា មន្ត្រី និងភ្នាក់ងារទាំងអស់ដែលទទួលបន្ទុកគ្រប់គ្រង និងអនុវត្តច្បាប់សុទ្ធតែចូលពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងការជួញដូរ។ ហេតុនេះ ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពត្រូវពង្រីកវិសាលភាព ដើម្បីបញ្ចូលទីភ្នាក់ងារ និងមន្ត្រីដែលទទួលបន្ទុកគ្រប់គ្រងច្បាប់មួយចំនួន ចាប់ពីវិស័យការងារ រហូតដល់វិស័យនេសាទ។

ទាក់ទងនឹង**ការកំណត់អត្តសញ្ញាណជនរងគ្រោះ៖** ការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាអាស្រ័យទៅលើការយល់ដឹងរួមច្បាស់លាស់ទៅលើកត្តានានានៃបទល្មើសជួញដូរ។ វិធីសាស្ត្រនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដែលត្រូវបានបង្កើតឡើងនៅកម្រិតតំបន់ និងដោយរដ្ឋសមាជិកអាស៊ានមួយចំនួន (សូមមើលបន្ថែម ជំពូកទី ៤) អាចផ្តល់នូវគំរូ និងឧទាហរណ៍មានប្រយោជន៍ដល់រដ្ឋសមាជិកអាស៊ានផ្សេងទៀតដែលនឹងទទួលបានប្រយោជន៍ពីឧបករណ៍នេះ។ រដ្ឋសមាជិកអាស៊ានត្រូវការពារទប់ទល់នឹងភាពទន់ខ្សោយនៅក្នុងដំណើរការកំណត់

អត្តសញ្ញាណ។ ដូចបានកត់សម្គាល់ខាងលើ ការកំណត់អត្តសញ្ញាណខុសបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរ៖ បុគ្គលដែលមិនមែនជាជនជួញដូរត្រូវបានចាប់ខ្លួនចំពោះបទល្មើសជួញដូរ បុគ្គលដែលមិនមែនជាជនរងគ្រោះនៃការជួញដូរត្រូវបានចាត់ទុកជាជនរងគ្រោះ ជនរងគ្រោះនៃការជួញដូរដែលគួរត្រូវបានកំណត់អត្តសញ្ញាណ និងយកចេញពីគ្រោះថ្នាក់ ត្រូវបានទុកឱ្យស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ច និងកាលានុវត្តភាពក្នុងការស្វែងរក និងស៊ើបអង្កេតទៅលើជនបំពានទៅលើពួកគេ បែរជាមិនត្រូវបានយកចិត្តទុកដាក់ទៅវិញ។ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះជាចំហ និងមានតម្លាភាពអាចនៅមានដំណើរយ៉ាងវែងឆ្ងាយឆ្ពោះទៅកាត់បន្ថយនូវហានិភ័យទាំងនេះ។

ទាក់ទងនឹង**ការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ៖** អ្នកដែលស្ថិតនៅកន្លែងកើតហេតុនៃការជួញដូរ ពីដំបូងត្រូវទទួលខុសត្រូវក្នុងការធានាថា ជនរងគ្រោះពីការជួញដូរត្រូវបានបញ្ជូនទាន់ពេលវេលាទៅទីភ្នាក់ងារដែលផ្តល់ដល់ពួកគេនូវជំនួយ ការការពារ និងការគាំទ្រភ្លាមៗដែលពួកគេមានសិទ្ធិទទួលបាន។ រដ្ឋសមាជិកអាស៊ានទាំងឡាយ ដែលមិនបានរៀបចំបែបនេះគួរតែធានាថា នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបទដ្ឋាននីតិវិធីប្រតិបត្តិការបញ្ចូលនូវការណែនាំស្តីពីសកម្មភាពបញ្ជូនទៅស្ថាប័នពាក់ព័ន្ធដែលត្រូវធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់ជួរមុខ។ សូមមើលបន្ថែម ជំពូកទី ៥។

ទាក់ទងនឹង**ការឆ្លើយតបនៃការស៊ើបអង្កេតបឋម៖** វានឹងមានសារៈសំខាន់ សម្រាប់រដ្ឋសមាជិកអាស៊ានដែលត្រូវបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយការលំបាក និងការប្រឈមដែលបានរកឃើញនៅក្នុងជំពូកមុន រួមទាំង ការខកខានរួមក្នុងការជូនដំណឹង និងសហការជាមួយអាជ្ញាធរអយ្យការ និងការខកខានមិនបានកំណត់អត្តសញ្ញាណ កំណត់ទីកន្លែង និងយកចេញពីគ្រោះថ្នាក់នូវជនរងគ្រោះទាំងឡាយដែលកំពុងស្ថិតក្នុងស្ថានភាពនៃការកេងប្រវ័ញ្ច។ ទាំងការបណ្តុះបណ្តាល ទាំងការបង្កើត បទដ្ឋាននីតិវិធីប្រតិបត្តិការនឹងជួយដោះស្រាយនូវការប្រឈមទាំងនេះ និងការប្រឈមផ្សេងទៀត ដូចជាចម្លើយបឋមរបស់សាក្សីដែលមានគុណភាពទាប ការខកខានមិនបានធ្វើការវាយតម្លៃហានិភ័យបឋម និងការខកខានមិនបានកំណត់ និងដោះស្រាយករណីពុករលួយជាដើម។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ជួរមុខ

បើប្រៀបធៀបទៅនឹងតំបន់ផ្សេងទៀតនៅលើពិភពលោក តំបន់អាស៊ានមានគុណសម្បត្តិរឹងមាំ និងពិសេសក្នុងការប្រើប្រាស់ការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញរបស់មន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ។ អត្ថិភាពនៃកម្មវិធីដែលមានការព្រមព្រៀងនៅទូទាំងអាស៊ាន សម្រាប់ក្រុមមន្ត្រីសំខាន់នេះគឺជាសមិទ្ធផលដែលមានសារៈសំខាន់។ ការណ៍ដែលថា នាពេលបច្ចុប្បន្ន កម្មវិធីនេះត្រូវបានផ្តល់ដល់មន្ត្រីអនុវត្តច្បាប់ជួរមុខរាប់ពាន់នាក់នៅក្នុងតំបន់អាស៊ាន គឺជាភស្តុតាងបញ្ជាក់ពីការទទួលយក និងភាពពាក់ព័ន្ធរបស់វាយ៉ាងទូលំទូលាយ។

ប៉ុន្តែ ក៏មានហានិភ័យចំពោះនិរន្តរភាព មួយចំនួននៃគំនិតផ្តួចផ្តើមការបណ្តុះបណ្តាល សម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខ។ មកទល់នឹងពេលនេះ ការបណ្តុះបណ្តាលភាគច្រើនអំពីការជួញដូរមនុស្ស ត្រូវបានធ្វើឡើងដោយមានការគាំទ្រពីខាងក្រៅ។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ភ្នាក់ងារពាក់ព័ន្ធមិនបានទទួលថវិកា ឬការគាំទ្រចំពោះការបណ្តុះបណ្តាលនេះទេ ហើយក៏ពុំចាប់អារម្មណ៍ក្នុងការធានាជាលក្ខណៈស្ថាប័ននៃការបណ្តុះបណ្តាលនេះទេ។ ឧទាហរណ៍ តាមរយៈសាលានគរបាលជាតិ ។ នៅក្នុងករណីមួយចំនួន ចំនុចខ្វះខាតទាំងនេះត្រូវបានបំពេញដោយ អង្គការក្រៅ

រដ្ឋាភិបាល។ នេះជាដំណោះស្រាយមួយផ្នែកដែលទំនងជាផ្តល់នូវព័ត៌មានមួយចំនួនដែលមន្ត្រីអនុវត្តច្បាប់ជួរមុខចាំបាច់ត្រូវបានដើម្បីចែករំលែកទៅដល់ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការប្រមូល និងការគ្រប់គ្រងព័ត៌មានសម្ងាត់

នៅក្នុងតំបន់នេះ ក៏ដូចជាតំបន់ទាំងអស់ផ្សេងទៀតដែរ នាពេលបច្ចុប្បន្ននេះ ទីភ្នាក់ងារ និងមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខមិនបានបំពេញនូវសក្តានុពលរបស់ខ្លួនទាក់ទងនឹងការប្រមូល និងការគ្រប់គ្រងព័ត៌មានសម្ងាត់ទេ។ ការប្រឈមនេះត្រូវគេដោះស្រាយ ជាផ្នែកនៃការពិចារណាទូលំទូលាយពីរបៀបដោះស្រាយចំពោះព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងបទល្មើសគ្រប់ប្រភេទ ដោយទីភ្នាក់ងារនគរបាលជាតិដែលពាក់ព័ន្ធ។ រដ្ឋសមាជិកអាស៊ានទាំងនេះដែលមាន ឬដែលស្ថិតក្នុងដំណើរការអភិវឌ្ឍសមត្ថភាពនៃការប្រមូល និងគ្រប់គ្រងព័ត៌មានសម្ងាត់ធំធេង ត្រូវពិចារណាទៅលើវិសាលភាពនៃបទល្មើសជួញដូរ នៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់។ រដ្ឋសមាជិកអាស៊ានទាំងឡាយដែលមិនទាន់មានសមត្ថភាពទូទៅនេះ ត្រូវធ្វើការផ្តោះទៅការបង្កើតវា ដោយទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់ព័ត៌មានសម្ងាត់នៅក្នុងទិដ្ឋភាពទាំងអស់នៃការអនុវត្តន៍ច្បាប់។

ស្របទៅនឹងកិច្ចខិតខំប្រឹងប្រែងទូលំទូលាយទាំងនេះ ភ្នាក់ងារជួរមុខក៏គួរតែ៖

- ចងក្រងបញ្ជីដៃគូភ្នាក់ងារនានា និងដៃគូខាងក្រៅដែលអាចចូលរួមក្នុងការផ្តល់ចំណេះដឹងស្តីពីការជួញដូរនៅថ្នាក់មូលដ្ឋាន និងបង្កើត និងសម្របសម្រួលនូវការប្រាស្រ័យទាក់ទងការងារជាមួយដៃគូទាំងនេះ
- បង្កើតប្រព័ន្ធតាមដានគេហទំព័រនៃបទល្មើសពាក់ព័ន្ធនឹងការជួញដូរដែលអាចមាន មុនពេលកើតហេតុ
- បង្កើតកិច្ចព្រមព្រៀងជាមួយអង្គភាពឯកទេសប្រឆាំងការជួញដូរ ដោយផ្អែកលើវិធីសាស្ត្ររួមនៃការកត់ត្រា និងផ្សព្វផ្សាយព័ត៌មានសម្ងាត់។

ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃទៅលើស្ថានភាពបច្ចុប្បន្ននៅក្នុងតំបន់អាស៊ានទាំងមូល មានការផ្តល់អនុសាសន៍នូវសកម្មភាពជាក់លាក់នានាដូចខាងក្រោម៖

- រដ្ឋសមាជិកអាស៊ានទាំងអស់គួរធ្វើការផ្តោះទៅការធានាថា មន្ត្រីអនុវត្តច្បាប់ជួរមុខទាំងអស់បានទទួលការបណ្តុះបណ្តាលជាមូលដ្ឋានស្តីពី ការជួញដូរមនុស្សសមស្របទៅនឹងតួនាទីសក្តានុពលរបស់ខ្លួននាពេលបច្ចុប្បន្ន។ សមត្ថភាពស៊ើបអង្កេតឯកទេសដែលមានស្រាប់គួរតែចូលរួមក្នុងការរៀបចំ និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី និងភ្នាក់ងារអនុវត្តច្បាប់ជួរមុខ។
- ការបណ្តុះបណ្តាលគួរតែបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់សម្រាប់មន្ត្រីដែលទើបចូលធ្វើការ និងអ្នកកំពុងបំពេញការងារឲ្យបានច្រើនជាអតិបរមា។ ការបណ្តុះបណ្តាលគួរត្រូវបានពិនិត្យ និងសម្រួលដើម្បីឆ្លុះបញ្ចាំងនូវស្ថានភាពប្រតិបត្តិការ។
- ភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់គួរធានាថា ទីភ្នាក់ងារ និងមន្ត្រីអនុវត្តច្បាប់ជួរមុខបានទទួលការណែនាំចាំបាច់ (ជាទម្រង់នៃគោលការណ៍ណែនាំរបស់ បទដ្ឋាននីតិវិធីប្រតិបត្តិការ ។ល។) ដើម្បីធានាថា ពួកគេអាចកំណត់អត្តសញ្ញាណជនរងគ្រោះ និងផ្តល់ការឆ្លើយតបបឋមឲ្យបានពេញលេញ។

- មន្ត្រីអនុវត្តច្បាប់ជួរមុខគួរតែយល់ដឹងពីលក្ខណៈរសើបនៃបញ្ហាអំពើពុករលួយ និងការសមគំនិតពាក់ព័ន្ធនឹងការជួញដូរ និងហានិភ័យពាក់ព័ន្ធនឹងដំណោះស្រាយ “ក្រៅផ្លូវការ” ចំពោះបណ្តឹងស្តីពីការជួញដូរដែលបណ្តាយឲ្យចារីចៀសផុតពីយុត្តិធម៌។

| ជំពូកទី ៣៖ សមត្ថភាពការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព | |
|---|---|
| លេខយោង | បទដ្ឋានគុណភាព |
| ៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខដឹងពីរបៀបឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងសំណុំរឿងជួញដូរ |
| ៣.១ | បទដ្ឋាននីតិវិធីប្រតិបត្តិការច្បាស់លាស់ដែលគ្រប់គ្រងការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខទៅនឹងសំណុំរឿងជួញដូរមានជាក់ស្ដែង និងកំពុងអនុវត្ត |
| ៣.១.១ | បទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់មន្ត្រីអនុវត្តជួរមុខគ្រប់គ្រងដំណើរការនានាដូចខាងក្រោម៖<br>• ការស៊ើបអង្កេតមុនពេលកើតហេតុ និងការតាមដាននូវវិស័យជួញដូរដែលងាយរងគ្រោះ<br>• នីតិវិធីកំណត់អត្តសញ្ញាណ រួមទាំងការប្រើប្រាស់សូចនាករ និងរចនាសម្ព័ន្ធនៃការស្ដាប់ចម្លើយ<br>• ការថែទាំ និងការពារភ្លាមៗដល់ជនរងគ្រោះរួមទាំងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ<br>• ការការពារសិទ្ធិជនរងគ្រោះ ជាពិសេសសិទ្ធិទទួលបានពេលវេលាវិលទៅរកសភាពដើម និងគិតត្រឡប់<br>• ក្នុងករណីចាំបាច់ផ្នែកប្រតិបត្តិការ ការស្ដាប់ចម្លើយជនរងគ្រោះជាភស្តុតាង ដើម្បីបង្ហាញនូវធាតុផ្សំចាំបាច់នៃការបង្ហាញអំពីបទល្មើសជួញដូរ និងពាក់ព័ន្ធនឹងការជួញដូរ<br>• រក្សាទីកន្លែងកើតហេតុ និងធានាសុវត្ថិភាពនៃភស្តុតាង<br>• បទប្បញ្ញត្តិស្ដីពីការចាប់ខ្លួន ការឆែកឆេរ និងការចាប់យកវត្ថុតាង<br>• ធានាដល់សិទ្ធិរបស់ជនសង្ស័យនៅពេលចាប់ខ្លួន<br>• ការសួរចម្លើយជនសង្ស័យជាមូលដ្ឋានដើម្បីពិនិត្យនូវការចូលរួមរបស់ជនសង្ស័យទៅក្នុងអំពើល្មើស (ដែលចាំបាច់ដល់ប្រតិបត្តិការ)<br>• នីតិវិធីនៃការប្រាស្រ័យទាក់ទងការងារ/ការជូនដំណឹងរវាងភ្នាក់ងារជួរមុខ និង អង្គភាពឯកទេស/ស្ថាប័នដែលត្រូវបានចាត់តាំងផ្សេងទៀត<br>• ការកំណត់អត្តសញ្ញាណ ការប្រមូល ការកត់ត្រា និងការផ្សព្វផ្សាយព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ និងការបញ្ជូនព័ត៌មានសម្ងាត់ទាន់ពេលវេលាទៅអង្គភាពឯកទេស |
| ៣.១.២ | ក្នុងការបង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការសម្រាប់ប្រើប្រាស់ដោយមន្ត្រីអនុវត្តច្បាប់ជួរមុខ អង្គភាពជំនាញកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យនៃសកម្មភាពពុករលួយ និងការសមគំនិត និងធានាថា បទដ្ឋាននីតិវិធីប្រតិបត្តិការបញ្ចូលយន្តការដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យ។ |
| ៣.១.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខជូនដំណឹងដល់អង្គភាពឯកទេស ឬ ជូនដំណឹងទៅអង្គភាពស៊ើបអង្កេតសមស្រប ឬការិយាល័យព្រះរាជអាជ្ញា នៅពេលពុំទាន់មានអង្គភាពឯកទេស អំពីការស៊ើបអង្កេតបឋមពាក់ព័ន្ធនឹងការជួញដូរ និងអនុវត្តតាមការណែនាំដែលបានទទួល។ មន្ត្រីអនុវត្តជួរមុខក៏ជូនដំណឹងទាន់ពេលវេលាផងដែរដល់អង្គភាពឯកទេស អំពីព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងការជួញដូរ។ |
| ៣.១.៤ | សុពលភាពនៃបទដ្ឋាននីតិវិធីប្រតិបត្តិការ និងប្រសិទ្ធភាពនៃការអនុវត្តន៍ទៅលើនីតិវិធីទាំងនោះត្រូវពិនិត្យជាប្រចាំ។ |
| ៣.២ | មន្ត្រីអនុវត្តច្បាប់ជួរមុខមានសមត្ថភាពកំណត់អត្តសញ្ញាណជនរងគ្រោះ និងអ្នកជាជនរងគ្រោះឲ្យបានរហ័ស និងត្រឹមត្រូវ (សូមមើលផងដែរ បទដ្ឋានគុណភាព ៥.១) |

| ជំពូកទី ៣៖ សមត្ថភាពការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព | |
|---|---|
| ៣.២.១ | មាននីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរសម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយឆ្លុះបញ្ចាំងនូវវិធីសាស្ត្រនៃការជួញដូរ។ នីតិវិធី និងគោលការណ៍ណែនាំទាំងនេះគួរត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងត្រូវយកមកពិនិត្យជាបន្ត។ |
| ៣.២.២ | នីតិវិធី និងគោលការណ៍ណែនាំទាំងនេះ ស្របទៅនឹងបទដ្ឋានអន្តរជាតិ និងឧត្តមានុវត្តន៍ដែលអាចទទួលយកបាន និងបញ្ចូលជាអប្បបរមា នូវការប្រើប្រាស់រួមគ្នានូវសូចនាករ និងការស្តាប់ចម្លើយដែលមានរចនាសម្ព័ន្ធ។ |
| ៣.២.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខបានទទួលការបណ្តុះបណ្តាល ដើម្បីបែងចែកឲ្យដាច់នូវការជួញដូរអន្តរជាតិ ពីទម្រង់ទម្រង់ផ្សេងទៀតនៃការធ្វើទេសន្តរប្រវេសន៍ខុសប្រក្រតី និង បែងចែកឲ្យដាច់ស្រឡះនូវជនរងគ្រោះពីការជួញដូរបរទេសទៅនឹងជនទេសន្តរប្រវេសន៍ផ្សេងទៀត។ |
| ៣.២.៤ | មន្ត្រីអនុវត្តច្បាប់ជួរបានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រនៃការជួញដូរ និងចរន្តនៃការជួញដូរបច្ចុប្បន្ននៅថ្នាក់ជាតិ និងថ្នាក់តំបន់។ |
| ៣.២.៥ | មាននីតិវិធីជាលាយលក្ខណ៍អក្សរដែលណែនាំឲ្យមន្ត្រីអនុវត្តច្បាប់ជួរមុខស្តីពីយន្តការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ដើម្បីឲ្យពួកគេអាចបំពេញទៅតាមការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាថា ជនរងគ្រោះពីការជួញដូរបានទទួលការថែទាំ និងការការពារភ្លាមៗ ដោយមិនគិតដល់ថាតើជនរងគ្រោះមាន ឬគ្មានឆន្ទៈ ឬ អាច ឬមិនអាចសហការជាមួយមន្ត្រីអនុវត្តន៍ច្បាប់។ |
| ៣.២.៦ | មន្ត្រីអនុវត្តច្បាប់ជួរមុខបានទទួលការបណ្តុះបណ្តាលអំពីសិទ្ធិស្របច្បាប់ និងជម្រើសផ្នែកយុត្តិធម៌ព្រហ្មទណ្ឌរបស់ជនរងគ្រោះពីការជួញដូរ និង យល់ និងអនុវត្តតាមភារកិច្ចរបស់ខ្លួនដើម្បីការពារសិទ្ធិទាំងនេះ រួមមាន សិទ្ធិទទួលបានថវិវេលាវិលទៅរកសភាពដើមឡើងវិញ និងគិតត្រឡប់ និងជូនដំណឹងទៅជនរងគ្រោះអំពីជម្រើសដែលមានសម្រាប់ពួកគេ ជាភាសាមួយដែលពួកគេអាចយល់បាន។ |
| ៣.២.៧ | មន្ត្រីអនុវត្តច្បាប់ជួរមុខមានការយល់ដឹងជាមូលដ្ឋានពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តពីបទល្មើសទៅលើជនរងគ្រោះពេញវ័យ និងកុមាររងគ្រោះ និងពីរបៀបដែលផលប៉ះពាល់នោះមានឥទ្ធិពលទៅលើសមត្ថភាពរបស់ពួកគេក្នុងការយល់ដឹង និងការឆ្លើយតប។ |
| ៣.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខមានសមត្ថភាពអនុវត្តការទទួលខុសត្រូវផ្នែកស៊ើបអង្កេតបឋមរបស់ខ្លួន នៅពេលប្រឈមនឹងសំណុំរឿងជួញដូរ |
| ៣.៣.១ | ក្នុងករណីចាំបាច់ផ្នែកប្រតិបត្តិការ មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាលស្តីពីការស្តាប់ចម្លើយជនរងគ្រោះជាភស្តុតាងមូលដ្ឋានដែលកំណត់អំពីធាតុផ្សំគន្លឹះនៃភស្តុតាងរបស់បទល្មើស និងសកម្មភាពរបស់អ្នកដែលត្រូវចោទប្រកាន់ថាជាជនសង្ស័យ |
| ៣.៣.២ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាល និងអាចរក្សាទីកន្លែងកើតហេតុ និង ទទួលស្គាល់ និងធានាបាននូវភស្តុតាងពាក់ព័ន្ធនឹងការជួញដូរ |
| ៣.៣.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាល និងអាចប្រើប្រាស់អំណាចចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យពីការជួញដូរ។ |
| ៣.៣.៤ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាល និងដឹងពីសិទ្ធិរបស់ជនសង្ស័យក្រោយពេលចាប់ខ្លួន និងឃុំខ្លួន។ |

| ជំពូកទី ៣៖ សមត្ថភាពការអនុវត្តន៍ច្បាប់របស់មន្ត្រីអនុវត្តច្បាប់ជួរមុខដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព | |
|---|---|
| ៣.៣.៥ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាលឲ្យធ្វើការសួរចម្លើយជនសង្ស័យដែលត្រូវបានចាប់ខ្លួនជាភស្តុតាងមូលដ្ឋាន ដើម្បីស្វែងរកភាពពាក់ព័ន្ធរបស់ពួកគេទៅក្នុងអំពើល្មើស។ |
| ៣.៤ | មន្ត្រីអនុវត្តច្បាប់ជួរមុខមានសមត្ថភាពប្រមូល និងរៀបចំព័ត៌មានសម្ងាត់នៃការជួញដូរ |
| ៣.៤.១ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាល និងអាចកំណត់ និងតាមដានវិស័យជួញដូរដែលងាយរងគ្រោះ និងទទួលស្គាល់សូចនាករនៃព័ត៌មានសម្ងាត់នៃការជួញដូរ ដូចជា វត្តមានរបស់ជនបរទេសដែលធ្វើការក្នុងឧស្សាហកម្មផ្លូវភេទ ឬ វត្តមាននៃកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ និង/ឬ ការផ្តល់ប្រាក់ឈ្នួលជាទៀងទាត់នៅកន្លែងធ្វើការក្នុងករណីពាក់ព័ន្ធ។ |
| ៣.៤.២ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាល និង អាចកត់ត្រា និងអនុត្តនូវម៉ាទ្រីសវាយតម្លៃទៅលើព័ត៌មានសម្ងាត់ អនុលោមទៅតាមបទដ្ឋាននីតិវិធីប្រតិបត្តិការបច្ចុប្បន្ន។ |
| ៣.៤.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខផ្សព្វផ្សាយព័ត៌មានសម្ងាត់ដល់អង្គភាពឯកទេស អនុលោមតាមបទដ្ឋាននីតិវិធីប្រតិបត្តិការ និងបានទាន់ពេលវេលា និងទទួលព័ត៌មានសម្ងាត់បានទាន់ពេលវេលាពីអង្គភាពឯកទេសវិញ។ មន្ត្រីអនុវត្តច្បាប់ជួរមុខក៏ផ្សព្វផ្សាយផងដែរនូវទិន្នន័យព័ត៌មានសម្ងាត់ដល់មូលដ្ឋានទិន្នន័យព័ត៌មានសម្ងាត់នៃបទល្មើសនៅថ្នាក់ជាតិ នៅពេលមានបរិក្ខារនេះ។ |
| ៣.៤.៤ | ការប្រមូល និងការគ្រប់គ្រងព័ត៌មានសម្ងាត់ដោយមន្ត្រីអនុវត្តច្បាប់ជួរមុខ និងការផ្សព្វផ្សាយព័ត៌មាននេះទៅអង្គភាពឯកទេស ត្រូវបានពិនិត្យជាប្រចាំដើម្បីធានានូវប្រសិទ្ធភាព។ |
| ៣.៥ | មន្ត្រីអនុវត្តច្បាប់ជួរមុខទទួលការបណ្តុះបណ្តាលស្តីពីការជួញដូរសមស្របទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ពួកគេដូចបានរៀបរាប់ខាងលើ |
| ៣.៥.១ | ម៉ូឌុលបណ្តុះបណ្តាលលើប្រធានបទក្នុងចំណុច ១, ២ និង ៣ ខាងលើ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលមូលដ្ឋាន និងអ្នកថ្មីថ្មោងរបស់ស្ថាប័ននគរបាល ឬស្ថាប័នផ្នែកសេវាអន្តោប្រវេសន៍។ |
| ៣.៥.២ | មន្ត្រីដែលបានជ្រើសរើសថ្មីទាំងអស់ឲ្យទៅបំពេញការងារនៅផ្នែកសេវាកម្មរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខ ទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការជួញដូរ មុននឹងដាក់ឲ្យបំពេញភារកិច្ច |
| ៣.៥.៣ | មន្ត្រីអនុវត្តច្បាប់ជួរមុខដែលកំពុងបម្រើការងារនៅគ្រប់លំដាប់ទទួលការបណ្តុះបណ្តាលស្តីពីការជួញដូរសមស្របទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ |
| ៣.៥.៤ | មានសមត្ថភាពផ្ទៃក្នុងនៅក្នុង (ឬអាចទទួលបានដោយ) ស្ថាប័នបណ្តុះបណ្តាល ដើម្បីផ្តល់ និងវាយតម្លៃពីផលប៉ះពាល់ និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនេះ។ |

# ជំពូកទី ៤៖ ការឆ្លើយតបដែលរឹងមាំ និងមានព័ត៌មានគ្រប់គ្រាន់ពីអយ្យការ និងតុលាការ

ទោះបីភ្នាក់ងារអនុវត្តន៍ច្បាប់ ទាំងផ្នែកឯកទេស ទាំងមន្ត្រីអនុវត្តច្បាប់ជួរមុខ មានការទទួលខុសត្រូវចម្បងក្នុងការស៊ើបអង្កេតបឋមទៅលើសំណុំរឿងជួញដូរក៏ដោយ តែស្ថាប័នអយ្យការ និងតុលាការជាតិមានសារៈសំខាន់ ដើម្បីធានាថា ការងារដែលផ្នែកអនុវត្តន៍ច្បាប់បានបំពេញ មិនត្រូវបានធ្វើឲ្យខូចខាត ឬទៅជាអាសារឥតការឡើយ។ កង្វះចំណេះដឹង និងការប្តេជ្ញាចិត្តនៅកម្រិតនេះ អាចនាំឲ្យមានរៀបចំមិនបាន និងការបង្ហាញមិនបានល្អនូវការបង្ហាញនៃការចោទប្រកាន់ ការខកខានមិនបានប្រើប្រាស់ និងការពារជនរងគ្រោះឲ្យបានពេញលេញ ការខកខានមិនបានអនុវត្តនីតិវិធីជំនុំជម្រះឲ្យបានសមស្រប និងការផ្តន្ទាទោសមិនត្រឹមត្រូវ។ ជំនឿទុកចិត្តរបស់ជនរងគ្រោះ និងសីលធម៌នៃការអនុវត្តន៍ច្បាប់ និងគុណភាពនៃការស៊ើបអង្កេតនាពេលអនាគត ត្រូវទទួលរង នៅសំណុំរឿងខ្លាំងៗត្រូវបានចាញ់ ឬត្រូវបានដោះស្រាយមិនល្អ ដោយសារភាពទន់ខ្សោយរបស់អយ្យការ និងតុលាការ ឬជាជម្រើសម្យ៉ាងទៀត នៅពេលសំណុំរឿងខ្សោយមិនត្រូវបានកំណត់ និងដោះស្រាយតាមរយៈដំណើរការជំនុំជម្រះ។

ជំពូកនេះ ស្តីពីការឆ្លើយតបរបស់អយ្យការ និងតុលាការ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជំពូកទី ៦ ដែលដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងសាក្សីជាជនរងគ្រោះ។ ជំពូកនោះគួរតែត្រូវយកមកពិគ្រោះយោបល់សម្រាប់ព័ត៌មានលម្អិតទៅលើបញ្ហានាដូចជាការការពារ និងការគាំទ្រ ជនរងគ្រោះដែលបានពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសជាងគឺ ដោយសារបញ្ហាទាំងនេះពាក់ព័ន្ធនឹងព្រះរាជអាជ្ញា និងតុលាការ។

## ៤.១ ធាតុផ្សំសំខាន់ៗនៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពពីអយ្យការ និងតុលាការ

ទម្លាប់អនុវត្តន៍ជាអន្តរជាតិ រួមទាំងបទពិសោធន៍របស់រដ្ឋសមាជិកអាស៊ានជាច្រើនបានបញ្ជាក់ថា តម្រូវការចាំបាច់ដើម្បីធានាថា ចៅក្រម និងព្រះរាជអាជ្ញា នៅក្នុងប្រយោគមួយនៃគោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិ

អាស៊ាន “ទទួលការបណ្តុះបណ្តាលឯកទេសដើម្បីផ្តល់ឲ្យពួកគេនូវចំណេះដឹង និងជំនាញបច្ចេកទេសចាំបាច់ ដើម្បីឲ្យពួកគេអាចបំពេញតួនាទីរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ”[១០២]។

តាមការអនុវត្តន៍ជាក់ស្តែង និងបទពិសោធន៍ក៏បានបញ្ជាក់ផងដែរ ពីតួនាទីសំខាន់របស់ព្រះរាជអាជ្ញា ក្នុងការធានាថា **សាក្សីជាជនរងគ្រោះទទួលជំនួយ និងការគាំទ្រសមស្របមុនពេលជំនុំជម្រះ**។ ព្រះរាជអាជ្ញាចាំបាច់ត្រូវធានាថា ក្នុងអំឡុងពេលមុនការជំនុំជម្រះ ត្រូវរក្សាទំនាក់ទំនងជាប្រចាំ និងញឹកញយជាមួយជនរងគ្រោះ ដើម្បីឲ្យច្បាស់ក្នុងចិត្តថា ជនរងគ្រោះនោះ៖ ទទួលបានព័ត៌មានអំពីស្ថានភាពនៃសំណុំរឿង នៅក្នុងបរិយាកាសសុវត្ថិភាព និងមានសន្តិសុខ រួចផុតពីលទ្ធភាពនៃការគំរាមកំហែង ឬបង្ខូចដោយជនជួញដូរ ហើយបំពេញទៅតាមសេចក្តីត្រូវការជាមូលដ្ឋានរបស់គាត់។

មុនពេលជំនុំជម្រះក្តី ព្រះរាជអាជ្ញាក៏គួរតែបញ្ជាក់ឲ្យច្បាស់ពីការប្រើប្រាស់សក្ខីកម្មមុនសវនាការ ឬនីតិវិធីផ្តល់ចម្លើយមុនពេលជំនុំជម្រះ ដើម្បីកត់ត្រានូវចម្លើយរបស់សាក្សីក្នុងទម្រង់មួយដែលនឹងត្រូវបានទទួលយកជាភស្តុតាងនៅពេលជំនុំជម្រះ ឲ្យបានត្រឹមត្រូវ និងអនុញ្ញាតដោយច្បាប់។ វាជាការសំខាន់ផងដែរដែលថា ព្រះរាជអាជ្ញាគួររៀបចំជនរងគ្រោះ និងសាក្សីផ្សេងទៀតឲ្យបានពេញលេញ ដើម្បីធ្វើជាសាក្សីដែលមានប្រសិទ្ធភាព ដោយជួបផ្ទាល់ៗម្នាក់ៗជាមួយពួកគេមុនពេលជំណុំជម្រះ ដើម្បី៖ ពន្យល់អំពីដំណើរការជំនុំជម្រះក្តី បញ្ជាក់ឲ្យច្បាស់ថា កាតព្វកិច្ចតែមួយគត់របស់ជនរងគ្រោះ និងសាក្សី គឺនិយាយប្រាប់ការពិត ពិនិត្យឡើងវិញនូវខ្លឹមសារនៃសក្ខីកម្មដែលនឹងផ្តល់ ដោយមិនណែនាំឲ្យឆ្លើយតាម និង រៀបចំជនរងគ្រោះ និងសាក្សីដើម្បីឆ្លើយតបតាមការពិតទៅនឹងសំណួររបស់មេធាវីការពារក្តី។

**ការរៀបចំមុនការជំនុំជម្រះ**បានល្អ គឺជាទិដ្ឋភាពសំខាន់មួយទៀតសម្រាប់ការឆ្លើយតបផ្នែកអយ្យការដែលរឹងមាំ។ ជាការសំខាន់ដែលព្រះរាជអាជ្ញាមានពេលវេលាគ្រប់គ្រាន់ដើម្បីទទួលបានសំណុំរឿង និងយកមកពិនិត្យឲ្យបានត្រឹមត្រូវនៅចំពោះមុខតុលាការ។ ជាការសំខាន់ផងដែរដែលថា ព្រះរាជអាជ្ញាចំណាយពេលរៀបចំមុនពេលជំនុំជម្រះនូវការពិនិត្យជនរងគ្រោះ និងសាក្សីដោយផ្ទាល់ ដើម្បីធានាថា សក្ខីកម្មរបស់ពួកគឺមានភាពពេញលេញ ហើយថាធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ត្រូវបានគ្របដណ្តប់យ៉ាងពេញលេញ។ ព្រះរាជអាជ្ញាក៏គួរតែរៀបចំលំដាប់លំដោយនៃសំណួរមុនពេលជំនុំជម្រះដែរ ដើម្បីធានាថាការសួរដេញដោលមានប្រសិទ្ធភាព។ នៅពេលបញ្ចប់ការជំនុំជម្រះ ព្រះរាជអាជ្ញាគួរតែធ្វើសេចក្តីថ្លែងបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់តាមច្បាប់អនុញ្ញាត ដាក់ជូនតុលាការ ដោយសង្ខេបនូវអង្គហេតុពាក់ព័ន្ធ រៀបរាប់អំពីធាតុផ្សំនៃអង្គច្បាប់ដែលយកមកសំអាង និងបង្ហាញថាអង្គហេតុទាំងនេះបានបង្ហាញនូវធាតុផ្សំនីមួយៗមែន។

ការបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជួញដូរ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់**វិធានផ្ទៃក្នុង ដែលគ្រប់គ្រងផ្នែករដ្ឋបាលតុលាការ**ឡើយ។ វិធានទាំងនេះ ដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលត្រូវបានទទួលយកដោយស្ម័គ្រចិត្តដោយរដ្ឋភាគច្រើនលើសលុប បានធានាដល់មនុស្សគ្រប់រូបនូវសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈ

[១០២] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ - ផ្នែក ២៖ កថាខណ្ឌ ២.៥។

ដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលត្រូវបានបង្កើតដោយច្បាប់[១០៣]។ ដូចដែលបានលើកឡើងនៅក្នុងគោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ានថា៖

> អ្នកប្រតិបត្តិឯកទេសគួរសម្របសម្រួលនូវការរៀបចំ និងគ្រប់គ្រងការចោទប្រកាន់ទៅលើការជួញដូរ ដើម្បីធានានូវការអនុវត្តន៍តាមយ៉ាងពេញលេញចំពោះច្បាប់ និងនីតិវិធីពាក់ព័ន្ធ ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ[១០៤]។

ការធានាផ្នែកនីតិវិធីសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានស្គាល់យ៉ាងច្បាស់ និងទទួលយកដោយរដ្ឋសមាជិកអាស៊ាន ហើយត្រូវយកមកអនុវត្តនៅសំណុំរឿងជួញដូរទាំងអស់។ រដ្ឋដែលមិនបានសង្កេតទៅលើបទដ្ឋានទាំងនេះ ប្រឈមនឹងហានិភ័យនៃការប៉ះពាល់ដល់សុចរិតភាព និងកិត្តិយសនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិរបស់ខ្លួន។ ការខកខានទាំងនេះក៏អាចបណ្តាលឱ្យសហគមន៍បាត់បង់ការគាំទ្រដល់ការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើជនជួញដូរ។

ចរន្តថ្មីមួយ ដែលស្របទៅនឹងការអភិវឌ្ឍន៍នៅក្នុងផ្នែកអនុវត្តន៍ច្បាប់ គឺផ្តោះទៅការបង្កើតក្រុមព្រះរាជអាជ្ញា**ឯកទេស**តូចមួយដែលប្រមូលផ្តុំ ដើម្បីដោះស្រាយសំណុំរឿងជួញដូរ និងផ្តល់ការគាំទ្របច្ចេកទេសដល់សហការីក្នុងករណីចាំបាច់។ ការដាក់ពង្រាយក្រុមព្រះរាជអាជ្ញាដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានការប្តេជ្ញាចិត្តចំពោះការងារ អាចចូលរួមចំណែកដល់កម្រិតខ្ពស់នៃសមត្ថភាពក្នុងការឆ្លើយតបដោយអយ្យការ និងអាចមិនលើកទឹកចិត្តដល់អំពើពុករលួយ ដោយការលើកកម្ពស់ភាពវិជ្ជាជីវៈ និងជួយឱ្យបំពេញការងារដែលត្រូវបានតាមដាន និងវាយតម្លៃបានងាយស្រួលជាងមុន។ *ផែនការសកម្មភាពអាស៊ាន* (ឆ្នាំ២០១៥) បានអំពាវនាវឱ្យរដ្ឋសមាជិកធ្វើការ៖

> ចាត់តាំងព្រះរាជអាជ្ញាជំនាញ និងបង្កើតអង្គភាពអយ្យការឯកទេសដែលនឹងដោះស្រាយសំណុំរឿងជួញដូរ បើអាចធ្វើបាន[១០៥]។

គោលការណ៍ណែនាំ*សម្រាប់អ្នកប្រតិបត្តិអាស៊ាន* អះអាងអំពីតម្លៃនៃវិធីសាស្ត្រ ដោយលើកឡើងថា៖

> ភ្នាក់ងារអយ្យការគួរបង្កើតសមត្ថភាពឆ្លើយតបឯកទេសស្របទៅនឹងបន្ទុកការងារបច្ចុប្បន្ន និងដែលបានប្រមើលទុកនាពេលអនាគត។ សមត្ថភាពឯកទេសនេះគួរត្រូវបានផ្តល់តាមរយៈការបង្កើតអង្គភាពអយ្យការឯកទេស ឬតាមរយៈការចាត់តាំងព្រះរាជអាជ្ញាឯកទេសមួយចំនួន ដែលការបណ្តុះបណ្តាល និងការចាត់តាំងអ្នកទាំងនោះគួរ ឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រនៃការប្រព្រឹត្តិបទល្មើសនាពេលបច្ចុប្បន្ន[១០៦]។

---

[១០៣] លិខិតុបករណ៍គន្លឹះនៅក្នុងចំណុចនេះគឺ*កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ដែលត្រូវបានផ្តល់សច្ចាប័នដោយប្រទេសជាង ១៦០។ មាត្រា ១៤ នៃលិខិតុបករណ៍នោះរៀបរាប់នូវការធានាផ្នែកនីតិវិធីសម្រាប់ការជំនុំជម្រះក្នុងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។ *កតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ឯកសារ 999 UNTS 171 ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

[១០៤] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ផ្នែក ៣៖ កថាខណ្ឌ ៣.៥។

[១០៥] ផែនការសកម្មភាពអាស៊ាន IV C (d)។

[១០៦] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ផ្នែក ២៖ កថាខណ្ឌ ២.២។

ភាពឯកទេសនៃមុខងារចោទប្រកាន់ក៏អាចសម្របសម្រួលផងដែរដល់**កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ និងមានប្រសិទ្ធភាពរវាងព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត** ត្រូវបានទទួលស្គាល់នៅក្នុង គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន ថាជាធាតុផ្សំសំខាន់មួយនៅក្នុងការចោទប្រកាន់នៅក្នុងសំណុំរឿងជួញដូរ ប្រកបដោយប្រសិទ្ធភាព[១០៧]។ ក៏ប៉ុន្តែ បទពិសោធន៍បញ្ជាក់ថា កិច្ចសហប្រតិបត្តិការនេះត្រូវដាក់ឲ្យស្ថិតនៅក្នុងការការពារយ៉ាងត្រឹមត្រូវ ឧទាហរណ៍ ដើម្បីបញ្ចៀសការគំរាមកំហែងដោយជនសង្ស័យ ឬតាមណែនាំសាក្សីឲ្យឆ្លើយតាម។

គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ានកំណត់ថា **ភាពឯកទេសក៏អាចលាតសន្ធឹងទៅដល់តុលាការដែរ** ដោយកត់សម្គាល់ថា៖

> ចៅក្រមមួយចំនួន ស្របទៅនឹងបន្ទុកការងារបច្ចុប្បន្ន និងត្រូវបានប្រមើលមើល គួរត្រូវបានរៀបចំ និងបង្កើតជាពិសេស ដើម្បីធ្វើការគ្រប់គ្រង និងការវិនិច្ឆ័យទៅលើការជំនុំជម្រះពាក់ព័ន្ធនឹងការជួញដូរមនុស្ស[១០៨]។

ទោះបីភាពឯកទេសអាចនាំប្រយោជន៍សំខាន់ក៏ដោយ តែវាក៏អាចនាំយកនូវ**ហានិភ័យ**មួយចំនួនដែរ។ ការដឹកនាំច្បាស់លាស់ និងមានតម្លាភាព និងការតាមដានប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់ ដើម្បីធានាថាភាពឯកទេសនៃមុខងារអយ្យការមិនបានផ្តល់កាលានុវត្តភាពសម្រាប់អំពើពុករលួយទេ។ ហានិភ័យនៃការយកច្បាប់មកអនុវត្តមិនត្រឹមត្រូវ តាមរយៈការជ្រៀតជ្រែកផ្នែកនយោបាយ និងអំណរសាទរជ្រុលពេកក្នុងការសម្រេចឲ្យបាននូវគោលដៅចោទប្រកាន់ដែលមានមហិច្ឆតាមិនត្រឹមត្រូវ និងហួសពីការពិត ក៏ត្រូវទទួលស្គាល់ និងរៀបចំមុនពេលកើតហេតុដែរ។ នេះជាបញ្ហាបន្តមាននៅក្នុងតំបន់អាស៊ាន ហើយនៅក្នុងប្រទេសមួយចំនួន បន្តជាមូលហេតុនាំមកនូវការព្រួយបារម្ភដែរ។

## ៤.២ ខ្លួនភាពរបស់អាស៊ានឆ្ពោះទៅការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពពីស្ថាប័នអយ្យការ និងស្ថាប័នតុលាការ

ឧបសគ្គមួយចំនួនចំពោះការយល់ដឹងពីលក្ខណៈនៃការឆ្លើយតបផ្នែកអយ្យការ និងតុលាការចំពោះការជួញដូរមនុស្ស នៅក្នុងតំបន់អាស៊ាន គឺភាពកម្រព័ត៌មានអំពីការគ្រប់គ្រងការចោទប្រកាន់ពីការជួញដូរ និងការជំនុំជម្រះ។ នៅក្នុងស្ថានភាពមួយចំនួនការទទួលបានសំណុំរឿងពីខាងក្រៅត្រូវបានកម្រិត ដោយសារការព្រួយបារម្ភសមហេតុផលអំពីការសម្ងាត់ និងឯកជនភាពនៃសំណុំរឿង។ នៅក្នុងស្ថានភាពផ្សេងទៀត វិធីប្រមូល និងរក្សាទុកទិន្នន័យសំណុំរឿងរារាំងដល់ការទទួលបានទិន្នន័យសំខាន់ៗ។ ហេតុនេះ ការវិភាគខាងក្រោមទោះបីដកស្រង់ចេញពីប្រភពជាច្រើនក៏ដោយ តែមិនទាន់បានពេញលេញទេ។ ឧទាហរណ៍ នៅមានព័ត៌មានល្អៗអំពីការបណ្តុះបណ្តាលដល់ព្រះរាជអាជ្ញា និង

[១០៧] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ផ្នែក ៣៖ កថាខណ្ឌ ៣.១។

[១០៨] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ផ្នែក ២៖ កថាខណ្ឌ ២.៣។

ចៅក្រម។ម្យ៉ាងវិញទៀត ព័ត៌មានអំពីកិច្ចសហប្រតិបត្តិការរវាងព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត និងនៅពេលធ្វើការជំនុំជម្រះ ជារឿងមួយដាច់ដោយឡែក និងជារឿងសំខាន់ផងដែរ។

*ប្រអប់អត្ថបទ ១៣៖ សមិទ្ធិផលសំខាន់ៗរបស់អាស៊ានពាក់ព័ន្ធនឹងការឆ្លើយតបរបស់តុលាការ និងអយ្យការទៅនឹងការជួញដូរ*

> នៅក្នុងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១១ ការវិភាគសំណុំរឿង និងការសង្កេត ព្រមទាំងការសហការជាមួយព្រះរាជអាជ្ញា និងចៅក្រម រួមមាន តាមរយៈការបណ្តុះបណ្តាល បានបង្ហាញនូវកែលម្អមួយចំនួន រួមមាន៖
>
> - ការយល់ដឹងកាន់តែប្រសើរក្នុងចំណោមព្រះរាជអាជ្ញា និងចៅក្រមដែលមានមានការរីកចម្រើនខ្លាំងនៃការជួញដូរមនុស្ស ដែលមានឥទ្ធិពលទៅលើផ្ទះ និងលទ្ធភាពរបស់ជនរងគ្រោះក្នុងការសហការជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងតម្រូវការចាំបាច់ដែលជនរងគ្រោះត្រូវទទួលបានការគាំទ្រ និងការពារ
> - ការកើនឡើងនូវការយល់ដឹងពីអត្ថប្រយោជន៍របស់អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាដែលធ្វើការ កាន់តែមានភាពជិតស្និទ្ធ និងធ្វើការជាក្រុម នៅក្នុងសំណុំរឿងទាំងនេះ។
>
> ចាប់តាំងពីពេលនោះមក មានការអភិវឌ្ឍន៍ផ្សេងទៀតរួមមាន៖
>
> - ការទទួលស្គាល់យ៉ាងធំធេងដោយព្រះរាជអាជ្ញា និងតុលាការ អំពីតម្រូវការចាំបាច់ដើម្បីគាំទ្រ និងផ្តល់អំណាចដល់សាក្សីជាជនរងគ្រោះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងភាពរសើបក្នុងការដោះស្រាយបញ្ហាសាក្សីជាជនរងគ្រោះ។
> - កែលម្អការការពារជនរងគ្រោះមុនពេលជំនុំជម្រះ និងនៅក្នុងតុលាការ។

## វឌ្ឍនភាពទាក់ទងនឹងការកសាងសមត្ថភាពរបស់ព្រះរាជអាជ្ញា និងចៅក្រម

បើប្រៀបធៀបជាមួយអ្នកស៊ើបអង្កេតឯកទេស និងមន្ត្រីអនុវត្តច្បាប់ជួរមុខ ស្ថាប័នព្រះរាជាអាជ្ញា និងចៅក្រមនៅក្នុងតំបន់អាស៊ាន មានការប្រឈមនឹងបញ្ហាជួញដូរតិចតួចជាង ហើយមានការបណ្តុះបណ្តាល និងការគាំទ្រតិចតួចណាស់នៅក្នុងស្ថាប័ននេះ។ ក៏ប៉ុន្តែ ស្ថានភាពនេះកំពុងមានការផ្លាស់ប្តូរ និងមានការអភិវឌ្ឍន៍សំខាន់ៗចាប់តាំងពីការកែសម្រួលលើកទីមួយទៅលើ*របាយការណ៍វឌ្ឍនភាព*។

តាមរយៈ SOMTC រដ្ឋសមាជិកអាស៊ានបានធ្វើការបង្កើត ដាក់ឲ្យអនុវត្តសាកល្បង និងអនុម័តនូវសម្ភារបណ្តុះបណ្តាលមួយចំនួនសម្រាប់ព្រះរាជអាជ្ញា និងចៅក្រម។ កម្មវិធីបណ្តុះបណ្តាល ដែលត្រូវបានបង្កើតឡើងដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយព្រះរាជអាជ្ញាអាស៊ាន រួមមានកម្មវិធីចំនួន ២ គឺ៖ *កម្មវិធីយល់ដឹងទូទៅ* មានគោលបំណងសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ និង *កម្មវិធីលម្អិតផ្អែកលើជំនាញជាមូលដ្ឋាន* ដែលមានគោលបំណងសម្រាប់ព្រះរាជអាជ្ញាដែលមានឯកទេសក្នុងសំណុំរឿងជួញដូរ ឬដែលរំពឹងថានឹងមានឯកទេសលើសំណុំរឿងទាំងនេះនាពេលអនាគត។

កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញា និងចៅក្រម

កម្មវិធីជំនាញអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ព្រះអាជ្ញាឯកទេស (ឆ្នាំ២០១០)

កម្មវិធីការយល់ដឹងអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ចៅក្រម និង ព្រះរាជអាជ្ញា (ឆ្នាំ២០០៨)

*កម្មវិធីការយល់ដឹងអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា*ត្រូវបានសម្រួល និងប្រើប្រាស់នៅក្នុង រដ្ឋសមាជិកអាស៊ានភាគច្រើន សម្រាប់ការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា។

*កម្មវិធីការយល់ដឹង*ត្រូវបានបង្កើតឡើងដើម្បីសម្រប ដល់ការប្រើប្រាស់នៅថ្នាក់ជាតិ និងរៀបចំបញ្ចូលទៅក្នុងសាលាបណ្តុះបណ្តាលថ្នាក់ជាតិ។ ចំណុចនេះបានកើតឡើងនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន។ ឧទាហរណ៍ សាលាបណ្ឌិត្យសភាវិជ្ជាជីវៈចៅក្រមនៅ**ប្រទេសកម្ពុជា** បានច្របាច់បញ្ចូលកម្មវិធីនេះ ទៅក្នុងកម្មវិធីបណ្តុះបណ្តាលដល់ចៅក្រម និងព្រះរាជអាជ្ញាដែលកំពុងបំពេញការងារ និងព្រះរាជអាជ្ញា និងចៅក្រមថ្មី។ ស្រដៀងគ្នាដែរ ការបណ្តុះបណ្តាលស្តីពីការជួញដូរមនុស្ស ត្រូវបានបញ្ចូលទៅក្នុងការបណ្តុះបណ្តាលផ្នែកចោទប្រកាន់នៅ**ប្រទេសកម្ពុជា** និង **វៀតណាម**។

ទោះបីការបណ្តុះបណ្តាលនូវការយល់ដឹងជាមូលដ្ឋានមានសារៈសំខាន់ ដល់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ក្តី តែជាការសំខាន់ដែលត្រូវទទួលស្គាល់សេចក្តីត្រូវការ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិនីមួយៗ ឲ្យមានអ្នកជំនាញដែលមានចំណេះដឹង និងជំនាញពាក់ព័ន្ធដែលស៊ីជម្រៅ។ *កម្មវិធីជំនាញអាស៊ានស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញាឯកទេស* ត្រូវបានបង្កើតឡើងដើម្បីយកមកសម្រួលប្រើប្រាស់នៅថ្នាក់ជាតិ ហើយបន្ទាប់មកត្រូវបានបញ្ចូលទៅក្នុងស្ថាប័នបណ្តុះបណ្តាលជាតិ។ មានវឌ្ឍនភាពមួយចំនួនក្នុងចំណុចនេះ។ ឧទាហរណ៍ នៅ**ប្រទេសកម្ពុជា** រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការបានសម្រួលយកកម្មវិធីឯកទេសអាស៊ានទៅក្នុងបរិបទកម្ពុជា។ វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT) ជាស៊េរី ដែលមានមូលដ្ឋាននៅក្នុងកម្មវិធីឯកទេសអាស៊ានត្រូវបានដំណើរការ។ គិតមកត្រឹមខែធ្នូ ឆ្នាំ២០១៧ មានព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតចំនួន ៣០ រូបត្រូវបានបណ្តុះបណ្តាលជាគ្រូបង្គោលផ្នែកជួញដូរមនុស្ស។ គ្រូបង្គោលរំពឹងថាបន្តបណ្តុះបណ្តាលព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតជំនាន់ក្រោយៗទៀត។

**ប្រទេសថៃ** (ការិយាល័យអគ្គមេធាវី) បានដំណើរការវគ្គបណ្តុះបណ្តាលយ៉ាងទូលំទូលាយដល់ព្រះរាជអាជ្ញារបស់ខ្លួន (ទាំងការយល់ដឹងទូទៅ និងឯកទេសពិសេស) ព្រមទាំងសិក្ខាសាលាជាស៊េរី ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការឲ្យកាន់តែច្រើន និងប្រសើរជាងមុនរវាងផ្នែកអនុវត្តន៍ច្បាប់ និងព្រះរាជអាជ្ញានៅក្នុងសំណុំរឿងជួញដូរមនុស្ស។ ប្រទេសថៃក៏បានបង្កើតសៀវភៅស្តីពីបទដ្ឋាននីតិវិធីប្រតិបត្តិការស្តីពីការជួញដូរសម្រាប់ព្រះរាជអាជ្ញា ដោយប្រើប្រាស់សម្ភារកម្មវិធីអាស៊ាន។ នាពេលថ្មីៗនេះ នីតិវិធីទាំងនេះកំពុងត្រូវបានកែសម្រួល។ បច្ចុប្បន្ននេះក៏កំពុងបង្កើតនូវការចងក្រងច្បាប់ករណីសិក្សាអំពីការជួញដូរមនុស្ស សម្រាប់ឲ្យព្រះរាជអាជ្ញាយកទៅប្រើប្រាស់ដែរ។

យ៉ាងហោចណាស់មាន រដ្ឋសមាជិកអាស៊ានមួយគឺ **ប្រទេសឡាវ** មិនដំណើរការបណ្តុះបណ្តាលព្រះរាជអាជ្ញាទេ តែមានកម្មវិធីបណ្តុះបណ្តាលចៅក្រមស្តីពីការជួញដូរមនុស្ស ដែលទទួលការគាំទ្រដល់អនុប្រធានតុលាការកំពូលប្រជាជន (ខែធ្នូ ឆ្នាំ២០១៧)។ ក៏ប៉ុន្តែទូទៅជាងនេះទៀត មានការកើនឡើងជាខ្លាំងនូវការបណ្តុះបណ្តាលដល់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងតំបន់អាស៊ានទាំងមូល។ ខាងក្រោមគឺជាលើកឡើងនូវបទពិសោធន៍ជាច្រើនឆ្នាំកន្លងមក។

**ប្រទេសប្រ៊ុយណេ**បានបណ្តុះបណ្តាលព្រះរាជអាជ្ញាក្នុងការដោះស្រាយសំណុំរឿងជួញដូរមនុស្ស។ ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌប្រទេសនេះក៏បានចេញសៀវភៅស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញាដែរ។ សៀវភៅនេះត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យព្រះរាជអាជ្ញាមានភាពស្ទាត់ជំនាញនឹងបញ្ហាជួញដូរ រួមមានភាពខុសគ្នារវាងការជួញដូរមនុស្ស និងការរត់ពន្ធមនុស្សទេសន្តរប្រវេសន៍ និងដំណើរការពាក់ព័ន្ធចាប់តាំងពីការរកឃើញបទល្មើសរហូតដល់ការជំនុំជម្រះ ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។

**ប្រទេសឥណ្ឌូនេស៊ី** បានចូលរួមក្នុងការអភិវឌ្ឍន៍សមត្ថភាពទូលំទូលាយដល់ព្រះរាជអាជ្ញារបស់ខ្លួន ការបណ្តុះបណ្តាលទាំងព្រះរាជអាជ្ញាដែលទើបនឹងចូលថ្មី និងអ្នកកំពុងបម្រើការ ដើម្បីដោះស្រាយសំណុំរឿងជួញដូរមនុស្ស។ ចាប់តាំងពីឆ្នាំ២០១៤ មក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងអប់រំព្រះរាជអាជ្ញាបានផ្តល់នូវម៉ូឌុលពិសេសស្តីពីការជួញដូរដល់ព្រះរាជអាជ្ញាដែលទើបនឹងជ្រើសរើសថ្មីៗចំនួន ៤៥០ រូប និងព្រះរាជអាជ្ញាដែលមានបទពិសោធន៍ចំនួន ៤០ រូបជារៀងរាល់ឆ្នាំ។

នៅ**ប្រទេសហ្វីលីពីន** សម្ភារបណ្តុះបណ្តាលអាស៊ានត្រូវបានយកមកប្រើប្រាស់ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់ព្រះរាជអាជ្ញា ចៅក្រម អ្នកស៊ើបអង្កេត និងមន្ត្រីសង្គមកិច្ច។ សាលាបណ្ឌិត្យសភាពតុលាការ (PHILJA) បានបណ្តុះបណ្តាលគ្រូបង្គោលឱ្យផ្តល់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការជួញដូរមនុស្សទាំងកម្រិតមូលដ្ឋាន ទាំងកម្រិតខ្ពស់។ គ្រូបង្គោលថ្នាក់ជាតិផ្តល់នូវកម្មវិធីផ្អែកលើជំនាញរបស់អាស៊ានជាលំនាំនៅមូលដ្ឋានសម្រាប់ព្រះរាជអាជ្ញា តាមរយៈក្រសួងយុត្តិធម៌ និងក្រុមការងារប្រឆាំងការជួញដូរ។ ប្រទេសហ្វីលីពីនក៏បានបង្កើតឧបករណ៍ និងធនធានជាច្រើនដើម្បីគាំទ្រដល់ព្រះរាជអាជ្ញាក្នុងការដោះស្រាយសំណុំរឿងជួញដូរមនុស្ស។

នៅ**ប្រទេសវៀតណាម** ក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលបានធ្វើការជាមួយអង្គការអន្តរជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ សម្រាប់ព្រះរាជអាជ្ញាចំនួន ៣៨ រូបដែលកំពុងបំពេញការងារនៅថ្នាក់ស្រុក រៀបចំសិក្ខាសាលាមួយសម្រាប់ព្រះរាជអាជ្ញាចំនួន ២៥ រូបស្តីពីឧត្តមានុវត្តន៍ប្រឆាំងការជួញដូរ និងវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ព្រះរាជអាជ្ញាគ្រប់គ្រងចំនួន ២៥ រូប។

ការបណ្តុះបណ្តាលរួមគ្នាសម្រាប់អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាត្រូវបានធ្វើឡើងតាមរយៈកម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែនសម្រាប់**ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ** និង**វៀតណាម**។ កម្មវិធីនេះត្រូវបានបង្កើតឡើងដើម្បីជួយសិក្ខាកាមក្នុងការកំណត់ និងវាយតម្លៃទៅលើការប្រឈមផ្នែកច្បាប់ នីតិវិធី និងប្រតិបត្តិការសំខាន់ដែលពួកគេនឹងប្រឈមនៅពេលបំពេញការងារនៅកម្រិតឆ្លងដែន និងអភិវឌ្ឍសមត្ថភាពពួកគេដើម្បីបំពេញទៅតាមការប្រឈមទាំងនោះ ហើយក្នុងករណីសមស្រប នឹងបង្កើតវិធីសាស្ត្រកិច្ចសហប្រតិបត្តិការថ្មីៗ។

កម្មវិធីបណ្តុះបណ្តាលអាស៊ាន ស្តីពីការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុនៅក្នុងសំណុំរឿងជួញដូរមនុស្សត្រូវបានផ្តល់ដល់ចៅក្រម អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញានៅ**ប្រទេសឥណ្ឌូនេស៊ី** និង**ហ្វីលីពីន**។ កម្មវិធីនេះត្រូវបានបង្កើតឡើងដើម្បីជួយដល់អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាឯកទេសនាពេលបច្ចុប្បន្ន និងទៅអនាគត ដើម្បីពង្រឹងនូវសមត្ថភាពជំនាញផ្នែកជួញដូរមនុស្ស ដែលមានស្រាប់ តាមរយៈការអនុវត្តន៍បច្ចេកទេសស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ដើម្បីធានានូវការរឹបអូសដល់ទ្រព្យដែលបានពីបទល្មើសជួញដូរមនុស្ស ការបាត់បង់សិទ្ធិលើមធ្យោបាយបទល្មើស និងក្នុងករណីសមស្រប ដើម្បីធានាការចោទប្រកាន់ឲ្យបានជោគជ័យចំពោះបទល្មើសពាក់ព័ន្ធនឹងការសម្អាតប្រាក់។

## វឌ្ឍនភាពឆ្ពោះទៅភាពឯកទេសនៃមុខងារអយ្យការ

ដូចបានកត់សម្គាល់ខាងលើ អាស៊ាន និងរដ្ឋសមាជិករបស់ខ្លួនបានទទួលស្គាល់ថា អង្គភាពឯកទេសរួមមានព្រះរាជអាជ្ញាឯកទេស និងបុគ្គលិកជំនួយ អាចជួយគាំទ្រដល់ការឆ្លើយតបតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរកាន់តែមានប្រសិទ្ធភាព។ ចាប់តាំងពីការកែសម្រួលចុងក្រោយចំពោះរបាយការណ៍វឌ្ឍនភាព មានវឌ្ឍនភាពសំខាន់ៗទៅលើទិដ្ឋភាពនៃការឆ្លើយតបទៅនឹងការជួញដូរ។ ឧទាហរណ៍ ដូចដែលនឹងបង្ហាញនៅក្នុងប្រអប់អត្ថបទខាងក្រោម **ប្រទេសថៃ**បានបង្កើតអង្គភាពព្រះរាជអាជ្ញាជំនាញសម្រាប់សំណុំរឿងជួញដូរមនុស្ស នៅក្នុងការិយាល័យអគ្គមេធាវីនៅឆ្នាំ២០១៥។

### *ប្រអប់អត្ថបទ ១៤៖ មុខងារអយ្យការឯកទេសនៅប្រទេសថៃ*

អង្គភាពព្រះរាជអាជ្ញាឯកទេសជួញដូរមនុស្ស នៅក្នុងការិយាល័យអគ្គមេធាវីត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥។ អង្គភាពនេះបែងចែកជាពីរផ្នែកគឺ៖ មួយផ្នែកសម្រាប់ដោះស្រាយការជំនុំជម្រះ និងមួយផ្នែកទៀតសម្រាប់ដោះស្រាយបញ្ហាយុទ្ធសាស្ត្រ និងទិន្នន័យ។

ផ្នែកជំនុំជម្រះ ដែលបានលាតសន្ធឹងយ៉ាងឆាប់រហ័សក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ មានមុខងារខាងស៊ើបអង្កេតផង និងចោទប្រកាន់ផង។ ការិយាល័យយុទ្ធសាស្ត្រ និងមូលដ្ឋានទិន្នន័យក៏ទទួលខុសត្រូវក្នុងការបង្កើត និងផ្តល់ការបណ្តុះបណ្តាលដល់ព្រះរាជអាជ្ញា។ ផ្នែកនេះក៏កំពុងរៀបរៀងគោលការណ៍ណែនាំដើម្បីគាំទ្រដល់វិធីសាស្ត្រក្នុងការចោទប្រកាន់ក្នុងសំណុំរឿងជួញដូរមនុស្សឲ្យកាន់តែមានលក្ខណៈវិជ្ជាជីវៈ និងស្របគ្នាដែរ។

សមិទ្ធិផលចម្បងនាពេលបច្ចុប្បន្នរបស់អង្គភាពនេះគឺការចោទប្រកាន់ចុងចោទចំនួន ១៣០ នាក់ (រួមមានមន្ត្រីរដ្ឋាភិបាល មន្ត្រីយោធា និងអ្នកស៊ើបអង្កេតផ្នែកនគរបាល) សម្រាប់ការជួញដូរ និងការគេងប្រវ័ញ្ចជនភៀសខ្លួនមកពីប្រទេសមីយ៉ាន់ម៉ា។ សំណុំរឿងពាក់ព័ន្ធនឹងសាក្សីជាង ២០០ នាក់។ ព្រះរាជអាជ្ញានៅក្នុងអង្គភាពនេះបានបើកការស៊ើបអង្កេតរួមគ្នាជាមួយភ្នាក់ងារអនុវត្តន៍ច្បាប់ និងការិយាល័យប្រឆាំងការសម្អាតប្រាក់ ហើយបានបង្កើតប្រព័ន្ធគ្រប់គ្រងឯកសារថ្មីមួយ ដើម្បីដោះស្រាយភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់។ លទ្ធផលចុងក្រោយ នៅសាលាដំបូង មានការផ្តន្ទាទោសចំនួន ៦២ ករណី។

**ប្រទេសហ្វីលីពីន** ក៏បានបង្កើតក្រុមប្រមូលផ្តុំព្រះរាជអាជ្ញានៅក្នុងក្រសួងយុត្តិធម៌របស់ខ្លួន ដែលមានឯកទេសក្នុងការបើកសវនាការបឋមក្នុងអង្គសេចក្តី និងធ្វើការសម្រេចចិត្តចោទប្រកាន់នៅក្នុងសំណុំរឿងជួញដូរមនុស្ស។ នៅឆ្នាំ២០១៦ ក្រសួងយុត្តិធម៌បានចេញដីកាមួយដោយតែងតាំងព្រះរាជអាជ្ញាចំនួន ១៦៩ រូប ពីតំបន់ចំនួន ១៧ ឲ្យកាន់

សំណុំរឿងជួញដូរមនុស្ស បន្ថែមទៅលើភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនជាប្រចាំ។ **ប្រទេសឥណ្ឌូនេស៊ី** ក៏មានក្រុមរដ្ឋអាជ្ញាតូចមួយដែលប្រមូលផ្តុំនៅក្នុងការិយាល័យអគ្គមេធាវីនៅក្រុងហ្សាការតា ដោយមានឯកទេសពិសេសក្នុងការចោទប្រកាន់បទល្មើសឆ្លងដែនរួមទាំង ការជួញដូរមនុស្សផងដែរ។ ព្រះរាជអាជ្ញាទាំងនោះត្រូវបានចាត់តាំងឲ្យកាន់ និងជួយសំណុំរឿងជួញដូរជាប្រចាំ (សំណុំរឿងនៅតុលាការភាគច្រើននៅប្រទេសឥណ្ឌូនេស៊ីត្រូវបានជំនុំជម្រះនៅក្នុងតុលាការនៅជុំលំនៅដ្ឋានជនរងគ្រោះ ហេតុនេះការចោទប្រកាន់ជាធម្មតានឹងធ្វើឡើងនៅក្នុងមណ្ឌលថ្នាក់តំបន់ឆ្ងាយពីក្រុងហ្សាការតា)។ **ប្រទេសម៉ាឡេស៊ី** រាយការណ៍ថា គិតមកត្រឹមឆ្នាំ២០១៨ មានព្រះរាជអាជ្ញារងសាធារណៈ (DPPs) ចំនួន ៥៤ រូប បានទទួលការបណ្តុះបណ្តាលឲ្យកាន់សំណុំរឿងជួញដូរមនុស្ស។ មន្ទីរអគ្គមេធាវីក៏បានបើកវគ្គបណ្តុះបណ្តាលសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាក្នុងទូទាំងប្រទេសម៉ាឡេស៊ី ដើម្បីពិភាក្សាពីវិធីសាស្ត្រក្នុងការចោទប្រកាន់។ ប្រធានបទនានាត្រូវបានបញ្ចូលទៅក្នុងការស្តាប់ចម្លើយ ការកំណត់អត្តសញ្ញាណ និងបំពេញទៅតាមតម្រូវការចាំបាច់របស់ជនរងគ្រោះ និងធ្វើការជាមួយអ្នកបកប្រែ។

នៅថ្នាក់តំបន់ រដ្ឋអាជ្ញាមកពីរដ្ឋសមាជិកអាស៊ានទាំង ១០ បានជួបប្រជុំគ្នានៅប្រទេសសិង្ហបុរីនៅខែកក្កដា ឆ្នាំ២០១១ ក្នុងគោលបំណងជាក់លាក់គឺការពិភាក្សាអំពីភាពឯកទេសនៃមុខងារអយ្យការទាក់ទិននឹងសំណុំរឿងជួញដូរមនុស្ស។ អ្នកប្រតិបត្តិនៅអាស៊ានបានពិភាក្សានូវគំនិត កាលានុវត្តភាព និងការប្រឈមជាច្រើនជាមួយព្រះរាជអាជ្ញាមកពីទ្វីបអាហ្វ្រិក អាស៊ី និងអាមេរិកខាងជើង ដែលកំពុងធ្វើការនៅក្នុងវិស័យឯកទេសរួចហើយ។ អនុសាសន៍មួយចំនួនពីកិច្ចប្រជុំនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការអភិវឌ្ឍន៍នៅថ្នាក់ជាតិ ដូចបានកត់សម្គាល់ខាងលើ។ ក៏ប៉ុន្តែ នៅពុំទាន់មានវឌ្ឍនភាពក្នុងការបង្កើតវេទិកាតាមការផ្តល់យោបល់ ដែលព្រះរាជអាជ្ញាមកពីតំបន់នេះអាចជួបប្រជុំគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍នៅឡើយទេ។

## វឌ្ឍនភាពទាក់ទិននឹងកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា

ដូចបានកត់សម្គាល់នៅក្នុងផ្នែក ៤.១ ឧត្តមានុវត្តន៍ជាអន្តរជាតិបានទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាចាប់ពីដំណាក់កាលដំបូងបង្អស់នៃការស៊ើបអង្កេត អាចជួយធានាថា យុទ្ធសាស្ត្រនៃការស៊ើបអង្កេតត្រូវបានយល់ដឹងយ៉ាងច្បាស់ ការចាប់ខ្លួនត្រូវបានគាំទ្រដល់ភស្តុតាងគ្រប់គ្រាន់ ហើយថាមានការប្រមូលភស្តុតាងត្រឹមត្រូវអនុលោមទៅតាមច្បាប់ និងនីតិវិធីពាក់ព័ន្ធ ដោយសារមានការការពារចាំបាច់។ នៅក្នុងតំបន់អាស៊ាន ប្រភេទកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាបន្តមានជាកម្រ។ វិធាននៃនីតិវិធី ឬការអនុវត្តន៍ជាយូរអង្វែងដែលជំរុញឲ្យបែងចែងនូវមុខងារស៊ើបអង្កេត និងចោទប្រកាន់ត្រូវបានដកស្រង់ជាញឹកញយ ជាមូលដ្ឋានសម្រាប់ភាពពុំមានកិច្ចសហប្រតិបត្តិការ។ ក៏ប៉ុន្តែ វាអាចកត់សម្គាល់នូវឧទាហរណ៍នៃកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ ហើយចរន្តនៅក្នុងទិសដៅនេះនៅកម្រិតគោលនយោបាយ។ ឧទាហរណ៍ទាំងអស់ផ្តល់ជាយោបល់ថាអាចរកឃើញ និងលើកម្ពស់មធ្យោបាយនៃកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា នៅពេលមានការយល់ដឹងពីផលប្រយោជន៍ជាសក្តានុពល និងឆន្ទៈពីភាគីទាំងពីរក្នុងការគាំទ្រដល់កិច្ចសហប្រតិបត្តិការនេះ។

នៅ**ប្រទេសឥណ្ឌូនេស៊ី** ជាគោលការណ៍ អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាអាចសហការគ្នាយ៉ាងជិតស្និទ្ធ ដែលអ្នកស៊ើបអង្កេតអាចទាក់ទង និងពិគ្រោះយោបល់ជាមួយព្រះរាជអាជ្ញាទៅលើសំណុំរឿង រួមទាំងប្រភេទភស្តុតាងដែលត្រូវប្រមូល និងមាត្រានានាក្នុងច្បាប់ស្តីពីការជួញដូរមនុស្ស ដែលគួរយកមកប្រើ។ ក៏ប៉ុន្តែ ភាពញឹកញាប់ និងគុណភាព

នៃកិច្ចសហប្រតិបត្តិការពឹងផ្អែកជាខ្លាំងទៅលើ ថាតើ ទំនាក់ទំនងមានភាពចាំបាច់ ឬទេ។ ក្នុងរយៈកាលច្រើនឆ្នាំមកនេះ ការគាំទ្រពីខាងក្រៅត្រូវបានផ្ដល់ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ពិសេសក្នុងអំឡុងពេលនៃការស៊ើបអង្កេតលើការជួញដូរមនុស្ស នៅដំណាក់កាលដំបូង។ ប្រទេសឥណ្ឌូនេស៊ី បានរាយការណ៍ថា កិច្ចសហប្រតិបត្តិការពីដំបូង និងយ៉ាងជិតស្និទ្ធរវាងអ្នកស៊ើបអង្កេតឯកទេស និងព្រះរាជអាជ្ញានៅក្នុងសំណុំរឿងជួញដូរមនុស្ស នាំឱ្យមានកំណើននូវចំនួនសំណុំរឿងដែលត្រូវបានទទួលយកដើម្បីចោទប្រកាន់។ ឧទាហរណ៍នាពេលថ្មីៗនេះរួមមានសំណុំរឿងមួយពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចទៅលើនាវិកនេសាទបរទេសមួយរូប ដែលព្រះរាជអាជ្ញា និងនគរបាលបានសហការគ្នាធានានូវសំណងបងិទានសម្រាប់ជនរងគ្រោះមីយ៉ាន់ម៉ា។

នៅ**ប្រទេសហ្វីលីពីន** ការបណ្ដុះបណ្ដាលពីទីភ្នាក់ងារច្រើន (ពាក់ព័ន្ធនឹងអ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងមន្ត្រីគាំទ្រជនរងគ្រោះ) បានសម្របសម្រួលតាមរយៈសាលាបណ្ឌិត្យសភាជាតិដែលបណ្ដុះបណ្ដាលចៅក្រម និងព្រះរាជអាជ្ញា បានចូលរួមចំណែកក្នុងការធ្វើឱ្យមានការយល់ដឹងប្រសើរឡើងនូវផ្នែកចិត្តសាស្ត្ររបស់ជនរងគ្រោះ និងពីមូលហេតុដែលពួកគេមានការស្ទាក់ស្ទើរក្នុងការបន្តសំណុំរឿងចោទប្រកាន់ជនជួញដូរមកលើខ្លួន។ ព្រះរាជអាជ្ញាមួយរូបបានរាយការណ៍ថា ចាប់តាំងពីបានប្រើប្រាស់បច្ចេកទេសពីការបណ្ដុះបណ្ដាលមកដែលបានជួយគាត់ក្នុងការធានាបាននូវទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការពីជនរងគ្រោះ ដែលបានជួយកែលម្អនូវការផ្ដល់សក្ខីកម្មរបស់ពួកគេក្នុងតុលាការ។ អ្នកស៊ើបអង្កេត និងមន្ត្រីសង្គមកិច្ចបានរាយការណ៍ពីការសម្របសម្រួលកាន់តែជិតស្និទ្ធ ដោយសារទំនាក់ទំនងការងារត្រូវបានបង្កើតឡើងតាមរយៈការបណ្ដុះបណ្ដាល។

នៅ**ប្រទេសវៀតណាម** វិធាននីតិវិធីបានតម្រូវឱ្យនគរបាល និងព្រះរាជអាជ្ញាធ្វើការរួមគ្នាក្នុងដំណាក់កាលស៊ើបអង្កេត។ នៅពេលចាប់ផ្ដើមការស៊ើបអង្កេត ការិយាល័យរដ្ឋអាជ្ញាត្រូវទទួលដំណឹង ហើយព្រះរាជអាជ្ញាត្រូវបានចាត់តាំងឱ្យគ្រប់គ្រងការស៊ើបអង្កេត និងទំនាក់ទំនងជាមួយនគរបាល។ ទាំងនគរបាល និងព្រះរាជអាជ្ញាបានរាយការណ៍ថា ពួកគេបានធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាក្នុងពេលស៊ើបអង្កេត។ កិច្ចសហប្រតិបត្តិការនេះពាក់ព័ន្ធនឹងការពិនិត្យរបស់ព្រះរាជអាជ្ញាទៅលើរបាយការណ៍ស៊ើបអង្កេតក្រែងមានកំហុសឆ្គងផ្នែកនីតិវិធី។ នៅក្នុងករណីមួយចំនួន ព្រះរាជអាជ្ញាក៏បានពិភាក្សាផងដែរពីយុទ្ធសាស្ត្រស៊ើបអង្កេតជាមួយអ្នកស៊ើបអង្កេត និងអាចចូលរួមក្នុងការស្ដាប់ចម្លើយសាក្សី។ នៅក្នុងសំណុំរឿងជួញដូរដែលត្រូវបានពិនិត្យនៅក្នុងរបាយការណ៍នេះ ការឆ្លើយតបទាន់ពេលវេលាពីរដ្ឋអាជ្ញាទៅនឹងសំណើរបស់នគរបាលដែលស្នើសុំដីកា និងបញ្ជាឱ្យឃុំខ្លួនត្រូវបានសម្របសម្រួលដោយការដាក់ឱ្យមានព្រះរាជអាជ្ញាប្រចាំការនៅស្ថានីយ៍នគរបាលនៅថ្នាក់ខេត្ត ដែលអាចធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស៊ើបអង្កេត ក្នុងករណីចាំបាច់។ ផលប្រយោជន៍នៃការចាត់តាំងឱ្យមន្ត្រីបំពេញភារកិច្ចផ្នែកអយ្យការមានភាពច្បាស់លាស់ណាស់ជាពិសេស ប្រសិនបើពួកគេដើរតួនាទីយ៉ាងសកម្មផ្នែកគ្រប់គ្រងនៅក្នុងទិដ្ឋភាពប្រតិបត្តិការស៊ើបអង្កេតដែលធ្វើដោយនគរបាល។

នៅ**ប្រទេសថៃ** វិធាននៃនីតិវិធីមួយដែលត្រូវបានអនុម័តនៅឆ្នាំ២០០៩ អនុញ្ញាតឱ្យមានការចូលរួមពីព្រះរាជអាជ្ញាមួយរូបក្នុងពេលស៊ើបអង្កេតទៅលើសំណុំរឿងដែលពាក់ព័ន្ធនឹងបញ្ហាឆ្លងដែន[១០៩]។ ដោយសារវាលក្ខណៈឆ្លងដែន វិធាននេះនឹងអនុវត្តចំពោះសំណុំរឿងជួញដូរជាច្រើន។ ទោះបីការអនុម័តវិធាននេះជាជំហ៊ានមួយដ៏ធំឆ្ពោះទៅមុខក៏ពិតមែន តែបញ្ហានានាបានកើតឡើងទាក់ទងនឹងការអនុវត្តន៍វិធាននេះ។ វិធាននេះមិនត្រូវបានអនុវត្តជាប្រចាំទេក្នុងការ

---

[១០៩] *វិសោធនកម្មទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ* (ចូលជាធរមាននៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៩) (ថៃ) ផ្នែក ២០។

អនុវត្តន៍ជាក់ស្តែង ជាបឋមដោយសារដំណើរការចាត់តាំងការងារជារឿយៗមានភាពយឺតយ៉ាវ ហេតុនេះនៅពេលព្រះរាជអាជ្ញាបានទទួលការចាត់តាំង ការស៊ើបអង្កេតត្រូវបានបញ្ចប់មួយភាគធំហើយ។ ការចាត់តាំងព្រះរាជអាជ្ញាភ្លាមៗនឹងធានាថា គោលដៅនៃវិធាននៃនីតិវិធីសំខាន់នេះមិនបានខកខានទេ។

វិធាននីតិវិធីមួយទៀតនៅ**ប្រទេសថៃ**តម្រូវថា នៅដំណាក់កាលស៊ើបអង្កេត ការស្តាប់ចម្លើយអនីតិជនត្រូវបានធ្វើឡើងនៅក្នុងអគារដែលរៀបចំជាពិសេសសម្រាប់ការស្តាប់ចម្លើយ។ ព្រះរាជអាជ្ញាត្រូវមានវត្តមានក្នុងពេលស្តាប់ចម្លើយដើម្បីធានាថា កុមាររងគ្រោះត្រូវបានប្រព្រឹត្តយ៉ាងត្រឹមត្រូវ។ ការវិភាគសំណុំរឿងបង្ហាញថា ដំណើរការនេះត្រូវបានអនុញ្ញាតយ៉ាងហោចណាស់នៅទីក្រុង ហើយថា ជាធម្មតា ព្រះរាជអាជ្ញាជាស្ត្រីត្រូវបានជ្រើសរើសដើម្បីចូលរួមក្នុងការស្តាប់ចម្លើយទាំងនេះ។ ប្រទេសថៃរាយការណ៍ថា មានការផ្តល់នូវបច្ចេកវិទ្យា និងអាគារចាំបាច់ទៅគ្រប់ខេត្តទាំងអស់ ដើម្បីគាំទ្រដល់ការអនុវត្តន៍ជាក់ស្តែងទាំងនេះ។ ប្រទេសថៃបានអនុម័តយកប្រព័ន្ធដឹកនាំដោយតុលាការនៅឆ្នាំ២០១៦ ដែលព្រះរាជអាជ្ញាបានចូលរួមយ៉ាងសកម្មក្នុងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្ស រួមជាមួយមន្ត្រីនគរបាល។ ដើម្បីជួយក្នុងការផ្លាស់ប្តូរ និងការអនុវត្តន៍ មានការចេញនូវ គោលការណ៍ណែនាំសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាស្តីពីរបៀបគ្រប់គ្រងប្រព័ន្ធដឹកនាំដោយតុលាការថ្មីក្នុងការអនុវត្តន៍ជាក់ស្តែង ក្នុងឆ្នាំ២០១៧។

នៅក្នុងរដ្ឋសមាជិកអាស៊ានមួយ ព្រះរាជអាជ្ញាត្រូវបានតម្រូវដោយច្បាប់ ឲ្យគ្រប់គ្រងការស៊ើបអង្កេតដោយមន្ត្រីនគរបាល។ ក៏ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង ជារឿយៗ ព្រះរាជអាជ្ញាមិនបានអនុវត្តសិទ្ធិអំណាចគ្រប់គ្រងរបស់ខ្លួនទេ។ ផ្ទុយទៅវិញ នគរបាលអនុវត្តតាមការណែនាំពីថ្នាក់លើរបស់ខ្លួន។ ក៏ប៉ុន្តែ នគរបាលកាន់តែច្រើនឡើងៗមានការយល់ដឹងពីលក្ខខណ្ឌនៃការអនុវត្តតាមការណែនាំរបស់ព្រះរាជអាជ្ញា។ ដោយសារនគរបាលមានការយល់ដឹង និងទទួលស្គាល់នូវភាពពាក់ព័ន្ធនៃការចូលរួមរបស់ព្រះរាជអាជ្ញានៅក្នុងការងាររបស់ខ្លួន ពួកគេបានបង្កើតទំនាក់ទំនងកាន់តែជិតស្និទ្ធ។

ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ ករណីសហប្រតិបត្តិការរវាងនគរបាល និងព្រះរាជអាជ្ញានៅក្នុងសំណុំរឿងជួញដូរបន្តនៅតែជាករណីលើកលែង មិនមែនជាវិធានទេ។ ការប្រឈមនេះនឹងត្រូវយកមកពិចារណាលម្អិតបន្ថែមទៀតនៅក្នុងផ្នែក ៤.៣ ខាងក្រោម ដោយយោងជាក់លាក់ទៅដល់ករណីសិក្សាជាច្រើន។

## វឌ្ឍនភាពទាក់ទងនឹងការគ្រប់គ្រងសាក្សីជាជនរងគ្រោះ (សូមមើលផងដែរ ជំពូកទី ៦)

ព្រះរាជអាជ្ញាចាំបាច់ត្រូវមានជំនាញ ការគាំទ្រ និងពេលវេលាដើម្បីបង្កើនកម្រិតនៃទំនាក់ទំនង និងទំនុកចិត្តទៅវិញទៅមក ដែលតម្រូវឲ្យមាន ដើម្បីយកឈ្នះភាពរារែករបស់ជនរងគ្រោះពីការជួញដូរជាច្រើន ក្នុងការមិនចង់សហការជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ដើម្បីកាត់បន្ថយហានិភ័យដែលថា ជនរងគ្រោះនឹងបាត់បង់ទំនុកចិត្តនៅក្នុងដំណើរការរបស់តុលាការ និងដកខ្លួនពីការសហការមុនពេលការជំនុំជម្រះចាប់ផ្តើម ជាការសំខាន់ដែលព្រះរាជអាជ្ញារក្សាទំនាក់ទំនងជាប្រចាំជាមួយជនរងគ្រោះក្នុងអំឡុងពេលមុនការជំនុំជម្រះ ដើម្បីត្រៀមពួកគេឲ្យបានពេញលេញក្នុងការមកផ្តល់សក្ខីកម្មនៅតុលាការ និងពិភាក្សាជាមួយពួកគេនូវវិធានការដែលមានដើម្បីការពារសុវត្ថិភាព និងឯកជនភាពរបស់ពួកគេនៅក្នុងតុលាការ។

ការខកខានមិនបានគាំទ្រដល់ជនរងគ្រោះ ជារឿយៗបណ្តាលឲ្យបាត់បង់សំណុំរឿង ដោយសារជនរងគ្រោះដកខ្លួនចេញពីបណ្តឹង ផ្តល់សក្ខីកម្មមិនបានល្អនៅពេលជំនុំជម្រះ ឬបាត់ខ្លួន ហើយមិនអាចផ្តល់ភស្តុតាងនៅពេលជំនុំជម្រះបាន។ កថាខណ្ឌខាងក្រោមរៀបរាប់ដោយសង្ខេបនូវវឌ្ឍនភាពនៅក្នុងតំបន់អាស៊ានទាក់ទងនឹងការទាក់ទងមុនពេលជំនុំជម្រះ ការរៀបចំសាក្សីជាជនរងគ្រោះនៅមុនពេលជំនុំជម្រះ និងផែនការគ្រប់គ្រងសាក្សីជាជនរងគ្រោះនៅក្នុងដំណើរការជំនុំជម្រះ។ ការវិភាគអំពីការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការគ្រប់គ្រងសាក្សីជាជនរងគ្រោះនឹងត្រូវផ្តល់ជូននៅក្នុងផ្នែក ៤.៣ ខាងក្រោម។ គួរកត់សម្គាល់ថា ជំពូកទី ៦ នៃ*របាយការណ៍វឌ្ឍនភាព*នេះនឹងពន្យល់លម្អិតអំពីតួនាទីរបស់សាក្សីជាជនរងគ្រោះនៅក្នុងការឆ្លើយតបតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរ។

ជារួម មានវឌ្ឍនភាពមួយចំនួនក្នុងការគ្រប់គ្រងសាក្សីជាជនរងគ្រោះនៅក្នុងសំណុំរឿងជួញដូរ ឬយ៉ាងហោចណាស់នៅក្នុងការបង្កើតបែបបទ និងនីតិវិធីដែលធ្វើឡើងដើម្បីគាំទ្រដល់ការគ្រប់គ្រងសាក្សីជាជនរងគ្រោះឲ្យមានប្រសិទ្ធភាព។ ឧទាហរណ៍ នៅ**ប្រទេសប្រ៊ុយណេ** បែបបទមួយសម្រាប់ព្រះរាជអាជ្ញាមានបំណងធានាថា ជនរងគ្រោះមានការយល់ដឹងពេញលេញអំពីការធ្វើសក្ខីកម្មក្នុងតុលាការ។ ចំណុចបញ្ចូលនូវការជូនដំណឹងដល់សាក្សីអំពីសិទ្ធិរបស់ពួកគេក្នុងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ និង ការផ្សុំសាក្សីទៅនឹងបន្ទប់សវនាការ ជាកន្លែងដែលពួកគេនឹងមកផ្តល់ភស្តុតាង។

### ការរក្សាទំនាក់ទំនងមុនពេលជំនុំជម្រះ

នៅក្នុងតំបន់អាស៊ានទាំងមូល រដ្ឋអាជ្ញាបានកត់សម្គាល់ថា ជនរងគ្រោះនៅក្នុងសំណុំរឿងជួញដូរជាញឹកញយបានបាត់ខ្លួនមុនពេលជំនុំជម្រះ ឬមុនពេលដាក់សេចក្តីថ្លែងពីទុក្ខវេទនា ដោយដកបណ្តឹងរបស់ខ្លួនតែម្តង។ មានមូលហេតុជាច្រើនចំពោះការមិនសហការនេះ តែមានការសង្ស័យតិចតួចដែលថា ការពន្យារពេលយ៉ូរនៅក្នុងដំណើរការវិនិច្ឆ័យ ការខកខានមិនបានការពារជនរងគ្រោះពីការគំរាមកំហែង ឬការទិញទឹកចិត្តដោយជនជាប់ចោទ ឬមេធាវីពួកគេ និងការខកខានមិនបានជូនដំណឹងដល់ជនរងគ្រោះអំពីការវិវត្តន៍គឺជាកត្តាពាក់ព័ន្ធទាំងអស់។ ដោយសារតែមានមូលហេតុទាំងនេះ ជាការសំខាន់ដែលថា ព្រះរាជអាជ្ញា ឬអ្នកស៊ើបអង្កេតត្រូវរក្សាទំនាក់ទំនងជាប្រចាំជាមួយជនរងគ្រោះក្នុងអំឡុងពេលមុខការជំនុំជម្រះ ជូនដំណឹងជនរងគ្រោះអំពីការវិវត្តន៍នៃសំណុំរឿង ការបញ្ជាក់ឲ្យច្បាស់ថាជនរងគ្រោះបានទទួលការយកចិត្តទុកដាក់ និងធានាដល់ជនរងគ្រោះថា ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌយកចិត្តទុកដាក់ស្វែងរកយុត្តិធម៌

នៅក្នុងសំណុំរឿងនេះ។ ប្រសិនបើជនរងគ្រោះចង់ធ្វើមាតុភូមិនិវត្ត ព្រះរាជអាជ្ញាគួរស្វែងរកវិធីដើម្បីដំណើរការរឿងនេះ។

ការវិភាគសំណុំរឿងបញ្ជាក់ថា មានឧទាហរណ៍មួយចំនួនពីតំបន់អាស៊ាន ដែលព្រះរាជអាជ្ញាដែលបានស្វែងរក និងរក្សាទំនាក់ទំនងជាប្រចាំជាមួយជនរងគ្រោះពីការជួញដូរ ក្នុងអំឡុងពេលសំខាន់មុនការជំនុំជម្រះ។ ឧទាហរណ៍ នៅក្នុងសំណុំរឿងមួយនៅ**ប្រទេសឥណ្ឌូនេស៊ី** ដែលពាក់ព័ន្ធនឹងការជួញដូរសម្រាប់អំពើពេស្យាចារទៅលើអនីតិជន តាមរយៈកលល្បិចជាការងារតាមផ្ទះ ព្រះរាជអាជ្ញាបានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយជនរងគ្រោះ និងគ្រួសាររបស់នាង។ ដោយសារពុំមានសេវាគាំទ្រជនរងគ្រោះនៅក្នុងតំបន់ជាក់លាក់នោះ ព្រះរាជអាជ្ញាបានធ្វើការយ៉ាងសកម្មជាមួយអាជ្ញាធរមូលដ្ឋានដើម្បីធានាថា ជនរងគ្រោះនឹងអាចបន្តការសិក្សាអប់រំរបស់ខ្លួនបាន ដែលជាទិដ្ឋភាពសំខាន់មួយនៃភាពជោគជ័យរបស់នាងក្នុងការធ្វើសមាហរណកម្មទៅក្នុងសហគម។ នៅក្នុងករណីមួយទៀតនៅ**ប្រទេសវៀតណាម** ក្រោយពេលចំណាយពេលជាមួយជនរងគ្រោះដើម្បីស្វែងយល់អំពីស្ថានភាពរបស់ពួកគេ និងសាងទំនុកចិត្តមក ព្រះរាជអាជ្ញាបានទាក់ទងមេធាវីពី អង្គការក្រៅរដ្ឋាភិបាល ដើម្បីស្នើសុំជំនួយពីពួកគេសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សពីរនាក់ ដែលរស់នៅឆ្ងាយពីតុលាការដើម្បីអាចចូលរួមក្នុងការជំនុំជម្រះបាន។ បន្ទាប់ អង្គការក្រៅរដ្ឋាភិបាល បានផ្តល់នូវជំនួយផ្នែកច្បាប់ ដោយបង្ហាញវត្តមានជនរងគ្រោះនៅពេលជំនុំជម្រះ និងគាំទ្រដល់ការធ្វើដំណើរ និងការស្នាក់នៅរបស់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេដើម្បីបានចូលរួមក្នុងការជំនុំជម្រះ។ ជាមួយភស្តុតាងដែលដាក់បង្ហាញ និងចម្លើយដែលជនរងគ្រោះបានផ្តល់ ចារីបានទទួលស្គាល់បទល្មើសរបស់ខ្លួន និងក្រោយមកបានទទួលការផ្តន្ទាទោសពីការជួញដូរមនុស្ស។

## មិនលើកទឹកចិត្តឱ្យមានការដោះស្រាយក្រៅផ្លូវការ

ដូចបានកត់សម្គាល់ពីមុនមក មានឧទាហរណ៍ជាច្រើននៅក្នុងតំបន់ ដែលបណ្តឹងត្រូវបានដកវិញ ឬសំណុំរឿងត្រូវបានលើកលែងការចោទប្រកាន់ ដោយសារជនរងគ្រោះបានសម្រេចដោះស្រាយក្រៅផ្លូវការជាមួយចារី។ ការអនុវត្តន៍ជាក់ស្តែងនេះជាទូទៅឆ្លុះបញ្ចាំងពីប្រពៃណីនៃការដោះស្រាយក្រៅផ្លូវការនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងរបួសស្នាមផ្ទាល់ខ្លួន។ ជាទូទៅអ្នកដែលចូលរួមនឹងលើកជាទឡ្ហីករណ៍ថា ការដោះស្រាយក្រៅផ្លូវការអាចជាទម្រង់មួយទៀតនៃយុត្តិធម៌ដែលមានប្រយោជន៍។ ក៏ប៉ុន្តែ ការអនុវត្តន៍ជាក់ស្តែងវាផ្ទុយស្រឡះដោយផ្ទាល់ទៅនឹងវិធានអន្តរជាតិ និងក្នុងតំបន់ដែលអះអាងអំពីសារៈសំខាន់ នៃការកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះការជួញដូរ និងនាំយកចារីទៅកាន់យុត្តិធម៌។ វាក៏ធ្វើឱ្យប៉ះពាល់ដល់នីតិរដ្ឋ ដោយលើកទឹកចិត្តឱ្យអំពើនិទណ្ឌភាពក្នុងចំណោមអ្នកដែលអាចបង់លុយកាក់ ដើម្បីគេចផុតពីការជំនុំជម្រះ និងការផ្តន្ទាទោសចំពោះបទល្មើសរបស់ខ្លួន។ ការចូលរួមដោយមិនអាចចៀសវាងបានរបស់ទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងការរៀបចំទាំងនេះ ប្រឈមនឹងហានិភ័យធ្ងន់ធ្ងរដោយសារអំពើពុករលួយ។

នៅ**ប្រទេសឥណ្ឌូនេស៊ី** ការសម្រុះសម្រួលត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធក្នុងគោលបំណងស្វែងរកសំណងបដិទាន។ អ្វីដែលហៅថា “ការសម្រុះសម្រួលផ្នែកព្រហ្មទណ្ឌ” តម្រូវឱ្យព្រះរាជអាជ្ញាធ្វើការវាយតម្លៃអំពីសមត្ថភាពរបស់ចុងចោទក្នុងការបង់សងការខូចខាតដែលបានប៉ាន់ស្មាន នៅមុនពេលជំនុំជម្រះ។ គោលបំណងនៃការសម្រុះសម្រួលនេះគឺមិនមែនលើកលែងការចោទប្រកាន់ទេ តែគឺស្វែងរកសំណងដែលមានតុល្យភាព និងយុត្តិធម៌។ លទ្ធភាពរបស់ចុងចោទក្នុងការបង់សងការខូចខាតត្រូវបានយកមកពិចារណានៅក្នុងទោសទណ្ឌដែលស្នើសុំ និងដាក់។

### *ប្រអប់អត្ថបទ ១៥៖ ការបដិសេធន៍ការដោះស្រាយក្រៅផ្លូវការនៅប្រទេសមីយ៉ាន់ម៉ា និងហ្វីលីពីន*

> នៅ**ប្រទេសមីយ៉ាន់ម៉ា** កុមារ ៣ នាក់ត្រូវធ្វើបាបលើរូបរាងកាយ និងបង្ខំឱ្យធ្វើការនៅក្នុងហាងកាត់សម្លៀកបំពាក់មួយកន្លែងអស់រយៈពេល ៥ ឆ្នាំ ដោយបានទទួលប្រាក់ឈ្នួលតិចតួច។ មេបញ្ជាការនគរបាល ២ រូបបានច្រានចោលរបាយការណ៍បឋមពីការធ្វើបាន ធ្វើឱ្យអ្នកកាសែតនៅមូលដ្ឋានម្នាក់សម្រេចដាក់ពាក្យប្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សជាតិ (NHRC)។ NHRC សុខចិត្តធ្វើការដោះស្រាយដោយបង់ប្រាក់ជាមួយចារី ជាជាងបញ្ជូនសំណុំរឿងនោះទៅចោទប្រកាន់អនុលោមតាមច្បាប់ប្រឆាំងការជួញដូរ។ បន្ទាប់ពីមានកំហឹងក្រេវក្រោធពីសាធារណជនទៅលើការឆ្លើយតបមិនពេញលេញរបស់ NHRC ទៅនឹងសំណុំរឿងនោះ ស្នងការ ៤ នាក់បានលាលែងតំណែង ប្រធាននគរបាលដែលមិនយកចិត្តទុកដាក់ចំពោះរបាយការណ៍បឋមនោះរងការស៊ើបអង្កេត និងត្រូវបានដកតំណែងមកថ្នាក់ក្រោមវិញ ហើយអាជ្ញាធរបានចាប់ផ្តើមចោទប្រកាន់ជនសង្ស័យទាំង ៦ នាក់នោះ។ ជនសង្ស័យ ២ នាក់ត្រូវបានលើកលែងការចោទប្រកាន់ ហើយអ្នកផ្សេងទៀតប្រឈមនឹងការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។
>
> នៅប្រទេស**ហ្វីលីពីន** ការដោះស្រាយក្រៅផ្លូវការត្រូវបានឆ្លើយតបនៃបទប្បញ្ញត្តិច្បាប់មួយដែលទប់ស្កាត់ជនរងគ្រោះពីការជួញដូរមន្ត្រីមិនឱ្យធ្វើសកម្មភាពដើម្បីបញ្ចប់សំណុំរឿង។ អ្នកដែលស្វែងរកជំនួយដល់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការបញ្ចប់សំណុំរឿងត្រូវទទួលខុសត្រូវចំពោះទណ្ឌកម្មព្រហ្មទណ្ឌ[១១០]។

## ការរៀបចំសាក្សីជាជនរងគ្រោះសម្រាប់តុលាការនៅមុនពេលជំនុំជម្រះ

ការត្រៀមមុនពេលជំនុំជម្រះ រួមទាំងការត្រៀមជនរងគ្រោះ និងសាក្សីផ្សេងទៀតដើម្បីផ្តល់សក្ខីកម្មនៅតុលាការ គឺជាខុសធម្មតានៅតំបន់អាស៊ាន។ ក៏ប៉ុន្តែ ដោយសារព្រះរាជអាជ្ញានៅក្នុងតំបន់នេះ កាន់តែមានការយល់ដឹងប្រសើរឡើងអំពីភាពស្មុគស្មាញនៃការចោទប្រកាន់ពាក់ព័ន្ធនឹងការជួញដូរ និងតួនាទីយ៉ាងសំខាន់របស់សាក្សី វាមានកម្រិតរីកចម្រើនយ៉ាងល្អ និងបើកចំហក្នុងការប្រើប្រាស់នៃវិធីសាស្ត្រនេះ។ ឧទាហរណ៍ នៅក្នុងសំណុំរឿងដែលត្រូវបានពិនិត្យនៅក្នុងការត្រៀមនៅក្នុង*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ ព្រះរាជអាជ្ញាបានជួបជាមួយជនរងគ្រោះមុនថ្ងៃជំនុំជម្រះ បានពន្យល់អំពីអ្វីដែលនឹងកើតឡើងនៅក្នុងតុលាការ និងពិនិត្យឡើងវិញជាមួយជនរងគ្រោះនូវចំណុចជាមូលដ្ឋាននៃសក្ខីកម្មរបស់ពួកគេ។ ការត្រៀមនេះពិតជាចូលរួមចំណែក ដល់លំហូព័ត៌មានដែលមានលក្ខណៈប្រាកដនិយម និងគួរឱ្យជឿជាក់បាន ពីសាក្សីជាជនរងគ្រោះ និងបានជួយកាត់បន្ថយការភ័យខ្លាចរបស់មនុស្សនោះ ជុំវិញដំណើរការនៅតុលាការ។ នៅក្នុងសំណុំរឿងដដែលនោះ តាមការសង្កេតរបស់តុលាការឃើញថា ព្រះរាជអាជ្ញាបានត្រៀមជាមុននូវបញ្ជីសំណួរលម្អិតដែលត្រូវជនរងគ្រោះ។ ព្រះរាជអាជ្ញាក៏ដំណើរការសាកសួរតាមវិធីសាស្ត្រនៅក្នុងបញ្ជីនោះ។ ប្រការនេះបានធ្វើឱ្យព្រះរាជអាជ្ញាធ្វើការសាកសួរដោយផ្ទាល់យ៉ាងលម្អិត និងមានការរៀបចំត្រឹមត្រូវ ដែលជួយឱ្យជនរងគ្រោះផ្តល់សក្ខីកម្មស៊ីចង្វាក់ និងគួរឱ្យជឿជាក់បានដល់តុលាការ។

នៅ**ប្រទេសមីយ៉ាន់ម៉ា** ព្រះរាជអាជ្ញាមិនត្រូវលើកទឹកចិត្តឱ្យទាក់ទងជាមួយសាក្សីជាជនរងគ្រោះ មុនពេលពួកគេមកផ្តល់សក្ខីកម្មនៅតុលាការជាយូរមកហើយ ហើយទាក់ទងនិងបញ្ហានេះអាចនឹងត្រូវគេចាត់ទុកថា វាអាចប្រើឥទ្ធិពល

[១១០] ផ្នែក ៨ នៃ RA លេខ ៩២០៨ ត្រូវបានធ្វើវិសោធនកម្មដោយ RA លេខ ១០៣៦៤។

ទៅលើការធ្វើសក្ខីកម្ម។ ក៏ប៉ុន្តែ អនុលោមតាមការណែនាំពីការិយាល័យអគ្គមេធាវីសហព័ន្ធ នាពេលបច្ចុប្បន្ននេះ ព្រះរាជអាជ្ញាមួយចំនួនជួបជាមួយសាក្សីជាជនរងគ្រោះ មុនពេលពួកគេមានវត្តមាននៅក្នុងតុលាការ ដើម្បីពន្យល់អំពីអ្វីដែលនឹងកើតឡើងក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីតុលាការ។ មានសញ្ញាណខ្លះបង្ហាញថា ការអនុវត្តន៍ជាក់ស្តែងបែបនេះក្លាយជារឿងធម្មតាហើយ។

## ការធានាការការការពារនៅក្នុងតុលាការ ត្រូវបានប្រើប្រាស់

នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ច្បាប់ និងយន្តការមួយចំនួនបានអនុញ្ញាតឱ្យមានយ៉ាងហោចណាស់ផ្តល់នូវការការពារមួយចំនួននៅក្នុងតុលាការដល់សាក្សីដែលងាយរងគ្រោះ រួមមាន កុមារ និងជនរងគ្រោះ ពីការរំលោភបំពានផ្លូវភេទ និងបទល្មើសហិង្សាផ្សេងទៀត។ ជួនកាល ការការពារទាំងនេះត្រូវបានពង្រឹងជាក់ស្តែងទៅដល់ជនរងគ្រោះពីការជួញដូរទៀតផង។ ឧទាហរណ៍ នៅ**ប្រទេសថៃ** សារព័ត៌មានត្រូវបានហាមឃាត់មិនឱ្យចូលក្នុងបន្ទប់សវនាការ និងមិនឱ្យបញ្ចេញអត្តសញ្ញាណជនរងគ្រោះ។ វិធានការនេះអនុវត្តចំពោះជនរងគ្រោះពេញវ័យព្រមទាំងកុមារ។ នៅ**ប្រទេសកម្ពុជា** ចំណុចនេះត្រូវបានរាយការណ៍ថា ជួនកាលមានប្រើរបាំងការពារ នៅក្នុងតុលាការ ចំពោះសំណុំរឿងជួញដូរពាក់ព័ន្ធនឹងកុមាររងគ្រោះ ដើម្បីការពារជនរងគ្រោះមិនឱ្យប្រឈមនឹងជនជាប់ចោទ។ ក្រៅពីនេះ ដំណើរការស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតនៅប្រទេសកម្ពុជាត្រូវបានបិទបាំងពីសារព័ត៌មាន និងសាធារណជន។ ចំណុចនេះផ្តល់ជាវិធានការសំខាន់នូវការការពារសម្រាប់ជនរងគ្រោះដែលអត្តសញ្ញាណ និងសក្ខីកម្មរបស់ពួកគេមិនត្រូវបានបញ្ចេញជាសាធារណៈឡើយ។ ការប្រើប្រាស់ចម្លើយមុនពេលជំនុំជម្រះ ដូចជា សក្ខីកម្មមុនសវនាការ គឺជាយុទ្ធសាស្ត្រនៃការការពារយ៉ាងសំខាន់ដល់ជនរងគ្រោះ ដោយសារវាអាចបញ្ជៀសនូវភាពចាំបាច់របស់ជនរងគ្រោះក្នុងការមានវត្តមាននៅក្នុងតុលាការ។ ក៏ប៉ុន្តែ ចម្លើយមុនពេលជំនុំជម្រះបែបនេះត្រូវស្តាប់ដោយអនុលោមទៅតាមការការពារដល់សិទ្ធិជាសារវន្តរបស់ជនសង្ស័យ ក្នុងការសាកសួរជនរងគ្រោះដោយផ្ទាល់ ឬតាមរយៈមេធាវី។

វិធាននីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋសមាជិកអាស៊ានតម្រូវឱ្យមានសវនាការអសាធារណៈ នៅពេលអនីតិជនផ្តល់ភស្តុតាងនៅក្នុងតុលាការ។ តម្លៃនៃវិធាននេះត្រូវបានពន្យល់ដោយសំណុំរឿងជួញដូរឆ្នាំ២០០៩ ពី**ប្រទេសថៃ**។ នៅក្នុងសំណុំរឿងនេះ នៅពេលមានភាពច្បាស់លាស់ថា សាក្សីជាជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ តុលាការបានបញ្ជាក់ឱ្យដំណើរការសវនាការជាអសាធារណៈ។ តុលាការ នៅក្រុងបាងកក ពាក់ព័ន្ធនិងករណីព្រហ្មទណ្ឌ ពួកគេត្រូវបានឱ្យបន្ទប់ពិសេសមួយដែលរៀបចំជាពិសេសដើម្បីផ្តល់បរិយាកាសគាំទ្រ និងគ្មានការគំរាមកំហែងសម្រាប់កុមារដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ បន្ទប់នោះមានភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់សវនាការ ដើម្បីឱ្យអនីតិជនអាចផ្តល់សក្ខីកម្មដោយមិនចាំបាច់មានវត្តមានផ្ទាល់នៅក្នុងបន្ទប់សវនាការ។ វិធាននៃនីតិវិធីពាក់ព័ន្ធអនុញ្ញាតឱ្យជនរងគ្រោះអមដំណើរដោយអ្នកពិគ្រោះយោបល់មួយរូប ឬឪពុក/ម្តាយនៅពេលផ្តល់សក្ខីកម្ម។ តុលាការអាចតម្រូវថា រាល់សំណួរទាំងអស់ដែលសួរទៅកុមារ គួរសួរទៅអ្នកពិគ្រោះយោបល់ជាមុនសិន ហើយគាត់ជាអ្នកដែលសួរសំណួរនោះទៅកុមារដោយផ្ទាល់។

ការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍នៅក្នុងការជំនុំជម្រះសំណុំរឿងជួញដូរ បានកើនឡើង ចាប់តាំងពី*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ មក ទូទាំងតំបន់។ ច្បាប់ថ្មីស្តីពីនីតិវិធីសម្រាប់សំណុំរឿងជួញដូរមនុស្ស ព.ស ២៥៥៩ (ផ្នែក ៩) ជំរុញឱ្យតុលាការអនុញ្ញាតឱ្យជនរងគ្រោះផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ប្រសិនបើជនរងគ្រោះ ឬព្រះរាជអាជ្ញាស្នើសុំ។ ពុំមានព័ត៌មានច្បាស់លាស់ ថាតើមធ្យោបាយនេះត្រូវបានស្នើសុំ ឬប្រើប្រាស់ញឹកញាប់យ៉ាងណានោះទេ។

នៅ**ប្រទេសឡាវ** តុលាការក៏កំពុងប្រើប្រាស់វិធានការធម្មតា តែមានប្រសិទ្ធភាពដើម្បីការពារជនរងគ្រោះ និងសាក្សីងាយរងគ្រោះនៅពេលជំនុំជម្រះ។ ឧទាហរណ៍ ការជំនុំជម្រះលើការជួញដូរមនុស្សមួយដែលបានសង្កេតនៅឆ្នាំ២០១៧ វិធានការការពារជនរងគ្រោះនៅក្នុងតុលាការរួមមាន៖

- ក្នុងពេលជនរងគ្រោះផ្តល់សក្ខីកម្ម មានរាំងនននបាំងជនរងគ្រោះពីចុងចោទ។
- ជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យផ្តល់សក្ខីកម្ម ជាមួយមេធាវីជនរងគ្រោះនៅឈរក្បែរគាត់ នៅវេទិកាសម្រាប់សាក្សី។
- លើកលែងក្នុងពេលផ្តល់សក្ខីកម្មផ្ទាល់ ជនរងគ្រោះស្ថិតនៅឆ្ងាយ និងខាងក្រៅបន្ទប់សវនាការសម្រាប់អំឡុងពេលកិច្ចដំណើរការនីតិវិធី។ គាត់មិនត្រូវទាក់ទងជាមួយចុងចោទទាល់តែសោះ។
- ចៅក្រមដែលកាន់សំណុំរឿង បង្ហាញពីការយល់ដឹងនូវតម្រូវការរបស់ជនរងគ្រោះ និងដោះស្រាយជាមួយជនរងគ្រោះជាលក្ខណៈរសើបសមរម្យ។

វាជាការសំខាន់តែត្រូវកត់សម្គាល់ថា *ភាពរកបាន* នៃការការពារពុំចាំបាច់មានន័យថាត្រូវយកវាមកប្រើក្នុងពេលអនុវត្តន៍ជាក់ស្តែងទេ។ ឧទាហរណ៍ ទោះបីវិធាននៃភស្តុតាងអាចអនុញ្ញាតឱ្យប្រើប្រាស់សវនាការជាអសាធារណៈ ឬសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍សម្រាប់អនីតិជន ឬសាក្សីងាយរងគ្រោះផ្សេងទៀតក៏ដោយ តែវិធានការទាំងនេះមិនត្រូវបានយកមកប្រើជានិច្ចកាលនៅក្នុងសំណុំរឿងជួញដូរទេ។ ឧទាហរណ៍ជាក់លាក់នឹងលើកឡើងនៅក្នុងផ្នែក ៤.៣ ខាងក្រោម ដែលពិចារណាដល់ការប្រឈម និងកាលានុវត្តភាព។

## ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ

សក្ខីកម្មមុនការជំនុំជម្រះ អាចជួយឱ្យសាក្សី ផ្តល់ភស្តុតាងពេលមុននៅក្នុងដំណើរការតុលាការ ទន្ទឹមនឹងនោះដើម្បីធានាថា មេធាវីការពារក្តី មានឱកាសអាចសួរដេញដោល ដល់សាក្សីចំពោះភស្តុតាងរបស់ពួកគេ។ នេះអាចជាយន្តការមានប្រយោជន៍ជាពិសេសនៅក្នុងសំណុំរឿងជួញដូរ។ ជារឿយៗជនរងគ្រោះជាសាក្សី មិនពេញចិត្តនឹងឱ្យគេឃុំខ្លួននៅក្នុងទីជម្រក ឬអាគារឃុំខ្លួនផ្សេងទៀតទេ ហើយពួកគេតែងតែចង់វិលត្រឡប់ទៅផ្ទះវិញឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។ សក្ខីកម្មមុនការជំនុំជម្រះ អនុញ្ញាតឱ្យការរាយរាប់របស់ជនរងគ្រោះត្រូវបានដាក់បង្ហាញនៅពេលជំនុំជម្រះ ទន្ទឹមនឹងនោះជួយដល់ការធ្វើមាតុភូមិនិវត្តន៍ ឬវិលត្រឡប់ទៅទីកន្លែងវិញដោយគ្មានការពន្យារពេលឥតប្រយោជន៍។ សក្ខីកម្មមុនជំនុំជម្រះ ក៏ក្លាយជាសក្ខីកម្មដែលមានតម្លៃ ក្នុងស្ថានភាពដែលសាក្សីជាជនរងគ្រោះ ស្ថិតក្រោមការគំរាមកំហែង ឬការទិញទឹកចិត្តពីជនជួញដូរឱ្យដកកិច្ចសហការរបស់ខ្លួនវិញ។ ការពិត ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះគួរគោរពដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការជំទាស់ទៅនឹងភស្តុតាងដាក់បន្ទុកជានិច្ច។

សក្ខីកម្មមុនការជំនុំជម្រះមានចែងក្នុងច្បាប់ជួញដូរទាំងនៅ**ប្រទេសថៃ** និង**ម៉ាឡេស៊ី**[១១១] ព្រមទាំងនៅក្នុង*ក្រមនីតិវិធី***ហ្វីលីពីន** និង*ក្រមនីតិវិធីព្រហ្មទណ្ឌ***សិង្ហបុរី**។ សក្ខីកម្មមុនការជំនុំជម្រះត្រូវបានធ្វើឡើងជាការអនុវត្តន៍ជាក់ស្តែងនៅ**ប្រទេសកម្ពុជា** នៅចំពោះមុខចៅក្រមស៊ើបអង្កេត ទោះបីវាជាលើកទីបីនៃការស្តាប់ចម្លើយជនរងគ្រោះ ដោយសារនគរបាល និងព្រះរាជអាជ្ញាបានស្តាប់ចម្លើយជនរងគ្រោះរួចហើយ ពាក់ព័ន្ធនឹងបទពិសោធន៍នៃការជួញដូរចំពោះរូបគាត់ក៏ដោយ។

---

[១១១] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧) [ច្បាប់លេខ ៦៧០] (ម៉ាឡេស៊ី) ផ្នែក ៦១ក។

*ប្រអប់អត្ថបទ ១៦៖ ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះនៅប្រទេសថៃ*

ប្រទេសថៃបានរាយការណ៍ថា នាពេលបច្ចុប្បន្ន សក្ខីកម្មមុនការជំនុំជម្រះជាការអនុវត្តន៍ជាក់ស្តែងនៅក្នុងសំណុំរឿងជួញដូរ។ ឧទាហរណ៍មួយនៃការប្រើប្រាស់សក្ខីកម្មបែបនេះត្រូវបានផ្តល់ដោយការចោទប្រកាន់នៅក្នុងសំណុំរឿងជួញដូរទ្រង់ទ្រាយធំមួយក្នុងឆ្នាំ២០១៦ ដែលប្រទេសពាក់ព័ន្ធនឹងការចោទប្រកាន់ពីការកេងប្រវ័ញ្ចជនភៀសខ្លួនមកពីប្រទេសមីយ៉ាន់ម៉ា។ សំណុំរឿងនេះ ដែលបានចំណាយពេល ២ ឆ្នាំដើម្បីបញ្ចប់ ពាក់ព័ន្ធនឹងចុងចោទចំនួន ១០៣ នាក់ និងមានសាក្សីជាង ២០០ នាក់ ដែលពួកគេភាគច្រើនជាជនរងគ្រោះពីការជួញដូរមនុស្សជាជនបរទេស។ ដោយសារចំនួនដ៏ច្រើនបែបនេះ ការគ្រប់គ្រងការជំនុំជម្រះរបស់តុលាការ រួមទាំងតាមរយៈការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ ជាកត្តាសំខាន់ដើម្បីធានានូវផ្នែករដ្ឋបាលតុលាការឲ្យបានសមរម្យ។

មុនពេលជំនុំជម្រះ និងអនុលោមតាមក្រមនីតិវិធី និងច្បាប់ស្តីពីជួញដូរមនុស្សរបស់ថៃ ព្រះរាជអាជ្ញាបានសួរសាក្សីមួយចំនួន នៅចំពោះមុខវត្តមានចៅក្រមមួយរូប។ មេធាវីការពារក្តីក៏មានវត្តមានដែរ ហើយមានកាលានុវត្តភាពសួរដេញដោលជនរងគ្រោះ។ នីតិវិធីបានអនុញ្ញាតឲ្យយកសក្ខីកម្មមុនការជំនុំជម្រះនោះមកធ្វើជាភស្តុតាងក្នុងតុលាការដែរ។ ដំណើរការនេះបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ជនរងគ្រោះ ដោយជួយឲ្យពួកគេបានសម្រាកភ្លាមៗ ដោយមិនចាំបាច់រង់ចាំ (នៅក្នុងទីជម្រក) មុននឹងបញ្ចប់ការជំនុំជម្រះ។

ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះនៅប្រទេសថៃ ក៏ដូចជានៅទីកន្លែងផ្សេងទៀត មិនមែនគ្មានបញ្ហាចោទនោះទេ។ ឧទាហរណ៍ មានពេលវេលាខ្លីសម្រាប់កម្មវិធីជំនុំជម្រះដ៏ច្រើនរបស់តុលាការ។ ក្រៅពីនេះ ចៅក្រម និងព្រះរាជអាជ្ញាមួយចំនួនស្ទាក់ស្ទើរនឹងគាំទ្រដល់សក្ខីកម្មមុនការជំនុំជម្រះនេះ ដោយចង់ឲ្យជនរងគ្រោះមកផ្តល់ភស្តុតាងដោយផ្ទាល់នៅពេលជំនុំជម្រះជាង។

## វឌ្ឍនភាពទាក់ទងនឹងការវិភាគយ៉ាងហ្មត់ចត់ទៅលើអង្គច្បាប់ និងភស្តុតាង

វាជាគោលការណ៍គតិយុត្តិជាមូលដ្ឋានដែលថា រាល់ធាតុផ្សំនីមួយៗនៃបទល្មើស ត្រូវតែបង្ហាញដោយភស្តុតាងដែលជឿជាក់បាន និងសមហេតុផលមុនពេលសន្និដ្ឋានថាជនជាប់ចោទមានពិរុទ្ធភាពចំពោះបទល្មើសណាមួយ។ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ បទល្មើសស្តីពីការជួញដូរមនុស្ស បទល្មើសពាក់ព័ន្ធនឹងការជួញដូរជាបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរដែលមានការផ្តន្ទាទោសធ្ងន់ធ្ងរ។ ដោយសារភាពធ្ងន់ធ្ងរនៃទោសទណ្ឌដែលមានមកជាមួយនឹងបទចោទជួញដូរ និងភាពធ្ងន់ធ្ងរនៃភាពអយុត្តិធម៌ដែលកើតឡើងដោយសារការចោទប្រកាន់ ឬការផ្តន្ទាទោសខុស វាជាការសំខាន់ដែលព្រះរាជអាជ្ញា និងចៅក្រមត្រូវចូលរួមក្នុងការវិភាគទៅលើអង្គច្បាប់ និងអង្គហេតុយ៉ាងយកចិត្តទុកដាក់ដើម្បីធានាឲ្យបាននូវយុត្តិធម៌។

ចំណុចនេះនឹងតម្រូវថា អង្គហេតុនៃសំណុំរឿងត្រូវបានទំនាក់ទំនងគ្នាយ៉ាងច្បាស់ ជាលក្ខណៈស៊ីចង្វាក់ និងសមហេតុផល ទៅនឹងធាតុផ្សំនៃបទល្មើលដែលចោទប្រកាន់។ ការពិត វាជាការសំខាន់ដែលថា ព្រះរាជអាជ្ញា និងចៅក្រមត្រូវយល់ដឹងពីធាតុផ្សំមូលដ្ឋាននៃបទល្មើស ហើយពួកគេអាចបង្ហាញអំពីធាតុផ្សំទាំងនេះយ៉ាងច្បាស់នៅក្នុងតុលាការ។ ប្រសិនបើគ្មានការបង្កើតទំនាក់ទំនងយ៉ាងរឹងមាំ រវាងធាតុផ្សំនៃបទល្មើស និងភស្តុតាងដែលមានទេ ការសម្រេចចិត្តចោទប្រកាន់របស់ព្រះរាជអាជ្ញាបណ្តាលឲ្យមានការសង្ស័យ ភស្តុតាងពាក់ព័ន្ធមិនអាចកំណត់ និងបង្ហាញបាននៅពេលជំនុំជម្រះ ការសាកសួរសាក្សីនឹងគ្មានការផ្តោតច្បាស់លាស់ ហើយសេចក្តីសម្រេចរបស់តុលាការអាចនាំ

ឲ្យមានការចោទសួរ ឬត្រូវបានច្រានចោលដោយបណ្តឹងឧទ្ធរណ៍។ ក្រៅពីនេះ កង្វះភាពច្បាស់លាស់ និងការវិភាគយ៉ាងហ្មត់ចត់ទាក់ទងនឹងភស្តុតាង និងច្បាប់ជាធរមានអាចបណ្តាលឲ្យការបរាជ័យនូវការធានានូវភាពត្រឹមត្រូវជាមូលដ្ឋាន។ នៅពេលចៅក្រមមិនដឹងច្បាស់ពីធាតុផ្សំដែលត្រូវបង្ហាញដើម្បីបញ្ជាក់នូវពិរុទ្ធភាព គាត់ហាក់ដូចជានៅតែទទួចថា ព្រះរាជអាជ្ញាមិនបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវក្នុងការបង្ហាញភស្តុតាងទេ។

កិច្ចខិតខំប្រឹងប្រែងធំៗ ក្នុងការបណ្តុះបណ្តាលដែលធ្វើឡើងដោយរដ្ឋសមាជិកអាស៊ាននាពេលប៉ុន្មានឆ្នាំកន្លងមកនេះ បង្ហាញថា ហាក់ដូចជាមានការកែលម្អសមត្ថភាពចៅក្រម និងព្រះរាជអាជ្ញាក្នុងការវិភាគលើអង្គច្បាប់នៅក្នុងសំណុំរឿងជួញដូរ។ ក៏ប៉ុន្តែ ការវិភាគសំណុំរឿងលម្អិតនៅក្នុងផ្នែក ៤.៣ ខាងក្រោមបង្ហាញថា ព្រះរាជអាជ្ញា និងចៅក្រមមួយចំនួន នៅតែមិនបានចូលរួមក្នុងការវិភាគលើអង្គច្បាប់ និងអង្គហេតុយ៉ាងយកចិត្តទុកដាក់ជាការចាំបាច់ដើម្បីធានាថាយុត្តិធម៌អាចសម្រេចបាននៅគ្រប់សំណុំរឿងនោះទេ។

## វឌ្ឍនភាពទាក់ទងនឹងការដោះស្រាយអំពើពុករលួយ

ដូចបានកត់សម្គាល់នៅក្នុងជំពូកទី ២ និង ៣ បញ្ហាអំពើពុករលួយ និងការសមគំនិតនៃវិស័យសាធារណៈនៅក្នុងការជួញដូរគឺជាបញ្ហាមួយនៅក្នុងប្រទេសជាច្រើននៅទូទាំងពិភពលោក។ តំបន់អាស៊ានក៏ដូចគ្នាដែរ។ មានវឌ្ឍនភាពមួយចំនួនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលបានបង្ហាញយ៉ាងល្អបំផុត តាមរយៈការចោទប្រកាន់ និងផ្តន្ទាទោសទៅលើមន្ត្រីសាធារណៈល្បីៗដែលពាក់ព័ន្ធនឹងការជួញដូរនៅ**ប្រទេសថៃ**។ រដ្ឋសមាជិកអាស៊ានជាច្រើនផ្សេងទៀតបានរាយការណ៍ពីការផ្តន្ទាទោសដល់មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌចំពោះទម្លាប់ពុករលួយពាក់ព័ន្ធនឹងការជួញដូរ។ ក៏ប៉ុន្តែ បញ្ហានៅតែមិនទាន់បានដោះស្រាយយ៉ាងធំធេង ហើយនឹងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពជាច្រើននៃការឆ្លើយតបទៅនឹងការជួញដូរ។ ឧទាហរណ៍ អំពើពុករលួយអាចប៉ះពាល់ដល់ប្រភេទនៃសំណុំរឿងដែលកំពុងដំណើរការ ដោយធានាថា មន្ត្រីសាធារណៈដែលបានប្រយោជន៍ពីការជួញដូរអាចចៀសផុតពីការចោទប្រកាន់។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួនចៅក្រម និងព្រះរាជអាជ្ញាត្រូវបានគេឆ្លើយដាក់ថា មានការពាក់ព័ន្ធនិងជនសង្ស័យ ដែលអាចឱ្យជនសង្ស័យគេចវេសពីយុត្តិធម៌ ឧទាហរណ៍ តាមរយៈការបំភិតបំភ័យសាក្សី និងគ្រួសាររបស់ពួកគេជំនួសជនសង្ស័យ ឬដោះលែងជនសង្ស័យថាជាអ្នកជួញដូរឲ្យនៅក្រៅឃុំដោយមិនខុសច្បាប់។

## វឌ្ឍនភាពក្នុងការធានាឲ្យមានប្រវត្តិរូបផ្នែកយេនឌ័រចំពោះព្រះរាជអាជ្ញា និងចៅក្រម

នៅតំបន់អាស៊ាន ក៏ដូចជាផ្នែកផ្សេងទៀតក្នុងពិភពលោកដែរ មានអតុល្យភាពយេនឌ័រធំធេងនៅក្នុងស្ថាប័នអយ្យការ និងស្ថាប័នតុលាការ ដោយមានបុរសជាអ្នកកាន់តំណែងទាំងនេះភាគច្រើន ជាពិសេសតំណែងជាន់ខ្ពស់។ ស្ថានភាពនេះបានបន្តចាប់តាំងពីមានការកត់សម្គាល់ជាលើកដំបូងនៅក្នុង*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ ទោះបីរូបភាពជាក់ស្តែងមានការលំបាក ដោយសារទិន្នន័យទាក់ទងនឹងបញ្ហានេះនៅមានកម្រិត ។ ឧទាហរណ៍ ព័ត៌មានស្តីពីតុល្យភាពយេនឌ័រនៅក្នុងស្ថាប័នអយ្យការ និងចៅក្រមនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួនពុំមានជាសាធារណៈទេ។

នាពេលបច្ចុប្បន្ន មានការទទួលស្គាល់ថា កិច្ចខិតខំប្រឹងប្រែងដើម្បីធានាឲ្យបាន នូវតុល្យភាពយេនឌ័រកាន់តែប្រសើរឡើង តាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាទិដ្ឋភាពយ៉ាងសំខាន់មួយនៃការពង្រឹងប្រព័ន្ធនោះ ធានានូវភាព

ពាក់ព័ន្ធសម្រាប់សហគមន៍ដែលបានប្រើប្រាស់ប្រព័ន្ធនេះ និងពង្រឹងសមត្ថភាពរបស់វាក្នុងការផ្តល់យុត្តិធម៌។ បទល្មើសជួញដូរ បើមានវិស័យយេនឌ័ររឹងមាំ ទំនងជាទទួលបានផលប្រយោជន៍ដ៏អស្ចារ្យ ពីការខិតខំប្រឹងប្រែងនានា ក្នុងគោលបំណងបង្កើតឱ្យមានតុល្យភាពយេនឌ័រកាន់តែប្រសើរនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

## វឌ្ឍនភាពទាក់ទងនឹងការកាត់បន្ថយការពន្យារពេល

ដូចបានកត់សម្គាល់ខាងលើ សំណុំរឿងជួញដូរអាចអូសបន្លាយជាច្រើនខែ ឬជាច្រើនឆ្នាំ។ ចំណុចនេះមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជនរងគ្រោះជាសាក្សី ដែលតម្រូវឱ្យមានវត្តមានដើម្បីផ្តល់ភស្តុតាង ជួនកាលដែលធ្វើឱ្យពួកគេមិនអាចត្រឡប់ទៅផ្ទះវិញបាន។ *គោលការណ៍ណែនាំអ្នកប្រតិបត្តិនៅអាស៊ាន* បានគូសបញ្ជាក់ពីសារៈសំខាន់នៃការធានាថា ការជំនុំជម្រះលើសំណុំរឿងជួញដូរគួរត្រូវបានធ្វើឡើងដោយគ្មានការពន្យារពេលឥតប្រយោជន៍ យកល្អទៅតាមយន្តការមួយដែលពន្លឿនដំណើរការជាផ្លូវការ[១១២]។

មានវឌ្ឍនភាពមួយចំនួននៅក្នុងតំបន់អាស៊ានលើបញ្ហានេះ។ នៅ**ប្រទេសហ្វីលីពីន** តុលាការកំពូលបានចេញ *គោលការណ៍ណែនាំដែលបានកែប្រែសម្រាប់បន្តការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌ* ដែលហាមឃាត់ការពន្យារពេល លើកលែងតែមានករណីប្រធានសក្តិ ឬ អសមត្ថភាពផ្លូវការរបស់សាក្សីក្នុងការផ្តល់សាក្សី។ *សេចក្តីណែនាំ* បានរៀបរាប់នូវសំណើសុំដែលធ្វើឱ្យយឺតយ៉ាវដែលត្រូវបានហាមឃាត់ដែលអាចបដិសេធភ្លាមៗ និងកាត់បន្ថយថិរវេលាសម្រាប់ដោះស្រាយលើសំណើទាំងនេះ និងដំណើរការជំនុំជម្រះ។ *គោលការណ៍ណែនាំ* អនុវត្តចំពោះសំណុំរឿងព្រហ្មទណ្ឌទាំងអស់ សូម្បីតែសំណុំរឿងពាក់ព័ន្ធនឹងច្បាប់ពិសេសដូចជាច្បាប់ស្តីពីការជួញដូរមនុស្សជាដើម និងនៅក្នុងករណីមានទំនាស់ពាក់ព័ន្ធនឹងពេលវេលានៃការជំនុំជម្រះ និងថិរវេលានៃការសម្រេចទៅលើសំណុំរឿង ដោយអនុវត្តតាមពេលវេលាដែលខ្លី។ **ប្រទេសមីយ៉ាន់ម៉ា** បានរាយការណ៍ថា ការរៀបចំការអនុម័តទៅលើការកំណត់ទោសទណ្ឌសម្រាប់ការចោទប្រកាន់នៅក្នុងសំណុំរឿងជួញដូរមនុស្ស ត្រូវឆ្លងកាត់ស្ថាប័នរដ្ឋ/តំបន់សម្រាប់ការបង្ក្រាបការជួញដូរមនុស្ស កាត់បន្ថយការពន្យារពេលចោទប្រកាន់ទៅលើសំណុំរឿងជួញដូរមនុស្ស។

នៅឆ្នាំ២០១៥ **ប្រទេសថៃ** បានបង្កើតផ្នែកជំនួយប្រឆាំងការជួញដូរមនុស្ស នៅក្នុងតុលាការព្រហ្មទណ្ឌក្រុងបាងកកដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ឱ្យមានសាលក្រមឆាប់រហ័ស និងភាពឯកទេសផ្នែកជួញដូរក្នុងចំណោមព្រះរាជអាជ្ញា និងចៅក្រម។ ផ្នែកនេះរួមមានចៅក្រម ១២ រូបដែលបានទទួលការបណ្តុះបណ្តាលឯកទេសផ្នែកជួញដូរមនុស្ស។ (កត់សម្គាល់ថា ការិយាល័យវិស័យតុលាការមានអាណត្តិការងារផ្តល់ការបណ្តុះបណ្តាលផ្នែកជួញដូរមនុស្ស ដល់ចៅក្រមទាំងអស់ដែលមានភាពគុណវុឌ្ឍិគ្រប់គ្រាន់)។ ផ្នែកនេះមានយុត្តាធិការទៅលើសំណុំរឿងនានានៅក្នុងក្រុងបាងកក និងសំណុំរឿងដែលបញ្ជូនមកពីតុលាការផ្សេងទៀត អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ កំណែទម្រង់ផ្សេងទៀតកំពុងដំណើរការ ដូចជាការបង្កើតក្រុមអ្នកបកប្រែដែលមានការទទួលស្គាល់ សម្រាប់បន្ទប់សវនាការនៅទូទាំងប្រទេស ដែលរំពឹងថានឹងចូលរួមចំណែកបន្ថែមទៀតក្នុងការកែលម្អប្រសិទ្ធភាពរបស់តុលាការក្នុងការដោះស្រាយសំណុំរឿងជួញដូរមនុស្ស។

---

[១១២] គោលការណ៍ណែនាំអ្នកប្រតិបត្តិនៅអាស៊ាន វគ្គ ១ ផ្នែក ២ កថាខណ្ឌ ២.១០។

# ៤.៣ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត

សម្រាប់ព្រះរាជអាជ្ញា និងចៅក្រម នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ការជួញដូរមនុស្សនៅតែបន្តជាបទល្មើសថ្មី។ ព្រះរាជអាជ្ញា និងចៅក្រមជាច្រើនមិនធ្លាប់ចូលរួមដោយផ្ទាល់ទៅក្នុងសំណុំរឿងទាំងនេះទេ ហើយច្បាប់ពាក់ព័ន្ធក៏នៅថ្មី និងមិនទាន់បានសាកល្បងយកមកប្រើដែរ។ មានការបោះជំហានសំខាន់ៗមួយចំនួនឆ្ពោះទៅការអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិឲ្យមានប្រសិទ្ធភាពដើម្បីចោទប្រកាន់ និងវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ។ ផ្នែកនេះធ្វើសង្ខេបអំពីការប្រឈមធំៗរបស់ព្រះរាជអាជ្ញា និងចៅក្រមនៅក្នុងរដ្ឋសមាជិកអាស៊ាន ដោយមានយោងទៅដល់បញ្ហានីមួយៗក្នុងចំណោមបញ្ហាធំៗដែលបានបង្ហាញនៅដើមជំពូកនេះ។ បន្ទាប់មក វាបង្ហាញពីឱកាសសំខាន់ៗមួយចំនួនសម្រាប់អនាគត។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការបណ្តុះបណ្តាល

នាពេលបច្ចុប្បន្ន ការបណ្តុះបណ្តាលសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាមានការបោះជំហានយ៉ាងល្អនៅក្នុងតំបន់អាស៊ានទាំងមូល។ កម្មវិធីអាស៊ានចំនួន ២ ដែលបានពិពណ៌នានៅក្នុងផ្នែក ៤.២ ខាងលើផ្តល់នូវមូលដ្ឋានគ្រឹះរឹងមាំមួយសម្រាប់ធានាថា ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់មានចំណេះដឹង និងឯកទេសដែលចាំបាច់ដើម្បីបំពេញទៅតាមការទទួលខុសត្រូវសំខាន់ៗរបស់ខ្លួនទាក់ទងនឹងសំណុំរឿងជួញដូរមនុស្ស។

មានការផ្តល់អនុសាសន៍នូវសកម្មភាពជាក់លាក់ខាងក្រោមដើម្បីធានាថារក្សាឲ្យបាននូវសន្ទុះបច្ចុប្បន្ន៖

- វឌ្ឍនភាពឆ្ពោះទៅការធ្វើជាស្ថាប័ននៃ *កម្មវិធីយល់ដឹងស្តីពីការជួញដូរមនុស្សសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាអាស៊ាន* គួរត្រូវបានរក្សាទុក និងបង្កើនឡើង ក្នុងគោលបំណងធានាថា ជាចុងក្រោយ រដ្ឋសមាជិកអាស៊ានទាំងអស់មានសមត្ថភាពផ្តល់វគ្គនេះដល់ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់។
- រដ្ឋសមាជិកអាស៊ានក៏គួរតែធ្វើដំណើរឆ្ពោះទៅអភិវឌ្ឍ *កម្មវិធីជំនាញស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញាអាស៊ាន* ជាសំណៅជាក់លាក់ទៅតាមបរិបទជាតិ និងធានានូវសមត្ថភាពថ្នាក់ជាតិ ដើម្បីផ្តល់វគ្គនេះ និងនៅពេលចាំបាច់។
- ទាក់ទងកម្មវិធីទាំងពីរនេះ ជាការសំខាន់ដែលថា កម្មវិធីនេះស្ថិតក្រោមការវាយតម្លៃនិងពិនិត្យជាទៀងទាត់ និងត្រូវបានធ្វើបច្ចុប្បន្នទៅតាមការតម្រូវ ដើម្បីធានាថា ពួកគេនៅមានភាពពាក់ព័ន្ធទៅនឹងស្ថានភាពនៅថ្នាក់ជាតិ និងការទទួលខុសត្រូវរបស់សិក្ខាកាម។ ចំណុចនេះបញ្ចូលការវាយតម្លៃសំណុំរឿងដោយគិតទៅដល់ការកំណត់អំពីបញ្ហា និងភាពខ្សោយដែលនឹងត្រូវដោះស្រាយតាមរយៈការបណ្តុះបណ្តាល។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងឯកភាពកម្ម

ផ្នែក ៤.២. បានរៀបរាប់លម្អិតនូវវឌ្ឍនសំខាន់ៗមួយចំនួនទាក់ទងនឹងគោលដៅបង្កើនភាពឯកទេសរបស់អាស៊ានក្នុងការឆ្លើយតបតាមរយៈការចោទប្រកាន់ទៅនឹងការជួញដូរ។ ក៏ប៉ុន្តែ នៅក្នុងប្រទេសដែលមាន (ឬគួរតែមាន) បន្ទុកការងារធ្ងន់ធ្ងរ ការដែលពុំមានអង្គភាពឯកទេសដំណើរការពេញលេញ ដើម្បីយកចិត្តទុកដាក់ក្នុងការចោទប្រកាន់

សំណុំរឿងជួញដូរមនុស្ស គឺជាបញ្ហា។ អង្គភាពពិសេសទាំងនេះ ដែលរួមមានព្រះរាជអាជ្ញាដែលទទួលបានបណ្ដុះបណ្ដាលជាពិសេស និងបុគ្គលិកជំនួយដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គភាពស៊ើបអង្កេតឯកទេស ត្រៀមរួចជាស្រេចក្នុងប្រតិបត្តិការនៅទូទាំងតំបន់ នឹងបំពេញការងារបានច្រើនក្នុងការដោះស្រាយបញ្ហានានាដែលបានកត់សម្គាល់ខាងលើ ដោយប្រមូលផ្ដុំធនធាន និងបទពិសោធន៍ស្ដីពីសំណុំរឿងជួញដូរមនុស្ស ដែលលំបាក និងមានលក្ខណៈរស៊ើបបំផុត។ អង្គភាពឯកទេសក៏អាចជាធនធានមួយសម្រាប់អង្គភាពនគរបាល និងព្រះរាជអាជ្ញាដែលមានបទពិសោធន៍តិចតួច ដែលកាន់សំណុំរឿងជួញដូរតូចតាច នៅតាមខេត្ត ដោយផ្ដល់ការណែនាំ ការស្រាវជ្រាវ និងក្នុងករណីចាំបាច់ ជាការពិគ្រោះយោបល់នៅពេលជំនុំជម្រះ។ ការពិតទៅ គឺមិនចាំបាច់ធ្វើឱ្យមានអង្គភាពឯកទេសពេញលេញ នោះទេ។ នៅក្នុងប្រទេសមួយចំនួនដែលមានករណីជួញដូរតិចតួច ភាពជំនាញតាមរយៈការតែងតាំង និងការបណ្ដុះបណ្ដាលដល់ព្រះរាជអាជ្ញាម្នាក់ ឬពីរនាក់អាចទទួលផលប្រយោជន៍ដូចគ្នា។

នាពេលថ្មីៗនេះ គំនិតផ្ដួចផ្ដើមជាច្រើនកំពុងដំណើរការ ឬត្រូវបានផ្ដល់អនុសាសន៍នៅក្នុងជំពូកនេះ នឹងចែករំលែកដោយផ្ទាល់ដល់គោលដៅ នៃការសម្រេចឱ្យបាននូវការឆ្លើយតបតាមរយៈការចោទប្រកាន់ឯកទេសទៅនឹងការជួញដូរ។ ឧទាហរណ៍ ជំពូកនេះបានកត់សម្គាល់នូវសារៈសំខាន់ នៃ៖

- ការផ្ដល់ជាទៀងទាត់នូវ សំណៅដែលត្រូវបានអនុម័តទៅតាមបរិបទថ្នាក់ជាតិនៃ *កម្មវិធីជំនាញស្ដីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញាអាស៊ាន* ៖ ការបង្កើតក្រុមព្រះរាជអាជ្ញានៃរដ្ឋសមាជិកអាស៊ានដែលមានចំណេះដឹង និងជំនាញពិសេស និងដោយឡែកនៅក្នុងវិស័យជួញដូរ
- ចាត់តាំងសំណុំរឿងជួញដូរមនុស្ស ដល់ព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្ដុះបណ្ដាលឯកទេស ដោយជោគជ័យ
- ការប្ដេជ្ញាចិត្តខ្លាំងជាងមុន និងការអនុវត្តន៍នៅក្នុងកិច្ចសហប្រតិបត្តិការតាមផ្លូវច្បាប់ជាអន្តរជាតិ និងទម្រង់ផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការឆ្លងដែន ដែលនឹងពង្រឹងទំនាក់ទំនងរវាងអ្នកដែលធ្វើការក្នុងវិស័យនេះ។
- មានព្រះរាជអាជ្ញាដែលទទួលការបណ្ដុះបណ្ដាលពិសេសដើម្បីជួយសហការីក្នុងការស៊ើបអង្កេត និងចោទប្រកាន់ក្នុងសំណុំរឿងជួញដូរ
- ការបង្កើតប្រព័ន្ធជូនដំណឹងដែលអាចជំនួយដល់សមត្ថភាពព្រះរាជអាជ្ញាពិសេស និងវិភាគលើទិន្នន័យផ្នែកជួញដូរថ្នាក់ជាតិ និងផ្ដល់ជំនួយលើសំណុំរឿងនានាក្នុងករណីចាំបាច់
- អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាដែលទទួលការបណ្ដុះបណ្ដាលពិសេសត្រូវធ្វើការរួមគ្នា នៅក្នុងដំណើរការស៊ើបអង្កេតទាំងមូល និងការចោទប្រកាន់ក្នុងសំណុំរឿងជួញដូរ នៅក្នុងការការពារដែលទទួលស្គាល់ដោយច្បាប់។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា

នៅក្នុងតំបន់អាស៊ាន គំរូនៃកិច្ចសហប្រតិបត្តិការរវាងមន្ត្រីនគរបាល និងព្រះរាជអាជ្ញាមិនត្រូវបានបង្កើតឡើងឱ្យបានសមរម្យទេ។ ទាក់ទងនឹងសំណុំរឿងជួញដូរ កិច្ចសហប្រតិបត្តិការនេះបន្តមានដោយកម្រ។ ជាក់ស្ដែង ការវិភាគ

សំណុំរឿងបានបញ្ជាក់ថា ក្នុងករណីមួយចំនួន អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញានឹងជួបគ្នាតែនៅពេលជំនុំជម្រះប៉ុណ្ណោះ ឬការពិត អត់សោះតែម្តង។ កង្វះកិច្ចសហប្រតិបត្តិការនេះអាចរារាំងមិនឱ្យធ្វើការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរយ៉ាងជោគជ័យទេ។ វាក៏មានឥទ្ធិពលជាអវិជ្ជមានផងដែរទៅលើជនរងគ្រោះ ឧទាហរណ៍ ដោយបង្ខាញពួកគេនៅក្នុងការស្តាប់ចម្លើយដែលមិនចាំបាច់។ ការស្តាប់ចម្លើយជនរងគ្រោះជាច្រើន និងគ្មានការសម្របសម្រួល ក្លាយជាទម្លាប់អនុវត្តន៍ជាប្រចាំនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន។ ឧទាហរណ៍ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយ ពីដំបូងជនរងគ្រោះពីការជួញដូរបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេត ដែលបានបញ្ចប់សំណុំរឿងពាក់ព័ន្ធដោយមិនបានពិគ្រោះយោបល់ជាមួយព្រះរាជអាជ្ញាទេ។ បន្ទាប់មក ព្រះរាជអាជ្ញាបានទទួលយកសំណុំរឿងនោះ ដោយមិនបានពិភាក្សាជាមួយមន្ត្រីនគរបាលទេ ហើយក៏បានស្តាប់ចម្លើយជនរងគ្រោះម្តងទៀត។ ចៅក្រមចង់ធ្វើការស៊ើបអង្កេតដោយខ្លួនឯងដោយគ្មានការពិគ្រោះយោបល់ជាមួយអ្នកស៊ើបអង្កេតដែលជាមន្ត្រីនគរបាល ដែលបានចូលរួមក្នុងការស៊ើបអង្កេតពីដំបូង។ ទោះបីចៅក្រមបានទទួលការជូនដំណឹងជាប្រចាំពីព្រះរាជអាជ្ញានូវការស៊ើបអង្កេតរបស់ខ្លួនក៏ដោយ តែព្រះរាជអាជ្ញាកម្រចូលរួមក្នុងការស្តាប់ចម្លើយដែលធ្វើឡើងដោយចៅក្រមណាស់។ នាពេលបច្ចុប្បន្ននេះ ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានមួយនេះហាក់ដូចជាអនុញ្ញាតឱ្យមានកិច្ចសហប្រតិបត្តិការ និងការសហការកាន់តែទូលំទូលាយ។ ហេតុនេះ កាលានុវត្តភាពក្នុងការពង្រឹងការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស ត្រូវបានបាត់បង់។

កង្វះកិច្ចសហប្រតិបត្តិការរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាក៏អាចធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរទៅលើសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងការផ្តល់យុត្តិធម៌។ ឧទាហរណ៍ នៅក្នុងសំណុំរឿងជាច្រើនដែលត្រូវបានពិនិត្យឡើងវិញសម្រាប់*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ សំណុំរឿងស៊ើបអង្កេតមិនត្រូវបានផ្តល់ជូនព្រះរាជអាជ្ញាទេរហូតដល់មួយរយៈខ្លីមុនពេល ដែលរយៈពេលឃុំខ្លួនជនជាប់ចោទផុតកំណត់ ដែលធ្វើឱ្យកាន់តែលំបាកដល់ការស៊ើបអង្កេត និងតម្រូវឱ្យធ្វើការសម្រេចចោទប្រកាន់ឱ្យបានឆាប់ មុនពេលបញ្ចប់ការពិនិត្យភស្តុតាងឱ្យបានគ្រប់ជ្រុងជ្រោយ និងយកចិត្តទុកដាក់ជាក់ស្តែង។ វាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេដែលថា សម្ពាធនៃពេលវេលាបណ្តាលឱ្យមានកំហុសឆ្គងនៅក្នុងសាលក្រម។ ហេតុនេះនៅក្នុងសំណុំរឿងមួយដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីពលកម្មកុមារ ដោយស្ថិតក្រោមសម្ពាធការផុតកំណត់រយៈពេលខ្លី ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពីការជួញដូរ ទោះបីជនជាប់ចោទ និងជនរងគ្រោះជាសាច់ញាតិនឹងគ្នា ហើយទោះបីជនរងគ្រោះបានអះអាងថា ពួកគេមិនត្រូវបានគេងប្រវ័ញ្ចទេ តែគ្រាន់តែជួយគ្រួសាររបស់ខ្លួនក៏ដោយ។ នៅពេលជំនុំជម្រះ ការចោទប្រកាន់ពីការជួញដូរត្រូវបានបដិសេធដោយតុលាការ ដោយសារពុំមានភស្តុតាងគ្រប់គ្រាន់។ ក៏ប៉ុន្តែ ជនជាប់ចោទបានចំណាយពេលជិតមួយឆ្នាំ នៅក្នុងការឃុំឃាំងរង់ចាំការជំនុំជម្រះ និងមិនត្រូវបានដោះលែងឱ្យនៅក្រៅឃុំដោយសារតែភាពធ្ងន់ធ្ងរនៃការប្រកាន់មកលើរូបគាត់។ ប្រសិនបើព្រះរាជអាជ្ញាមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិចារណាទៅលើភស្តុតាងឱ្យបានពេញលេញមុននឹងសម្រេចចោទប្រកាន់ ភាពអយុត្តិធម៌ធ្ងន់ធ្ងរមកលើជនស្លូតត្រង់ប្រហែលជាអាចបញ្ចៀសបាន។

សរុបមក នៅក្នុងសំណុំរឿងភាគច្រើន ពុំទាន់មានកិច្ចសហប្រតិបត្តិការគ្នាជាផ្លែផ្កានៅឡើយទេ រវាងមន្ត្រីនគរបាល និងព្រះរាជអាជ្ញា នៅដំណាក់កាលស៊ើបអង្កេត។ ការមិនទាក់ទងគ្នានេះនាំឱ្យមានការប្រមូលភស្តុតាងមិនបានពេញលេញ ពុំមានយុទ្ធសាស្ត្រស៊ើបអង្កេតត្រឹមត្រូវ ធ្វើការចាប់ខ្លួនលឿនពេក ការដោះស្រាយចំពោះជនរងគ្រោះមិនបានល្អ ការស្តាប់ចម្លើយសាក្សីជាជនរងគ្រោះ និងជនរងគ្រោះមិនបានល្អ ការពន្យារពេលស៊ើបអង្កេត ឬស៊ើបអង្កេតមិនពេញលេញ និង ការមិនទុកចិត្តគ្នា និងការមិនគោរពគ្នា ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការឆ្លើយតបតាមរយៈការអនុវត្តន៍ច្បាប់ដែលមានប្រសិទ្ធភាព និងការសម្របសម្រួលត្រឹមត្រូវ ទៅនឹងការជួញដូរ។ ជួនកាល កង្វះក្រុមការងារ

ដែលទទួលអាណត្តិការងារ ដោយវិធីនីតិវិធី ឬទម្លាប់អនុវត្តន៍ជាយូរឆ្នាំមកហើយ ដែលតម្រូវឲ្យមានការបែងចែងដាច់ពីគ្នារវាងមុខងារស៊ើបអង្កេត និងចោទប្រកាន់។ ក៏ប៉ុន្តែ ក្នុងសភាពជាក់ស្តែង ឧបសគ្គទាំងនេះ ចំពោះវិធីសាស្ត្រធ្វើការជាក្រុមចំពោះការជួញដូរមនុស្ស ភាគច្រើនជាការប្រឌិត ហើយបញ្ហានេះត្រូវបានគេមើលឃើញថា គឺជាឆន្ទះដែលភាគីទាំងពីរ រវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ក្នុងការធ្វើបែបនេះ។

ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋសមាជិកអាស៊ានចាប់ផ្តើមមានការយល់ដឹង និងឲ្យតម្លៃដល់ផលប្រយោជន៍នៃកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ។ ដំណើរការនោះគួរតែត្រូវបានបង្កើន និងគាំទ្រ។ ជាពិសេស រដ្ឋសមាជិកអាស៊ានគួរពិចារណាដល់៖

- ការកំណត់នូវបទបញ្ញា ឬការអនុវត្តន៍ជាក់ស្តែងដែលរារាំងដល់កិច្ចសហប្រតិបត្តិការ និងកែប្រែបទបញ្ញា ឬការអនុវត្តន៍ទាំងនោះ ដើម្បីកាត់បន្ថយឧបសគ្គផ្លូវការ
- ផ្តល់សេចក្តីថ្លែងពីគោលនយោបាយច្បាស់លាស់ពីថ្នាក់ដឹកនាំ នៅកម្រិតកំពូលដែលអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញារំពឹងថានឹងធ្វើការរួមគ្នាជាក្រុមនៅគ្រប់ដំណាក់កាលទាំងអស់នៃការស៊ើបអង្កេតលើការជួញដូរមនុស្ស និងការចោទប្រកាន់ ដោយមានការការពារសមរម្យ ដើម្បីបញ្ចៀសសភាពជាក់ស្តែង ឬការយល់ឃើញរបស់សាក្សី ដែលត្រូវណែនាំ ឬអុកឡុករំខានរបស់ជនសង្ស័យ
- ដំណើរការសិក្ខាសាលារួមគ្នារវាងនគរបាល និងព្រះរាជអាជ្ញាក្នុងការបង្កើតយុទ្ធសាស្ត្រអនុវត្តន៍ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការឲ្យកាន់តែច្រើនឡើងៗ
- ផ្តល់ការណែនាំផ្ទៃក្នុង ដើម្បីបញ្ជាក់បំភ្លឺអំពីតួនាទី និងការទទួលខុសត្រូវរៀងៗគ្នារបស់អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ក្នុងការធ្វើការជាមួយគ្នានៅក្នុងសំណុំរឿងជួញដូរមនុស្ស
- ដំណើរការបណ្តុះបណ្តាលឯកទេសរួមគ្នាសម្រាប់នគរបាល និងព្រះរាជអាជ្ញា
- ស្វែងយល់ពីលទ្ធភាពនៃការធ្វើការងាររួមគ្នា រវាងអ្នកស៊ើបអង្កេតឯកទេស និងព្រះរាជអាជ្ញាឯកទេស។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការគ្រប់គ្រងជនរងគ្រោះ និងសាក្សី

ជំពូកនេះបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់ដែលគាំទ្រយ៉ាងសមរម្យដល់សាក្សីជាជនរងគ្រោះ នៅក្នុងការឆ្លើយតបតាមរយៈប្រព័ន្ធយុត្តិធម៌ទៅនឹងការជួញដូរ។ ដូចបានពន្យល់លម្អិតនៅក្នុងផ្នែក ៤.២ ខាងលើ ព្រះរាជអាជ្ញាមានតួនាទីសំខាន់ក្នុងការផ្តល់ឲ្យជនរងគ្រោះនូវការគាំទ្រ និងការលើកទឹកចិត្តដែលពួកគេត្រូវការដើម្បីឲ្យក្លាយជាសាក្សីល្អ និងជឿជាក់បាន។ ការខកខានមិនអាចគ្រប់គ្រងជនរងគ្រោះយ៉ាងមានប្រសិទ្ធភាពបាន ប្រាកដជាប៉ះពាល់ដល់សុខុមាលភាពរបស់ជនរងគ្រោះ និងលទ្ធភាពជោគជ័យនៃការចោទប្រកាន់។ ការប្រឈមជាក់លាក់មួយចំនួនទាក់ទងនឹងការគ្រប់គ្រងជនរងគ្រោះ និងសាក្សីត្រូវបានបង្ហាញ និងពិភាក្សាដូចខាងក្រោម។

**ការគ្រប់គ្រងសាក្សីជាជនរងគ្រោះមុនពេលជំនុំជម្រះ៖** ជាទូទៅ ព្រះរាជអាជ្ញានៅក្នុងតំបន់អាស៊ានមិនបានជួបសាក្សីមុនពេលជំនុំជម្រះទេ ហើយក៏មិនបានផ្សាំពួកគេទៅនឹងដំណើរការ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការនិយាយការពិត ឬពិនិត្យទៅលើខ្លឹមសារនៃសេចក្តីកម្មរបស់ពួកគេដែរ។ ដូចបានកត់សម្គាល់ពីមុនមក ការទាក់ទងលើកដំបូងដែលព្រះរាជអាជ្ញាបានធ្វើជាមួយសាក្សី នៅក្នុងសំណុំរឿងជាច្រើនដែលត្រូវបានយកមកពិនិត្យសម្រាប់របាយការណ៍នេះ គឺធ្វើឡើង

នៅពេលជំនុំជម្រះជាក់ស្តែង។ ព្រះរាជអាជ្ញានៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើនបានសម្តែងការព្រួយបារម្ភថា ការត្រៀមមុនការជំនុំជម្រះអាចត្រូវបានគេមើលឃើញថាជាការណែនាំជនរងគ្រោះ ឬសាក្សី។ វាជាការសំខាន់ដែលគួរពិចារណាដល់ការព្រួយបារម្ភនេះ និងថាតើ វាតំណាងឲ្យឧបសគ្គពិតប្រាកដ ឬគ្រាន់តែជាការយល់ឃើញចំពោះការត្រៀមសាក្សីមុនការជំនុំជម្រះ។ ការពិនិត្យទៅលើច្បាប់ និងនីតិវិធីដែលពាក់ព័ន្ធនៅក្នុងរដ្ឋសមាជិកអាស៊ានហាក់ដូចជាបញ្ជាក់ថា ការជួបជាមួយសាក្សីសម្រាប់ត្រៀមមុនការជំនុំជម្រះ (ខុសពីការណែនាំសាក្សីដែលមិនត្រឹមត្រូវ) មិនត្រូវបានហាមឃាត់ទេ។ និយាយម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យជួប និងត្រៀមជាមួយសាក្សីមុនពេលជំនុំជម្រះ ដរាបណាគេធ្វើបែបនេះដោយមានការទទួលខុសត្រូវ និងសមស្រប។ ការណ៍ដែលថា រឿងនេះមិនបានកើតឡើងជាប្រចាំ បង្ហាញថា ចាំបាច់តម្រូវឲ្យមានការបណ្តុះបណ្តាលបន្ថែមទៀតស្តីពីសារៈសំខាន់ នៃការត្រៀមសាក្សីសំខាន់ទាំងអស់មុនការជំនុំជម្រះ ហើយក៏ជាការបែងចែកដាក់ពីគ្នារវាងការត្រៀមមុនការជំនុំជម្រះ និងការណែនាំមិនត្រឹមត្រូវដែរ។

នៅក្នុងសំណុំរឿងមួយទៀត ដែលបានពិនិត្យសម្រាប់របាយការណ៍នេះ ជនរងគ្រោះនៅក្នុងសំណុំរឿងជួញដូរបានរត់ចេញពីទីជម្រកដែលពួកគេត្រូវបានដាក់ មុនពេលជំនុំជម្រះ ដោយសារពួកគេមិនសប្បាយចិត្តទៅនឹងការវិវត្តន៍យ៉ាងយឺតយ៉ាវនៃសំណុំរឿង និងស្ថានភាពរស់នៅនៅក្នុងទីជម្រកនោះ។ ជាលទ្ធផល សំណុំរឿងនៅពេលជំនុំជម្រះទទួលបរាជ័យ ហើយជនជាប់ចោទពុំត្រូវបានរកឃើញថាមានពិរុទ្ធទេ។ ព្រះរាជអាជ្ញាមិនបានបង្កើតទំនាក់ទំនងជាមួយជនរងគ្រោះនៅក្នុងពេលកំពុងរង់ចាំនោះ។ ប្រសិនបើព្រះរាជអាជ្ញាបានទំនាក់ទំនង គាត់ប្រហែលជាអាចដោះស្រាយការព្រួយបារម្ភរបស់ពួកគេ និងអាចរក្សាបាននូវកិច្ចសហការពីពួកគេ។ គាត់ក៏អាចដឹងពីភាពផុយស្រួយនៃស្ថានភាពរបស់ជនរងគ្រោះ ហើយអាចចាត់វិធានការដើម្បីកត់ត្រាសក្ខីកម្មពួកគេមុនការជំនុំជម្រះ ដើម្បីធានាថា ភស្តុតាងសំខាន់អាចរកបាននៅពេលជំនុំជម្រះ ទោះបីជនរងគ្រោះបានដកកិច្ចសហការរបស់ខ្លួនចេញក៏ដោយ។

**ការគ្រប់គ្រងសាក្សីជាជនរងគ្រោះក្នុងដំណើរការជំនុំជម្រះ៖** ដូចបានកត់សម្គាល់នៅផ្នែក ៤.២ ខាងលើ ការគ្រប់គ្រងជនរងគ្រោះជារឿងកម្រ បើទោះបីជាព្រះរាជអាជ្ញាផ្តោតការយកចិត្តទុកដាក់ជាពិសេសក៏ដោយ ឧទាហរណ៍តាមរយៈការបង្កើតផែនការគ្រប់គ្រងដើម្បីធានាថាជនរងគ្រោះ ដែលផ្តល់សក្ខីកម្មមានភាពសុខស្រួលក្នុងចិត្តទៅនឹងដំណើរការរបស់តុលាការ និងទទួលការការពារពីការរំខានផ្សេងៗដល់ពួកគេ។ នៅក្នុងករណីមួយទៀត មានការសង្កេតឃើញថា ជនរងគ្រោះដែលផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងជួញដូរត្រូវបានទុកចោលម្នាក់នៅក្នុងបន្ទប់សវនាការប្រឈមនឹងជនជាប់ចោទ និងមេធាវីការពារក្តី នៅពេលរង់ចាំផ្តល់សក្ខីកម្ម។ នៅពេលឈប់សម្រាកកិច្ចដំណើរការនីតិវិធី មេធាវីការពារក្តីទៅនិយាយជាមួយជនរងគ្រោះម្នាក់នៅក្នុងបន្ទប់សវនាការ ហើយដំណើរការស្តាប់ចម្លើយពួកគេតាមចិត្តខ្លួនចង់។

នៅក្នុងករណីមួយទៀត ជនសង្ស័យ និងគូរកនរបស់ខ្លួនបានទៅនិយាយជាមួយជនរងគ្រោះ នៅពេលពួកគេធ្វើដំណើរមកផ្តល់សក្ខីកម្មនៅតុលាការ។ ជាអកុសល នេះមិនដែលជាឧទាហរណ៍ដោយឡែកតែមួយទេ។ ព្រះរាជអាជ្ញានៅក្នុងរដ្ឋសមាជិកអាស៊ានបានកត់សម្គាល់ថា ជារឿយៗជនរងគ្រោះ ឬគ្រួសាររបស់ពួកគេត្រូវបានផ្តល់សំណូក ឬគំរាមកំហែងដោយជនជួញដូរ នៅក្នុងការប៉ុនប៉ងបំបាក់ជនរងគ្រោះមិនឲ្យសហការជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលជាញឹកញយបានទទួលជោគជ័យ។ ពុំមានរកឃើញករណីដែលអំពើរាំងយុត្តិធម៌បែបនេះត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ទេ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយ សាក្សីម្នាក់ដែលបានទទួលការគាំទ្រពី អង្គការក្រៅរដ្ឋាភិបាលបានទទួលការអនុញ្ញាតឲ្យពន្យារពេលផ្តល់សក្ខីកម្ម ក្រោយពេលមានការបៀតបៀនពីជនជាប់ចោទនៅតាមផ្លូវមកកាន់

តុលាការ។ ការមិនបានឆ្លើយតបទៅនឹងការរំខានផ្សេងៗចំពោះសាក្សី ធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់សាក្សីមកលើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងបណ្តោយឱ្យឧក្រិដ្ឋជនបន្តប្រតិបត្តិការអំពើនិទណ្ឌភាពបន្តទៀត។ ព្រះរាជអាជ្ញាដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីនគរបាល គួរគិតគូរនិងចោទប្រកាន់ពីការរំខានសាក្សី ដែលត្រូវស៊ើបអង្កេត ថាជាការរំលោភបំពានទៅលើច្បាប់ស្តីពីការការរំខាន ការផ្តល់សំណូក ឬបំផ្លាញសាក្សី និងចោទប្រកាន់ករណីនេះឱ្យបានធ្ងន់ធ្ងរនៅពេលមានភស្តុតាងគ្រប់គ្រាន់។

**ការការពារសាក្សីងាយរងគ្រោះនៅក្នុងពេលសវនាការ៖** ការប្រឈមនៃការផ្តល់ការការពារយ៉ាងខ្លាំងក្លាដល់សាក្សីនៅក្នុងពេលសវនាការ ជារឿងស្រួចស្រាវមួយនៅក្នុងតំបន់អាស៊ានទាំងមូល។ ទោះបីរដ្ឋសមាជិកអាស៊ានជាច្រើនកាន់តែចាត់វិធានការនានាដើម្បីផ្តល់នូវការការពារតាមច្បាប់ និងនីតិវិធីដល់ជនរងគ្រោះដែលងាយរងគ្រោះក៏ដោយ តែក្នុងសភាពជាក់ស្តែងគឺថាសាក្សីជាជនរងគ្រោះភាគច្រើនដែលផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងជួញដូរមិនបានទទួលការការពារនេះទេ។ ឧទាហរណ៍ នៅក្នុងការជំនុំជម្រះមួយ មានការសង្កេតថា កុមារដែលផ្តល់ភស្តុតាងអំពីបញ្ហារសើបខ្លាំង រួមមានការបំពានផ្លូវភេទជាដើម នៅក្នុងតុលាការជាសាធារណៈ ដោយគ្មានការការពារដល់ជនរងគ្រោះ ដូចជា ប្រព័ន្ធសោតទស្សន៍ ឬរបាំងជាក់ស្តែងរវាងជនរងគ្រោះ និងជនជាប់ចោទ។ ជាការសំខាន់ដែលថាព្រះរាជអាជ្ញាត្រូវយល់ដឹងពីលក្ខណៈរសើបនៃភាពងាយរងគ្រោះរបស់ជនរងគ្រោះពីការជួញដូរ ជាពិសេសបំផុតគឺកុមារ ហើយព្រះរាជអាជ្ញាបានទទួលការបណ្តុះបណ្តាលឱ្យស្នើសុំការការពារសមស្របនៅពេលចាំបាច់ ឬជាការប្រសើរ។ ទោះបីព្រះរាជអាជ្ញាមិនបានស្នើសុំបែបនេះក៏ដោយ ចៅក្រមក៏មានការទទួលខុសត្រូវច្បាស់លាស់ដើម្បីធានាថា ការការពារក្នុងពេលសវនាការត្រូវបានប្រើប្រាស់ឱ្យបានត្រឹមត្រូវ។

**ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ៖** ការគ្រប់គ្រងសាក្សីជាជនរងគ្រោះយ៉ាងមានប្រសិទ្ធភាព អាចសម្របសម្រួលបានតាមរយៈការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ ក្នុងវិធីមួយដែលមិនបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ។ ដូចបានកត់សម្គាល់នៅក្នុងផ្នែក ៤.២ ខាងលើ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់រដ្ឋសមាជិកអាស៊ានជាច្រើនអនុញ្ញាតឱ្យប្រើមធ្យោបាយនេះ។ ក៏ប៉ុន្តែ បទពិសោធន៍បង្ហាញថា នៅក្នុងប្រទេសទាំងនេះ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីធានាថា នៅក្នុងករណីសមស្រប មានការស្នើសុំឱ្យមានសក្ខីកម្មមុនការជំនុំជម្រះ និងបញ្ចប់ឱ្យបានរហ័ស។ រដ្ឋសមាជិកអាស៊ានទាំងឡាយដែលមិនបានផ្តល់នូវលទ្ធភាពឱ្យមានសក្ខីកម្មមុនការជំនុំជម្រះ គួរពិចារណាដោយយកចិត្តទុកដាក់ចំពោះអត្ថប្រយោជន៍ដែលសក្ខីកម្មបែបនេះ បានផ្តល់ ក្នុងការកែលម្អការគ្រប់គ្រងជនរងគ្រោះជាសាក្សី និងបង្កើនភាពជោគជ័យនៃការចោទប្រកាន់។

**កាត់បន្ថយការពន្យារពេល៖** រដ្ឋសមាជិកអាស៊ានជាច្រើន ជួបប្រទះនូវការពន្យារពេលយ៉ាងយូរក្នុងការនាំយកសំណុំរឿងទៅជំនុំជម្រះ ការពន្យារបែបនេះអាចធ្វើឱ្យខូចខាតជាពិសេសដល់ដំណើការនៃសំណុំរឿងជួញដូរមនុស្ស។ ការណ៍ដែលជនរងគ្រោះត្រូវចំណាយពេលរង់ដំណើរការតាមផ្លូវតុលាការកាន់តែយូរ គាត់កាន់តែលែងប្តេជ្ញាចិត្ត ឬអាចដកខ្លួនចេញដោយសារការជ្រៀតជ្រែកពីជនជួញដូរផងដែរ។ ការអនុវត្តន៍នូវដំណើរការរហ័សសម្រាប់សំណុំរឿងជួញដូរមនុស្ស ធានាឱ្យមានការជំនុំជម្រះឆាប់រហ័ស ដែលនឹងជួយកាត់បន្ថយនូវហានិភ័យដល់ជនរងគ្រោះ និងបង្កើននូវលទ្ធភាពដែលថា ភស្តុតាងសំខាន់ៗនឹងមិនបាត់បង់។

សរុបសេចក្តីមក នៅមានការងារជាច្រើនទៀត ដែលត្រូវធ្វើ មុននឹងអាចធ្វើឱ្យការគ្រប់គ្រងជនរងគ្រោះ ជាសាក្សីឱ្យមានប្រសិទ្ធភាព ដោយព្រះរាជអាជ្ញា និង ចៅក្រមដើម្បីធ្វើឱ្យវាក្លាយទៅជាទម្លាប់នៅក្នុងតំបន់អាស៊ានទាំងមូល។ ព្រះរាជអាជ្ញាភាគច្រើនមិនមានជំនាញ និងការគាំទ្រ និងពេលវេលា ដើម្បីបង្កើតទំនាក់ទំនង និងទំនុកចិត្ត

ដែលចាំបាច់ ដើម្បីឱ្យជនរងគ្រោះធ្វើការសហការជាមួយប្រព័ន្ធយុត្តិធម៌ទេ។ ព្រះរាជអាជ្ញាមិនបានយល់ថា នេះជាការទទួលខុសត្រូវរបស់ខ្លួនក្នុងការរក្សាទំនាក់ទំនងជាប្រចាំជាមួយជនរងគ្រោះនៅមុនពេលជំនុំជម្រះ ត្រៀមជនរៀបចំជនរងគ្រោះឱ្យបានពេញលេញដើម្បីផ្តល់សក្ខីកម្មនៅក្នុងតុលាការ ឬមិនបានពិភាក្សាជាមួយសាក្សីនូវវិធានការដែលមានដើម្បីធានាផ្តល់សន្តិសុខ និងឯកជនភាពរបស់ជនរងគ្រោះនៅក្នុងតុលាការឡើយ។ ការដែលមិនមានការគាំទ្រឱ្យបានត្រឹមត្រូវដល់ជនរងគ្រោះជារឿយៗ ភាគច្រើនបណ្តាលឱ្យសំណុំរឿងទទួលបរាជ័យ ដោយសារជនរងគ្រោះដកបណ្តឹងខ្លួនចេញវិញ ឬផ្តល់សក្ខីកម្មមិនបានល្អនៅពេលជំនុំជម្រះ ឬអាចមិនបង្ហាញខ្លួន និងមិនអាចមកផ្តល់ភស្តុតាងនៅពេលជំនុំជម្រះបាន។

អនុសាសន៍ជាក់លាក់សម្រាប់រដ្ឋសមាជិកអាស៊ានទាំងអស់ទាក់ទងនឹងការគ្រប់គ្រង ជនរងគ្រោះជាសាក្សីរួមមាន៖

- ព្រះរាជអាជ្ញាគួរធ្វើកិច្ចសហការយ៉ាងសកម្មជាមួយអ្នកស៊ើបអង្កេត ដើម្បីធានានូវការគ្រប់គ្រងដល់ជនរងគ្រោះជាសាក្សីយ៉ាងមានប្រសិទ្ធភាព។
- ព្រះរាជអាជ្ញាគួរស្វែងរកការបញ្ជាក់ ពីថ្នាក់លើ ថាការប្រជុំត្រៀមមុនការជំនុំជម្រះជាមួយសាក្សី (ខុសពី *ការណែនាំ*មិនត្រឹមត្រូវ) មិនត្រូវបានហាមឃាត់ទេ។
- ព្រះរាជអាជ្ញាត្រូវធានាថា ត្រូវរក្សាទំនាក់ទំនងជាញឹកញយជាមួយជនរងគ្រោះក្នុងអំឡុងពេលមុនការជំនុំជម្រះ ដើម្បីកាត់បន្ថយហានិភ័យដែលថា កិច្ចសហប្រតិបត្តិការនឹងត្រូវបានដកចេញតាមរយៈការដោះស្រាយក្រៅផ្លូវការ។
- ព្រះរាជអាជ្ញាគួរត្រៀមជនរងគ្រោះឱ្យបានល្អ ដើម្បីឱ្យអាចផ្តល់សក្ខីកម្មដែលមានប្រសិទ្ធភាព និងជឿជាក់បាននៅពេលជំនុំជម្រះ ដោយបញ្ចៀសនូវការយល់ឃើញ ថាពួកគេត្រូវបានបង្ហាត់ឱ្យផ្តល់សក្ខីកម្ម។
- សក្ខីកម្មមុនពេលជំនុំជម្រះគួរត្រូវបានយកមកប្រើប្រាស់ ដើម្បីរក្សាសក្ខីកម្មរបស់ជនរងគ្រោះ និងពន្លឿនដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍ របស់ជនរងគ្រោះ។ នៅពេលច្បាប់មិនអនុញ្ញាត ឬកំហិតមិនត្រឹមត្រូវនូវការប្រើប្រាស់នូវការអនុវត្តន៍សក្ខីកម្មមុនការជំនុំជម្រះ គួរពិចារណាដល់ការកែប្រែវិធាននីតិវិធីដើម្បីអនុញ្ញាតឱ្យស្តាប់ចម្លើយមុនការជំនុំជម្រះ នៅក្រោមស្ថានភាពដែលស្របទៅនឹងវិធាននៃដំណើរការដោយត្រឹមត្រូវ និងអនុញ្ញាតឱ្យយកទៅប្រើប្រាស់ជាភស្តុតាង លើអង្គសេចក្តីនៅក្នុងតុលាការ។
- ព្រះរាជអាជ្ញា ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស៊ើបអង្កេត គួរធ្វើការវាយតម្លៃហានិភ័យ និងបង្កើតផែនការគ្រប់គ្រងជនរងគ្រោះ ធ្វើការកិច្ចការប្រចាំថ្ងៃនៅក្នុងសំណុំរឿងជួញដូរមនុស្សទាំងអស់។
- គួរពិចារណាដល់ការអនុវត្តនូវប្រព័ន្ធលឿនសម្រាប់សំណុំរឿងជួញដូរមនុស្ស ដើម្បីធានាឱ្យមានការជំនុំជម្រះឆាប់រហ័ស និងកាត់បន្ថយហានិភ័យដល់ជនរងគ្រោះ។
- ព្រះរាជអាជ្ញា និងចៅក្រមគួរស្នើទៅនឹងយន្តការដែលមានដើម្បីផ្តល់ការការពារដល់ជនរងគ្រោះជាសាក្សីនៅក្នុងពេលជំនុំជម្រះ ដោយផ្តោតជាពិសេសទៅលើអ្នកដែលងាយរងគ្រោះជាពិសេស ដូចជា កុមារជាដើម។ ប្រសិនបើព្រះរាជអាជ្ញាមិនបានស្នើសុំការការពារសមស្រប ចៅក្រមគួរតម្រូវឱ្យមានការការពារទាំងនេះតាមការផ្តួចផ្តើមរបស់ខ្លួន។

# ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការវិភាគយ៉ាងហ្មត់ចត់ទៅលើអង្គច្បាប់ និងភស្តុតាង

រដ្ឋសមាជិកអាស៊ានជាច្រើនប្រឈមយ៉ាងខ្លាំងទាក់ទងនឹងវិធីវិភាគអង្គភាព និងភស្តុតាង។ ជារឿយៗ បញ្ហាទាំងនេះផ្ទុះបញ្ចាំង ឬកាន់តែធ្ងន់ធ្ងរដោយភាពទន់ខ្សោយផ្នែកស៊ើបអង្កេតដែលបានពន្យល់លម្អិតនៅក្នុងជំពូកចំនួនពីរខាងលើ។

ការសង្កេតទៅលើតុលាការ និងការវិភាគសំណុំរឿងដែលបានធ្វើឡើង សម្រាប់ការកែសម្រួលឆ្នាំ២០១១ នៃ *របាយការណ៍វឌ្ឍនភាព* និងនាពេលថ្មីៗបានបញ្ជាក់ថា ព្រះរាជអាជ្ញា និងចៅក្រមមិនបានធ្វើការវិភាគទៅលើអង្គច្បាប់ និងអង្គហេតុចាំបាច់ដើម្បីផ្តល់យុត្តិធម៌ជាទៀងទាត់នោះទេ។ ជាពិសេស ជារឿយៗ អង្គហេតុនៃសំណុំរឿងមួយចំនួនមិនពាក់ព័ន្ធ ស៊ីចង្វាក់ និងសមហេតុផលទៅនឹងធាតុផ្សំនៃបទល្មើសដែលបានចោទប្រកាន់នោះទេ។ ការពិត ជារឿយៗ ធាតុផ្សំនៃបទល្មើសមិនត្រូវបានលើកឡើង ឬយល់ឲ្យបានច្បាស់ពីព្រះរាជអាជ្ញា ឬចៅក្រមទេ។ ជាលទ្ធផល ការសម្រេចចិត្តចោទប្រកាន់ដោយព្រះរាជអាជ្ញាមានមន្ទិលសង្ស័យជាច្រើន មានភស្តុតាងពាក់ព័ន្ធមួយចំនួយមិនត្រូវបានកំណត់ និងបង្ហាញនៅពេលជំនុំជម្រះ ការសាកសួរសាក្សីមិនបានផ្តោតឲ្យចំទៅនឹងសាច់រឿងនៃសំណុំរឿង ដែលជាហេតុធ្វើឱ្យសេចក្តីសម្រេចរបស់តុលាការនៅមានបញ្ហាចោទជាច្រើន។ ក្រៅពីនេះ កង្វះភាពច្បាស់លាស់ និងការមិនបានវិភាគឲ្យបានហ្មត់ចត់នេះ អាចបណ្តាលឲ្យមានការបរាជ័យដល់ការធានានូវភាពយុត្តិធម៌ជាមូលដ្ឋាន ដោយសារចៅក្រមមិនដឹងច្បាស់អំពីធាតុផ្សំដែលត្រូវតែបង្ហាញ ដើម្បីបញ្ជាក់ពីពិរុទ្ធភាពនោះ គាត់ហាក់ដូចជាមិនបានស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបំពេញកាតព្វកិច្ច ស្វែងរកភស្តុតាងដាក់បន្ទុកបន្ថែមឲ្យបានត្រឹមត្រូវ ក្នុងការចោទប្រកាន់នោះ។

នៅក្នុងសំណុំរឿងមួយដែលត្រូវបានពិនិត្យក្នុងពេលរៀបចំរបាយការណ៍ឆ្នាំ២០១១ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើស "លក់ដូរមនុស្ស" ទោះបីពុំមានភស្តុតាងបញ្ជាក់ថា ជនសង្ស័យបានទទួលផលប្រយោជន៍ពីប្រតិបត្តិការនោះក៏ដោយ។ បន្ទាប់មក ជនជាប់ចោទនៅក្នុងសំណុំរឿងនោះត្រូវបានឲ្យរួចខ្លួន។ ប៉ុន្តែវាជាអកុសល ការលែងឲ្យរួចខ្លួននេះកើតឡើងក្រោយពេលដែលជនជាប់ចោទបានចំណាយពេល ៣ ឆ្នាំក្នុងការឃុំឃាំងរួចទៅហើយ។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចលើកលែងការចោទប្រកាន់តាំងពីដំបូង វានឹងកាត់បន្ថយនូវការឃុំឃាំង ហើយបុគ្គលសាមីនោះក៏មិនបានទទួលរងភាពអយុត្តិធម៌ដែរ។

នៅក្នុងសំណុំរឿងផ្សេងទៀត ការស៊ើបអង្កេត និងការចោទប្រកាន់ហាក់ដូចជាមិនបានផ្អែកទៅលើធាតុផ្សំជាក់លាក់នៃបទល្មើសដែលបានចោទប្រកាន់នោះទេ។ ឧទាហរណ៍ នៅក្នុងសំណុំរឿងដែលត្រូវបានពិនិត្យ ហាក់ដូចជាពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថា ជនសង្ស័យបានជ្រើសរើសជនរងគ្រោះ*ក្នុងគោលបំណងកេងប្រវ័ញ្ចជនរងគ្រោះ* ដូចបានតម្រូវដោយច្បាប់ជាតិពាក់ព័ន្ធទេ។ ទោះបីជាមិនភស្តុតាងគ្រប់គ្រាន់ក៏ដោយ តែជនជាប់ចោទត្រូវបានទទួលការផ្តន្ទាទោស ហើយតុលាការបានកំណត់ទោសដាក់ពន្ធនាគារជននោះផងដែរ។ ជាងនេះទៀត នៅក្នុងសំណុំរឿងនីមួយៗដែលបានវិភាគ ជនទាំងអស់ដែលត្រូវបានផ្តន្ទាទោស ស្ទើរតែទាំងអស់គឺគ្រាន់តែជាអ្នកជ្រើសរើស ឬអ្នកដឹកជញ្ជូនដែលមានពិរុទ្ធតិចតួច ហើយដែលមិនមែនជាអ្នកទទួលខុសត្រូវ ឬទទួលប្រយោជន៍ពីការកេងប្រវ័ញ្ចនោះទេ។ ចំណុចនេះបង្ហាញពីនិន្នាការ ដូចដែលបានបង្ហាញនៅក្នុងជំពូកមុនៗ ដែលយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានត្រូវផ្តោតផ្តោះតែទៅជនល្មើសតូចតាចតែប៉ុណ្ណោះ ដោយមិនគិតដល់ជនល្មើសដែលទទួលប្រយោជន៍ធំធេងពីការកេងប្រវ័ញ្ចនេះទេ។

នៅក្នុងសំណុំរឿងផ្សេងទៀត ហាក់ដូចជាមានចន្លោះប្រហោងច្រើនទាក់ទងនិងភស្តុតាង ដោយឆ្លុះបញ្ចាំងឱ្យឃើញនូវកង្វះខាតនៅក្នុងការស៊ើបអង្កេត។ ឧទាហរណ៍ ការវិភាគបង្ហាញថា អ្នកស៊ើបអង្កេត មិនបានធ្វើការឆែកឆេរបរិវេណឲ្យបានល្អិតល្អន់ ដើម្បីទទួលបានភស្តុតាងរូបវ័ន្ត ក្នុងការតាមដានការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ឬព្យាយាមធានាឲ្យបានភស្តុតាងស៊ីចង្វាក់គ្នាឡើយ។ មានសំណុំរឿងមួយ ដែលជនរងគ្រោះបាននិយាយថា បង្អួចនៃបន្ទប់ដែលគាត់ត្រូវបានគេចាក់សោរបង្ខាំងនោះមានលាបថ្នាំពណ៌ខ្មៅ ហើយថាគាត់មិនមើលមកក្រៅឃើញទេ។ គាត់បានគេចខ្លួនដោយការបំបែកកញ្ចក់បង្អួច និងតោងចុះតាមកន្លែងដែលបែកចំហនោះ។ មន្ត្រីនគរបាល ៣ រូប ព្រះរាជអាជ្ញា និងក្រឡាបញ្ជីបានឆែកឆេរផ្ទះនោះដែលត្រូវប្រើប្រាស់ជាផ្ទះបនពេស្យាចារ ហើយបានរកឃើញអ្នកប្រកប របរផ្លូវភេទ ៩ នាក់ និងអតិថិជនម្នាក់នៅក្នុងផ្ទះនោះ។ ពួកគេក៏បានឆែកឆេរបន្ទប់ដែលឃុំឃាំងជនរងគ្រោះនោះ តែមិនបានព្យាយាមផ្ទៀងផ្ទាត់ចំពោះការលើកឡើងរបស់ជនរងគ្រោះថាមានលាបថ្នាំពណ៌ខ្មៅ និងមានកញ្ចក់បង្អួចបែកនោះទេ។ ជាការងាយ គេគួរថតរូបកញ្ចក់បង្អួចដែលបែកនោះដើម្បីបញ្ជាក់សាច់រឿងរបស់ជនរងគ្រោះ។ នៅក្នុងសំណុំរឿងមួយផ្សេងទៀត អ្នកស៊ើបអង្កេត មិនបានស្តាប់ចម្លើយជនរងគ្រោះទេ ហើយពួកគេយកតែភស្តុតាងអង្គហេតុតែមួយគត់ដែលដាក់បន្ទុកទៅលើជនជាប់ចោទ គឺការសារភាពកំហុសរបស់ជននោះតែប៉ុណ្ណោះ។ សំណុំរឿងទាំងនេះបញ្ជាក់ឃើញអំពីទំនាក់ទំនងរវាង នៃភាពទន់ខ្សោយផ្នែកស៊ើបអង្កេត និងការចោទប្រកាន់។

នៅក្នុងសំណុំរឿងជាច្រើនដែលបានយកមកពិនិត្យ ហាក់ដូចជាមានសំណួរអំពីចំណុចខ្លាំង ឬភាពពាក់ព័ន្ធនៃភស្តុតាង ដែលបានដាក់ដើម្បីគាំទ្រការចោទប្រកាន់។ ឧទាហរណ៍ នៅក្នុងសំណុំរឿងមួយ មានភស្តុតាងថា ជនជាប់ចោទបានឲ្យប្រាក់មួយចំនួនតូច ដល់ឪពុកម្តាយជនរងគ្រោះ ដើម្បីទិញទឹកដោះគោឲ្យកូនបៅ។ ចំណុចនេះត្រូវបានបកស្រាយថា ជាភស្តុតាងគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរផលប្រយោជន៍ជាសម្ភារ ដូចដែលតម្រូវដោយច្បាប់ពាក់ព័ន្ធ ហេតុនេះត្រូវបានចាត់ទុកថាគ្រប់គ្រាន់ដើម្បីចោទប្រកាន់ពីបទចោទអង្គសេចក្តីនៃការជួញដូរមនុស្ស។ ចំណុចនេះហាក់ដូចជាការបកស្រាយតឹងតែងដែលយកមកធ្វើជាសំអាងសម្រាប់ការចោទប្រកាន់ពីបទល្មើសធ្ងន់ធ្ងរបែបនេះ។

ដើម្បីលើកកម្ពស់ការវិភាគលើអង្គច្បាប់ និងភស្តុតាងឲ្យបានកាន់តែហ្មត់ចត់ រដ្ឋសមាជិកអាស៊ានគួរពិចារណា៖

- ធ្វើការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាឲ្យបានហ្មត់ចត់ ដើម្បីធានាថា ពួកគេអាចកំណត់បានអំពីធាតុផ្សំដែលចាំបាច់ត្រូវយកមកបង្ហាញ នៅក្រោមច្បាប់ស្តីពីការជួញដូរមនុស្សថ្នាក់ជាតិ និងច្បាប់ដែលពាក់ព័ន្ធ និង ប្រភេទ និងគុណភាពនៃភស្តុតាងដែលចាំបាច់ដើម្បីបង្កើតធាតុផ្សំទាំងនោះ
- តម្រូវឲ្យមានការអនុវត្តន៍ជាក់ស្តែងដែលថា គ្មានអនុសាសន៍នៃការចោទប្រកាន់ណាមួយ ត្រូវបានយល់ព្រមសម្រាប់ការចោទប្រកាន់ឡើយ លុះត្រាតែធាតុផ្សំនៃបទចោទត្រូវបានកំណត់ច្បាស់ និងភស្តុតាងដែលបង្ហាញច្បាស់នូវធាតុផ្សំនីមួយៗត្រូវបានយកមកវិភាគ ទាក់ទងនឹងធាតុផ្សំទាំងនោះ
- ត្រូវរម្លឹកចៅក្រមថា នេះជាភារកិច្ចរបស់ខ្លួនក្នុងការតម្រូវឲ្យ ព្រះរាជអាជ្ញាត្រូវមានបន្ទុក ក្នុងការបង្ហាញភស្តុតាង ដោយតម្រូវឲ្យព្រះរាជអាជ្ញាលើកឡើងនូវធាតុផ្សំដែលចាំបាច់ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដើម្បីយកមកបញ្ជាក់ និងបង្ហាញយ៉ាងសមហេតុផលថាតើភស្តុតាងដែលបានដកស្រង់នៅក្នុងតុលាការបង្កើតជាធាតុផ្សំនីមួយគួរឲ្យជឿជាក់បានដោយរបៀបណា
- តម្រូវថា មតិយោបល់ចៅក្រមដែលគាំទ្រដល់សាលក្រមផ្តន្ទាទោសត្រូវរៀបរាប់យ៉ាងច្បាស់នូវធាតុផ្សំនានាដែលត្រូវយកមកបញ្ជាក់ និងពន្យល់យ៉ាងសមហេតុផលថាតើភស្តុតាងដែលបានដកស្រង់នៅក្នុងតុលាការបង្កើតជាធាតុផ្សំនីមួយៗគួរឲ្យជឿជាក់បានដោយរបៀបណា។

## ការប្រឈម និងការលំនាំទុវត្តភាពទាក់ទិននឹងភាពជាបន្តនៃការកាន់សំណុំរឿង

ជារឿយៗ សំណុំរឿងជួញដូរមនុស្សមានភាពស្មុគស្មាញ ដោយពាក់ព័ន្ធនឹងសារណានៃភស្តុតាងយ៉ាងវែង។ ភាពជាបន្តនៃសំណុំរឿងជារឿងសំខាន់ ដើម្បីឲ្យព្រះរាជអាជ្ញាមានភាពស៊ាំទៅនឹងសារណា ទទួលបានទំនុកចិត្ត និងជំនឿជាក់ពីជនរងគ្រោះ និងត្រៀមបានយ៉ាងល្អសម្រាប់ការជំនុំជម្រះ។ នៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់ ប្រព័ន្ធប្តូរវេន និងទម្លាប់ចាត់តាំងសំណុំរឿងឡើងវិញអាចរារាំងដល់ភាពជាបន្តនៃសំណុំរឿង និងបណ្តាលឲ្យព្រះរាជអាជ្ញាដែលមិនមានភាពស៊ាំនឹងសំណុំរឿងនោះមានការលំបាកនៅក្នុងដំណើរការជំនុំជម្រះជាក់ស្តែង។ ជាងនេះទៀត ការផ្លាស់ប្តូររដ្ឋអាជ្ញានៅពាក់កណ្តាលសំណុំរឿងអាចធ្វើឲ្យមានភាពស្មុគស្មាញនូវការខិតខំប្រឹងប្រែងដើម្បីទទួលបានទំនុកចិត្ត និងជំនឿជាក់ពីជនរងគ្រោះ។

ឧទាហរណ៍ យ៉ាងហោចណាស់នៅក្នុងរដ្ឋសមាជិកអាស៊ានមួយ ព្រះរាជអាជ្ញាត្រូវបានចាត់តាំងឲ្យទៅចូលរួមការជំនុំជម្រះតាមផ្អែកលើប្រព័ន្ធប្តូរវេន។ ប្រសិទ្ធភាពរបស់វាគឺថា ព្រះរាជអាជ្ញាដែលពិនិត្យមើលរបាយការណ៍ របស់មន្ត្រីនគរបាលពីដំបូង និងបានផ្តល់អនុសាសន៍ក្នុងការចោទប្រកាន់មិនមែនសុទ្ធតែដូចគ្នាទៅនឹងព្រះរាជអាជ្ញាដែលបង្ហាញសំណុំរឿងនៅពេលជំនុំជម្រះទេ។ ជាលទ្ធផល ព្រះរាជអាជ្ញាជំនុំជម្រះមិនសុទ្ធតែមានភាពស៊ាំទៅនឹងបញ្ហានានានៅក្នុងសំណុំរឿងនោះទេ ហើយជារឿយៗក៏មិនមានពេលគ្រប់គ្រាន់ដើម្បីត្រៀមសម្រាប់ការជំនុំជម្រះដែរ។

**នៅប្រទេសហ្វីលីពីន** សំណុំរឿងជួញដូរមនុស្សត្រូវបានចាត់តាំងជាថ្មី ជាប្រចាំពីរដ្ឋអាជ្ញាស៊ើបអង្កេត ទៅកាន់រដ្ឋអាជ្ញាជំនុំជម្រះដែលនៅជាប់នឹងតុលាការណាមួយ។ រដ្ឋអាជ្ញាជំនុំជម្រះហាក់ដូចជាមមាញឹកខ្លាំង ហើយជារឿយៗមិនអាចមានពេលវេលាគ្រប់គ្រាន់ចាំបាច់ដើម្បីត្រៀមសំណុំរឿងជួញដូរមនុស្ស ឲ្យបានត្រឹមត្រូវសម្រាប់ការជំនុំជម្រះទេ។ ជាងនេះទៀត ប្រសិនបើរដ្ឋអាជ្ញាជំនុំជម្រះត្រូវបានផ្លាស់ទៅតុលាការផ្សេង សំណុំរឿងនេះនឹងត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅកាន់រដ្ឋអាជ្ញាថ្មីដែលត្រូវបានចាត់តាំងទៅតុលាការនោះ។ ហាក់ដូចជាមានការប្រាស្រ័យទាក់ទងគ្នាតិចតួច ឬគ្មានសោះរវាងព្រះរាជអាជ្ញាស៊ើបអង្កេត និងរដ្ឋអាជ្ញាជំនុំជម្រះ នៅពេលដែលសំណុំរឿងនោះត្រូវបានបញ្ជូនមកដល់តុលាការ។ នៅក្នុងសំណុំរឿងតែមួយគត់ដែលបានយកមកពិនិត្យ ដែលរដ្ឋអាជ្ញាស៊ើបអង្កេតពិតជាបានតាមដានជាមួយរដ្ឋអាជ្ញាជំនុំជម្រះដើម្បីចង់ដឹងពីរបៀបកាន់សំណុំរឿងនោះ ដើម្បីកំណត់ថាតើត្រូវបានជំនួយបន្ថែមឬទេ។ នៅក្នុងសំណុំរឿងនោះ រដ្ឋអាជ្ញាស៊ើបអង្កេតបានកត់សម្គាល់ថា ពុំមានការយកចិត្តទុកដាក់ឲ្យបានពេញលេញទៅលើសំណុំរឿងនោះទេ ហើយគាត់ក៏បានសម្រេចចិត្តយកសំណុំរឿងមកកាន់ខ្លួនឯងវិញ។ គាត់មានការប្តេជ្ញាចិត្តខ្លាំងចំពោះសំណុំរឿងនោះ ហើយបានចំណាយពេលចាំបាច់ដើម្បីត្រៀមសំណុំនោះសម្រាប់ការជំនុំជម្រះ។ ជាចុងក្រោយ គាត់ក៏សម្រេចបានការផ្តន្ទាទោសមួយលើជនល្មើស។

ជាទូទៅ ដំណើរការចាត់តាំងសំណុំរឿងជាថ្មីធ្វើឲ្យទន់ខ្សោយដល់ស្មារតីនៃការទទួលខុសត្រូវ ភាពជាម្ចាស់ និងការប្តេជ្ញាចិត្តដែលចាំបាច់ដើម្បីទទួលការចោទប្រកាន់យ៉ាងជោគជ័យនៅក្នុងសំណុំរឿងជួញដូរមនុស្ស។ កង្វះភាពជាម្ចាស់ និងការប្តេជ្ញាចិត្តនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឆន្ទៈរបស់ព្រះរាជអាជ្ញាមួយដែលចង់ផ្ទេរការទទួលខុសត្រូវមួយភាគធំនៃដំណើរការជំនុំជម្រះលើសំណុំរឿងជួញដូរមនុស្សទៅឲ្យមេធាវីដែលបម្រើការនៅ អង្គការក្រៅរដ្ឋាភិបាលវិញ ដែលទទួលយកកាតព្វកិច្ចនានាដូចជាការត្រៀមជនរងគ្រោះ ការពិនិត្យសាក្សី និងការរៀបរៀងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ បើគ្មានស្មារតីនៃការទទួលខុសត្រូវនេះទេ ព្រះរាជអាជ្ញាដែលមានភារកិច្ចមមាញឹកដូចជាមិនចំណាយពេលដែលចាំបាច់ ដើម្បីដោះស្រាយឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះដែលបាក់ទឹកចិត្ត និងត្រៀមពួកគេឲ្យធ្វើ

ជាសាក្សីដែលមានប្រសិទ្ធភាពនៅពេលជំនុំជម្រះឡើយ។ នៅពេលដែលជនរងគ្រោះមិនទទួលបានការយកចិត្តទុកដាក់ ពួកគេកាន់តែងាយរងគ្រោះទៅនឹងការរំខានពីជនជាប់ចោទ។

ដើម្បីកែលម្អភាពជាបន្តក្នុងការកាន់សំណុំរឿង រដ្ឋសមាជិកអាស៊ានគួរពិចារណាបញ្ហាមួយចំនួនដូចជា៖

- អភិវឌ្ឍសមត្ថភាពឯកទេសដែលរដ្ឋអាជ្ញាជំនាញ ត្រូវបានចាត់តាំង ឱ្យទទួលខុសត្រូវបឋមជាប្រចាំ ក្នុងការគ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃសំណុំរឿងជួញដូរមនុស្ស តាំងពីពេលចាប់ផ្ដើម រហូតដល់ពេលជំនុំជម្រះ
- បង្កើតនីតិវិធីចាត់តាំងរដ្ឋអាជ្ញាឯកទេសសម្រាប់សំណុំរឿងជួញដូរមនុស្ស ដើម្បីធានាការតាមដានបន្តរបស់អយ្យការ តាំងពីពេលចាប់ផ្ដើម រហូតដល់ពេលជំនុំជម្រះ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទិននឹងការសម្របសម្រួល និងការប្រាស្រ័យការងាររវាងទីភ្នាក់ងារមួយទៅភ្នាក់ងារមួយទៀត

គុណភាពនៃការសម្របសម្រួល និងការប្រាស្រ័យទាក់ទងការងារ រវាងភ្នាក់ងារមួយ ទៅភ្នាក់ងារមួយទៀតអាចមានឥទ្ធិពលទៅគ្រប់ទិដ្ឋភាពនៃការចោទប្រកាន់លើការជួញដូរមនុស្ស។ ចំណុចនេះត្រូវបានបង្ហាញទាក់ទងនឹងតម្រូវការឱ្យមានការសហការ រវាងព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតជាដើម។ ការប្រាស្រ័យទាក់ទងការងារមិនបានល្អ រវាងទីភ្នាក់ងារនានា ដែលមានតួនាទីក្នុងការគាំទ្រដល់ការចោទប្រកាន់លើការជួញដូរមនុស្សវាធ្វើឱ្យកាត់បន្ថយនូវប្រសិទ្ធភាពនៃការឆ្លើយតបតាមរយៈយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ ជារឿយៗ ឧទាហរណ៍នានានៃបរាជ័យក្នុងការប្រាស្រ័យទាក់ទងការងារ ត្រូវបានកត់សម្គាល់នៅក្នុងការវិភាគសំណុំរឿង។ ឧទាហរណ៍ ជួនកាលព្រះរាជអាជ្ញាមិនបានដឹងអំពីទិដ្ឋភាពមួយចំនួន នៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលទេ ដូចជាការចាប់យកទ្រព្យ និងការសម្អាតប្រាក់ជាដើម។ និយាយជារួម ជាលទ្ធផល ភស្តុតាងសំខាន់ៗមិនត្រូវបានយកមកបង្ហាញនៅពេលជំនុំជម្រះឡើយ។ នៅក្នុងសំណុំរឿងមួយ ព្រះរាជអាជ្ញាជំនុំជម្រះមិនបានជូនដំណឹងថា ជនរងគ្រោះជាច្រើន បានផ្ដល់សក្ខីកម្មមុនការជំនុំជម្រះ នៅពេលស៊ើបអង្កេតដំបូង ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះរាជអាជ្ញាម្នាក់ទៀត ដែលត្រូវបានចាត់តាំងឱ្យទៅកាន់សំណុំរឿងថ្មីចាប់តាំងពីពេលនោះមកទេ។ ព្រះរាជអាជ្ញាទាំងពីររូបមិនដែលបានជួបនិយាយជាមួយគ្នាទេ។ ជាលទ្ធផល ព្រះរាជអាជ្ញាជំនុំជម្រះបានកោះហៅសាក្សីទាំងអស់ ១១ នាក់នៅពេលជំនុំជម្រះ ដែលគាត់អាចកាត់បន្ថយករណីនេះបាន និងសម្រាលបន្ទុកទៅលើជនរងគ្រោះមួយចំនួនដោយបង្ហាញសក្ខីកម្មមុនការជំនុំជម្រះជាជំនួសវិញ។

នៅក្នុងករណីមួយទៀត មេធាវីមួយរូបដែលត្រូវបានចាត់តាំងឱ្យធ្វើការលើសំណើសុំធ្វើបត្យាប័នមិនបានដឹងថាមានការផ្ដន្ទាទោសរួចហើយនៅក្នុងសំណុំរឿងដដែលនោះកាលពីប៉ុន្មានខែមុន ដោយព្រះរាជអាជ្ញានៅផ្នែកមួយទៀតទេ។ នៅក្នុងសំណុំរឿងមួយទៀត ព្រះរាជអាជ្ញាដែលត្រូវបានចាត់តាំងឱ្យជួយពេលស្ដាប់ចម្លើយពីកុមារ មិនបានពិគ្រោះយោបល់ ឬប្រាប់ដោយសង្ខេបដល់ព្រះរាជអាជ្ញាជំនុំជម្រះទេ ទាំងមុនពេល និងក្រោយពេលស្ដាប់ចម្លើយ ធ្វើឱ្យកាន់តែមានករណីដែលថា ការស្ដាប់ចម្លើយគ្រាន់តែជាការបង្គ្រប់កិច្ចតែប៉ុណ្ណោះ ភស្តុតាងសំខាន់មិនត្រូវបានបង្កើតឡើងទេ ហើយសិទ្ធិ និងការការពារដែលត្រូវផ្ដល់កុមារជាសាក្សីនោះមិនត្រូវបានគោរពដែរ។

ការប្រាស្រ័យទាក់ទងការងារជាមួយសេវាកម្ម គាំទ្រសាក្សី គឺជាទិដ្ឋភាពសំខាន់មួយនៃដំណើរការជំនុំជម្រះ។ នៅក្នុងករណីមួយ អង្គការក្រៅរដ្ឋាភិបាល មួយដែលផ្ដល់ទីជម្រកដល់ជនរងគ្រោះពីការជួញដូរមនុស្សមិនបានជូន

ដំណឹងដល់មន្ត្រីនគរបាលថា ជនរងគ្រោះរងការបំភិតបំភ័យ ហើយបានគំរាមចង់ចាកចេញពីទីជម្រកនោះទេ។ ជាលទ្ធផល មន្ត្រីនគរបាល និងព្រះរាជអាជ្ញាមិនអាចចាត់វិធានការការពារបាន ដូចជា ធានាដល់ជនរងគ្រោះ ឬរៀបចំធ្វើសក្ខីកម្មមុនការជំនុំជម្រះ ដើម្បីធានាបាននូវការសហការ និងរក្សាបាននូវភស្តុតាងសំខាន់ឡើយ។

ដើម្បីកែលម្អការសម្របសម្រួល និងការប្រាស្រ័យទាក់ទងការងារ រវាងភ្នាក់ងារមួយទៅទីភ្នាក់ងារមួយទៀត ដែលពាក់ព័ន្ធនឹងព្រះរាជអាជ្ញា និងតុលាការ រដ្ឋសមាជិកអាស៊ានគួរពិចារណា៖

- តម្រូវឱ្យមានការសម្របសម្រួលកាន់តែជិតស្និទ្ធរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលទាំងអស់នៃសំណុំរឿង ដូចបានកត់សម្គាល់ខាងលើ
- អភិវឌ្ឍសមត្ថភាពឯកទេសដែលព្រះរាជអាជ្ញាមួយរូប ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវចម្បងសម្រាប់គ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃសំណុំរឿង ដូចបានកត់សម្គាល់ខាងលើ
- រៀបចំការបណ្តុះបណ្តាល និងសិក្ខាសាលារួមគ្នាជាមួយព្រះរាជអាជ្ញា អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារគាំទ្រជនរងគ្រោះ ដើម្បីបង្កើនការយល់ដឹង និងទំនុកចិត្តទៅវិញទៅមក
- កំណត់ និងដោះស្រាយការប្រឈមនានា ដែលរារាំងដល់កិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិឱ្យមានប្រសិទ្ធភាព។
- បង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការ សម្រាប់ភ្នាក់ងារពាក់ព័ន្ធទាំងអស់ ដោយគ្របដណ្តប់ទៅលើសំណុំរឿងតាំងពីពេលចាប់ផ្តើមរហូតដល់ពេលចេញសេចក្តីសម្រេចរបស់តុលាការ[១១៣]។

ការវាយតម្លៃសំណុំរឿងបានបញ្ជាក់ថា ព្រះរាជអាជ្ញាមិនបានទាក់ទងជាមួយព្រះរាជអាជ្ញានៅប្រទេសផ្សេងទៀត ឬជាមួយមេធាវីនៅក្នុងអាជ្ញាធរកណ្តាលរបស់ខ្លួនជាផ្លូវការ ឬតាមមធ្យោបាយផ្សេង ដើម្បីទទួលបានភស្តុតាង ស្នើសុំការធ្វើបត្យាប័ន ឬផ្តល់ព័ត៌មានទេ។ ព័ត៌មានបន្ថែមរួមទាំងឧទាហរណ៍ពីសំណុំរឿង មានផ្តល់ជូននៅក្នុងជំពូកទី ៧ នៃរបាយការណ៍នេះ។

| *ជំពូកទី ៤៖ ការឆ្លើយតបដែលរឹងមាំ និងមានព័ត៌មានគ្រប់គ្រាន់ពីអយ្យការ និងតុលាការទៅនឹងការជួញដូរមនុស្ស* | |
|---|---|
| លេខយោង | បទដ្ឋានគុណភាព |
| ៤ | ព្រះរាជអាជ្ញា និងចៅក្រមចូលរួមចំណែកក្នុងការឆ្លើយនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌយ៉ាងមានប្រសិទ្ធភាពទៅនឹងការជួញដូរមនុស្ស |
| ៤.១ | ព្រះរាជអាជ្ញា និងចៅក្រមយល់ដឹងអំពីច្បាប់ពាក់ព័ន្ធ និងបញ្ហាសំខាន់នានាពាក់ព័ន្ធ ក្នុងការចោទប្រកាន់ និងវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរមនុស្ស (ត្រូវបានកំណត់ថាជាបទដ្ឋានគុណភាព ១.១, ១.២ និង ១.៣) |
| ៤.១.១ | ព្រះរាជអាជ្ញា និងចៅក្រមបង្ហាញនូវការយល់ដឹងយ៉ាងច្បាស់អំពីឋាមភាពនៃការជួញដូរមនុស្ស រួមមានកត្តារូបរាងកាយ និងចិត្តសាស្ត្រ ដែលជនជួញដូរមនុស្សយកមកប្រើដើម្បីជ្រើសរើស និងត្រួតត្រាជនរងគ្រោះ ឋាមភាពផ្នែកយេនឌ័រ និងចិត្តសាស្ត្រជាមូលដ្ឋានរបស់ជនរងគ្រោះ ជាពិសេសទាក់ទងនឹងភាពងាយរងគ្រោះជាពិសេសរបស់ |

[១១៣] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១ ផ្នែក ២ កថាខណ្ឌ ២.៤។

| | |
|---|---|
| | កុមាររងគ្រោះ និងផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តទៅលើលទ្ធភាពរបស់កុមារ ក្នុងការផ្តល់ភស្តុតាងស៊ីចង្វាក់ និងផ្តល់សក្ខីកម្មក្នុងនាមជាសាក្សី |
| ៤.១.២ | ព្រះរាជអាជ្ញា និងចៅក្រមបង្ហាញនូវការយល់ដឹងយ៉ាងច្បាស់អំពីវិធីសាស្ត្រនៃការជួញដូរមនុស្សបច្ចុប្បន្ន លំនាំ និងនិន្នាការរបស់វា យុទ្ធសាស្ត្រនៃការជ្រើសរើសជនរងគ្រោះ វិធីសាស្ត្រត្រួតត្រាជនរងគ្រោះ និងទម្រង់នៃការកេងប្រវ័ញ្ចបច្ចុប្បន្ន និងថ្មីៗ |
| ៤.១.៣ | ព្រះរាជអាជ្ញា និងចៅក្រមបង្ហាញនូវការយល់ដឹងយ៉ាងច្បាស់អំពីក្របខ័ណ្ឌគតិយុត្តិជាធរមាន ជាពិសេសធាតុផ្សំដែលត្រូវយកមកបង្ហាញ ក្នុងារកបញ្ជាក់អំពីសំណុំរឿងមួយនៅក្រោមច្បាប់ជួញដូរមនុស្ស ព្រមទាំងនៅក្រោមច្បាប់ព្រហ្មទណ្ឌពាក់ព័ន្ធជាច្រើនទៀតដែលអាចអនុវត្តនៅក្នុងការស៊ើបអង្កេតទៅលើការជួញដូរមនុស្ស។ |
| ៤.១.៤ | ព្រះរាជអាជ្ញា និងចៅក្រមយល់ដឹង និងបង្ហាញនូវលទ្ធភាព ក្នុងការអនុវត្តន៍នូវបទប្បញ្ញត្តិនានាដើម្បីការពារជនរងគ្រោះ និងសាក្សីដែលងាយរងគ្រោះ ជាពិសេសកុមារ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលជំនុំជម្រះ ដូចមានចែងនៅក្នុងច្បាប់ជាតិ ព្រមទាំងកាតព្វកិច្ចនានាដែលកើតមានតាមរយៈការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា និងឧត្តមានុវត្តន៍ផ្នែកអយ្យការ និងតុលាការដែលត្រូវទទួលស្គាល់ជាអន្តរជាតិ។ |
| ៤.១.៥ | ព្រះរាជអាជ្ញា និងចៅក្រមបង្ហាញនូវលទ្ធភាពក្នុងការកំណត់ និងអនុវត្តនូវអង្គហេតុដែលពាក់ព័ន្ធទៅនឹងធាតុផ្សំនៃបទល្មើសដែលបានចោទប្រកាន់ |
| ៤.១.៦ | ព្រះរាជអាជ្ញា និងចៅក្រមបង្ហាញនូវលទ្ធភាពក្នុងការកំណត់ និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងបញ្ហាអង្គច្បាប់ និងអង្គហេតុ និងឧបសគ្គនានា នៅក្នុងសំណុំរឿងជួញដូរមនុស្ស រួមមានកត្តានានាដែលរារាំងជនរងគ្រោះមិនឲ្យចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ អាចមានការរំខានជនរងគ្រោះ និងហានិភ័យនៃការសមគំនិតពីវិស័យសាធារណៈ។ |
| ៤.១.៧ | មានសមត្ថភាពនៅថ្នាក់ជាតិក្នុងការបង្កើត និងដំណើរការបណ្តុះបណ្តាលពីការយល់ដឹងជាបន្តសម្រាប់ព្រះរាជអាជ្ញា និងចៅក្រម |
| ៤.២ | ព្រះរាជអាជ្ញាដែលបានទទួលការតែងតាំង និងការបណ្តុះបណ្តាលជាពិសេស ក្នុងការដោះស្រាយសំណុំរឿងជួញដូរ និងផ្តល់ការគាំទ្រដល់សហការីដែលមិនមែនជំនាញ តាមការចាំបាច់ |
| ៤.២.១ | ព្រះរាជអាជ្ញាតាំងមួយក្រុម ដែលត្រូវបានតែង សមស្របទៅនឹងបន្ទុកការងារបច្ចុប្បន្ន និងតាមការប្រមើលមើល និងមានប្រវត្តិសមស្រប (រួមមានប្រវត្តិរូបផ្នែកយេនឌ័រ) តាមរយៈការបណ្តុះបណ្តាលឯកទេស ទទួលបានជំនាញបច្ចេកទេសខ្ពស់ ចំណេះដឹង និងការយល់ដឹងពីការជួញដូរមនុស្ស រួមមាន ចិត្តសាស្ត្រជនរងគ្រោះ ក្របខ័ណ្ឌគតិយុត្តិជាតិ និងឆ្លងដែន ជាធរមាន រួមមានអំណាចផ្នែកហិរញ្ញវត្ថុ និងការរឹបអូស ហានិភ័យនៃការសមគំនិតពីវិស័យសាធារណៈ និងបទដ្ឋាននីតិវិធីប្រតិបត្តិការស៊ើបអង្កេតដែលអនុវត្តដោយការឆ្លើយតបនៃការអនុវត្តន៍ច្បាប់ឯកទេស (សូមមើលបទដ្ឋានគុណភាព ២.៤) |
| ៤.២.២ | ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទទួលស្គាល់នូវតម្លៃ របស់ព្រះរាជអាជ្ញាដែលបានទទួលការបណ្តុះបណ្តាលជាពិសេស ដោយចាត់តាំងពួកគេឲ្យដោះស្រាយការចោទប្រកាន់ទៅលើការជួញដូរមនុស្សទាំងអស់ នៅក្នុងយុត្តាធិការរដ្ឋបាលរបស់ខ្លួន (សូមមើលផងដែរ បញ្ជីត្រួតពិនិត្យនៅជំពូកទី ៧) |
| ៤.២.៣ | ព្រះរាជាអាជ្ញា ដែលទទួលការចាត់តាំង និងការបណ្តុះបណ្តាលពិសេស បង្ហាញនូវលទ្ធភាពក្នុងការគ្រប់គ្រង និងផ្តល់ការផ្តន្ទាទោសដែលមានគុណភាពខ្ពស់ដោយ៖ |

| | |
|---|---|
| | • ធ្វើការយ៉ាងជិតស្និទ្ធ និងប្រកបដោយកិច្ចសហការជាមួយអង្គភាពឯកទេស និងមន្ត្រីអនុវត្តច្បាប់ជួរមុខនៅក្នុងការធ្វើផែនការ ការបង្កើត និងគ្រប់គ្រងការស៊ើបអង្កេតគ្រប់ដំណាក់កាល ឲ្យបានឆាប់ទៅតាមការអនុវត្តន៍ជាក់ស្តែង និងដែលស្របទៅនឹងនីតិវិធី<br>• គ្រប់គ្រងការស៊ើបអង្កេតដើម្បីធានាថា ភស្តុតាងពាក់ព័ន្ធនឹងច្បាប់ជាធរមានត្រូវបានស្វែងរកយ៉ាងត្រឹមត្រូវ ហើយជនរងគ្រោះ និងសាក្សីដែលងាយរងគ្រោះមានសុវត្ថិភាព និងសន្តិសុខ ហើយសិទ្ធិរបស់ពួកគេក្នុងការទទួលបានសំណងត្រូវបានកំណត់ និងគាំទ្រយ៉ាងពេញលេញ<br>• ធានាថា នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមាររងគ្រោះ ភាពងាយរងគ្រោះពិសេសរបស់ពួកគេត្រូវបានទទួលស្គាល់យ៉ាងពេញលេញ ហើយរាល់វិធានការការពារសមស្របទាំងអស់ ត្រូវបានយកមកអនុវត្តដើម្បីធានាការពារដល់ពួកគេ រួមមាន ការគាំទ្រ ការការពារអត្តសញ្ញាណ និងជម្រើសផ្សេងទៀតដែលមិនប៉ះទង្គិចផ្លូវចិត្តជំនួសឲ្យសក្ខីកម្មដោយផ្ទាល់<br>• ធានាថា ការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុស្របគ្នា និងដំណាលគ្នាត្រូវបានអនុវត្តនៅក្នុងករណីសមស្រប ដើម្បីបង្កើនកាលានុវត្តភាពក្នុងការតាមដាន និងរឹបអូសទ្រព្យដែលបានពីការជួញដូរមនុស្ស និងការបាត់បង់សិទ្ធិលើមធ្យោបាយដែលយកមកប្រើដើម្បីប្រព្រឹត្តបទល្មើសនោះ។<br>• ជួយក្នុងការកំណត់អត្តសញ្ញាណ និងផ្តល់ការណែនាំតាមផ្លូវច្បាប់ក្នុងការបង្កើតភស្តុតាងឲ្យស្របទៅនឹងការលើកឡើងរបស់ជនរងគ្រោះ ជាពិសេស នៅក្នុងករណីសមស្រប ការប្រើប្រាស់ភស្តុតាងគាំទ្ររបស់អ្នកឯកទេស<br>• ប្រមើមើលពីការប្រឈមលើអង្គច្បាប់ និងអង្គហេតុដែលអាចមាននៅពេលជំនុំជម្រះ និងត្រៀមដើម្បីទប់ទល់នឹងការប្រឈមទាំងនោះ នៅក្នុងតុលាការយ៉ាងប្រសិទ្ធភាព តាមរយៈសារណាជាលាយលក្ខណ៍អក្សរដែលមានការរៀបចំត្រឹមត្រូវ និងអំណះអំណាងផ្ទាល់មាត់<br>• ផ្តល់ឲ្យមេធាវីការពារក្តី នូវសម្ភារចាំបាច់ទាំងអស់មុនពេលជំនុំជម្រះ ដើម្បីធានានូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ទន្ទឹមហ្នឹងនោះក៏ធានាការពារនូវភាពចាំបាច់នៃឯកជនភាព និងសន្តិសុខស្របច្បាប់របស់ជនរងគ្រោះ<br>• ទទួលស្គាល់ពីសារៈសំខាន់ នៃការអនុវត្តន៍វិធានការការពារជនរងគ្រោះ/សាក្សីដែលសមស្រប និងជំរុញឲ្យតុលាការទទួលស្គាល់នូវវិធានការការពារយ៉ាងមានប្រសិទ្ធភាពដែរ។<br>• ធានាថាជនរងគ្រោះ និងសាក្សីត្រូវបានត្រៀម ដើម្បីមកផ្តល់សក្ខីកម្មពិតប្រាកដ ដែលស៊ីចង្វាក់ ដែលគ្របដណ្តប់យ៉ាងពេញលេញទៅលើធាតុផ្សំនៃបទចោទ និងដោះស្រាយនូវអង្គហេតុដែលស៊ីចង្វាក់គ្នាគួរឲ្យជឿជាក់បាន។<br>• ធានាថាជនរងគ្រោះ និងសាក្សីត្រូវបានត្រៀមដើម្បីឆ្លើយដោយពិតត្រង់ទៅនឹងសំណួរពីចៅក្រម ឬមេធាវីការពារក្តីដែលបានគិតជាមុន។<br>• ត្រៀមតាមលំដាប់លំដោយសំណួរ ដែលត្រូវសួរជនជាប់ចោទដោយព្រះរាជអាជ្ញា និងចៅក្រម ដើម្បីធានានូវការសួរដេញដោលប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ<br>• ផ្តល់ជូនតុលាការនូវសេចក្តីសង្ខេបត្រឹមត្រូវ និងពេញលេញ ជាទម្រង់សមស្រប និងនៅពេលសមស្រប ដែលលើកឡើងនូវអង្គហេតុពាក់ព័ន្ធ និងធាតុផ្សំក្នុងអង្គច្បាប់ដែលត្រូវបញ្ជាក់ ដោយធ្វើវិភាគឲ្យបានច្បាស់ៗ និងគួរឲ្យជឿជាក់បាន ពីរបៀបដែលអង្គហេតុទាំងនោះបង្កើតជាធាតុផ្សំនីមួយៗ |

| | |
|---|---|
| ៤.២.៤ | ព្រះរាជអាជ្ញាដែលទទួលការចាត់តាំង និងការបណ្ដុះបណ្ដាលពិសេស ផ្ដល់នូវចំណេះដឹង និងការគាំទ្រដល់សហការី មិនមែនជំនាញតាមការចាំបាច់ និងមានប្រព័ន្ធធានាឱ្យដំណើរការនេះលេចចេញជារូបរាង។ |
| ៤.៣ | តុលាការមានសមត្ថភាពក្នុងការវិនិច្ឆ័យទៅលើសំណុំរឿងជួញដូរមនុស្សយ៉ាងយុត្តិធម៌ និងពេញលេញ |
| ៤.៣.១ | ក្នុងករណីសមស្រប មួយចំនួន ចៅក្រមដែលទទួលបន្ទុកការងារបច្ចុប្បន្ន និងដែលបានប្រមើលទុក គួរតែត្រូវបានជ្រើសរើស និងចាត់តាំងជាពិសេសដើម្បីធ្វើការគ្រប់គ្រង និងវិនិច្ឆ័យនៅក្នុងការជំនុំជម្រះទាំងអស់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ |
| ៤.៣.២ | នៅក្នុងវិធាននៃច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ចៅក្រមដែលត្រូវបានចាត់តាំងបង្ហាញនូវលទ្ធភាពដើម្បីគ្រប់គ្រង និងវិនិច្ឆ័យនៅក្នុងការជំនុំជម្រះលើការជួញដូរមនុស្សដោយធានានូវ៖<br>• ការទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធី<br>• កិច្ចដំណើរការនីតិវិធីបឋម ពាក់កណ្ដាល និងជំនុំជម្រះត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព<br>• ការកម្រិតយ៉ាងតឹងរ៉ឹងត្រូវបានដាក់ចំពោះការអូសបន្លាយ ឬការពន្យារពេល ដោយមិនគិតដល់ថាតើ ការអនុវត្តនូវការអូសបន្លាយពេល ឬការពន្យារពេលនោះមកពីភាគីអយ្យការ ឬភាគីមេធាវីការពារក្ដីនៃកិច្ចដំណើរការនីតិវិធីទេ<br>• កិច្ចដំណើរការនីតិវិធីជំនុំជម្រះត្រូវបានដំណើរការឱ្យបានឆាប់តាមតែអាចធ្វើទៅបាន<br>• សាក្សីដែលងាយរងគ្រោះ ជាពិសេសសាក្សីជាកុមារ ដែលមកពីភាគីណាមួយត្រូវបានទទួលការការពារសមស្របតាមផ្លូវតុលាការដែលច្បាប់អនុញ្ញាត<br>• អំណាចនៃការរឹបអូសទ្រព្យដែលបានមកពីបទល្មើសជួញដូរមនុស្ស និងការរឹបអូសឧបករណ៍ដែលយកទៅប្រព្រឹត្តបទល្មើសត្រូវបានស្វែងរក និងអនុវត្តយ៉ាងពេញលេញ ដែលស្ថិតក្រោមការផ្ដន្ទាទោសនៅក្នុងការជំនុំជម្រះដោយយុត្តិធម៌<br>• រាល់សំណងតាមផ្លូវច្បាប់ទាំងអស់ ដែលត្រូវសងដល់ជនរងគ្រោះចំពោះព្យសនកម្មដែលបានទទួលរងត្រូវបានស្វែងរក និងអនុវត្តយ៉ាងពេញលេញ ដែលស្ថិតក្រោមការផ្ដន្ទាទោសនៅក្នុងការជំនុំជម្រះដោយយុត្តិធម៌។ |
| ៤.៣.៣ | ចៅក្រមដែលត្រូវបានចាត់តាំង ត្រូវផ្ដល់នូវការណែនាំ និងការគាំទ្រដល់សហការី មិនមែនឯកទេស តាមការចាំបាច់ |
| ៤.៣.៤ | នៅពេលភាពជំនាញនៃមុខងារតុលាការមិនត្រូវបានចាត់ទុកថាចាំបាច់ ចៅក្រមដែលរំពឹងថានឹងចូលរួមនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទទួលការគាំទ្រតាមរយៈការអភិវឌ្ឍន៍វិជ្ជាជីវៈ និងវិធានការផ្សេងទៀតដើម្បីធានាថាពួកគេអាចបំពេញមុខងាររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព។ |
| ៤.៤ | ព្រះរាជអាជ្ញាធានានូវការគាំទ្រសមរម្យដល់ជនរងគ្រោះមុនពេលការជំនុំជម្រះ |
| ៤.៤.១ | ព្រះរាជអាជ្ញាធានាថា ក្នុងអំឡុងពេលមុនការជំនុំជម្រះ ត្រូវរក្សាទំនាក់ទំនងជាទៀងទាត់ និងញឹកញាប់ជាមួយជនរងគ្រោះដើម្បីដឹងឱ្យច្បាស់ថា ជនរងគ្រោះបានដឹងយ៉ាងពេញលេញនូវស្ថានភាពនៃសំណុំរឿង ជនរងគ្រោះស្ថិតក្នុងបរិយាកាសមានសុវត្ថិភាព និងសន្តិសុខ ដែលរួចផុតពីលទ្ធភាពនៃការគំរាមកំហែង ឬការយាយី ការរំខានពីជនជួញដូរមនុស្ស និងបំពេញទៅតាមតម្រូវការជាមូលដ្ឋានរបស់ជនរងគ្រោះ |

| | |
|---|---|
| ៤.៤.២ | ក្នុងករណីសមស្របដែលច្បាប់អនុញ្ញាត មុនពេលជំនុំជម្រះ រដ្ឋអាជ្ញាត្រូវប្រើប្រាស់នីតិវិធីរៀបចំសក្ខីកម្មមុនការជំនុំជម្រះ ឬស្តាប់ចម្លើយមុនការជំនុំជម្រះ ដើម្បីកត់ត្រាចម្លើយរបស់ជនរងគ្រោះ ជាទម្រង់មួយដែលត្រូវបានទទួលយកជាភស្តុតាងនៅពេលជំនុំជម្រះ |
| ៤.៤.៣ | ព្រះរាជអាជ្ញាត្រៀមជនរងគ្រោះ និងសាក្សីផ្សេងទៀតឱ្យបានពេញលេញ ដើម្បីក្លាយជាសាក្សីដែលមានប្រសិទ្ធភាពនៅពេលជំនុំជម្រះ ដោយជួបមួយទល់និងមួយជាមួយជនរងគ្រោះ និងសាក្សីមុនពេលជំនុំជម្រះ ដើម្បីពន្យល់ឱ្យបានច្បាស់អំពីដំណើរការជំនុំជម្រះ ពន្យល់ឱ្យយល់ច្បាស់ថាកាតព្វកិច្ចតែមួយគត់របស់ជនរងគ្រោះ និងសាក្សីគឺនិយាយការពិត ពិនិត្យទៅលើខ្លឹមសារនៃសក្ខីកម្មដែលនឹងមកផ្តល់ ដោយមិនណែនាំឱ្យឆ្លើយតាម និងត្រៀមជនរងគ្រោះ និងសាក្សីក្នុងការឆ្លើយតបតាមការពិតចំពោះសំណួរពីមេធាវីការពារក្តី |
| ៤.៥ | សំណុំរឿងជួញដូរមនុស្សត្រូវបានចោទប្រកាន់ និងវិនិច្ឆ័យដោយយុត្តិធម៌អនុលោមតាមបទដ្ឋានយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ |
| ៤.៥.១ | ចៅក្រម និងព្រះរាជអាជ្ញា ទទួលខុសត្រូវដើម្បីធានាថា ជនជាប់ចោទត្រូវបានការការពារពីការជំនុំជម្រះដោយមិនយុត្តិធម៌ និងការផ្តន្ទាទោសគ្មានសុវត្ថិភាព រួមទាំង តាមរយៈការគោរពសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។ |
| ៤.៥.២ | ជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿងជួញដូរទទួលបានសិទ្ធិនានាដូចខាងក្រោម៖<br>• សិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី<br>• សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលត្រូវបានបង្កើតឡើងដោយច្បាប់<br>• សិទ្ធិទទួលបានការសន្មតថាគ្មានទោសពៃ រហូតទាល់តែត្រូវបានរកឃើញពិរុទ្ធភាពតាមផ្លូវច្បាប់<br>• សិទ្ធិទទួលបានព័ត៌មានទាន់ពេលវេលាអំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រកាន់នឹងរូបគាត់<br>• សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការការពារក្តី ដែលរួមទាំងកាលានុវត្តភាពក្នុងពិនិត្យភស្តុតាងដាក់បន្ទុកមកលើខ្លួន ទទួលបានការបង្ហាញភស្តុតាងខាងភាគីអយ្យការដែលដោះបន្ទុករូបគាត់ និងទំនាក់ទំនងជាឯកជនជាមួយមេធាវីតាមការជ្រើសរើសរបស់ខ្លួន<br>• សិទ្ធិទទួលបានសវនាការ ដោយមិនពន្យារពេលឥតប្រយោជន៍<br>• សិទ្ធិទទួលបានការកាត់សេចក្តីដោយផ្ទាល់<br>• សិទ្ធិទទួលបានជំនួយផ្លូវច្បាប់<br>• សិទ្ធិក្នុងការពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុកមកលើរូបគាត់ និងទទួលបានការចូលរួម និងពិនិត្យទៅលើសាក្សីក្នុងនាមរូបគាត់ នៅក្នុងស្ថានភាពដូចគ្នាទៅនឹងសាក្សីដាក់បន្ទុកមកលើរូបគាត់ដែរ<br>• សិទ្ធិទទួលបានសេវាបកប្រែភាសាក្នុងករណីចាំបាច់ |
| ៤.៥.៣ | គ្រប់គ្រងយន្តការដែលមាន ដើម្បីធានាឱ្យបានតម្លាភាព និងការទទួលខុសត្រូវនៃដំណើរការអយ្យការ/តុលាការ |

# ជំពូកទី ៥៖ ការកំណត់អត្តសញ្ញាណជនរងគ្រោះបានឆាប់រហ័ស និងត្រឹមត្រូវ ការផ្តល់ការការពារ និងការគាំទ្រផ្សេងៗ

ជនរងគ្រោះពីការជួញដូរមនុស្ស មានសិទ្ធិតាមផ្លូវច្បាប់ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ក្នុងការទទួលការកំណត់អត្តសញ្ញាណឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ និង ទទួលបានការការពារ និងការគាំទ្រផ្សេងៗ។ សិទ្ធិនោះត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាអន្តរជាតិជាច្រើន ដែលរដ្ឋសមាជិកអាស៊ានភាគច្រើនជាភាគី រួមមាន *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* និង *ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស*។ អាស៊ាន និងបណ្តារដ្ឋសមាជិករបស់ខ្លួនបានទទួលស្គាល់ម្តងហើយម្តងទៀត នូវសារសំខាន់នៃការគោរព និងការការពារសិទ្ធិរបស់ជនរងការជួញដូរមនុស្ស។

ការឆ្លើយតបនៅថ្នាក់ជាតិយ៉ាងមានប្រសិទ្ធភាព ទៅនឹងការជួញដូរមនុស្ស តម្រូវឲ្យមានការកំណត់អត្តសញ្ញាណបឋមឆាប់រហ័ស និងត្រឹមត្រូវចំពោះជនដែលត្រូវបានសន្មតថាជាជនរងគ្រោះ ការកំណត់អត្តសញ្ញាណផ្លូវចំពោះជនរងគ្រោះដែលត្រូវបានបញ្ជាក់ ព្រមទាំងការផ្តល់នូវការការពារ និងការគាំទ្រផ្សេងៗដោយភ្នាក់ងាររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ ទស្សនៈទាំងនេះមានទំនាក់ទំនងគ្នា ដោយសារការកំណត់អត្តសញ្ញាណជនរងគ្រោះបានត្រឹមត្រូវមានសារៈសំខាន់ ចំពោះពួកគេក្នុងការទទួលបាន ការការពារ និងជំនួយ។ ការណ៍ដែលថា ការស៊ើបអង្កេត ឬការចោទប្រកាន់កម្រ នឹងដំណើរការទៅមុខបានដោយគ្មានកិច្ចសហការពីជនរងគ្រោះគឺជាមូលហេតុជាក់ស្តែងមួយទៀត ដែលត្រូវកំណត់ជាអាទិភាព នូវការកំណត់អត្តសញ្ញាណឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ។ សរុបមក ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌបានទទួលស្គាល់ថា ជនរងគ្រោះជាធនធានសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ការខកខានមិនបានកំណត់អត្តសញ្ញាណជនរងគ្រោះ ឬធានាថា ជនដែលត្រូវបានកំណត់អត្តសញ្ញាណ បានទទួលជំនួយ និងការការពារ មិនត្រឹមតែធ្វើបរាជ័យជនរងគ្រោះ និងរារាំងពួកគេមិនឲ្យទទួលបានព័ត៌មាន ការគាំទ្រ សេវាជំនាញដែលមាន និងសំណងជួសជុលប៉ុណ្ណោះទេ តែវាថែមទាំងធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការនាំយកជនកេងប្រវ័ញ្ចយកមករកយុត្តិធម៌ថែមទៀតផង។

# ៥.១ ធាតុផ្សំសំខាន់នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ

ជាធម្មតា ការកំណត់អត្តសញ្ញាណជនរងគ្រោះគឺមិនមែនទៅលើសកម្មភាពតែមួយទេ ផ្ទុយទៅវិញ វាអាចជាដំណើរការស្មុគស្មាញ និងកើតឡើងនៅតាមដំណាក់កាល ឬដំណាក់កាលជាច្រើនផ្សេងទៀត ដោយមានផលប៉ះពាល់ដែលប្រែប្រួល។ ឧទាហរណ៍៖

- ***ការកំណត់អត្តសញ្ញាណបឋម*** ចំពោះអ្នកដែលត្រូវបានសន្មតថាជាជនរងគ្រោះអាចធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល (អង្គការក្រៅរដ្ឋាភិបាល) ឬដោយមន្ត្រីអនុវត្តន៍ច្បាប់ជួរមុខ (នគរបាល មន្ត្រីអន្តោប្រវេសន៍ឆ្មាំព្រំដែន)។
- ***ការកំណត់អត្តសញ្ញាណផ្លូវការ*** ចំពោះជនរងគ្រោះអាចធ្វើឡើងដោយមន្ត្រីនគរបាលឯកទេស ឬទីភ្នាក់ងារផ្សេងទៀត ក្នុងគោលបំណងសម្រេចថាតើ មានការប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស ឬទេ និងថាតើមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណ គឺជាជនរងគ្រោះ/សាក្សីនៃបទល្មើសនេះ ឬទេ។
- ***ការកំណត់អត្តសញ្ញាណទៅតាមនីតិវិធី*** អាចកើតឡើងនៅពេលមានយន្តការរដ្ឋបាល ដើម្បីកំណត់ថាអ្នកណាជាជនរងគ្រោះពីការជួញដូរមនុស្ស ក្នុងគោលបំណងផ្តល់ជំនួយ និងការគាំទ្រ។
- ***ការកំណត់អត្តសញ្ញាណតាមផ្លូវតុលាការ*** (ដោយតុលាការ) អាចត្រូវបានស្នើសុំ ឬជាការតម្រូវ ដើម្បីផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងស្នើសុំ និងទទួលបានសំណងជួសជុល។

ជនរងគ្រោះពីការជួញដូរមនុស្ស អាចត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងប្រទេសនៃការកេងប្រវ័ញ្ច ឬជួនកាលនៅពេលក្រោយ នៅពេលពួកគេវិលត្រឡប់ទៅផ្ទះវិញ។ ជួនកាល នេះអាចជាជម្រើសរើសរបស់ជនរងគ្រោះ៖ ឧទាហរណ៍ គាត់អាចជ្រើសរើសមិនបង្ហាញអត្តសញ្ញាណ នៅក្នុងប្រទេសនៃការកេងប្រវ័ញ្ច ដោយបារម្ភថានឹងត្រូវគេឃុំខ្លួននៅក្នុងទីជម្រក។ ការសម្រេចចិត្តបែបនេះ មិនគួរធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គលដែលជាសិទ្ធិបន្តមាន ដែលត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានប្រព្រឹត្តក្នុងនាមជាជនរងគ្រោះពីការជួញដូរមនុស្សឡើយ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាបញ្ហាសម្រាប់រដ្ឋទាំងអស់ នៅក្នុងតំបន់ទាំងអស់ទូទាំងពិភពលោក ហើយអាស៊ានក៏មិនខុសគ្នាដែរ។ លក្ខណៈសម្ងាត់នៃសកម្មភាពជួញដូរមនុស្សជាច្រើន មានការប៉ះទង្គិចផ្លូវចិត្តកម្រិតខ្ពស់ និងការបំភិតបំភ័យដែលជាប់ជាមួយជាធម្មតា ភាពគ្មានទំនុកចិត្តទៅលើការអនុវត្តន៍ច្បាប់ ឧបសគ្គផ្នែកភាសា និងកង្វះការយល់ដឹងក្នុងចំណោមបុគ្គលជាច្រើន ដែលរងការជួញដូរមនុស្ស ទាក់ទងនឹងឋានៈរបស់ពួកគេផ្ទាល់ជាជនរងគ្រោះ គឺជាកត្តាមួយចំនួនដែលអាចពន្យល់បានជាសាកលនូវអត្រាទាបនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ។

បទពិសោធន៍បញ្ជាក់ថា **ការកំណត់អត្តសញ្ញាណជនរងគ្រោះ នឹងមិនកើតឡើងដោយស្វ័យប្រវត្តិទេ** វាតែងតម្រូវឱ្យមានសកម្មភាពច្រើន និងការចូលរួមទាំងខាងរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល ជាពិសេសអ្នកដែលពាក់ព័ន្ធនៅក្នុងការអនុវត្តន៍ច្បាប់ ការគ្រប់គ្រងព្រំដែន និងអន្តោប្រវេសន៍ ការតាមដានរបស់វិស័យការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ និង ការផ្តល់សេវាសុខាភិបាល និងសង្គមកិច្ច។ ជាបញ្ហាអនុវត្តន៍ជាក់ស្តែង ចំណុចនេះនឹងតម្រូវឱ្យមានការបង្កើតនូវ **បញ្ជីត្រួតពិនិត្យ សេចក្តីណែនាំ និងនីតិវិធី** សម្រាប់មន្ត្រី និងអ្នកផ្សេងទៀតដែលអាចជួបប្រទះជនរងការជួញដូរ

មនុស្ស។ មន្ត្រី និងអ្នកពាក់ព័ន្ធមួយចំនួនដែលអាចទាក់ទងជាមួយជនរងការជួញដូរមនុស្សគួរទទួលបាន**ការបណ្តុះបណ្តាល** ក្នុងការអនុវត្តន៍នូវមធ្យោបាយនៃការកំណត់អត្តសញ្ញាណឲ្យបានត្រឹមត្រូវ។

ជាកម្រិតអប្បបរមា នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ គួររួមមានការវាយតម្លៃត្រួតគ្នាដោយផ្អែកលើ "ប្រភព" ព័ត៌មាន ២ ខុសគ្នាគឺ៖ (១) លទ្ធផលដែលទទួលបានតាមរយៈការអនុវត្តន៍សូចនាករកំណត់អំពីការជួញដូរមនុស្ស ដូចជា អាយុ ភេទ សញ្ជាតិ សារតារ ឯកសារ ឬពុំមានឯកសារ ទីកន្លែងដែលបានរកឃើញ ឬដែលបានគេចចេញ និងស្ថានភាពបុគ្គល ដូចមាននៅក្នុងបញ្ជីត្រួតពិនិត្យ ឬឧបករណ៍ផ្សេងទៀត និង (២) ការឆ្លើយតបទៅជនដែលអាចជាជនរងគ្រោះ (ឬអ្នកដែលស្មុំនឹងស្ថានភាពនោះ) ក្នុងពេលស្តាប់ចម្លើយដែលមានរៀបចំត្រឹមត្រូវ ដែលត្រូវបានបង្កើតឡើង ដើម្បីទាញយកព័ត៌មានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃបទល្មើសនៅក្នុងដំណាក់កាលជ្រើសរើស ដឹកជញ្ជូន និងកេងប្រវ័ញ្ច។ លទ្ធផលដែលទទួលបានពីប្រភពពីរដាច់ពីគ្នានេះ គួរត្រូវបានយកមកវិភាគ ទល់នឹងការដឹងនាពេលបច្ចុប្បន្នអំពីស្ថានភាពជួញដូរមនុស្ស និងវិធីសាស្ត្រនៃបទល្មើស ដើម្បីកំណត់ថាតើ បុគ្គលពាក់ព័ន្ធ អាចជាជនរងគ្រោះពីការជួញដូរមនុស្ស ឬមិនមែន។

ការលំបាក និងការពន្យារពេលពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស បណ្តាលឲ្យមានអំពាវនាវឲ្យមាន**ការសន្មតពីឋានៈរបស់ជនរងគ្រោះ**។ ប្រសិនបើមានមូលហេតុគួរឲ្យជឿបានថា ជនណាម្នាក់រងការជួញដូរ បន្ទាប់មក ជននោះត្រូវបានប្រព្រឹត្តក្នុងនាមជាជនរងគ្រោះ ដរាបណាមានការកំណត់ផ្សេងពីនេះ។ ចំណុចនេះមានសារសំខាន់ជាពិសេស នៅក្នុងសំណុំរឿងរបស់ជនទេសន្តរប្រវេសន៍ខុសប្រក្រតី និងកុមារ ដែលការកំណត់អត្តសញ្ញាណសម្រាប់ជំនួយ ការគាំទ្រ ការកំណត់តាមផ្លូវច្បាប់នូវឋានៈជាជនអន្តោប្រវេសន៍ និងកាតព្វកិច្ចការការពារពីរដ្ឋដែលនឹងមិនត្រូវបានផ្តល់តាមវិធីណាផ្សេងទៀតទេ។ **ការសន្មត**សំខាន់មួយទៀតគឺ**ពាក់ព័ន្ធនឹងអាយុរបស់ពួកគេ**។ ប្រសិនបើពួកគេជាកុមារ ជាទូទៅត្រូវទទួលបានការការពារ និងការគាំទ្រមួយកម្រិតផ្សេងទៀត។ ជនរងគ្រោះពីការជួញដូរមនុស្ស ដែលអាចជាកុមារគួរត្រូវបានកំណត់អត្តសញ្ញាណត្រឹមត្រូវ និងត្រូវយកចិត្តទុកលើពួកគេជាពិសេស ការប្រព្រឹត្តផ្សេងៗពីនេះ ដរាបណាមានការកំណត់អ្វីផ្សេងពីនេះ។

## ស្ថានភាពពិសេសរបស់កុមាររងគ្រោះ៖ ការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ

ដូចដែលនឹងពិភាក្សាបន្ថែមនៅខាងក្រោម ទីភ្នាក់ងារ និងមន្ត្រីរដ្ឋាភិបាលទាំងអស់ មានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការធ្វើការផ្តោតទៅលើការវាយតម្លៃ និងការពារឧត្តមប្រយោជន៍របស់កុមារ រួមទាំងកុមារដែលរងការជួញដូរមនុស្សផងដែរ។ នេះជាមូលដ្ឋានដែលត្រូវធ្វើសកម្មភាព និងការសម្រេចចិត្តទាំងអស់ពាក់ព័ន្ធនឹងកុមាររងគ្រោះ (ឬកុមារអាចជាជនរងគ្រោះ) ពីការជួញដូរមនុស្ស។

មន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះគោលនយោបាយ ព្រមទាំងទីភ្នាក់ងារអនុវត្តន៍ច្បាប់ និងទីភ្នាក់ងារសុខុមាលភាពកុមារជាច្រើនទៀត មានភារកិច្ចអនុម័តនូវនីតិវិធីដែលអនុញ្ញាតឲ្យពួកគេធ្វើការ**កំណត់អត្តសញ្ញាណកុមាររងគ្រោះពីការជួញដូរមនុស្ស** ឲ្យបានឆាប់រហ័ស និងយ៉ាងមានប្រសិទ្ធភាពតាមតែអាចធ្វើទៅបាន។ ភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធរួមមាន៖ អាជ្ញាធរអនុវត្តន៍ច្បាប់ អន្តោប្រវេសន៍ និងភ្នាក់ងារព្រំដែន សេវាសង្គមកិច្ច សុខាភិបាល និងអាជ្ញា

ធរផ្នែកអប់រំ និង អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ គួរមានប្រព័ន្ធនឹងនីតិវិធីសម្រាប់ការបញ្ជូនករណីសង្ស័យទៅអាជ្ញាធរអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធ។

គោលនយោបាយ និងនីតិវិធីទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សគួរបញ្ចូល**ការសន្មតទាក់ទងនឹងអាយុ**។ នោះគឺថា នៅពេលមិនដឹងច្បាស់ពីអាយុរបស់ជនរងគ្រោះ និងមានហេតុផលជឿបានថាជនរងគ្រោះជាកុមារ គេត្រូវសន្មតថាជនរងគ្រោះនោះជាកុមារ។ នៅពេលរង់ចាំការផ្ទៀងផ្ទាត់អាយុរបស់ជនរងគ្រោះ ជនរងគ្រោះនឹងទទួលការប្រព្រឹត្តដូចជាកុមារ ហើយនឹងទទួលបានវិធានការការពារពិសេសទាំងអស់។ នៅពេលមានមូលដ្ឋានបង្ហាញថា កុមារណាម្នាក់ជាជនរងគ្រោះនៃការជួញដូរមនុស្ស គួរមាន**ការសន្មត**វិជ្ជមានលើកទីពីរ **ជាប្រយោជន៍ដល់កុមារនោះដែលជារងគ្រោះពីការជួញដូរមនុស្ស** ដោយរង់ចាំការបញ្ជាក់ជាផ្លូវការទៅលើអង្គហេតុនេះ។ នីតិវិធីនៃការកំណត់អត្តសញ្ញាណក៏គួរផ្តល់នូវការណែនាំស្តីពីជំហ៊ាននានារួមមាន ការផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗ និង**ការបញ្ជូនទៅអាជ្ញាធរឯកទេសផ្នែកការពារកុមារ។**

*ប្រអប់អត្ថបទ ១៧៖ ការអនុវត្តន៍ឧត្តមប្រយោជន៍របស់កុមារនៅក្នុងបរិបទនៃការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ*

នៅក្នុងបរិបទនៃការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ការបំពេញទៅតាមបទដ្ឋាន "ឧត្តមប្រយោជន៍របស់កុមារ" តម្រូវឲ្យចាប់អារម្មណ៍ទៅលើចំណុចនានាដូចខាងក្រោម៖

- **ការកំណត់អត្តសញ្ញាណកុមាររងគ្រោះពីការជួញដូរមនុស្សមុនពេលកើតហេតុ** ត្រូវធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល (អនុវត្តន៍ច្បាប់ សេវាសង្គមកិច្ច អប់រំ អន្តោប្រវេសន៍ និងការត្រួតពិនិត្យព្រំដែន) ផង និងមន្ត្រីក្រៅរដ្ឋាភិបាលផង។
- **ការសន្មតស្ថានភាពរបស់កុមារ**មុនពេលកើតហេតុ ជាប្រយោជន៍ដល់បុគ្គល ដែលត្រូវបានកំណត់អត្តសញ្ញាណជាកុមារ នៅពេលមានការសង្ស័យ។
- **ការសន្មតថាជាជនរងគ្រោះ**មុនពេលកើតហេតុ នៅពេលមានមូលដ្ឋានជឿជាក់ថា កុមារនេះរងការជួញដូរមនុស្ស។
- **ការបញ្ជូនសំណុំរឿង**របស់កុមារដែលសង្ស័យថារងការជួញដូរមនុស្សពីអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលទៅផ្នែកអនុវត្តន៍ច្បាប់ ឬពីផ្នែកអនុវត្តន៍ច្បាប់ទៅអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងគោលបំណងផ្តល់ជំនួយដោយផ្ទាល់ និង**ចែករំលែកព័ត៌មាន** និង**ការសម្របសម្រួលការធ្វើអន្តរាគមន៍**រវាងភ្នាក់ងាររដ្ឋាភិបាល និងភ្នាក់ងារក្រៅរដ្ឋាភិបាល។

# ៥.២ វឌ្ឍនភាពរបស់អាស៊ានពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ

ទោះបីការយល់ដឹងជាទូទៅរបស់យើងអំពីលក្ខណៈ និងវិសាលភាពនៃការជួញដូរមនុស្សបានកែលម្អក៏ដោយ តែពុំមានការប៉ាន់ស្មានត្រឹមត្រូវអំពីទំហំជារួមនៃបញ្ហានេះទេ។ ហេតុនេះ វាជាការលំបាកណាស់ ក្នុងការវាស់ស្ទង់ឲ្យបានត្រឹមត្រូវថាតើមានការកើនឡើង ឬថយចុះនូវអត្រានៃការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ថ្វីត្បិតតែយ៉ាងនេះក្តី គេអាចធ្វើផ្តល់ការសង្កេតមួយចំនួនអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយផ្អែកលើការប៉ាន់ស្មានបច្ចុប្បន្នទៅលើចំនួនជនរងគ្រោះ តួលេខនៃការកំណត់អត្តសញ្ញាណនៅថ្នាក់ជាតិ (ដែលអាចរកបាននៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន) និងការសង្កេតដែលបានធ្វើឡើងដោយអ្នកជំនាញផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ដែលបានគាំទ្រដល់ការឆ្លើយតបតាមរយៈការប្រឆាំងការជួញដូរមនុស្សនៅក្នុងតំបន់។ រួមបញ្ចូលគ្នា តួលេខទាំងនេះគាំទ្រដល់សេចក្តីសន្និដ្ឋានចំនួន ២ គឺ៖

- ចាប់តាំងពីឆ្នាំ២០០០ មក មានការកើនឡើងជាខ្លាំងនូវចំនួនជនរងគ្រោះពីការជួញដូរមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសភាគច្រើននៅក្នុងតំបន់អាស៊ានទាំងមូល
- ក៏ប៉ុន្តែ ចំនួនមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណថា "ទទួលរងការជួញដូរមនុស្ស" នៅតែមានកម្រិតទាបជាខ្លាំង បើប្រៀបធៀបទៅនឹងចំនួនសរុបនៃជនរងគ្រោះពីការជួញដូរមនុស្សដែលត្រូវបានប៉ាន់ស្មាន។

ទោះបីជាមានអត្រាទាបនៃការកំណត់អត្តសញ្ញាណជនរងគ្រោះក៏ដោយ តែមានចរន្តវិជ្ជមានមួយចំនួនទៀតដែលបង្ហាញនូវការកែលម្អយឺតៗ នៅក្នុងទិដ្ឋភាពដ៏សំខាន់នៃការឆ្លើយតប តាមរយៈការប្រឆាំងការជួញដូរមនុស្សនេះ។ ឧទាហរណ៍ យ៉ាងហោចណាស់នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ការកំណត់អត្តសញ្ញាណជាប្រពៃណីផ្តោតទៅលើស្ត្រី និងកុមារី នៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទ ហើយក៏មានពង្រីកវិសាលភាពមួចំនួនដែរ ដោយមានបញ្ចូលការជួញដូរបុរស ស្ត្រី និងកុមារទៅក្នុងការកេងប្រវ័ញ្ចផ្នែកការងារ នៅក្នុងវិស័យនានាដូចជា សំណង់ សេវាកម្មតាមផ្ទះ ការងារក្នុងរោងចក្រ និងការនេសាទ។ ជាការសំខាន់គឺថា នាពេលបច្ចុប្បន្ន មនុស្សទាំងឡាយដែល*ត្រូវបាន*កំណត់អត្តសញ្ញាណថាបានទទួលរងការជួញដូរមនុស្សមានកាលានុវត្តភាពប្រសើរជាងមុន ដោយអាជ្ញាធរផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបញ្ជូនទៅកាន់សេវាគាំទ្រសមស្រប។

## វឌ្ឍនភាពក្នុងតំបន់ទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ

នៅថ្នាក់តំបន់ អាស៊ានមានដើរតួនាទីយ៉ាងសកម្មក្នុងការបង្កើតបទដ្ឋាន និងនីតិវិធីជុំវិញការកំណត់អត្តសញ្ញាណជនរងគ្រោះពីអំពើជួញដូរមនុស្ស។ នាពេលថ្មីៗនេះ *អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* បានកំណត់កាតព្វកិច្ចជាក់លាក់ចំនួន ២ ដល់រដ្ឋភាគីគឺ៖ (១) **បង្កើតគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ** ឬនីតិវិធី និង (២) **ទទួលស្គាល់ការសម្រេចចិត្តទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះ**របស់រដ្ឋភាគីមួយទៀត គឺថា៖

*ភាគីនីមួយៗត្រូវបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ ឬនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សឱ្យបានត្រឹមត្រូវ ហើយក្នុងករណីសមស្រប អាចសហការជាអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជំនួយផងដែរ។*

**មាត្រា ១៤(១)**

*នៅក្នុងករណីដែលការជួញដូរមនុស្សកើតឡើងនៅកន្លែងច្រើនជាងមួយប្រទេស ភាគីនីមួយៗត្រូវគោរព និងទទួលស្គាល់ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សដែលបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ។*

**មាត្រា ១៤(២)**

នៅឆ្នាំដែលអនុម័ត *អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* (ឆ្នាំ២០១៥) នោះដែរ គណៈកម្មការអាស៊ានទទួលបន្ទុកការពារ និងលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រី និងកុមារបានបង្កើតឡើងនូវគោលការណ៍ណែនាំមួយចំនួនស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស (សូមមើលខាងក្រោម)។ លិខិតូបករណ៍សំខាន់នេះអះអាងនូវបទដ្ឋានសំខាន់ជាច្រើន ដូចបានលើកឡើងខាងលើ រួមមានការសន្មតអំពីឋានៈរបស់ជនរងគ្រោះជាដើម។ ប្រការសំខាន់គឺថា តាមរយៈលិខិតូបករណ៍នេះ ACWC បានអំពាវនាវឱ្យរដ្ឋសមាជិកអាស៊ាននីមួយៗត្រូវ៖ (១) **ចាត់តាំងប្រព័ន្ធជនបង្គោលមួយសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះ/ការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ** និង (២) បង្កើត**បទដ្ឋាននីតិវិធីអាស៊ានសម្រាប់ការបញ្ជូនជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ និងការចែករំលែកព័ត៌មានយ៉ាងមានប្រសិទ្ធភាព** ដែលការពារសិទ្ធិរបស់ជនរងគ្រោះ និងគាំទ្រដល់ការធ្វើ សមាហរណកម្មពួកគេចូលក្នុងសហគមន៍វិញ។

### *ប្រអប់អត្ថបទ ១៨៖ គោលការណ៍ណែនាំនៃការប្រកាន់យកយេនឌ័ររបស់ ACWC សម្រាប់ការកំណត់អត្តសញ្ញាណស្ត្រី និងកុមារីរងគ្រោះពីការជួញដូរមនុស្ស*

ខាងក្រោមនេះជាបទប្បញ្ញត្តិសំខាន់មួយចំនួនពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះពី *គោលការណ៍ណែនាំនៃការប្រកាន់យកយេនឌ័រសម្រាប់ដោះស្រាយចំពោះស្ត្រីរងគ្រោះពីការជួញដូរមនុស្ស* ត្រូវបានបង្កើត និងអនុម័តដោយ ACWC នៅខែកុម្ភៈ ឆ្នាំ២០១៥៖

- ការសន្មតពីឋានៈរបស់ជនរងគ្រោះ (ពោលគឺថា បុគ្គលត្រូវ/គួរទទួលបានការប្រព្រឹត្តិក្នុងនាមជាជនរងគ្រោះ និងបានទទួលការគាំទ្រ និងសេវាផ្សេងៗ ដរាបណាភស្តុតាងចុងក្រោយបញ្ជាក់ផ្សេងពីនេះ)
- ការសន្មតពីអាយុ (ពោលគឺថា បុគ្គលដែលមានអាយុមិនច្បាស់លាស់ តែអាចជាកុមារ គួរត្រូវបានប្រព្រឹត្តិដូចជាកុមារ អនុលោមទៅតាមគោលការណ៍របស់អនុសញ្ញា អ.ស.ប ស្តីពីសិទ្ធិកុមារ)
- ប្រើប្រាស់វិធីសាស្ត្រផ្តោតលើជនរងគ្រោះដែលគោរពដល់សិទ្ធិមនុស្សរបស់ជនរងគ្រោះ
- ត្រូវយកចិត្តទុកដាក់ខ្ពស់ និងចៀសវាងសកម្មភាពនានាដែលអាចធ្វើឱ្យជនរងគ្រោះប៉ះទង្គិចផ្លូវចិត្តសាជាថ្មី
- បង្កើតបទដ្ឋានបញ្ជីត្រួតពិនិត្យ ឬទម្រង់នៃការកំណត់អត្តសញ្ញាណសម្រាប់ធ្វើការស្តាប់ចម្លើយបឋមជាមួយបុគ្គលដែលអាចជាជនរងគ្រោះ
- បញ្ចូលបុគ្គលិកជាស្ត្រី និងមន្ត្រីសង្គមកិច្ចជាស្ត្រីដែលបានទទួលការបណ្តុះបណ្តាលសម្រាប់ស្តាប់ចម្លើយស្ត្រីរងគ្រោះ

- ផ្តល់ដល់បុគ្គលដែលអាចជាជនរងគ្រោះនូវកាលានុវត្តភាពទទួលបានអ្នកគាំទ្រជាមួយពួកគេនៅក្នុងដំណើរការកំណត់អត្តសញ្ញាណទាំងមូល
- ធានាធ្វើការស្តាប់ចម្លើយនៅកន្លែងមានសុវត្ថិភាព ដាច់ចេញពីជនសង្ស័យ ឬចារីនៃការជួញដូរមនុស្ស
- ស្ថានទូតនានាគួរចាត់តាំងជនបង្គោលសម្រាប់ទាក់ទងដែលទទួលខុសត្រូវសម្របសម្រួលជាមួយភ្នាក់ងាររដ្ឋាភិបាលរៀងៗខ្លួន ក្រោយពេលបានទទួលការជូនដំណឹងជាផ្លូវការដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស
- ធ្វើឲ្យការស្តាប់ចម្លើយឲ្យបានខ្លីតាមតែអាចធ្វើទៅបាន និងផ្តល់លទ្ធផលដល់ភ្នាក់ងារពាក់ព័ន្ធដើម្បីប្រើប្រាស់ដើម្បីបញ្ចៀសការស្តាប់ចម្លើយជនរងគ្រោះច្រើនដង។

ប្រភព៖ គោលការណ៍ណែនាំនៃការប្រកាន់យកយេនឌ័ររបស់ ACWC សម្រាប់ដោះស្រាយចំពោះស្ត្រីរងគ្រោះពីការជួញដូរមនុស្ស (ឆ្នាំ២០១៥)

នៅក្នុងឆ្នាំ២០១៥ អាស៊ាន និង COMMIT បានរួមគ្នាដើម្បីបង្កើតជាគោលការណ៍ណែនាំសម្រាប់ការកំណត់អត្តសញ្ញាណជាធរមាននៅថ្នាក់តំបន់ (សូមមើលប្រអប់អត្ថបទទី ២១ ខាងក្រោម)។ លិខិតូបករណ៍នេះសម្រាប់ដឹកនាំប្រតិបត្តិការដល់មន្ត្រីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ រួមមាន នគរបាល មន្ត្រីព្រំដែន និងបុគ្គលកុងស៊ុល ដែលជារឿយៗស្ថិតនៅជួរមុខក្នុងការកំណត់អត្តសញ្ញាណ។

### *ប្រអប់អត្ថបទ ១៥៖ គោលការណ៍ណែនាំរបស់អាស៊ាន/COMMIT ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពី ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ*

*សិក្ខាកាមដែលបានចូលរួមសិក្ខាសាលារបស់អាស៊ាន/COMMIT ការបង្កើតនូវបញ្ជីសញ្ញាបដិរូប និងសូចនាករដំបូងដែលមន្ត្រីអនុវត្តច្បាប់ជួរមុខ និងអ្នកឆ្លើយតបមុនគេផ្សេងទៀតអាចយកទៅប្រើក្នុងការបង្ហាញថា តើស្ថានភាពមួយអាចជាស្ថានភាពដែលតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែមទៀត ដែលអាចជាសំណុំរឿងជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ ឬយ៉ាងណា។ បញ្ជីនេះមិនទាន់ពេញលេញនៅឡើយទេ។ បញ្ជីនេះមិនមានគោលបំណងកំណត់ជាក់លាក់ទេ តែគ្រាន់តែផ្តល់នូវវចនាសម្ព័ន្ធ និងជាកម្លាំងជំរុញមួយសម្រាប់រដ្ឋយកទៅបង្កើតក្របខ័ណ្ឌនៃការកំណត់អត្តសញ្ញាណកាន់តែលម្អិត និងត្រឹមត្រូវសម្រាប់យកទៅអនុវត្តន៍នៅថ្នាក់ជាតិតែប៉ុណ្ណោះ។*

១. សញ្ញាបដិរូបដែលជំរុញឲ្យមានការស៊ើបសួរបន្ថែមទៀត

*មន្ត្រីជួរមុខ និងអ្នកឆ្លើយតបដំបូងផ្សេងទៀត អាចជួបប្រទះនូវស្ថានភាពមួយដែលបណ្តាលឲ្យមានការ ព្រួយបារម្ភថាអាចមានការជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ។ ចំពោះសញ្ញា (គឺជារូបភាពដែលមើលឃើញធម្មតា) ដែលអាចពញ្ញាក់ឱ្យមានការចាប់អារម្មណ៍ និងការសម្រេចចិត្តធ្វើការស៊ើបសួរបន្ថែមទៀត (ដូចជាការស្តាប់ចម្លើយបុគ្គលដែលអាចជាជនរងគ្រោះ) អាចរាប់បញ្ចូលនូវ៖*

- សញ្ញានៃការត្រួតពិនិត្យ/ឃ្លាំមើល (ឧទា. របង កាម៉េរ៉ា អាវុធ)
- សញ្ញានៃការភ័យខ្លាច/ទុក្ខព្រួយ/ធុញថប់ក្នុងចិត្ត/ការធ្វើបាបផ្លូវចិត្ត

- បង្ហាញកង្វះនូវភាពស៊ាំទៅនឹងបរិយាកាស/ស្ថានភាព
- គ្មានលទ្ធភាព/គ្មានឆន្ទៈចង់ប្រាស្រ័យទាក់ទង (ភាសា គ្មានទូរស័ព្ទដៃ ត្រូវបានណែនាំឱ្យនិយាយ ។ល។)
- អាយុ/ឋានៈជាបុគ្គលដែលអាចជាជនរងគ្រោះ (កុមារដែលគ្មានអ្នកអមដំណើរ មនុស្សដែលក្រោមអាយុអប្បបរមាតាមច្បាប់កំណត់សម្រាប់ស្ថានភាព/ទីកន្លែងធ្វើការ កុមារនៅក្នុងស្ថានភាពមិនសមរម្យ)
- សញ្ញានៃការធ្វើបាបផ្លូវកាយ របួសរាងកាយ ស្ថានភាពរូបកាយមិនល្អ
- បរិយាកាសធ្វើការជាធម្មតាហាក់ដូចជាមានគ្រោះថ្នាក់ ដោយគិតទៅដល់អាយុ/ស្ថានភាពរបស់មនុស្សនោះ
- ស្ថានភាពការងារហាក់ដូចជាអាក្រក់ខ្លាំង (ឧទា. ធ្វើការជាច្រើនម៉ោង មិនបានសម្រាក គ្មានពេលឈប់សម្រាក)
- ស្ថានភាពរស់នៅហាក់ដូចជាអាក្រក់ខ្លាំង (ឧទា. អាហារ ការរៀបការកន្លែងដេក ចំនួនមនុស្សច្រើនរស់នៅកន្លែងធ្វើការ)

២. សំណួរពិនិត្យជាមូលដ្ឋានសម្រាប់មន្ត្រីអនុវត្តច្បាប់ជួរមុខ/អ្នកឆ្លើយតបមុនគេ

*មន្ត្រីអនុវត្តច្បាប់ជួរមុខ និងអ្នកឆ្លើយតបមុនគេផ្សេងទៀត អាចជួបប្រទះមនុស្សណាម្នាក់ដែលពួកគេចង់និយាយជាមួយដើម្បីបង្ហាញថាតើ មានមូលហេតុអ្វីខ្លះដែលថាជននោះអាចជាជនរងគ្រោះពីការជួញដូរមនុស្ស ឬយ៉ាងណា។ សំណួរដូចខាងក្រោម (ដែលសំណួរទាំងអស់គួរតែយកមកសួរដើម្បីទទួលបានរូបភាពរួមនៃស្ថានភាពនោះ) គួរតែជួយដើម្បីកំណត់ថាតើ ពិតជាមានសញ្ញាណដែលអាចមានករណីជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ ដែលតម្រូវឱ្យមានការតាមដាន និងបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ឬយ៉ាងណា។ កត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថា មនុស្សណាម្នាក់អាចជាជនរងគ្រោះពីការជួញដូរមនុស្សគួរតែអាយុ១៨ឆ្នាំ ឬអាចមានអាយុក្រោម ១៨ ឆ្នាំ ឬក៏ទាបជាងនេះទៀត។ លើសពីអ្នកឆ្លើយតបជួរមុខក៏ត្រូវតែទទួលស្គាល់ថា មនុស្សដែលត្រូវបានសាកសួរនោះ អាចមិនបានត្រៀមខ្លួនចាំឆ្លើយតបភ្លាមៗ និង/ឬ ឱ្យបានពេញលេញនោះទេ។*

**សូចនាករទី ១៖ បុគ្គលមិនត្រូវបានទទួលនូវអ្វីសោះ ឬតិចជាងអ្វីដែលពួកគេបានរំពឹងទុក ឬត្រូវបានសន្យា។**

*តើបុគ្គលនោះជាបុគ្គលដែលមិនបានទទួល ឬបានទទួលតិចជាងអ្វីដែលពួកគេរំពឹងទុក ឬត្រូវបានសន្យា ឬយ៉ាងណា?*

**សូចនាករទី ២៖ ការរំពឹងទុក ឬការសន្យាបានទទួលប្រាក់/លទ្ធភាពទទួលបានប្រាក់របស់ជននោះត្រូវបានរក្សាដដែល ឬកាត់បន្ថយ។**

*តើការរំពឹងទុក ឬការសន្យាទទួលប្រាក់របស់ជននោះត្រូវបានរក្សាដដែល ឬកាត់បន្ថយ?*

**សូចនាករទី ៣៖ មនុស្សនៅក្នុងការងារ/ស្ថានភាពខុសគ្នាជាងអ្វីដែលគាត់បានរំពឹង ឬត្រូវបានសន្យា។**

*តើមនុស្សនៅក្នុងការងារ/ស្ថានភាពខុសគ្នាពីអ្វីដែលគាត់បានរំពឹងទុក ឬត្រូវបានសន្យា ឬទេ?*

**សូចនាករទី ៤៖ ស្ថានភាពការងារ និង/ឬស្ថានភាពរស់នៅខុសពីអ្វីដែលបានរំពឹងទុក ឬត្រូវបានសន្យា។**

*តើស្ថានភាពការងារ (ដូចជាម៉ោងធ្វើការ ពេលឈប់សម្រាក) និង/ឬ ស្ថានភាពរស់នៅខុសគ្នាពីស្ថានភាពការងារ និងស្ថានភាពរស់នៅដែលបានរំពឹងទុក ឬត្រូវបានសន្យា ឬទេ?*

**សូចនាករទី ៥៖ តើបុគ្គលនោះត្រូវបានធ្វើឲ្យមានភាពភ័យខ្លាច ឬគ្មានសុវត្ថិភាពនៅកន្លែងធ្វើការ។**

*តើអ្នកនៅកន្លែងធ្វើការ/ស្ថានភាពនោះធ្វើឲ្យបុគ្គលនោះមានអារម្មណ៍ភ័យខ្លាច ឬគ្មានសុវត្ថិភាព (អំពីខ្លួនឯង ឬគ្រួសារពួកគេ) ដែរឬទេ?*

**សូចនាករទី ៦៖ តើបុគ្គលនោះត្រូវបានគេបោកបញ្ឆោត ឬបង្ខំឲ្យធ្វើអ្វីមួយដែលពួកគេមិនចង់ធ្វើ។**

*តើមាននរណាមកបោកបញ្ឆោត ឬបង្ខំបុគ្គលឲ្យធ្វើអ្វីមួយដែលគេមិនចង់ធ្វើ ឬទេ?*

**សូចនាករទី ៧៖ តើបុគ្គលនោះទទួលរងសម្ពាធឲ្យរួមភេទជាមួយនរណាម្នាក់។**

*តើបុគ្គលនោះទទួលរងសម្ពាធឲ្យរួមភេទជាមួយនរណាម្នាក់ ឬទេ?*

**សូចនាករទី ៨៖ តើបុគ្គលនោះ/គ្រួសាររបស់តើបុគ្គលនោះជំពាក់ប្រាក់ ឬផលប្រយោជន៍ផ្សេងទៀតដល់និយោជករបស់ខ្លួន ឬអ្នកផ្សេងទៀតដែលបានជួយឲ្យទទួលបានការងារធ្វើ។**

*តើបុគ្គលនោះ (គ្រួសាររបស់ខ្លួន) ជំពាក់ប្រាក់និយោជករបស់ខ្លួន ឬអ្នកដែលបានជួយឲ្យទទួលបានការងារធ្វើ ឬស្ថានភាពជាប្រាក់ ឬផលប្រយោជន៍ផ្សេងទៀត ឬទេ?*

**សូចនាករទី ៩៖ តើបុគ្គលនោះឬអ្នកផ្សេងទៀតនៅកន្លែងធ្វើការ បានទទួលរងព្យសនកម្ម ឬរងការគំរាមឲ្យមានព្យសនកម្ម។**

*តើបុគ្គលនោះឬអ្នកផ្សេងទៀតនៅកន្លែងធ្វើការតែមួយ ឬស្ថានភាពតែមួយ បានទទួលព្យសនកម្ម ឬរងការគំរាមឲ្យមានព្យសនកម្មឬទេ?*

**សូចនាករទី ១០៖ តើបុគ្គលនោះត្រូវគេធ្វើឲ្យមានអារម្មណ៍ថា ខ្លួនមិនអាចចាកចេញពីកន្លែងធ្វើការរបស់ខ្លួន ឬកន្លែងដែលខ្លួនបានទេ។**

*តើបុគ្គលនោះធ្លាប់ត្រូវបានគេប្រាប់ (ត្រូវគេធ្វើឲ្យមានអារម្មណ៍) ថា ខ្លួនមិនអាចចាកចេញពីកន្លែងធ្វើការរបស់ខ្លួន ឬកន្លែងដែលខ្លួនរស់នៅដែរឬទេ?*

**សូចនាករទី១១៖ តើបុគ្គលនោះពុំមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនមែនទេ។**

*តើឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលនោះត្រូវបានគេយកទៅបាត់ ឬយកទៅរក្សាទុកហើយ?*

**សូចនាករទី ១២៖ តើបុគ្គលនោះត្រូវបានរារាំងមិនឲ្យទាក់ទងជាមួយអ្នកណានៅក្រៅកន្លែងធ្វើការរបស់ខ្លួន ឬស្ថានភាពរបស់ខ្លួន។**

*តើលទ្ធភាពរបស់បុគ្គលនោះក្នុងការទាក់ទងជាមួយពិភពខាងក្រៅត្រូវបានកំហិតដែរឬទេ?*

**សូចនាករទី ១៣៖ តម្រូវការជាមូលដ្ឋានរបស់បុគ្គលនោះមិនត្រូវបានបំពេញទេ។**

*តើបុគ្គលនោះបានទទួលអាហារ សេវាសុខាភិបាល ឯកជនភាព តម្រូវការជាមូលដ្ឋានផ្សេងទៀត ឬទេ?*

ប្រភព៖ ឯកសារលទ្ធផលសិក្ខាសាលាអាស៊ាន និង *COMMIT* ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស និងទម្រង់នៃការកេងប្រវ័ញ្ចពាក់ព័ន្ធ៖ ការបង្កើតសូចនាកររួមសម្រាប់អ្នកប្រតិបត្តិ ទីក្រុងគួឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥

## វឌ្ឍនភាពរបស់អាស៊ានស្តីពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ៖ ច្បាប់ និងគោលនយោបាយ[១១៤]

ច្បាប់ស្តីពីការជួញដូរមនុស្សរបស់រដ្ឋសមាជិកអាស៊ាន មិនបានយោងជាទូទៅ ដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សទេ ហើយក៏មិនបានបង្កើតជានីតិវិធីកំណត់អត្តសញ្ញាណផ្លូវការ ឬបញ្ជូនទៅស្ថាប័នពាក់ព័ន្ធដែរ។ ក៏ប៉ុន្តែ ច្បាប់របស់រដ្ឋសមាជិកអាស៊ានបានពន្យល់ច្បាស់ពីទំនាក់ទំនងសំខាន់រវាងការកំណត់អត្តសញ្ញាណការជួញដូរមនុស្ស ដោយអះអាងថា ជនរងគ្រោះពីការជួញដូរមនុស្ស ជាមនុស្សដែលរងអំពើមួយក្នុងចំណោមអំពើនានាដែលបានប្រព្រឹត្តឡើង ដោយមានចែងនៅក្នុងច្បាប់។ ឧទាហរណ៍ នៅក្រោមច្បាប់ពាក់ព័ន្ធរបស់**ប្រទេសសិង្ហបុរី** "ជនរងគ្រោះពីការជួញដូរមនុស្ស" ត្រូវបានកំណត់និយមន័យសំដៅដល់ជនណាម្នាក់ដែលរងការប្រព្រឹត្តិបទល្មើសមួយ នៅក្រោមផ្នែកនៃបទល្មើស ដែលកំណត់ជាបទល្មើសព្រហ្មទណ្ឌនៃការជួញដូរមនុស្ស និងបញ្ចូលជាជនរងគ្រោះនៃបទល្មើសនោះ។ តាមច្បាប់ស្តីពីការជួញដូរមនុស្សរបស់ប្រទេស**ម៉ាឡេស៊ី** "ជនរងគ្រោះពីការជួញដូរមនុស្ស" មានន័យថា "ជនណាដែលជាជនរងគ្រោះ ឬជាកម្មវត្ថុនៃអំពើជួញដូរមនុស្ស"។ នៅក្នុងច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ប្រទេសឥណ្ឌូនេស៊ី** "ជនរងគ្រោះ" គឺជា "ជនណាម្នាក់ដែលទទួលរងការប៉ះទង្គិចផ្នែកចិត្តសាស្ត្រ ផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ សេដ្ឋកិច្ច និង/ឬសង្គម ដែលបណ្តាលមកពីអំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស"។ បទប្បញ្ញត្តិទាំងនេះគួរប្រតិបត្តិការដើម្បីធានាថា ជនណាម្នាក់ដែលត្រូវបានសន្មតថា ជាជនរងគ្រោះនៃបទល្មើសជួញដូរមនុស្សជាក់ស្តែង ឬអាចជាបទល្មើសជួញដូរមនុស្ស ត្រូវបានប្រព្រឹត្តដូចជាជនរងគ្រោះពីការជួញដូរមនុស្ស ក្នុងគោលបំណងទទួលបានជំនួយការការពារ និងការគាំទ្រ។

ដោយមិនគិតដល់ ថាតើច្បាប់ពាក់ព័ន្ធបាន ឬមិនបានកំណត់និយមន័យនៃ "ជនរងគ្រោះពីការជួញដូរមនុស្ស" ហាក់ដូចជាមានការសន្មតមួយស្រដៀងគ្នាដែលអនុវត្តជាទូទៅនៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់គឺថា៖ ជនរងគ្រោះត្រូវបានកំណត់អត្តសញ្ញាណដោយផ្អែកលើមូលដ្ឋាននៃសញ្ញាណដែលថា បទល្មើសជួញដូរមនុស្សត្រូវបានប្រព្រឹត្តមកលើរូបគាត់។ នៅគ្រប់ករណីទាំងអស់ អ្វីដែលមិនច្បាស់នោះគឺថា តើការសន្មតពីឋានៈជាជនរងគ្រោះបែបនេះមានភាពពេញលេញ ដើម្បីអាចឱ្យអ្នកទាំងនោះមានសិទ្ធិទទួលបានការការពារ និងជំនួយដូច "ជនរងគ្រោះពីការជួញដូរមនុស្ស" ដែរឬយ៉ាងណា។

ខុសពីរដ្ឋសមាជិកអាស៊ានជាច្រើនទៀត ក្របខ័ណ្ឌគតិយុត្តិរបស់**ប្រទេសវៀតណាម** ផ្តល់នូវការណែនាំលម្អិតបង្ហូរស្តីពីរបៀបកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ។ ច្បាប់ស្តីពីការជួញដូរមនុស្សចម្បង (LPSAHT មាត្រា ២៤ និង ២៥) ចែងថា ជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានបញ្ជូនទៅស្ថាប័នរដ្ឋាភិបាលដែលសមស្រប ដែលពិនិត្យជាបឋមទៅលើពួកគេដើម្បីស្វែងរកព័ត៌មានមូលដ្ឋាន និងផ្តល់ "លិខិតបញ្ជាក់ពីឋានៈជាជនរងគ្រោះ" ក្នុងរយៈពេល ៣ ថ្ងៃ និងបន្ទាប់មក បញ្ជូនទៅកាន់សេវាថែទាំដែលសមស្រប។ ក្រឹត្យឆ្នាំ២០១២ ស្តីពីការកំណត់អត្តសញ្ញាណ និងសុវត្ថិភាពរបស់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេបានដកចេញនូវលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់ដែលថា ការកំណត់អត្តសញ្ញាណ និងការគាំទ្រជនរងគ្រោះត្រូវធ្វើឡើងនៅពេលកំណត់អត្តសញ្ញាណ ឬចាប់ខ្លួនជនជួញដូរមនុស្ស។ ក្រឹត្យនេះអះអាងថា ការកំណត់អត្តសញ្ញាណជនរងគ្រោះគឺផ្អែកទៅលើប្រភពជាច្រើន រួមមាន

---

[១១៤] ព័ត៌មាននេះដកស្រង់ចេញពី *ទស្សនាវដ្តី ACWC Regional Review* (ឆ្នាំ២០១៥)។

ឯកសារ និងភស្តុតាងពីភ្នាក់ងារដែលបើកកិច្ចដំណើរការនីតិវិធី ព័ត៌មាន និងឯកសារដែលផ្តល់ដោយជនរងគ្រោះដែលបានជួយសង្គ្រោះ/ដែលបានបញ្ជូនត្រឡប់មកវិញ ព័ត៌មាន និងឯកសារដែលផ្តល់ការិយាល័យតំណាងវៀតណាមនៅបរទេស ឯកសារដែលចេញដោយដៃគូបរទេស សក្ខីកម្មដែលជនរងគ្រោះបានផ្តល់ និងសក្ខីកម្មដែលសាក្សីបានផ្តល់។ ប្រសិនបើប្រភពទាំងនេះមិនគ្រប់គ្រាន់ទេ កត្តាផ្សេងទៀត (ដូចជា ថាតើជននោះត្រូវបានជួយសង្គ្រោះនៅក្នុងចំណោមជនរងគ្រោះផ្សេងទៀត សញ្ញានៃការកេងប្រវ័ញ្ចផ្លូវភេទ ឬការងារដោយបង្ខំ។ល។) នឹងត្រូវយកមកពិចារណា នៅពេលសម្រេចថាតើជននោះគឺជាជនរងគ្រោះពីការជួញដូរមនុស្ស ឬយ៉ាងណា[១១៥]។ ច្បាប់ទាំងនេះត្រូវបានបំពេញបន្ថែមដោយសារាចររបស់អន្តរក្រសួងដែលលើកឡើងនូវគោលការណ៍ណែនាំលម្អិត ជាពិសេសសម្រាប់ការកំណត់អត្តសញ្ញាណ និងការទទួលយកស្ត្រី និងកុមារវៀតណាមដែលរងការជួញដូរមនុស្សពីបរទេស។ សារាចរឆ្នាំ២០០៨ បានកំណត់អត្តសញ្ញាណភ្នាក់ងារបង្គោល និងទទួលខុសត្រូវ និង នីតិវិធីសម្រាប់ដោះស្រាយការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធនៅក្នុងសេណារីយ៉ូជាច្រើន (វិលត្រឡប់ពីប្រទេសដែលមានព្រំដែនជាប់គ្នា ឬគ្មានព្រំដែនជាប់គ្នា ការបញ្ជូនពីភ្នាក់ងារតំណាងវៀតណាមនៅបរទេស ជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះ ឬវិលត្រឡប់មកវិញដោយខ្លួនឯង ។ល។)។

## វឌ្ឍនភាពរបស់រដ្ឋសមាជិកអាស៊ានស្តីពីការកំណត់អត្តសញ្ញាណ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ៖ នីតិវិធី និងការអនុវត្តន៍ជាក់ស្តែង[១១៦]

ដូចបានកត់សម្គាល់ខាងលើ ហាក់ដូចជាមានមួយភាគតូចប៉ុណ្ណោះ នៃចំនួនមនុស្សសរុបដែលរងការជួញដូរមនុស្សនៅក្នុងតំបន់អាស៊ានដែលបានទទួលការយកចិត្តទុកដាក់ជាផ្លូវការ។ ក្នុងចំណោមអ្នកទាំងនោះ មនុស្សជាច្រើនត្រូវបានប្រព្រឹត្ត ដោយភាន់ច្រឡំថា ជាជនទេសន្តរប្រវេសន៍មិនប្រក្រតី។ រដ្ឋសមាជិកអាស៊ានមួយបានរាយការណ៍ថា បញ្ហាដែលកំពុងបន្តមានជាមួយជនទេសន្តរប្រវេសន៍ដែលត្រូវបាននិរទេស ក្រោយមកមួយចំនួនត្រូវបានរកឃើញថាជាជនរងគ្រោះពីការជួញដូរមនុស្ស ដែលត្រូវបានបញ្ជូនឆ្លងដែន។ ឧទាហរណ៍នេះក៏ចង់ចង្អុលបង្ហាញថា កាតព្វកិច្ចនៃការកំណត់អត្តសញ្ញាណជនរងគ្រោះគឺជាកាតព្វកិច្ចមួយដែលមានចំពោះប្រទេសគោលដៅផង និងប្រទេសដើមផង។ ពុំមានភស្តុតាងដែលថា កុមាររងគ្រោះពីការជួញដូរមនុស្សត្រូវបានបញ្ជូនយ៉ាងស៊ីចង្វាក់គ្នាទៅកាន់អាជ្ញាធរការពារកុមារទេ ឬក៏ពួកគេបានទទួលការថែទាំជាពិសេសតាមវិធីណាផ្សេងដែរ។

នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន នីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ និងបញ្ជូនទៅស្ថាប័នពាក់ព័ន្ធគឺផ្អែកទៅលើនីតិវិធី និងគោលការណ៍ណែនាំដែលមានគោលបំណងធានាដល់អ្នកនៅជួរមុខថាអាចទទួលស្គាល់ជនរងគ្រោះពីការជួញដូរមនុស្ស និងផ្តល់នូវការឆ្លើយតបដំបូងដែលពេញលេញ។ ឧទាហរណ៍ នៅក្នុង**ប្រទេសឡាវ ថៃ ម៉ាឡេស៊ី** និង**សិង្ហបុរី** ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធបានបង្កើតមធ្យោបាយនានា (ដូចជាបញ្ជីត្រួតពិនិត្យ គោលការណ៍ណែនាំ និងប័ណ្ណផ្សព្វផ្សាយចំណេះដឹង) ដែលជាគោលការណ៍ មានគោលបំណងជួយមន្ត្រីអនុវត្តច្បាប់ជួរមុខក្នុងការ

---

[១១៥] ក្រឹត្យលេខ *62/2012/ND-CP* ស្តីពីការរៀបរាប់អំពីមូលដ្ឋានសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស និងការការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ (វៀតណាម)។

[១១៦] ព័ត៌មាននេះដកស្រង់ចេញពី *ទស្សនាវដ្តី ACWC Regional Review* (ឆ្នាំ២០១៥)។

កំណត់អត្តសញ្ញាណជនដែលអាចរងការជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ានមួយចំនួន រួមមាន**ប្រទេសឥណ្ឌូនេស៊ី**ជាដើម បានបង្កើតមធ្យោបាយសម្រាប់កំណត់អត្តសញ្ញាណសម្រាប់វិស័យជាក់លាក់ (ដូចជានេសាទជាដើម)។

នៅក្នុងតំបន់អាស៊ានទាំងមូល ជាគោលការណ៍ការអនុវត្តន៍ជាក់ស្តែងនៃការកំណត់អត្តសញ្ញាណជនរងគ្រោះមិនទាន់សកម្មទេ៖ ជនរងគ្រោះមិនត្រូវបាន "រកឃើញ" ដោយអ្នកឆ្លើយតបជួរមុខ ដូចជា មន្ត្រីនគរបាលទេ តែជាទូទៅពួកគេបានបង្ហាញអត្តសញ្ញាណដោយខ្លួនឯងដល់មន្ត្រីនគរបាល ឬទៅអង្គការគាំទ្រនានា ខណៈដែលពួកគេស្ថិតក្នុងស្ថានភាពរងការកេងប្រវ័ញ្ចនៅឡើយ ឬនៅពេលពួកគេបានគេចខ្លួនពីជនជួញដូរមកលើពួកគេ។ ចំណុចនេះបង្ហាញថាទីភ្នាក់ងារអនុវត្តន៍ច្បាប់ និងភ្នាក់ងាររបស់មន្ត្រីអនុវត្តច្បាប់ជួរមុខផ្សេងទៀតកំពុងដើរតួនាទីមិនទាន់សកម្មទេ ទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស។ ឧទាហរណ៍ ការសិក្សាមួយទៅក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅ**ប្រទេសវៀតណាម** បានរកឃើញថា ជនរងគ្រោះចំនួន ៤០ភាគរយ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាល ត្រូវបានរកឃើញតាមរយៈសេវាទូរស័ព្ទទាន់ហេតុការណ៍នៅទូទាំងប្រទេស ចំណែកឯ ៦០ភាគរយទៀត បានមកទាក់ទងមន្ត្រីនគរបាលតាមរយៈការបង្ហាញអត្តសញ្ញាណដោយខ្លួនឯងនៅប៉ុស្តិ៍នគរបាល សារអ៊ីមែលដែលជនរងគ្រោះបានផ្ញើមក និងបេសកកម្មជួយសង្គ្រោះ[១១៧]។ សារាចររដ្ឋបាលមួយដែលបានផ្សព្វផ្សាយនៅឆ្នាំ២០១៣ បានអះអាងថា ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សនៅវៀតណាមកើតឡើងតាមរយៈ (១) ការស៊ើបអង្កេតផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ (២) ការស្តាប់ចម្លើយជនរងគ្រោះ (៣) ការទទួលការចោទប្រកាន់ពីបុគ្គល និង/ឬអង្គការនានា និង (៤) ការសហការជាមួយប្រទេសផ្សេងទៀត (ឧទាហរណ៍ ប្រសិនបើជនរងគ្រោះវៀតណាមពីការជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណដោយមន្ត្រីនៅក្នុងប្រទេសគោលដៅមួយទៀត)។

ក្នុងការអនុវត្តន៍ជាក់ស្តែង ការវាយតម្លៃនៅតាមប្រទេសដែលបានធ្វើឡើងសម្រាប់ទស្សនាវដ្តី ACWC Regional Review បានរកឃើញថា រដ្ឋសមាជិកអាស៊ានភាគច្រើនជួបការលំបាក ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្ស។ បញ្ហានេះហាក់ដូចជាធ្ងន់ធ្ងរ ជាពិសេសទាក់ទងនឹងការងារដោយបង្ខំ។ ឧទាហរណ៍ មានការរាយការណ៍ថា បុគ្គលិកអនុវត្តន៍ច្បាប់ជាច្រើនមិនធ្វើការពិនិត្យឲ្យបានពេញលេញទេ ច្រើនមានគំនិតច្រានចោលសំណុំរឿងទាំងនេះដោយគ្រាន់តែចាត់ទុកថាជា "បញ្ហាការងារ" ឬ "សំណុំរឿងបំពារបំពាន" ដែលប្រព្រឹត្តទៅលើជនដែលបានយល់ព្រមធ្វើការនៅក្នុងវិស័យឧស្សាហកម្មនោះតែប៉ុណ្ណោះ។ ស្រដៀងគ្នាដែរ មានរបាយការណ៍ដែលថា ស្ត្រីដែលរងការជួញដូរមនុស្សសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ អាចត្រូវបានចោទប្រកាន់ពីបទល្មើសពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ជាជាងយកពិនិត្យស្វែងរកការជួញដូរមនុស្ស។ មានការដកស្រង់នូវឧទាហរណ៍ចេញពីសំណុំរឿងនានា ដែលមានសូចនាកររបៀបចាស់ ស្តីពីការជួញដូរមនុស្ស ដូចជា ការដកហូតលិខិតឆ្លងដែន ការបដិសេធមិនផ្តល់សិទ្ធិក្នុងការធ្វើដំណើរការ មិនបង់ប្រាក់ឈ្នួល ក្លែងបន្លំ និងធ្វើការបន្ថែមម៉ោងដោយបង្ខំ ត្រូវបានបញ្ជូនទៅមន្ត្រីផ្នែកការងារ ជាជាងធ្វើការស៊ើបអង្កេតជាបទល្មើសជួញដូរមនុស្ស។ នៅក្នុងបរិបទនោះ មានការកត់សម្គាល់ថា ពុំមានការលើកទឹកចិត្តឲ្យមន្ត្រី ធ្វើការកំណត់អត្តសញ្ញាណសំណុំរឿងនានាថាជា "ការជួញដូរមនុស្ស" ទេ លុះត្រាតែសំណុំរឿងទាំងនោះទាក់ទាញឲ្យមានបន្ទុករដ្ឋបាលធ្ងន់ធ្ងរ។ មានការឆ្លើយតបផ្សេងមួយទៀត នៅក្នុងការស្ទាបស្ទង់មតិនៅតាមប្រទេសបានលើកឡើងអំពីកង្វះការបណ្តុះបណ្តាល និងការប្រែប្រួលនៃវិធីសាស្ត្របទល្មើសរបស់ជនជួញដូរមនុស្ស (ឧទា.

[១១៧] UNODC ការវាយតម្លៃពីតម្រូវការចាំបាច់សម្រាប់បង្កើតនូវយន្តការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធនៅវៀតណាម (N.D.) ទំព័រ ២៩។

ប្រើប្រាស់ឯកសារក្លែងក្លាយដើម្បីបញ្ចៀសពីការកំណត់អត្តសញ្ញាណជនរងគ្រោះនៅលើទូកនេសាទ) ដែលជាឧបសគ្គបន្ថែមទៀតចំពោះការកំណត់អត្តសញ្ញាណយ៉ាងមានប្រសិទ្ធភាព។

នៅ**ប្រទេសឥណ្ឌូនេស៊ី** ជនរងគ្រោះភាគច្រើនហាក់ដូចជាត្រូវបានកំណត់អត្តសញ្ញាណ ក្រោយពេលមានការរាយការណ៍ទៅអាជ្ញាធរជាតិ (ដោយជនរងគ្រោះ ដោយអង្គការក្រៅរដ្ឋាភិបាល ឬដោយសារព័ត៌មាន)[១១៨]។ ដំណើរការកំណត់អត្តសញ្ញាណផ្លូវការសម្រាប់ជនរងគ្រោះឥណ្ឌូនេស៊ីពីការជួញដូរមនុស្សត្រូវបានធ្វើ តាមរយៈការសម្ភាសន៍ និងការសង្កេត។ មន្ត្រីនគរបាល បុគ្គលិកសង្គមកិច្ច ពីអាជ្ញាធររដ្ឋាភិបាល (ឧទាហរណ៍ មជ្ឈមណ្ឌលគាំទ្រអ្នកមានវិបត្តិ និងផ្ទះមានសុវត្ថិភាព) អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីបម្រើសេវាប្រជាពលរដ្ឋនៅក្នុងស្ថានទូត និងស្ថានកុងស៊ុលឥណ្ឌូនេស៊ីទាំង ២៤ នៅបរទេស អាចចូលរួមក្នុងការកំណត់អត្តសញ្ញាណ។ គោលការណ៍ណែនាំលម្អិតត្រូវបានបង្កើតឡើង ដើម្បីជួយដល់ដំណើរការកំណត់អត្តសញ្ញាណ។ វគ្គបណ្តុះបណ្តាលត្រូវបានបើកឡើង ដើម្បីធានាថាមន្ត្រីដែលបំពេញកាតព្វកិច្ចនេះមានសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះយ៉ាងត្រឹមត្រូវ និងដោយមិនបណ្តាលឱ្យពួកគេមានគ្រោះថ្នាក់ឡើយ។ ក៏ប៉ុន្តែមានការរាយការណ៍ថា មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលពុំមានគ្រប់គ្រាន់ជានិច្ចកាលទេ ហើយចំណុចនេះអាចបណ្តាលឱ្យមានការគំរាមកំហែង និងវិធីសាស្ត្រមិនសមរម្យផ្សេងទៀត ដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះ[១១៩]។

គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះថ្នាក់ជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦ ហើយបច្ចុប្បន្នកំពុងអនុវត្តនៅ**ប្រទេសឡាវ**។ ដោយសារជាចម្បងប្រទេសឡាវជាប្រទេសដើមសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ជាទូទៅការកំណត់អត្តសញ្ញាណផ្លូវការកើតឡើងនៅក្នុងប្រទេសគោលដៅ។ ឧទាហរណ៍ នៅ**ប្រទេសថៃ** បានយល់ព្រមឱ្យឱ្យមាននីតិវិធីរវាងប្រទេសឡាវ និងថៃ គ្រប់គ្រងលើដំណើរការកំណត់អត្តសញ្ញាណសម្រាប់ជនរងគ្រោះឡាវពីការជួញដូរមនុស្ស។ បន្ទាប់ពីមានការកំណត់អត្តសញ្ញាណផ្លូវការ ជនរងគ្រោះត្រូវបានដាក់នៅក្នុងជម្រកស្នាក់នៅ ក្នុងអំឡុងពេលមានកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ហើយការធ្វើមាតុភូមិនិវត្តន៍នឹងមិនកើតឡើងទេ រហូតទាល់តែដំណើរការចោទប្រកាន់ចប់សព្វគ្រប់។ ជនរងគ្រោះដែលត្រូវធ្វើមាតុភូមិនិវត្តន៍ ត្រូវបានដាក់នៅក្នុងជម្រកឆ្លងកាត់ដែលគ្រប់គ្រង ដោយសមាគមស្ត្រីឡាវក្នុង រយៈពេល ៧ ថ្ងៃ ដើម្បីធ្វើការវាយតម្លៃចំពោះតម្រូវការចាំបាច់របស់ពួកគេ និងផ្តល់/រៀបចំជំនួយ។ ថិរវេលានេះក៏ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីឱ្យមន្ត្រីអនុវត្តន៍ច្បាប់ឡាវអាចសម្ភាសអ្នករិលត្រឡប់ទាំងនោះផងដែរ។ ក្រោយពេល ៧ ថ្ងៃកន្លងផុតទៅ ជាទូទៅ ជនរងគ្រោះត្រូវបានបញ្ជូនទៅទីកន្លែងដើម ហើយមន្ត្រីមូលដ្ឋានមានភារកិច្ចក្នុងការផ្តល់ការគាំទ្របន្ថែមទៀត ទៅតាមការចាំបាច់។

---

[១១៨] ឧទាហរណ៍មានប្រយោជន៍មួយនាពេលបច្ចុប្បន្នអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយប្រភពដែលមិនផ្លូវការទាក់ទិននឹងការបង្ហាញនូវការជួញដូរមនុស្សនៅក្នុងវិស័យនេសាទឥណ្ឌូនេស៊ី។ ចំណុចនេះលេចចេញជារូបរាង បន្ទាប់ពីមានការស៊ើបអង្កេតមួយដោយកាសែត Associated Press (AP) ដែលបានចុះផ្សាយរបាយការណ៍មួយនៅខែមីនា ឆ្នាំ២០១៥ មានចំណងជើងថា "តើទាសករកំពុងចាប់ត្រីដែលអ្នកទិញមែនទេ?"។ ផ្អែកលើអត្ថបទកាសែតបែបស៊ើបអង្កេតនេះ មន្ត្រីអនុវត្តន៍ច្បាប់បានបើកការស៊ើបអង្កេតផ្លូវការមួយ បន្ទាប់មកបានកំណត់អត្តសញ្ញាណមនុស្សចំនួន ៣៦៩ នាក់មកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា ឡាវ ថៃ និងឥណ្ឌូនេស៊ីជាជនរងគ្រោះពីការជួញដូរមនុស្ស។ ដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលឥណ្ឌូនេស៊ី ដែលមានការគាំទ្រពីមន្ត្រីកំណត់អត្តសញ្ញាណមកពី អង្គការ IOM ប្រចាំប្រទេសឥណ្ឌូនេស៊ី។

[១១៩] បទបញ្ជាថ្នាក់ក្រសួងនៃ *PPPA* លេខ ២២ ឆ្នាំ២០១០ ស្តីពីសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស និងអំពើហិង្សាមកលើកុមារ។

នៅ**ប្រទេសមីយ៉ាន់ម៉ា** ជាទូទៅ ការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាការទទួលខុសត្រូវរបស់អង្គភាពឯកទេសផ្នែកជួញដូរមនុស្សនៅក្នុងនគរបាលជាតិ។ ភាពចាំបាច់នៃការបង្កើតនីតិវិធីជាប្រព័ន្ធសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះ (ទាំងជនរងគ្រោះជាជនជាតិខ្លួន និងបរទេស) ត្រូវបានទទួលស្គាល់ជាទូទៅ។ ប្រទេសមីយ៉ាន់ម៉ាក៏បានទទួលស្គាល់ពីតម្រូវការចាំបាច់ឱ្យមានការសម្របសម្រួលជាប្រព័ន្ធរវាងប្រទេសនិងប្រទេស។ ឧទាហរណ៍ ដោយសារមន្ត្រីមកពីប្រទេសមីយ៉ាន់ម៉ា មិនអាចសហការជាមួយដៃគូរបស់ខ្លួននៅប្រទេសចិនបាន ជនរងគ្រោះមីយ៉ាន់ម៉ាពីការជួញដូរមនុស្សនៅប្រទេសចិន អាចត្រូវបានកំណត់អត្តសញ្ញាណខុស ជាអ្នកទេសន្តរប្រវេសន៍ខុសច្បាប់ទៅវិញ និងត្រូវបាននិរទេស ជាជាងត្រូវបានប្រព្រឹត្តជាជនរងគ្រោះនៃបទល្មើស។ ប្រទេសមីយ៉ាន់ម៉ារាយការណ៍ ពីសហប្រតិបត្តិការល្អជាមួយអាជ្ញាធរថៃស្តីពីការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តចំពោះជនរងគ្រោះមីយ៉ាន់ម៉ា ពីការជួញដូរមនុស្សនៅប្រទេសថៃ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ មានការប្រឈមនៅពេលកម្រិតសមស្រប នៃកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារនិងភ្នាក់ងារមិនបានកើតឡើងទេ។

**ប្រទេសហ្វីលីពីន** រាយការណ៍ថា ជនរងគ្រោះពីការជួញដូរមនុស្ស ត្រូវបានកំណត់អត្តសញ្ញាណរួមគ្នាតាមរយៈប្រតិបត្តិការជួយសង្គ្រោះ សម្ភាសន៍ពិនិត្យនៅតាមកំពង់ផែ និងព្រំដែន របាយការណ៍ពីស្ថានទូត និងស្ថានកុងស៊ុលនៅបរទេស ការបញ្ជូនសំណុំរឿងទៅស្ថាប័នពាក់ព័ន្ធ និងការរាយការណ៍តាមរយៈការអំពាវនាវរបស់រដ្ឋាភិបាល និងខ្សែទូរស័ព្ទទាន់ហេតុការណ៍/ខ្សែទូរស័ព្ទផ្តល់ជំនួយរបស់អង្គការក្រៅរដ្ឋាភិបាល។ នៅក្នុងករណីមួយចំនួន សំណុំរឿងជួញដូរមនុស្សត្រូវបានរកឃើញ ក្នុងអំឡុងពេលកសាងសំណុំរឿងដែលស្រដៀងគ្នា ការពិភាក្សាក្នុងអំឡុងពេលប្រជុំ ឬសន្និសីទអំពីសំណុំរឿង និងកាលៈទេសៈស្រដៀងគ្នាផ្សេងទៀត។ នៅក្នុងសំណុំរឿងទាំងនោះ អ្នកផ្តល់សេវានៃភ្នាក់ងារទទួលត្រូវសម្របសម្រួល នូវការកំណត់អត្តសញ្ញាណស្ត្រីរងការជួញដូរមនុស្សឱ្យបានឆាប់រហ័ស តាមរយៈជំហាន ៣ គឺ៖ ការសម្ភាសន៍ និងវាយតម្លៃបឋម ការប្រើប្រាស់បញ្ជីត្រួតពិនិត្យសូចនាករ និងការពិនិត្យទៅលើសម្ភារគាំទ្របន្ថែមទៀត។ អ្នកផ្តល់សម្ភាសន៍បានគូសបញ្ជាក់នូវសភាពជាក់ស្តែងនៅប្រទេសហ្វីលីពីន ដែលពិតជាអនុវត្តបានទូលំទូលាយជាងគេគឺថា៖ ការកំណត់អត្តសញ្ញាណត្រឹមត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនាញរបស់បុគ្គលិកដែលធ្វើការវាយតម្លៃ។ ការសន្មតអំពីឋានៈរបស់ជនរងគ្រោះទាក់ទងនឹងកុមារ ដែលអាចរងការជួញដូរមនុស្ស (ដែលជាផ្នែកនៃច្បាប់ហ្វីលីពីនផងដែរនោះ) ក៏ត្រូវបានកត់សម្គាល់ថាជាផ្នែកសំខាន់នៃទម្លាប់អនុវត្តន៍ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដែរ។

នៅ**ប្រទេសសិង្ហបុរី** ជនរងគ្រោះពីការជួញដូរមនុស្ស អាចត្រូវបានកំណត់អត្តសញ្ញាណតាមរយៈទីកន្លែងនានា (ឧទា. នៅចំណុចត្រួតពិនិត្យ ដោយមន្ត្រីអនុវត្តច្បាប់ជួរមុខតាមរយៈការឆ្មក់ ការបញ្ជូនពីអង្គការក្រៅរដ្ឋាភិបាល និងប្រតិបត្តិការផ្សេងទៀត ។ល។)។ ប្រទេសសិង្ហបុរីបានរាយការណ៍ថា បន្ទាប់មក មន្ត្រីមកពីក្រុមស៊ើបអង្កេតឯកទេសនៅក្នុងក្រសួងកម្លាំងពលកម្ម (MOM) ឬកងកម្លាំងនគរបាលសិង្ហបុរី (SPF) នឹងស្តាប់ចម្លើយជនរងគ្រោះពីការជួញដូរមនុស្ស។ អ្នកបកប្រែ និង/ឬមន្ត្រីជាស្ត្រី នឹងជួយក្នុងពេលស្តាប់ចម្លើយ ក្នុងករណីចាំបាច់។ សិង្ហបុរីបានរាយការណ៍បន្ថែមថា ជនរងគ្រោះពីការជួញដូរមនុស្ស ត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំងដោយមានការយល់ចិត្ត និងសេចក្តីថ្លៃថ្នូរដល់ពួកគេ។ មានការកត់សម្គាល់បន្ថែមថា ជនរងគ្រោះបរទេស មានសិទ្ធិទទួលបានឋានៈគតិយុត្តិរបស់ខ្លួន ដែលត្រូវបានកំណត់បណ្តោះអាសន្នតាមរយៈលិខិតបញ្ជាក់ពិសេស ដែលមានសុពលភាពអាចបន្តការស្នាក់នៅក្នុងប្រទេសសិង្ហបុរីបានទៀត។

ក្រុមការងារអន្តរទីភ្នាក់ងារទទួលបន្ទុកផ្នែកជួញដូរមនុស្សរបស់សិង្ហបុរី បានរាយការណ៍ថា ក្រុមការងារនេះទទួលស្គាល់នូវសេវាតភ្ជាប់ដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ហើយថា ក្រុមនេះបានបង្កើតបណ្តាញផ្ទាល់ជាមួយ

ពួកគេសម្រាប់បញ្ជូនសំណុំរឿងជួញដូរមនុស្សដែលអាចមាន។ អង្គការក្រៅរដ្ឋាភិបាលទាក់ទងដោយផ្ទាល់ទៅសមាជិកក្រុមការងារនេះ ហេតុនេះអាចផ្តល់ព័ត៌មានស្តីពីជនរងគ្រោះពីការជួញដូរមនុស្ស និងចារី ដើម្បីឲ្យរដ្ឋាភិបាលតាមដានដោយការស៊ើបអង្កេតផ្លូវការ។ ដើម្បីពង្រឹងភាពជាដៃគូនេះ ដោយមានការពិគ្រោះយោបល់ជាមួយ អង្គការក្រៅរដ្ឋាភិបាល ក្រុមការងារនេះបានបង្កើតយន្តការបញ្ជូនសំណុំរឿងជួញដូរមនុស្ស នៅខែសីហា ឆ្នាំ២០១៣ ដើម្បីកាត់បន្ថយឧបសគ្គផ្នែកនីតិវិធីក្នុងការដោះស្រាយសំណុំរឿង។ យន្តការនៃការបញ្ជូនសំណុំរឿងសម្របសម្រួលការធ្វើអន្តរាគមន៍បានទាន់ពេលវេលា ដើម្បីធានាថាសំណុំរឿងបានលេចឡើង និងយកមកដោះស្រាយ និងជួយឲ្យ MOM និង SPF អាចធ្វើការតាមដានសំណុំរឿងឲ្យមានប្រសិទ្ធភាពជាងមុន។ ហេតុនេះ ការបញ្ជូនទាំងអស់ត្រូវបានរាយការណ៍ថាបានស៊ើបអង្កេតហើយ។ ទោះបីការបញ្ជូនភាគច្រើនក្នុងចំណោមការបញ្ជូនទាំងនេះ ត្រូវបានបង្កើតឡើងយ៉ាងពេញលេញ ជាសំណុំរឿងជួញដូរមនុស្ស ក៏ដោយ តែប្រទេសសិង្ហបុរីបានរាយការណ៍ថា ក្នុងករណីចាំបាច់ សកម្មភាពអនុវត្តន៍ច្បាប់សមស្របត្រូវបានធ្វើឡើងប្រឆាំងនឹងនិយោជកដែលប្រព្រឹត្តខុស ក្រោមច្បាប់ការងារពាក់ព័ន្ធផ្សេងទៀត។

បញ្ហានៃ**ការកំណត់អត្តសញ្ញាណខុស** កម្រនឹងលើកយកមកពិភាក្សាណាស់ តែជាប្រភពកង្វល់ធំមួយសម្រាប់រដ្ឋសមាជិកអាស៊ានមួយចំនួន។ នៅក្នុងករណីទាំងនេះ ការបកស្រាយទូលំទូលាយពេកទៅលើនិយមន័យនៃការជួញដូរមនុស្ស និងការអនុវត្តន៍ច្បាប់ និងទម្លាប់ចោទប្រកាន់មិនត្រឹមត្រូវនាំឲ្យមានស្ថានភាពដែលបទល្មើសផ្សេងទៀត ឬការប្រព្រឹត្តដែលមិនមែនការបទល្មើសព្រហ្មទណ្ឌតឹងរ៉ឹង ត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ជាការជួញដូរមនុស្ស ហើយ "ជនរងគ្រោះ" ត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះពីការជួញដូមនុស្សរ។ ឧទាហរណ៍ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយ ការប្រព្រឹត្តិដែលត្រូវបានចោទប្រកាន់យ៉ាងត្រឹមត្រូវជាការទាក់ម៉ូយ ត្រូវបានស៊ើបអង្កេតជាប្រចាំ និងត្រូវបានចោទប្រកាន់ជាការជួញដូរមនុស្ស។ យ៉ាងហោចណាស់នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន អ្នកដែលពាក់ព័ន្ធនឹងការរៀបចំអាពាហ៍ពិពាហ៍ឆ្លងដែនត្រូវបានកំណត់អត្តសញ្ញាណជាប្រចាំថាជា "ចារី" និង "ជនរងគ្រោះ" ពីការជួញដូរមនុស្ស ទោះបីពុំមានភស្តុតាងអំពីការបង្ខិតបង្ខំ ឬការកេងប្រវ័ញ្ចក៏ដោយ។

## វឌ្ឍនភាពរបស់រដ្ឋសមាជិកអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកនូវការសម្រេចកំណត់អត្តសញ្ញាណជនរងគ្រោះ

ការទទួលស្គាល់ដោយរដ្ឋមួយ នូវការសម្រេចកំណត់អំពីឋានៈជនរងគ្រោះ ដែលធ្វើឡើងដោយរដ្ឋមួយទៀតជាការសំខាន់សម្រាប់ធានាថា សិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារ។ ដូចបានកត់សម្គាល់ខាងលើ *អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* តម្រូវឲ្យមានការទទួលស្គាល់ទៅវិញទៅមកនូវការសម្រេចកំណត់ថាជាជនរងគ្រោះក្នុងចំណោមរដ្ឋភាគី។

ក្នុងការអនុវត្តន៍ជាក់ស្តែង ជាទូទៅ រដ្ឋសមាជិកអាស៊ានហាក់ដូចជាទទួលស្គាល់ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ និងធ្វើមាតុភូមិនិវត្តន៍ដោយទីភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសគោលដៅនៅក្នុងអាស៊ាន។ ករណីនេះហាក់ដូចជាការពិត ជាពិសេសសម្រាប់ប្រទេស "ប្រភព" ធំៗនៃរដ្ឋសមាជិកអាស៊ានដែលមានចំនួនពលករធ្វើការនៅបរទេសដ៏ច្រើនសន្ធឹកសន្ធាប់ ដូចជា **ប្រទេសឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា** និង**ហ្វីលីពីន**។ នៅក្នុងករណីរបស់រដ្ឋសមាជិកអាស៊ានមួយចំនួន ចំនួនជនរងគ្រោះសរុបដែលត្រូវបានជួយ រួមមានតែអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណ និងធ្វើមាតុភូមិនិវត្តន៍ពីប្រទេសគោលដៅប៉ុណ្ណោះ ដែលបង្ហាញថា អ្នកដែលវិលត្រឡប់មកផ្ទះវិញដោយខ្លួនឯង តាមរយៈនិយោជក ឬតាមរយៈ អង្គការក្រៅរដ្ឋាភិបាល មិនត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះពីការ

ជួញដូរមនុស្សទេ។ ក៏ប៉ុន្តែ ជារួម បញ្ហាចម្បងហាក់ដូចជាការកំណត់អត្តសញ្ញាណជនរងគ្រោះ ពីការជួញដូរមនុស្ស នៅក្នុងប្រទេសគោលដៅមិនស៊ីចង្វាក់ ឬមិនពេញលេញ ដែលបណ្ដាលឱ្យមានការបដិសេធមិនផ្ដល់ជំនួយ ការគាំទ្រ និងការការពារដល់អ្នកដែលត្រូវការចាំបាច់តាំងពីដើមដល់ចប់។

## ៥.៣ ធាតុផ្សំសំខាន់ៗនៃការការពារ និងការគាំទ្រជនរងគ្រោះ

ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់ មានសិទ្ធិត្រូវបានប្រព្រឹត្តដោយមានមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរ។ សិទ្ធិនេះបានកំណត់កាតព្វកិច្ចដល់រដ្ឋនានាទាក់ទង នឹងរបៀបដែលរដ្ឋទាំងនោះដោះស្រាយជាមួយជនរងការជួញដូរមនុស្ស។ ជាទូទៅមានការទទួលស្គាល់ថា ក្របខ័ណ្ឌគតិយុត្តិនៅថ្នាក់ជាតិគួរផ្ដល់ដល់ជនរងគ្រោះគ្រប់រូប *ដោយមិនគិតដល់ការជាប់ពាក់ព័ន្ធរបស់ពួកគេនៅក្នុងដំណើរការផ្លូវច្បាប់នានា* នូវ**សិទ្ធិទទួលបានការគាំទ្រ និងការការពារ**ជាក់ស្ដែង។ ក្នុងន័យធម្មតា ជាទូទៅចំណុចនេះតម្រូវឱ្យរដ្ឋមួយ ត្រូវបង្កើតគោលនយោបាយ និងនីតិវិធីទាក់ទងនឹងការទទួលស្គាល់**ឋានៈ**របស់ជនរងការជួញដូរមនុស្ស ដែលមានសិទ្ធិទទួលបានសេវាកម្មនានាដែលមាន។ ការកំណត់នេះគឺមានសារៈសំខាន់ណាស់ ពីព្រោះវាគឺជាសកម្មភាពមួយដែលជំរុញឱ្យជនរងគ្រោះទទួលបានការគាំទ្រ និងជំនួយ។ ដូចបានកត់សម្គាល់ខាងលើ ជាធម្មតា មានតែបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការថាជា "ជនរងគ្រោះពីការជួញដូរមនុស្ស" ទេ ដែលអាចអនុវត្តសិទ្ធិ និងការទទួលបាននៅជំនួយប្រភេទនេះ។

### ការការពារមិនឱ្យមានព្យសនកម្មបន្ថែមទៀត

កាតព្វកិច្ចបន្ទាន់ដំបូង និងសំខាន់បំផុតរបស់គាត់រដ្ឋនោះ គឺដើម្បីធានាថា ជនរងគ្រោះ ឬបុគ្គលដែលអាចជាជនរងគ្រោះ ត្រូវបានការការពារពីការកេងប្រវ័ញ្ច និងព្យសនកម្មបន្ថែមទៀត គេចចេញពីអ្នកដែលបានកេងប្រវ័ញ្ចជននោះរួចហើយ ព្រមទាំងពីអ្នកដទៃទៀត។ ក្នុងការអនុវត្តន៍ជាក់ស្ដែងត្រង់ចំណុចនេះ នឹងអាស្រ័យទៅលើកាលៈទេសៈនៃសំណុំរឿងនីមួយៗ តែតាមបទដ្ឋានអន្តរជាតិ និងតំបន់ គឺតម្រូវឱ្យរដ្ឋសមាជិកអាស៊ានចាត់*វិធានការសមហេតុផល*ដើម្បីសម្រេចដល់គោលដៅនេះ។ នៅក្នុងស្ថានភាពភាគច្រើន ការការពារសមហេតុផលពីព្យសនកម្មតម្រូវឱ្យ៖

- យកជនរងការជួញដូរមនុស្សចេញពីកន្លែងកេងប្រវ័ញ្ច ទៅកាន់កន្លែងមានសុវត្ថិភាព។
- ចូលរួមផ្ដល់នូវសេចក្ដីត្រូវការចាំបាច់ភ្លាមៗ ផ្នែកសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនរងការជួញដូរមនុស្ស។ និង
- វាយតម្លៃថាតើ ជនរងការជួញដូរមនុស្សកំពុងប្រឈមនឹងការបំភិតបំភ័យ ឬការសងសឹក ឬយ៉ាងណា និងចាត់វិធានការដើម្បីដោះស្រាយបញ្ហាព្រួយបារម្ភផ្នែកសុវត្ថិភាព។

សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការការពារសុវត្ថិភាពផ្លូវកាយរបស់ខ្លួន ត្រូវបានទទួលស្គាល់ជាក់ស្ដែងនៅក្នុង*អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស* (ដូចដែលបានបង្ហាញខាងក្រោម) និងគោលការណ៍ណែនាំ

សម្រាប់អ្នកប្រតិបត្តិអាស៊ាន[១២០]។ សិទ្ធិទទួលបានសុវត្ថិភាពផ្លូវកាយ ក៏ត្រូវបានលើកឡើងក្នុងការការពារជនរងគ្រោះបរទេសពីការធ្វើមាតុភូមិនិវត្តន៍ភ្លាមៗដែរ។

*ភាគីនីមួយៗត្រូវពិចារណាអនុម័តវិធានការផ្លូវច្បាប់ ឬវិធានការសមស្របផ្សេងទៀត ដែលអនុញ្ញាតឲ្យជនរងគ្រោះពីការជួញដូរមនុស្ស ស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ នៅក្នុងករណីសមស្រប។ ភាគីនីមួយៗត្រូវផ្តល់ការពិចារណាសមស្របដល់កត្តាសិទ្ធិមនុស្ស និងមានក្តីអនុគ្រោះដើម្បីសម្រេចតាមគោលបំណងនេះ។*

**មាត្រា ១៤(៤)**

*ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែង ដើម្បីផ្តល់សុវត្ថិភាពផ្លូវកាយ ដល់ជនរងគ្រោះពីការជួញដូរមនុស្ស នៅពេលពួកគេស្ថិតនៅក្នុងទឹកដីរបស់ខ្លួន។*

**មាត្រា ១៤(៥)**

ទោះបីមានកាតព្វកិច្ចភ្លាមៗ ដើម្បីជួយជាបឋម ដល់ជនរងគ្រោះ ដើម្បីឲ្យពួកគេចេញផុតពីគ្រោះថ្នាក់បន្ថែមទៀត វាក៏អាចជួយទៅដល់អ្នកផ្សេងទៀត ដែលអាចទទួលរងព្យសនកម្ម ឬបំភិតបំភ័យពីជនជួញដូរមនុស្ស និងអ្នកសមគំនិត។ ក្រៅពីជនរងគ្រោះ បញ្ជីនេះអាចបញ្ចូលអ្នកផ្តល់ព័ត៌មាន ដែលផ្តល់ សក្ខីកម្ម សមាជិកគ្រួសារ និងអ្នកផ្តល់សេវាគាំទ្រដល់ជនរងការជួញដូរមនុស្ស។

## ការផ្តល់ការគាំទ្រភ្លាមៗ

រដ្ឋដែលជនរងការជួញដូរមនុស្សស្ថិតនៅ ត្រូវផ្តល់ដល់ជននោះនូវការថែទាំផ្លូវកាយ និងផ្លូវចិត្តឲ្យបានពេញលេញ ដើម្បីបំពេញទៅតាមសេចក្តីត្រូវការភ្លាមៗ។ រដ្ឋក៏ត្រូវផ្តល់ដល់ជនរងគ្រោះ ឬអ្នកដែលសន្មតថាជាជនរងគ្រោះផងដែរនូវសិទ្ធិ និងការទទួលបានរបស់គាត់។ *អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* រួមមានបទប្បញ្ញត្តិដូចខាងក្រោម៖

*ក្នុងករណីសមស្រប ភាគីនីមួយៗត្រូវផ្តល់ការថែទាំ និងការគាំទ្រដល់ជនរងគ្រោះពីការជួញដូរមនុស្ស រួមទាំង នៅក្នុងករណីសមស្របធ្វើការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការផ្សេងទៀត និងផ្នែកផ្សេងទៀតនៃសង្គមស៊ីវិល ដូចខាងក្រោម៖*

*(ក) ការផ្តល់ផ្ទះសម្បែងសមស្រប*

*(ខ) ការប្រឹក្សាយោបល់ និងព័ត៌មាន ជាពិសេសពាក់ព័ន្ធនឹងសិទ្ធិស្របច្បាប់របស់ពួកគេ ជាភាសាដែលជនរងគ្រោះពីការជួញដូរមនុស្សអាចយល់បាន។*

*(គ) ជំនួយផ្នែកសុខាភិបាល ចិត្តសាស្ត្រ និងសម្ភារ។ និង*

---

[១២០] *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* វគ្គ ២ ផ្នែក ១ កថាខណ្ឌ ១.១.៦ (“នៅពេលដែលមានមូលដ្ឋានគ្រប់គ្រាន់គួរឲ្យសង្ស័យថាមនុស្សម្នាក់អាចជាជនរងគ្រោះពីការជួញដូរមនុស្ស បុគ្គលដែលនោះគួរត្រូវបានសន្មតថាជាជនរងគ្រោះពីការជួញដូរមនុស្ស និងត្រូវបានយកចេញទាន់ពេលវេលាពីគ្រោះថ្នាក់ ទៅកាន់កន្លែងមានសុវត្ថិភាព រង់ចាំការផ្ទៀងផ្ទាត់បន្ថែមទៀត”)។ សូមមើលផងដែរ UNTOC មាត្រា ២៥, *ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* មាត្រា ៦ និង ៩។

*(ឃ) ឱកាសការងារ អប់រំ និងបណ្តុះបណ្តាល។*

**មាត្រា ១៤(១០)**

*រដ្ឋភាគីត្រូវធ្វើទំនាក់ទំនងទៅកាន់ជនរងគ្រោះនៃការជួញដូរមនុស្ស ដែលត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងពេលវេលាមួយសមស្រប ព័ត៌មានស្តីពីលក្ខណៈនៃការការពារ ជំនួយ និងការគាំទ្រដែលពួកគេមានសិទ្ធិទទួលបាន ទៅតាមច្បាប់ជាតិ និងទៅតាមអនុសញ្ញានេះ។*

**មាត្រា ១៤(៩)**

ការផ្តល់ការការពារ និងការគាំទ្រភ្លាមៗ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជា*សិទ្ធិរបស់ជនរងគ្រោះដែលមិនអាចប្រកែកបាន៖* សិទ្ធិដែលគួរត្រូវបានទទួលស្គាល់ និងអនុវត្ត ដោយមិនគិតដល់សមត្ថភាព ឬឆន្ទៈរបស់ជននោះក្នុងការសហការជាមួយអាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌ។ មានហេតុផលល្អមួយចំនួនសម្រាប់ជំហរនេះ។ សំខាន់ជាងគេ បទពិសោធន៍បង្ហាញថា ការភ្ជាប់ការគាំទ្រជនរងគ្រោះទៅនឹងកិច្ចសហការមិនជោគជ័យទេ។ ជនរងគ្រោះដែលរងការបង្ខិតបង្ខំហាក់ដូចជាមិនអាចក្លាយជាសាក្សីដ៏សំខាន់នោះទេ ជាពិសេស នៅក្នុងព្រឹត្តិការណ៍ដែលថា ជននេះនៅតែទទួលរងការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្ត ឬភ័យខ្លាចពីការសងសឹក។ ជំនួយដែលមានលក្ខខណ្ឌ អាចរំពឹងថានឹងបង្កើននូវកម្រិតមិនទុកចិត្តខ្ពស់ដែលមានរួចទៅហើយរវាងជនរងគ្រោះ និងការអនុវត្តន៍ច្បាប់។ ជំនួយដែលមានលក្ខខណ្ឌអាចធ្វើឲ្យប៉ះពាល់ដល់ភាពជឿជាក់បានរបស់ជនរងគ្រោះនៅក្នុងតុលាការ ជាលក្ខណៈដែលអាចចៀសវាងបាន ប្រសិនបើជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណទាំងអស់បានទទួលជំនួយ និងការគាំទ្រក្នុងកម្រិតស្រដៀងគ្នា។

## ការការពារឯកជនភាព

សិទ្ធិទទួលបានឯកជនភាព គឺជាទិដ្ឋភាពសំខាន់មួយ នៃការការពារជនរងគ្រោះ ពីគ្រោះថ្នាក់បន្ថែមទៀត។ ការខកខានមិនបានការពារឯកជនភាព អាចបង្កើនភាពងាយរងគ្រោះរបស់ជនរងគ្រោះ ទៅនឹងការបំភិតបំភ័យ និងការសងសឹក។ វាអាចបង្កឲ្យមានការអាម៉ាស និងឈឺចាប់ដល់ជនរងគ្រោះ ដែលធ្វើឲ្យប៉ះពាល់ដល់ការវិលត្រឡប់ទៅរកសភាពដើមរបស់ខ្លួន និងការធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ។ បើតាមទស្សនាទានយុត្តិធម៌ព្រហ្មទណ្ឌ ការមិនបានការពារឯកជនភាព នឹងធ្វើឲ្យជនរងគ្រោះលែងមាន ឆន្ទៈចូលរួមនៅក្នុងការចោទប្រកាន់ជនជួញដូរមនុស្សមកលើពួកគេ ដោយព្រួយបារម្ភថាអាចនឹងត្រូវលាតត្រដាង និងទទួលការមាក់ងាយពីសង្គម។

ការការពារឯកជនភាពគួរតែលាតសន្ធឹងទៅដល់ជនរងការជួញដូរមនុស្សគ្រប់រូប រួមទាំង ឯកជនភាពពីបណ្តាញសារព័ត៌មានជាដើម លុះត្រាតែមានមូលដ្ឋានសមហេតុផលដែលសក្តិសមនឹងការជ្រៀតជ្រែក ដូចជា ការពិចារណាទៅដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ឧទាហរណ៍ លក្ខខណ្ឌការពារមួយដែលថា រាល់កិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ទាំងអស់ពាក់ព័ន្ធនឹងការជួញដូរមនុស្សត្រូវរក្សាជាការសម្ងាត់ អាចដំណើរការដោយជ្រៀតជ្រែកទៅដល់សិទ្ធិរបស់ជនជាប់ចោទ ហើយក៏អាចរារាំងនូវការត្រួតពិនិត្យយ៉ាងសំខាន់ពីខាងក្រៅទៅលើដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* អះអាងនូវសិទ្ធិទទួលបានឯកជនភាពដូចខាងក្រោម៖

*នៅក្នុងករណីសមស្រប និងនៅក្នុងវិសាលភាពដែលអាចធ្វើទៅបាន ក្រោមថ្នាក់ជាតិ រដ្ឋភាគីនីមួយៗត្រូវការពារឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះពីការជួញដូរមនុស្ស រួមមាន តាមរយៈរក្សាការសម្ងាត់នូវកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ពាក់ព័ន្ធ នឹងការជួញដូរមនុស្សនោះ។*

**មាត្រា ១៤(៦)**

## សិទ្ធិមិនត្រូវបានស្ថិតនៅក្នុងស្ថានភាពឃុំខ្លួន ឬចោទប្រកាន់ចំពោះបទល្មើស

ក្នុងការអនុវត្តន៍នូវនីតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះ ជនរងការជួញដូរមនុស្សក៏**មិនគួរត្រូវបានឃុំខ្លួន**លើសពីការចាំបាច់ ដើម្បីទទួលបានព័ត៌មានលម្អិតពីពួកគេ និងទទួលបានព័ត៌មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់អំពីស្ថានភាពពួកគេជាជនរងគ្រោះពីការជួញដូរមនុស្សឡើយ។ ការឃុំខ្លួន "ការពារ" ជនរងគ្រោះពីការជួញដូរមនុស្សទោះបីចាក់សោរឃុំនៅប៉ុស្តិ៍នគរបាល អគារអន្តោប្រវេសន៍ ឬមណ្ឌលសុខុមាលភាព ក៏ដោយ ក៏ចាំបាច់ត្រូវពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់ទល់នឹងច្បាប់របស់ប្រទេសនីមួយៗ ព្រមទាំងកាតព្វកិច្ចជាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស និងរដ្ឋបាលតុលាការ រួមទាំងសិទ្ធិរបស់ជនគ្រប់រូបក្នុងការវិលត្រឡប់ទៅកាន់ប្រទេសដើមរបស់ខ្លួនដែរ។

នៅក្នុងករណីជនរងគ្រោះពេញវ័យ ការដាក់ក្នុងទីជម្រកការពារយូរពេក ក្នុងគោលបំណងរក្សាសុវត្ថិភាពភ្លាមៗ និងបង្កើតឋានៈជាជនរងគ្រោះ មិនមែនជាប្រយោជន៍ដល់ជនរងគ្រោះទេ។ ការឃុំខ្លួនយូរ ឬគ្មានពេលកំណត់ហាក់ដូចជារឹតតែធ្វើឲ្យពួកគេមានភាពឯកោ និងទន់ខ្សោយ ហេតុនេះវាធ្វើឲ្យពួកទទួលរងព្យសនកម្មបន្ថែមទៀត និងកាត់បន្ថយនូវទស្សនៈបង្ហាញពីកិច្ចសហការរបស់ពួកគេ។ ជនរងគ្រោះពីការជួញដូរមនុស្សក៏មិនគួរត្រូវបានចោទប្រកាន់ ឬទទួលទោសទណ្ឌចំពោះបទល្មើសជាឋានៈ (បទល្មើសដែលពាក់ព័ន្ធនឹងស្ថានភាពជួញដូរមនុស្សរបស់ពួកគេ ដូចជា ការចូលដោយខុសច្បាប់ ឬការងារខុសច្បាប់)។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* អះអាងនូវការការពារទាំងនេះសិទ្ធិទទួលបានឯកជនភាពដូចខាងក្រោម៖

*ភាគីនីមួយៗត្រូវពិចារណាមិនចោទប្រកាន់ឲ្យជនរងគ្រោះនៃការជួញដូរមនុស្ស ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ឬរដ្ឋបាលចំពោះអំពើខុសច្បាប់ដែលពួកគេបានប្រព្រឹត្ត ប្រសិនបើអំពើទាំងនោះគ្មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការជួញដូរមនុស្សទេ ដោយស្ថិតក្រោមច្បាប់ វិធាន បទបញ្ជា និងគោលនយោបាយ និងនៅក្នុងសំណុំរឿងសមស្រប។*

**មាត្រា ១៤(៧)**

*ភាគីនីមួយៗមិនត្រូវឃុំឃាំង ឬដាក់ក្នុងពន្ធនាគារដោយមិនសមហេតុផលចំពោះបុគ្គលដែលអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលសម្រាប់ការជួញដូរមនុស្ស។*

**មាត្រា ១៤(៩)**

# សិទ្ធទទួលបានការកំណត់ស្ថានភាពស្របច្បាប់

ជនរងគ្រោះពីការជួញដូរមនុស្ស ដែលនៅក្នុងប្រទេសមួយដោយខុសច្បាប់ ប្រឈមនឹងគ្រោះថ្នាក់ និងភាពងាយរងគ្រោះពិសេស ដោយសារលទ្ធផលនៃស្ថានភាពខុសច្បាប់របស់ពួកគេ។ ឧទាហរណ៍ ពួកគេប្រហែលជា មិនអាចទទួលបានធនធានមូលដ្ឋាននៃការចិញ្ចឹមជីវិត និងការគាំទ្រសំខាន់ៗបាន ដូចជា ផ្ទះសម្បែង និងឱកាសការងារ។ ពួកគេអាចងាយរងគ្រោះទៅនឹងការកេងប្រវ័ញ្ចបន្ថែមទៀត ព្រមទាំងការបំភិតបំភ័យ និងការសងសឹក។ ពួកគេប្រឈមនឹងការរារាំងមិនឲ្យចូលរួមពេញលេញ ក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ប្រឆាំងនឹងជនជួញដូរមនុស្ស លើពួកគេឱ្យមានប្រសិទ្ធភាពបានទេ (សូមមើល ជំពូកទី ៦ ខាងក្រោម)។ បើគ្មានការកំណត់ស្ថានភាពរបស់ពួកគេទេ ជនរងគ្រោះក៏ប្រឈមនឹងហានិភ័យនៃការឃុំខ្លួននៅក្នុងអាគារអន្តោប្រវេសន៍ ឬទីជម្រកបិទជិត ឬ ទទួលទោសទណ្ឌបន្ថែមទៀតពីបទល្មើសដែលពាក់ព័ន្ធនឹងស្ថានភាពរបស់ពួកគេ ដោយសាររងការជួញដូរមនុស្ស។ ក្រៅពីនេះ ពួកគេទទួលខុសត្រូវចំពោះការនិរទេសនៅពេលណាក៏បាន។ ការកំណត់ស្ថានភាពទៅតាមច្បាប់របស់ជនរងគ្រោះគឺជាប្រយោជន៍របស់អាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌ។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* អះអាងនូវសិទ្ធិទទួលបានការកំណត់ស្ថានភាព ដូចខាងក្រោម៖

> *ភាគីនីមួយៗ ត្រូវពិចារណាអនុម័តវិធានការផ្លូវច្បាប់ ឬវិធានការសមស្របផ្សេងទៀត ដែលអនុញ្ញាតឲ្យជនរងគ្រោះពីការជួញដូរមនុស្សស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ នៅក្នុងករណីសមស្រប។ ភាគីនីមួយៗ ត្រូវផ្តល់ការពិចារណាសមស្របដល់កត្តាសិទ្ធិមនុស្ស និងមានការអនុគ្រោះលើករណីនេះដើម្បីសម្រេចតាមគោលបំណងនេះ។*
>
> **មាត្រា ១៤(៤)**

# ស្ថានភាពពិសេសរបស់កុមាររងគ្រោះពីការជួញដូរមនុស្ស៖ ការការពារ និងការគាំទ្រ

ទោះបីកុមាររងគ្រោះពីការជួញដូរមនុស្សត្រូវបានបញ្ចូលទៅក្នុងវិធាន និងគោលការណ៍នានាដែលបានលើកឡើងខាងលើក្តី តែច្បាប់អន្តរជាតិបានទទួលស្គាល់យ៉ាងច្បាស់នូវភាពងាយរងគ្រោះរបស់កុមារ ហេតុនេះបានផ្តល់សិទ្ធិពិសេសមួយចំនួនដល់ពួកគេ។ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ានថ្លែងថា៖

សេចក្តីត្រូវការចាំបាច់របស់កុមាររងគ្រោះពីការជួញដូរមនុស្ស ព្រមទាំងសិទ្ធិពិសេសរបស់ពួកគេក្នុងការទទួលបានការការពារ ការថែទាំ និងការគាំទ្រ គួរត្រូវបានទទួលស្គាល់ និងគោរពដោយភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌទាំងអស់[១២១]។

សេចក្តីថ្លែងការណ៍ច្បាស់លាស់នេះផ្តល់ជាមូលដ្ឋាន និងជាឯកសារយោងមួយយ៉ាងសំខាន់ស្រាប់មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌអាស៊ានទាំងអស់ នៅក្នុងការដោះស្រាយជាមួយកុមាររងគ្រោះពីការជួញដូរមនុស្ស។

[១២១] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២ ផ្នែក ៣។

ចំណុចសំខាន់បំផុតគឺ ក្នុងការដោះស្រាយជាមួយកុមាររងគ្រោះពីការជួញដូរមនុស្ស **ឧត្តមប្រយោជន៍របស់កុមារ** គឺជាចំណុចកំពូល។ គោលការណ៍ដ៏ចម្បងនេះគួរត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ និងបញ្ចូលជាផ្លូវការទៅក្នុងនីតិវិធី និងគោលការណ៍ណែនាំរបស់រដ្ឋសម្រាប់ដោះស្រាយជាមួយកុមាររងគ្រោះ[១២២]។ ជាពាក្យពេចន៍ធម្មតា រដ្ឋនឹងត្រូវបង្កើតប្រព័ន្ធ និងនីតិវិធីដែលធានាគោរពដល់ឧត្តមប្រយោជន៍របស់កុមាររងគ្រោះពីការជួញដូរមនុស្ស ជាទស្សនាទានមួយដែលនឹងពន្យល់លម្អិតបន្ថែមទៀតនៅក្នុងប្រអប់អត្ថបទខាងក្រោម។

### *ប្រអប់អត្ថបទ ២០៖ ការការពារ និងការគាំទ្រដល់កុមាររងការជួញដូរមនុស្ស*

គោលការណ៍ និងវិធានសំខាន់ទាក់ទងនឹងការការពារ និងការគាំទ្រដល់កុមាររងការជួញដូរមនុស្សរួមមាន៖

- កុមាររងការជួញដូរមនុស្ស **មិនគួរត្រូវបានចាត់ទុកថា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ** នៅក្នុងវិធីណាក៏ដោយ ហើយមិនគួរដាក់ឲ្យទទួលខុសត្រូវចំពោះការចោទប្រកាន់ចំពោះបទល្មើសនានាដែលពាក់ព័ន្ធ នឹងស្ថានភាពនេះឡើយ។
- កុមាររងការជួញដូរមនុស្ស **មិនគួរត្រូវបានដាក់នៅក្នុង**អាគារ**ឃុំឃាំងផ្នែកអនុវត្តន៍ច្បាប់** ដូចជាបន្ទប់ឃុំនៅប៉ុស្តិ៍នគរបាល ពន្ធនាគារ ឬមជ្ឈមណ្ឌលឃុំឃាំងពិសេសសម្រាប់កុមារឡើយ។ រាល់ការសម្រេចនានាទាក់ទងនឹងការឃុំឃាំងកុមារគួរតែត្រូវធ្វើឡើង**ទៅតាមករណីជាក់ស្តែងនីមួយៗ និងជាឧត្តមប្រយោជន៍របស់ពួកគេ**។ នៅគ្រប់ករណីទាំងអស់នៃ ការឃុំឃាំងកុមាររងគ្រោះពីការជួញដូរមនុស្សត្រូវធ្វើឡើងក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន ហើយត្រូវស្ថិតក្រោមការគ្រប់គ្រង និងការពិនិត្យដោយឯករាជ្យ។
- គួរផ្តល់ការថែទាំ និងការគាំទ្រដល់កុមាររងការជួញដូរមនុស្ស ក្នុងនាមជាសិទ្ធិមួយ។ **មិនត្រូវមានលក្ខខណ្ឌ**កំណត់ឲ្យពួកគេសហការជាមួយភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌទេ។
- កុមារ**មិនគួររងការបង្ខិតបង្ខំ**ឲ្យទទួលយកការថែទាំ និងការការពារទេ រួមទាំង ជំនួយ និងការពិនិត្យផ្នែកសុខាភិបាល លុះត្រាដែលមានការបង្ហាញទៅតាមករណីជាក់ស្តែងនីមួយៗថា នេះជាឧត្តមប្រយោជន៍របស់ពួកគេ។
- កុមារគ្រប់រូបដែលស្ថិតក្រោមយុត្តាធិការ ឬការគ្រប់គ្រងរបស់រដ្ឋមួយ មានសិទ្ធិទទួលបាន**ការថែទាំ និងការការពារស្មើៗគ្នា**។ ចំណុចនេះមានន័យថា កុមាររងគ្រោះពីការជួញដូរមនុស្សដែលមិនមែនជាជនជាតិរបស់រដ្ឋនោះទទួលបានសិទ្ធិដូចកុមារនៃជនជាតិនោះ ឬកុមារដែលស្នាក់នៅក្នុងរដ្ឋនោះដែរ។
- **ទស្សនៈរបស់កុមាររងគ្រោះ**ពីការជួញដូរមនុស្សគួរទទួលការគោរព និងផ្តល់តម្លៃ ដែលសមស្របទៅនឹងអាយុ និងសមត្ថភាពបញ្ញាស្មារតីរបស់ពួកគេ ហើយគួរ**ទទួលបានព័ត៌មាន**អំពីស្ថានភាព និងអ្វីដែលពួកគេគួរទទួលបាន។
- **ពុំគួរមានការជ្រៀតជ្រែកតាមអំពើចិត្តទៅលើឯកជនភាពរបស់កុមារទេ**។ រដ្ឋគួរធានាថា អត្តសញ្ញាណ ឬព័ត៌មានលម្អិតដែលអាចឲ្យគេកំណត់អត្តសញ្ញាណរបស់កុមាររងគ្រោះពីការជួញដូរមនុស្ស មិនត្រូវបញ្ចេញជាសាធារណៈទេ។

---

[១២២] *អនុសញ្ញាស្តីពីសិទ្ធិកុមារ* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ឯកសារ 1577 UNTS 3 ចូលជាធរមាននៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩០ មាត្រា ៣ (២) [តទៅនេះហៅថា *អនុសញ្ញាស្តីពីសិទ្ធិកុមារ*]។ *គោលការណ៍ និងគោលការណ៍ណែនាំ អ.ស.ប ប្រឆាំងការជួញដូរ* គោលការណ៍ ១០។

- រដ្ឋគួរផ្តល់ការធ្វើជាតំណាងឲ្យកុមាររងគ្រោះ ពីការជួញដូរមនុស្ស ដែលត្រូវបានកំណត់អត្តសញ្ញាណ (ឬត្រូវបានសន្មត) នូវ**អាណាព្យាបាលស្របច្បាប់**មួយ ឧទាហរណ៍ ជាអង្គការ ឬអាជ្ញាធរ ដើម្បីធានាថា ឧត្តមប្រយោជន៍របស់កុមារនៅតែជាចំណុចកំពូល នៅពេលពិចារណាទៅលើសកម្មភាព ឬការសម្រេចចិត្តទាំងអស់ ដើម្បីធានាផ្តល់ជំនួយ ការគាំទ្រ និងការការពារទាំងអស់ដែលចាំបាច់ មានវត្តមានក្នុងពេលចូលរួមជាមួយអាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីសម្របសម្រួលក្នុងការបញ្ជូនទៅទទួលសេវាសមស្រប និង ដើម្បីជួយក្នុងការកំណត់ និងអនុវត្តនូវដំណោះស្រាយយូរអង្វែង។
- គួរមានវិធានការជាក់ស្តែង ដើម្បីជួយកុមាររងគ្រោះពីការជួញដូរមនុស្សដើម្បី**ចូលរួមទៅក្នុងដំណើរការតុលាការយ៉ាងមានសុវត្ថិភាព និងប្រកបដោយអត្ថន័យខ្លឹមសារ**។ ចំណុចទាំងនេះអាចរួមមានការកំណត់ឋានៈតាមផ្លូវច្បាប់ ការផ្តល់ព័ត៌មាន ជំនួយតាមផ្លូវច្បាប់ និងការធ្វើជាតំណាងតាមផ្លូវច្បាប់ និងចាត់វិធានការដើម្បីកាត់បន្ថយការប៉ះទង្គិចនានាដែលអាចមានដោយសារការចូលរួមនេះ ឧទាហរណ៍ ដោយប្រើជម្រើសផ្សេងទៀតក្រៅពីការផ្តល់សក្ខីកម្មដោយផ្ទាល់។

**ប្រភព៖** អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអឺរ៉ុបប្រឆាំងការជួញដូរមនុស្ស អនុសាសន៍ស្តីពីគោលការណ៍ និងសេចក្តីណែនាំ និងគោលការណ៍ណែនាំរបស់ *UNICEF* ផែនការសកម្មភាពអាស៊ាន (ឆ្នាំ២០១៥) តារាងដែលសម្រួលពី OHCHR សិទ្ធិមនុស្ស និងការជួញដូរមនុស្ស ឯកសារអង្គហេតុ #36 (ឆ្នាំ២០១៤) និង ឯកសារផលិតឡើងវិញចេញពីទស្សនាវដ្តី *ACWC Regional Review*

# ៥.៤ វឌ្ឍនភាពរបស់អាស៊ានទាក់ទងនឹងការការពារ និងការគាំទ្រជនរងគ្រោះ

ផ្នែកនេះសង្ខេបអំពីការប្រែប្រួល នៅក្នុងក្របខ័ណ្ឌគតិយុត្តិទាក់ទងនឹងការការពារ និងការគាំទ្ររងគ្រោះ នៅក្នុងរដ្ឋសមាជិកអាស៊ាន។ សំណួរអំពីរបៀបដំណើរការជួយជនរងគ្រោះ*នៅក្នុង**ការអនុវត្តន៍ជាក់ស្តែង*** មានការលំបាកក្នុងការវាយតម្លៃ និងវាស់ស្ទង់។ ដូចបានលើកឡើងនៅក្នុង*ទស្សនាវដ្តី* ACWC Regional Review ព័ត៌មាន និងទិន្នន័យមានចំនួនតិចតួច ហើយជានិច្ចកាលមិនអាចបញ្ជាក់បាន។ ព័ត៌មានពីទស្សនាវដ្តី ACWC Regional Review ត្រូវបានយកមកប្រើ ដើម្បីផ្តល់នូវសេចក្តីសង្ខេបនូវទិន្នាការនៃការអនុវត្តន៍ជាក់ស្តែង ដែលបានយោងនៅក្នុងទស្សនាវដ្តីនោះ សម្រាប់ការវាយតម្លៃកាន់តែទូលំទូលាយទៅលើស្ថានភាពបច្ចុប្បន្ន។

## វឌ្ឍនភាពក្នុងតំបន់ទាក់ទិននឹងការការពារ និងការគាំទ្រ

គតិយុត្តិ និងគោលនយោបាយនៅកម្រិតតំបន់ ការអភិវឌ្ឍន៍ដែលសំខាន់គឺការអនុម័ត*អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស* និង*ផែនការសកម្មភាពអាស៊ាន*។ ការអះអាងសំខាន់ៗផ្សេងទៀតអំពីសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការទទួលបានការការពារ និងការគាំទ្រភ្លាមៗ មាននៅក្នុង*ផែនការសកម្មភាពអាស៊ាន* (ឆ្នាំ២០១៥) ដែលត្រូវបានសង្ខេបនៅក្នុងប្រអប់អត្ថបទខាងក្រោម។

*ប្រអប់អត្ថបទ ២១៖ ការការពារជនរងគ្រោះក្រោមផែនការសកម្មភាពអាស៊ាន*

**ផ្នែក IV ខ៖ ការការពារជនរងគ្រោះ**

យើង រដ្ឋសមាជិកអាស៊ានសម្រេចចិត្ត...

ក. អះអាងសាជាថ្មីថា ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់ និងវិធានការដែលមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្ស ជាការបំពេញបន្ថែម និងពង្រឹងទៅវិញទៅមក។

ខ. ស្របទៅនឹងមាត្រា ១៤ កថាខណ្ឌ ១០ នៃ *ACTIP* បន្តអភិវឌ្ឍការថែទាំ ការការពារ និងការគាំទ្រសមស្រប សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស។

គ. ផ្តល់សេវាជំនាញដល់ជនរងគ្រោះពីការជួញដូរមនុស្សដែលបានកំណត់អត្តសញ្ញាណ ស្របទៅនឹង *ACTIP* និងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធផ្សេងទៀត រួមមាន ការទទួលបានសេវាថែទាំសុខភាពនានា ដូចជា ក្នុងគោលបំណងជាសេវាបង្ការ ព្យាបាល ថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគ *HIV* និងជំងឺ *AIDS* ជំងឺឆ្លងតាមឈាម និងជំងឺឆ្លងដទៃទៀតដល់ជនរងគ្រោះពីការជួញដូរមនុស្សដែលបានរងការកេងប្រវ័ញ្ចផ្លូវភេទ ដោយពិចារណាទៅដល់ការណ៍ដែលថា ការជួញដូរមនុស្សក្នុងការគោលបំណងកេងប្រវ័ញ្ចផ្លូវភេទប្រឈមនឹងហានិភ័យដល់សុខភាពធ្ងន់ធ្ងរ ភ្លាមៗ និងរយៈពេលយូរ រួមទាំង សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

ឃ. ដោយអនុលោមទៅតាមច្បាប់ វិធាន បទបញ្ញា និងគោលនយោបាយជាតិ និងនៅក្នុងករណីសមស្របពិចារណាមិនទាមទារឲ្យជនរងគ្រោះពីការជួញដូរមនុស្សទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬរដ្ឋបាល ចំពោះអំពើខុសច្បាប់នានាដែលពួកគេបានប្រព្រឹត្តទេ ប្រសិនបើអំពើទាំងនោះមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងអំពើជួញដូរមនុស្ស។

ង. ធានាថា មានវិធីសាស្ត្រសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ដោយយកចិត្តទុកដាក់ជាពិសេសទៅលើកុមាររងគ្រោះ ឲ្យទទួលបានការការពារ ជំនួយ និងសេវានានាដើម្បីបានជាសះស្បើយផ្លូវកាយ ផ្លូវចិត្ត សង្គម និងការស្តារនីតិសម្បទាដោយមានការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធផ្សេងទៀត និងវិស័យសង្គមស៊ីវិល ដូចជា ការបង្កើតបណ្តាញអ្នកផ្តល់សេវា ដើម្បីផ្តល់នូវការថែទាំសុខភាព ការប្រឹក្សាយោបល់ កាលានុវត្តភាពទទួលការអប់រំ និងការបណ្តុះបណ្តាល ជំនួយផ្នែកច្បាប់ និងសេវាបកប្រែភាសា។

ច. បង្កើត និងប្រើប្រាស់នីតិវិធីសមស្របសម្រាប់ការជួយសង្គ្រោះ ការការពារ ការវិលទៅរកសភាពដើមវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មរបស់ជនរងគ្រោះទៅក្នុងគ្រួសារ និងសហគមន៍ខ្លួនវិញ អនុលោមទៅតាមច្បាប់ជាតិ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះកុមាររងគ្រោះ។

ឆ. ធានាថា ប្រព័ន្ធច្បាប់ ឬរដ្ឋបាលជាតិមានបញ្ចូលវិធានការនានាដើម្បីផ្តល់ព័ត៌មានដល់ជនរងគ្រោះពីការជួញដូរមនុស្ស ជាភាសាដែលពួកគេយល់បាន ទាក់ទងនឹងសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន និងកិច្ចដំណើរការតាមផ្លូវតុលាការ ឬរដ្ឋបាល និងសម្របសម្រួលឲ្យគេទទួលបានជំនួយ ដើម្បីឲ្យពួកគេអាចបញ្ចេញទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួន និងយកទៅពិចារណានៅក្នុងដំណាក់កាលសមស្របនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនោះប្រឆាំងនឹងជនជួញដូរមនុស្ស ជាលក្ខណៈដែលមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិការពារក្តី ស្របទៅនឹង *ACTIP*។

ជ. ទទួលស្គាល់នូវតួនាទីយ៉ាងសំខាន់របស់អង្គការសង្គមស៊ីវិលនៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ ក្នុងការផ្តល់ជំនួយ និងផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះពីការជួញដូរមនុស្ស ដែលជួយឲ្យពួកគេអាចស្វែងរកដំណោះស្រាយ និងសម្របសម្រួលការថែទាំ និងការផ្តល់សេវាសមស្របដល់ជនរងគ្រោះ រួមទាំងកិច្ចសហការ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធិជាមួយមន្ត្រីអនុវត្តន៍ច្បាប់។

ACWC ក៏បានបង្កើតគោលការណ៍ណែនាំមួយចំនួនផងដែរជុំវិញការការពារ និងការគាំទ្រជនរងគ្រោះដែលអះអាងនូវបទដ្ឋានសំខាន់ដែលមានរៀបរាប់នៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* និង *ផែនការសកម្មភាព* ដែលត្រូវបានសង្ខេបដូចខាងក្រោម។

*ប្រអប់អត្ថបទ ២២៖ ការការពារ និងការគាំទ្រជនរងគ្រោះក្រោមគោលការណ៍ណែនាំរបស់ ACWC*

- ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ គួរត្រូវបានបញ្ជូនទៅអង្គភាពនគរបាលពាក់ព័ន្ធដែលទទួលការបណ្តុះបណ្តាលឲ្យស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្ស ដែលបន្ទាប់មកគួរសម្របសម្រួល**ការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ/អន្តរាគមន៍ចាំបាច់**។
- ប្រសិនបើជនរងគ្រោះទទួលរងរបួស អ្នកផ្តល់សេវាដែលមានការទទួលខុសត្រូវគួរចាត់វិធានការដើម្បីផ្តល់ឲ្យជននោះនូវ**ការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ**ភ្លាមៗ។
- នៅក្នុងករណីដែលជនរងគ្រោះមិនអាចប្រាស្រ័យទាក់ទងបាន គួរផ្តល់នូវ**អ្នកបកប្រែភាសា**ដែលត្រូវបានពិនិត្យ និងផ្តល់ការបណ្តុះបណ្តាលដោយអាជ្ញាធរពាក់ព័ន្ធ។
- ជនរងគ្រោះគួរត្រូវបាននាំទៅទីជម្រក/ផ្ទះ/មជ្ឈមណ្ឌលសាកសួរព័ត៌មាន និងផ្តល់សេវាពាក់ព័ន្ធនានាដែលអាចរួមមានសេចក្តីត្រូវចាំបាច់ជាមូលដ្ឋាន និងការពិគ្រោះយោបល់។
- **មិន**គួរមាន**ការរើសអើង**នៅក្នុងការបញ្ជូនជនរងគ្រោះទៅផ្នែកផ្តល់សេវា ឬជំនួយឡើយ។
- គួរមាន**ជំនួយផ្នែកច្បាប់**ដើម្បីជួយជនរងគ្រោះ។

គោលការណ៍ណែនាំ ACWC ផ្នែក ៣.៣ និង ៣.៤

# វឌ្ឍនភាពទាក់ទិននឹងច្បាប់ និងគោលនយោបាយស្តីពីការការពារ និងការគាំទ្រជនរងគ្រោះ

ដូចបានពន្យល់លម្អិតនៅក្នុងជំពូកទី ១ រួចហើយ ក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយនៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន (បើមិនទាំងអស់) ផ្តល់ឲ្យជនរងគ្រោះពីការជួញដូរមនុស្សនូវសិទ្ធិទទួលបានការការពារ និងការគាំទ្រ។ នៅក្នុងករណីមួយចំនួន បទប្បញ្ញត្តិទាំងនេះមានលក្ខណៈលម្អិតណាស់។ ឧទាហរណ៍ នៅ**ប្រទេសហ្វីលីពីន** *ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៣)* បានផ្តល់នូវបញ្ជីសេវាយ៉ាងទូលំទូលាយដែលត្រូវមានសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស រួមមាន៖ ទីជម្រកបន្ទាន់ និងការស្នាក់នៅ ការប្រឹក្សាយោបល់ សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ សេវាផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត ជីវភាពរស់នៅ និងការបណ្តុះបណ្តាលជំនាញ និង ការអប់រំសម្រាប់កុមារ[១២៣]។

---

[១២៣] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៣ (ប្រទេសហ្វីលីពីន) ផ្នែក ២៣។

បទប្បញ្ញត្តិទូលំទូលាយស្រដៀងគ្នានេះក៏មានចែងនៅក្នុងច្បាប់របស់**ប្រទេសថៃ** និង**ឥណ្ឌូនេស៊ី**ដែរ។ ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ប្រទេសឥណ្ឌូនេស៊ី** មានបញ្ញត្តិបន្ថែមសំខាន់មួយដែលតម្រូវឲ្យរដ្ឋនៅក្នុងប្រទេសជនរងគ្រោះឥណ្ឌូនេស៊ីស្ថិតនៅត្រូវផ្តល់ការការពារ និងការគាំទ្រ។

ក្រោម*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* របស់**ប្រទេសថៃ** នគរបាលអាចផ្តល់ឲ្យបុគ្គល ដែលអាចជាជនរងគ្រោះពីការជួញដូរមនុស្ស នូវការការពាររបស់នគរបាលរយៈពេល ២៤ ម៉ោង ដែលអាចពន្យាររហូតដល់ ៧ ថ្ងៃដោយតុលាការ ប្រសិនបើត្រូវការពេលវេលាបន្ថែមទៀត ដើម្បីបញ្ចប់ដំណើរការកំណត់អត្តសញ្ញាណ[១២៤]។ នេះជាការបន្ថែមទៅលើវិធានការនៃការការពារ និងការគាំទ្រដែលមានចែងនៅក្នុងច្បាប់នេះ[១២៥]។ ប្រទេសថៃបានបង្កើតលិខិតូបករណ៍ស្តីពីគោលនយោបាយដើម្បីគាំទ្រដល់ការកែលម្អការការពារ និងការថែទាំជនរងគ្រោះពីការជួញដូរមនុស្ស។ ឧទាហរណ៍ នៅឆ្នាំ២០១៧ ប្រទេសថៃបានកែប្រែគោលនយោបាយស្តីពីការកំណត់ស្ថានភាពតាមផ្លូវច្បាប់ដល់ជនរងគ្រោះបរទេស ដោយពង្រីកពេលវេលាជាអតិបរមាដល់ជនរងគ្រោះ និងសាក្សីរហូតដល់ ២ ឆ្នាំ និងផ្តល់ដល់ពួកគេនូវសិទ្ធិធ្វើការងារនៅគ្រប់វិស័យទាំងអស់ (ពីមុន ការកំណត់នេះកម្រិតត្រឹមតែការងារនៅក្នុងវិស័យដែលធ្វើការដោយកម្លាំងធុនធ្ងរ និងការងារនៅផ្ទះតែប៉ុណ្ណោះ)។

ច្បាប់នៅ**ប្រទេសមីយ៉ាន់ម៉ា** និង**វៀតណាម** ផ្តល់ជំនួយ និងការគាំទ្រនៅមានកម្រិត។ នៅ**ប្រទេសមីយ៉ាន់ម៉ា** "ការរក្សាសេចក្តីថ្លៃថ្នូរ សន្តិសុខផ្លូវកាយ និងផ្លូវចិត្ត" ត្រូវបានចែងនៅក្នុងច្បាប់ តែពាក់ព័ន្ធចំពោះស្ត្រី កុមារ និងជនរងគ្រោះពីការជួញដូរមនុស្សជាយុវវ័យប៉ុណ្ណោះ (មាត្រា ១២)[១២៦]។ ការការពារផ្សេងទៀតនៅក្នុងច្បាប់ រួមមានជំនួយផ្នែកសុខាភិបាល ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពារឯកជនភាព និងសេរីភាពចៀសផុតពីការបញ្ចេញព័ត៌មានត្រូវបានកំហិតស្រដៀងគ្នាតែចំពោះស្ត្រី កុមារ និងជនរងគ្រោះជាយុវវ័យប៉ុណ្ណោះ។ នៅ**ប្រទេសឡាវ** *ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០១៥)* បានផ្តល់វិធានការគាំទ្រ និងជំនួយជាច្រើនសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ដោយផ្តល់ជាការបំពេញបន្ថែមដល់សិទ្ធិទទួលបានជំនួយដែលមានចំពោះស្ត្រី និងកុមាររងគ្រោះពីការជួញដូរមនុស្សនៅក្រោម*ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារស្ត្រី (ឆ្នាំ២០០៤)*។

*ច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស (ឆ្នាំ២០១៤)* របស់**ប្រទេសសិង្ហបុរី** បានបំពេញបន្ថែមទៅលើវិធានការការពារដែលមានស្រាប់ ដែលត្រូវបានផ្តល់ពីផ្នែករដ្ឋបាលដូចជា ជម្រកស្នាក់នៅ អាហារ សេវាប្រឹក្សាយោបល់ ការថែទាំសុខភាព និងការងារបណ្តោះអាសន្ន។ ឧទាហរណ៍ ច្បាប់នេះផ្តល់អំណាចដល់នាយកផ្នែកសុខុមាលភាពសង្គម (ឬអ្នកដែលបានទទួលការអនុញ្ញាតពីគាត់) ដើម្បីផ្តល់ដល់ជនរងគ្រោះពីការជួញដូរមនុស្សនូវជំនួយនានាដែលគាត់យល់ឃើញថាមានតម្រូវការជាក់ស្តែង និងចាំបាច់។ ជនរងគ្រោះនីមួយៗត្រូវបានវាយតម្លៃឲ្យបានគ្រប់ជ្រុងជ្រោយទៅលើតម្រូវចាំបាច់របស់ខ្លួន និង ចាត់ និងផ្តល់វិធានការការពារទៅតាមតម្រូវការចាំបាច់នោះ។ ក្រៅពីនេះ ច្បាប់នេះក៏ការពារ

---

[១២៤] រាជរដ្ឋាភិបាលថៃ ២៣។ ច្បាប់ឆ្នាំ២០០៣ កិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅឆ្នាំ២០១៤ ផ្នែក ២.៣។

[១២៥] ជាពិសេសបំផុតនៅក្នុងជំពូកទី ៤ (មាត្រា ៣៣-៤១) ដែលចែងអំពីការការពារ និងការគាំទ្រដល់ជនរងគ្រោះ។

[១២៦] កត់សម្គាល់ថា បញ្ញត្តិមួយចែងថា "ស្ថាប័នមជ្ឈមត្រូវរៀបចំ និងអនុវត្តនូវការការពារសន្តិសុខអាយុជីវិតរបស់ជនរងគ្រោះពីការជួញដូរ និងរៀបចំទៅតាមបំណងប្រាថ្នារបស់ពួកគេក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការតាំងទីលំនៅឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន"។ បទប្បញ្ញត្តិនេះមិនច្បាស់ថាតើវាពាក់ព័ន្ធតែចំពោះស្ត្រី កុមារ និងយុវវ័យរងគ្រោះដែលបានលើកឡើងខាងដើម ឬសំដៅដល់ជនរងគ្រោះពីការជួញដូរទាំងអស់។

ជនងាយរងគ្រោះនានា កំណត់និយមន័យថាកុមារជាមនុស្សអាយុក្រោម ១៨ ឆ្នាំ ស្របទៅនឹងបទដ្ឋានអន្តរជាតិ និងចែងនូវលក្ខខណ្ឌគតិយុត្តិកម្រិតទាបជាងសម្រាប់បទល្មើសជួញដូរមនុស្សដែលប្រព្រឹត្តចំពោះកុមាររងគ្រោះ ដោយទទួលស្គាល់នូវភាពងាយរងគ្រោះរបស់ពួកគេទៅនឹងការកេងប្រវ័ញ្ច។ ក្រៅពីនេះ ការបំពានទៅលើភាពងាយរងគ្រោះរបស់ជនរងគ្រោះ (ដូចជាអសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ពួកគេ) គឺជាស្ថានទម្ងន់ ដែលគាំទ្រដល់ការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។ ក្រោមច្បាប់ PHT Act តុលាការអាចបង្គាប់ឲ្យរៀបចំកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទល្មើសកេងប្រវ័ញ្ចផ្លូវភេទជាអសាធារណៈ ដើម្បីការពារអត្តសញ្ញាណជនរងគ្រោះ និងជំរុញឲ្យពួកគេផ្តល់សក្ខីកម្មដោយសម្ងាត់ផង។ កិច្ចដំណើរការនីតិវិធីអសាធារណៈគឺជាកាតព្វកិច្ចនៅពេលជនរងគ្រោះជាកុមារ។ ក្រៅពីនេះ នឹងមានការបង្គាប់មិនឲ្យផ្សព្វផ្សាយជាសាធារណៈចំពោះសំណុំរឿងកេងប្រវ័ញ្ចផ្លូវភេទទាំងអស់។

ក្រោម*ច្បាប់ស្តីពីការទប់ស្កាត់ និងការបង្ក្រាបការជួញដូរមនុស្ស (ឆ្នាំ២០១១)* របស់**ប្រទេសវៀតណាម** ជនរងគ្រោះពីការជួញដូរមនុស្ស ត្រូវទទួលបានការគាំទ្រនូវតម្រូវការចាំបាច់ជាមូលដ្ឋាន និងការចំណាយការធ្វើដំណើរ ការថែទាំសុខភាព បញ្ហាផ្លូវច្បាប់ និងអង្គច្បាប់។ ជនរងគ្រោះជាជនជាតិវៀតណាម ឬអ្នកមានទីលំនៅអចិន្ត្រៃយ៍នៅវៀតណាម ទទួលបានសិទ្ធិបន្ថែមទៀតក្នុងការទទួលជំនួយពីការសិក្សាអប់រំ និងការរៀនសូត្រផ្នែកពាណិជ្ជកម្ម និងការគាំទ្របឋមក្នុងការទទួលបានប្រាក់កម្ចីសម្រាប់វិនិយោគ[១២៧]។ ឯកសារស្តីពីគោលនយោបាយផ្តល់សិទ្ធិបន្ថែមទៀតដល់ជនរងគ្រោះ និងគ្រួសារពួកគេ[១២៨]។

ច្បាប់ស្តីពីការជួញដូរមនុស្សរបស់**ប្រទេសម៉ាឡេស៊ី** មានបទប្បញ្ញត្តិលម្អិតស្តីពី “ការថែទាំ និងការការពារ” ដល់ជនរងគ្រោះ រួមមានការបង្កើតកន្លែងជ្រកកោន និង ការពិនិត្យ និងការព្យាបាលផ្នែកវេជ្ជសាស្ត្រ[១២៩]។ ជាការពាក់ព័ន្ធដែលត្រូវកត់សម្គាល់ថា ជនរងគ្រោះដែលស្ថិតក្រោមការថែទាំរបស់រដ្ឋនៅក្នុងជម្រកមានសិទ្ធិទទួលបានវិធានការជំនួយនានាជាច្រើន។ នៅ**ប្រទេសកម្ពុជា** *ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ* មិនបានដោះស្រាយបញ្ហានៃការផ្តល់ជំនួយ និងការការពារដល់ជនរងគ្រោះទេ។ ក៏ប៉ុន្តែ លិខិតូបករណ៍លម្អិតស្តីពីគោលនយោបាយ *(គោលនយោបាយស្តីពីការការពារសិទ្ធិជនរងគ្រោះពីការជួញដូរមនុស្ស)* ជាអ្នកបំពេញចន្លោះប្រហោងក្នុងការងារនោះដោយលើកឡើងនូវបទដ្ឋានអប្បបរមានៅក្នុងផ្នែកនេះ (សូមមើលប្រអប់អត្ថបទខាងក្រោម)[១៣០]។

---

[១២៧] គោលការណ៍ណែនាំស្តីពីដំណើរការ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ និងការទទួលយកស្ត្រី និងកុមាររងការជួញដូរមនុស្សពីបរទេស (សារាចរអន្តរក្រសួងលេខ *03/2008/TTLT-BCA-BQP-BNG-BLĐTBXH)* (០៨/០៥/២០០៨)) របស់វៀតណាម បានបង្កើតនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណ និងទទួលយកស្ត្រី និងកុមាររងការជួញដូរមនុស្សពីបរទេសដែលជាជនជាតិវៀតណាម។ ក្រោមគោលការណ៍ណែនាំទាំងនេះ ស្ត្រីដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះ និងបង្ហាញថាជាពលរដ្ឋវៀតណាម បានទទួលការគាំទ្រក្នុងការវិលត្រឡប់មកគេហដ្ឋានវិញ។ កុមាររងគ្រោះ និងស្ត្រីរងគ្រោះដែលត្រូវការការថែទាំផ្នែកសុខាភិបាល និងការប្រឹក្សាអំពីចិត្តសង្គម ត្រូវបានបញ្ជូនទៅនាយកដ្ឋានការងារ ទុព្វលភាព និងសង្គមកិច្ច (DOLISA) នៅខេត្តដែលខ្លួនរស់នៅ។ ពុំមានបទប្បញ្ញត្តិចែងអំពីការផ្តល់ជំនួយ និងការគាំទ្រដល់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងប្រទេស។

[១២៨] គោលការណ៍ណែនាំស្តីពីការរៀបរាប់អំពីមូលដ្ឋានសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរ និងការការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ (ក្រឹត្យលេខ 62/2012/ND-CP) របស់វៀតណាម។

[១២៩] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ [ច្បាប់លេខ ៦៧០] (ម៉ាឡេស៊ី) វគ្គ IV។

[១៣០] គោលការណ៍ណែនាំស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្ស លេខ ៨៥៧ S.V.Y (ឆ្នាំ២០០៩) (កម្ពុជា)។

*បទបញ្ញត្តិស្តីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស* របស់**ប្រទេសប្រ៊ុយណេ** មិនបានចែងអំពីការការពារ និងការផ្តល់ជំនួយដល់ជនរងគ្រោះទេ។ ក៏ប៉ុន្តែច្បាប់ផ្សេងទៀតពិតជាមានចែងផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងការទទួលបានការការពារ និងជំនួយ។ ឧទាហរណ៍ ឯកជនភាពរបស់ជនរងគ្រោះអាចទទួលបានការការពារតាមរយៈបទបញ្ញាដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីតុលាការ។ ក្រៅពីនេះ នៅពេលបទល្មើសក្រោម *បទបញ្ញត្តិស្តីពីការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស*ត្រូវបានផ្តន្ទាទោសរួមជាមួយបទល្មើសផ្សេងទៀតក្រោម *ច្បាប់ស្តីពីការការពារស្ត្រី និងកុមារី* និង *ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង* ដែលបទប្បញ្ញត្តិនៃច្បាប់ទាំងពីរនេះត្រូវបានយកមកប្រើប្រាស់ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះ និងផ្តល់នូវយន្តការផ្តល់ជំនួយ និងការគាំទ្រជាច្រើនដល់ពួកគេ។

## វឌ្ឍនភាពទាក់ទិននឹងច្បាប់ និងគោលនយោបាយស្តីពីការការពារ និងការគាំទ្រដល់កុមាររងគ្រោះ

ដូចដែលនឹងបង្ហាញដូចខាងក្រោម ក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយជុំវិញការជួញដូរមនុស្សនៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើនបានធ្វើការរៀបចំពិសេសឲ្យមានការផ្តល់នូវការការពារ និងការគាំទ្រដល់កុមាររងគ្រោះ។ ក៏ប៉ុន្តែ នៅក្នុងករណីភាគច្រើន ក្របខ័ណ្ឌពាក់ព័ន្ធមិនបានបំពេញទៅតាមបទដ្ឋានដែលត្រូវបានបង្កើតឡើងនៅក្នុង *ផែនការសកម្មភាពអាស៊ាន* ឲ្យបានពេញលេញទេ (ខាងលើ ប្រអប់អត្ថបទ ១២)។

*តារាង ៧៖ វិធានការពិសេសសម្រាប់កុមាររងការជួញដូរមនុស្ស*

| | |
|---|---|
| **ប្រ៊ុយណេ** | **ច្បាប់ស្តីពីការជួញដូរមនុស្សមិនបានចែងអំពីវិធានការពិសេសនៃការការពារ និងការគាំទ្រដល់កុមាររងគ្រោះទេ។ ក៏ប៉ុន្តែ *ច្បាប់ស្តីពីការការពារស្ត្រី និងកុមារី* និង *ច្បាប់ស្តីពីកុមារ និងមនុស្សវ័យក្មេង* ពិតជាមានចែងបទប្បញ្ញត្តិដែលផ្តល់ការការពារ និងទីជម្រក ដែលត្រូវកំណត់ដោយអាជ្ញាធរ។** |
| **កម្ពុជា** | ច្បាប់ស្តីពីការជួញដូរមនុស្សមិនបានដោះស្រាយបញ្ហាទាំងនេះទេ តែក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធ ការអនុញ្ញាតឲ្យមានសិទ្ធិទទួលបានព័ត៌មាន និងរក្សាការសម្ងាត់ ការសន្មតអំពីអាយុ ទីជម្រកសុវត្ថិភាព សន្តិសុខ និងល្អសម្រាប់កុមារ ការកំណត់តាមផ្លូវឲ្យស្នាក់នៅ ជំនួយផ្នែកច្បាប់ គោលការណ៍ឧត្តមប្រយោជន៍។ |
| **ឥណ្ឌូនេស៊ី** | ច្បាប់ស្តីពីការជួញដូរមនុស្សចែងឲ្យមានការគាំទ្រ និងការការពារជាឧត្តមប្រយោជន៍របស់កុមារ ជាពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់។ ការគាំទ្របន្ថែមទៀតសម្រាប់ជំនួយផ្នែកច្បាប់ រក្សាការសម្ងាត់ត្រូវបានផ្តល់នៅក្នុងច្បាប់ស្តីពីការការពារកុមារ។ |
| **ឡាវ** | ច្បាប់ស្តីពីការជួញដូរមនុស្សផ្តល់ការគាំទ្រ និងការការពារសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ជាពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ជំនួយផ្នែកច្បាប់ ការការពារ ទីជម្រកស្នាក់នៅ ព័ត៌មាន និងរក្សាការសម្ងាត់។ ក៏ប៉ុន្តែវាមិនជាក់លាក់ចំពោះកុមារទេ។ ក្រោម *ច្បាប់ស្តីពីការការពារសិទ្ធិ និងប្រយោជន៍របស់កុមារ (ឆ្នាំ២០០៦)* កុមារ |

| | |
|---|---|
| | រងគ្រោះត្រូវបានអនុញ្ញាតឱ្យទទួលការការពារពិសេស និងបុព្វសិទ្ធិនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ រួមទាំងសិទ្ធិទទួលបានការការពារឯកជនភាពរបស់ខ្លួន "វិធានការបន្ទាន់" ចំពោះការការពារ និងជំនួយ ជំនួយផ្នែកអប់រំ សុខាភិបាល និងការបណ្ដុះបណ្ដាលឯកទេសសម្រាប់ការធ្វើសមាហរណកម្ម។ |
| **ម៉ាឡេស៊ី** | ច្បាប់ស្ដីពីការជួញដូរមនុស្សមិនបានចែងឱ្យមានវិធានការពិសេសនៃការការពារ និងការគាំទ្រដល់កុមាររងគ្រោះទេ ទោះបី*ច្បាប់ស្ដីពីភស្ដុតាងរបស់សាក្សីជាកុមារ* មានចែងអំពីការអនុវត្តន៍នូវវិធានការពិសេសទាក់ទងនឹងសាក្សីកុមារនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ក៏ដោយ[១៣១]។ |
| **មីយ៉ាន់ម៉ា** | ច្បាប់ស្ដីពីការជួញដូរមនុស្សចែងឱ្យមានការការការពារសម្រាប់ជនរងគ្រោះដែលងាយរងគ្រោះ រួមទាំងកុមារ និងយុវវ័យផង ទោះបីច្បាប់នេះមិនបានចែងអំពីវិធានការដើម្បីសម្រេចបានការការពារនេះក៏ដោយ។ គោលការណ៍ឧត្ដមប្រយោជន៍ដើម្បីជួយកុមារមានចែងនៅក្នុងច្បាប់ស្ដីពីកុមារ និងសេចក្ដីណែនាំថ្នាក់ជាតិ។ |
| **ហ្វីលីពីន** | កុមារបានទទួលការការពារ និងជំនួយពិសេស រួមទាំងសិទ្ធិទទួលបានព័ត៌មាន និងរក្សាការសម្ងាត់ ការគោរពដល់អត្តសញ្ញាណវប្បធម៌របស់កុមារ និងការមិនរើសអើង និងគោលការណ៍ឧត្ដមប្រយោជន៍ក្រោមក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយ។ |
| **សិង្ហបុរី** | ច្បាប់ស្ដីពីការជួញដូរមនុស្សមិនបានចែងឱ្យមានវិធានការពិសេសនៃជំនួយចំពោះកុមារទេ តែមានចែងពីការការពារដល់ឯកជនភាពរបស់កុមាររងគ្រោះទាក់ទងនឹងកិច្ចដំណើរការនីតិវិធីច្បាប់។ *ច្បាប់ស្ដីពីកុមារ និងមនុស្សវ័យក្មេង* ចែងឱ្យមានលទ្ធភាពដែលកុមាររងការជួញដូរមនុស្សអាចស្នាក់នៅក្នុងកន្លែងមានសុវត្ថិភាព ឬកន្លែងដែលទទួលការថែទាំ និងការការពារបណ្ដោះអាសន្ន ឬ ចាត់ឱ្យទទួលបានថែទាំដោយមនុស្សសមរម្យណាម្នាក់។ |
| **ថៃ** | ទោះបី ច្បាប់ស្ដីពីការជួញដូរមនុស្សមិនបានចែងឱ្យមានវិធានការពិសេសនៃការការពារ និងការគាំទ្រក៏ដោយ តែ *ក្រមនីតិវិធីព្រហ្មទណ្ឌ* និង *ច្បាប់ស្ដីពីការការពារកុមារ*បានចែងឱ្យមានវិធានការពិសេសសម្រាប់ការការពារកុមារ និងការពារឯកជនភាពរបស់ពួកគេនៅក្នុងដំណើរការកំណត់អត្តសញ្ញាណ និងកិច្ចដំណើរការនីតិវិធីច្បាប់ រួមទាំង ទាក់ទងនឹងការផ្ដល់ភស្ដុតាងផងដែរ។ |
| **វៀតណាម** | ក្រៅពីច្បាប់ស្ដីពីការជួញដូរមនុស្ស *ក្រមព្រហ្មទណ្ឌចែងឱ្យមានការការពារ និងបុព្វសិទ្ធិ*សម្រាប់កុមាររងគ្រោះនៅក្នុងដំណើរការស៊ើបអង្កេត និងការជំនុំជម្រះ ទោះបីមិន |

[១៣១] ប្រទេសម៉ាឡេស៊ីរបាយការណ៍ថា ឧត្ដមប្រយោជន៍របស់កុមារគឺជាគោលការណ៍ណែនាំទាក់ទិននឹងការប្រព្រឹត្តិចំពោះកុមាររងគ្រោះពីបទល្មើស រួមទាំងការជួញដូរផងដែរ។

| | |
|---|---|
| | មានបទប្បញ្ញត្តិដែល មិនឱ្យកុមារចូលរួមក្នុង “ការតទល់” ជាមួយជនល្មើសក៏ដោយ។ កត់សម្គាល់ថា ក្របខ័ណ្ឌគតិយុត្តិវៀតណាមចាត់ទុកមនុស្សអាយុក្រោម ១៦ ឆ្នាំថាជាកុមារ។ |

# ៥.៥ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត

ព័ត៌មានទូលំទូលាយស្តីពីការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋសមាជិកអាស៊ាន ទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ការការពារ និងការគាំទ្រ មិនត្រូវបានចងក្រងក្នុងគោលបំណងរៀបរៀងរបាយការណ៍នេះទេ (ការកែសម្រួលបច្ចុប្បន្ន ឬពីមុន)។ ការពិភាក្សាខាងក្រោម ត្រូវបានដកស្រង់យ៉ាងច្រើនពី *ទស្សនាវដ្តី* ACWC Regional Review និងមានបំពេញបន្ថែមដោយព័ត៌មានស៊ីជម្រៅដែលផ្តល់ដោយអ្នកប្រតិបត្តិផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកផ្សេងទៀតដែលមានបទពិសោធន៍ប្រតិបត្តិការនៅក្នុងតំបន់។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ

នៅក្នុងតំបន់អាស៊ាន ក៏ដូចជាផ្នែកផ្សេងទៀតនៅក្នុងពិភពលោកដែរ ទោះបីមានវឌ្ឍនភាពមួយក៏ដោយ តែការកំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវនៅតែជារឿងមួយដ៏កម្រនៅឡើយ។ ជាលទ្ធផលជនរងគ្រោះជាច្រើនត្រូវបានបដិសេធមិនផ្តល់សិទ្ធិក្នុងការទទួលបាននានា នៅក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ភ្នាក់ងារអនុវត្តន៍ច្បាប់បាត់បង់ប្រភពដ៏សំខាន់ ក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីចោទប្រកាន់បទល្មើសធ្ងន់ធ្ងរនេះ និង វិសាលភាពនៃបញ្ហាជួញដូរមនុស្សត្រូវបានទទួលការការផ្តល់តម្លៃឱ្យបានពេញលេញ។ មានមូលហេតុច្រើន និងស្មុគស្មាញដែលបណ្តាលឱ្យការកំណត់អត្តសញ្ញាណមានកម្រិតទាប។

កត្តាមួយចំនួន ដូចជា ការយល់ឃើញចំពោះអំពើពុករលួយ និងការសមគំនិតដែលបណ្តាលឱ្យជនរងគ្រោះមិនទុកចិត្ត និងរារែកក្នុងការបង្ហាញអត្តសញ្ញាណរបស់ខ្លួន នឹងតម្រូវឱ្យមានវិធានការសម្រាប់រយៈពេលវែង ក្នុងគោលបំណងកែលម្អភាពជឿជាក់បាន និងភាពវិជ្ជាជីវៈរបស់ភ្នាក់ងារអនុវត្តន៍ច្បាប់។ ភាពដឹកនាំមិនល្អ និងឥរិយាបថគ្មានប្រយោជន៍ចំពោះក្រុមងាយរងគ្រោះ រួមមាន កម្មករទេសន្តរប្រវេសន៍ និងស្ត្រី ក៏មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការខកខានមិនបានកំណត់អត្តសញ្ញាណដែរ ដែលតម្រូវឱ្យមានការផ្លាស់ប្តូរស៊ីជម្រៅជាប្រព័ន្ធ។ ហើយទម្លាប់អនុវត្តន៍ការដោះស្រាយមិនផ្លូវការចំពោះ “បណ្តឹង” ស្តីពីការជួញដូរមនុស្សដែលក៏ធ្វើឱ្យការកំណត់អត្តសញ្ញាណជនរងគ្រោះមានអត្រាទាបដែរនោះ នឹងតម្រូវឱ្យកំណែទម្រង់នៅក្នុងវប្បធម៌នៃយុត្តិធម៌ព្រហ្មទណ្ឌស្រដៀងគ្នាដែរ។ ក៏ប៉ុន្តែ កត្តាផ្សេងៗទៀត ដូចជាកង្វះការយល់ដឹងក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ជួរមុខ ក៏អាច និងគួរត្រូវបានដោះស្រាយយ៉ាងងាយស្រួលដែរ រួមមាន តាមរយៈការបណ្តុះបណ្តាល និងគំនិតផ្តួចផ្តើមអភិវឌ្ឍសមត្ថភាពផ្សេងទៀត។ នៅក្នុងចំណុចនេះ វាជាការសំខាន់ដែលគួរកត់សម្គាល់ថា តាមការអនុវត្តន៍របស់ខ្លួន អាស៊ានមានកម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់របស់ខ្លួនជាច្រើនដែលបានសាកល្បងយ៉ាងត្រឹមត្រូវ ដែលអាចយកមកប្រើប្រាស់សម្រាប់គោលបំណងនេះបាន។

ក៏មានតម្រូវការចាំបាច់មួយដែរសម្រាប់រដ្ឋសមាជិកអាស៊ានដែលត្រូវដោះស្រាយនូវ**ភាពខ្វះនីតិវិធី និងលក្ខណៈវិនិច្ឆ័យស្ដីពីការកំណត់អត្តសញ្ញាណដូចគ្នា** ដែលនាំឱ្យមានភាពមិនស៊ីចង្វាក់គ្នាពីរបៀបដែលរដ្ឋសមាជិកអាស៊ានកំណត់ថាតើបុគ្គលម្នាក់ជាជនរងគ្រោះពីការជួញដូរ ឬត្រូវបានសន្មតជាជនរងគ្រោះពីការជួញដូរមនុស្សក្នុងគោលបំណងដើម្បីការពារ និងគាំទ្រ។ នៅក្នុងប្រទេសមួយចំនួន ហាក់ដូចជាមិនមានយន្តការផ្លូវការទេ តែចំណុចនេះប្រហែលជាមិនអាចដំណើរការបានល្អឡើយ។ នៅប្រទេសផ្សេងទៀត ការទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះក្នុងគោលបំណងដើម្បីការពារ និងគាំទ្រត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមភ្នាក់ងារផ្សេងៗគ្នាដែលអាចប្រកាន់យកនីតិវិធី និងលក្ខណៈវិនិច្ឆ័យខុសៗគ្នា។

**ការកំណត់អត្តសញ្ញាណជនរងគ្រោះខុស៖** នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ករណីដែលមិនបានសម្រេចទៅតាមលក្ខខណ្ឌវិនិច្ឆ័យចំពោះការជួញដូរមនុស្សក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ (ជាញឹកញយបំផុតគឺទាក់ទងនឹងអំពើពេស្យាចារ និងអាពាហ៍អាពាហ៍ដែលមានការរៀបចំ) ត្រូវបានស៊ើបអង្កេត និងចោទប្រកាន់ជាការជួញដូរមនុស្ស។ យ៉ាងហោចណាស់មានមួយផ្នែក ដែលការកំណត់អត្តសញ្ញាណខុសហាក់ដូចជាឆ្លើយតបទៅនឹងសម្ពាធខាងក្រៅ និងខាងក្នុងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវបានគេមើលឃើញថាត្រូវ “ធ្វើអ្វីម្យ៉ាង” អំពីការជួញដូរមនុស្ស។ ជាទូទៅ បន្ទុកស៊ើបអង្កេត និងចោទប្រកាន់នៅក្នុងសំណុំរឿងទាំងនេះមានកម្រិតទាប ដោយផ្ដល់នូវការជំរុញចិត្តបន្ថែមទៀតដល់មន្ត្រីក្នុងការបន្តស៊ើបអង្កេត ដែលជួយកែលម្អដល់ចំនួននៃភាពជោគជ័យរបស់ខ្លួន។ មានផលវិបាកធ្ងន់ធ្ងរដល់ “ចារី” និង “ជនរងគ្រោះ” គឺថា៖ បុគ្គលដែលត្រូវបានផ្ដន្ទាទោសពី “បទល្មើសជួញដូរមនុស្ស” និងទទួលរងទោសទណ្ឌដែលធ្ងន់ធ្ងរនិងគ្មានមូលដ្ឋានគ្រប់គ្រាន់។ ជារឿយៗ “ជនរងគ្រោះ” ត្រូវបានឃុំខ្លួនផ្ទុយពីឆន្ទៈរបស់ខ្លួន ហើយជួនកាលត្រូវបានបង្ខំឱ្យទទួលយក “ជំនួយ” ដែលពួកគេមិនត្រូវការ ឬមិនចង់បាន។ បញ្ហាពាក់ព័ន្ធមួយទៀតគឺ**ការកំណត់អត្តសញ្ញាណទប់ស្កាត់ជាមុន** ដែលលំនាំនៃការធ្វើដំណើរ ឬសូចនាករផ្សេងៗទៀតរបស់បុគ្គលនានាធ្វើឱ្យមានការសង្ស័យថា ពួកគេអាចរងការជួញដូរមនុស្ស ត្រូវបានរារាំងមិនឱ្យធ្វើដំណើរទៅក្រៅប្រទេស។ នេះអាចជាវិធានការទប់ស្កាត់ដែលមានប្រយោជន៍ ប្រសិនបើយកទៅអនុវត្តឱ្យស៊ីចង្វាក់គ្នាដោយមន្ត្រីដែលទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ និងគាំទ្រដោយព័ត៌មានសម្ងាត់រឹងមាំ។ ក៏ប៉ុន្តែ មិនគ្មានការការពារទាំងនេះទេ វិធានទប់ស្កាត់ជាមុនបែបនេះទំនងជាពុំមានប្រសិទ្ធភាព ទាំងការអនុវត្តន៍ និងផលប៉ះពាល់។

កម្រិតខ្ពស់នៃការជួញដូរមនុស្សឆ្លងដែន នៅក្នុងតំបន់អាស៊ានបង្កឱ្យមានសំណួរជាច្រើន អំពី**ការទទួលស្គាល់ដោយរដ្ឋសមាជិកអាស៊ានមួយចំពោះស្ថានភាព របស់ជនរងគ្រោះដែលកំណត់ដោយរដ្ឋសមាជិកអាស៊ានមួយទៀត**។ ឧទាហរណ៍ វាអាចមានសារៈសំខាន់ សម្រាប់បញ្ហាចម្រុះ ដូចជា ការវិលត្រឡប់ ការធ្វើសមាហរណកម្ម និងសំណងជួសជុលដែលការសម្រេចរបស់អាជ្ញាធរ នៃរដ្ឋគោលដៅក្នុងការទទួលស្គាល់មនុស្សណាម្នាក់ជាជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានទទួលយកដោយរដ្ឋដើម។ ជាវិធានទូទៅ ការកំណត់អត្តសញ្ញាណជនរងគ្រោះពីការជួញដូរមនុស្សនឹងកើតឡើងជាទូទៅនៅក្នុងប្រទេសដែលការកេងប្រវ័ញ្ចកើតឡើង (ប្រទេសគោលដៅ)។ ហេតុនេះ គឺច្បាប់ និងនីតិវិធីរបស់ប្រទេសនោះ ដែលនឹងសម្រេចថាតើ មនុស្សណាម្នាក់ត្រូវបានកំណត់អត្តសញ្ញាណថារងការជួញដូរមនុស្ស ឬយ៉ាងណា។ ដើម្បីធានាថា ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណត្រូវបានបញ្ជូនត្រឡប់ទៅវិញ និងធ្វើសមាហរណកម្មបានយ៉ាងជោគជ័យ ជាការសំខាន់ដែលថា ប្រទេសដើមត្រូវទទួលយកសេចក្ដីសម្រេចរបស់ប្រទេសគោលដៅ។ ផ្ទុយទៅ ជារឿយៗមានករណីដែលថា ប្រទេសដើមនឹងកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់ថាទទួលរងការជួញដូរមនុស្សនៅពេលពួកគេត្រឡប់ទៅផ្ទះសម្បែងវិញ។ នៅក្នុងករណីទាំងនេះ ប្រទេសគោលដៅគួរទទួលយកការកំណត់ដែលបានធ្វើឡើងដោយប្រទេសដើម និងធ្វើការជាមួយប្រទេសនោះដើម្បីបន្តការស៊ើបអង្កេត និងគាំទ្រដល់ការអះអាង

នានាដែលថា ជនរងគ្រោះអាចបានទទួលសំណងជួសជុល ឬសំណងផ្សេងទៀត។ ការបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យនៃការកំណត់អត្តសញ្ញាណរួមគឺជាសំខាន់ឆ្ពោះទៅការធានានូវការទទួលស្គាល់ទៅវិញទៅមកនូវសេចក្តីសម្រេចដែលកំណត់អំពីជនរងគ្រោះ។ ដូចបានកត់សម្គាល់ខាងលើ ទិដ្ឋភាពទាំងពីរនេះត្រូវបានទទួលស្គាល់នៅក្នុងមាត្រា ១៤ នៃ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស*។

នៅក្នុងការស្វែងរកការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានរហ័ស និងត្រឹមត្រូវ និង ការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធឲ្យបានសមស្រប ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌរបស់តំបន់ អាចធ្វើការវិភាគយ៉ាងប្រុងប្រយ័ត្នទៅលើស្ថានភាពបច្ចុប្បន្នដោយគិតទៅដល់ការកំណត់ការផ្លាស់ប្តូរនៅផ្នែកស្ថាប័ន វប្បធម៌ និងថ្នាក់ដឹកនាំដែលចាំបាច់។ ជាបន្ទាន់ទៅទៀត ទីភ្នាក់ក៏ពិចារណាដល់អនុសាសន៍នានាដូចខាងក្រោម ដែលធ្វើឡើងដោយ ACWC បន្ទាប់ពីបានពិនិត្យទៅលើច្បាប់ គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងរបស់រដ្ឋសមាជិកអាស៊ាន នៅក្នុងវិស័យនេះដូចជា៖

- ពិនិត្យមើល**ការបណ្តុះបណ្តាល និងធនធាន**បច្ចុប្បន្នដែលមានដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ជួរមុខដែលត្រូវកែលម្អការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ ព្រមទាំងដើម្បីចែករំលែកនូវវិធីសាស្ត្រមុនកើតហេតុ និងកាន់តែស៊ីចង្វាក់នៃការកំណត់អត្តសញ្ញាណនៅក្នុងតំបន់ទាំងមូល។
- បង្កើតគោលការណ៍ណែនាំ**ដែលមានការព្រមព្រៀងសម្រាប់ការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះ**ពីការជួញដូរមនុស្ស**ទៅស្ថាប័នពាក់ព័ន្ធ**។ គោលការណ៍ណែនាំគួរអះអាងនូវការសន្មតពីស្ថានភាព ឬឋានៈរបស់ជនរងគ្រោះនៅក្នុងស្ថានភាពមួយចំនួន ព្រមទាំងការសន្មតពីអាយុ ជាប្រយោជន៍របស់បុគ្គលដែលអាចមានអាយុក្រោម ១៨ ឆ្នាំ ហើយមានសិទ្ធិទទួលបានការថែទាំ និងការការពារទៅតាមបទដ្ឋានមួយផ្សេង។
- ពិចារណាធ្វើវិសោធនកម្មច្បាប់ និង/ឬ កិច្ចព្រមព្រៀងទ្វេភាគីដើម្បីចែងឲ្យមានការទទួលស្គាល់ទៅវិញទៅមកនូវនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះរបស់រដ្ឋសមាជិកអាស៊ានផ្សេងទៀត ដែលត្រូវបានតម្រូវទៅតាម*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស*។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការការពារ និងផ្តល់ជំនួយដល់ជនរងគ្រោះ

ទោះបីមានការកែលម្អជាដុំកំភួនមួយចំនួន នៅក្នុងការការការពារដល់សិទ្ធិរបស់ជនរងគ្រោះ តាមផ្លូវច្បាប់ក៏ដោយ តែមានភស្តុតាងតិចតួចដែលថា ចំណុចនេះក្លាយជាការអនុវត្តន៍ជាក់ស្តែងល្អប្រសើរ។ និយាយឲ្យងាយយល់គឺថា៖ មានគម្លាតយ៉ាងធំធេងរវាងសិទ្ធិទទួលបានការការពារ និងជំនួយដែលផ្តល់ដល់ជនរងគ្រោះពីការជួញដូរមនុស្ស និង ការការពារ និងជំនួយជាក់ស្តែងដែលពួកគេបានទទួល។ *ទស្សនាវដ្តី* ACWC Regional Review បានគូសបញ្ជាក់នូវការប្រឈមជាច្រើនដល់រដ្ឋសមាជិកអាស៊ាន ក្នុងការផ្តល់ការការពារ និងជំនួយយ៉ាងមានប្រសិទ្ធភាព។ ការប្រឈមទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបទពិសោធន៍របស់អ្នកប្រតិបត្តិ និងអ្នកផ្សេងទៀតដែលត្រូវបានពិគ្រោះយោបល់សម្រាប់រៀបរៀងរបាយការណ៍នេះ។ ការប្រឈមមួយចំនួន (ឧទា. ការកម្រិតសមត្ថភាព និងចំណុចខ្វះខាតផ្នែកច្បាប់) មិនអាចត្រូវបានដោះស្រាយដោយផ្ទាល់ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទេ។ ក៏ប៉ុន្តែ ការប្រឈមផ្សេងទៀត (ឧទា. ការ

ភ្ជាប់ជំនួយទៅនឹងការសហការ ការមិនបញ្ជូនជនរងគ្រោះ និងអ្នកដែលអាចជាជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ ការមិនការពារឯកជនភាព) មាននៅក្នុងអំណាចរបស់មន្ត្រី និងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវដោះស្រាយ។

**សមត្ថភាព និងធនធានមានកម្រិត៖** ការគាំទ្រជនរងគ្រោះប្រកបដោយគុណភាពមានការចំណាយច្រើន និងតម្រូវឲ្យមានបុគ្គលិកដែលមានជំនាញផងដែរ។ នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ការផ្តល់ការការពារ និងជំនួយមិនគ្រប់គ្រាន់ដល់ជនរងគ្រោះគឺជាលទ្ធផលដោយផ្ទាល់ពីកង្វះសមត្ថភាព និងកង្វះធនធានក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដែលទទួលខុសត្រូវ ផ្តល់ការគាំទ្រដល់ជនរងគ្រោះពីការជួញដូរមនុស្ស។ ក្នុងតំបន់ទាំងមូល ម្ចាស់ជំនួយខាងក្រៅចូលរួមយ៉ាងច្រើនក្នុងការគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព និងការផ្តល់សេវា។ ទោះបីប្រការផ្តល់ការជួយជ្រោមជ្រែងសំខាន់ក៏ដោយ តែគំរូនេះពុំមាននិរន្តរភាពសម្រាប់រយៈពេលយូរអង្វែងទេ។

**បទប្បញ្ញត្តិច្បាប់មិនពេញលេញ៖** មានតែរដ្ឋសមាជិកអាស៊ានមួយចំនួនប៉ុណ្ណោះដែលមានច្បាប់ពេញលេញ។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ច្បាប់ពាក់ព័ន្ធពុំបានចែងជាក់លាក់ ឬមានចែងជាក់លាក់តិចតួចដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាន។ ទោះបីក្នុងទ្រឹស្តី ជនរងគ្រោះអាចប្រើប្រាស់ច្បាប់ផ្សេងទៀតក៏ដោយ តែកង្វះមូលដ្ឋានគតិយុត្តិសម្រាប់ការការពារ និងជំនួយនៅក្នុងច្បាប់ស្តីពីការជួញដូរមនុស្សវាបង្កើនទូវលទ្ធភាពដែលថា ការការពារ និងជំនួយទាំងនេះនឹងមិនត្រូវបានផ្តល់ឲ្យទេ ឬថា ត្រូវបានផ្តល់ឲ្យតាមវិធីមួយដែលបង្កើនភាពងាយរងគ្រោះរបស់ជនរងគ្រោះ និងហានិភ័យនៃការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត។ ឧទាហរណ៍ រដ្ឋសមាជិកអាស៊ានមួយចំនួនតូច បានការពារយ៉ាងពេញលេញ ទៅសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ ដែលជាទិដ្ឋភាពជាមូលដ្ឋាននៃការការពារចៀសផុតពីព្យសនកម្មបន្ថែមទៀត។

ការការពារ និងការគាំទ្រភ្លាមៗ ត្រូវបានភ្ជាប់ទៅនឹងការសហការ ជាមួយភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងការឃុំខ្លួននៅក្នុងទីជម្រក៖ ដូចដែលនឹងរៀបរាប់លម្អិតនៅក្នុងជំពូកបន្ទាប់ ទម្រង់ជាក់លាក់នៃជំនួយជារឿយៗ ត្រូវបានភ្ជាប់ទៅនឹងឋានៈរបស់ជនរងគ្រោះជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ដោយសារមានការការពារពេញលេញ ការអនុវត្តន៍ជាក់ស្តែងទាំងនេះត្រូវបានចាត់ទុកថាអាចទទួលយកបាន។ ក៏ប៉ុន្តែ ការភ្ជាប់ការការពារ និងការគាំទ្រ*ចាំបាច់ភ្លាមៗ*ទៅនឹងការសហការរបស់ជនរងគ្រោះបង្កឲ្យមានបញ្ហាខ្ពស់។ ទោះបី ពុំមានរដ្ឋសមាជិកអាស៊ានណាមួយ បានភ្ជាប់ជាក់ស្តែងរវាងជំនួយភ្លាមៗដល់ជនរងគ្រោះ ទៅនឹងការសហការពីជនរងគ្រោះក៏ដោយ តែភស្តុតាងដែលមានបង្ហាញច្បាស់ថា ការកំណត់លក្ខខណ្ឌបែបនេះ ដំណើរការយ៉ាងទូលំទូលាយក្នុងការអនុវត្តន៍ជាក់ស្តែង។ នៅក្នុងករណីមួយចំនួន ចំណុចនេះកើតឡើង ដោយសារមធ្យោបាយ ដែលអាចមានដើម្បីផ្តល់ជំនួយផ្សេងៗ ត្រូវបានបិទ ហេតុនេះវាជាការបង្ខំយ៉ាងមានប្រសិទ្ធភាព ដល់ជនរងគ្រោះឲ្យទទួលយកជំនួយផង*និង*សហការនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផង។

**កង្វះការយល់ដឹង និងការសម្របសម្រួលរារាំងដល់ការផ្តល់ការការពារ និងជំនួយ៖** មានការសម្របសម្រួលមិនពេញលេញទាំងនៅក្នុងរដ្ឋសមាជិកអាស៊ាន និង រវាងរដ្ឋសមាជិកអាស៊ាននិងរដ្ឋសមាជិកអាស៊ាន ដែលបណ្តាលឲ្យមានស្ថានភាពមួយ ដែលជនរងគ្រោះពីការជួញដូរមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណរួចហើយ មិនត្រូវបានបញ្ជូនឲ្យបានត្រឹមត្រូវទៅកាន់អ្នកដែលអាចផ្តល់ការការពារ និងជំនួយបាន។ ជួនកាល ចំណុចនេះកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារពុំមានការយល់ដឹងក្នុងចំណោមមន្ត្រី ដែលទាក់ទងជាមួយជនរងគ្រោះអំពីការទទួលខុសត្រូវរបស់ខ្លួន នីតិវិធី និងសិទ្ធិក្នុងការទទួលបានរបស់ជនរងគ្រោះ។ មានការយល់ដឹងមួយចំនួន ពីការទទួលខុសត្រូវរបស់មន្ត្រីនៅក្នុងចំណុចនេះ។ ឧទាហរណ៍ នាពេលបច្ចុប្បន្ន នៅប្រទេសថៃ មន្ត្រីអនុវត្តន៍ច្បាប់ត្រូវជូនដំណឹងដល់ជនរង

គ្រោះ និងអ្នកដែលអាចជាជនរងគ្រោះនូវសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេនៅពេលកំណត់អត្តសញ្ញាណ រួមទាំងសិទ្ធិទទួលការការពារ សិទ្ធិទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងជម្រកបណ្ដោះអាសន្ន។ ការកែលម្អនូវការសម្របសម្រួល និងចំណេះដឹងក្នុងចំណោម និងរវាងមន្ត្រីអនុវត្តន៍ច្បាប់ និងអ្នកផ្ដល់សេវានឹងជួយកែលម្អនូវលំហូរនៃព័ត៌មានចំពោះជនរងគ្រោះ សម្របសម្រួលការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធឱ្យបានសមស្រប បញ្ចៀសការខិតខំប្រឹងប្រែងត្រួតគ្នា និងរក្សាធនធាន។

ទោះបី រដ្ឋសមាជិកអាស៊ានភាគច្រើនបានបញ្ចូល ក្នុងបទប្បញ្ញត្តិច្បាប់នូវការការពារឯកជនភាពរបស់ជនរងគ្រោះក៏ដោយ តែ**ការខកខានមិនបានការពារឯកជនភាព** គឺជាបញ្ហានៅបន្តមាននៅឡើយ ដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ជនរងគ្រោះ និងរារាំងដល់លទ្ធភាព និងឆន្ទៈរបស់ពួកគេក្នុងការសហការ នៅក្នុងការកំណត់អត្តសញ្ញាណ និងការចោទប្រកាន់ជនកេងប្រវ័ញ្ចពួកគេ។ ខណៈពេលដែលមានបញ្ហានៅគ្រប់ដំណាក់កាលទាំងអស់នៃបទពិសោធន៍របស់ជនរងគ្រោះ អាជ្ញាធរយុត្តិធម៌ព្រហ្មទណ្ឌមិនបានការពារឯកជនភាពរបស់ជនរងគ្រោះ គឺជាបរាជ័យមួយដែលមានសភាពធ្ងន់ធ្ងរ និងជាកាលៈទេសៈដែលមានគ្រោះថ្នាក់បំផុត ជាពិសេសនៅពេលជនរងគ្រោះដើរតួនាទីជាសាក្សី។

អនុសាសន៍ខាងក្រោម មានគោលបំណងដើម្បីកែលម្អការផ្ដល់ការការពារឱ្យបានពេញលេញ ដល់បុគ្គលទាំងអស់ដែលត្រូវបានសង្ស័យថា ទទួលរងការជួញដូរមនុស្ស៖

- រដ្ឋសមាជិកអាស៊ានទាំងអស់ត្រូវពិចារណាពិនិត្យ និងក្នុងករណីចាំបាច់ **កែប្រែច្បាប់របស់ខ្លួន** ដើម្បីធានាថាជនរងគ្រោះពីការជួញដូរមនុស្ស (រួមទាំងអ្នកដែលត្រូវបានសន្មតថា ជាជនរងគ្រោះពីការជួញដូរមនុស្ស) មានសិទ្ធិទទួលបានការការពារភ្លាមៗ ពីព្យសនកម្មបន្ថែមទៀត និងជំនួយដែលគ្រប់គ្រាន់ដើម្បីឱ្យពួកគេអាចបំពេញទៅតាមតម្រូវការចាំបាច់របស់ខ្លួន និងមិនមានសំពាធលក្ខខណ្ឌដែលតម្រូវឱ្យសហការជាមួយអាជ្ញាធរឡើយ។
- ទីភ្នាក់ងារ និងមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ដែលបានចូលរួមនៅដំណាក់កាលដំបូងៗ នៃការស៊ើបអង្កេតទៅលើការជួញដូរមនុស្សត្រូវមានការយល់ដឹង តាមរយៈការបណ្ដុះបណ្ដាល និងមធ្យោបាយផ្សេងទៀត នូវ**សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានការការពារ និងការគាំទ្រ** និងរបៀបធានាឱ្យបាននូវសិទ្ធិទាំងនេះ។
- ទីភ្នាក់ងារ និងមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវមានការយល់ដឹង តាមរយៈការបណ្ដុះបណ្ដាល និងមធ្យោបាយផ្សេងទៀត នូវ**កាតព្វកិច្ច**របស់ខ្លួន**ក្នុងការការពារឯកជនភាពរបស់ជនរងគ្រោះ** និងអ្នកដែលអាចជាជនរងគ្រោះពីការជួញដូរមនុស្ស។
- រដ្ឋសមាជិកអាស៊ានទាំងអស់ត្រូវធ្វើការឆ្ពោះទៅរក**នីតិវិធីបញ្ជូន ទៅស្ថាប័នពាក់ព័ន្ធដែលរឹងមាំ** រវាងសេវាសង្គមកិច្ចរបស់រដ្ឋាភិបាល និងអ្នកផ្ដល់សេវាផ្សេងទៀត ដោយទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌទទួលបានការណែនាំច្បាស់លាស់ អំពីអ្វីដែលពួកគេគួរធ្វើ នៅពេលជំរុញឱ្យជនរងគ្រោះ ឬអ្នកអាចជាជនរងគ្រោះពីអំពើជួញដូរមនុស្ស។
- រដ្ឋសមាជិកអាស៊ានទាំងអស់ ត្រូវធ្វើការឆ្ពោះទៅ**លុបបំបាត់ការអនុវត្តន៍ នៃការឃុំខ្លួនជនរងគ្រោះពេញវ័យ** នៅក្នុងទីជម្រក ឬនៅកន្លែងផ្សេងទៀត និងការបញ្ចៀសការចោទប្រកាន់ទៅលើជនរងគ្រោះ ឬអ្នកអាចជាជនរងគ្រោះពីបទល្មើសពាក់ព័ន្ធនឹងការជួញដូរ។

- ទាក់ទងនឹងកុមារ រដ្ឋសមាជិកអាស៊ានទាំងអស់ត្រូវធានាថា **ត្រូវបាននីតិវិធីចាំបាច់សម្រាប់កុមារ** ដែលត្រូវបានកំណត់អត្តសញ្ញាណ (ឬត្រូវបានកំណត់អត្តសញ្ញាណបណ្តោះអាសន្ន) ថាបានទទួលរងការជួញដូរមនុស្ស ដើម្បីធានាថា ពួកគេទទួលបានការការពារ និងការគាំទ្រភ្លាមៗ។ វិធានការទាំងនេះគួរបញ្ចូលការចាត់ចែង ឱ្យមានអាណាព្យាបាលជាប្រចាំម្នាក់ ដើម្បីតំណាង និងការពារឧត្តមប្រយោជន៍របស់កុមារ។

# កំណត់សម្គាល់ទៅលើសំណងជួសជុលដល់ជនរងគ្រោះ

បញ្ហាសំណង រួមទាំងសំណងជួសជុល គឺជាបញ្ហាសំខាន់មួយសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស។ ភាពអាចរកបាននៃប្រព័ន្ធ និងដំណើរការដើម្បីធានាថា ជនរងគ្រោះបានទទួលសំណងបដិទាន ចំពោះ បទល្មើសដែលបានប្រព្រឹត្តមកលើពួកគេគឺជាកត្តាចម្បងនៃការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព។ ការផ្តោតទៅលើរបាយការណ៍នេះមិនអនុញ្ញាតឱ្យធ្វើការដោះស្រាយទៅបញ្ហាសំណងជួសជុលយ៉ាងលម្អិតទេ។ ហេតុនេះ ចំណុចខាងក្រោមផ្តល់នូវទិដ្ឋភាពទូទៅដោយសង្ខេបពីច្បាប់ គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែងនាពេលបច្ចុប្បន្ននៅក្នុងផ្នែកនេះ។ អ្នកអានគួរអានបន្ថែមនូវ *ទស្សនាវដ្តី* ACWC Regional Review (ជំពូកទី ៥) សម្រាប់ការពិចារណាលម្អិតទៅលើប្រធានបទនេះ។

ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់មានសិទ្ធិទទួលបានយុត្តិធម៌ ចំពោះបទល្មើស និងការរំលោភបំពានសិទ្ធិមនុស្សដែលបានប្រព្រឹត្តមកលើពួកគេ។ ជាពិសេស ចំណុចនេះបញ្ចូលនូវសិទ្ធិទទួលបានសំណងផងដែរ ដូចជាសំណងជួសជុលចំពោះព្យសនកម្ម និងចំពោះប្រាក់ឈ្នួលដែលមិនបានទទួល។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* អះអាងនូវសិទ្ធិនេះដូចខាងក្រោម៖

> *ភាគីនីមួយៗត្រូវធានាថា ប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់ខ្លួនមានវិធាននានា ដែលផ្តល់ឱ្យជន រងគ្រោះនៃការជួញដូរមនុស្សនូវ លទ្ធភាពក្នុងការទទួលបានសំណង ចំពោះព្យសនកម្មដែលបានទទួលរង។*
> **មាត្រា ១៤(១៣)**

អនុលោមតាមអង្គការសហប្រជាជាតិ លក្ខខណ្ឌតម្រូវឱ្យរដ្ឋភាគីត្រូវផ្តល់ដល់ជនរងគ្រោះនូវ "លទ្ធភាពនៃការទទួលបានសំណងជួសជុល" ដែលរដ្ឋត្រូវបំពេញដោយបង្កើតនូវជម្រើសណាមួយ ឬលើសពីមួយ ក្នុងចំណោមជម្រើសទាំងបីដូចខាងក្រោម៖

- បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យជនរងគ្រោះប្តឹងទាមទារសំណងរដ្ឋប្បវេណីដល់ជនល្មើស។
- បទប្បញ្ញត្តិដែលអនុញ្ញាតឱ្យតុលាការព្រហ្មទណ្ឌផ្តល់សំណងព្រហ្មទណ្ឌ (ដែលបង់ដោយជនល្មើស) ឬបង្គាប់ឱ្យជនដែលត្រូវបានផ្តន្ទាទោស ពីបទល្មើសជួញដូរមនុស្ស ត្រូវបង់សំណងជួសជុល ឬសំណងបដិទាន។ ឬ
- បទប្បញ្ញត្តិដែលបង្កើតជាមូលនិធិ ឬផែនការដែលអនុញ្ញាតឱ្យជនរងគ្រោះ ទាមទារសំណងជួសជុលពីរដ្ឋចំពោះការខូចខាត ឬព្យសនកម្ម ដែលពួកគេទទួលរង[១៣២]។

---

[១៣២] គោលការណ៍ណែនាំផ្នែកច្បាប់ចំពោះអនុសញ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងពិធីសាររបស់វា វគ្គ ១ កថាខណ្ឌ ៦០។

*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* ក៏ដោះស្រាយបញ្ហា*ទទួលបាន*សំណងផងដែរ គឺថា៖ ការបញ្ជាក់អំពីកាតព្វកិច្ចរបស់អាជ្ញាធរ ក្នុងការជូនដំណឹងទៅជនរងគ្រោះ និងអ្នកដែលអាចជាជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានសំណងជួសជុស (មាត្រា ១៤(៩))។ ចំណុចនេះបានដោះស្រាយនូវអនុសាសន៍មួយដែលបានធ្វើឡើងនៅក្នុងសំណៅលើកមុននៃ *របាយការណ៍វឌ្ឍនភាព* ដែលថា៖

រដ្ឋសមាជិកអាស៊ានគួរធ្វើការដើម្បីធានាថា វាជាឧបសគ្គរួម ចំពោះការទទួលបានសំណង ត្រូវបានដោះស្រាយ។ វាមានសារៈសំខាន់ ជាពិសេសដែលថាមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ និងអ្នកផ្សេងទៀតត្រូវដឹងអំពីតម្រូវការរបស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មានពេញលេញអំពីសិទ្ធិស្របច្បាប់របស់ខ្លួន រួមទាំង សិទ្ធិទទួលបានសំណងតាមរយៈកិច្ចដំណើរការនីតិវិធីតុលាការ និងរដ្ឋបាលឱ្យបានទាន់ពេលវេលា សិទ្ធទទួលបានផ្នែកភាសា និងទម្រង់ណាមួយដែលពួកគេអាចយល់បាន។

លិខិតូបករណ៍ស្តីពីគោលនយោបាយជាច្រើនរបស់អាស៊ាន (ទោះបីមិនមែនជា*ផែនការសកម្មភាពអស៊ាន*ក៏ដោយ) បានអះអាងនូវសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្ស ក្នុងការទទួលបានសំណង។ ឧទាហរណ៍ *គោលការណ៍ណែនាំអំពីការប្រកាន់យកយេនឌ័រ* ACWC បានដាក់ការទទួលខុសត្រូវ ទៅលើព្រះរាជអាជ្ញាក្នុងការអនុវត្តសំណងជួសជុលដល់ជនរងគ្រោះក្នុងករណីដែលមាន (នៅត្រង់ចំណុច ៣.៦.៩)។ *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* បានធ្វើឱ្យកាន់តែមានទំនាក់ទំនងសំខាន់ទៀតរវាងសំណងជួសជុលសម្រាប់ជនរងគ្រោះ និងការរឹបអូសទ្រព្យរបស់ជនកេងប្រវ័ញ្ចពួកគេ ដោយលើកឡើងថា៖

> អ្នកប្រតិបត្តិគួរកំណត់នូវរាល់សំណងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីទាំងអស់ ដែលមានសម្រាប់ជនរងគ្រោះ និងនីតិវិធីចាំបាច់ដើម្បីគាំទ្រឱ្យជនរងគ្រោះទទួលបានសំណងទាំងនោះ រួមទាំង លទ្ធភាពនៃការប្រើប្រាស់ទ្រព្យដែលបានរឹបអូស ធ្វើជាប្រភពថវិកាសម្រាប់ផ្តល់សំណងជួសជុលចំពោះព្យសនកម្មដែលបានទទួលរង[១៣៣]។

មានវឌ្ឍនភាពមួយចំនួន នៅក្នុងតំបន់ទាក់ទងនឹងការទទួលស្គាល់តាមផ្លូវច្បាប់ នូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងជួសជុល។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន សិទ្ធិតាមផ្លូវច្បាប់របស់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការទទួលបានសំណងជួសជុលមិនមានភាពច្បាស់លាស់ទេ។ នីតិវិធីសម្រាប់ទទួលបានសំណងជួសជុលក៏មិនច្បាស់លាស់ស្រដៀងគ្នាដែរ។ ឧទាហរណ៍ ជារឿយៗពុំមានភាពច្បាស់លាស់ថាតើអ្នកណាទទួលខុសត្រូវជួយជនរងគ្រោះ តើវិធីជាក់លាក់នៃសំណងជួសជុលណាមួយដែលសមស្របនៅក្នុងករណីជាក់លាក់មួយ ហើយ តើសំណងជួសជុល គួរត្រូវយកមកគណនាដោយរបៀបណា។

ទាក់ទងនឹងការអនុវត្តន៍ជាក់ស្តែង ស្ថានភាពនេះមានភាពធ្ងន់ធ្ងរនៅក្នុងតំបន់នេះ ដូចតំបន់ទាំងអស់ដទៃទៀតដែរ។ របកគំហើញសំខាន់ៗដូចខាងក្រោមមានភាពពាក់ព័ន្ធជាពិសេស៖

- **ការចោទប្រកាន់ផ្តោតលើជនល្មើសតូចតាច៖** នៅក្នុងប្រទេសជាច្រើន រួមទាំងរដ្ឋសមាជិកអាស៊ានជាច្រើនផង លទ្ធផលនៃការផ្តល់សំណងជួសជុលតាមរយៈកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការជំនុំជម្រះ និងការផ្តន្ទាទោសជនជួញដូរមនុស្ស។ ដូចបាន

[១៣៣] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិ ឆ្នាំ២០១៨ វគ្គ ១ ផ្នែក ៣៖ កថាខណ្ឌ ៣.៤។

ពិភាក្សាលម្អិតនៅក្នុងជំពូកមុនរួចមកហើយ ចំណុចនេះនៅតែជាការប្រឈមដ៏ធំមួយ មានជនជួញដូរតិចតួចណាស់ដែលត្រូវបានចោទប្រកាន់ និងទទួលទោសទណ្ឌនៅក្នុងតំបន់អាស៊ាន ហើយករណីដែលជនរងគ្រោះពីការជួញដូរមនុស្សបានទទួលសំណងជួសជុល នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមានភាពដាច់ឆ្ងាយ។ សូម្បីតែនៅពេលមានការផ្តល់សំណងនៅក្នុងករណីទាំងនេះក៏ដោយ ក៏ជនរងគ្រោះហាក់ដូចជា ជួបប្រទះនូវការលំបាកជាខ្លាំងក្នុងការធានាបានសំណងចំពោះព្យសនកម្មដែលបានកំណត់ឱ្យ។ ជួនកាលចំណុចនេះឆ្លុះបញ្ចាំងនូវភាពកំសោយរ៉ាំរ៉ៃនៅក្នុងប្រព័ន្ធចំពោះការវាយតម្លៃ និងការបង់សំណងចំពោះព្យសនកម្ម។ ជារឿយៗ វាឆ្លុះបញ្ចាំងនូវការពិតដែលថាភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌកំណត់ជាគោលដៅនូវជនល្មើសតូចតាច ដែលមានធនធានតិចតួចដែលផ្តល់នូវសំណងបដិទានដល់ជនរងគ្រោះ។

- **មធ្យោបាយផ្សេងទៀតមិនត្រូវបានយកមកប្រើ៖** ទោះបីមានការអភិវឌ្ឍន៍នៅផ្នែកផ្សេងទៀតក្នុងពិភពលោកក៏ដោយ តែលទ្ធភាពសម្រាប់ជនរងការជួញដូរមនុស្សទទួលបានសំណងជួសជុលតាមរយៈកិច្ចដំណើរការនីតិវិធីក្នុងវិស័យការងារ ឬមធ្យោបាយស្រដៀងគ្នានៅតំបន់អាស៊ានជារឿយៗមានកម្រិតទាបណាស់។ ស្ថានភាពនេះមានការលំបាកជាពិសេសសម្រាប់ជនរងគ្រោះបរទេសដែលមកធ្វើការនៅក្នុងវិស័យមួយក្រៅប្រព័ន្ធ និងមិនមានកំណត់ក្នុងច្បាប់ ឬមានកំណត់ក្នុងច្បាប់មិនពេញលេញ (ដូចជាការងារតាមផ្ទះជាដើម) ឬ អ្នកដែលទទួលរងការជួញដូរមនុស្សនៅក្នុងឧស្សាហកម្មផ្លូវភេទ ដែលនៅក្រៅច្បាប់ និងមិនត្រូវបានទទួលស្គាល់ថាទម្រង់នៃការងារមួយដែលអនុវត្តការការពារពីវិស័យការងារ។
- **ភាពទន់ខ្សោយជាប្រព័ន្ធ៖** កង្វះតម្លាភាពជាទូទៅនៅក្នុងប្រព័ន្ធ និងទំនុកចិត្តអំពីសមត្ថភាពក្នុងការផ្តល់យុត្តិធម៌មានកម្រិតទាប អាចជាការមិនលើកទឹកចិត្តឱ្យជនរងគ្រោះស្វែងរកសំណង។ រដ្ឋសមាជិកអាស៊ានតិចតួចមានប្រព័ន្ធល្អសម្រាប់វាយតម្លៃអំពីព្យសនកម្ម ផ្តល់ថវិកាសម្រាប់ការទាមទារសំណងជួសជុលនៅពេលចារី មិនអាចបង់សំណង់បាន ហើយធានានូវការអនុវត្តដីកាបង្គាប់ឱ្យធ្វើសំណងបដិទាន។
- **ឧបសគ្គសម្រាប់ជនរងគ្រោះបរទេស៖** ជនរងគ្រោះពីការជួញដូរមនុស្ស ជាជនបរទេសដែលស្វែងរកសំណងជួសជុល ជួបប្រទះនូវការប្រឈមជាក់លាក់មួយចំនួន។ នៅក្នុងករណីជាច្រើនការទាមទារសំណងជួសជុលតម្រូវឱ្យជនរងគ្រោះ ត្រូវស្ថិតនៅក្នុងប្រទេសដែលការប្រព្រឹត្តកើតឡើង។ រដ្ឋសមាជិកអាស៊ានមួយចំនួនតូច អាចដាក់ឱ្យដំណើរការនូវនីតិវិធីដែលអនុញ្ញាតឱ្យពន្យារពេលស្នាក់នៅ ឬតាមការពេញចិត្តបាន។ នៅក្នុងករណីដែលសំណងជួសជុលត្រូវបានផ្តល់ដល់ជនរងគ្រោះបរទេសដែលបានវិលត្រឡប់ទៅប្រទេសដើមរបស់ខ្លួនវិញហើយនោះ វាមានលំបាកក្នុងការបង្ហាញឱ្យឃើញថា ជនរងគ្រោះពិតជាបានទទួលសំណងជួសជុលនេះមែន។
- **ការទទួលយក "ដំណោះស្រាយ" ក្រៅផ្លូវការ៖** នៅក្នុងប្រទេសមួយចំនួននៅក្នុងតំបន់ មានភស្តុតាងរឹងមាំពីសំណងជួសជុលក្រៅផ្លូវការ ដែលត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន និង/ឬនគរបាល។ ដូចបានលើកឡើងនៅក្នុងជំពូកមុនៗរួចមកហើយ ទម្លាប់អនុវត្តន៍បែបនេះធ្វើឱ្យប៉ះពាល់ដល់នីតិរដ្ឋ និងជំរុញឱ្យមានឥរិយាបថ នៃយុត្តិធម៌ព្រហ្មទណ្ឌគ្មានក្រមសីលធម៌ និងពុករលួយ។ វាក៏ធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍នូវប្រព័ន្ធរឹងមាំសម្រាប់វាយតម្លៃ និងផ្តល់សំណងជួសជុលតាមរយៈយន្តការស្របច្បាប់ដែរ។

| ជំពូកទី ៥ បញ្ជីត្រួតពិនិត្យ៖ ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ និង ផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗ | |
|---|---|
| យោង | បទដ្ឋានគុណភាព |
| ៥ | ជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណ ការពារ និងគាំទ្រមុនពេលកើតហេតុ ឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ |
| ៥.១ | ជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណមុនពេលកើតហេតុ ឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ |
| ៥.១.១ | មាននីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ។ ចំណុចទាំងនេះឆ្លុះបញ្ចាំងពីបទដ្ឋានអន្តរជាតិ និងឧត្តមានុវត្តន៍ដែលត្រូវបានទទួលយក។ នីតិវិធី និងគោលការណ៍ណែនាំទាំងនេះត្រូវបានបង្កើតឡើង ស្គាល់ និងយកមកប្រើប្រាស់ដោយបុគ្គលិកនៅក្នុងអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ និងភ្នាក់ងារគាំទ្រជនរងគ្រោះដែលមានភារកិច្ចត្រូវទៅទាក់ទងជាមួយជនរងគ្រោះពីការជួញដូរមនុស្ស ជាពិសេសអ្នកដែលមាន តួនាទីពាក់ព័ន្ធនឹងការស្វែងរក ការឃុំខ្លួន ការទទួល និងការបញ្ជូនជនទេសន្តរប្រវេសន៍ខុសប្រក្រតី។ នីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរ ស្ថិតក្រោមការពិនិត្យជាប្រចាំ។ (សូមមើលផងដែរ QS 3.2)។ |
| ៥.១.២ | នីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរឆ្លុះបញ្ចាំងដូចខាងក្រោម៖<br>• នៅពេលមានមូលដ្ឋានសមហេតុផលគ្រប់គ្រាន់ ដែលគាំទ្រដល់ការសង្ស័យថា ជនណាម្នាក់អាចជាជនរងគ្រោះពីការជួញដូរមនុស្ស ជននោះនឹងត្រូវបានសន្មតថាជាជនរងគ្រោះ ក្នុងគោលបំណងទទួលបានការការពារ និងការគាំទ្ររហូតទាល់តែមានការបង្ហាញផ្ទុយពីនេះ។<br>• នៅពេលមានមូលដ្ឋានដែលសង្ស័យថា កុមារណាម្នាក់អាចជាជនរងគ្រោះពីការជួញដូរមនុស្ស កុមារនោះនឹងត្រូវបានសន្មតថាជាជនរងគ្រោះរហូតទាល់តែមានការបង្ហាញផ្ទុយពីនេះ។<br>• នៅពេលមានមូលដ្ឋានសង្ស័យថា ជនរងគ្រោះ និងអ្នកដែលត្រូវបានសន្មតថាជាជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ជននោះនឹងត្រូវបានសន្មតថាជាកុមារ និងទទួលបានវិធានការការពារពិសេសដែលកុមារមានសិទ្ធិទទួលបានរហូតទាល់តែមានការបង្ហាញផ្ទុយពីនេះ។<br>• ការការពារ និងការគាំទ្រចំពោះជនរងគ្រោះពេញវ័យត្រូវបានផ្តល់ដោយផ្អែកលើការព្រមព្រៀងដែលមានព័ត៌មានពេញលេញ និងដោយគ្មានការបង្ខិតបង្ខំ។ |
| ៥.១.៣ | ជាការឆ្លើយតបអប្បបរមា នីតិវិធីនៃការកំណត់អត្តសញ្ញាណ គួររួមមានការវាយតម្លៃបន្តបន្ទាប់គ្នានូវ "ប្រភព" ព័ត៌មានពីរផ្សេងគ្នាគឺ៖ (១) លទ្ធផលដែលទទួលបានតាមរយៈការអនុវត្តន៍នូវសូចនាករនៃការកំណត់អត្តសញ្ញាណនៃការជួញដូរមនុស្សដែលគ្របដណ្តប់ទៅលើទម្រង់នៃការកេងប្រវ័ញ្ចទាំងអស់ដែលបានដឹង និងដែលទើបលេចឡើងមុនពេលសម្ភាសន៍ និង (២) ការឆ្លើយតបរបស់អ្នកដែលអាចជាជនរងគ្រោះ ក្នុងពេលមានការសម្ភាសន៍ត្រឹមត្រូវ។ |
| ៥.១.៤ | អាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធ ព្រមទាំងបុគ្គលិកនៃភ្នាក់ងារគាំទ្រជនរងគ្រោះ បានទទួលការបណ្តុះបណ្តាលក្នុងការកំណត់អត្តសញ្ញាណជនរងការជួញដូរមនុស្ស អនុលោមទៅតាមនីតិវិធី និងគោលការណ៍ណែនាំដែលបានព្រមព្រៀង (សូមមើលផងដែរ QS 3.2)។ |
| ៥.១.៥ | ដើម្បីកែលម្អការកំណត់អត្តសញ្ញាណ ត្រូវពិនិត្យតាមដានយ៉ាងសកម្មនូវវិស័យ និងទីតាំងងាយរងគ្រោះមួយចំនួនដើម្បីស្វែងរកការកេងប្រវ័ញ្ច (សូមមើលផងដែរ QS 3.2)។ |

| ជំពូកទី ៥ បញ្ជីត្រួតពិនិត្យ៖ ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ និង ផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗ | |
|---|---|
| ៥.១.៦ | អត្រានៃការកំណត់អត្តសញ្ញាណជនរងគ្រោះទាក់ទងនឹងវិសាលភាពដែលត្រូវបានទទួលស្គាល់នៃបញ្ហា អាចទទួលយកបាន៖ ដោយបញ្ជាក់ថា ផ្នែកសំខាន់នៃជនរងការជួញដូរមនុស្សពិតជាត្រូវបានកំណត់អត្តសញ្ញាណ។ |
| ៥.១.៧ | ករណីនៃការកំណត់អត្តសញ្ញាណខុសត្រូវបានទទួលស្គាល់ និងដោះស្រាយទាន់ពេលវេលា។ ដាក់ឲ្យមាននីតិវិធីដើម្បីការពារទល់នឹងការកំណត់អត្តសញ្ញាណខុស ចំពោះការប្រព្រឹត្តិមួយចំនួន (ជាពិសេស ទាក់ទងនឹងអំពើពេស្យាចារ និងការរៀបចំឲ្យរៀបអាពាហ៍ពិពាហ៍) ថាជាការជួញដូរមនុស្ស នៅពេលដែលការប្រព្រឹត្តិនោះមិនបំពេញទៅតាមធាតុផ្សំទាំងអស់នៃបទល្មើសនេះ។ |
| ៥.១.៨ | ដាក់ឲ្យមានគោលនយោបាយ និងនីតិវិធី ដើម្បីសម្របសម្រួលនូវការទទួលស្គាល់ទៅវិញទៅមកនូវការសម្រេចទៅលើការកំណត់អត្តសញ្ញាណរបស់រដ្ឋផ្សេងទៀត ទៅដល់វិសាលភាពដែលចំណុចនេះផ្តោះទៅមុខ និងគាំទ្រដល់សិទ្ធិរបស់បុគ្គលពាក់ព័ន្ធ។ |
| ៥.២ | ក្របខ័ណ្ឌគតិថ្នាក់ជាតិ ផ្តល់សិទ្ធិទទួលបានការគាំទ្រ និងការការពារដល់ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់ដែលបានកំណត់អត្តសញ្ញាណ រួមទាំង សិទ្ធិទទួលបានសំណង |
| ៥.២.១ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបានការការពារពីព្យសនកម្មបន្ថែមទៀត រួមទាំង តាមរយៈការគោរពដល់អត្តសញ្ញាណ និងឯកជនភាពរបស់ពួកគេ។ |
| ៥.២.២ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបានជំនួយ និងការគាំទ្រភ្លាមៗ រួមមាន ទីជម្រកជាបន្ទាន់ ជំនួយផ្នែកវេជ្ជសាស្ត្រ ព័ត៌មាន និងដំបូន្មានផ្នែកច្បាប់ដោយឯករាជ្យ និងអះអាងថា ការការពារ និងការគាំទ្រនេះមិនត្រូវដាក់លក្ខខណ្ឌទៅលើសមត្ថភាព ឬឆន្ទៈរបស់ជនរងគ្រោះក្នុងការសហការជាមួយអាជ្ញាធរជាតិនោះឡើយ។ |
| ៥.២.៣ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ឋានៈគតិយុត្តិដល់ជនរងគ្រោះបរទេស ជាបណ្តោះអាសន្ន (ឬ ក្នុងករណីសមស្រប ជាអចិន្ត្រៃ) ដោយពិចារណាទៅលើកត្តាមនុស្សធម៌ និងកត្តាពាក់ព័ន្ធផ្សេងទៀត។ |
| ៥.២.៤ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបានរយៈពេលសមស្របសម្រាប់ការវិលត្រឡប់ទៅរកសភាពដើមវិញ និងការគិតត្រឡប់ ដែលក្នុងអំឡុងពេលនេះ ពួកគេអាចសម្រេចអំពីជំហានបន្ទាប់ ដោយផ្អែកលើព័ត៌មានពេញលេញ។ |
| ៥.២.៥ | ក្របខ័ណ្ឌគតិយុត្តិផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបានសំណងពេញលេញ និងមានប្រសិទ្ធភាព |
| ៥.២.៦ | ក្របខ័ណ្ឌគតិយុត្តិការពារជនរងគ្រោះពីការឃុំខ្លួន ឬទម្រង់ផ្សេងទៀតនៃការស្នាក់នៅមិនស្ម័គ្រចិត្ត និងពីការចោទប្រកាន់ចំពោះបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស |
| ៥.២.៧ | ក្របខ័ណ្ឌគតិយុត្តិផ្តល់នូវវិធានការពិសេស និងបន្ថែមទៀតនៃការការពារ និងការគាំទ្រសម្រាប់កុមាររងគ្រោះពីការជួញដូរមនុស្ស |
| ៥.៣ | ជនរងគ្រោះពីការជួញដូរមនុស្សត្រូវបានការពារ និងគាំទ្រយ៉ាងពេញលេញ ក្នុងការអនុវត្តន៍<br>ជាក់ស្តែង |
| ៥.៣.១ | មាននីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរដែលផ្តល់ការការពារ និងការគាំទ្រដល់ជនរងគ្រោះ។ ចំណុចទាំងនេះឆ្លុះបញ្ចាំងពីបទដ្ឋានអន្តរជាតិ និងឧត្តមានុវត្តន៍ដែលត្រូវបានទទួលយក។ នីតិវិធី និងគោលការណ៍ណែនាំទាំងនេះបង្កើតនូវកិច្ចសហប្រតិបត្តិការនៅក្នុងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងរវាងភ្នាក់ងារយុត្តិធម៌ព្រហ្ម |

| ជំពូកទី ៥ បញ្ជីត្រួតពិនិត្យ៖ ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ និង ផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗ | |
|---|---|
| | ទណ្ឌ និងភ្នាក់ងារគាំទ្រជនរងគ្រោះ។ នីតិវិធី និងគោលការណ៍ណែនាំជាលាយលក្ខណ៍អក្សរស្ថិតក្រោមការពិនិត្យជាទៀងទាត់។ |
| ៥.៣.២ | លទ្ធផលនៃការអនុវត្តន៍ នីតិវិធី និងគោលការណ៍ណែនាំដោយអ្នកដែលពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណ ការការពារ និងការគាំទ្រដល់ជនរងគ្រោះ៖<br>• ជនរងគ្រោះត្រូវបានការពារពីព្យសនកម្មបន្ថែមទៀត ពីជនកេងប្រវ័ញ្ចទៅលើពួកគេ និងពីអ្នកផ្សេងទៀត<br>• អត្តសញ្ញាណ និងឯកជនភាពរបស់ជនរងគ្រោះត្រូវបានការការពារ នៅក្នុងវិសាលភាពដែលស្របទៅនឹងប្រយោជន៍យុត្តិធម៌។<br>• ទិន្នន័យសម្ងាត់ទាក់ទងនឹងជនរងគ្រោះ ត្រូវបានគ្រប់គ្រងយ៉ាងមានសុវត្ថិភាព ពីគ្រប់ភាគីទាំងអស់ ហើយចែករំលែកតែជាមួយដៃគូអន្តរភ្នាក់ងារផ្សេងទៀតប៉ុណ្ណោះ ក្នុងវិសាលភាពដែលចាំបាច់ ដើម្បីធានាផ្តល់ការការពារ និងការគាំទ្រយ៉ាងមានប្រសិទ្ធភាព។<br>• មនុស្សទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណ ឬត្រូវបានកំណត់អត្តសញ្ញាណបណ្តោះអាសន្នបានទទួលជំនួយ និងការគាំទ្រជាប្រចាំ និងទាន់ពេលវេលា រួមមានទីជម្រកជាបន្ទាន់ ជំនួយផ្នែកវេជ្ជសាស្ត្រ និងព័ត៌មានសមស្របទៅនឹងតម្រូវការជាក់លាក់របស់ខ្លួន (ឧទា. យេនឌ័រ ភាសា ជាតិពន្ធុ និងអាយុ)<br>• មនុស្សទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណ ឬត្រូវបានកំណត់អត្តសញ្ញាណបណ្តោះអាសន្នថាបានរងការជួញដូរមនុស្ស បានទទួលព័ត៌មានទាន់ពេលវេលា និងពេញលេញអំពីសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ និងការជ្រើសរើស ជាភាសាដែលពួកគេយល់បាន និងបានទទួលជំនួយផ្នែកច្បាប់ និងការបកប្រែភាសា ក្នុងករណីចាំបាច់<br>• ជនរងគ្រោះបានទទួលសំណងពេញលេញ និងមានប្រសិទ្ធភាព រួមមានសំណងពីតុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី<br>• ជនរងគ្រោះមិនត្រូវបានឃុំខ្លួន រងបទចោទ ឬចោទប្រកាន់ចំពោះបាន: និង/ឬ បទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងដាក់ឲ្យមានការណែនាំជាក់លាក់ ដើម្បីសម្រេចតាមបំណងនេះ<br>• ជនរងគ្រោះបរទេសមិនត្រូវបានចាប់បញ្ជូនដោយបង្ខំទៅប្រទេសដើមវិញទេ លុះត្រាតែការវាយតម្លៃពីហានិភ័យផ្ទាល់ខ្លួនបញ្ជាក់ថា វាមានសុវត្ថិភាព។ |
| ៥.៤ | កុមាររងគ្រោះពីការជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណ ការពារ និងគាំទ្រយ៉ាងពេញលេញស្របទៅនឹងគោលការណ៍ "ឧត្តមប្រយោជន៍របស់កុមារ" |
| ៥.៤.១ | ដាក់ឲ្យមានវិធានការពិសេស និងរឹងមាំ ដើម្បីផ្តល់សុវត្ថិភាព ការគាំទ្រ និងជំនួយដល់កុមាររងគ្រោះ និងមានបទប្បញ្ញត្តិពិសេសសម្រាប់ការពារឯកជនភាព និងអត្តសញ្ញាណរបស់ពួកគេ។ |
| ៥.៤.២ | ក្រៅពីអ្វីដែលមានចែងនៅក្នុងក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធ គោលការណ៍ "ឧត្តមប្រយោជន៍របស់កុមារ" ត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងនីតិវិធី និងគោលការណ៍ណែនាំរបស់រដ្ឋសម្រាប់ដោះស្រាយបញ្ហាកុមាររងគ្រោះពីការជួញដូរមនុស្ស |
| ៥.៤.៣ | បុគ្គលសមរម្យម្នាក់ត្រូវបានចាត់តាំងដើម្បីការពារ "ឧត្តមប្រយោជន៍របស់កុមារ" នៅពេលកុមាររងគ្រោះត្រូវបានកំណត់អត្តសញ្ញាណផ្លូវការ ឬបណ្តោះអាសន្នភ្លាម ហើយកុមារនោះទទួលបានព័ត៌មាន និងការពិភាក្សានៅគ្រប់ដំណាក់កាលទាំងនៃនីតិវិធី ស្របទៅតាមអាយុ ការអប់រំ និងប្រាជ្ញាស្មារតី។ |

| ជំពូកទី ៥ បញ្ជីត្រួតពិនិត្យ៖ ធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ និង ផ្តល់នូវការការពារ និងការគាំទ្រភ្លាមៗ | |
|---|---|
| ៥.៤.៤ | ផ្តល់ការបណ្តុះបណ្តាលសមស្រប នៅក្នុងការអនុវត្តន៍ច្បាប់ គោលការណ៍ណែនាំ និងនីតិវិធីពាក់ព័ន្ធ ទាក់ទងនឹងកុមាររងគ្រោះ និងឆ្លុះបញ្ចាំងនៅក្នុងការអនុវត្តន៍ជាក់ស្តែង និងឥរិយាបថរបស់មន្ត្រី និងអាជ្ញាធរពាក់ព័ន្ធ |
| ៥.៤.៥ | គ្មានការបែងចែក ក្នុងច្បាប់ ឬការអនុវត្តន៍ រវាងសិទ្ធិរបស់កុមាររងគ្រោះពីការជួញដូរមនុស្ស ដែលមិនមែនជាជនជាតិខ្លួន ក្នុងការទទួលបាន នូវអ្វីដែលកុមារត្រូវទទួលបាន |
| ៥.៤.៦ | កុមាររងគ្រោះមិនបានបានចោទប្រកាន់ ជាបទល្មើសព្រហ្មទណ្ឌ និងមិនត្រូវបានឃុំខ្លួនទេ លើកលែងតែដើម្បីការពារ និងសុខុមាលភាពរបស់ពួកគេ និងស្របយ៉ាងពេញលេញទៅនឹងវិធាន និងបទដ្ឋានអន្តរជាតិ និង ក្នុងមធ្យោបាយដែលស្របទៅនឹងអាយុ ឃេនឌ័រ និងតម្រូវការពិសេសសរបស់ពួកគេតែប៉ុណ្ណោះ។ ការឃុំខ្លួនកុមារត្រូវស្ថិតគឺត្រូវស្ថិតក្នុងការពិនិត្យរបស់តុលាការ។ |

# ជំពូកទី ៦៖ ការគាំទ្រពិសេសដល់ជនរងគ្រោះជាសាក្សី

បុគ្គលទទួលរងការជួញដូរមនុស្ស មានតួនាទីសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ប្រឆាំងនឹងជនកេងប្រវ័ញ្ចទៅលើពួកគេ និងផលប្រយោជន៍ស្របច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។ ហេតុនេះ រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ត្រូវធ្វើឡើងដើម្បីធានាថា ពួកគេអាចចូលរួមដោយសេរី ដោយសុវត្ថិភាព និងផ្អែកលើព័ត៌មានពេញលេញ។ បទពិសោធន៍នៅក្នុងតំបន់អាស៊ាន និងទីកន្លែងផ្សេងទៀតក៏បានចង្អុលបង្ហាញនូវហេតុផលមួយទៀតដើម្បីគាំទ្រដល់ការចូលរួមរបស់បុគ្គលទាំងនោះគឺថា៖ ការស៊ើបអង្កេត និងការចោទប្រកាន់តែងតែមានការលំបាក និងជួនកាលមិនអាចធ្វើបានផង ប្រសិនបើគ្មានកិច្ចសហការ និងសក្ខីកម្មរបស់ជនរងគ្រោះ។ ហេតុនេះ ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់នេះគឺធ្វើការឆ្ពោះទៅស្ថានភាព ដែលជនរងគ្រោះពីការជួញដូរបានទទួលការការពារ និងការគាំទ្រងាយៗដែលពួកគេត្រូវការដើម្បីចូលរួមដោយសុវត្ថិភាពកទៅក្នុងការចោទប្រកាន់ចំពោះជនកេងប្រវ័ញ្ចមកលើពួកគេ។ ដូចបានកត់សម្គាល់នៅក្នុងគោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ានថា៖

> ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតគួរធ្វើការយ៉ាងជិតស្និទ្ធដើម្បីធានាឲ្យបានការព្រមព្រៀង និងកិច្ចសហការពីជនរងគ្រោះពីការជួញដូរមនុស្សមកធ្វើជាសាក្សីជាជនរងគ្រោះ... ដើម្បីផ្តល់ចម្លើយភស្តុតាង [និង] ផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះជនជួញដូរមនុស្សមកលើពួកគេនៅក្នុងសំណុំរឿងនានាដែលសក្ខីកម្មរបស់ពួកគេមានភាពចាំបាច់ សម្រាប់ការចោទប្រកាន់[១៣៤]។

បើទោះបីជាមានការធានា នូវការការពារ និងការគាំទ្រក៏ដោយ ក៏ជនរងគ្រោះ នៅតែមិនមានឆន្ទៈសហការនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ដែល ហាក់ដូចជាមិនមានប្រយោជន៍ចំពោះពួកគេតាមវិធីមួយយ៉ាងពេញលេញនោះទេ។ ជាធម្មតា ការចូលរួមធ្វើឲ្យជនរងគ្រោះត្រូវលះបង់ បញ្ហាផ្ទាល់ខ្លួនជាច្រើន។ វាជាស្ថានភាពធម្មតាចំពោះមន្ត្រីពាក់ព័ន្ធនឹងមិនដឹងពីបទប្បញ្ញត្តិនៅក្នុងច្បាប់ និងគោលនយោបាយដែលគាំទ្រដល់សិទ្ធិរបស់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ នៅក្នុងករណីមួយចំនួន មន្ត្រីអាចសមគំនិតនៅក្នុងការជួញដូរមនុស្ស ឬត្រូវបានជំរុញតាមវិធីផ្សេងទៀតឲ្យធ្វើការរារាំងដល់ដំណើរការអនុវត្តន៍ច្បាប់ និងតាមផ្លូវតុលាការ ដែលមានគោលបំណងនាំយកជនជួញដូរមនុស្សឲ្យមកទទួលខុសត្រូវ។ កង្វះតម្លាភាព និងការមិនទុកចិត្តពីសាធារណជន ទៅលើប្រព័ន្ធតុលាការក៏អាចជំរុញជនរងគ្រោះ មិនឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ប្រឆាំងនឹងជនជួញដូរមនុស្សមកលើពួកគេដែរ។ ហេតុនេះ រដ្ឋដែលបានប្តេជ្ញាចិត្ត ក្នុងការពង្រឹងការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្សគួរពិចារណារិះរកវិធីសាស្ត្រងាយស្រួលដល់ជនរងគ្រោះក្នុងការសហការ ដោយផ្តល់ឲ្យលើសពីលក្ខខណ្ឌដែលបានតម្រូវនៃការការពារ និង

[១៣៤] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២ ផ្នែក ២។

ការគាំទ្រ ដូចដែលនឹងលើកឡើងខាងក្រោម។ ការពិត បទប្បញ្ញត្តិទាំងនេះគួរត្រូវបានបង្កើតឡើង និងយកមកអនុវត្តក្នុងវិធីមួយដែលមិនប៉ះពាល់ដល់ភាពជឿជាក់ទៅលើជនរងគ្រោះក្នុងនាមជាសាក្សី ឬធ្វើឲ្យប៉ះពាល់ដល់សុចរិតភាពនៃដំណើរការជំនុំជម្រះតាមវិធីផ្សេងទៀត។

ការទទួលស្គាល់នៃការលះបង់ដ៏ធំធេងរបស់ជនរងគ្រោះ ចំពោះការចូលរួមរបស់ពួកគេ នៅក្នុងការចោទប្រកាន់លើជនល្មើស ធ្វើឲ្យមានការទទួលស្គាល់កាន់តែច្រើនឡើងនូវតម្រូវការ ក្នុងការកាត់បន្ថយនូវកម្រិតខ្ពស់នៃការពឹងផ្អែកទៅលើសក្ខីកម្មរបស់ជនរងគ្រោះ ឧទាហរណ៍ តាមរយៈការកែលម្អនីតិវិធីស៊ើបអង្កេត ដើម្បីផ្តោតទៅលើប្រភពភស្តុតាងដែលគាំទ្រ និងប្រភពផ្សេងទៀត ទាក់ទងនឹងការជួញដូរមនុស្សផង ឬបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្សផង។ ចំណុចនេះត្រូវបានទទួលស្គាល់ នៅក្នុងផែនការសកម្មភាពអាស៊ាន ដែលអំពាវនាវដល់រដ្ឋសមាជិកអាស៊ានឲ្យ៖

> បង្កើតវិធីសាស្ត្រនៃស៊ើបអង្កេតមុនពេលកើតហេតុ និងក្នុងករណីសមស្រប ត្រូវធ្វើការឃ្លាំមើល និងវិធានការមុនពេលកើតហេតុផ្សេងទៀត ដើម្បីប្រមូលភស្តុតាង ដើម្បីកសាងសំណុំរឿងចោទប្រកាន់ពីការជួញដូរមនុស្ស ទោះបីពុំមានសក្ខីកម្មពីជនរងគ្រោះក៏ដោយ[១៣៥]។

## ៦.១ ធាតុផ្សំសំខាន់នៃការការពារពិសេសដល់ជនរងគ្រោះជាសាក្សី

ច្បាប់អន្តរជាតិ រួមទាំង អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស និងគោលនយោបាយរបស់អាស៊ានដែលបានលើកឡើងនៅក្នុងគោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិនៅអាស៊ាន ស្តីពីការឆ្លើយតបយ៉ាងមានប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស (គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន) និងផែនការសកម្មភាព ACWC បានទទួលស្គាល់នូវតួនាទីសំខាន់របស់ជនរងគ្រោះនៅក្នុងការចោទប្រកាន់ទៅលើជនកេងប្រវ័ញ្ចមកលើពួកគេ និងចាំបាច់ត្រូវផ្តល់ការគាំទ្រពេញលេញដល់ពួកគេនៅក្នុងដំណើរការនេះ។ ក្នុងអត្ថន័យងាយយល់ចំណុចនេះពាក់ព័ន្ធដូចខាងក្រោម៖

**<u>តម្កល់សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម៖</u>** ជនរងគ្រោះពីការជួញដូរមនុស្សមានសិទ្ធិចូលរួមទៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ និងបង្ហាញពីទស្សនៈរបស់ខ្លួននៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងខ្លួន[១៣៦]។ ជាបញ្ហាអនុវត្តន៍ជាក់ស្តែង ចំណុចនេះអាចពាក់ព័ន្ធនឹងការបង្ហាញខ្លួនជនរងគ្រោះ តែក៏អាចបញ្ចូលនូវវត្តមានអ្នកតំណាងតាមផ្លូវច្បាប់របស់ជនរងគ្រោះ ឬចម្លើយរបស់ជនរងគ្រោះដែរ (រួមមានសេចក្តីថ្លែងការណ៍ពីផលប៉ះពាល់) តាមរយៈការដាក់ឯកសារជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងមុនពេលជំនុំជម្រះ ឬខ្សែវីដេអូ ផ្តល់សក្ខីកម្មនៅមុន ឬក្នុងពេលជំនុំជម្រះ។ សិទ្ធិចូលរួមមិនគួរច្រឡំនឹង*កាតព្វកិច្ច*នៃការចូលរួមទេ។ ទោះបីរដ្ឋមួយចំនួនពិតជាតម្រូវឲ្យជនរងគ្រោះពីបទល្មើសចូលរួមសហការជាមួយភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ (ឧទាហរណ៍ តាមរយៈការផ្តល់ចម្លើយ) ក៏ដោយ តែការ

---

[១៣៥] ផែនការសកម្មភាពអាស៊ាន វគ្គ IV(C) (b)។

[១៣៦] *ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស* មាត្រា ៦(២)(ខ)។ សូមមើលផងដែរ *UNTOC* មាត្រា ២៥(៣)។

បង្ខំជនរងគ្រោះពីការជួញដូរមនុស្សឱ្យផ្ដល់សក្ខីកម្មត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាគ្មានសុវត្ថិភាព និងគ្មានសីលធម៌វិជ្ជាជីវៈ។

<u>**ការពារសាក្សីជាជនរងគ្រោះពីការបំភិតបំភ័យ និងការសងសឹក៖**</u> ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌគួរដឹងថា ជារឿយៗ ជនរងគ្រោះពីការជួញដូរមនុស្សគ្មានឆន្ទៈជួយនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌទេ ដោយភ័យខ្លាចមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬគ្រួសាររបស់ខ្លួនពីជនជួញដូរមនុស្ស។ ការភ័យខ្លាចទាំងនោះមានមូលដ្ឋានត្រឹមត្រូវ ហើយរដ្ឋគួរប្រើអំណាច និងធនធានរបស់ខ្លួនដើម្បីវាយតម្លៃពីហានិភ័យ និងធានានូវការការពារដល់ជនរងគ្រោះដែលកំពុងសហការនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ[១៣៧]។ ចំណុចនេះរាប់បញ្ចូលក្នុងអំឡុងពេលដំណើរការជំនុំជម្រះតែម្ដង (សូមមើលប្រអប់អត្ថបទ ១៤)។ *អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស* កំណត់នូវកាតព្វកិច្ចជាក់លាក់ដល់រដ្ឋភាគីក្នុងចំណុចនេះដូចខាងក្រោម៖

> ភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីរក្សាសុចរិតនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ រួមទាំងតាមរយៈការការពារជនរងគ្រោះ និងសាក្សី ចៀសផុតពីការបំភិតបំភ័យ និងការបៀតបៀន ក្នុងករណីចាំបាច់ ហើយដាក់ទោសទណ្ឌដល់ចារីដែលបានប្រព្រឹត្តអំពើទាំងនេះ នៅក្នុងករណីសមស្រប។**មាត្រា ១៦(៧)**

វាជាការសំខាន់ដែលត្រូវទទួលស្គាល់ថា រដ្ឋភាគច្រើនមិនមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ ឬបច្ចេកទេសក្នុងការរក្សាកម្មវិធី**ការពារសាក្សី**ឱ្យបានពេញលេញ សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សទេ។ ក៏ប៉ុន្តែ រដ្ឋសមាជិកអាស៊ានទាំងអស់គួរត្រូវបានជំរុញឱ្យទទួលស្គាល់នូវសារៈសំខាន់ របស់សាក្សីជាជនរងគ្រោះ និងពិចារណានូវវិធានការបច្ចេកទេសទាប និងចំណាយទាបដើម្បីគាំទ្រ និងការពារពួកគេ។ នៅក្នុងករណីជាច្រើន មន្ត្រីអនុវត្តន៍ច្បាប់មិនអាចផ្ដល់ឱ្យជនរងគ្រោះនូវកម្រិតនៃការពារដែលពួកគេត្រូវការ ឬចង់បានទេ ដោយសារ កង្វះអាណត្តិការងារ ឬធនធាន ឬកង្វះទាំងពីរមុខ។ ជាការសំខាន់ដែលត្រូវពន្យល់ឱ្យជនរងគ្រោះយល់ពីកំហិតនៃការការពារ និងមិនត្រូវបានលួងលោមឱ្យសហការដោយផ្អែកលើ**ការសន្យាក្លែងក្លាយ ឬខុសការពិត** ទាក់ទងនឹងសុវត្ថិភាពរបស់ពួកគេ និងរបស់គ្រួសារ។

<u>**ការការពារនៅក្នុងតុលាការ៖**</u> ការគាំទ្រ និងការការពារសាក្សីត្រូវពង្រីកទៅដល់ដំណើរការជំនុំជម្រះ និងហួសពីនេះទៀត។ ជនរងគ្រោះពីការជួញដូរមនុស្សនឹងមានការអល់អែកក្នុងការផ្ដល់ភស្តុតាង ប្រសិនបើការផ្ដល់ភស្តុតាងធ្វើឱ្យពួកគេត្រូវបានបង្ហាញអត្តសញ្ញាណដោយបណ្ដាញសារព័ត៌មាន ឬឈរនៅក្នុងបន្ទប់សវនាការជាសាធារណៈ ជារឿយៗ នៅចំពោះមុខជនកេងប្រវ័ញ្ចមកលើពួកគេ និងនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនដែលធ្វើឱ្យប៉ះទង្គិចផ្លូវចិត្ត។ ពួកគេក៏អាចប្រឈមនឹងហានិភ័យពិតប្រាកដពីការសងសឹក និងការបំភិតបំភ័យដែរ។ ជាការសំខាន់ដែលថា ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិ ត្រូវស្វែងរកវិធីនានា ដើម្បីជួយដល់ជនរងគ្រោះពីការជួញដូរមនុស្សឱ្យបានចូលរួមទៅក្នុងដំណើរការតុលាការយ៉ាងមានសុវត្ថិភាព និងប្រកបដោយអត្ថន័យខ្លឹមសារ។

<u>**ការការពារឯកជនភាព៖**</u> គឺជាទិដ្ឋភាពសំខាន់នៃការការពារជនរងគ្រោះ។ ដូចបានលើកឡើងនៅក្នុង*គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន*ថា៖

[១៣៧] UNTOC មាត្រា ២៤។ សូមមើលផងដែរ គោលការណ៍ណែនាំ ACWC ចំណុច ៣.៦.៥ និង ៣.៦.៦។

អ្នកប្រតិបត្តិត្រូវវាយតម្លៃអំពីលក្ខណៈ និងកម្រិតនៃហានិភ័យ និងចាត់វិធានការនានាដើម្បីគ្រប់គ្រងហានិភ័យដែលបានរកឃើញចំពោះជនរងគ្រោះ និងអ្នកផ្សេងទៀតដែលពាក់ព័ន្ធ។ សុវត្ថិភាព និងសុខុមាលភាពរបស់សាក្សីជាជនរងគ្រោះតម្រូវឱ្យការពារដល់ឯកជនភាពរបស់ពួកគេ[១៣៨]។

**ផ្តល់ការគាំទ្រ ជំនួយ និងព័ត៌មាន៖** ជនរងគ្រោះពីការជួញដូរមនុស្សគ្រប់រូបដែលចូលរួមនៅក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ចំពោះជនកេងប្រវ័ញ្ចមកលើពួកគេគួរទទួលបានការគាំទ្រ និងជំនួយគ្រប់គ្រាន់ សម្រាប់រយៈពេលដែលពួកគេចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ពួកគេក៏គួរបានទទួលផងដែរនូវព័ត៌មានស្តីពីសិទ្ធិរបស់ខ្លួន និងដំណើរការតាមផ្លូវច្បាប់ជាភាសា និងលក្ខណៈដែលពួកគេយល់បាន[១៣៩]។ ការផ្តល់នូវការប្រឹក្សាផ្លូវច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះជាសាក្សី ក៏ជាវិធីមួយទៀតដើម្បីគាំទ្រដល់ការចូលរួមរបស់ពួកគេទៅក្នុងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌដែរ។

**ការសម្របសម្រួលនូវការផ្តល់សក្ខីកម្ម៖** *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ទទួលស្គាល់នូវសារៈសំខាន់ នៃជម្រើសនានាជំនួសឱ្យការផ្តល់សក្ខីកម្ម ដោយផ្ទាល់ដែលមានគោលបំណងការពារអត្តសញ្ញាណ ឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់សាក្សី។ គោលការណ៍ណែនាំក៏បានកំណត់អំពីវិធានការបន្ថែមដែលអាចយកមកប្រើប្រាស់ដើម្បីបង្កើនការចូលរួមរបស់ជនរងគ្រោះប្រកបដោយផលិតភាព ទៅក្នុងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌប្រឆាំងនឹងអ្នកជួញដូរមនុស្សគឺថា៖

> ដើម្បីឱ្យការជំនុំជម្រះកាត់បន្ថយនូវភាពតានតឹង សម្រាប់ការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះជាសាក្សី គួរតែស្វែងរកឱ្យមានជម្រើសនានាមួយចំនួនជំនួសឱ្យការផ្តល់សក្ខីកម្មនៅក្នុងតុលាការជាចំហរ។ ជម្រើសទាំងនោះអាចបញ្ចូលនូវកាលានុវត្តភាពនៃការផ្តល់សក្ខីកម្ម តាមរយៈអេក្រង់ទូរទស្សន៍ ឬនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការជាអសាធារណៈ ឬតាមមធ្យោបាយសោតទស្សន៍ផ្សេងៗទៀត[១៤០]។ មធ្យោបាយគាំទ្រតុលាការបែបងាយៗផ្សេងទៀតរួមមាន៖ ការទស្សនាបន្ទប់សវនាការមុនពេលជំនុំជម្រះ ការអមដំណើរចូល និងចេញពីអាគារតុលាការ ការប្រើប្រាស់ច្រកចូលអាគារតុលាការដាច់ដោយឡែក កន្លែងរង់ចាំដោយឡែក និងការផ្តល់ព័ត៌មានជាប្រចាំពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះពីភាគីអយ្យការ នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការទាំងមូល[១៤១]។

> នៅពេលបង្កើតប្រព័ន្ធ និងដំណើរការជំរុញការចូលរួមរបស់ជនរងគ្រោះទៅក្នុងដំណើរការតុលាការ ជាការសំខាន់ត្រូវចងចាំថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវឱ្យប៉ះពាល់តាមវិធីណាមួយឡើយ[១៤២]។

---

[១៣៨] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ២.៤។

[១៣៩] ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៦។ គោលការណ៍ និងគោលការណ៍ណែនាំ អ.ស.ប ប្រឆាំងការជួញដូរ គោលការណ៍ណែនាំលេខ ៦។ គោលការណ៍ណែនាំ ACWC ៣.៦.៥។

[១៤០] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ២.៧។

[១៤១] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ២.៧។

[១៤២] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ២.៨។ គោលការណ៍ និងគោលការណ៍ណែនាំ អ.ស.ប ប្រឆាំងការជួញដូរ គោលការណ៍ណែនាំលេខ ៦.៦។

**ការពន្លឿនកិច្ចដំណើរការនីតិវិធី៖** *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ក៏បានទទួលស្គាល់នូវគ្រោះថ្នាក់ពាក់ព័ន្ធនឹងការជំនុំជម្រះរយៈពេលយូរ និងសារៈសំខាន់ នៃការពន្លឿនកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែរ ដើម្បី "កាត់បន្ថយភាពតានតឹង និងសម្ពាធដែលធ្លាក់ទៅលើជនរងគ្រោះដែលរង់ចាំអស់រយៈពេលយ៉ាងយូរ ដើម្បីផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ"[១៤៣]។ គោលការណ៍ណែនាំបានលើកឡើងបន្ថែមថា៖

> *ជាប្រយោជន៍យុត្តិធម៌ និងការការពារជនរងគ្រោះ ការជំនុំជម្រះពាក់ព័ន្ធនឹងការជួញដូរមនុស្ស គួរត្រូវចាប់ផ្តើម និងបញ្ចប់ដោយគ្មានការពន្យារពេលឥតប្រយោជន៍។ គួរពិចារណាដល់យន្តការនានាដែរ ដូចជាសវនាការបឋមមុនអង្គសេចក្តី ក្នុងករណីសមស្រប[១៤៤]។*

ការផ្តល់ការប្រឹក្សាផ្លូវច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះជាសាក្សីគឺជាវិធីមួយទៀតដែលអាចគាំទ្រដល់ការចូលរួមរបស់ពួកគេទៅក្នុងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌបាន។

**បទប្បញ្ញត្តិពិសេសសម្រាប់សាក្សីជាកុមារ៖** គួរមានបទប្បញ្ញត្តិច្បាប់ពិសេសដែលគ្រប់គ្រងដល់ការចូលរួមរបស់កុមារ ទៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ប្រឆាំងជនជួញដូរមនុស្ស ដែលឆ្លុះបញ្ចាំងនូវគោលការណ៍ "ឧត្តមប្រយោជន៍" ដែលមានរៀបរាប់នៅក្នុង*អនុសញ្ញា អ.ស.ប ស្តីពីសិទ្ធិកុមារ* (ពោលគឺថា រាល់សេចក្តីសម្រេចទាំងអស់ដែលបានធ្វើឡើង និងសកម្មភាពនានាដែលបានធ្វើទាក់ទងនឹងកុមារ នៅក្នុងបរិបទនោះគួរផ្តល់អាទិភាពដល់ឧត្តមប្រយោជន៍របស់ពួកគេ)។ កាន់តែទូទៅជាងនេះគឺថា សាក្សីជាកុមារត្រូវស្ថិតក្រោមវិធានការពិសេសក្នុងគោលបំណងធានាដល់ឯកជនភាព សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ ដោយគិតដល់អាយុ និងដំណាក់កាលអភិវឌ្ឍន៍របស់ពួកគេ[១៤៥]។

**ការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះមិនចាំបាច់ត្រូវធ្វើលឿនពេកទេ៖** លុះត្រាតែពួកគេសម្តែងនូវបំណងប្រាថ្នាចង់វិលត្រឡប់មកផ្ទះវិញនៅក្នុងពេលកំពុងធ្វើអន្តរាគមន៍ មិនពុំដូច្នោះទេ ជនរងគ្រោះជាសាក្សីមិនគួរត្រូវបានធ្វើមាតុភូមិនិវត្តន៍ទេ រហូតទាល់តែបញ្ចប់កិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ដែលពាក់ព័ន្ធសិន។ ក្រោយពេលទទួលបានសំណងជួសជុលយ៉ាងជោគជ័យរួច និងក្រោយពេលដែលមានការវាយតម្លៃថាការវិលត្រឡប់នោះមានសុវត្ថិភាព[១៤៦]។ ក្នុងការអនុវត្តន៍ជាក់ស្តែង ចំណុចនេះមានន័យថា រដ្ឋត្រូវស្វែងរកវិធីដើម្បីកំណត់អំពីស្ថានភាពគតិយុត្តិរបស់ជនរងគ្រោះបរទេស ដែលជាទូទៅមិនបានកំណត់ដល់ពួកគេទេ។ ច្បាប់អន្តរជាតិទទួលស្គាល់ថា ការធ្វើមាតុភូមិនិវត្តន៍ឆាប់រហ័សពេក ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការបង្ហាញខ្លួន និងក្នុងការបញ្ចេញមតិរបស់ខ្លួនក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់។ ប្រសិនបើជនរងគ្រោះពិតជាមានបំណងចង់វិលត្រឡប់ទៅផ្ទះវិញមែន ពួកគេគួរទទួលបានជំនួយក្នុងការធ្វើមាតុភូមិនិវត្តន៍យ៉ាងមានសុវត្ថិភាព និងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

---

[១៤៣] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១៖ ផ្នែក ១៖ កថាខណ្ឌ ២.៦។

[១៤៤] *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ២.៦។ សវនាការមុនអង្គសេចក្តី នៅក្នុងបរិបទនេះអាចបញ្ចូលនូវយន្តការនានាដូចជាការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ ដូចបានពិភាក្សាលម្អិតនៅក្នុងជំពូកទី ៤។

[១៤៥] ចំណុចនេះត្រូវបានទទួលស្គាល់នៅក្នុង *គោលការណ៍ និងគោលការណ៍ណែនាំ អ.ស.ប ប្រឆាំងការជួញដូរ* គោលការណ៍ណែនាំលេខ ៨.៨។

[១៤៦] ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៨។

**ជួយដល់ការវិលត្រឡប់របស់សាក្សីជាជនរងគ្រោះ៖** ជនរងគ្រោះដែលបានវិលត្រឡប់ទៅផ្ទះវិញ អាចត្រូវបានតម្រូវឲ្យវិលត្រឡប់មកប្រទេសដែលពួកគេរងការកេងប្រវ័ញ្ច ដើម្បីចូលរួមនៅក្នុងការចោទប្រកាន់ទៅលើជនជួញដូរមនុស្សមកលើពួកគេ។ ចំណុចនេះតម្រូវឲ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងរដ្ឋពាក់ព័ន្ធទាំងពីរ។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* បានចែងដូចខាងក្រោម៖

រដ្ឋនីមួយៗត្រូវជំរុញឲ្យជនរងគ្រោះពីការជួញដូរមនុស្ស ចូលដោយស្ម័គ្រចិត្ត និងស្នាក់នៅបណ្តោះអាសន្ននៅក្នុងទឹកដីនៃភាគីទទួល តាមរយៈកិច្ចសហការក្រៅផ្លូវការ ឬជំនួយផ្នែកច្បាប់ទៅវិញទៅមក ក្នុងករណីសមស្រប អនុលោមទៅតាមច្បាប់ជាតិរបស់ភាគីបញ្ជូន និងទទួល ក្នុងគោលបំណងផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសហការតាមវិធីផ្សេងទៀតនៅក្នុងការចោទប្រកាន់ជនជួញដូរមកលើពួកគេ ដោយគិតទៅដល់សុវត្ថិភាពរបស់ជនរងគ្រោះពីការជួញដូរមនុស្ស។ **មាត្រា ១៦(៥)**[១៤៧]

# ៦.២ វឌ្ឍនភាពរបស់អាស៊ានទាក់ទងនឹងការគាំទ្រជនរងគ្រោះជាសាក្សី

ផ្នែកនេះសង្ខេបអំពីវឌ្ឍនភាពសំខាន់ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ទាក់ទងនឹងការគាំទ្រដល់សាក្សីជាជនរងគ្រោះ។ ក៏ប៉ុន្តែ បញ្ហាទាក់ទងនិងការមានព័ត៌មានតិចតួច ដូចបានពន្យល់លម្អិតនៅក្នុងជំពូកមុនៗ ក៏មានដូចគ្នាដែលនៅក្នុងវិស័យនេះ។ ព័ត៌មានជាច្រើនដែលរកបាន គឺទាក់ទងនឹងច្បាប់ និងគោលនយោបាយដោយគេត្រឹមតែអាចធានាបាននូវព័ត៌មានស៊ីជម្រៅតិចតួច ឧទាហរណ៍ អំពីរបៀបទំនាក់ទំនងរវាងច្បាប់ និងគោលនយោបាយទាំងនេះទៅនឹងការការពារឯកជនភាព ការផ្តល់ព័ត៌មាន និងសិទ្ធិក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី នៅក្នុងការអនុវត្តន៍ជាក់ស្តែង។ ព័ត៌មានតិចតួចដែលអាចបញ្ជាក់បានស្តីពីរបៀបដែលរដ្ឋសមាជិកអាស៊ានគាំទ្រដល់ជនរងគ្រោះជាសាក្សីមានន័យថា សេចក្តីសង្ខេបខាងក្រោមនេះ គ្រាន់តែមួយផ្នែកទេ ដោយផ្តោតជាពិសេសទៅលើការផ្លាស់ប្តូរក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយទាក់ទងនឹងការគាំទ្រដល់ជនរងគ្រោះជាសាក្សី និងគូសបញ្ជាក់នូវវិសាលភាពពាក់ព័ន្ធជាច្រើននៃវឌ្ឍនភាពទាក់ទងនឹងព័ត៌មានមួយចំនួនដែលរកបាន ដូចករណីនៅក្នុងការកែសម្រួលទៅលើ *របាយការណ៍វឌ្ឍនភាព* លើកមុនដែរ។

វាក៏មានការពាក់ព័ន្ធផងដែរដែលត្រូវកត់សម្គាល់ថា ទោះបីជំពូកនេះ ដោះស្រាយអំពីបទពិសោធន៍របស់ *ជនរងគ្រោះ* នៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ តែចំណុចខ្លាំង និងប្រសិទ្ធិភាពនៃដំណើរការនោះ ដែលពាក់ព័ន្ធខ្លាំងដល់ជនរងគ្រោះ និងការចូលរួមរបស់ពួកគេ។ ព័ត៌មានដែលអាចរកបាន បង្ហាញអំពីការប្រឈមជាច្រើន រួមមាន៖ ការ

---

[១៤៧] កត់សម្គាល់ថា *ផែនការសកម្មភាពអាស៊ាន* ដោះស្រាយយ៉ាងហោចណាស់ជានិមិត្តរូប នូវបញ្ហានៃការចំណាយពាក់ព័ន្ធនឹងការវិលត្រឡប់របស់ជនរងគ្រោះដើម្បីមកផ្តល់សក្ខីកម្ម ដោយអះអាងនូវភាពចាំបាច់ចំពោះរដ្ឋសមាជិកអាស៊ានឲ្យ៖ "លះបង់ទៅតាមវិសាលភាពដែលច្បាប់ជាតិបានកំណត់ នូវប្រាក់ចំណាយផ្នែកអន្តោប្រវេសន៍ ដើម្បីជួយសម្រួលដល់ការចូល និងការស្នាក់នៅបណ្តោះអាសន្នរបស់ជនរងគ្រោះពីការជួញដូរមនុស្ស នៅក្នុងទឹកដីនៃរដ្ឋសមាជិកអាស៊ាន ក្នុងគោលបំណងផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសហការតាមវិធីផ្សេងទៀតក្នុងការចោទប្រកាន់ជនជួញដូរ"។ *ផែនការសកម្មភាពអាស៊ាន* វគ្គ IV(C)(j)។

យល់ដឹងមិនស្មើគ្នារបស់មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌចំពោះទស្សនៈសំខាន់ ការត្រៀមជនរងគ្រោះជាសាក្សីមិនបានពេញលេញ ទំនាក់ទំនង និងការប្រាស្រ័យទាក់ទងការងារមិនល្អរវាងបុគ្គលិកផ្នែកអនុវត្តន៍ច្បាប់/តុលាការ និងជនរងគ្រោះជាសាក្សី និង ការយល់ដឹងទាបក្នុងចំណោមបុគ្គលិកផ្នែកអនុវត្តន៍ច្បាប់ និងបុគ្គលិកតុលាការ ពីឥទ្ធិពលនៃការប៉ះទង្គិចផ្លូវចិត្តមកលើជនរងគ្រោះ។ ជារឿយៗ សំណុំរឿងជួញដូរមនុស្សមានការលំបាកក្នុងការចោទប្រកាន់ឲ្យបានជោគជ័យ ទោះបីស្ថិតក្រោមកាលៈទេសៈល្អបំផុតក្តី។ តែមានភស្តុតាងមួយចំនួនបង្ហាញពីបញ្ហានានា នៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ រួមមាន កង្វះភស្តុតាងរឹងមាំ ដែលបណ្តាលឲ្យលើកលែងការចោទប្រកាន់ និងអត្រានៃការផ្តន្ទាទោសទាប។ អត្រានៃការផ្តន្ទាទោសទាប (ដូចបានជួបប្រទេសនៅ**ប្រទេសម៉ាឡេស៊ី**ក្នុងឆ្នាំ២០១៥) អាចជាការជំរុញជាខ្លាំងមិនឲ្យជនរងគ្រោះសហការក្នុងការចោទប្រកាន់ជនជួញដូរមនុស្ស មកលើពួកគេ ជាពិសេស ដោយសារសំណុំរឿងភាគច្រើនទំនងជាចំណាយពេលយូរ ហើយការណ៍ដែលថា ជារឿយៗជីវិតរបស់ជនរងគ្រោះ ត្រូវស្ថិតនៅទ្រឹងក្នុងអំឡុងពេលនោះ។ ជាការសំខាន់ដែលត្រូវទទួលស្គាល់ថា មានការព្រួយបារម្ភខុសៗគ្នាបានកើតឡើង នៅតាមប្រទេសនានាដែលអត្រា ផ្តន្ទាទោសមានកម្រិតខ្ពស់ខ្លាំង ហើយនៅពេលមានសញ្ញាណថា ការចោទប្រកាន់ត្រូវបានធានា នៅពេលពុំមានភស្តុតាងរឹងមាំ។

## វត្តមានភាពទាក់ទងនឹងសិទ្ធិមកបង្ហាញខ្លួន និងទទួលការពិចារណាទៅលើយោបល់របស់ជនរងគ្រោះ

នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន ច្បាប់ពាក់ព័ន្ធមិនបានផ្តល់សិទ្ធិ ដោយផ្ទាល់ដល់ជនរងគ្រោះក្នុងការមកបង្ហាញខ្លួន និងទទួលការពិចារណាទៅលើយោបល់របស់ខ្លួនទេ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទពីការជួញដូរមនុស្ស។ ក៏ប៉ុន្តែ នៅក្នុងសំណុំរឿងមួយចំនួន សិទ្ធិនេះអាចរកឃើញនៅក្នុងលិខិតូបករណ៍មិនមែនគតិយុត្ត ឬនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌទូទៅ។ ឧទាហរណ៍ នៅ**ប្រទេសកម្ពុជា** ទោះបីច្បាប់ស្តីពីការជួញដូរមនុស្ស មិនបានដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌក៏ដោយ តែគោលការណ៍ណែនាំរដ្ឋបាលអះអាងពីសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្សក្នុងការបង្ហាញខ្លួន និងទទួលការពិចារណាទៅលើយោបល់របស់ពួកគេ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទពីបទល្មើសជួញដូរមនុស្ស[១៤៨]។ ជនរងគ្រោះពីការជួញដូរមនុស្សអាចមានសិទ្ធិមួយចំនួនក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌធម្មតារបស់**ប្រទេសឡាវ** និង**វៀតណាម**។ ឧទាហរណ៍ នៅ**ប្រទេសវៀតណាម** មាត្រា ៥១ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ*ចែងថា ជនរងគ្រោះនៃបទល្មើស (ពោលគឺ ជនដែលបានទទួលរងរបួសផ្លូវកាយ ឬផ្លូវចិត្ត ឬបាត់បង់ទ្រព្យសម្បត្តិដែលបណ្តាលមកពីបទល្មើស) ឬអ្នកតំណាងតាមច្បាប់របស់ពួកគេមានសិទ្ធិជាច្រើន រួមមាន សិទ្ធិចូលរួមនៅក្នុងពេលសវនាការនៅតុលាការ និងសិទ្ធិប្តឹង ឬប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រម។ ក៏ប៉ុន្តែសិទ្ធិទាំងនេះអាចមិនពេញលេញ ដើម្បីគាំទ្រដល់ការអនុវត្តន៍ជាក់ស្តែងជាវិជ្ជមានទេ។

ដូចបានកត់សម្គាល់ខាងលើ សិទ្ធិបង្ហាញខ្លួន និងទទួលការពិចារណាទៅលើយោបល់របស់អ្នកណាម្នាក់ មិនគួរភាន់ច្រឡំទៅនឹងកាតព្វកិច្ចនៃការចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការទេ។ ជាវិធានទូទៅនៃការអនុវត្តន៍ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌដែលល្អ ជនរងគ្រោះមិនត្រូវបានបង្ខិតបង្ខំឲ្យមកផ្តល់សក្ខីកម្មប្រឆាំងនឹងជនកេងប្រវ័ញ្ចមកលើពួក

---

[១៤៨] (មាត្រា ៦ ប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការការពារសិទ្ធិរបស់ជនរងគ្រោះពីការជួញដូរមនុស្ស)។

គេទេ។ ការបង្ខិតបង្ខំជនរងគ្រោះតាមវិធីនេះអាចធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ ហើយទំនងជាផ្តល់លទ្ធផលមិនល្អផង។

*ប្រអប់អត្ថបទ ២៣៖ ឧទាហរណ៍អនុវត្តន៍៖*
*ការធានានូវសិទ្ធិរបស់ជនរងគ្រោះក្នុងការបង្ហាញខ្លួន និងការស្តាប់យោបល់របស់ពួកគេ*

នៅ**ប្រទេសមីយ៉ាន់ម៉ា** មន្ត្រីបានរាយការណ៍អំពីការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរវាងអ្នករស់រានពីការជួញដូរមនុស្ស ដែលនៅពេលនោះ ជនរងគ្រោះត្រូវបានជំរុញឲ្យចែករំលែកនូវបទពិសោធន៍របស់ខ្លួន ក្នុងគោលបំណងផ្តល់ឥទ្ធិពលជាវិជ្ជមានទៅលើគោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែង។ គំនិតផ្តួចផ្តើមផ្សេងទៀត រួមមាន ការផ្តល់សម្ភារព័ត៌មាន

ក្រោម*ក្រមនីតិវិធីព្រហ្មទណ្ឌ*របស់**ប្រទេសឡាវ** សាក្សីមានសិទ្ធិផ្តល់សក្ខីកម្ម និងទទួលការការពារពីការគំរាមកំហែងនានាដោយសារសក្ខីកម្មរបស់ខ្លួន។ ជាងនេះទៀត *កិច្ចព្រមព្រៀងរវាង**ប្រទេសឡាវ និងវៀតណាម**ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការការពារជនរងគ្រោះពីការជួញដូរមនុស្ស (ឆ្នាំ ២០១០)* អាចឲ្យជនរងគ្រោះជាជនជាតិវៀតណាមនៅក្នុងប្រទេសឡាវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ ដោយទទួលបានការការពារ និងជំនួយដូចគ្នាដែលមានចំពោះជនរងគ្រោះជាជនជាតិឡាវដែរ។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ជនរងគ្រោះពីការជួញដូរមនុស្ស ត្រូវបានដកចេញជាប្រចាំពីបន្ទប់សវនាការ។ ការប្រឈមក្នុងការអនុវត្តន៍អាចទាក់ទងនឹងសមត្ថភាពផ្លូវច្បាប់ ដែលមានកម្រិតនៅក្នុងប្រទេសដែលកាន់សំណុំរឿងជួញដូរមនុស្ស[១៤៩]។ ចំណុចនេះធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (សិទ្ធិសួរដេញដោលសាក្សី) ព្រមទាំងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចមកលើពួកគេ។

## វឌ្ឍនភាពទាក់ទងនឹងការការពារឯកជនភាពរបស់សាក្សីជាជនរងគ្រោះ

រដ្ឋសមាជិកអាស៊ានបានផ្តល់នូវការការពារជាទូទៅដល់ឯកជនភាពសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស។ ក្នុងការទទួលស្គាល់នូវភាពងាយរងគ្រោះដ៏ធំធេងរបស់ពួកគេ និងតម្រូវការចាំបាច់បន្ថែម រដ្ឋសមាជិកអាស៊ានផ្សេងទៀតបានបំពេញបន្ថែមនូវបទប្បញ្ញត្តិនៃឯកជនភាពជាទូទៅមួយដោយមានការការពារបន្ថែម ក្នុងគោលបំណងផ្តល់ដោយផ្ទាល់ដល់ជនរងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា នៅក្នុងប្រទេសមួយចំនួន ការការពារឯកជនភាពសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សអាចរកឃើញ ឬពង្រឹងបន្ថែមទៀតនៅក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ឬច្បាប់ឯកទេសនានា ដូចជា ច្បាប់ពាក់ព័ន្ធនឹងការការពារកុមារជាដើម។ តារាងខាងក្រោមផ្តល់នូវសេចក្តីសង្ខេបនៃបទប្បញ្ញត្តិច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានស្តីពីការការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សី។ គួរកត់សម្គាល់ថា តារាងនេះពុំមានបញ្ចូលវិធានការមិនមែនច្បាប់ ដូចជាគោលការណ៍ណែនាំ ដែលអាចមាននៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗទេ។

---

[១៤៩] របាយការណ៍ពីប្រទេសឡាវ (ខែធ្នូ ឆ្នាំ២០១៥)។

*តារាង ៨៖ ការការពារតាមផ្លូវច្បាប់ចំពោះឯកជនភាពរបស់ជនរងគ្រោះជាសាក្សី*

| | បុរសពេញវ័យ | ស្ត្រីពេញវ័យ | កុមារ (អាយុក្រោម ១៨ ឆ្នាំ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ) |
|---|---|---|---|
| ប្រ៊ុយណេ | ច្បាប់ស្តីពីការជួញដូរមនុស្សរបស់ប្រទេសប្រ៊ុយណេ មិនមានចែងនូវការការពារជាក់លាក់ទាក់ទងនឹងឯកជនភាពរបស់ជនរងគ្រោះ និងជនរងគ្រោះជាសាក្សីទេ។ ក៏ប៉ុន្តែច្បាប់នានាដូចជា *ច្បាប់ស្តីពីតុលាការកំពូល* និង *ច្បាប់ស្តីពីតុលាការថ្នាក់ក្រោម* អាចឲ្យតុលាការរក្សាឯកជនភាព រួមមាន តាមរយៈការបើកសវនាការជាអសាធារណៈ និងការពារអត្តសញ្ញាណរបស់សាក្សី។ | | ក្រោម *ច្បាប់ស្តីកុមារ និងមនុស្សវ័យក្មេង* ការផ្សព្វផ្សាយ ឬនាំឲ្យមានការផ្សព្វផ្សាយឈ្មោះ ឬព័ត៌មានអត្តសញ្ញាណផ្សេងទៀតរបស់កុមារ ឬមនុស្សវ័យក្មេងដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីតុលាការ គឺជាបទល្មើសព្រហ្មទណ្ឌ[១៥០]។ |
| កម្ពុជា | *ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស* ហាមឃាត់កាសែត និងបណ្តាញសារព័ត៌មានមហាជនទាំងអស់ផ្សេងទៀត មិនឲ្យបោះពុម្ពផ្សាយ ប្រកាសផ្សាយ ឬផ្សព្វផ្សាយព័ត៌មាននានាដែលអាចនាំឲ្យសាធារណជនដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ[១៥១]។ ច្បាប់សារព័ត៌មានរបស់កម្ពុជាក៏មានបទប្បញ្ញត្តិដែលការពារដល់ឯកជនភាពរបស់ជនរងគ្រោះដែរ។ | | |
| ឥណ្ឌូនេស៊ី | *ច្បាប់ស្តីពីការលុបបំបាត់ការជួញដូរមនុស្ស* ធានានូវភាពអនាមិកក្នុងអំឡុងពេលស៊ើបអង្កេត និងដំណើរការតុលាការសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សទាំងអស់ ព្រមទាំងសិទ្ធិរបស់ពួកគេក្នុងការរក្សាការសម្ងាត់ និងការការពារអត្តសញ្ញាណពួកគេ[១៥២]។ *ច្បាប់ការពារកុមារ*ចែងថា "កុមារគ្រប់រូបដែលជាជនរងគ្រោះពីបទល្មើស មានសិទ្ធិទទួលបានការការពារអត្តសញ្ញាណរបស់ខ្លួនពីសារព័ត៌មាន" ដែលអនុវត្តចំពោះជនរងគ្រោះពីបទល្មើសជួញដូរ[១៥៣]។ | | |
| ឡាវ | ច្បាប់ស្តីពីការជួញដូរមនុស្ស ឆ្នាំ២០១៥ របស់ឡាវផ្តល់ការការពារជនភាពដល់ជនរងគ្រោះពីការជួញដូរមនុស្សគ្រប់រូប។ | | *ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារស្ត្រី (ឆ្នាំ២០០៤)* ចែងថា ស្ត្រី និងកុមាររងគ្រោះពីការជួញដូរមនុស្សមានសិទ្ធិមិនត្រូវបានថតរូប ថតវីដេអូ ឬផ្សាយនៅលើទូរទស្សន៍ដែលនឹង "ប៉ះពាល់ដល់កិត្តិយសផ្ទាល់របស់ពួកគេ។ នគរបាលត្រូវរក្សាការសម្ងាត់ដល់ជនរងគ្រោះ និងសាក្សីដែលចូលរួមនៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់នូវសំណុំរឿងព្រហ្មទណ្ឌនៃការជួញដូរមនុស្សទៅលើស្ត្រី និងកុមារ។ ក្រៅពីនេះ ការការពារឯកជនភាពក៏ត្រូវបាន ផ្តល់ដោយស្ថានទូត ឬស្ថានកុងស៊ុលឡាវដែលពាក់ព័ន្ធដល់ជនរងគ្រោះនៅបរទេសដែលជាពលរដ្ឋឡាវ និង |

---

[១៥០] បទបញ្ញាស្តីពីកុមារ និងមនុស្សវ័យក្មេង (ឆ្នាំ២០០៦) (ប្រ៊ុយណេ) ផ្នែក ៩៥។

[១៥១] ច្បាប់ស្តីពីការបង្ក្រាបអំពីជួញដូរមនុស្ស (កម្ពុជា) មាត្រា ៤៩។

[១៥២] ច្បាប់ស្តីពីការលប់បំបាត់ការជួញដូរមនុស្ស (ឥណ្ឌូនេស៊ី) មាត្រា ២៤, ៣៣, ៤៤។

[១៥៣] *ច្បាប់ការពារកុមារ* (ឥណ្ឌូនេស៊ី) មាត្រា ៦៤។

| | បុរសពេញវ័យ | ស្ត្រីពេញវ័យ | កុមារ (អាយុក្រោម ១៨ ឆ្នាំ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ) |
|---|---|---|---|
| | | | ដោយមន្ត្រីឡាវចំពោះជនរងគ្រោះបរទេសនៅក្នុងប្រទេសឡាវ[១៥៤]។ *ច្បាប់ស្តីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ* ចែងថាកុមាររងគ្រោះ និងសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានការការពារចំពោះឯកជនភាពរបស់ខ្លួន។ ជនណាដែលបញ្ចេញអត្តសញ្ញាណ ឬព័ត៌មានផ្ទាល់ខ្លួនរបស់កុមារជាជនរងគ្រោះ ជនសង្ស័យ ចុងចោទ ឬទណ្ឌិត អាចទទួលទោសទណ្ឌ[១៥៥]។ |
| ម៉ាឡេស៊ី | *ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (ឆ្នាំ២០០៧)* [ច្បាប់លេខ ៦៧០] ទប់ស្កាត់មិនឲ្យសារព័ត៌មានបញ្ចេញព័ត៌មានលម្អិតនានាដែលអាចនាំឲ្យបញ្ចេញនូវអត្តសញ្ញាណរបស់បុគ្គលដែលជាជនរងការជួញដូរមនុស្ស ឬសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីនានា (ផ្នែក ៥៨)។ | | *ច្បាប់ស្តីពីភស្តុតាងរបស់សាក្សីជាកុមារឆ្នាំ ២០០៧* ហាមឃាត់មិនឲ្យមានការផ្សព្វផ្សាយព័ត៌មានដែលនឹងបញ្ចេញអត្តសញ្ញាណរបស់សាក្សីជាកុមារ*ណាម្នាក់*[១៥៦] ដែលអនុវត្តចំពោះសាក្សីជាកុមាររងគ្រោះនៅក្នុងសំណុំរឿងជួញដូរ។ |
| មីយ៉ាន់ម៉ា | ពុំមានបទប្បញ្ញត្តិអនុវត្តចំពោះជនរងគ្រោះ ជាបុរសពេញវ័យទេ ទោះបីច្បាប់ព្រហ្មទណ្ឌនៅមីយ៉ាន់ម៉ាអនុវត្តចំពោះការជួញដូរមនុស្សទៅលើបុរស ស្ត្រី និងកុមារ ក៏ដោយ។ | *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* តម្រូវឲ្យការពារដល់ឯកជនភាពរបស់ "ស្ត្រី កុមារ និងយុវវ័យ" ជនរងគ្រោះពីការជួញដូរមនុស្ស[១៥៧]។ នៅក្នុងដំណើរការជំនុំជម្រះលើការជួញដូរមនុស្ស ប្រសិនបើជនរងគ្រោះជាស្ត្រី កុមារ និងយុវវ័យ តុលាការត្រូវបើកសវនាការជាអាសធារណៈ និងត្រូវស្នើសុំនូវការអនុញ្ញាតពិសេសដើម្បីចុះផ្សាយនូវ "ព័ត៌មាននៅក្នុងដំណាក់កាលនានានៃការស៊ើបអង្កេត ការចោទប្រកាន់ និងការវិនិច្ឆ័យទោស"[១៥៨]។ | |
| ហ្វីលីពីន | *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* អនុញ្ញាតឲ្យមានការស៊ើបអង្កេត ការចោទប្រកាន់ ឬការជំនុំជម្រះជាអសាធារណៈ ប្រសិនបើផ្នែកអនុវត្តន៍ច្បាប់ ព្រះរាជអាជ្ញា ឬចៅក្រមយល់ឃើញថាជាការចាំបាច់។ ឈ្មោះ និងកាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងការជួញដូរមនុស្ស ឬព័ត៌មានផ្សេងទៀតដែលមានបំណងបង្ហាញពីអត្តសញ្ញាណរបស់ពួកគេ និងកាលៈទេសៈទាំងនេះ ឬព័ត៌មាននានាមិនត្រូវបញ្ចេញជាសាធារណៈទេស។ | | | |

---

[១៥៤] *ច្បាប់ស្តីពីការអភិវឌ្ឍន៍ និងការការពារស្ត្រី* (ឆ្នាំ២០០៤) (ឡាវ) មាត្រា ២៥(៧), ២៧, ២៨។ នាយករដ្ឋមន្ត្រី ១៨។

[១៥៥] ច្បាប់ស្តីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ (ឆ្នាំ២០០៧) (ឡាវ) មាត្រា ៤៤, ៨៥។

[១៥៦] ច្បាប់ស្តីពីភស្តុតាងរបស់សាក្សីជាកុមារឆ្នាំ២០០៧ (ម៉ាឡេស៊ី) ច្បាប់លេខ ៦៧៦ ផ្នែក ១៤។

[១៥៧] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (ច្បាប់លេខ ៥/២០០៥) (មីយ៉ាន់ម៉ា) ផ្នែក ១៦។

[១៥៨] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (ច្បាប់លេខ ៥/២០០៥) (មីយ៉ាន់ម៉ា) ផ្នែក ១១(ខ)។ កត់សម្គាល់ថា វិសាលភាពចំពោះពាក្យ "ព័ត៌មាន" ពុំច្បាស់លាស់ទេ។

| | បុរសពេញវ័យ | ស្ត្រីពេញវ័យ | កុមារ (អាយុក្រោម ១៨ ឆ្នាំ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ) |
|---|---|---|---|
| | វិសោធនកម្មឆ្នាំ២០១២ ទៅលើច្បាប់នេះអនុញ្ញាតឲ្យយកឈ្មោះជនសង្ស័យថាជាអ្នកជួញដូរមនុស្សទៅរាយការណ៍ និងផ្សព្វផ្សាយជាសាធារណៈសម្រាប់ការស៊ើបអង្កេត។ | | |
| សិង្ហបុរី | នៅប្រទេសសិង្ហបុរី កិច្ចដំណើរការនីតិវិធីតុលាការដែលពាក់ព័ន្ធនឹងជនរងគ្រោះពីការជួញដូរមនុស្ស ដែលត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ អាចផ្តល់សក្ខីកម្ម "ជាអសាធារណៈ" បាន។ នៅពេលជនរងគ្រោះជាកុមារ កិច្ចដំណើរការនីតិវិធីតុលាការត្រូវដំណើរការ "ជាអសាធារណៈ"។ មានការហាមឃាត់ផងដែរ ស្តីពីការផ្សព្វផ្សាយព័ត៌មាន ដែលទំនងជាបណ្តាលឲ្យមានការបញ្ចេញអត្តសញ្ញាណរបស់ជនរងគ្រោះពីការជួញដូរមនុស្សដែលត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ។ ក្រោមច្បាប់ស្តីពីរដ្ឋបាលតុលាការកំពូល និងច្បាប់ស្តីពីតុលាការតាមរដ្ឋ តុលាការមានសិទ្ធិអំណាចស្តាប់សក្ខីកម្មនូវកិច្ចដំណើរការនីតិវិធី "ជាអសាធារណៈ" ហើយអាចបង្គាប់បន្ថែមថា ឈ្មោះរបស់សាក្សីត្រូវដកចេញ ឬកោសលុបពីឯកសារតុលាការ ហើយ ឈ្មោះ ឬរូបថតរបស់សាក្សីមិនត្រូវយកទៅចុះផ្សាយឡើយ។ | | |
| ថៃ | *ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* បញ្ជាក់ច្បាស់នូវអំពើនានាដែលត្រូវបានហាមឃាត់ ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះពីការជួញដូរមនុស្ស រួមមាន៖<br>(១) ការថតរូប ការថតវាចរ ឬការបោះពុម្ពរូបថត ឬការផ្សាយសំឡេងរបស់បុគ្គលណាម្នាក់ នៅក្នុងដំណាក់កាលណាក៏ដោយ ដែលអាចនាំឲ្យបញ្ចេញអត្តសញ្ញាណរបស់ជនរងការជួញដូរមនុស្ស។<br>(២) ការចុះផ្សាយ ឬការផ្សព្វផ្សាយខ្លឹមសារដែលមាននៅក្នុងដំណើរការស៊ើបអង្កេតរបស់មន្ត្រីស៊ើបអង្កេត ឬដំណើរការសវនាការនៅក្នុងតុលាការ ដែលអាចបញ្ចេញឈ្មោះរបស់ជនរងការជួញដូរ ឬសមាជិកគ្រួសាររបស់ពួកគេ តាមរយៈបណ្តាញទំនាក់ទំនងសារព័ត៌មានប្រភេទណាក៏ដោយ។<br>(៣) ការចុះផ្សាយ ឬការផ្សព្វផ្សាយខ្លឹមសារ រូបភាព ឬសំឡេង តាមរយៈបណ្តាញទំនាក់ទំនងសារព័ត៌មានប្រភេទណាក៏ដោយ ដែលបញ្ចេញប្រវត្តិ ទីកន្លែងរស់នៅ ទីកន្លែងធ្វើការ ឬទីកន្លែងសិក្សាអប់រំរបស់ជនរងការជួញដូរមនុស្ស[១៥៩]។ | | |
| វៀតណាម | *ក្រមព្រហ្មទណ្ឌ* អនុញ្ញាតឲ្យមានសវនាការជាអសាធារណៈ ដើម្បីការពារ "ភាពសម្ងាត់របស់បុគ្គលពាក់ព័ន្ធ"[១៦០] និងផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សីដោយស្ថាប័នមានសមត្ថកិច្ចផ្នែកនីតិវិធី តាមរយៈការអនុវត្តន៍នូវវិធានការចាំបាច់ អនុលោមតាមច្បាប់ នៅពេលដែលជីវិត និងសុខភាពរបស់ពួកគេស្ថិតក្នុងភាពគ្រោះថ្នាក់ កិត្តិយស សេចក្តីថ្លៃថ្នូរ ឬទ្រព្យសម្បត្តិរបស់ពួកគេរងការរំលោភបំពាន[១៦១]។<br><br>*ច្បាប់ស្តីពីការទប់ស្កាត់ និងការបង្ក្រាបប្រឆាំងនឹងការជួញដូរមនុស្ស (ឆ្នាំ២០១១)* អនុញ្ញាតឲ្យតុលាការការពិចារណា ដល់ការជំនុំជម្រះជាអសាធារណៈ ទៅលើសំណុំរឿងជួញដូរមនុស្ស ទៅតាមការស្នើសុំរបស់សាក្សីជាជនរងគ្រោះ ឬអ្នកតំណាងតាមផ្លូវច្បាប់របស់ពួកគេ។ ច្បាប់នោះក៏ហាមឃាត់ផងដែរមិនឲ្យបញ្ចេញព័ត៌មានអំពីជនរងគ្រោះ ដោយគ្មានការព្រមព្រៀងពីពួកគេ ឬពីអ្នកតំណាងតាមផ្លូវច្បាប់របស់ពួកគេ។ | | |

[១៥៩] ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ថៃ) ផ្នែក ៥៦។

[១៦០] ក្រមនីតិវិធីព្រហ្មទណ្ឌ (វៀតណាម) មាត្រា ១៨។

[១៦១] ក្រមនីតិវិធីព្រហ្មទណ្ឌ (វៀតណាម) មាត្រា ៧។

| | | | |
|---|---|---|---|
| | បុរសពេញវ័យ | ស្ត្រីពេញវ័យ | កុមារ (អាយុក្រោម ១៨ ឆ្នាំ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ) |
| | ក្របខ័ណ្ឌគតិយុត្តិវៀតណាមចាត់ទុកថាជាកុមារ ចំពោះមនុស្សអាយុក្រោម ១៦ ឆ្នាំ។ | | |

មានព័ត៌មានដែលអាចបញ្ជាក់បានតិចតួច ស្តីពីរបៀបគោរពដល់សិទ្ធិទទួលបានឯកជនភាពរបស់សាក្សីជាជនរងគ្រោះ នៅក្នុងការអនុវត្តន៍ជាក់ស្តែងនៅតំបន់អាស៊ាន។ អ្នកប្រតិបត្តិនៅក្នុងរដ្ឋសមាជិកអាស៊ានបានផ្តល់នូវឧទាហរណ៍ស្តីពីការបង្កើតថ្មីដូចខាងក្រោម។

*ប្រអប់អត្ថបទ ២៤៖ ឧទាហរណ៍អនុវត្តន៍៖ ការបង្កើតថ្មីក្នុងការការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សី*

> **ប្រទេសថៃ**បានបង្កើតនូវវិធីសាស្ត្រ និងការអនុវត្តន៍ជាក់ស្តែងមួយចំនួន ដើម្បីការពារឯកជនភាព និងសុខុមាលភាពរបស់សាក្សីជាជនរងគ្រោះដែលចូលរួមនៅក្នុងសំណុំរឿងជួញដូរមនុស្ស។ ចំណុចទាំងនេះរួមមានការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ (សូមមើលខាងក្រោម) ព្រមទាំងវិសោធនកម្មច្បាប់ដែលអាចឲ្យព្រះរាជអាជ្ញាការការពារអត្តសញ្ញាណរបស់សាក្សីជាជនរងគ្រោះបាន។

ជាការគួរឲ្យថ្លែងអំណរគុណគឺថា នាពេលបច្ចុប្បន្នការបញ្ចេញអត្តសញ្ញាណរបស់ជនរងគ្រោះពីការជួញដូរមនុស្ស ជាសាធារណៈតាមរយៈសារព័ត៌មាន ឬតាមរយៈរដ្ឋាភិបាលមិនមែនជារឿងធម្មតាទៀតទេ។ ក៏ប៉ុន្តែ ការការពារឯកជនភាពនៅតែជាការប្រឈមនៅឡើយ ដែល *ទស្សនាវដ្តី ACWC Regional Review* បញ្ជាក់ថា បញ្ហានេះនៅតែបន្តមាននៅឡើយ។ ឧទាហរណ៍ នៅក្នុងប្រទេសមួយចំនួន វាជាបទដ្ឋាននៃការអនុវត្តន៍ជាក់ស្តែងដែលថា ជនរងគ្រោះត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មនៅក្នុងតុលាការ នៅចំពោះមុខជនដែលត្រូវបានចោទប្រកាន់ថាជាអ្នកកេងប្រវ័ញ្ច ហើយក៏ត្រូវបានបង្ខំឲ្យបញ្ចេញព័ត៌មានរសើបនានា ដូចជាអាសយដ្ឋានរបស់ពួកគេជាដើម។ អ្នកឆ្លើយតបម្នាក់ដែលបានអមដំណើរការជនរងគ្រោះទៅកន្លែងស៊ើបអង្កេតបានរម្លឹកឡើងនូវសំណុំរឿងមួយ នៅពេលដែលជនរងគ្រោះត្រូវបានស្តាប់ចម្លើយនៅចំពោះមុខជនដែលត្រូវបានចោទប្រកាន់ថាជាចារី ដែលធ្វើឲ្យគាត់ត្រូវដកចម្លើយរបស់ខ្លួនអំពីជនល្មើសនោះវិញ។ មន្ត្រីរដ្ឋាភិបាលដែលបានចូលរួមក្នុងកិច្ចពិភាក្សាតុមូលសម្រាប់*ទស្សនាវដ្តី ACWC Regional Review* បានសន្និដ្ឋានថា ការរក្សាការសម្ងាត់ និងសិទ្ធិរបស់ជនរងគ្រោះ អាចត្រូវបានប៉ះពាល់ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។

## វឌ្ឍនភាពទាក់ទងនឹងការទទួលបានព័ត៌មានអំពីសិទ្ធិ និងកិច្ចដំណើរការនីតិវិធី

ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ចែងជាក់លាក់ថាជនរងគ្រោះជាសាក្សី មានសិទ្ធិតាមផ្លូវច្បាប់ក្នុងការទទួលបានព័ត៌មាន និងដំបូន្មាន។ ឧទាហរណ៍ *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* របស់**ប្រទេសហ្វីលីពីន** ចែងថា ជនរងគ្រោះមានសិទ្ធិទទួលបានសេវាផ្លូវច្បាប់ដោយឥតគិតថ្លៃ រួមទាំង ព័ត៌មានអំពីសិទ្ធិរបស់ពួកគេ និងនីតិវិធីក្នុងការដាក់ពាក្យបណ្តឹង ការទាមទារសំណងជួសជុល និងសំណងតាមផ្លូវច្បាប់ផ្សេងទៀតដែលមាន។ នៅ**ប្រទេសថៃ** *ច្បាប់ប្រឆាំងការជួញដូរមនុស្ស(ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* អះអាងអំពីសិទ្ធិរបស់ជនរងការជួញដូរមនុស្សក្នុងការទទួលបានជំនួយផ្លូវច្បាប់។ ច្បាប់នេះ*តម្រូវ* ឲ្យអ្នកស៊ើបអង្កេត ឬព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជនរងការជួញដូរមនុស្ស នូវសិទ្ធិនេះតាំងពីដំបូង។ នេះជាការទទួលស្គាល់យ៉ាងសំខាន់នូវការណ៍ដែលថា ជនរងគ្រោះត្រូវ

បានទទួលដំណឹងពីសិទ្ធិរបស់ខ្លួន ប្រសិនបើពួកគេរំពឹងថានឹងអនុវត្តនូវសិទ្ធិទាំងនោះ។ ជាងនេះទៀត នគរបាលភូមិន្ទថៃទទួលអាណត្តិការងារផ្តល់ព័ត៌មានជាប្រចាំដល់ជនរងការជួញដូរមនុស្ស ឬសាក្សីនូវវឌ្ឍនភាពស្តីពីការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្សជាលាយលក្ខណ៍អក្សរ អនុលោមទៅតាមបទដ្ឋាននៃទម្រង់[១៦២]។ ពុំមានភាពច្បាស់លាស់ពីរបៀបដំណើរការបទប្បញ្ញត្តិនេះនៅក្នុងការអនុវត្តន៍ជាក់ស្តែងទេ។

នៅ**ប្រទេសឥណ្ឌូនេស៊ី** សាក្សីនៅក្នុងសំណុំរឿងជួញដូរមនុស្ស មានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងវឌ្ឍនភាពនៃសំណុំរឿងរបស់ខ្លួន។ សិទ្ធិនេះអនុវត្តនៅក្នុងអំឡុងពេលស៊ើបអង្កេត ចោទប្រកាន់ និងដំណើរការត្រួតពិនិត្យនៅក្នុងតុលាការ[១៦៣]។ ទោះបីជនរងគ្រោះពីការជួញដូរមនុស្សពុំមានសិទ្ធិដោយស្វ័យប្រវត្តិនូវការទទួលបានដំបូន្មានផ្លូវច្បាប់ និងជំនួយក៏ដោយ តែច្បាប់ចែងថា ពួកគេអាចទាមទារសំណងបដិទានចំពោះការចំណាយផ្លូវច្បាប់បាន។ កុមាររងគ្រោះមានសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ក្រោម*ច្បាប់ការពារកុមារ* របស់ឥណ្ឌូនេស៊ី។ ក្រោម*ច្បាប់ស្តីពីការការពារសាក្សី និងជនរងគ្រោះ* ជនរងគ្រោះពីបទល្មើសមានសិទ្ធិមួយចំនួន រួមមាន សិទ្ធិទទួលបានព័ត៌មានអំពីការវិវត្តន៍នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ សិទ្ធិទទួលបានព័ត៌មានអំពីសាលក្រមរបស់តុលាការ សិទ្ធិទទួលបានព័ត៌មានអំពីការដោះលែងជនល្មើស និងសិទ្ធិទទួលបានដំបូន្មានផ្លូវច្បាប់[១៦៤]។

ច្បាប់នៅ**ប្រទេសកម្ពុជា**ចែងថា ជនរងគ្រោះពីការជួញដូរមនុស្សគ្រប់រូប ត្រូវទទួលបានសេវាផ្លូវច្បាប់ និងរាល់ព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងពួកគេ។ ជនរងគ្រោះដែលមិនអាចនិយាយ ឬអានភាសាខ្មែរបាន នឹងទទួលបានជំនួយពីអ្នកបកប្រែភាសា ដើម្បីឱ្យគេអាចយល់បាននូវរាល់ព័ត៌មានទាំងអស់ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់។ អ្នកប្រតិបត្តិដែលបានផ្តល់បទសម្ភាសន៍សម្រាប់ការវាយតម្លៃរបស់ ACWC បានកត់សម្គាល់ថា ចំណុចនេះត្រូវបានយកមកអនុវត្តជាក់ស្តែង យ៉ាងហោចណាស់ទាក់ទងនឹងជនរងគ្រោះពីការជួញដូរមនុស្សជាជនជាតិវៀតណាមចំពោះការកេងប្រវ័ញ្ចផ្លូវភេទ។ ច្បាប់នៅ**ប្រទេសវៀតណាម** (*ក្រមនីតិវិធីព្រហ្មទណ្ឌ* មាត្រា ៥១) ផ្តល់ដល់ជនរងគ្រោះពីបទល្មើសគ្រប់រូបនូវសិទ្ធិជាច្រើន រួមមាន សិទ្ធិទទួលបានព័ត៌មាននៃការបញ្ចប់ការស៊ើបអង្កេតដែលពាក់ព័ន្ធជាដើម[១៦៥]។ ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់ដល់ប្រភេទជនមួយចំនួនរួមទាំងជនរងគ្រោះពីការជួញដូរមនុស្សផងដែរ[១៦៦]។ នាពេលថ្មីៗនេះ មានការណែនាំមួយពីនាយកដ្ឋានជំនួយផ្នែកច្បាប់តម្រូវមជ្ឈមណ្ឌលជំនួយផ្នែកច្បាប់ថ្នាក់ខេត្ត ត្រូវផ្តល់ជំនួយដល់ជនរងគ្រោះពីការជួញដូរមនុស្ស ក្នុងការដាក់ពាក្យសុំចុះឈ្មោះស្នាក់នៅអចិន្ត្រៃយ៍ ការចុះបញ្ជីអត្រានុកូលដ្ឋាន សិទ្ធិទទួលបានការគាំទ្រផ្សេងទៀត ការទាមទារសំណងជួសជុល និងការចូលរួមនៅក្នុងវិវាទ និងនីតិវិធីផ្លូវច្បាប់ផ្សេងទៀតទាក់ទងនឹងសំណុំរឿងរបស់ខ្លួន។ ការណែនាំនេះ មិនមានចងជាកាតព្វកិច្ចគតិយុត្តិទេ ហើយក៏មិនច្បាស់ថាតើជនរងគ្រោះពីការជួញដូរមនុស្សបានដឹងពីសិទ្ធិរបស់ខ្លួនតាមផ្លូវរដ្ឋបាល ក្នុងការទទួលបានជំនួយផ្នែកច្បាប់ដែរឬយ៉ាងណា។

---

[១៦២] ក្រុមការងារទទួលបន្ទុកបង្កើតសៀវភៅណែនាំសម្រាប់មន្ត្រី ស្តីពីការអនុវត្តនូវការទប់ស្កាត់ និងការបង្ក្រាបការជួញដូរមនុស្ស (ឆ្នាំ២០១៣) ដែលត្រូវបានដកស្រង់នៅក្នុងរបាយការណ៍ពីប្រទេសថៃ (ខែធ្នូ ឆ្នាំ២០១៥)។

[១៦៣] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស (ឥណ្ឌូនេស៊ី) មាត្រា ៣៦។

[១៦៤] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ១៣/២០០៦ ស្តីពីការការពារសាក្សី និងជនរងគ្រោះ (ឥណ្ឌូនេស៊ី) មាត្រា ៥។

[១៦៥] ក្រមនីតិវិធីព្រហ្មទណ្ឌ (វៀតណាម) មាត្រា ៥១។

[១៦៦] មាត្រា ៣៦ ច្បាប់ស្តីពីការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

បទប្បញ្ញត្តិច្បាប់ដែលផ្តល់ដល់ជនរងគ្រោះពីការជួញដូរមនុស្សនូវព័ត៌មានអំពីសិទ្ធិរបស់ខ្លួន និងអំពីកិច្ចដំណើរការនីតិវិធីច្បាប់ និងការទទួលបានជំនួយផ្នែកច្បាប់មិនទាន់ត្រូវបានដាក់ឲ្យអនុវត្តនៅ**ប្រទេសប្រ៊ុយណេ ឬម៉ាឡេស៊ី**ទេ។ ច្បាប់ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៥ របស់**ប្រទេសឡាវ** ផ្តល់ដល់ជនរងគ្រោះនូវសិទ្ធិទទួលបានព័ត៌មាន និងជំនួយផ្នែកច្បាប់។ ជនរងគ្រោះក៏អាចទទួលបានសំណុំរឿងរបស់ខ្លួនដែរ តែក្រោយពេលបញ្ចប់ការស៊ើបអង្កេត (និងកិច្ចដំណើរការនីតិវិធីច្បាប់ដែលពាក់ព័ន្ធ) ប៉ុណ្ណោះ។ បើតាមការលើកឡើងរបស់មន្ត្រី ច្បាប់របស់**ប្រទេសមីយ៉ាន់ម៉ា** មិនអនុញ្ញាតឲ្យជនរងគ្រោះពីការជួញដូរមនុស្សទទួលបានព័ត៌មានទេ ដោយសារវាផ្ទុយទៅនឹងការប្រាស្រ័យទាក់ទងនានាអំពីសំណុំរឿង។ ចំណុចនេះអាចយល់បានថា ព្រះរាជអាជ្ញា ឬមេធាវីមិនអាចពិភាក្សាអំពីស្ថានភាពនោះ រួមទាំង តួនាទី និងការទទួលខុសត្រូវ តារាងពេលវេលា ផលវិបាក និងសារៈសំខាន់ នៃការចូលរួមរបស់ជនរងគ្រោះបានទេ។ មានការបង្ហាញតិចតួចណាស់ដែលថា ចំណុចនេះអាចនឹងមានការផ្លាស់ប្តូរ។ **ប្រទេសមីយ៉ាន់ម៉ា**បានបង្កើតកូនសៀវភៅស្តីពីព័ត៌មានជនរងគ្រោះ និងគំនូរជីវចលទៅលើបន្ទះឌីវីឌី ដើម្បីផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេ តាមរយៈដៃគូនានារបស់រដ្ឋាភិបាលដូចជា ក្រុមការងារប្រឆាំងការជួញដូរមនុស្ស នាយកដ្ឋានសុខុមាលភាពសង្គម ការិយាល័យអគ្គមេធាវីសហភាព និងរដ្ឋបាលទូទៅ។ ប្រទេសនេះក៏បានសហការជាមួយ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង CBOs ដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះដែរ។ ជាងនេះទៀត គំនូរជីវចលត្រូវបានផ្សព្វផ្សាយនៅតាមបណ្តាញសារព័ត៌មានដើម្បីលើកកម្ពស់ការយល់ដឹងពីសាធារណជន ហើយនគរបាល ATTF បានរៀបចំសកម្មភាពលើកកម្ពស់ការយល់ដឹងពីសាធារណជនជាប្រចាំនៅតាមសាលារៀន ទីប្រជុំជន។ល។

មានទិន្នន័យដែលអាចបញ្ជាក់បានតិចតួច ស្តីពីរបៀបនៃការគោរពទៅដល់សិទ្ធិរបស់ជនរងគ្រោះជាសាក្សីក្នុងការទទួលបានព័ត៌មានអំពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ និងកិច្ចដំណើរការនីតិវិធីនៅក្នុងការអនុវត្តន៍ជាក់ស្តែង។ មានការរាយការណ៍ពីការវិវត្តន៍ជាវិជ្ជមានតាមរយៈការវាយតម្លៃនៅតាមប្រទេសនីមួយៗ។ ឧទាហរណ៍ នៅ**ប្រទេសថៃ** បុគ្គលិកនៅជម្រកសុវត្ថិភាពរបស់រដ្ឋាភិបាល រួមទាំងបុគ្គលិកសង្គមកិច្ច និងមន្ត្រីច្បាប់ផង បានរាយការណ៍ថាមានទំនាក់ទំនងជាមួយមេធាវី អ្នកបកប្រែភាសា និង អង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាថា សិទ្ធិតាមផ្លូវច្បាប់របស់ជនរងគ្រោះត្រូវបានគោរព ហើយថា ពួកគេបានទទួលព័ត៌មានទាន់ពេលវេលាអំពីសិទ្ធិ ការការពារដែលមាន និងនីតិវិធីច្បាប់។ ក្រៅពីនេះ រដ្ឋាភិបាលបានបង្កើតឲ្យមានសារព័ត៌មានដែលល្អសម្រាប់កុមារ ដូចជាគំនូរជីវចលជាដើម ជាភាសាតាមតំបន់ជាច្រើន ដើម្បីផ្តល់ដំណឹងដល់កុមាររងគ្រោះនូវសិទ្ធិរបស់ពួកគេ[១៦៧]។ ក៏ប៉ុន្តែ របាំងផ្នែកភាសានៅតែជាបញ្ហាមួយរារាំងការផ្តល់ព័ត៌មានអំពីសិទ្ធិ ការការពារ និងនីតិវិធីច្បាប់ដដែល អាចដោយសារកង្វះអ្នកបកប្រែភាសា ឬបញ្ហាគុណភាពទាក់ទងនឹងការបកប្រែអត្ថន័យឲ្យបានត្រឹមត្រូវពីភាសាមួយទៅភាសាមួយ[១៦៨]។ រដ្ឋសមាជិកអាស៊ានជាច្រើនផ្សេងទៀត បានសហការជាមួយដៃគូពីខាងក្រៅ ដើម្បីបង្កើតសម្ភារព័ត៌មានសម្រាប់ជនរងគ្រោះ ក្នុងគោលបំណងធានាថាពួកគេយល់ពីសិទ្ធិរបស់ខ្លួន និងកិច្ចដំណើរការនីតិវិធីច្បាប់ដែលពួកគេចូលរួម ឬអាចចូលរួម។

ជារួម រដ្ឋសមាជិកអាស៊ានអាចបញ្ជាក់អំពីអត្ថិភាពនៃនីតិវិធី និងបែបបទនានាដែលមានប្រសិទ្ធភាព ដែលធានាថា ជនរងគ្រោះពីការជួញដូរមនុស្សបានទទួលព័ត៌មានសមរម្យអំពីសិទ្ធិរបស់ខ្លួន និងស្ថានភាពនៃកិច្ចដំណើរការនីតិវិធីច្បាប់ដែលពួកគេចូលរួម ឬអាចចូលរួម។ នៅក្នុងការវាយតម្លៃតាមប្រទេសជាច្រើនដែលធ្វើឡើងសម្រាប់*ទស្សនាវដ្តី*

---

[១៦៧] រាជរដ្ឋាភិបាលថៃ ១.៣/២០០៦ ស្តីពីការការពារសាក្សី និងជនរងគ្រោះ និង ជនរងការជួញដូរនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។

[១៦៨] ក្រោយពេលជួញដូរ៖ បទពិសោធន៍ និងការប្រឈមនៅក្នុងការធ្វើសមាហរណកម្មជនរងការជួញដូរនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ Surtees, R. (ឆ្នាំ២០១៣) ក្រុងបាងកក៖ វិទ្យាស្ថាន UNIAP/NEXUS។

*ACWC Regional Review* ជនរងគ្រោះបានជួបប្រទះនូវភាពអន្ទះសារដោយសារពុំមានព័ត៌មានអំពីដំណើរការនៃសំណុំរឿងរបស់ខ្លួន ពេលវេលាដែលតម្រូវឱ្យពួកគេទៅបង្ហាញខ្លួននៅក្នុងតុលាការ និងពេលដែលអាចវិលត្រឡប់ទៅផ្ទះវិញបាន។

វាក៏ជាការសំខាន់ផងដែរដែលត្រូវគូសបញ្ជាក់ថា *ការជូនដំណឹង*ដល់ជនរងគ្រោះនូវសិទ្ធិរបស់គេមិនទាន់គ្រប់គ្រាន់ទេ នៅពេលដែលសិទ្ធិទាំងនោះមិនត្រូវបានយកមកអនុវត្តជាក់ស្តែង។ ការសិក្សាមួយដែលបានធ្វើឡើងនៅក្នុងរដ្ឋសមាជិកអាស៊ានមួយបានបង្ហាញថា ទោះបីជនរងគ្រោះអាចបានទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន ដោយបង្កើននូវការយល់ដឹងពីអ្វីដែលពួកគេមានសិទ្ធិនឹងទទួលបានក៏ដោយ តែនេះមិនមែនមានន័យថាពួកគេមានកំណើនសមត្ថភាពក្នុងការទទួលបានសិទ្ធិទាំងនោះឡើយ។

## វឌ្ឍនភាពទាក់ទងនឹងការការពារចៀសផុតពីការបំភិតបំភ័យ និងការសងសឹក

ច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន (តែមិនទាំងអស់ទេ) ផ្តល់ដល់ជនរងគ្រោះជាសាក្សី និងគ្រួសាររបស់ពួកគេនូវសិទ្ធិទទួលបានការការពារ ពីការគំរាមកំហែងដល់សុវត្ថិភាពផ្លូវកាយ ដោយសារការសងសឹក និងការគំរាមកំហែង។ ទាក់ទងនឹងការការពារឯកជនភាពរបស់ជនរងគ្រោះ សិទ្ធិអាចមិនបានទទួលតាម រយៈច្បាប់ប្រឆាំងការជួញដូរមនុស្សទេ តែតាមរយៈច្បាប់ពាក់ព័ន្ធមួយផ្សេងទៀត។

ច្បាប់ស្តីពីការជួញដូរមនុស្ស របស់**ប្រទេសឥណ្ឌូនេស៊ី** ចែងថា នៅពេលសាក្សី ឬជនរងគ្រោះ ឬគ្រួសាររបស់ពួកគេបានទទួលការគំរាមកំហែងដែលមានគ្រោះថ្នាក់ដល់ជីវិត ឬទ្រព្យសម្បត្តិ កម្លាំងនគរបាលត្រូវផ្តល់ការការពារនៅមុនពេល ក្នុងអំឡុងពេល និង/ឬ ក្រោយពេលដំណើរការជំនុំជម្រះ[១៦៩]។ ក្រៅពីនេះ ក្រោម*ច្បាប់ស្តីពីការការពារសាក្សី និងជនរងគ្រោះ*របស់ឥណ្ឌូនេស៊ី ជនរងគ្រោះ និងសាក្សីគ្រប់រូបមានសិទ្ធិជាច្រើន រួមមាន៖ សិទ្ធិទទួលបានការការពារផ្ទាល់ខ្លួន គ្រួសារ និងទ្រព្យសម្បត្តិប្រឆាំងនឹងការគំរាមកំហែងនានាដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មដែលពួកគេនឹងមកផ្តល់ ឬកំពុងផ្តល់ ឬបានផ្តល់រួចហើយ សិទ្ធិទទួលបានព័ត៌មានអំពីការដោះលែងជនល្មើស សិទ្ធិទទួលបានអត្តសញ្ញាណថ្មី និងសិទ្ធិទទួលការផ្លាស់ទីកន្លែងថ្មី[១៧០]។ នៅ**ប្រទេសហ្វីលីពីន** ច្បាប់ស្តីពីការជួញដូរមនុស្ស ផ្តល់ដល់ជនរងគ្រោះនូវសិទ្ធិទទួលបានតាមការពេញចិត្តនូវកម្មវិធីការពារសាក្សី[១៧១]។

ច្បាប់ស្តីពីការជួញដូរមនុស្សនៅ**ប្រទេសម៉ាឡេស៊ី** ចែងនូវការការពារមួយចំនួន ដល់ជនរងគ្រោះជាសាក្សីតាមរយៈបទប្បញ្ញត្តិមួយ (ផ្នែក ៥៨(១)) ដែលការពារអត្តសញ្ញាណរបស់សាក្សី។ ជាងនេះទៀត *ច្បាប់ការពារសាក្សី*របស់ម៉ាឡេស៊ីចែងថា "អគ្គនាយកត្រូវធ្វើសកម្មភាពនានា ដែលយល់ឃើញថាជាការចាំបាច់ និងសមហេតុផល ដើម្បីការពារ

---

[១៦៩] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស (ឆ្នាំ២០០៧) (ឥណ្ឌូនេស៊ី) មាត្រា ៤៧។

[១៧០] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ១៣/២០០៦ ស្តីពីការការពារសាក្សី និងជនរងគ្រោះ (ឥណ្ឌូនេស៊ី) មាត្រា ៥។

[១៧១] R.A. លេខ ៩២០៨ ត្រូវបានធ្វើវិសោធនកម្មដោយ RA លេខ ១០៣៦៤ (ហ្វីលីពីន) ផ្នែក ១៨។

សុវត្ថិភាព និងសុខុមាលភាពរបស់សាក្សី (ដែលអាចបញ្ចូលគ្រួសារ និងអ្នកមានទំនាក់ទំនងជាមួយជនរងគ្រោះ)[១៧២]។ ចំណុចនេះអាចបញ្ចូលនូវការស្នាក់នៅ ការផ្លាស់ទីកន្លែង ការផ្លាស់ប្តូរអត្តសញ្ញាណ ការគាំទ្រហិរញ្ញវត្ថុ និងជំនួយ និងការទទួលបានការងារធ្វើ ឬការអប់រំ។

### *ប្រអប់អត្ថបទ ២៥៖ ឧទាហរណ៍អនុវត្តន៍៖ការការពារជនរងគ្រោះជាសាក្សី ពីការគំរាមកំហែង និងការសងសឹក*

> ក្របខ័ណ្ឌគតិយុត្តិរបស់**ប្រទេសថៃ** អាចឲ្យជនរងគ្រោះ ព្រះរាជអាជ្ញា ឬមន្ត្រីសង្គមកិច្ចស្នើសុំទៅតុលាការសម្រាប់ "ការផ្តល់ភស្តុតាងដោយគ្មានការតទល់"៖ ជាការព្រមព្រៀងដោយចៅក្រមថា សាក្សីនឹងផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍ ដើម្បីកុំឲ្យគាត់ស្ថិតនៅក្នុងបន្ទប់សវនាការជាមួយជនជាប់ចោទ។

នៅ**ប្រទេសវៀតណាម** ច្បាប់ស្តីពីការជួញដូរមនុស្សចែងថា ទីភ្នាក់ងារ អង្គភាព ឬមនុស្សដែលស្ថិតក្នុងកម្លាំងនគរបាលប្រជាជន និងកងទ័ពប្រជាជនដែលត្រូវបានចាត់តាំង ឲ្យទៅប្រយុទ្ធប្រឆាំង ឬទប់ស្កាត់ការជួញដូរមនុស្ស ត្រូវ "ចាត់វិធានការទាំងអស់ដែលចាំបាច់ដើម្បីការពារជនរងគ្រោះ ដោយរាយការណ៍ដល់មនុស្ស និងសាក្សី និងសាច់ញាតិរបស់ពួកគេ នៅពេលមនុស្សទាំងនេះបានគំរាមកំហែង ឬត្រូវបានគំរាមកំហែងដល់អាយុជីវិត សុខភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ឬទ្រព្យសម្បត្តិរបស់ពួកគេ"[១៧៣]។ *ក្រឹត្យរដ្ឋាភិបាលលេខ ៦២ ស្តីពីការកំណត់អត្តសញ្ញាណ និងសុវត្ថិភាពជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ* បានអនុញ្ញាតជាពិសេសឲ្យភ្នាក់ងារទទួលខុសត្រូវ ធ្វើការរៀបចំសន្តិសុខនៅក្នុងគេហដ្ឋាន ឬនៅពេលសវនាការក្នុងតុលាការ និងរៀបចំកន្លែងស្នាក់នៅ ធ្វើការ ឬសិក្សាថ្មី ដើម្បីការពារជីវិត និងសុខភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។

ច្បាប់ស្តីពីការការពារជនរងគ្រោះជាសាក្សី និងគ្រួសាររបស់ពួកគេ ពុំសូវមានភាពទូលំទូលាយទេ នៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត។ នៅ**ប្រទេសមីយ៉ាន់ម៉ា** ច្បាប់ផ្តល់សន្តិសុខ និងការការពារដល់ស្ត្រី កុមារ និងយុវវ័យរងគ្រោះ "ក្នុងអំឡុងពេលចោទប្រកាន់" និង "ក្នុងអំឡុងពេលដាក់ពាក្យបណ្តឹងទាមទារសំណងជួសជុល"[១៧៤]។ ពុំមានលើកឡើងនូវការការពារចំពោះជនរងគ្រោះដែលមិនបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ទេ ឬការពិត ការការពារដល់ជនរងគ្រោះជាបុរសពេញវ័យនៅក្នុងដំណាក់កាលណាមួយទេ[១៧៥]។

នៅ**ប្រទេសសិង្ហបុរី** ទោះបីច្បាប់ស្តីពីការជួញដូរមនុស្ស មិនបានដោះស្រាយជាក់លាក់នូវការការពារដល់ជនរងគ្រោះ ឬសាក្សីក៏ដោយ ប៉ុន្តែជនរងគ្រោះគ្រាន់តែរងពីការបៀតបៀន និងបោកបញ្ឆោតផ្សេងៗអាចដាក់ពាក្យសុំដោយផ្ទាល់ដល់តុលាការដោយស្នើសុំដីកាការពារក្រោម*ច្បាប់ការពារពីការបៀតបៀន*។ ជាងនេះទៀត តុលាការអាច

---

[១៧២] *ច្បាប់ការការពារសាក្សីឆ្នាំ២០០៩* (ច្បាប់លេខ ៦៩៦) (ម៉ាឡេស៊ី) ផ្នែក ១៣។

[១៧៣] *ច្បាប់ទាំងការជួញដូរមនុស្ស* (ឆ្នាំ២០១១) (វៀតណាម) មាត្រា ២១។

[១៧៤] *ច្បាប់ប្រឆាំងការជួញដូរមនុស្ស* (ច្បាប់លេខ ៥/២០០៥) (មីយ៉ាន់ម៉ា) ផ្នែក ១៧។

[១៧៥] ក៏ប៉ុន្តែ *ផែនការសកម្មភាពជាតិស្តីពីការជួញដូរមនុស្សសម្រាប់ឆ្នាំ២០១២-២០១៧* (ឆ្នាំ២០១២) របស់មីយ៉ាន់ម៉ាពិតជាបានលើកឡើងពីតម្រូវការចាំបាច់ដើម្បីការពារជនរងគ្រោះពីការជួញដូរមនុស្សជាបុរស។

ចេញដីកាហាមឃាត់ ដើម្បីការពារអត្តសញ្ញាណរបស់សាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ អនុលោមតាមផ្នែក ៧ នៃ*ច្បាប់ស្តីពីតុលាការរដ្ឋ* និងផ្នែក ៨ នៃ*ច្បាប់ស្តីពីរដ្ឋបាលតុលាការកំពូល*។

ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់**ប្រទេសថៃ** តម្រូវឱ្យមន្ត្រីពាក់ព័ន្ធត្រូវផ្តល់សុវត្ថិភាព និងការការពារដល់ជនរងការជួញដូរមនុស្សនៅក្នុងការថែទាំរបស់ខ្លួននៅគ្រប់ករណី ដោយមិនគិតពីកន្លែងដែលជននោះស្នាក់នៅ ទោះបីជាមុនពេល ក្នុងអំឡុងពេល ឬក្រោយពេលកិច្ចដំណើរការនីតិវិធីនោះឡើយ។ នៅក្នុងករណីដែលជនរងគ្រោះជាជនបរទេសដែលបានវិលត្រឡប់ទៅផ្ទះខ្លួនវិញ ភ្នាក់ងារពាក់ព័ន្ធត្រូវសម្របសម្រួលជាមួយសមភាគីបរទេសដើម្បីធានា "បន្ត" ការការពារ។ *ក្រមនីតិវិធីព្រហ្មទណ្ឌ* របស់ថៃ (ឆ្នាំ២០០៩) ក៏បានលើកឡើងនូវលក្ខខណ្ឌបន្ថែមជាក់លាក់ក្នុងករណីមានសាក្សីជាកុមាររងគ្រោះ ដោយតម្រូវថា អ្នកទាំងនោះត្រូវបានអមដំណើរជានិច្ចកាលដោយមនុស្សណាម្នាក់ដែលមានសមត្ថភាពក្នុងការមើលថែទាំពីសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេបាន[១៧៦]។ ប្រទេសថៃបានរាយការណ៍ថា សាក្សីនៃសំណុំរឿងជួញដូរមនុស្សទាំងអស់នឹងទទួលបានសិទ្ធិដោយស្វ័យប្រវត្តិក្នុងការទទួលបានកម្មវិធីការពារសាក្សីរបស់ខ្លួន។ ក៏ប៉ុន្តែ ពុំមានព័ត៌មានដែលអាចរកបានស្តីពីរបៀបអនុវត្តក្នុងការអនុវត្តន៍ជាក់ស្តែង។

## វឌ្ឍនភាពទាក់ទងនឹងការផ្តល់ជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់

ស្របជាមួយនឹងការកំណត់អំពីស្ថានភាពគតិយុត្តិរបស់ជនរងគ្រោះ ការប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះក៏អាចសម្របសម្រួលដល់ការចូលរួមយ៉ាងមានប្រសិទ្ធភាពពីសាក្សីជាជនរងគ្រោះ ជាជនបរទេស ទៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ សក្ខីកម្មមុនការជំនុំជម្រះអនុញ្ញាតឱ្យព្រះរាជអាជ្ញាអាចនាំយកសាក្សីជាជនរងគ្រោះទៅកាន់តុលាការនៅដំណាក់ដំបូងក្នុងកិច្ចដំណើរការនីតិវិធី (ជួនកាល មុនមានការកំណត់បទចោទទៀតផង) ដើម្បីឱ្យតុលាការអាចស្តាប់ និងកត់ត្រាសក្ខីកម្មរបស់ជនរងគ្រោះបាន។ សក្ខីកម្មមុនការជំនុំជម្រះផ្តល់កាលានុវត្តភាពដល់សាក្សីជាជនរងគ្រោះក្នុងការចូលរួមទៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ ដោយមិនរង់ចាំ (ជួនកាលរយៈពេលជាច្រើនឆ្នាំ) ដើម្បីផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះពេញលេញ ឬរម្លឹកឡើងវិញនូវសាច់រឿងរបស់ខ្លួនម្តងហើយម្តងទៀត។ ការពិត ជនរងគ្រោះដែលបានផ្តល់សក្ខីកម្មមុនការជំនុំជម្រះក៏អាច ឬត្រូវបានកោះហៅមកផ្តល់សក្ខីកម្មផងដែរ ប្រសិនបើមានលេចឡើងនូវអង្គហេតុថ្មី។

ការប្រើប្រាស់ជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់ ដូចជាសក្ខីកម្មមុនការជំនុំជម្រះជាដើម ត្រូវយកចិត្តទុកដាក់ឱ្យបានពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិសួរដេញដោលសាក្សីដាក់បន្ទុកមកលើរូបគាត់ផងដែរ។

សក្ខីកម្មមុនការជំនុំជម្រះ ត្រូវបានផ្តល់នៅក្នុង**ប្រទេសម៉ាឡេស៊ី**[១៧៧] ដែលផ្នែក ៦១ក នៃច្បាប់លេខ ៦៧០ អនុញ្ញាតឱ្យទទួលយកសក្ខីកម្មបែបនោះជាភស្តុតាង នៅពេលដែលជនរងការជួញដូរ មិនអាចរកឃើញ និងនៅក្នុងផ្នែក ២៩៥ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ* របស់**ប្រទេសសិង្ហបុរី**[១៧៨]។ *វិធានស្តីពីការពិនិត្យសាក្សីជាកុមារ*របស់**ប្រទេសហ្វីលីពីន**

[១៧៦] ច្បាប់ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០០៨ និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥) (ថៃ) ផ្នែក ៣៦។ កិច្ចខិតខំប្រឹងប្រែងធំធេងរបស់រាជរដ្ឋាភិបាលថៃ ដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅក្នុងរបាយការណ៍ឆ្នាំ២០១៤ ផ្នែក ៣.៥ សេវាសម្រាប់កុមាររងគ្រោះ។

[១៧៧] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនចំណាកស្រុក (ច្បាប់លេខ ៦៧០) (ម៉ាឡេស៊ី) ផ្នែក ៦១ក។

[១៧៨] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១០ (សិង្ហបុរី) ផ្នែក ២៩៥។

កំណត់ឲ្យសាក្សីជាជនរងគ្រោះជាកុមារផ្តល់សក្ខីកម្មមុនការជំនុំជម្រះ ព្រមទាំងសាក្សីជាមនុស្សពេញវ័យនៅក្នុងកាលៈទេសៈជាក់លាក់[១៧៩]។ ច្បាប់ជួញដូររបស់**ប្រទេសមីយ៉ាន់ម៉ា** ចែងឲ្យមានសក្ខីកម្មដែលថតជាវីដេអូ ដែលយកមកអនុវត្តក្នុងករណីចាំបាច់ដើម្បីប្រើប្រាស់ភស្តុតាងនេះ។ *ក្រមនីតិវិធីព្រហ្មទណ្ឌ* (ឆ្នាំ១៩៩៩) របស់**ប្រទេសថៃ** អនុញ្ញាតឲ្យសាក្សីផ្តល់សក្ខីកម្មមុនការជំនុំជម្រះ នៅពេលមានមូលដ្ឋានសមហេតុផលគួរឲ្យជឿថា សាក្សីនឹងចាកចេញពីប្រទេសថៃ ពុំមានអាស័យដ្ឋានជាប់លាក់ ឬរស់នៅឆ្ងាយពីតុលាការ ឬមានមូលដ្ឋានសមហេតុផលគួរឲ្យជឿថា សាក្សីនឹងទទួលរងព្យសនកម្មដោយផ្ទាល់ ឬដោយប្រយោល[១៨០]។ ជាងនេះទៀត ច្បាប់ស្តីពីការជួញដូរមនុស្សរបស់ប្រទេសថៃ មានផ្នែកពិសេសមួយដែលចែងឲ្យមានសក្ខីកម្មមុនការជំនុំជម្រះនៅគ្រប់ករណីទាំងអស់ ដោយផ្អែកលើឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាដែលកាន់សំណុំរឿងនោះ ឬក្រោយពីមានសំណើពីជនរងគ្រោះ។ បន្ទាប់មក សក្ខីកម្មមុនការជំនុំជម្រះទាំងនេះត្រូវបានចាត់ទុកជាភស្តុតាងនៅពេលជំនុំជម្រះ។ នីតិវិធីនេះធានានូវការចូលរួមរបស់សាក្សីជាជនរងគ្រោះ ទន្ទឹមនឹងនោះ ក៏កាត់បន្ថយថិរវេលាដែលជនរងគ្រោះត្រូវរង់ចាំដើម្បីផ្តល់សក្ខីកម្ម និងពេលដែលត្រូវស្នាក់នៅក្នុងជម្រក។ សក្ខីកម្មមុនការជំនុំជម្រះត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងជួញដូរមនុស្សជាច្រើននៅប្រទេសថៃ ជាពិសេស នៅពេលដែលជនរងគ្រោះជាជនបរទេស និងមានផែនការដាក់ឲ្យដំណើរការសាកល្បងនូវគម្រោងសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ដែលបានវិលត្រឡប់ទៅប្រទេសមីយ៉ាន់ម៉ាអាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីស្ថានទូតថៃនៅទីក្រុងយ៉ាងហ្គោន ទោះបីនីតិវិធីនេះមិនទាន់បានយកមកអនុវត្តច្រើនក៏ដោយ។

ជម្រើសមួយទៀតដើម្បីគាំទ្រដល់ការចូលរួមយ៉ាងមានប្រសិទ្ធភាព ពីសាក្សីជាជនរងគ្រោះជាជនបរទេស គឺអនុញ្ញាតឲ្យអ្នកដែលមានបំណង ឬត្រូវវិលត្រឡប់ទៅផ្ទះវិញ អាចធ្វើបែបនេះបាន ហើយបន្ទាប់មកជួយពួកគេក្នុងការផ្តល់ភស្តុតាងពីចម្ងាយបាន។ នៅ**ប្រទេសប្រ៊ុយណេ** *ក្រមនីតិវិធីព្រហ្មទណ្ឌ* (ឆ្នាំ២០០៧ ដែលត្រូវបានធ្វើវិសោធកម្មនៅឆ្នាំ២០១៦) អនុញ្ញាតឲ្យសាក្សី ទោះបីនៅក្នុង ឬក្រៅប្រទេសប្រ៊ុយណេ អាចផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍ ឬការថតជាវីដេអូបាន ទាំងនៅក្នុងការស៊ើបអង្កេត ការជំនុំជម្រះ កិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងផ្សេងទៀត ប្រសិនបើតុលាការយល់ឃើញថា វាប្រយោជន៍យុត្តិធម៌ដែលត្រូវធ្វើបែបនេះ[១៨១]។ ច្បាប់របស់**ប្រទេសម៉ាឡេស៊ី** ក៏អនុញ្ញាតឲ្យផ្តល់សក្ខីកម្មពីចម្ងាយដែរ តែបទប្បញ្ញត្តិនេះមិនទាន់យកមកអនុវត្តនៅក្នុងសំណុំរឿងជួញដូរមនុស្សណាមួយនៅឡើយទេ។

កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស[១៨២] របស់**ប្រទេសកម្ពុជា** ផ្តល់ឲ្យតុលាការនូវកម្រិតនៃភាពបត់បែន ទាក់ទងនឹងរបៀប និងពេលវេលាដែលសាក្សីជាជនរងគ្រោះផ្តល់ភស្តុតាងរបស់ខ្លួន។ កិច្ចព្រមព្រៀងនេះអនុញ្ញាតឲ្យសាក្សីជាជនរងគ្រោះអាចផ្តល់សក្ខីកម្មរបស់ខ្លួនតាមមធ្យោបាយសមស្របផ្សេងទៀត រួមមានតាមរយៈប្រព័ន្ធសោតទស្សន៍ ឬការថតជាវីដេអូ ឬផ្តល់សក្ខីកម្មមុនពេលជំនុំជម្រះ និងឲ្យគេអានចម្លើយនៅក្នុងពេលជំនុំ

---

[១៧៩] *វិធានស្តីពីការពិនិត្យសាក្សីជាកុមារ* (ឆ្នាំ២០០០) (ហ្វីលីពីន)។ កត់សម្គាល់ផងដែរនូវវិធានស្តីពីសក្ខីកម្មមុនការជំនុំជម្រះដែលពាក់ព័ន្ធនឹងមនុស្សពេញវ័យក្រោម *ក្រមនីតិវិធីព្រហ្មទណ្ឌ* វិធាន ១១៩ ផ្នែក ១៥។

[១៨០] ក្រមនីតិវិធីព្រហ្មទណ្ឌ (ថៃ) មាត្រា ២៣៧។

[១៨១] ក្រមនីតិវិធីព្រហ្មទណ្ឌ (ប្រ៊ុយណេ) ផ្នែក ២៣៦ខ។

[១៨២] កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង បណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស (ឆ្នាំ២០០៧) (កម្ពុជា)។

ជម្រះ។ នីតិវិធីសម្រាប់ចៅក្រមស៊ើបអង្កេតនៅប្រទេសកម្ពុជាក៏គួរត្រូវបានលើកឡើងផងដែរ ដោយសារមានលក្ខណៈដូចគ្នាទៅនឹងសក្ខីកម្មមុនការជំនុំជម្រះ នៅក្នុងទិដ្ឋភាពសំខាន់ៗមួយចំនួន។ ហាក់ដូចជាមិនមានបទប្បញ្ញត្តិដែលចែងអំពីសក្ខីកម្មមុនការជំនុំជម្រះនៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀតឡើយ។

នៅក្រោមផ្នែក ២៨១ នៃ *ក្រមនីតិវិធីព្រហ្មទណ្ឌ* របស់**ប្រទេសសិង្ហបុរី** តុលាការអាចអនុញ្ញាតឱ្យជន រងគ្រោះ ឬសាក្សីនៅក្នុងសំណុំរឿងជួញដូរមនុស្ស អាចផ្តល់ភស្តុតាងនៅពេលជំនុំជម្រះតាមរយៈប្រព័ន្ធសោត ទស្សន៍ ប្រសិនបើជនរងគ្រោះ ឬសាក្សីមានអាយុក្រោម ១៦ ឆ្នាំ ឬប្រសិនបើតុលាការយល់ឃើញថា ដើម្បីប្រយោជន៍យុត្តិធម៌ដែលត្រូវធ្វើបែបនេះ។

នៅក្នុងច្បាប់ស្តីពីការជួញដូរមនុស្ស របស់**ប្រទេសឥណ្ឌូនេស៊ី** ជនរងគ្រោះមានសិទ្ធិផ្តល់ចម្លើយជាសាក្សីនៅខាងក្រៅបន្ទប់សវនាការបាន និងសិទ្ធិដកចុងចោទចេញពីបន្ទប់សវនាការ នៅពេលសាក្សីផ្តល់ចម្លើយក្នុងតុលាការ[១៨៣]។ *ច្បាប់ស្តីពីការការពារសាក្សី និងជនរងគ្រោះ* ក៏ផ្តល់ឱ្យសាក្សីជាជនរងគ្រោះមានជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់ដែរ។ ឧទាហរណ៍ ពួកគេអាចផ្តល់សក្ខីកម្មដោយមិនបង្ហាញខ្លួននៅក្នុងសវនាការ ផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ តាមមធ្យោបាយនៅលើក្រដាស ឬតាមរយៈឧបករណ៍អេឡិចត្រូនិកបាន ក្រោយពីមានការយល់ព្រមពីចៅក្រម។ ជម្រើសផ្សេងទៀតនៃការផ្តល់សក្ខីកម្មជារឿយៗត្រូវបានយកមកប្រើប្រាស់ប្រសិនបើជនរងគ្រោះជាកុមារ។ ក៏ប៉ុន្តែ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ជម្រើសទាំងនេះត្រឹមតែ*អនុញ្ញាត* មិនមែន*តម្រូវ* ទេ។ នៅក្នុងសំណុំរឿងភាគច្រើន ចៅក្រមចង់ឱ្យសាក្សីមកផ្តល់សក្ខីកម្មក្នុងតុលាការជាង។ ការវាយតម្លៃទៅលើប្រទេសនីមួយបានកត់សម្គាល់ថា ការខកខានរបស់ជនរងគ្រោះមិនមកផ្តល់សក្ខីកម្មដោយផ្ទាល់អាចមានឥទ្ធិពលលើការកាត់បន្ថយការផ្តន្ទាទោស ប្រហែលជាខូចខាតដល់ចំណុចខ្លាំងនៃសំណុំរឿងនោះផង។

នៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត ពុំមានភាពច្បាស់លាស់អំពីស្ថានភាពគតិយុត្តិទាក់ទងនឹងជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់ សម្រាប់សាក្សីជាជនរងគ្រោះនៅក្នុងការជំនុំជម្រះលើការជួញដូរមនុស្សទេ។ ជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់នៅក្នុងករណីសាក្សីជាកុមារនឹងត្រូវយកមកពិភាក្សាបន្ថែមនៅខាងក្រោម។

## វឌ្ឍនភាពទាក់ទងនឹងការការពារ និងការគាំទ្រដល់សាក្សីជាកុមាររងគ្រោះ

ច្បាប់ គោលនយោបាយ និងនីតិវិធីនៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន (តែមិនទាំងអស់) ចែងឱ្យមានបទប្បញ្ញត្តិពិសេសសម្រាប់ការការពារក្នុងតុលាការដល់កុមារដែលផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះលើការជួញដូរ។ នេះជាការសំខាន់ពិសេសដោយហេតុថា ដំណាក់នៃការអភិវឌ្ឍន៍របស់កុមារមានឥទ្ធិពលទៅលើលទ្ធភាពរបស់កុមារក្នុងការយល់ដឹងពីកិច្ចដំណើរការនីតិវិធីក្នុងបន្ទប់សវនាការ និងភាពរសើបរបស់ពួកគេទៅនឹងបទពិសោធន៍នានាអាចធ្វើឱ្យពួកគេងាយរងគ្រោះទៅនឹងការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី។

[១៨៣] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្តីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស (ឥណ្ឌូនេស៊ី) មាត្រា ៣៤ និង ៣៧។

ច្បាប់ស្ដីពីការជួញដូរមនុស្ស របស់**ប្រទេសឥណ្ឌូនេស៊ី**ចែងថា៖

> ការស៊ើបអង្កេត ការចោទប្រកាន់ និងការពិនិត្យនៅក្នុងតុលាការ ទៅលើសាក្សី និង/ឬ កុមាររងគ្រោះ គួរត្រូវធ្វើឡើងដោយពិចារណាដល់ឧត្ដមប្រយោជន៍របស់កុមារ ដោយមិនស្លៀកពាក់ឯកសណ្ឋានផ្លូវការជាចៅក្រម ឬមន្ត្រីតុលាការ[១៨៤]។

*ច្បាប់ស្ដីពីការការពារកុមារ* របស់ឥណ្ឌូនេស៊ី ចែងនូវការការពារបន្ថែម ដោយតម្រូវឱ្យចាត់តាំងអ្នកប្រឹក្សាយោបល់ ហេដ្ឋារចនាសម្ព័ន្ធពិសេស និងមធ្យោបាយ ហើយថា អត្តសញ្ញាណរបស់កុមារមិនត្រូវបានបញ្ចេញឱ្យដឹងឡើយ។ ច្បាប់ដដែលនេះក៏ចែងផងដែរនូវការគ្រប់គ្រងពិសេស ការការពារ ការថែទាំ និងកិច្ចខិតខំប្រឹងក្នុងការស្ដារនីតិសម្បទា សម្រាប់កុមារដែលជាជនរងគ្រោះពីការចាប់ជម្រិត លក់ ឬជួញដូរ។ ឥណ្ឌូនេស៊ីក៏បាន អនុម័តនូវបទបញ្ជាទាក់ទងនឹងការបង្កើតមណ្ឌលផ្ដល់សេវាពិសេសសម្រាប់ជនរងគ្រោះពីការជួញដូរ។ បទបញ្ជាទាំងនេះបញ្ជាក់ច្បាស់ថា៖ "ក្នុងករណីដែលសាក្សី និង/ឬ ជនរងគ្រោះជាកុមារ (អនីតិជន) សេវាត្រូវផ្ដល់ជាពិសេសដើម្បីឧត្ដមប្រយោជន៍របស់កុមារ"[១៨៥]។

*ច្បាប់ប្រឆាំងការជួញដូរមនុស្ស (ឆ្នាំ២០០៨) និងវិសោធនកម្ម (លេខ ២) (ឆ្នាំ២០១៥)* របស់**ប្រទេសថៃ** តម្រូវឱ្យទីភ្នាក់ងារពាក់ព័ន្ធផ្ដល់ជំនួយដល់ជនរងការជួញដូរ ដោយទទួលស្គាល់នូវភាពខុសគ្នា នូវចំណុចនានាដូចជាអាយុជាដើម[១៨៦]។ សន្មតថា បទប្បញ្ញត្តិនេះនឹងតម្រូវថា គួរផ្ដល់ការគាំទ្រនូវកម្រិតមួយផ្សេង និងខ្ពស់ ដល់កុមាររងគ្រោះទាក់ទិននឹងការចូលរួមរបស់ពួកគេ ទៅក្នុងកិច្ចដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។ មាន*ច្បាប់ស្ដីពីវិសោធកម្មក្រមនីតិវិធីព្រហ្មទណ្ឌ (លេខ ២៦) (ឆ្នាំ២០០៧)* ដែរ ដែលចែងនូវបទប្បញ្ញត្តិនានាទាក់ទងនឹងការចូលរួមរបស់កុមារនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ និងនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដោយចែងនូវនីតិវិធីសម្រាប់ការប្រមូលចម្លើយសាក្សីពីកុមារ (ដោយអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ ឬការថតជាវីដេអូ) និងអនុញ្ញាតឱ្យមានវត្តមានរបស់ព្រះរាជអាជ្ញា មន្ត្រីសង្គមកិច្ច ឬអ្នកជំនាញចិត្តសាស្ត្រកុមារនៅពេលស៊ើបសួរ។ ការវិភាគសំណុំរឿង និងការសង្កេតនៅតាមតុលាការបង្ហាញថា យ៉ាងហោចណាស់ ជាគោលការណ៍ ព្រះរាជអាជ្ញាជាស្ត្រី ជាធម្មតាត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងការស្ដាប់ចម្លើយទាំងនេះ[១៨៧]។ ហើយក៏មានការរាយការណ៍ផងដែរថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នគរបាលភូមិន្ទថៃបានធ្វើសកម្មភាពដើម្បីបង្កើនសមត្ថភាពមន្ត្រីស៊ើបសួរជាស្ត្រី ដើម្បីគាំទ្រកុមារ និងការស៊ើបអង្កេតដែលមានរំញោចយេនឌ័រនៅក្នុងសំណុំរឿងទាក់ទងនឹងកុមារ ស្ត្រី និងការជួញដូរមនុស្ស[១៨៨]។ ក្រៅពីនេះ ប្រទេសថៃ

---

[១៨៤] ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ីលេខ ២១ ឆ្នាំ២០០៧ ស្ដីពីការលុបបំបាត់អំពើព្រហ្មទណ្ឌនៃការជួញដូរមនុស្ស (ឥណ្ឌូនេស៊ី) មាត្រា ៣៨ (ការបកប្រែក្រៅផ្លូវការ)។

[១៨៥] បទបញ្ជារដ្ឋាភិបាលលេខ ៩ ឆ្នាំ២០០៨ ស្ដីពីនីតិវិធី និងយន្តការរបស់មណ្ឌលស្ដារនីតិសម្បទាសម្រាប់សាក្សី និង/ឬ ជនរងគ្រោះពីការជួញដូរមនុស្ស ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ត្រូវបានដកស្រង់នៅក្នុង IOM គោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍ច្បាប់ និងការការពារជនរងគ្រោះពីការជួញដូរមនុស្សក្នុងការដោះស្រាយសំណុំរឿងជួញដូរមនុស្ស (IOM ឆ្នាំ២០០៩) នៅត្រង់ទំព័រ ៥២។ តាមការសន្មត ចំណុចនេះតម្រូវឱ្យអ្នកផ្ដល់សេវាគាំទ្រ និងធានានូវការគោរពដល់ឧត្តមប្រយោជន៍របស់កុមារជាក់លាក់ម្នាក់ៗ រួមទាំង ទាក់ទិននឹងការចូលរួមរបស់កុមារនៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

[១៨៦] ច្បាប់ប្រឆាំងការជួញដូរមនុស្ស ព.ស ២៥៥១ (ឆ្នាំ២០០៨) (ថៃ) ផ្នែក ៣៣។

[១៨៧] របាយការណ៍វឌ្ឍនភាពរបស់ប្រទេសថៃស្ដីពីការខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

[១៨៨] របាយការណ៍ស្ដីពីប្រទេសថៃ (ខែធ្នូ ឆ្នាំ២០១៥)។

បានពង្រីកទៅដល់ការបង្កើតបន្ទប់ពិសេសនៅតាមតុលាការនៅទូទាំងប្រទេស ក្នុងគោលបំណងទប់ស្កាត់មិនឲ្យចុងចោទឃើញជនរងគ្រោះ[១៨៩]។

នៅ**ប្រទេសថៃ** សាក្សីជាកុមារត្រូវបានអមដំណើរទៅតុលាការដោយមន្ត្រីសង្គមកិច្ច។ *ក្រមនីតិវិធីព្រហ្មទណ្ឌ*ចែងថា សាក្សីជាកុមារអាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ហើយសំណួរនានាត្រូវបានសួរម្តងហើយម្តងទៀត ឬសម្រួលឃ្លាប្រយោគតាមរយៈអ្នកឯកទេសចិត្តសាស្ត្រ ឬមន្ត្រីសង្គមកិច្ច ដល់កុមារ[១៩០]។ ប្រសិនបើកុមារ មិនអាចចូលរួមក្នុងការជំនុំជម្រះដោយសារកាលៈទេសៈពិសេស ការថតជាវីដេអូនៃការស្តាប់ចម្លើយកុមារជាមួយអ្នកស៊ើបអង្កេតអាចយកមកធ្វើជាភស្តុតាងជំនួសបាន។ ការស្តាប់ចម្លើយដែលត្រូវបានថតជាវីដេអូនេះក៏អាចយកមកបញ្ចាំងនៅក្នុងតុលាការ មុនពេលកុមារផ្តល់សក្ខីកម្ម ឬអាចចាត់ទុកជាផ្នែកនៃសក្ខីកម្មរបស់កុមារ ប្រសិនបើមានការបង្គាប់បែបនេះ។

### *ប្រអប់អត្ថបទ ២៦៖ ឧទាហរណ៍អនុវត្តន៍៖ ការការពារសាក្សីជាកុមារនៅក្នុងសំណុំរឿងជួញដូរមនុស្ស នៅក្នុងតុលាការ*

**ចៅក្រមឡាវការពារកុមាររងគ្រោះនៅក្នុងតុលាការ៖** ចៅក្រមពីប្រទេសឡាវដែលបានចូលរួមក្នុងការសិក្សាអំពីការអនុវត្តន៍ជាក់ស្តែងនូវការការពារជនរងគ្រោះជាសាក្សីនៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត បានណែនាំនូវវិធានការថ្មីនៅក្នុងតុលាការក្នុងគោលបំណងការការពារកុមាររងការជួញដូរ។ ក្នុងអំឡុងពេលជំនុំជម្រះលើសំណុំរឿងជួញដូរមនុស្សមួយនៅឆ្នាំ២០១៧ ដែលដឹកនាំដោយចៅក្រមដដែល មានការសង្កេតនូវវិធានការថ្មីៗដូចខាងក្រោម៖

- ក្នុងពេលស្តាប់សក្ខីកម្មសាក្សី មានប្រើរាំងននបាំងជនរងគ្រោះពីចុងចោទ។
- ជនរងគ្រោះបានទទួលការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មជាមួយមេធាវីតំណាងជនរងគ្រោះដែលឈរនៅក្បែរគាត់ នៅកន្លែងសាក្សី។
- ជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យនៅនៅឆ្ងាយពីមនុស្សទូទៅ និងនៅខាងក្រៅបន្ទប់សវនាការ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងអស់លើកលែងតែសក្ខីកម្មជាក់ស្តែង។ ជនរងគ្រោះពុំបានទាក់ទងជាមួយចុងចោទទាល់តែសោះ។
- ចៅក្រមបានបង្ហាញនូវភាពរសើបចំពោះជនរងគ្រោះក្នុងពេលចូលរួមរបស់ខ្លួន។

**ប្រភព៖** សេចក្តីរាយការណ៍ពី AAPTIP (ឆ្នាំ២០១៧)

នៅ**ប្រទេសមីយ៉ាន់ម៉ា** នាយកដ្ឋានសុខុមាលភាពសង្គម និងអង្គភាពការពារកុមារជាអ្នកផ្តល់ជំនួយ ដូចជា ការគាំទ្រផ្នែកចិត្តសង្គម ការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងការការពារជនរងគ្រោះជាសាក្សីតាំងពីពេលចាប់ផ្តើមសំណុំរឿងជួញដូរមនុស្ស រហូតដល់សំណុំរឿងបានបញ្ចប់ ប្រសិនបើជនរងគ្រោះជាសាក្សីជាកុមារ។

នៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត ច្បាប់ពាក់ព័ន្ធពុំបានយោងជាក់លាក់ ទៅដល់សាក្សីជាកុមារ រងគ្រោះ ឬបញ្ជាក់នូវវិធានការបន្ថែមនៅក្នុងលិខិតូបករណ៍ក្រៅពីច្បាប់។ ឧទាហរណ៍ *គោលការណ៍ណែនាំសម្រាប់ការការពារសិទ្ធិកុមាររងការជួញដូរនៃព្រះរាជាណាចក្រ* **កម្ពុជា** មានបទប្បញ្ញត្តិពិសេសសម្រាប់សាក្សីជាកុមាររងគ្រោះ។ ជា

[១៨៩] របាយការណ៍វឌ្ឍនភាពរបស់ប្រទេសថៃស្តីពីការខិតខំប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

[១៩០] ក្រមនីតិវិធីព្រហ្មទណ្ឌ (ថៃ) ផ្នែក ១៧២។

ពិសេស គោលការណ៍ណែនាំទាំងនេះតម្រូវថា មិនត្រូវបង្ខំកុមាររងការជួញដូរឱ្យធ្វើជាសាក្សីទេ អាជ្ញាធរមានសមត្ថកិច្ចជាអ្នកតម្លៃពីលក្ខណៈសម្បត្តិរបស់សាក្សីនោះមកធ្វើជាសាក្សី ហើយ សាក្សីជាកុមារគួរទទួលបានវិធានការការពារពិសេស។ វិធានការការពារទាំងនេះរួមមាន ការប្រើប្រាស់ការស្តាប់ចម្លើយដែលថតជាវីដេអូ ប្រព័ន្ធសោតទស្សន៍ និងវិធានការផ្សេងទៀតដែលពុំចាំបាច់ឱ្យកុមារមកបង្ហាញខ្លួនដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ។ *គោលការណ៍*ក៏បានផ្តល់យោបល់បន្ថែមថា កុមាររងគ្រោះត្រូវបានអមដោយអ្នកប្រឹក្សាយោបល់ ឬមន្ត្រីគាំទ្រ ក្នុងអំឡុងពេលផ្តល់ភស្តុតាង ប្រសិនបើការវាយតម្លៃផ្នែកចិត្តសាស្ត្រកុមារយល់ថាជាការចាំបាច់។ គោលការណ៍ទាំងនេះអះអាងថាគួរការពារដល់ឯកជនភាពរបស់កុមាររងការជួញដូរ នៅគ្រប់ដំណាក់កាលទាំងអស់នៃការស៊ើបអង្កេត ការចោទប្រកាន់ និងសវនាការ។ ពុំមានព័ត៌មានដែលអាចបញ្ជាក់ស្តីពីវិសាលភាពនៃការអនុវត្តន៍ទៅលើអនុសាសន៍ទាំងនេះទេ[១៩១]។

នៅ**ប្រទេសសិង្ហបុរី** *ក្រមនីតិវិធីព្រហ្មទណ្ឌ* ចែងថា តុលាការអាចអនុញ្ញាតឱ្យសាក្សីអាយុក្រោម ១៦ ឆ្នាំផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍។ សម្រាប់សំណុំរឿងដែលពាក់ព័ន្ធនឹងកុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទ វាជាកាតព្វកិច្ចតាមច្បាប់ស្តីពីការជួញដូរមនុស្សរបស់សិង្ហបុរីដែលថា កិច្ចដំណើរការនីតិវិធីតុលាការត្រូវធ្វើជាអសាធារណៈ។ សម្រាប់ជនរងគ្រោះពីការកេងប្រវ័ញ្ចផ្នែកការងារ ផ្នែក ៧ នៃ*ច្បាប់ស្តីពីតុលាការរដ្ឋ* និងផ្នែក ៨ នៃ*ច្បាប់ស្តីពីរដ្ឋបាលតុលាការកំពូល* ចែងថា តុលាការមានអំណាចស្តាប់បញ្ហានានា ឬកិច្ចដំណើរការនីតិវិធីជាអសាធារណៈបាន ប្រសិនបើតុលាការយល់ឃើញថា ជាប្រយោជន៍យុត្តិធម៌ សុវត្ថិភាពសាធារណៈ សន្តិសុខសាធារណៈ ឬទ្រព្យសម្បត្តិសាធារណៈ ឬមានមូលហេតុពេញលេញផ្សេងទៀតដែលត្រូវធ្វើបែបនេះ។ *ធម្មនុញ្ញស្តីពីស្ត្រី* ចែងថា កិច្ចដំណើរការនីតិវិធីតុលាការត្រូវធ្វើជាអសាធារណៈ នៅពេលជនរងគ្រោះពីបទល្មើសមួយចំនួន រួមមានបទល្មើសជួញដូរដែលត្រូវបានចោទប្រកាន់ក្រោមធម្មនុញ្ញស្តីពីស្ត្រី មានអាយុក្រោម ១៦ ឆ្នាំ។ ក្រៅពីនេះ តុលាការក៏អាចបង្គាប់ឱ្យមានការវិធានការបិទបាំងនានា ដូចជាមានរបាំងជាដើម ដើម្បីបញ្ចៀសមិនឱ្យជនរងគ្រោះមើលឃើញជនល្មើសក្នុងអំឡុងកិច្ចដំណើរការនីតិវិធីតុលាការ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៦ ឆ្នាំ ឬសម្រាប់ជនរងគ្រោះមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ ប្រសិនបើភាពជឿបាននៃភស្តុតាងរបស់ជនរងគ្រោះត្រូវបានកាត់បន្ថយ ដោយសារពួកគេមានការភ័យខ្លាច ឬធុញថប់ដោយសារវត្តមានរបស់ជនល្មើស។

នៅ**ប្រទេសហ្វីលីពីន** កុមារគ្រប់រូបដែលជាជនរងគ្រោះពីបទល្មើស រួមទាំងបទល្មើសជួញដូរ មានសិទ្ធិទទួលបានការការពារយ៉ាងទូលំទូលាយផងដែរ ដោយ *វិធានស្តីពីការពិនិត្យសាក្សីជាកុមារ*។ ការការពារទាំងនេះរួមមាន៖

- សិទ្ធិផ្តល់សក្ខីកម្មនៅក្នុងសវនាការសាធារណៈ លុះត្រាតែតុលាការសម្រេចដកសាធារណជន ដែលពុំមានផលប្រយោជន៍ដោយផ្ទាល់ ទៅនឹងសំណុំរឿងនោះចេញពីសាលសវនាការ។
- សិទ្ធិឆ្លើយសំណួររបស់អ្នកសម្របសម្រួល ក្រៅពីសំណួរដោយផ្ទាល់ពីមេធាវីភាគីនីមួយៗ។
- សិទ្ធិមានមនុស្សគាំទ្រម្នាក់ ឬពីរនាក់នៅពេលជំនុំជម្រះ (រួមទាំងសិទ្ធិកាន់ដៃកុមារនៅពេលផ្តល់សក្ខីកម្ម)។

---

[១៩១] ក៏ប៉ុន្តែ មានការរាយការណ៍ថា នៅឆ្នាំ២០០៩ ក្រសួងយុត្តិធម៌កម្ពុជាបានទទួលជំនួយគាំទ្រដើម្បីបង្កើតរនាំងនៅគ្រប់តុលាការទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយថា នាពេលបច្ចុប្បន្ន មានការតម្រូវថា មុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីតុលាការដែលពាក់ព័ន្ធនឹងសាក្សីជាកុមាររងគ្រោះ ចៅក្រម ឬព្រះរាជអាជ្ញាអាចសាកសួរសាក្សីថាតើពួកគេចង់ប្រើរនាំងនោះឬទេ។ សូមមើល របាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្សនៅតំបន់អាស៊ាន (ឆ្នាំ២០១១) ទំព័រ ៧៨។

- សិទ្ធិផ្លាស់ប្តូរទិដ្ឋភាពនៅក្នុងបន្ទប់សវនាការ ដើម្បីកាត់បន្ថយភាពគំរាមកំហែងដល់សាក្សីជាកុមារ រួមទាំងការអនុញ្ញាតឱ្យចៅក្រមស្លៀកពាក់សម្លៀកបំពាក់ធម្មតា និងអនុញ្ញាតឱ្យកុមារផ្តល់សក្ខីកម្មពីកន្លែងផ្សេងក្រៅពីកន្លែងសាក្សីឈរ។
- សិទ្ធិស្នើសុំផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខាងក្រៅបន្ទប់សវនាការ។
- សិទ្ធិប្រើប្រាស់របាំង កញ្ចក់មើលឃើញតែម្ខាង ឬឧបករណ៍ផ្សេងទៀត ដើម្បីបិទបាំងកុមារពីជនជាប់ចោទ។
- សិទ្ធិផ្តល់សក្ខីកម្មមុនការជំនុំជម្រះដោយថតជាវីដេអូ ដើម្បីយកទៅប្រើប្រាស់ជាភស្តុតាងនៅក្នុងតុលាការ។ និង
- សិទ្ធិរក្សាការសម្ងាត់។

វាជាការសម្ងាត់ដែលត្រូវកត់សម្គាល់ថា ការអនុវត្តន៍នូវសិទ្ធិទូលំទូលាយទាំងនេះតម្រូវឱ្យមានការរៀបចំធំធេង និងធនធានច្រើន ហើយអ្នកប្រតិបត្តិរាយការណ៍ថា ក្នុងការអនុវត្តន៍ជាក់ស្តែង សិទ្ធិទាំងនោះមិនត្រូវបានការពារឱ្យបានពេញលេញជានិច្ចកាលនោះទេ។

នៅ**ប្រទេសប្រ៊ុយណេ** *ក្រមនីតិវិធីព្រហ្មទណ្ឌ* ចែងថា ជនជាប់ចោទមិនអាចសួរដេញដោលកុមាររងគ្រោះដែលជាសាក្សីនោះទេ។ តុលាការអាចអនុញ្ញាតឱ្យកុមារ ផ្តល់ភស្តុតាងដែលបានថតជាវីដេអូបាន[១៩២]។ កត់សម្គាល់ថា វាពុំមានភាពច្បាស់លាស់ថាតើបទប្បញ្ញត្តិទាំងនេះ អាចអនុវត្តន៍ចំពោះក្រុមមនុស្សមានអាយុប៉ុន្មានឆ្នាំនោះទេ។ នៅក្នុង*ក្រមនីតិវិធីព្រហ្មទណ្ឌ* កុមារត្រូវបានកំណត់ថាជាមនុស្សដែលមានអាយុក្រោម ១៤ ឆ្នាំ ចំណែកឯច្បាប់ស្តីពីការជួញដូរមនុស្ស អនុម័តនូវបទដ្ឋានអន្តរជាតិ ដោយបញ្ជាក់ច្បាស់ថា កុមារគឺជាមនុស្សក្រោម ១៨ ឆ្នាំ។

*ច្បាប់ស្តីពីភស្តុតាងរបស់សាក្សីជាកុមារ*របស់**ប្រទេសម៉ាឡេស៊ី** អនុញ្ញាតឱ្យកុមារផ្តល់សក្ខីកម្មនៅខាងក្រោយរបាំង តាមរយៈប្រព័ន្ធសោតទស្សន៍ និងដោយការថតជាវីដេអូជាមុន។ សាក្សីជាកុមារអាចត្រូវបានសួរតាមរយៈអន្តរការីម្នាក់ ដែលអាចពន្យល់នូវសំណួរ ឬចម្លើយទៅតាមករណីចាំបាច់ ដើម្បីឱ្យសាក្សីជាកុមារអាចយល់បាន។ ច្បាប់នេះអនុវត្តចំពោះអាយុក្រោម ១៦ ឆ្នាំ មិនមែនទៅតាមបទដ្ឋានអន្តរជាតិអាយុ ១៨ នោះទេ។

មាត្រា ៧១ នៃច្បាប់ស្តីពីកុមាររបស់**ប្រទេសវៀតណាម** (ឆ្នាំ២០១៦) ចែងឱ្យមានវិធានការពារកុមារជាជនសង្ស័យ ជនរងគ្រោះ និង/ឬ សាក្សី[១៩៣]។ "ជីវិត សុខភាព សេចក្តីថ្លៃថ្នូរ កិត្តិយស និងឯកជនភាព" របស់សាក្សីជាកុមារត្រូវតែទទួលបានការការពារ[១៩៤]។ ការគាំទ្រដែលមានអាចរាប់បញ្ចូលនូវ៖ ការផ្តល់ការថែទាំសុខភាព ការព្យាបាលផ្លូវចិត្ត ការស្តារសម្បទាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ការរៀបចំឱ្យមានកន្លែងស្នាក់នៅបណ្តោះអាសន្ន និងការផ្តល់ដំបូន្មានដល់ឪពុកម្តាយ អាណាព្យាបាល និងសមាជិកគ្រួសារ[១៩៥]។ ក្រមនីតិវិធីព្រហ្មទណ្ឌចែងឱ្យមានសិទ្ធិបន្ថែមទៀតដល់សាក្សីជាកុមាររងគ្រោះ រួមមាន សិទ្ធិទទួលបានអ្នកតំណាង/អាណាព្យាបាលស្របច្បាប់ និងសិទ្ធិទទួលបានការប្រឹក្សា

---

[១៩២] *ក្រមនីតិវិធីព្រហ្មទណ្ឌ* (ប្រ៊ុយណេ) ផ្នែក ២៣៦ក និង ២៣៦ង។

[១៩៣] ច្បាប់ស្តីពីកុមារឆ្នាំ២០១៦ (វៀតណាម មាត្រា ៧១)។

[១៩៤] *ច្បាប់ស្តីពីកុមារ* (វៀតណាម) មាត្រា ៧១(៣)។

[១៩៥] *ច្បាប់ស្តីពីកុមារ* (វៀតណាម) មាត្រា ៧១(២) និង ៥០(២)។

យោបល់។ ដើម្បីការពារកុមាររងគ្រោះ តុលាការអាចសម្រេចដំណើរការជំនុំជម្រះជាអសាធារណៈ ឬពិចារណាដល់វិធានការនានាដើម្បីបញ្ចៀសការទាក់ទងដោយផ្ទាល់រវាងជនជាប់ចោទ និងកុមាររងគ្រោះ[១៩៦]។

នៅ**ប្រទេសឡាវ** កុមារត្រូវបានការពារក្រោម*ច្បាប់ស្តីពីការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ (ឆ្នាំ ២០០៦)* និង*ច្បាប់នីតិវិធីកុមារ (ឆ្នាំ២០០៣)*។ ច្បាប់នេះផ្តល់ដល់សាក្សីជាកុមាររងគ្រោះនូវសិទ្ធិទទួលបានការការពារចៀសផុតពីការបង្ខិតបង្ខំ ការគំរាមកំហែង និងគ្រោះថ្នាក់គ្រប់ប្រភេទ រួមទាំងសមាជិកគ្រួសារពួកគេផងដែរ។ ក្រៅពីនេះ កុមាររងគ្រោះពីការជួញដូរមនុស្សត្រូវបានចាត់ប្រភេទជា "កុមារត្រូវការការពារចាំបាច់" ហេតុនេះមានសិទ្ធិទទួលបាន "វិធានការបន្ទាន់" នៃការការពារ ជំនួយ និងការគាំទ្រ រួមទាំង ទាក់ទងនឹងការចូលរួមរបស់ពួកគេទៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ផងដែរ។ ប្រទេសឡាវរាយការណ៍ថា នាពេលបច្ចុប្បន្ន ចៅក្រមនៅតុលាការព្រហ្មទណ្ឌរដ្ឋធានីវៀងច័ន្ទប្រើប្រាស់វិធានការការពារជនរងគ្រោះជាប្រចាំ នៅក្នុងការជំនុំជម្រះពាក់ព័ន្ធនឹងសាក្សីជាកុមារ។ វិធានការទាំងនោះរួមមាន ការប្រើវាំងនន មានការអមដំណើរដោយអ្នកគាំទ្រសេវាសង្គមកិច្ច និងជំហានត្រៀមជាមុនផ្សេងទៀតដើម្បីបញ្ចៀសទំនាក់ទំនងរវាងជនរងគ្រោះ និងជនសង្ស័យ។

## វឌ្ឍនភាពទាក់ទងនឹងការកំណត់ឋានៈគតិយុត្តិដល់សាក្សីជាជនរងគ្រោះបរទេស

ជារឿយៗ ជនរងគ្រោះជាសាក្សីពីការជួញដូរជាជនបរទេស។ អ្នកទាំងនោះភាគច្រើនចង់វិលត្រឡប់ទៅផ្ទះខ្លួនវិញឲ្យបានឆាប់តាមដែលអាចធ្វើបាន ឬស្នាក់នៅ និងធ្វើការនៅក្នុងវិស័យដែលគ្មានការកេងប្រវ័ញ្ចនៅក្នុងប្រទេសគោលដៅ។ ដូចដែលនឹងពិភាក្សាបន្ថែមនៅក្នុងជំពូកទី ៧ ការធ្វើសមាហរណកម្មជនរងគ្រោះអាចមានឧបសគ្គដោយសារមានសម្ពាធពីគ្រួសារ ឬសហគមន៍ដែលត្រូវវិលត្រឡប់ដោយមានប្រាក់កាសជាប់នឹងខ្លួន ទោះបីមានការលំបាកយ៉ាងក៏ដោយ។ ហេតុនេះ ជនរងគ្រោះជាច្រើនចង់ចាកចេញឲ្យបំភ្លេចរឿងនេះឲ្យបានឆាប់ និងស្វែងរកការពារថ្មីជាជាងចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់ (ដែលជារឿយៗត្រូវចំណាយពេលយូរ)។

នាពេលថ្មីៗនេះ មានតែ**ប្រទេសថៃ** និង**ម៉ាឡេស៊ី**ទេដែលបានចាត់វិធានការផ្លូវច្បាប់ ដើម្បីកំណត់ស្ថានភាពគតិយុត្តិរបស់ជនរងគ្រោះពីការជួញដូរមនុស្សដែលជាជនបរទេស។ ក្នុងការអនុវត្តន៍ជាក់ស្តែង ការខកខានមិនបានកំណត់នូវស្ថានភាពគតិយុត្តិរបស់ជនរងគ្រោះបរទេស នៅក្នុងតំបន់អាស៊ានទាំងមូលអាចមានន័យថា ពួកគេត្រូវបានដាក់នៅក្នុងទីជម្រក ឬអាគារផ្សេងទៀតក្នុងអំឡុងពេលមានកិច្ចដំណើរការនីតិវិធីដែលពួកគេចូលរួម ឬក្នុងករណីមួយចំនួនអាចយូរជាងនេះ។ **ប្រទេសថៃ**បានរាយការណ៍ថា ក្នុងឆ្នាំ២០១៤ ជនរងគ្រោះបរទេសជាច្រើនត្រូវបានចេញលិខិតអនុញ្ញាតឲ្យធ្វើការក្នុងរយៈពេល ៦ខែ ដែលអនុញ្ញាតឲ្យពួកគេធ្វើការស្របច្បាប់បាននៅប្រទេសថៃ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីច្បាប់[១៩៧]។ នាយកដ្ឋានរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធ បានបង្កើតគោលការណ៍ណែនាំទាក់ទងនឹងប្រភេទការងារ សម្រាប់អ្នកកាន់លិខិតអនុញ្ញាតនោះ ហើយគោលការណ៍ណែនាំដើម្បីធានានូវការការពារ និងសុខុមាលភាពរបស់ពួកគេ។ សម្រាប់ព័ត៌មានលម្អិតស្តីពីវិសោធនកម្មទៅលើច្បាប់របស់**ប្រទេសម៉ាឡេស៊ី** ដើម្បីអនុញ្ញាតឲ្យជន

---

[១៩៦] មាត្រា ៤២៣ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០១៥ (វៀតណាម)។

[១៩៧] របាយការណ៍វឌ្ឍនភាពរបស់ប្រទេសថៃស្តីពីការខិតខំប្រឹងប្រែងប្រឆាំងការជួញដូរ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។

រងគ្រោះពីការជួញដូរមនុស្សបានចូលធ្វើការ សូមមើលជំពូកទី ២ ខាងលើ។ គម្រោងនេះត្រូវបានអនុវត្ត និងនាពេលបច្ចុប្បន្នកំពុងដំណើរការជួយសម្រួល ដើម្បីផ្តល់ជម្រើសកាន់តែទូលំទូលាយដល់ជនរងគ្រោះ។

ដូចបានលើកឡើងនៅក្នុងជំពូកទី ៣ **ប្រទេសសិង្ហបុរី**ក៏មានប្រព័ន្ធមួយដើម្បីផ្តល់លិខិតអនុញ្ញាតពិសេសដល់ពលករទេសន្តរប្រវេសន៍ ឬជនបរទេសដែលចូលរួមក្នុងការស៊ើបអង្កេតរបស់នគរបាល ឬមានសំណុំរឿងតាមផ្លូវច្បាប់ ហើយលិខិតអនុញ្ញាតធ្វើការរបស់ខ្លួនត្រូវបានលុបចោលដោយនិយោជករបស់ខ្លួន។ គម្រោងការងារបណ្តោះអាសន្ន អាចឲ្យជនរងគ្រោះពីការជួញដូរមនុស្សទទួលបានទម្រង់ការងារមួយចំនួន ហើយមានប្រាក់ចំណូល នៅពេលការស៊ើបអង្កេត និងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់កំពុងដំណើរការ។

## វឌ្ឍនភាពទាក់ទងនឹងវិធានការអនុវត្តន៍ជាក់ស្តែងផ្សេងទៀតដើម្បីជួយសាក្សីជាជនរងគ្រោះដែលផ្តល់សក្ខីកម្ម

នៅក្នុងតំបន់អាស៊ានទាំងមូល មានការវិវត្តន៍ជាវិជ្ជមានមួយចំនួន ទាក់ទងនឹងការប្រើប្រាស់វិធានការដើម្បីជួយជនរងគ្រោះជាសាក្សីដើម្បីផ្តល់សក្ខីកម្ម។ នៅ**ប្រទេសហ្វីលីពីន** ជាលក្ខណៈទ្រឹស្តី មានមន្ត្រីសង្គមកិច្ចចាំអមដំណើរជនរងគ្រោះទៅនិងមកពីតុលាការ ព្រមទាំងជួយ និងគាំទ្រដល់ជនរងគ្រោះក្នុងពេលជំនុំជម្រះទាំងមូល។ ដូចបានកត់សម្គាល់ខាងលើ ការកំហិតផ្នែកធនធាន និងការកំហិតផ្សេងទៀតមានន័យថា បទប្បញ្ញត្តិសំខាន់នេះមិនត្រូវបានយកមកអនុវត្តន៍ជាក់ស្តែងជានិច្ចកាលនោះទេ។ ក៏ប៉ុន្តែ ប្រទេសហ្វីលីពីនកំពុងដាក់ឲ្យដំណើរការសាកល្បងនូវគម្រោងមួយដែលចាត់តាំង*អ្នកសម្របសម្រួលជនរងគ្រោះជាសាក្សី* សម្រាប់គោលបំណងជាក់លាក់នៃការជួយជនរងការជួញដូរទាក់ទងនឹងគ្រប់ទិដ្ឋភាពទាំងអស់នៃការចូលរួមរបស់ពួកគេទៅក្នុងការចោទប្រកាន់ (សូមមើលប្រអប់អត្ថបទខាងក្រោម)។ នៅ**ប្រទេសឥណ្ឌូនេស៊ី** និង**មីយ៉ាន់ម៉ា** អង្គការក្រៅរដ្ឋាភិបាល ដែលចូលរួមក្នុងការផ្តល់ជំនួយដល់ជនរងគ្រោះពីការជួញដូរមនុស្សបានអមដំណើរសាក្សីទៅកាន់តុលាការ នៅក្នុងករណីមួយចំនួន។ ក៏ប៉ុន្តែ ចំណុចនេះមិនបានធ្វើជាប្រចាំទេ ហើយជាទូទៅវាអាស្រ័យទៅលើជនរងគ្រោះម្នាក់ដែលអាចទាក់ទង និង/ឬ ទទួលបានការគាំទ្រជាមុនពីអង្គការក្រៅរដ្ឋាភិបាល ពាក់ព័ន្ធ និងភាពរកបាននៃអង្គការក្រៅរដ្ឋាភិបាល ទៅនឹងធនធានដើម្បីឧបត្ថម្ភដល់សេវាគាំទ្រតុលាការ។ ក្រោម*កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និង កិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និង បណ្តាភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស* របស់**ប្រទេសកម្ពុជា** តុលាការអាចអនុញ្ញាតឲ្យមានមន្ត្រីគាំទ្រម្នាក់នៅជាមួយសាក្សីក្នុងអំឡុងពេលផ្តល់សក្ខីកម្ម។

***ប្រអប់អត្ថបទ ២៧៖ ឧទាហរណ៍អនុវត្តន៍៖***

***ការប្រើប្រាស់វិធានការបង្កើតថ្មីដើម្បីជួយជនរងគ្រោះជាសាក្សីនៅក្នុងតុលាការ***

កម្មវិធីគាំទ្រសាក្សីនៅ**ប្រទេសសិង្ហបុរី គឺបាន**ផ្តល់ការគាំទ្រដល់សាក្សីដែលងាយរងគ្រោះ ដែលផ្តល់ភស្តុតាងរបស់ខ្លួននៅតុលាការ រួមទាំងសំណុំរឿងជួញដូរផងដែរ។ អ្នកគាំទ្រស្ម័គ្រចិត្ត (VSP) និងជាប្រភពព័ត៌មានស្តីពីនីតិវិធីនៅក្នុងតុលាការ ហើយនឹងជួយសាក្សីក្នុងការគ្រប់គ្រងភាពតានតឹងផ្លូវចិត្ត ដែលអាចកើតឡើងពីកិច្ចដំណើរការនីតិវិធីនៅក្នុងតុលាការ។ នៅប្រទេសសិង្ហបុរី អ្នកគាំទ្រស្ម័គ្រចិត្ត អាចត្រូវបានចាត់តាំងសម្រាប់សាក្សីងាយរងគ្រោះនៅក្នុងសំណុំរឿងជួញដូរ ដើម្បីផ្តល់ការគាំទ្រផ្លូវចិត្តដល់សាក្សី។ តុលាការអាចអនុញ្ញាតឲ្យអ្នកគាំទ្រស្ម័គ្រចិត្តអង្គុយនៅខាងក្រោយសាក្សីក្នុងពេលសវនាការជាសាធារណៈ ឬនៅពេលសាក្សីផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នៅ

ក្នុងបន្ទប់សាក្សី ដែលនៅក្បែរបន្ទប់សវនាការ ក្នុងអំឡុងពេលជំនុំជម្រះ។ ក្រៅពីនេះជនរងគ្រោះពីការជួញដូរមនុស្ស ដែលតម្រូវឲ្យមានដំបូន្មានផ្នែកច្បាប់ មានជម្រើសក្នុងការស្នើសុំដំបូន្មានផ្នែកច្បាប់ ពីគ្លីនិកច្បាប់ដោយឥតគិតថ្លៃ។ ជនរងគ្រោះពីការជួញដូរមនុស្ស ដែលតម្រូវឲ្យមានជំនួយផ្នែកច្បាប់នឹងត្រូវបញ្ជូនទៅអង្គការពាក់ព័ន្ធ។ អង្គការសុខុមាលភាពស្ម័គ្រចិត្តជាច្រើន ជាអ្នកផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះបរទេសដែលស្នាក់នៅក្នុងប្រទេសសិង្ហបុរី។ សេវាស្ម័គ្រចិត្តរបស់ក្រុមមេធាវីនៅប្រទេសសិង្ហបុរីក៏ផ្តល់ជំនួយទៅតាមករណីជាក់ស្តែងនីមួយៗដែរ។

នៅ**ប្រទេសមីយ៉ាន់ម៉ា** ការិយាល័យអគ្គមេធាវីសហភាព បានចេញគោលការណ៍ណែនាំសម្រាប់ព្រះរាជអាជ្ញាធ្វើការស្តាប់ចម្លើយមុនពេលជំនុំជម្រះ/ការត្រៀមដើម្បី៖ កំណត់ទីកន្លែងសម្រាប់ការស្តាប់ចម្លើយត្រៀមការជំនុំជម្រះ ដែលមានលក្ខណៈឯកជនសមរម្យ ដើម្បីបង្ហាញនូវសមាណចិត្តដល់ជនរងគ្រោះ និងជំរុញឲ្យមានភាពស្មោះត្រង់ ការប្រើប្រាស់វិធីសាស្ត្រប្រឹក្សាយោបល់ ដែលអាចកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្ត និងយល់ដឹងពីអង្គហេតុដែលបានបញ្ចូលទៅក្នុងរបាយការណ៍នគរបាលឲ្យបានគ្រប់ជ្រុងជ្រោយ។

ការអមដំណើរទៅតុលាការជាបញ្ហាមួយនៅ**ប្រទេសថៃ** សម្រាប់ជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌល។ ជាធម្មតា ជនរងគ្រោះផ្សេងទៀតរំពឹងថាអាចរកផ្លូវទៅតុលាការដោយខ្លួនឯង។ ក្រសួងទទួលខុសត្រូវគាំទ្រជនរងគ្រោះរបស់ថៃបានកត់សម្គាល់ថា ជួនកាល ចុងចោទគំរាមកំហែងជនរងគ្រោះ និងសាក្សី។ នៅក្នុងករណីទាំងនេះ មន្ត្រីសង្គមកិច្ចនឹងជូនដំណឹងដល់តុលាការ ហើយចុងចោទត្រូវបានព្រមានឲ្យបញ្ឈប់ការជ្រៀតជ្រែកសាក្សី។ ការព្រួយបារម្ភពាក់ព័ន្ធគឺថា នៅក្នុងករណីមួយចំនួន អ្នកបកប្រែភាសាពុំមានកម្រិតចាំបាច់នៃឯករាជភាព ឬបកប្រែមិនបានត្រឹមត្រូវ។ ក្រសួងបានបញ្ជាក់ថា នៅពេលធ្វើការកត់សម្គាល់ទៅលើចំណុចនេះ ហើយក្រោយពេលចៅក្រមបានទទួលព័ត៌មានរួចហើយ ជាទូទៅ ចៅក្រមនឹងផ្លាស់ប្តូរអ្នកបកប្រែភាសា។

**ប្រទេសប្រ៊ុយណេ**បានរាយការណ៍ថា មានបែបបទមួយដែលតម្រូវឲ្យព្រះរាជអាជ្ញាធានាថា ជនរងគ្រោះមានការយល់ដឹងពេញលេញអំពីការផ្តល់សក្ខីកម្មនៅក្នុងតុលាការ។ ចំណុចនេះរួមទាំង ការជូនដំណឹងដល់ជនរងគ្រោះនូវសិទ្ធិរបស់ពួកគេក្នុងការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ និងការផ្សាំជនរងគ្រោះទៅនឹងបន្ទប់សវនាការកន្លែងដែលពួកគេនឹងមកផ្តល់ភស្តុតាង។

## វឌ្ឍនភាពទាក់ទងនឹងការពន្លឿនការជំនុំជម្រះលើសំណុំរឿងជួញដូរ

រយៈពេលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌដែលជនរងគ្រោះរំពឹងថានឹងចូលរួម គឺជាបញ្ហាចម្បងមួយសម្រាប់រដ្ឋសមាជិកអាស៊ានភាគច្រើន។ អ្នកប្រតិបត្តិនៅទូទាំងតំបន់បានកត់សម្គាល់ថា កាលណាការជំនុំជម្រះកាន់តែយូរ ជនរងគ្រោះកាន់តែលែងចង់ចូលរួម (រួមទាំង ដោយសារសម្ពាធពីគ្រួសារ និងលទ្ធភាពនៃការបំភិតបំភ័យពីភាគីជនជួញដូរ)។ ដំណើរការផ្លូវច្បាប់កាន់តែយូរ កាន់តែមានការលំបាកក្នុងការរក្សាបាននូវការផ្តន្ទាទោស។ ប្រទេសមួយចំនួន ដូចជា **ហ្វីលីពីន**ជាដើម កំពុងពិសោធលើការពន្លឿននូវនីតិវិធីជំនុំជម្រះ។ នាពេលថ្មីៗនេះ **ប្រទេសថៃ**បានបង្កើតផ្នែកមួយនៅក្នុងតុលាការព្រហ្មទណ្ឌដើម្បីកាន់សំណុំរឿងជួញដូរ។ ចំណុចនេះរំពឹងថានឹងធ្វើឲ្យដំណើរការជំនុំជម្រះកាន់តែមានប្រសិទ្ធភាព និងកាត់បន្ថយបន្ទុកទៅលើជនរងគ្រោះ។

*ប្រអប់អត្ថបទ ២៨៖ ឧទាហរណ៍អនុវត្តន៍៖ ការពន្លឿនការជំនុំជម្រះលើសំណុំរឿងជួញដូរមនុស្ស*

នាពេលថ្មីៗនេះ **ប្រទេសហ្វីលីពីន** បាន *អនុម័តគោលការណ៍ណែនាំដែលបានកែប្រែសម្រាប់បន្តការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌ* (សេចក្តីសម្រេច A.M. No. 15-06-10-SC)។ គោលការណ៍ណែនាំដែលបានកែប្រែដែលនឹងយកមកអនុវត្តចំពោះសំណុំរឿងជួញដូរថ្មីៗ និងដែលកំពុងរង់ចាំការសម្រេច ដោយកំណត់រយៈពេលត្រឹម ៣០០ ថ្ងៃទៅលើសំណុំរឿងព្រហ្មទណ្ឌ ចាប់ពីមានការចោទប្រកាន់ រហូតដល់ពេលចេញសាលក្រម សំណើសុំពន្យារពេលត្រូវបានហាមឃាត់។ ទោះបីមានភស្តុតាងអាចកំបាំងដែលថា ចៅក្រមមួយចំនួន កំពុងអនុវត្តវិធានការ ដើម្បីពន្លឿនការជំនុំជម្រះក៏ដោយ តែកង្វះព័ត៌មានពីរបៀបដែលការបន្តការជំនុំជម្រះប៉ះពាល់ទៅលើសំណុំរឿងជួញដូរ។

**ប្រទេសម៉ាឡេស៊ី**បានរាយការណ៍ថា ក្រោមច្បាប់ស្តីពីជួញដូរមនុស្ស[១៩៨] សំណើអាចធ្វើដោយផ្ទាល់មាត់ពីព្រះរាជអាជ្ញាសុំឱ្យជនរងការជួញដូរមកបង្ហាញខ្លួននៅក្នុងតុលាការដើម្បីសាកសួរ។ អនុផ្នែក ៥៣(៣) ចែងបន្ថែមថា ភស្តុតាងរបស់ជនរងការជួញដូរនឹងត្រូវកត់ត្រា និងបញ្ចប់ក្នុងរយៈពេល ៧ ថ្ងៃចាប់ពីថ្ងៃនៃការបង្ហាញខ្លួនជនរងការជួញដូរនៅចំពោះមុខចៅក្រមជំនុំជម្រះ។ ហេតុនេះ នៅពេលធ្វើការជំនុំជម្រះ ជាពិសេសក្នុងអំឡុងដំណាក់កាលនៃការកត់ត្រាភស្តុតាងរបស់ជនរងគ្រោះ ជាធម្មតា សំណើសុំពន្យារពេលនានាត្រូវបានផ្អាក លើកលែងមានកាលៈទេសៈដែលមិនអាចចៀសវាងបាន។

បន្ទាប់មកជនរងគ្រោះ អាចផ្តល់ភស្តុតាងរបស់ខ្លួនតាមរយៈមធ្យោបាយធម្មតា ដោយផ្ទាល់មាត់ ឬដោយប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរអនុលោមតាមផ្នែក ៤០២ខ នៃ *ក្រមនីតិវិធីព្រហ្មទណ្ឌ* [ច្បាប់លេខ ៥៩៣]។ វិធីសាស្ត្រទាំងពីរនេះនៅតែស្ថិតក្រោមការសួរដេញដោលដោយមេធាវីការពារក្តីដដែល។

ក្រសួងមហាផ្ទៃ តាមរយៈគំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សាប្រឆាំងការជួញដូរ និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ (MAPO) បានកោះប្រជុំប្រចាំខែជាមួយតំណាងមកពីភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាល រួមទាំងស្ថាប័នតុលាការផងដែរ ដើម្បីពិភាក្សាអំពីស្ថានភាពនៃការជំនុំជម្រះលើសំណុំរឿងជួញដូរមនុស្ស នៅពេលជនរងគ្រោះមិនទាន់បញ្ចប់ភស្តុតាងរបស់ខ្លួននៅក្នុងតុលាការ។ ប្រសិនបើតម្រវការនេះកើតឡើង ពាក់ព័ន្ធនឹងការពន្លឿនការជំនុំជម្រះដើម្បីឱ្យជនរងគ្រោះមកផ្តល់សក្ខីកម្ម ការរៀបចំបែបនេះអាចធ្វើបានដោយកំណត់កាលបរិច្ឆេទជំនុំជម្រះសាជាថ្មី។

ថ្វីត្បិតតែយ៉ាងនេះក្តី ការរៀបចំបែបនេះក៏ត្រូវពិភាក្សាពីភាពអាចរកបាននៃភាគីទាំងពីរនៅក្នុងតុលាការដែរមុនពេលបញ្ហានេះត្រូវបានសម្រេចជាស្ថាពរ។

---

[១៩៨] ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងប្រឆាំងការរត់ពន្ធជនទេសន្តរប្រវេសន៍ឆ្នាំ២០០៧ (ច្បាប់លេខ ៦៧០) (ម៉ាឡេស៊ី) ផ្នែក ៥២។

# ៦.៣ ការប្រឈម និងការលំបាកនាពេលអនាគត

ដូចបានកត់សម្គាល់នៅក្នុងរបាយការណ៍វឌ្ឍនភាពនេះទាំងមូលរួចមកហើយ ជាធម្មតា ការស៊ើបអង្កេត និងការចោទប្រកាន់មានការលំបាក ជួនកាលមិនអាចធ្វើបាន បើគ្មានកិច្ចសហការ និងសក្ខីកម្មរបស់ជនរងគ្រោះនោះ។ ទោះបីការចូលរួមរបស់ជនរងគ្រោះនៅក្នុងការចោទប្រកាន់ត្រូវប្រឈមនឹងគ្រោះ និងមានការលំបាកក៏ដោយ ជាពិសេសចំពោះបុគ្គលពាក់ព័ន្ធ តែជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ជនរងការជួញដូរមនុស្សគឺជាប្រភពចម្បង (ហើយជារឿយៗ) នៃភស្តុតាងដែលចាំបាច់ដើម្បីធានានូវការផ្តន្ទាទោសជនជួញដូរមនុស្សចំពោះការបំពារបំពានផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្តដែលពួកគេបានបង្កទៅលើជនរងគ្រោះ។ ហេតុនេះ ជាការសំខាន់គឺថា រដ្ឋត្រូវធ្វើការឆ្ពោះទៅស្ថានភាពមួយដែលជនរងគ្រោះពីការជួញដូរមនុស្សបានទទួលព័ត៌មានគ្រប់គ្រាន់ និងការគាំទ្រដើម្បីអាចឲ្យពួកគេចូលរួមប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ ជនរងគ្រោះដែលមានសុវត្ថិភាព សន្តិសុខ និងការគាំទ្រហាក់ដូចជាស្ថិតក្នុងស្ថានភាពដែលសក្ខីកម្មស៊ីចង្វាក់ និងមានប្រសិទ្ធភាពនៅពេលជំនុំជម្រះ។ ក៏ប៉ុន្តែ ការសម្រេចឲ្យបានតាមគោលដៅនេះជាការលំបាក ដោយសារមូលហេតុជាច្រើន ដែលមូលហេតុមួយចំនួននឹងលើកឡើងនៅក្នុងប្រអប់អត្ថបទខាងក្រោម។

*ប្រអប់អត្ថបទ ២៩៖ ឧបសគ្គរួមចំពោះការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនរងគ្រោះទៅក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចទៅលើពួកគេ*

ឧបសគ្គចំពោះការចូលរួមប្រកបដោយប្រសិទ្ធភាព របស់ជនរងគ្រោះទៅក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចទៅលើពួកគេរួមមាន៖

- **ជនរងគ្រោះមិនអាច/មិនចង់ចូលរួម**ទៅក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចទៅលើពួកគេ។
- **កង្វះធនធាន៖** ការផ្តល់ការគាំទ្រ និងការការពារដល់សាក្សីជាជនរងគ្រោះតម្រូវឲ្យមានធនធានមនុស្ស និងរូបវន្តគ្រប់គ្រាន់ ជារឿយៗដែលវាមានរយៈពេលយូរមកហើយ ដែលប្រទេសមួយចំនួនមិនអាចធ្វើបាន។
- **បញ្ហានៃភាពជឿជាក់បានរបស់ជនរងគ្រោះ៖** កម្មវិធីមួយដែលមានការគ្រប់គ្រងមិនត្រឹមត្រូវ អាចជាអាវុធសម្រាប់មេធាវីការពារក្តីដើម្បីជំទាស់ថា សក្ខីកម្មរបស់ជនរងគ្រោះទទួលឥទ្ធិពលតាមការចង់បានប្រយោជន៍ដែលកម្មវិធីផ្តល់ឲ្យ។ កម្មវិធីត្រូវតែមានគោលការណ៍ណែនាំច្បាស់លាស់ ហើយត្រូវយកមកអនុវត្តជាលក្ខណៈសត្យានុម័ត និងមានតម្លាភាព។
- **ឧបសគ្គផ្លូវច្បាប់៖** វិធានការការពារមួយចំនួន មិនអាចអនុវត្តបានដោយសារមិនមានកែប្រែទម្រង់វិធាន និងបទបញ្ញាដែលមានស្រាប់។
- **ហានិភ័យចំពោះសិទ្ធិរបស់ជនជាប់ចោទ៖** ការការពារ និងការគាំទ្រដល់ជនរងគ្រោះ មិនឲ្យប៉ះពាល់ដល់សិទ្ធិសារវ័ន្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ។ ត្រូវមានតុល្យភាពត្រឹមត្រូវរវាងសិទ្ធិរបស់ជនជាប់ចោទ និងតម្រូវការចាំបាច់របស់ជនរងគ្រោះ។
- **បញ្ហាសម្របសម្រួល៖** ត្រូវបង្កើតឲ្យមានការទុកចិត្ត និងការយល់ចិត្តគ្នាទៅវិញទៅមករវាងផ្នែកអនុវត្តន៍ច្បាប់ និងអ្នកផ្តល់សេវា ដើម្បីធានាឲ្យបាននូវវិធានការគាំទ្រ និងការពារជនរងគ្រោះមួយពេញលេញ។

- **ការសមគំនិតរបស់មន្ត្រី៖** អំពើពុករលួយ និងការយល់ឃើញពីអំពើពុករលួយនឹងបន្តធ្វើឱ្យស្មុគស្មាញដល់ការខិតខំប្រឹងប្រែងការពារជនរងគ្រោះ និងទទួលបានការទុកចិត្ត និងជំនឿជាក់ពីពួកគេ។

ត្រូវមានការទទួលស្គាល់ថា ទោះបីនៅក្នុងកម្មវិធីគាំទ្រ និងការពារសាក្សីដែលមានថវិកា និងការគ្រប់គ្រងត្រឹមត្រូវ ក៏ពុំធានាបាននូវភាពជោគជ័យទេ។ ជនរងគ្រោះនៅតែរងការគំរាមកំហែង ឬស្លុតប៉ាន់ លែងមានការជំរុញចិត្ត ឬទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មីដោយដំណើរការ។ ក៏ប៉ុន្តែ កម្មវិធីនេះជាការចាំបាច់ដើម្បីកាត់បន្ថយហានិភ័យទាំងនោះ និងចូលរួមចំណែកបង្កើនភាពជោគជ័យនៃការស៊ើបអង្កេត និងការចោទប្រកាន់។ ដូចបានកត់សម្គាល់ពីមុនរួចមកហើយ វាជាការសំខាន់សម្រាប់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវធ្វើការឆ្ពោះទៅកាត់បន្ថយការពឹងផ្អែកធ្ងន់ធ្ងរទៅលើសក្ខីកម្មរបស់ជនរងគ្រោះ។

ផ្នែកផ្សេងទៀតនៃជំពូកនេះ គូសបញ្ជាក់នូវការប្រឈមកាន់តែជាក់លាក់ នៅក្នុងវិស័យការពារ និងគាំទ្រដល់សាក្សីជាជនរងគ្រោះ ដែលរដ្ឋសមាជិកអាស៊ានកំណត់ថាមានភាពជាប់ពាក់ព័ន្ធ។ វាជាការសំខាន់ដែលត្រូវលើកឡើងជាថ្មីនូវការពញ្ញាក់ស្មារតីនេះឡើងវិញ (ដែលបានលើកឡើងរួចមកហើយនៅដើមជំពូកនេះ) ថាពុំមានព័ត៌មានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការយល់ដឹងឱ្យបានពេញលេញ ចំពោះស្ថានភាពបច្ចុប្បន្ននេះទេ។ ហេតុនេះ ការវិភាគខាងក្រោមគួរតែត្រូវចាត់ទុកថាជាការវិភាគបណ្ដោះអាសន្ន ហើយអនុសាសន៍នានាដែលបានធ្វើឡើងសម្រាប់រដ្ឋសមាជិកអាស៊ានទាក់ទងនឹងរបៀបដោះស្រាយ នូវការប្រឈមនានាដែលបានកំណត់ ក៏គួរចាត់ទុកជាអនុសាសន៍បណ្ដោះអាសន្នដែរ។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការការពារសាក្សីជាជនរងគ្រោះចៀសផុតពីការបំភិតបំភ័យ និងការសងសឹក

នៅក្នុងតំបន់អាស៊ាន ក៏ដូចជានៅផ្នែកផ្សេងទៀតក្នុងពិភពលោកដែរ ជារឿយៗ ជនរងគ្រោះពីការជួញដូរមនុស្សទទួលការស្លុតប៉ាន់ ឬបំភិតបំភ័យឱ្យជនរងគ្រោះនៅស្ងៀម។ ការសង្កេតនៅតាមតុលាការ និងការវិភាគទៅលើសំណុំរឿងដែលបានធ្វើសម្រាប់សំណៅឆ្នាំ២០១១ នៃ*របាយការណ៍វឌ្ឍនភាព* បានបញ្ជាក់ថា ជនរងគ្រោះស្ថិតក្នុងហានិភ័យពីពេលចាប់ផ្ដើម និងក្នុងដំណាក់កាលជំនុំជម្រះ។ ពុំមានភស្តុតាងបង្ហាញថាស្ថានភាពនេះមានការប្រែប្រួលទេ។ ការបំភិតបំភ័យ ឬការអុកឡុករំខានសាក្សីគឺជាឧបសគ្គចម្បងមួយចំពោះការឆ្លើយតបយ៉ាងប្រសិទ្ធភាពនៃយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្ស។ វាក៏ធ្វើឱ្យប៉ះពាល់ដល់នីតិរដ្ឋ និងទំនុកចិត្តពីសហគមន៍ទៅលើសមត្ថភាពរបស់រដ្ឋ ក្នុងការដោះស្រាយបញ្ហានិទណ្ឌភាពរបស់ឧក្រិដ្ឋជនដែរ។ ដូចដែលបានបង្ហាញនៅផ្នែក ៦.២ ខាងលើរួចមកហើយ រដ្ឋសមាជិកអាស៊ានភាគច្រើនបានបង្កើតច្បាប់ដើម្បីការពារសាក្សីជាជនរងគ្រោះពីការជួញដូរមនុស្ស។ ក៏ប៉ុន្តែ ការការពារទាំងនោះកម្រនឹងយកមកអនុវត្តន៍ជាក់ស្ដែង។

ភាពចាំបាច់នៃការការពារជនរងគ្រោះបន្តពីដំណើរការជំនុំជម្រះ និងក្រៅពីនោះ។ សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្សជាច្រើននាក់ បទពិសោធន៍នៃការផ្ដល់សក្ខីកម្ម នៅក្នុងតុលាការគឺជាបទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្តរបស់ពួកគេ។ ទោះបី គេមិនអាចដកទិដ្ឋភាពអវិជ្ជមាន នៃបទពិសោធន៍ចេញទាំងស្រុងបានក្ដី តែភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌទាំងអស់ ត្រូវមានសមត្ថភាពដើម្បីធានាថា ជនរងគ្រោះមានសុវត្ថិភាព ក្នុងពេលដែលពួកគេចូលរួម ហើយថា ការប៉ះទង្គិចផ្លូវចិត្តត្រូវបានកាត់បន្ថយតាមដែលអាចធ្វើទៅបាន។ ទោះបីកំហិតធនធានអាចរារាំងនូវការបង្កើតនូវយន្តការ និងមធ្យោបាយដែលមានចំណាយក្ដី តែជាការសំខាន់ដែលត្រូវទទួលស្គាល់ថា ការការពារជាមូលដ្ឋានក្នុងតុលាការដល់ជន

រងគ្រោះជាសាក្សីអាចផ្តល់បានដោយមានការចំណាយតិច ឬគ្មានការចំណាយអ្វីសោះ។ ឧទាហរណ៍ ប្រសិនបើកន្លែងរង់ចាំសម្រាប់សាក្សី ជាកន្លែងដែលសាធារណជនអាចចេញចូលបានដែលអាចធ្វើឱ្យសាក្សីទទួលរងការជ្រៀតជ្រែក ព្រះរាជអាជ្ញាអាចរៀបចំចាត់តាំងមន្ត្រីម្នាក់ឱ្យទៅអង្គុយរង់ចាំជាមួយជនរងគ្រោះ។ ជនរងគ្រោះដែលផ្តល់សក្ខីកម្ម ក៏អាចទទួលបានការដឹកជញ្ជូនជាឯកជនទៅតុលាការ ជាជាងពឹងផ្អែកលើការដឹកជញ្ជូនសាធារណៈ។

ជាអកុសល ការវិភាគទៅលើសំណុំរឿងបង្ហាញថា ទោះបីការការពារដែលចំណាយតិច ប្រើការប្រឹងប្រែងតិចតួច ក៏នៅមិនទាន់ទទួលបានជាប្រចាំនៅឡើយ នៅក្នុងការអនុវត្តន៍ជាក់ស្តែង។ ឧទាហរណ៍ មានភាពច្បាស់ថា ជនរងគ្រោះជាសាក្សីជាច្រើន មិនបានទទួលប្រយោជន៍ពីយុទ្ធសាស្ត្រ និងមធ្យោបាយធម្មតា ដូចជាការទស្សនាតុលាការមុនពេលជំនុំជម្រះ ការអមដំណើរការទៅតុលាការ ឬផ្លូវចូលដោយសុវត្ថិភាព ឬកន្លែងរង់ចាំឯកជន។ ដូចបានកត់សម្គាល់នៅចំណុចផ្សេងទៀតនៅក្នុងរបាយការណ៍នេះ រដ្ឋសមាជិកអាស៊ានមួយចំនួនហាក់ដូចជាមិនបានប្រកាន់យកសូម្បីតែវិធានការមូលដ្ឋាន ដើម្បីបញ្ចៀសមិនឱ្យជនរងគ្រោះ ឬសាក្សីទទួលរងការប៉ះទង្គិចផ្លូវចិត្តបន្ថែមទៀត ដោយសារដំណើរការជំនុំជម្រះនោះទេ ដូចជា ការធានាថា ជនរងគ្រោះជាសាក្សីបានទទួលព័ត៌មាន ការគាំទ្រ និងអមដំណើរគ្រប់ពេលវេលា។

រដ្ឋសមាជិកអាស៊ានដែលមានបំណងកែលម្អការការពារដល់ជនរងគ្រោះជាសាក្សី គួរពិចារណាដល់៖

- ការពង្រឹងការអនុវត្តន៍នូវសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានឯកជនភាព ដូចដែលនឹងលើកមកយកពិភាក្សាខាងក្រោម។
- ពិនិត្យឡើងវិញទៅលើច្បាប់ដែលពាក់ព័ន្ធ ដើម្បីធានាថា ការអុកឡុករំខានសាក្សី និងបទល្មើសពាក់ព័ន្ធផ្សេងទៀតត្រូវបានផ្តន្ទាទោសសមស្រប ហើយថា ជនរងគ្រោះជាសាក្សី និងគ្រួសាររបស់ពួកគេមានសិទ្ធិច្បាស់លាស់ក្នុងការទទួលបានការការពារពីការគំរាមកំហែងដល់សុវត្ថិភាពរូបវន្តរបស់ខ្លួន ដោយសារការសងសឹក និងការបំភិតបំភ័យ។
- ផ្តល់អាណត្តិការងារ និងធនធានដល់ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីធ្វើការវាយតម្លៃហានិភ័យ និងអនុវត្តនូវផែនការគ្រប់គ្រងសាក្សីយ៉ាងមានប្រសិទ្ធភាព។
- ផ្តល់ធនធានគ្រប់គ្រាន់ដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីបំពេញទៅតាមកាតព្វកិច្ចគតិយុត្តិដែលមានស្រាប់ ដើម្បីផ្តល់វិធានការការពារដែលបង្កើតឡើងដើម្បីធានាដល់សុវត្ថិភាពរបស់ជនរងគ្រោះជាសាក្សី។
- បង្កើត និងអនុវត្តវិធានការមូលដ្ឋានដែលអាចការពារជនរងគ្រោះក្នុងអំឡុងពេលជំនុំជម្រះ ដូចជាផ្តល់ការអមដំណើរ និងធានាឱ្យមានច្រកចូល និងកន្លែងរង់ចាំដាច់ដោយឡែកពីគ្នា។
- ចាត់វិធានការនានាដើម្បីកំណត់ និងដោះស្រាយហានិភ័យចំពោះជនរងគ្រោះ ក្រោយពេលដំណើការជំនុំជម្រះបានបញ្ចប់។

ACWC បានបញ្ជាក់សាជាថ្មីចំពោះអនុសាសន៍ទាំងនេះ ដោយបង្ហាញបន្ថែមថា រដ្ឋសមាជិកអាស៊ានគួរផ្តល់ការការពារបន្ទាន់ដល់អ្នកដែលអាចជាជនរងគ្រោះពីការជួញដូរមនុស្សរហូតដល់រយៈពេល ២៤ ម៉ោង នៅក្នុងដំណាក់កាលកំណត់អត្តសញ្ញាណ[១៩៩]។

---

[១៩៩] ទស្សនាវដ្តី ACWC Regional Review ជំពូកទី ៤ *អនុសាសន៍*។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការការពារឯកជនភាព

ច្បាប់ស្តីពីការការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សីមានសារៈសំខាន់ ហើយដូចបានរាយការណ៍នៅក្នុងផ្នែក ៦.២ ខាងលើ មានវឌ្ឍនភាពសំខាន់នៅក្នុងតំបន់អាស៊ាននៅក្នុងវិស័យនេះ។ ក៏ប៉ុន្តែ ការការពារក្នុងច្បាប់ជារឿងគ្មានប្រយោជន៍ បើគ្មានការអនុវត្តន៍ដោយមានប្រសិទ្ធភាព។ ជាអកុសល ជារឿយៗ ឈ្មោះ និងព័ត៌មានអត្តសញ្ញាណរបស់ជនរងគ្រោះពីការជួញដូរមនុស្ស ត្រូវបានរកឃើញនៅលើអត្ថបទកាសែត និងសារព័ត៌មានផ្សេងទៀត។ ហើយការវិភាគលើសំណុំរឿងបង្ហាញថា នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ទោះបីគេសន្មតថាចៅក្រមគួរដំណើរការសវនាការជាអសាធារណៈ នៅក្នុងសំណុំរឿងជួញដូរមនុស្សក៏ដោយ តែចំណុចនេះមិនត្រូវបានយកមកអនុវត្តជាប្រចាំទេ។ ប្រការនេះបង្ហាញថា មានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីធានាថាគោលនយោបាយ និងនីតិវិធីសមស្រប ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីអនុវត្តច្បាប់នានាដែលបង្កើតឡើងដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សី។

រដ្ឋសមាជិកអាស៊ានដែលបានអនុម័តច្បាប់ ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះជាសាក្សី គួរធ្វើការដើម្បីធានាថា ច្បាប់ទាំងនេះត្រូវបានយកមកអនុវត្តយ៉ាងមានប្រសិទ្ធភាព។ រដ្ឋសមាជិកអាស៊ានដែលពុំមានមូលដ្ឋានច្បាប់រឹងមាំសម្រាប់ការការពារនេះគួរពិចារណាអនុម័តច្បាប់ចាំបាច់ និងចាត់វិធានការនានាដើម្បីធានានូវការអនុវត្តន៍ច្បាប់ទាំងនោះយ៉ាងមានប្រសិទ្ធភាព។ *ទស្សនាវដ្តី ACWC Regional Review* បង្ហាញថា ក្នុងការកែលម្អការការពារតាមផ្លូវច្បាប់នូវឯកជនភាពរបស់ជនរងគ្រោះ និងការអនុវត្តន៍ច្បាប់ទាំងនោះ រដ្ឋសមាជិកអាស៊ាន បង្ហាញនូវបទពិសោធន៍ដែលបានជួបប្រទះ ទាំងនៅក្នុង និងក្រៅតំបន់ រួមទាំង ទាក់ទងនឹង៖

- ហាមឃាត់ការបោះពុម្ពផ្សាយនូវព័ត៌មានលម្អិត ដែលអាចឲ្យសាធារណជនដឹងពីអត្តសញ្ញាណ របស់ជនរងគ្រោះជាសាក្សី។
- បញ្ជាក់ឱ្យបានច្បាស់នូវទម្រង់នៃសារព័ត៌មាន ឬមធ្យោបាយផ្សេងទៀតដែលហាមឃាត់ ចំពោះការបញ្ចេញអត្តសញ្ញាណរបស់ជនរងគ្រោះ និង/ឬ សាក្សី។
- ពង្រីកសិទ្ធិទទួលបានឯកជនភាពដល់ជនរងគ្រោះជាមនុស្សពេញវ័យ និងកុមារ ពីគ្រប់ទម្រង់ទាំងអស់នៃការជួញដូរមនុស្ស។ និង
- បណ្តុះបណ្តាលមន្ត្រីតុលាការ និងព្រះរាជអាជ្ញាទាក់ទងនឹងការអនុវត្តន៍ចាំបាច់ ឬត្រូវបានអនុញ្ញាតដែលជួយការពារឯកជនភាពរបស់ជនរងគ្រោះ ជាពិសេ នៅក្នុងសំណុំរឿងនានាដែលទាក់ទងនឹងជន រងគ្រោះដែលងាយរងគ្រោះជាពិសេស។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការទទួលព័ត៌មាន

ទោះបីរដ្ឋសមាជិកអាស៊ានជាច្រើនបានបង្កើតសិទ្ធិទទួលព័ត៌មានតាមច្បាប់ក៏ដោយ តែជាបញ្ហាអនុវត្តន៍ជាក់ស្តែង ជនរងគ្រោះពីការជួញដូរមនុស្សនៅតំបន់អាស៊ានមិនបានទទួលព័ត៌មាននិងជំនួយជាប្រចាំ ដែលចាំបាច់ដើម្បីធានាថា ពួកគេអាចមានជម្រើសនានា និងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីច្បាប់យ៉ាងមានប្រសិទ្ធភាពនោះទេ។ មានភស្តុតាងមិនច្បាស់លាស់មួយចំនួនបង្ហាញថា ជារឿយៗជនរងគ្រោះមិនបានទទួលព័ត៌មាន អំពីវឌ្ឍនភាព និងលទ្ធផលនៃសំណុំរឿងដែលពួកគេចូលរួម នោះទេ។ ការខកខានមិនបានផ្តល់ព័ត៌មានដល់ជនរងគ្រោះ មានចាប់ដំណាក់កាលស៊ើប

អង្កេតរហូតដល់ដំណាក់កាលជាច្រើនទៀតនៃការជំនុំជម្រះ។ ព្រះរាជអាជ្ញា (និងអ្នកស៊ើបអង្កេត) មិនបានចាត់ទុកថា ការផ្តល់ព័ត៌មានអំពីវឌ្ឍនភាពនៃសំណុំរឿងដល់ជនរងគ្រោះ ជាផ្នែកនៃការងាររបស់ខ្លួនទេ។

រដ្ឋសមាជិកអាស៊ានដែលបានអនុម័តច្បាប់ដើម្បីការពារសិទ្ធិរបស់ជនរងគ្រោះ គួរធ្វើដើម្បីធានាថា ច្បាប់ទាំងនេះត្រូវបានយកទៅអនុវត្តយ៉ាងមានប្រសិទ្ធភាព រួមមាន តាមរយៈការបណ្តុះបណ្តាលដល់មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌពាក់ព័ន្ធ និងការផលិតសម្ភារផ្សព្វផ្សាយជាទម្រង់ណាមួយ និងភាសាមួយដែលជនរងគ្រោះអាចយល់បាន។ រដ្ឋសមាជិកអាស៊ានដែលពុំមានមូលដ្ឋានច្បាប់រឹងមាំសម្រាប់ការការពារនេះ គួរពិចារណាបង្កើតច្បាប់ចាំបាច់ និងធានានូវការអនុវត្តន៍ច្បាប់ទាំងនោះឲ្យមានប្រសិទ្ធភាព។

ACWC បានផ្តល់អនុសាសន៍ដល់រដ្ឋសមាជិកអាស៊ានឲ្យធានាថា ជនរងគ្រោះពីការជួញដូរមនុស្សបានទទួលព័ត៌មាន និងដំបូន្មានជាប្រចាំដែលជាសិទ្ធិមួយតាមផ្លូវច្បាប់ថា៖ (១) ស្ថានភាពគតិយុត្តិរបស់ពួកគេ រួមទាំងលក្ខណៈ ឬវិសាលភាពនៃកាតព្វកិច្ចគតិយុត្តិក្នុងការសហការជាមួយអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ប្រសិនបើមាន (២) នីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងតួនាទីរបស់ជនរងគ្រោះ (៣) វឌ្ឍនភាពនៃសំណុំរឿង និង (៤) នីតិវិធីសម្រាប់ការពាក្យបណ្តឹងការទាមទារសំណងជួសជុល និងសំណងតាមផ្លូវច្បាប់ផ្សេងទៀតដែលមាន។ ស្ថាប័ននេះបានកត់សម្គាល់បន្ថែមថា រដ្ឋសមាជិកអាស៊ានអាចលើកឡើងនូវបទពិសោធន៍នានាដែលបានជួបប្រទះ នៅក្នុង និងខាងក្រៅតំបន់ រួមទាំង ទាក់ទងនឹង៖

- អះអាងនូវសិទ្ធិតាមច្បាប់របស់ជនរងគ្រោះ ក្នុងការទទួលបានព័ត៌មានអំពីសិទ្ធិ ការការពារ និងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ដល់ជនរងគ្រោះជាភាសា និងលក្ខណៈមួយដែលពួកគេអាចយល់បាន។
- ការបណ្តុះបណ្តាលអ្នកបកប្រែភាសា ដើម្បីជួយដល់ជនរងគ្រោះពីការជួញដូរមនុស្សយ៉ាងមានប្រសិទ្ធភាព ដោយមានការយល់ដឹងកាន់តែទូលំទូលាយអំពីសិទ្ធិ និងចិត្តសាស្រ្តរបស់ជនរងគ្រោះពីការជួញដូរមនុស្ស។ និង
- បង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការ និងឧបករណ៍នានាដែលសម្រួលដល់ការផ្តល់ព័ត៌មានដល់ជនរងគ្រោះពីការជួញដូរមនុស្សនៅក្នុងដំណាក់កាលជាច្រើននៃការផ្តល់សេវា និងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ជាពិសេសសម្រាប់ជនរងគ្រោះដែលស្ថិតក្នុងមណ្ឌល[២០០]។

# ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការគាំទ្រដល់សាក្សីជាកុមាររងគ្រោះ

ជនរងគ្រោះពីការជួញដូរមនុស្សគ្រប់រូប ដែលសហការក្នុងការចោទប្រកាន់ តម្រូវឲ្យមានការគាំទ្រ និងការការពារជាបន្ត។ ក៏ប៉ុន្តែ ក្នុងការទទួលស្គាល់នូវភាពងាយរងគ្រោះពិសេសរបស់ពួកគេ កុមាររងគ្រោះ គួរទទួលបាននូវរបៀបរបបនៃការគាំទ្រ និងការការពារពិសេសមួយ។ ឧទាហរណ៍ ក្នុងដំណាក់កាលមុនការជំនុំជម្រះ គួរចាត់វិធានការទាំងអស់ដែលមានដើម្បីធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវបានតំណាងដោយអាណាព្យាបាលឯករាជ្យម្នាក់។

---

[២០០] ទស្សនាវដ្តី ACWC Regional Review ជំពូកទី ៤ *អនុសាសន៍*។

ផ្នែក ៦.២ ខាងលើបានបញ្ជាក់ថា ច្បាប់ និងនីតិវិធីរបស់រដ្ឋសមាជិកអាស៊ានភាគច្រើន ចែងឲ្យមានការការពារពិសេសក្នុងតុលាការលាតសន្ធឹងទៅដល់កុមារដែលផ្តល់សក្ខីកម្ម។ ក៏ប៉ុន្តែ ជារឿយៗ ការអនុវត្តន៍នូវការការពារដ៏សំខាន់ទាំងនេះមិនទាន់បានល្អនៅឡើយទេ។ ឧទាហរណ៍ នៅក្នុងសំណុំរឿងមួយដែលបានរាយការណ៍នៅក្នុង*របាយការណ៍វឌ្ឍនភាព*ឆ្នាំ២០១១ មានការកត់សម្គាល់ថា សាក្សីជាកុមាររងគ្រោះផ្តល់ភស្តុតាងអំពីបញ្ហាដែលមានលក្ខណរសើបជាខ្លាំង ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទ គឺកុមាររងគ្រោះមិនបានទទួលការការពារ ឬការគាំទ្រពិសេសអ្វីមួយឡើយ។ ចំណុចនេះបានកើតឡើង ទោះបីជាថា ច្បាប់ជាតិ*តម្រូវ*ឲ្យមានការការពារក្នុងតុលាការសម្រាប់កុមាររងគ្រោះ ដែលផ្តល់សក្ខីកម្មក៏ដោយ។ ការព្រួយបារម្ភជាពិសេសគឺថា ព្រះរាជអាជ្ញាដែលសួរសំណួរដល់កុមារ មិនបានស្នើសុំនូវវិធានការការពារណាមួយទេ ហើយការពិត គាត់ហាក់ដូចជាមិនបានដឹងពីលក្ខខណ្ឌតាមផ្លូវច្បាប់ដែលផ្តល់នូវវិធានការទាំងនោះទេ។ ឧទាហរណ៍នេះបង្ហាញថា មានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីធានាថា មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌគ្រប់រូប រួមទាំងព្រះរាជអាជ្ញាមានការយល់ដឹងនូវភាពរកបាន និងសារៈសំខាន់ នៃការការពារកុមារក្នុងតុលាការ ហើយថាចៅក្រមតម្រូវឲ្យប្រើប្រាស់នូវវិធានការទាំងនោះនៅក្នុងកាលៈទេសៈសមស្រប។

នៅក្នុង*ទស្សនាវដ្តី Regional Review* របស់ខ្លួន ACWC បានផ្តល់យល់ថា រដ្ឋសមាជិកអាស៊ាននឹងបានប្រយោជន៍ពីការពិនិត្យទៅលើច្បាប់ និងនីតិវិធីរបស់ខ្លួនដែលអនុវត្តចំពោះកុមាររងគ្រោះដែលអាច ឬកំពុងចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងនាមជាសាក្សី។ ACWC បានផ្តល់អនុសាសន៍ថា ការពិនិត្យនេះ ផ្តល់ទៅលើការវាយតម្លៃ ថាតើការអនុវត្តន៍ និងនីតិវិធីបច្ចុប្បន្នស្របទៅនឹងបទដ្ឋានចាំបាច់នៃ “ឧត្តមប្រយោជន៍របស់កុមារ” ដែរឬទេ។ ស្ថាប័ននេះបានកត់សម្គាល់ថា រដ្ឋសមាជិកអាស៊ានអាចលើកឡើងនូវបទពិសោធន៍ដែលបានជួបប្រទះនៅក្នុង និងខាងក្រៅតំបន់ រួមទាំង ទាក់ទងនឹង៖

- ការជូនដំណឹងដល់កុមារនូវសិទ្ធិរបស់ពួកគេ ដំណើរការការពារ និងកិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ជាភាសាមួយ និងលក្ខណៈ/វិធីសាស្ត្រដែលសមស្របទៅនឹងអាយុពួកគេ។
- ចាត់តាំងអាណាព្យាបាលម្នាក់ ក្នុងដំណាក់កាលមុនការជំនុំជម្រះ ដើម្បីតំណាងកុមារ និង វាយតម្លៃ និងធានាដល់ឧត្តមប្រយោជន៍របស់ពួកគេ។
- ធ្វើការវាយតម្លៃ ដើម្បីកំណត់ថាតើវាជាឧត្តមប្រយោជន៍របស់កុមារឬទេ ដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយមានជំនួយពីអ្នកឯកទេសចិត្តសាស្ត្រកុមារ ឬមន្ត្រីសង្គមកិច្ច។
- អនុញ្ញាតឲ្យសាក្សីជាកុមារផ្តល់សក្ខីកម្មជាអសាធារណៈ ឬនៅបន្ទប់មួយដោយឡែក ដោយមានវត្តមានរបស់អ្នកជំនាញចិត្តសាស្ត្រ/មន្ត្រីសង្គមកិច្ច។ និង
- អនុញ្ញាតឲ្យសួរសំណួរដល់សាក្សីជាកុមារដោយអ្នកឯកទេសចិត្តសាស្ត្រ ឬមន្ត្រីសង្គមកិច្ច។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងការសម្របសម្រួលនូវការចូលរួមយ៉ាងមានប្រសិទ្ធភាពពីសាក្សីជាជនរងគ្រោះបរទេស

ដូចបានកត់សម្គាល់នៅក្នុងផ្នែក ៦.២ ខាងលើ ជារឿយៗ សាក្សីជាជនរងគ្រោះជាជនបរទេសដែលមានបំណងចង់វិលត្រឡប់ទៅផ្ទះវិញ ឬស្នាក់នៅ និងទទួលការអនុញ្ញាតឲ្យធ្វើការ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន មិនទាន់មានលទ្ធភាពតាមផ្លូវច្បាប់សម្រាប់កំណត់ឋានៈរបស់ជនរងគ្រោះ ឧទាហរណ៍ តាម រយៈការផ្តល់ទិដ្ឋាការដល់ពួកគេ ថាជាអ្នកស្នាក់នៅបណ្តោះអាសន្ននៅឡើយទេ។ ក្នុងចំណោមរដ្ឋសមាជិកអាស៊ានដែលមានការវឌ្ឍនភាព

ទាក់ទងនឹងការផ្តល់សិទ្ធិរស់នៅ និងធ្វើការដល់សាក្សីជាជនរងគ្រោះនោះ នៅមានការលំបាកក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពដែរ។

ជាទ្រឹស្តី ពុំមានជនរងគ្រោះជាសាក្សីណាម្នាក់នៅក្នុងសំណុំរឿងជួញដូរមនុស្ស ត្រូវបានបង្ខំឱ្យស្ថិតនៅក្នុងប្រទេសគោលដៅ ដើម្បីត្រឹមតែឱ្យពួកគេអាចស្នាក់នៅ និងផ្តល់សក្ខីកម្មនោះទេ។ ក៏ប៉ុន្តែ នៅក្នុងស្ថានភាពជាក់ស្តែងគឺថា នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ជនរងគ្រោះពីការជួញដូរមនុស្សជាជនបរទេសត្រូវបានឃុំនៅក្នុងមណ្ឌលរហូតទាល់តែសំណុំរឿងនៅតុលាការត្រូវបានបញ្ចប់ និង/ឬ មានការសម្រេចតាមវិធីផ្សេងទៀតថា ត្រូវធ្វើមាតុភូមិវត្តន៍ដល់ជនរងគ្រោះ។ ចំណុចនេះអាចធ្វើឱ្យជនរងគ្រោះពីការជួញដូរមនុស្សត្រូវស្ថិតនៅក្នុងមណ្ឌលរយៈពេលជាច្រើនខែ ឬឆ្នាំ ជារឿយៗដោយមានទំនាក់ទំនងតិចតួច ឬគ្មានទាល់តែសោះជាមួយមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ហើយជារឿយៗបានទទួលព័ត៌មានតិចតួច ឬគ្មានទាល់តែសោះអំពីស្ថានភាពនៃសំណុំរឿងនោះ។ ការឃុំឃាំងនេះអាចបង្កើតជាស្ថានភាពមួយ ដែលជនរងគ្រោះពីការជួញដូរមនុស្ស នឹងមិនសហការជាមួយមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ហើយពួកគេតែបដិសេធថាពួកគេមិនមែនជាជនរងគ្រោះ ដើម្បីពួកគេអាចត្រូវបានបញ្ជូនត្រឡប់មកផ្ទះវិញ ឬគេចចេញពីការឃុំឃាំង។ ស្ថានភាពទាំងនេះ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជនរងគ្រោះ ហើយពួកគេពុំបានផ្តល់ប្រយោជន៍ដល់ប្រតិបត្តិការ របស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌយ៉ាងមានប្រសិទ្ធភាពទេ។

ដើម្បីជួយសម្រួលឱ្យមានការចូលរួមយ៉ាងមានប្រសិទ្ធភាពពីសាក្សីជាជនរងគ្រោះបរទេស នៅក្នុងការចោទប្រកាន់ជនកេងប្រវ័ញ្ចមកលើពួកគេ រដ្ឋសមាជិកអាស៊ានគួរពិចារណា៖

- បង្កើតនីតិវិធីច្បាស់លាស់ មានតម្លាភាព និងអាចព្យាករណ៍បាន ដើម្បីអាចឱ្យមានការកំណត់នូវស្ថានភាពដល់ជនរងគ្រោះបរទេស សម្រាប់ថិរវេលាដែលពួកគេចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ផ្សេងទៀត (ដូចជា ទាក់ទិននឹងសំណងនានា រួមមានសំណងជួសជុលជាដើម)
- ធានាថា ដាក់ឱ្យមានយន្តការ និងនីតិវិធីដើម្បីអាចឱ្យដំណើរការកំណត់ស្ថានភាពនេះកើតឡើងនៅក្នុងសំណុំរឿងទាំងអស់ដែលសមស្រប ដោយគ្មានការពន្យារពេល
- ចៀសវាងការឃុំឃាំងជនរងការជួញដូរមនុស្សបរទេស តាមរយៈការកំណត់ស្ថានភាពគតិយុត្តិរបស់ពួកគេ (ការធ្វើទេសន្តរប្រវេសន៍ និងរកការងារធ្វើ) និងវិធានការសមស្របផ្សេងទៀត
- អនុញ្ញាតឱ្យប្រើប្រាស់សក្ខីកម្មមុនការជំនុំជម្រះ (ដោយមានគំនិតផ្តួចផ្តើមពីព្រះរាជអាជ្ញាព្រមទាំងមានសំណើពីជនរងគ្រោះ) ដើម្បីធានាការចូលរួមរបស់សាក្សីជាជនរងគ្រោះ និងកាត់បន្ថយថិរវេលាដែលជនរងគ្រោះត្រូវរង់ចាំដើម្បីផ្តល់សក្ខីកម្ម
- ស្វែងរកជម្រើសនានាសម្រាប់ជនរងគ្រោះទាំងឡាយ ដែលចង់ ឬចាំបាច់ត្រូវវិលត្រឡប់មកផ្ទះវិញ ដើម្បីអាចផ្តល់សក្ខីកម្ម ពីប្រទេសកំណើតរបស់ខ្លួនបាន (ឧទាហរណ៍ តាមរយៈប្រព័ន្ធសោតទស្សន៍ ជាដើម)។

| ជំពូកទី ៦ បញ្ជីត្រួតពិនិត្យ៖ ជនរងគ្រោះពីការជួញដូរមនុស្សទទួលបានការគាំទ្រយ៉ាងពេញលេញក្នុងនាមជាសាក្សី | |
|---|---|
| លេខយោង | បទដ្ឋានគុណភាព |
| ៦ | ជនរងគ្រោះពីការជួញដូរមនុស្សបានទទួលការគាំទ្រយ៉ាងពេញលេញក្នុងនាមជាសាក្សី |
| ៦.១ | ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិគាំទ្រយ៉ាងពេញលេញដល់ជនរងគ្រោះជាសាក្សី |
| ៦.១.១ | ក្របខ័ណ្ឌគតិយុត្តិ ចែងពីការការពារដល់ឯកជនភាព និងអត្តសញ្ញាណរបស់ជនរងគ្រោះនៅក្នុងសំណុំរឿងសមស្រប ដោយពិចារណាដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ |
| ៦.១.២ | ក្របខ័ណ្ឌគតិយុត្តិផ្ដល់ដល់ជនរងគ្រោះនូវសិទ្ធិទទួលបានដំបូន្មានផ្នែកច្បាប់ឯករាជ្យ និងសិទ្ធិទទួលបានព័ត៌មានស្ដីពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ ព្រមទាំងកិច្ចដំណើរការនីតិវិធីតុលាការពាក់ព័ន្ធ និងកិច្ចដំណើរការនីតិវិធីផ្នែករដ្ឋបាល |
| ៦.១.៣ | ក្របខ័ណ្ឌគតិយុត្តិ ផ្ដល់ដល់ជនរងគ្រោះនូវសិទ្ធិបង្ហាញខ្លួន និងទទួលការពិចារណាទៅលើការព្រួយបារម្ភ និងទស្សនៈរបស់ពួកគេ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជួញដូរមនុស្ស |
| ៦.១.៤ | ក្របខ័ណ្ឌគតិយុត្តិ ផ្ដល់ដល់ជនរងគ្រោះដែលចូលរួមទៅក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ នូវសិទ្ធិទទួលការការពារ និងការគាំទ្រ រួមទាំង ការស្នាក់នៅមានសុវត្ថិភាព ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការប្រឹក្សាផ្នែកចិត្តសាស្ត្រ និងការគាំទ្រផ្នែកអប់រំ ការងារ និងហិរញ្ញវត្ថុ ក្នុងករណីសមស្រប។ |
| ៦.១.៥ | ក្របខ័ណ្ឌគតិយុត្តិ ចែងឲ្យមានការស្ដាប់ចម្លើយពីជនរងគ្រោះមុនពេលជំនុំជម្រះ និងទទួលយកជា ភស្តុតាងពេញលេញនៅពេលជំនុំជម្រះ ក្រោមកាលៈទេសៈដែលការពារដល់សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ |
| ៦.១.៦ | ក្របខ័ណ្ឌគតិយុត្តិ ចែងនូវបទប្បញ្ញត្តិពិសេសឲ្យមានការយកចិត្តទុកដាក់ និងថែទាំចំពោះសាក្សីជាកុមារ (សូមមើលផងដែរ ជំពូកទី ៥ បញ្ជីត្រួតពិនិត្យ) |
| ៦.១.៨ | ច្បាប់ និងនីតិវិធីធានាថា ជនរងគ្រោះមិនត្រូវបានចោទប្រកាន់ចំពោះការចូលរួមរបស់ពួកគេទៅក្នុងសកម្មភាពខុសច្បាប់ដែលបានប្រព្រឹត្តដោយផលវិបាកនៃស្ថានភាពរបស់ពួកគេដែលទទួលរងការជួញដូរមនុស្ស។ |
| ៦.១.៩ | ក្របខ័ណ្ឌគតិយុត្តិ ផ្ដល់ដល់ជនរងគ្រោះនូវការទទួលបានសំណងជួសជុលពិតប្រាកដ និងមានប្រសិទ្ធភាពចំពោះព្យសនកម្ម និង សំណងបដិទានចំពោះការបាត់បង់ដែលបានទទួលរងដោយសារការរងការជួញដូរមនុស្ស |
| ៦.២ | ជនរងគ្រោះពីការជួញដូរ បានទទួលការលើកទឹកចិត្ត និងគាំទ្រដើម្បីសហការក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះជនជួញដូរមនុស្ស |
| ៦.២.១ | ដាក់ឲ្យមាន និងដំណើរការនូវរចនាសម្ព័ន្ធ និងនីតិវិធីដែលសម្របសម្រួលនូវការសហការរបស់ជនរងគ្រោះ (ដូចជាការរៀបចំឲ្យមានទិដ្ឋាការពិសេសសម្រាប់ជនរងគ្រោះបរទេស) |
| ៦.២.២ | ឯកជនភាព និងអត្តសញ្ញាណរបស់សាក្សីជាជនរងគ្រោះ ត្រូវបានការពារទៅដល់កម្រិត ដែលមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ |
| ៦.២.៣ | ជនរងគ្រោះបានទទួលព័ត៌មានពេញលេញ អំពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគេ រួមទាំង សិទ្ធិរបស់ពួកគេក្នុងការស្នើសុំសំណងជួសជុល និងសំណងបដិទាន និង ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនីតិវិធីតុលាការ និងកិច្ចដំណើរការនីតិវិធីផ្នែករដ្ឋបាល |

| ជំពូកទី ៦ បញ្ជីត្រួតពិនិត្យ៖ ជនរងគ្រោះពីការជួញដូរមនុស្សទទួលបានការគាំទ្រយ៉ាងពេញលេញក្នុងនាមជាសាក្សី | |
|---|---|
| ៦.២.៤ | ទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងភ្នាក់ងារគាំទ្រជនរងគ្រោះ ត្រូវសហការគ្នា និងផ្តល់ដល់ជនរងគ្រោះដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ ដោយមានការការពារ និងការគាំទ្រសម្រាប់ចិរវេលាដែលពួកគេចូលរួម |
| ៦.២.៥ | ជនរងគ្រោះបរទេសដែលចូលរួមទៅក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ មិនត្រូវបានធ្វើមាតុភូមិនិវត្តន៍ផ្ទុយពីឆន្ទៈរបស់ខ្លួន រហូតទាល់តែកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ត្រូវបានបញ្ចប់ រួមទាំង កិច្ចដំណើរការនីតិវិធីនានាស្របទៅតាមសិទ្ធិរបស់ពួកគេក្នុងការស្នើសុំ និងទទួលបានសំណង |
| ៦.២.៦ | ជនរងគ្រោះបរទេសនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មិនតម្រូវឱ្យស្ថិតនៅក្នុងប្រទេសផ្ទុយពីឆន្ទៈរបស់ខ្លួន ក្នុងគោលបំណងផ្តល់សក្ខីកម្មនោះឡើយ។ អ្នកដែលវិលត្រឡប់មកផ្តល់សក្ខីកម្មនាពេលបន្ទាប់ ឬសហការនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌតាមវិធីផ្សេងទៀត បានទទួលការការពារ និងការគាំទ្រយ៉ាងពេញលេញ ក្នុងចិរវេលានៃការស្នាក់នៅរបស់ខ្លួនក្នុងប្រទេសនោះ |
| ៦.៣ | ការអនុវត្តន៍ជាក់ស្តែង និងនីតិវិធីនៃការចោទប្រកាន់ និងផ្នែកតុលាការគាំទ្រយ៉ាងពេញលេញដល់ការចូលរួមរបស់ជនរងគ្រោះទៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ជនជួញដូរមនុស្ស |
| | ក្នុងករណីសមស្រប ត្រូវមានបុគ្គលទទួលខុសត្រូវដែលមានគុណសម្បត្តិគ្រប់គ្រាន់ ត្រូវបានចាត់តាំងឱ្យបំពេញតួនាទីជាអ្នកសម្របសម្រួលដល់សាក្សីជាជនរងគ្រោះ ដើម្បីធានានូវការផ្តល់ និងការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពនូវវិធានការគាំទ្ររូបវ័ន្ត និងផ្នែកតុលាការ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលកិច្ចដំណើរការនីតិវិធីដែលជនរងគ្រោះចូលរួម។ |
| ៦.៣.១ | ដាក់ឱ្យមានបទប្បញ្ញត្តិគតិយុត្តិ និង/ឬ ជាក់ស្តែង ស្របទៅនឹងសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីសម្របសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះទៅក្នុងដំណើរការព្រហ្មទណ្ឌ។ បទប្បញ្ញត្តិទាំងនេះអាចរួមមាន៖ ការស្តាប់ចម្លើយយកភស្តុតាងជាសម្ងាត់ ការជំនុំជម្រះជាអសាធារណៈ ការហាមឃាត់មិនឱ្យសារព័ត៌មានបញ្ចេញអត្តសញ្ញាណរបស់ជនរងគ្រោះ ការទទួលយកភស្តុតាងជាខ្សែវីដេអូ ឬសក្ខីកម្មមុនការជំនុំជម្រះ បន្ទប់រង់ចាំដាច់ដោយឡែកនៅក្នុងតុលាការ និងការអមដំណើរទៅតុលាការ។ |
| ៦.៣.២ | តុលាការគួរការពារអត្តសញ្ញាណជនរងគ្រោះយ៉ាងសកម្ម ទៅដល់កម្រិតដែលមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ |
| ៦.៣.៣ | អាចធ្វើឱ្យមាន សន្តិសុខ និងការការពារ និងផ្តល់ដល់សាក្សី និងគ្រួសារពួកគេក្នុងករណីចាំបាច់ នៅក្នុងសំណុំរឿងសមស្រប និងនៅគ្រប់ដំណាក់កាលចាំបាច់ទាំងអស់ រួមទាំងក្រោយការជំនុំជម្រះផងដែរ |
| ៦.៣.៤ | ស្ថិតក្រោមក្របខ័ណ្ឌគតិយុត្តិជាធរមាន អាចធ្វើឱ្យមាន ការប្រឹក្សាយោបល់តាមផ្លូវច្បាប់ដោយឥតគិតថ្លៃ ដោយឯករាជ្យ និងដែលមានសមត្ថភាព និងផ្តល់ជនរងគ្រោះនៅក្នុងដំណើរការតុលាការ រួមទាំង ដោយមានការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ក្នុងករណីសមស្រប។ |
| ៦.៣.៥ | ផ្តល់សេវាបកប្រែភាសាដោយឥតគិតថ្លៃ និងដោយឯករាជ្យដល់សាក្សីដែលត្រូវការសេវាទាំងនោះក្នុងអំឡុងដំណើរការតុលាការ |
| ៦.៤ | សិទ្ធិអំណាចក្នុងការចោទប្រកាន់ និងតុលាការចែងជាបទប្បញ្ញត្តិពិសេសសម្រាប់ការការពារជនរងគ្រោះជាកុមារ រួមទាំង ការគាំទ្រ ការការពារអត្តសញ្ញាណ និងជម្រើសផ្សេងក្តៅពីការផ្តល់សក្ខីកម្មដោយផ្ទាល់ |
| ៦.៤.១ | មុនពេលធ្វើការសម្រេចថាតើគួរ ឬមិនគួរអនុញ្ញាតឱ្យជនរងគ្រោះជាកុមារចូលរួមក្នុងនាមជាសាក្សីជាជនរងគ្រោះទៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវធ្វើការវាយតម្លៃយ៉ាងទូលំទូលាយរវាងភ្នាក់ងារជាច្រើន។ នៅក្នុងដំណើរ |

| ជំពូកទី ៦ បញ្ជីត្រួតពិនិត្យ៖ ជនរងគ្រោះពីការជួញដូរមនុស្សទទួលបានការគាំទ្រយ៉ាងពេញលេញក្នុងនាមជាសាក្សី | |
|---|---|
| | ការនេះ និងនៅពេលពុំមានឪពុក/ម្ដាយ ឬ អាណាព្យាបាលសមរម្យ ត្រូវចាត់តាំងមនុស្សណាម្នាក់ដែលមានគុណសម្បត្តិសមស្របធ្វើជាតំណាងសិទ្ធិ និងផលប្រយោជន៍របស់កុមារ។ |
| ៦.៤.២ | ដំណើរការវាយតម្លៃរវាងភ្នាក់ងារជាច្រើនកំណត់ជាអប្បបរមានូវចំណុចនានាដូចខាងក្រោម៖<br>• តើការចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌបង្កើតនូវហានិភ័យទាំងនេះទៅនឹងសុខុមាលភាពផ្លូវកាយ ផ្នែកវេជ្ជសាស្ត្រ ផ្នែកចិត្តសាស្ត្រ ឬផ្លូវចិត្តរបស់កុមារ ផ្ទុយទៅនឹងឧត្តមប្រយោជន៍របស់ខ្លួន ឬយ៉ាងណា<br>• តើបទល្មើសអាចត្រូវបានចោទប្រកាន់តាមមធ្យោបាយផ្សេងទៀត ដោយមិនពឹងផ្អែកទៅលើភស្តុតាង និងសក្ខីកម្មរបស់កុមាររងគ្រោះ<br>• ទៅតាមអាយុ ភាសា និងកម្រិតនៃការអប់រំ និងសមត្ថភាពប្រាជ្ញាស្មារតីរបស់កុមារអាចជួយឲ្យគេយល់ដឹងពីព័ត៌មានពាក់ព័ន្ធនឹងនីតិវិធី និងសំដែងទស្សនៈរបស់ខ្លួន និងយល់ព្រមចំពោះនីតិវិធីទាំងនោះ<br>• ភាពអាចរកបាននៃបុគ្គលិកដែលមានជំនាញសមស្របពេញលេញ ដើម្បីគ្រប់គ្រងកុមារយ៉ាងមានសុវត្ថិភាពក្នុងនាមជាអ្នកចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ<br>• វិធានតាមផ្លូវច្បាប់ និងនីតិវិធីដែលមានដើម្បីគាំទ្រដល់ការចូលរួមរបស់កុមារ ប្រសិនបើមានការអនុញ្ញាត ដូចជាភស្តុតាង និងសក្ខីកម្មថតជាវីដេអូ និងវិធានគាំទ្រនៅក្នុងតុលាការ |

# ជំពូកទី ៧៖ កិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព

ធាតុផ្សំទាំងអស់នៃបទល្មើសជួញដូរមនុស្ស អាចកើតឡើងនៅក្នុងព្រំដែន ហើយជនល្មើស ជនរងគ្រោះ និងភស្តុតាងត្រូវបានរកឃើញនៅក្នុងរដ្ឋដដែលនោះ។ ក៏ប៉ុន្តែ ជាធម្មតា សំណុំរឿងជួញដូរមនុស្សមានភាពស្មុគស្មាញជាងនេះឆ្ងាយណាស់។ ជនល្មើស ជនរងគ្រោះ ភស្តុតាង និងទ្រព្យត្រូវបានរកឃើញនៅក្នុងរដ្ឋពីរ ឬច្រើន។ ស្ថានភាពនៃអង្គហេតុដដែលនេះអាចគាំទ្រ និងនាំឲ្យមានការស៊ើបអង្កេតព្រហ្មទណ្ឌ និងការចោទប្រកាន់នៅក្នុងយុត្តាធិការជាច្រើន។ យន្តការកិច្ចសហប្រតិបត្តិការក្រៅផ្លូវការ ដូចជា កិច្ចសហប្រតិបត្តិការរវាងមន្ត្រីនគរបាលនិងមន្ត្រីនគរបាល ព្រមទាំងលិខិតូបករណ៍គតិយុត្តិនានា ដូចជា ការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក គឺជាមធ្យោបាយសំខាន់នៃការលុបបំបាត់ជម្រកដ៏មានសុវត្ថិភាព និងបញ្ចប់កម្រិតខ្ពស់នៃនិទណ្ឌភាពដែលជនកេងប្រវ័ញ្ចទទួលបាន។ កិច្ចសហប្រតិបត្តិការជាអន្តរជាតិក៏ផ្តល់ផងដែរនូវកាលានុវត្តភាពដ៏មានតម្លៃ ដើម្បីរារាំងនូវដំណើរការជួញដូរ ចាប់ពីការជ្រើសរើសរហូតដល់ការកេងប្រវ័ញ្ច។

សារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិត្រូវបានទទួលស្គាល់នៅកម្រិតអន្តរជាតិ ព្រមទាំងនៅថ្នាក់តំបន់។ ឧទាហរណ៍ នៅក្នុងបុព្វកថានៃ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* រដ្ឋសមាជិកអាស៊ានអះអាងពី "ការប្តេជ្ញាចិត្តរបស់ខ្លួនឲ្យមានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងជាអន្តរជាតិកាន់តែខ្លាំងក្លា និងកាន់តែមានប្រសិទ្ធភាពប្រឆាំងនឹងការជួញដូរមនុស្ស" ដោយទទួលស្គាល់ថា៖

កិច្ចសហប្រតិបត្តិការត្រូវធ្វើជាចាំបាច់ដើម្បីធានាបានជោគជ័យនូវការស៊ើបអង្កេត ការចោទប្រកាន់ និងការលុបបំបាត់ទីជម្រកសុវត្ថិភាពសម្រាប់ចារី និងជនសមគំនិតទៅក្នុងការជួញដូរមនុស្ស និងការការពារយ៉ាងមានប្រសិទ្ធភាព និងជំនួយដល់ជនរងគ្រោះពីការជួញដូរ។

ដើម្បីសម្រេចតាមគោលបំណងនេះ រដ្ឋភាគីនៃ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* ទាំងអស់ត្រូវប្តេជ្ញាចិត្តរួមគ្នា៖

> ពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរមនុស្ស **(មាត្រា ១២(ឃ))**

បទពិសោធន៍បានបង្ហាញថា កិច្ចសហប្រតិបត្តិការជាអន្តរជាតិអាចសម្របសម្រួលទិដ្ឋភាពជាច្រើននៃការស៊ើបអង្កេត និងការចោទប្រកាន់ទៅលើការជួញដូរ។ ឧទាហរណ៍ នៅក្នុងតំបន់អាស៊ាន និងនៅទីកន្លែងផ្សេងទៀត កិច្ចសហប្រតិបត្តិការរវាងមន្ត្រីនគរបាលនិងមន្ត្រីនគរបាលត្រូវបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណ និងជួយសង្គ្រោះជនរងគ្រោះពីការជួញដូរ និងចាប់ខ្លួនជនសង្ស័យ។ ជំនួយផ្នែកច្បាប់ទៅវិញទៅមកត្រូវបានប្រើប្រាស់ ដើម្បីធានានូវ

ភស្តុតាងសំខាន់ដែលអាចធ្វើឲ្យមានការចោទប្រកាន់ ឬការចោទប្រកាន់កាន់តែរឹងមាំ។ លិខិតូបករណ៍នៃការធ្វើបត្យាប័នក៏ត្រូវបានយកមកប្រើប្រាស់ ដើម្បីធានាថា ជនសង្ស័យត្រូវបានបញ្ជូនត្រឡប់ទៅយុត្តាធិការសមស្រប និងប្រឈមនឹងការជំនុំជម្រះពីបទល្មើសពាក់ព័ន្ធនឹងការជួញដូរ។

## ការកំហិត និងឧបសគ្គនៅក្នុងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ

ទោះបីមានការអះអាងពីសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរក៏ដោយ តែជាការសំខាន់ផងដែរដែលត្រូវកត់សម្គាល់តាំងពីដំបូងនូវការកំហិតនៃកិច្ចសហប្រតិបត្តិការនេះ និងឧបសគ្គជាច្រើនដែលរារាំងមិនឲ្យកិច្ចសហប្រតិបត្តិការអាចកើតឡើង ឬធានាបាននូវលទ្ធផលតាមការចង់បាន។ ទោះបីមានការទទួលស្គាល់យ៉ាងទូលំទូលាយនូវ*តម្លៃ*របស់វាក៏ដោយ តែកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ទោះបីជាផ្លូវការក្តី ឬមិនផ្លូវការក្តី ជារឿយៗ នៅតែមានការលំបាកនឹងធានាបានដើម្បីយកមកការអនុវត្តន៍ជាក់ស្តែង។ នៅក្នុងតំបន់នេះ ក៏ដូចជានៅក្នុងតំបន់ទាំងអស់ផ្សេងទៀតដែរ ការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌជារឿយៗផ្តោតតែទៅលើទិដ្ឋភាពនៃសំណុំរឿងនៅថ្នាក់ជាតិប៉ុណ្ណោះ ទោះបីនៅពេលមានការបង្ហាញច្បាស់ពីសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនក្តី។

ជារឿយៗ អ្នកប្រតិបត្តិបានរាយការណ៍នូវការកំហិតនានាដូចខាងក្រោម៖

- ភាពខុសគ្នានៅក្នុងប្រព័ន្ធច្បាប់ និងការរាំងស្ទះនានាចំពោះកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិ
- ឧបគ្គសនៃភាសា
- កង្វះវប្បធម៌នៃកិច្ចសហប្រតិបត្តិការនៅក្នុងប្រទេសមួយ ឬទាំងពីរ
- កង្វះទំនាក់ទំនងចាំបាច់ដើម្បីសម្របសម្រួលនូវកិច្ចសហប្រតិបត្តិការនេះ
- ទំនុកចិត្តនៃទំនាក់ទំនងនៅមានកម្រិតទាប
- កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (មធ្យោបាយ ប្រព័ន្ធ និងនីតិវិធី អាជ្ញាធរកណ្តាលដែលដំណើរការ ។ល។) នៅក្នុងប្រទេសមួយ ឬទាំងពីរដែលពាក់ព័ន្ធ
- កង្វះចំណេះដឹងក្នុងចំណោមអ្នកប្រតិបត្តិលិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និង
- កំហិតធនធាន និងពេលវេលា។

ការកំហិតទាំងនេះ (រួមគ្នា ឬដាច់ពីគ្នា) ជារឿយៗចូលរួមចំណែកឲ្យមានការស្ទាក់ស្ទើរជាទូទៅនៅក្នុងទីភ្នាក់ងារ និងមន្ត្រីម្នាក់ៗ ក្នុងការចូលរួមទៅក្នុងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ ចំណុចនេះអាចលាតសន្ធឹងទៅដល់ការស្ទាក់ស្ទើរក្នុងការស្នើសុំកិច្ចសហប្រតិបត្តិការតាំងពីដំបូង ឬឆ្លើយតបយ៉ាងពេលពេញ (ឬទាល់តែសោះ) នៅពេលទៅបានសំណើពីប្រទេសមួយទៀត។

## ហេតុអ្វីបានជាសហប្រតិបត្តិការជាអន្តរជាតិមានភាព*ខុសគ្នា*នៅក្នុងសំណុំរឿងជួញដូរ

ជាធម្មតា ឧបសគ្គ និងការកំហិតនានាដែលបានលើកឡើងខាងលើអនុវត្តចំពោះសំណុំរឿងទាំងមូល ដែលអាចស្នើសុំ ឬផ្តល់នូវកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ នៅក្នុងន័យនោះ ការជួញដូរមនុស្សមិនខុសគ្នាទៅនឹងបទល្មើសផ្សេងទៀតទេ។ ក៏ប៉ុន្តែ មានចំណុចសំខាន់ជាច្រើននៃសំណុំរឿងជួញដូរ ដែលនឹងមានឥទ្ធិពលទាំងទៅលើ*មូលហេតុ* និង*របៀប*នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ ចំណុចទាំងនេះរួមមានដូចខាងក្រោម៖

- ការជួញដូរជា**បទល្មើសស្មុគស្មាញ**ខ្លាំង ដែលលំបាកក្នុងការស៊ើបអង្កេត និងចោទប្រកាន់ឱ្យបានជោគជ័យ
- ជារឿយៗ ការជួញដូរពាក់ព័ន្ធនឹងការប្រព្រឹត្ត**បទល្មើសច្រើននៅក្នុងរដ្ឋពីរឬច្រើន** និង**ពាក់ព័ន្ធនឹងបទល្មើសជាច្រើន**ក្រៅពីបទល្មើសជួញដូរ។ ចំណុចទាំងនេះអាចបញ្ចូលនូវបទល្មើសផ្នែកហិរញ្ញវត្ថុ (ឧទា. ការសម្អាតប្រាក់) និងអំពើពុករលួយ
- ក្រៅពីកើនឡើងនូវការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតពិសេស ដូចជា ការបញ្ជូនមនុស្សដែលស្ថិតក្រោមការគ្រប់គ្រង និងការចាប់បានទូរគមនាគមន៍ **ជនរងគ្រោះនៅតែជាប្រភពភស្តុតាងដែលខ្លាំងក្លាជាងគេ** នៅក្នុងសំណុំរឿងជាច្រើន
- ជារឿយៗ សក្ខីកម្មរបស់ជនរងគ្រោះមានភាពផុយស្រួយ និងចាំបាច់ត្រូវការការគាំទ្រដោយ**ភស្តុតាងបន្ថែម**។ ភស្តុតាងក្រៅពីសក្ខីកម្មរបស់ជនរងគ្រោះក៏ត្រូវបញ្ចេញនូវដំណើរការជួញដូរទាំងមូល ដែលជនរងគ្រោះអាចនឹងមិនដឹង
- ជាធម្មតា សំណុំរឿងជួញដូរពាក់ព័ន្ធនឹង**ជនរងគ្រោះដែលមានងាយរងគ្រោះ និងមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ** រួមទាំងកុមារផងដែរ។ ជារឿយៗ ការចូលរួមរបស់ពួកគេទៅក្នុងការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរ ជាការប្រថុយប្រថានជាខ្លាំង និងជួនកាលកើតឡើងដោយប្រឈមនឹងការលះបង់ផ្ទាល់ខ្លួនធំធេង និងមានហានិភ័យខ្ពស់
- ជនរងគ្រោះពីការជួញដូរមាន**សិទ្ធិ និងសិទ្ធិទទួលបាន**ដែលត្រូវគោរព និងតម្កល់។ ឧទាហរណ៍ ពួកគេគួរទទួលបានការលើកទឹកចិត្ត តែមិនត្រូវបានបង្ខិតបង្ខំ ឱ្យចូលរួមទៅក្នុងការចោទប្រកាន់ចំពោះជនកេងប្រវ័ញ្ចពួកគេ ជាពិសេស នៅពេលមិនអាចធានាដល់សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេបាន។ ក្រៅពីនេះ ជនរងគ្រោះមានសិទ្ធិទទួលបានការការពារ និងការគាំទ្រ រួមទាំងជំនួយផ្នែកច្បាប់ផងដែរ។ ពួកគេមិនគួរត្រូវបានឃុំឃាំងក្នុងគោលបំណងសម្របសម្រួលការស៊ើបអង្កេត ឬការចោទប្រកាន់ឡើយ
- ជនរងគ្រោះពីការជួញដូរត្រូវបានការពារចៀសផុតពីការចោទប្រកាន់ ចំពោះបទល្មើសនានាដែលពាក់ព័ន្ធនឹងការជួញដូររបស់ពួកគេ (ដូចជាបទល្មើសផ្នែកអន្តោប្រវេសន៍ និងការងារ)។ ក៏ប៉ុន្តែ ចំណុចនេះអាចធ្វើឱ្យមានភាពស្មុគស្មាញនៅក្នុងសំណុំរឿង នៅពេលមានភស្តុតាងពីការរួមគំនិត/ជនរងការកេងប្រវ័ញ្ចបានទទួលប្រយោជន៍
- ជនរងគ្រោះ**មានសិទ្ធិវិលត្រឡប់ទៅផ្ទះវិញ និងមិនអាចត្រូវបានរារាំងមិនឱ្យវិលត្រឡប់ឡើយ**ប្រសិនបើពួកគេចង់។ ការវិលត្រឡប់គួរធ្វើឡើងដោយស្ម័គ្រចិត្ត និងធ្វើឡើងតាមវិធីមួយដែលធានាដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ
- នៅក្នុងប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់តំបន់មួយចំនួន ជនរងគ្រោះដែលសហការជាមួយទីភ្នាក់ងារ យុត្តិធម៌ព្រហ្មទណ្ឌបានទទួលស្ថាន**ភាពគតិយុត្តិពិសេសដើម្បីស្នាក់នៅ** ទាំងក្នុងអំឡុងពេលចូលរួមរបស់ខ្លួន ឬជួនកាលជាអចិន្ត្រៃយ៍
- មុនពេល ក្នុងអំឡុងពេល និងក្រោយពេលដែលពួកគេចូលរួមនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ **ជនរងគ្រោះគួរទទួលបានព័ត៌មាន ជំនួយ និងការគាំទ្រសមស្រប** រួមទាំងការការពារចៀសផុតពីការទទួលរងការប៉ះទង្គិចផ្លូវចិត្តជាថ្មី។ កុមាររងគ្រោះនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌមានតម្រូវការចាំបាច់ពិសេសដែលត្រូវបំពេញ និងសិទ្ធិបន្ថែមដែលត្រូវគោរព និង

- ជនរងគ្រោះពីការជួញដូរ មានសិទ្ធិទទួលបាន**សំណង**ចំពោះព្យសនកម្មនានា ដែលប្រព្រឹត្តមកលើពួកគេ។ នៅក្នុងប្រទេសមួយចំនួន ការចោទប្រកាន់ និងការផ្តន្ទាទោសភ្ជាប់ទៅនឹងសំណងជួសជុលដល់ជនរងគ្រោះ។

ដោយសារភាពខុសគ្នាទាំងនេះហើយ ទើបវិធីសាស្ត្រនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិអាចចាំបាច់ត្រូវ**សម្រប តាម ឬកែសម្រួល** ដើម្បីតម្កល់សិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ។ ជាពិសេស

- កិច្ចសហប្រតិបត្តិការជាអន្តរជាតិអាច**ធ្វើឱ្យធ្ងន់ធ្ងរនូវហានិភ័យចំពោះសុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ**។ ភ្នាក់ងារដែលដាក់សំណើ ឬទទួលសំណើសុំកិច្ចសហប្រតិបត្តិការនៅក្នុងសំណុំរឿងជួញដូរគួរពិចារណានូវហានិភ័យទាំងនេះ ក្នុងការសម្រេចថាតើគួរសហការ ឬសហការដោយរបៀបណា និង
- ការប្រើប្រាស់**ជម្រើសផ្សេងទៀតក្រៅពីសក្ខីកម្មដោយផ្ទាល់នៅពេលជំនុំជម្រះ** ដូចជាសក្ខីកម្មមុនការជំនុំជម្រះ និងតាមរយៈប្រព័ន្ធសោតទស្សន៍ មានលក្ខណៈកាន់តែធម្មតានៅក្នុងសំណុំរឿងជួញដូរ ហើយត្រូវតែជាកត្តាមួយក្នុងការសម្រេចចិត្តជុំវិញកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។

## ការសម្រេចថាតើពេលណាដែលកិច្ចសហប្រតិបត្តិការជាអន្តរជាតិមានភាពចាំបាច់/មានប្រយោជន៍

ប្រអប់អត្ថបទខាងក្រោមលើកឡើងនូវបញ្ហាមួយចំនួនដែលអ្នកប្រតិបត្តិត្រូវយកមកពិចារណា នៅពេលសម្រេចថាតើ គួរដំណើរការនូវកិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងសំណុំរឿងជាក់លាក់ណាមួយ ឬយ៉ាងណា។

### *ប្រអប់អត្ថបទ ៣០៖ ការធ្វើសេចក្តីសម្រេចថាតើគួរដំណើរការដោយមានកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិ ឬយ៉ាងណា*

កិច្ចសហប្រតិបត្តិការជាអន្តរជាតិ តែងតែជា "ការងារបន្ថែម" នៅក្នុងដំណើរការស៊ើបអង្កេត និងការចោទប្រកាន់ ហើយមិនមែនសុទ្ធតែទទួលបានផលប្រយោជន៍នៅគ្រប់សំណុំរឿងជួញដូរមនុស្សនោះទេ។ សេចក្តីសម្រេចថាតើគួបន្តដំណើរការនូវកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ឬយ៉ាងណា នៅតែជាមានភាពជាក់លាក់ទៅតាមសំណុំរឿងនីមួយៗ ហើយពឹងផ្អែកលើកត្តាជាច្រើន។ គួរសួរសំណួរនានាដូចខាងក្រោម មុននឹងសម្រេចចិត្ត ឬធ្វើសម្រេចណាមួយ៖

**តើមានភស្តុតាងគ្រប់គ្រាន់នៅក្នុងប្រទេស ដើម្បីគាំទ្រដល់ការស៊ើបអង្កេត/ការចោទប្រកាន់ដែលខ្លាំងក្លាឬទេ?**

ប្រសិនបើមិនមានភស្តុតាងគ្រប់គ្រាន់ទេ ការស្នើសុំកិច្ចសហប្រតិបត្តិការជាអន្តរជាតិអាចជាការចំណាយពេល និងធនធានឥតប្រយោជន៍។ វាក៏អាចធ្វើឱ្យប៉ះពាល់ដល់ការចោទប្រកាន់ផងដែរ តាមរយៈការពន្យារពេលដែលចៀសមិនរួច ដែលបង្កនូវព្យសនកម្មដែលមិនចាំបាច់ដល់ជនរងគ្រោះ។

**ប្រសិនបើព័ត៌មាន/ភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការស៊ើបអង្កេត/ការចោទប្រកាន់ខ្លាំងក្លា<u>មិន</u>អាចរកបាននៅក្នុងប្រទេស៖**

- តើមានមូលហេតុសមហេតុផល ដើម្បីសន្មតថា ព័ត៌មាន/ភស្តុតាងដែលចាំបាច់អាចធានាបានតាមរយៈកិច្ចសហប្រតិបត្តិការជាអន្តរជាតិឬទេ?

- តើមានដាក់ឲ្យដំណើរការនូវរចនាសម្ព័ន្ធចាំបាច់ និងទំនាក់ទំនងដើម្បីអាចធានាបានព័ត៌មាន/ ភស្តុតាងនេះដោយមិន៖ ដាក់បន្ទុកដោយមិនចាំបាច់ទៅលើបុគ្គលណាម្នាក់ ឬភ្នាក់ងារពាក់ព័ន្ធ ឬ (២) បណ្តាលឲ្យមានការពន្យារពេលឥតប្រយោជន៍ដែលនឹងធ្វើឲ្យប៉ះពាល់ដល់សំណុំរឿង ឬទេ?
- តើជាការសមហេតុផលទេ ដែលប្រមើលមើលថា កិច្ចសហប្រតិបត្តិការជាអន្តរជាតិដែលកំពុងស្នើសុំនឹងបង្ហាញនូវហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ ឬមនុស្សពាក់ព័ន្ធផ្សេងទៀត ឬទេ? ប្រសិនបើមាន តើហានិភ័យនោះអាចគ្រប់គ្រងបានឬទេ?

សេចក្តីសម្រេចអំពីថា គួរឬមិនគួរដំណើរការកិច្ចសហប្រតិបត្តិការ *មិនផ្លូវការ* នឹងមិនផ្អែកលើការពិចារណាដូចគ្នាទេ។ ឧទាហរណ៍ ភ្នាក់ងារអនុវត្តន៍ច្បាប់មួយនៅថ្នាក់ជាតិ មានព័ត៌មានដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដៃគូអន្តរជាតិ (ឧទា. វត្តមានរបស់ជនសង្ស័យ ជនរងគ្រោះសកម្មភាពបទល្មើសនៅក្នុងទឹកដីរបស់ដៃគូនោះ) ជាធម្មតានឹងត្រូវបានគាំទ្រ ដោយការចែករំលែកនូវព័ត៌មាននោះ*មិនផ្លូវការ* ជាមួយដៃគូនោះយ៉ាងឆាប់រហ័ស។ ការសម្រេច*មិន* ចែករំលែកព័ត៌មានទាំងនោះ ហាក់ដូចជាត្រូវបានគាំទ្រដោយផ្អែកតែទៅលើមូលដ្ឋានថា ចំណុចនេះនឹងបង្ហាញពីហានិភ័យធ្ងន់ធ្ងរចំពោះមនុស្សដែលពាក់ព័ន្ធ (រួមមានជនរងគ្រោះ និងគ្រួសាររបស់ពួកគេ) ប៉ះពាល់ដល់ការស៊ើបអង្កេត ឬប្រតិបត្តិការប្រឆាំងការផលប្រយោជន៍យុត្តិធម៌របស់ជនរងគ្រោះ តែប៉ុណ្ណោះ។

## ៧.១ កិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព៖ ទិដ្ឋភាពទូទៅ និងធាតុផ្សំគន្លឹះ

កិច្ចសហប្រតិបត្តិការជាអន្តរជាតិអាចមិនផ្លូវការផង ឬផ្លូវការផង។ ***កិច្ចសហប្រតិបត្តិការមិនផ្លូវការ*** សំណៅដល់ការផ្លាស់ប្តូរព័ត៌មានដែលកើតឡើងដោយផ្ទាល់រវាងទីភ្នាក់ងារអនុវត្តន៍ច្បាប់ និងភ្នាក់ងារចេញបទបញ្ជា ជាមួយសមភាគីបរទេស។ ជួនកាលគេអាចយោងទៅកិច្ចសហប្រតិបត្តិការ “រវាងមន្ត្រីនគរបាលនិងមន្ត្រីនគរបាល” និង “រវាងភ្នាក់ងារនិងទីភ្នាក់ងារ”។ កិច្ចសហប្រតិបត្តិការមិនផ្លូវការគឺជាឧបករណ៍កិច្ចសហប្រតិបត្តិការលើបទល្មើសជាអន្តរជាតិដាច់ដោយឡែក មានចំណងវិធានតិចតួច ដែលអាចរកបាននៅខាងក្រៅរបស់នៃជំនួយទៅវិញទៅមកជាផ្លូវការ។ កិច្ចសហប្រតិបត្តិការមិនផ្លូវការអាចឲ្យទីភ្នាក់ងារអនុវត្តន៍ច្បាប់ និងទីភ្នាក់ងារចេញបទបញ្ជា (ដូចជា អាជ្ញាធរពន្ធដារ និងប្រាក់ចំណូល ក្រុមហ៊ុន និងអ្នកកំណត់សេវាហិរញ្ញវត្ថុ) ចែករំលែកព័ត៌មាន និងព័ត៌មានសម្ងាត់ដោយផ្ទាល់ជាមួយសមភាគីបរទេស ដោយមិនត្រូវឲ្យមានសំណើសុំជំនួយទៅវិញទៅមកជាផ្លូវការ។ នៅក្នុងន័យនេះ កិច្ចសហប្រតិបត្តិមិនផ្លូវការជួយបំពេញបន្ថែមនូវរបបជំនួយទៅវិញទៅមក។ ឧបករណ៍កិច្ចសហប្រតិបត្តិការជាអន្តរជាតិអាចត្រូវបានយកមកប្រើប្រាស់មុនពេលដែលការស៊ើបអង្កេតទៅជាផ្លូវការ និងមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីតុលាការ ឧទាហរណ៍ ដោយធ្វើការឃ្លាំមើល ឬស្តាប់ចម្លើយសាក្សីដោយស្ម័គ្រចិត្ត។ នៅក្នុងកាលៈទេសៈដែលមិនតម្រូវឲ្យមានវិធានការបង្ខិតបង្ខំ ជាធម្មតា ក្នុងការទទួលបានព័ត៌មាន ឬព័ត៌មានសម្ងាត់ដោយផ្អែកលើមូលដ្ឋានមិនផ្លូវការមានភាពរហ័សជាង ចំណាយតិចជាង និងងាយស្រួលជាងតាមរយៈយន្តការជំនួយទៅវិញមកជាផ្លូវការ (សូមមើលចំណុច ៧.១.៥ ខាងក្រោម)។

មានឧបករណ៍ចម្បងពីរនៃ *"កិច្ចសហប្រតិបត្តិការផ្លូវការ"* គឺ៖ ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន។ ***ជំនួយផ្នែកច្បាប់ទៅវិញទៅមក*** គឺជាដំណើរការដែលរដ្ឋយកមកប្រើដើម្បីស្នើសុំទៅរដ្ឋផ្សេងទៀតឲ្យផ្តល់ព័ត៌មាន និងភស្តុតាងក្នុងគោលបំណងស៊ើបអង្កេត ឬចោទប្រកាន់។ ជំនួយផ្នែកច្បាប់ទៅវិញទៅមកគឺជាឧបករណ៍សហប្រតិបត្តិការផ្លូវការ ជាទូទៅពាក់ព័ន្ធនឹងរដ្ឋមួយស្នើសុំទៅរដ្ឋមួយទៀតដើម្បីប្រើអំណាចបង្ខិតបង្ខំក្នុងនាមខ្លួន និង/ឬ ចាត់វិធានការនានាដើម្បីទទួលបានភស្តុតាងដែលអាចទទួលយកបាននៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌ។ សម្រាប់ហេតុផលទាំងនេះ វាដំណើរការនៅក្រោមវិធានផ្សេង និងតឹងរ៉ឹងច្រើនជាងកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារនិងភ្នាក់ងារ ឬរវាងមន្ត្រីនគរបាលនិងមន្ត្រីនគរបាលដែលមិនសូវផ្លូវការ។ ប្រព័ន្ធនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកធម្មតារួមមាន៖ ការស្តាប់ភស្តុតាង ឬចម្លើយពីបុគ្គលនានា ការកំណត់ទីកន្លែង និងការកំណត់អត្តសញ្ញាណសាក្សី និងជនសង្ស័យ បង្កើតឲ្យមានសេវាឯកសារតុលាការ អនុវត្តការឆែកឆេរ និងការចាប់យក ផ្តល់សំណៅដើម ឬសំណៅចម្លងនៃឯកសារ ឬកំណត់ហេតុពាក់ព័ន្ធ ការកំណត់អត្តសញ្ញាណ ការតាមដាន ការចាប់យក និងការស្វែងរកទ្រព្យបានមកពីបទល្មើស ការសម្របសម្រួលការបង្ហាញខ្លួនដោយស្ម័គ្រចិត្តរបស់បុគ្គលនានា នៅក្នុងរដ្ឋដែលស្នើសុំ ការរៀបចំការផ្ទេរអ្នកទោសដើម្បីផ្តល់ភស្តុតាង និងតាមរយៈប្រព័ន្ធសោតទស្សន៍/ការថតជាវីដេអូ។

***ការស្វែងរកទ្រព្យបានមកពីបទល្មើសឆ្លងដែនអន្តរជាតិ*** គឺជាទម្រង់មួយនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាទូទៅស្ថិតក្រោមរបបច្បាប់ដោយឡែក តែមានគោលការណ៍ បុរេលក្ខខណ្ឌ និងនីតិវិធីស្រដៀងគ្នា។

ពាក្យថា *"បត្យាប័ន"* សំណៅដល់ដំណើរការដែលរដ្ឋមួយ (រដ្ឋដាក់សំណើ) ស្នើសុំរដ្ឋមួយទៀត (រដ្ឋទទួលសំណើ) ឲ្យបញ្ជូនបុគ្គលណាម្នាក់មកទទួលការចោទប្រកាន់ ឬអនុវត្តទោសនៅក្នុងរដ្ឋដាក់សំណើ។ ដោយសារលក្ខណៈនៃដំណើរការនៅក្នុងការជួញដូរមនុស្ស ជារឿយៗ ជនសង្ស័យដែលគេចង់បានខ្លួនដើម្បីធ្វើការចោទប្រកាន់នៅក្នុងរដ្ឋមួយមានវត្តមាននៅក្នុងរដ្ឋមួយទៀត។ ចំណុចនេះអាចដោយសារពួកគេជាជនជាតិរបស់រដ្ឋមួយទៀត ឬដោយសារពួកគេបានបោះជំហានដើម្បីបញ្ចៀសការចោទប្រកាន់ ឬផ្តន្ទាទោសដល់គេចខ្លួនទៅរដ្ឋមួយទៀត។ ហេតុនេះ ជួនកាលការធ្វើបត្យាប័នមានសារៈសំខាន់ ចំពោះការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរមនុស្សឲ្យបានជោគជ័យ។ ការធ្វើបត្យាប័នផ្អែកលើមូលដ្ឋានថា ជនម្នាក់ដែលស្ថិតនៅក្នុងរដ្ឋមួយដែលត្រូវបានចោទប្រកាន់គួរឲ្យជឿបានពីការប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរដែលអាចត្រូវបានជំនុំជម្រះនៅរដ្ឋមួយទៀត គួរតែត្រូវប្រគល់ខ្លួនទៅឲ្យរដ្ឋនោះ ដើម្បីឆ្លើយតបទៅនឹងបទល្មើសដែលបានចោទប្រកាន់ទាំងនោះ[២០១]។ ក៏ប៉ុន្តែ វិធានជុំវិញការធ្វើបត្យាប័នក៏ស្វែងរកការកំណត់នូវការការពារផងដែរ ដើម្បីធានាថា បុគ្គលដែលត្រូវបានស្វែងរកការធ្វើបត្យាប័ននឹងត្រូវបានការពារពីការប្រគល់ខ្លួននៅក្នុងកាលៈទេសៈនានាដែលបុគ្គលនោះនឹងទទួលរងភាពអយុត្តិធម៌ ឬការបង្ក្រាប[២០២]។ នៅក្នុងបរិបទនេះ ជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ដំណើរការធ្វើបត្យាប័នមិនមែនជាការកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសនោះឡើយ។

---

[២០១] សូមមើលជាទូទៅ Clive Nicholls QC, Clare Montgomery QC និង Julian B. Knowles, *The Law of Extradition and Mutual Assistance ("ច្បាប់ស្តីពីការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក")* (Oxford University Press ការកែសម្រួលលើកទីពីរ ឆ្នាំ២០០៧) [តទៅនេះហៅថា Nicholls និងអ្នកផ្សេងទៀត *ច្បាប់ស្តីពីការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក*]។

[២០២] សំណុំរឿង *Knowles* តទល់នឹង រដ្ឋាភិបាលសហរដ្ឋអាមេរិក [ឆ្នាំ២០០៦] UKPC 38 កថាខណ្ឌ ១២ ត្រូវបានដកស្រង់នៅក្នុង Nicholls និងអ្នកផ្សេងទៀត ច្បាប់ស្តីពីការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក ទំព័រ ៣។

មធ្យោបាយមិនផ្លូវការ និងផ្លូវការនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងសំណុំរឿងព្រហ្មទណ្ឌមានលក្ខណៈ **ពឹងផ្អែកទៅលើគ្នាទៅវិញទៅមក**។ ឧទាហរណ៍៖

- ជំនួយមិនផ្លូវការអាចពឹងផ្អែកមូលដ្ឋាននៃសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកជាផ្លូវការនាពេលបន្ទាប់
- ជំនួយផ្នែកច្បាប់ទៅវិញទៅមកជាផ្លូវការ និងជំនួយមិនផ្លូវការរវាងភ្នាក់ងារនិងភ្នាក់ងារអាចកើតឡើងនៅពេលជាមួយគ្នាបាន
- ជារឿយៗ ជំនួយផ្នែកច្បាប់ទៅវិញទៅមកកើតឡើងក្រោយពីមានកិច្ចសហប្រតិបត្តិការដោយផ្ទាល់រវាងភ្នាក់ងារនិងទីភ្នាក់ងារ
- ជំនួយផ្នែកច្បាប់ទៅវិញទៅមកអាចបំពេញបន្ថែមដល់ការធ្វើបត្យាប័ន នៅពេលដែលជនល្មើស និងភស្តុតាងនៃបទល្មើសស្ថិតនៅឯបរទេស
- ជំនួយផ្នែកច្បាប់ទៅវិញទៅមកអាចយកមកប្រើប្រាស់ដើម្បីទទួលបានព័ត៌មាន ដើម្បីជំរុញសំណុំរឿងទៅមុខ នៅពេលអាចមានលទ្ធភាពថានឹងមានសំណើសុំធ្វើបត្យាប័ន និង
- នៅក្នុងស្ថានភាពដែលរដ្ឋទទួលសំណើបដិសេធមិនធ្វើបត្យាប័នជនណាម្នាក់ (ឧទាហរណ៍ ដោយសារជននោះមានសញ្ជាតិរបស់រដ្ឋទទួលសំណើ) រដ្ឋដាក់សំណើអាចផ្តល់ការគាំទ្រជំនួយផ្នែកច្បាប់ទៅវិញទៅមកនាពេលក្រោយទៅរដ្ឋទទួលសំណើ ដើម្បីឱ្យគេអាចធ្វើការស៊ើបអង្កេត ឬចោទប្រកាន់បុគ្គលដែលត្រូវបានស្វែងរកខ្លួននោះបាន។

## កិច្ចសហប្រតិបត្តិការមិនផ្លូវការនៅក្នុងសំណុំរឿង TIP

កិច្ចសហប្រតិបត្តិការមិនផ្លូវការអាចជួយឱ្យភ្នាក់ងារអនុវត្តន៍ច្បាប់ និងភ្នាក់ងារចេញបទបញ្ជា (ដូចជា អាជ្ញាធរពន្ធដារ និងប្រាក់ចំណូល ក្រុមហ៊ុន និងអ្នកកំណត់សេវាហិរញ្ញវត្ថុ) ផ្តល់ព័ត៌មាន និងព័ត៌មានសម្ងាត់ដោយផ្ទាល់ទៅសមភាគីបរទេសរបស់ខ្លួន ដោយពុំចាំបាច់មានសំណុំសុំជំនួយទៅវិញទៅមកជាផ្លូវការ។ ឧទាហរណ៍ កិច្ចសហប្រតិបត្តិការមិនផ្លូវការអាចយកមកប្រើប្រាស់ដើម្បីប្រមូលព័ត៌មានសម្ងាត់ ឬស្តាប់ចម្លើយសាក្សីដោយស្ម័គ្រចិត្ត។

កិច្ចសហប្រតិបត្តិការឆ្លងដែនរវាងភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងសំណុំរឿង TIP តាមរយៈការចែករំលែកព័ត៌មាន កិច្ចសហប្រតិបត្តិការទៅលើកិច្ចស៊ើបសួរទាក់ទងនឹងបទល្មើសជាក់លាក់ គឺមានភាពចាំបាច់ និងសូម្បីតែការស៊ើបអង្កេតរួមគ្នា ក៏ត្រូវបានអះអាងនៅក្នុង*អនុសញ្ញា អ.ស.ប ប្រឆាំងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង* និង *ពិធីសារប្រឆាំងការជួញដូរ* ដែរ[២០៣]។ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* បានលើសពីនេះទៅទៀត ដោយលើកឡើងយ៉ាងលម្អិតនូវលក្ខណៈ និងវិសាលភាពនៃកិច្ចសហប្រតិបត្តិការមិនផ្លូវការទាក់ទងនឹងសំណុំរឿងជួញដូរ (សូមមើលប្រអប់អត្ថបទ ៣១ ខាងក្រោម)។ *អនុសញ្ញា* អះអាងអំពីសារៈសំខាន់ របស់ភ្នាក់ងារអនុវត្តន៍ច្បាប់ក្នុងការចូលរួមយ៉ាងសកម្មទៅក្នុងការផ្លាស់ប្តូរព័ត៌មាន និងព័ត៌មានសម្ងាត់។ វាក៏ជំរុញឱ្យមានការបង្កើតកិច្ចព្រមព្រៀងរវាងរដ្ឋសមាជិកអាស៊ាន ដើម្បីសម្របសម្រួលនូវកិច្ចសហប្រតិបត្តិការដោយផ្ទាល់រវាងភ្នាក់ងារនិងភ្នាក់ងារ។ ប្រការសំខាន់គឺថា *អនុសញ្ញា* ផ្តល់ជាមូលដ្ឋានគតិយុត្តិសម្រាប់កិច្ចសហប្រតិបត្តិការនេះរវាងរដ្ឋភាគី។

---

[២០៣] UNTOC មាត្រា ១៩, ២៧, ២៨។ *ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ* មាត្រា ១០។

**មាត្រា ២០៖ កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់**

១. រដ្ឋភាគីត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាយ៉ាងជិតស្និទ្ធ ស្របទៅនឹងប្រព័ន្ធច្បាប់ និងរដ្ឋបាលរបស់រដ្ឋនីមួយៗ ដើម្បីពង្រឹងប្រសិទ្ធភាពនៃសកម្មភាពអនុវត្តន៍ច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹង បទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញានេះ។ ជាពិសេស ភាគីនីមួយៗត្រូវអនុម័តវិធានការនានាឲ្យមានប្រសិទ្ធភាពដូចជា៖

១) ដើម្បីពង្រឹង និងក្នុងករណីចាំបាច់ ដើម្បីបង្កើតព្រមទាំងប្រើប្រាស់យន្តការទំនាក់ទំនងការងារដែលមានស្រាប់រវាងអាជ្ញាធរមានសមត្ថកិច្ច ភ្នាក់ងារ និងសេវាកម្មនានា ដើម្បីសម្របសម្រួលនូវការផ្លាស់ប្តូរព័ត៌មានឆាប់រហ័ស និងមានសុវត្ថិភាពទាក់ទងគ្រប់ទិដ្ឋភាពទាំងអស់នៃបទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញានេះ រួមទាំង ទំនាក់ទំនងជាមួយសកម្មភាពបទល្មើសផ្សេងទៀត ប្រសិនបើភាគីសាមីយល់ថាជាការសមស្រប។

២) ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយភាគីផ្សេងទៀតក្នុងការបើកកិច្ចស៊ើបសួរទាក់ទងនឹងបទល្មើសផ្សេងទៀតដែលគ្របដណ្តប់ដោយអនុសញ្ញានេះ ទាក់ទិននឹង៖

- អត្តសញ្ញាណ ទីកន្លែង និងសកម្មភាពរបស់ជនសង្ស័យពីការចូលរួមនៅក្នុងបទល្មើសទាំងនេះ ឬទីតាំងរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត
- ការធ្វើចរាចរទ្រព្យបានមកពីបទល្មើស ឬទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តិបទល្មើសទាំងនោះ
- ការធ្វើចរាចរទ្រព្យសម្បត្តិ បរិក្ខារ ឬមធ្យោបាយផ្សេងទៀតដែលបានប្រើប្រាស់ ឬមានបំណងប្រើប្រាស់ក្នុងការប្រព្រឹត្តិបទល្មើសទាំងនេះ

៣) ដើម្បីផ្តល់នូវវត្ថុចាំបាច់ ឬបរិមាណនៃសារធាតុក្នុងគោលបំណងធ្វើវិភាគ ឬស៊ើបអង្កេត

៤) ដើម្បីសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពរវាងអាជ្ញាធរមានសមត្ថភាព ភ្នាក់ងារ និង សេវាកម្មនានារបស់ខ្លួន និងដើម្បីលើកកម្ពស់ការផ្លាស់ប្តូរបុគ្គលិក និងអ្នកឯកទេសផ្សេងទៀត រួមទាំង ការបង្កើតមុខតំណែងនៃមន្ត្រីទំនាក់ទំនងដែលស្ថិតក្រោមកិច្ចព្រមព្រៀងទ្វេរភាគី ឬការរៀបចំរវាងភាគីពាក់ព័ន្ធ

៥) ដើម្បីផ្លាស់ប្តូរព័ត៌មានជាមួយភាគីផ្សេងទៀត ស្តីពីមធ្យោបាយ និងវិធីសាស្រ្តជាក់លាក់ដែលជនជួញដូរយកមកប្រើប្រាស់ រួមមាន ផ្លូវធ្វើដំណើរការ និងការដឹកជញ្ជូន និងការប្រើប្រាស់អត្តសញ្ញាណក្លែងក្លាយ ឯកសារផ្សេងឬក្លែងក្លាយ ឬមធ្យោបាយលាក់បាំងសកម្មភាពរបស់ខ្លួនផ្សេងទៀត ក្នុងករណីជាក់ស្តែង

៦) ដើម្បីផ្លាស់ប្តូរព័ត៌មាន និងសម្របសម្រួលការចាត់វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលសមស្រប ក្នុងគោលបំណងកំណត់តាំងពីដំបូងនូវបទល្មើសដែលគ្រប ដណ្តប់ដោយអនុសញ្ញានេះ។

២. ដោយពិចារណាទៅដល់ការផ្តល់ប្រសិទ្ធភាពដល់អនុសញ្ញានេះ ភាគីត្រូវពិចារណាចុះកិច្ចព្រមព្រៀង ឬការរៀបចំជាទ្វេភាគី ឬពហុភាគីស្តីពីកិច្ចសហប្រតិបត្តិការដោយផ្ទាល់រវាងភ្នាក់ងារអនុវត្តន៍ច្បាប់របស់ខ្លួន ហើយ នៅពេលមានកិច្ចព្រមព្រៀង ឬការរៀបចំទាំងនេះ ត្រូវពិចារណាធ្វើវិសោធនកម្មទៅនឹងលិខិតូប

ករណីទាំងនោះ។ នៅពេលពុំមានកិច្ចព្រមព្រៀង ឬការរៀបចំទាំងនេះរវាងភាគីពាក់ព័ន្ធ ភាគីអាចពិចារណាយកអនុសញ្ញានេះធ្វើជាមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តន៍ច្បាប់ទៅវិញទៅមក ទាក់ទងនឹងបទល្មើសដែលគ្របដណ្តប់ដោយអនុសញ្ញានេះ។ ក្នុងករណីសមស្រប ភាគីត្រូវអនុវត្តឱ្យបានពេញលេញទៅតាមកិច្ចព្រមព្រៀង ឬការរៀបចំ រួមទាំងអង្គការអន្តរជាតិ ឬថ្នាក់តំបន់ផងដែរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអនុវត្តន៍ច្បាប់របស់ខ្លួន។

៣. ភាគីត្រូវខិតខំប្រឹងប្រែងក្នុងការធ្វើកិច្ចសហប្រតិបត្តិការនៅក្នុងមធ្យោបាយរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងបទល្មើសផ្សេងទៀតដែលគ្របដណ្តប់ដោយអនុសញ្ញានេះ ដែលបានប្រព្រឹត្តតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប។

ដើម្បីសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការមិនផ្លូវការនៅក្នុងសំណុំរឿងជួញដូរមនុស្ស *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ផ្តល់អនុសាសន៍ថា៖

- គួរបង្កើតសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពីការគ្រប់គ្រង និងការសម្របសម្រួលក្រុមស៊ើបអង្កេត និងការអនុវត្តន៍បច្ចេកទេសស៊ើបអង្កេតឯកទេសនៅក្នុងរដ្ឋសមាជិកអាស៊ានទាំងអស់
- គួរបង្កើតឱ្យមានអង្គភាពទំនាក់ទំនងព្រំដែននៅថ្នាក់ជាតិ ពហុភ្នាក់ងារ (ឧទា. នគរបាលយុត្តិធម៌ និងនគរបាលអន្តោប្រវេសន៍) នៅតាមព្រំដែនដែលកំណត់ថាជា "ចំណុចក្តៅ" ដើម្បីកែលម្អសមត្ថភាព និងគុណភាពនៃកិច្ចសហប្រតិបត្តិការឆ្លងដែន និង
- គួរបំពាក់បច្ចេកវិទ្យាព័ត៌មាន និងប្រាស្រ័យទំនាក់ទំនងការងារ ដើម្បីសម្របសម្រួលដំណើរការកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធ និងឆាប់រហ័ស[២០៤]។

មានការអំពាវនាវកាន់តែកើនឡើង ឱ្យមានការដាក់ពង្រាយ**ក្រុមស៊ើបអង្កេតឯកទេសរវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា**ដើម្បីធ្វើការរួមគ្នាឆ្លងកាត់ព្រំដែន។ ការស៊ើបអង្កេតឆ្លងដែនចំពោះការងារប្រភេទនេះ នៅក្នុងតំបន់ផ្សេងទៀតនៅទូទាំងពិភពលោក បាននាំឱ្យមានការចាប់ខ្លួនជនសង្ស័យដែលមានការសម្របសម្រួល ព្រមទាំងការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុដែលមានការសម្របសម្រួល និងការរឹបអូសយកតាមផ្លូវតុលាការនូវទ្រព្យដែលបានមកពីការកេងប្រវ័ញ្ចពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* គាំទ្រដល់វិធីសាស្ត្រនេះ[២០៥]។

## ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្ស

ច្បាប់អន្តរជាតិ ច្បាប់ក្នុងតំបន់ និងគោលនយោបាយអាស៊ានអះអាងពីសារៈសំខាន់ នៃជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្ស។ រដ្ឋសមាជិកអាស៊ានទាំងអស់ជាភាគីនៃសន្ធិសញ្ញាថ្នាក់តំបន់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលផ្តល់នូវមូលដ្ឋានគតិយុត្តិរឹងមាំមួយសម្រាប់ MLA រវាងរដ្ឋសមាជិក អាស៊ាន។ *សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានឆន្ទៈដូចគ្នា* (ឆ្នាំ២០០៤) (ASEAN MLAT) ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួល និងពង្រឹងកិច្ចខិតខំប្រឹងប្រែង

---

[២០៤] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិការអាស៊ាន វគ្គ ១៖ ផ្នែក ៤ក៖ កថាខណ្ឌ ១ ដល់ ១៩។

[២០៥] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិការអាស៊ាន វគ្គ ១៖ ផ្នែក ១៖ កថាខណ្ឌ ៤ក.១។

ដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់ទាំងអស់នៃឧក្រិដ្ឋកម្មឆ្លងដែន នៅក្នុងតំបន់អាស៊ាន។ លិខិតូបករណ៍នេះគឺជាដំណើរការមួយ ដែលរដ្ឋសមាជិកអាស៊ានអាចស្នើសុំ និងផ្តល់ជំនួយឲ្យគ្នាទៅវិញទៅមក ក្នុងការប្រមូលភស្តុតាងសម្រាប់ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ និងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋភាគីត្រូវបានតម្រូវឲ្យចេញនូវ "វិធានការនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងអង្គហេតុព្រហ្មទណ្ឌឲ្យបានទូលំទូលាយបំផុត"[២០៦] ដល់រដ្ឋភាគីផ្សេងទៀត នៅក្នុងទម្រង់មួយដែលអាចប្រើប្រាស់បាន និងអាចទទួលយកនៅក្នុងរដ្ឋទទួលសំណើ។

រដ្ឋសមាជិកអាស៊ានចំនួន ៩ ក៏បានក្លាយជាភាគីនៃ UNTOC ផងដែរ។ សន្ធិសញ្ញានេះផ្តល់នូវមូលដ្ឋានគតិយុត្តិដល់វិធានការនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកជាអន្តរជាតិរវាងរដ្ឋភាគី រួមមាន ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ននៅក្នុងសំណុំរឿងព្រហ្មទណ្ឌធ្ងន់ធ្ងររួមទាំងការជួញដូរមនុស្ស នៅពេលដែលរដ្ឋដាក់សំណុំមានមូលហេតុជឿថា បទល្មើសដែលមានលក្ខណៈឆ្លងដែន និងពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង[២០៧]។ គិតមកទល់នឹងពេលបច្ចុប្បន្ននេះ UNTOC មានរដ្ឋភាគីចំនួន ១៦៣[២០៨] សន្ធិសញ្ញានេះបានបង្កើតវិសាលភាពទូលំទូលាយជាខ្លាំងសម្រាប់ទម្រង់នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិជាច្រើនជាមួយរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនេះ។ វាជាការសំខាន់ដែលគួរកត់សម្គាល់ថា របបនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុង UNTOC មានគោលបំណងបំពេញបន្ថែម ជាជាងជំនួសរបបនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក ឬការធ្វើបត្យាប័នដែលមានរួចទៅហើយ ដោយសារសន្ធិសញ្ញាមួយផ្សេងទៀត ទោះបីទ្វេភាគី ឬពហុភាគីក្តី។ ហេតុនេះ រដ្ឋសមាជិកអាស៊ានគួរយក UNTOC មកប្រើប្រាស់ជាមូលដ្ឋានគតិយុត្តិសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ឬការធ្វើបត្យាប័ន នៅពេលពុំមានមូលដ្ឋានគតិយុត្តិសមស្របផ្សេងទៀត (ដូចជា ASEAN MLAT សន្ធិសញ្ញាទ្វេភាគី ឬច្បាប់ជាតិ)[២០៩]។

*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* មិនបានលើកឡើងនូវ ជំនួយផ្នែកច្បាប់ទៅវិញទៅមកលម្អិតទេ ផ្ទុយទៅវិញតម្រូវឲ្យរដ្ឋភាគីចូលរួមទៅក្នុងជំនួយនេះ និងអះអាងនូវភាពអាចអនុវត្តបាននៃក្របខ័ណ្ឌគតិយុត្តិថ្នាក់តំបន់ដែលមានស្រាប់ស្តីពីបញ្ហានេះ៖

> *ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសជួញដូរមនុស្សដែលមានលក្ខណៈឆ្លងដែន ភាគីត្រូវផ្តល់ឲ្យរដ្ឋមួយទៀតនូវវិធានការនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកយ៉ាងទូលំទូលាយបំផុតនៅក្នុងការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ឬកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹង [បទល្មើសនៅក្នុងអនុសញ្ញា] ដែលស្ថិតក្រោមបញ្ញត្តិនៅក្នុងច្បាប់ថ្នាក់ជាតិរបស់ខ្លួន។*

---

[២០៦] ASEAN MLAT មាត្រា ១(១)។

[២០៧] UNTOC មាត្រា ១៦ និង ១៨។ សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទំព័រ ១១២-១១៣។

[២០៨] គិតមកត្រឹមថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១។

[២០៩] កត់សម្គាល់ មាត្រា ១៦(៥) នៃ UNTOC ដែលតម្រូវឲ្យរដ្ឋភាគីដែលកំណត់លក្ខខណ្ឌទៅលើការធ្វើបត្យាប័នទៅលើសន្ធិសញ្ញាមួយ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ អ.ស.ប ទៅពេលទទួលយក UNTOC ថាតើ ពួកគេនឹងជ្រើសយកអនុសញ្ញាជាមូលដ្ឋានគតិយុត្តិសម្រាប់សហការជាមួយរដ្ឋភាគីផ្សេងទៀតទៅលើការធ្វើបត្យាប័ន ឬយ៉ាងណា។ ប្រសិនបើរដ្ឋទាំងនោះសម្រេចមិនជ្រើសរើសយក UNTOC ជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័ន បន្ទាប់មករដ្ឋនោះត្រូវបានតម្រូវឲ្យ "ស្វែងរកការកិច្ចសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នជាមួយរដ្ឋភាគីផ្សេងទៀត ក្នុងករណីសមស្រប" ដើម្បីអនុវត្តនូវបទប្បញ្ញត្តិរបស់អនុសញ្ញាស្រីពីការធ្វើបត្យាប័ន។

*ភាគីត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន [ខាងលើ] អនុលោមទៅតាមសន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ។*

**មាត្រា ១៨**

កាតព្វកិច្ចនៃកិច្ចសហប្រតិបត្តិការលាតសន្ធឹងហួសឆ្ងាយពីទម្រង់នៃជំនួយ ដូចជា ការអនុវត្តសិទ្ធិអំណាចឆែកឆេរ និងចាប់យក ដើម្បីប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជាការសម្របសម្រួលប្រព័ន្ធសោតទស្សន៍សម្រាប់ស្តាប់ភស្តុតាង[២១០]។ សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកពាក់ព័ន្ធនឹងការជួញដូរមនុស្សគួរតែត្រូវបានផ្តល់អាទិភាព និង**ពន្លឿន**ឱ្យបានឆាប់តាមដែលអាចធ្វើបាន[២១១]។ ចុងក្រោយ ច្បាប់អន្តរជាតិតម្រូវថា **សិទ្ធិមនុស្ស**ត្រូវបានគោរពនៅក្នុងដំណើរការជំនួយផ្នែកច្បាប់ទៅវិញទៅមក។ រដ្ឋត្រូវធានាថា សំណើ នីតិវិធី ឬលទ្ធផលនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកមិនរំលោភទៅលើសិទ្ធិសារវ័ន្តនានា រួមមានការហាមឃាត់ស្តីពីការរើសអើង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការហាមឃាត់ទៅលើការធ្វើទារុណកម្ម និងការធ្វើបាប និងការផ្តន្ទាទោសយ៉ាងសាហាវព្រៃផ្សៃអមនុស្សធម៌ និងបន្ទាបបន្ថោក[២១២]។

ជំនួយផ្នែកច្បាប់ទៅវិញទៅមក គឺជាយន្តការសំខាន់មួយសម្រាប់ ការស្វែងរកទ្រព្យបានមកពីបទល្មើសដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ ច្បាប់អន្តរជាតិ ស្របជាមួយនឹង*គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* បញ្ជាក់ថា រដ្ឋមានកាតព្វកិច្ចគតិយុត្តិដើម្បីធានាថា ច្បាប់ និងនីតិវិធីពាក់ព័ន្ធគាំទ្រដល់កិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងការកំណត់ និងការរឹបអូសទ្រព្យបានមកពីបទល្មើស[២១៣]។ *ASEAN MLAT អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* និងបទដ្ឋានពាក់ព័ន្ធផ្សេងទៀតក៏អះអាងថា រដ្ឋគួរ**សហការឆ្លងដែនដើម្បីជួយរដ្ឋមួយទៀត** នៅក្នុងការកំណត់ ការចាប់យក ការរឹបអូស និងការប្រគល់ត្រឡប់វិញនូវទ្រព្យបានមកពីបទល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស[២១៤]។ *ផែនការសកម្មភាពអាស៊ាន* ក៏បានដោះស្រាយបញ្ហានេះផងដែរ ដោយតម្រូវឱ្យរដ្ឋសមាជិកអាស៊ាន៖

*ពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្ស ពង្រឹងមធ្យោបាយដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ចោទប្រកាន់ចារី រួមទាំង តាមរយៈការប្រើប្រាស់ជាប្រព័ន្ធនូវការបង្កកទ្រព្យក្នុងគោលបំណងរឹបអូស អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១៧ នៃ ACTIP* ***(ផ្នែក IV.C (c))***

---

[២១០] *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ចែង (នៅត្រង់វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤ឃ.២) ថា៖ "ក្នុងករណីសមស្រប រដ្ឋត្រូវបានជំរុញឱ្យប្រើប្រាស់ និងទទួលយកជាភស្តុតាងនៃភស្តុតាងបានមកពីប្រព័ន្ធសោតទស្សន៍នៅក្នុងតុលាការ ហើយតុលាការអាចទទួលការបំពាក់បរិក្ខារ និងមានធនធានពេញលេញសម្រាប់ប្រើប្រាស់ប្រព័ន្ធសោតទស្សន៍"។

[២១១] *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤ឃ.៣។ UNTOC មាត្រា ១៨(២៤)។

[២១២] ASEAN MLAT មាត្រា ៣(១)(គ), ៣(១)(ឃ)។ *គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប* គោលការណ៍ណែនាំលេខ ១។

[២១៣] *UNTOC* មាត្រា ១២។ *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤ឃ.៥។

[២១៤] ASEAN MLAT មាត្រា ១(២)(ឆ)(i) មាត្រា ២២។ UNTOC មាត្រា ១៣។ *អនុសញ្ញាអាស៊ានស្តីពីប្រឆាំងការជួញដូរមនុស្ស* មាត្រា ២១។

ក្របខ័ណ្ឌគតិយុត្តិ/គោលនយោបាយអន្តរជាតិ និងថ្នាក់តំបន់អះអាងថា **ច្បាប់ជាតិ**គួរគាំទ្រដល់បទប្បញ្ញត្តិស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកទាក់ទងនឹងការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ[២១៥]។ ដោយសារលក្ខខណ្ឌនៃឧក្រិដ្ឋភាពទ្វេ និងភាពធ្ងន់ធ្ងរ ចំណុចនេះជាទូទៅមានន័យថា រដ្ឋត្រូវធានាថាការជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ជាតិ ដោយមានការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១២ ខែយ៉ាងតិច។

## ការធ្វើបត្យាប័ននៅក្នុងសំណុំរឿងជួញដូរមនុស្ស

**ការធ្វើបត្យាប័ន**សំដៅដល់ដំណើរការដែលរដ្ឋមួយ (រដ្ឋដាក់សំណើ) ស្នើសុំរដ្ឋមួយទៀត (រដ្ឋទទួលសំណើ) ឲ្យបញ្ជូនបុគ្គលណាម្នាក់មកទទួលការចោទប្រកាន់ ឬអនុវត្តទោសទណ្ឌនៅក្នុងប្រទេសដាក់សំណើ។ ដោយសារលក្ខណៈដំណើរការជួញដូរមនុស្សជារឿយៗ ជនសង្ស័យដែលត្រូវគេចង់បានឲ្យយកទទួលការចោទប្រកាន់នៅក្នុងរដ្ឋមួយទៀត។ ចំណុចនេះអាចដោយសារពួកគេជាជនជាតិ ឬស្នាក់នៅរដ្ឋផ្សេងមួយទៀត ឬដោយសារពួកគេបោះជំហានដើម្បីបញ្ចៀសការចោទប្រកាន់ ឬការផ្តន្ទាទោសដោយគេចខ្លួនទៅកាន់រដ្ឋមួយទៀត។ ហេតុនេះ ជួនកាលការធ្វើបត្យាប័នមានសារៈសំខាន់ សម្រាប់ការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរឲ្យបានជោគជ័យ។ ច្បាប់ និងគោលនយោបាយអន្តរជាតិ មិនមែនត្រឹមតែ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* មានភាពច្បាស់លាស់ទៅលើចំណុចដែលថាការជួញដូរ និងបទល្មើសពាក់ព័ន្ធត្រូវតែជា**បទល្មើសដែលអាចធ្វើបត្យាប័នបាន**[២១៦]។ ដូចបានទទួលស្គាល់នៅក្នុង*គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* សន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នទ្វេភាគីគឺជាជំហានសំខាន់មួយក្នុងការបញ្ចប់អំពើនិទណ្ឌភាពចំពោះជនជួញដូរ[២១៧] ដូចយន្តការផ្សេងទៀតដូចជាយន្តការមួយដែលបានបង្កើតឡើងដោយ UNTOC ផងដែរ[២១៨]។

បទប្បញ្ញត្តិនៃ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* ស្តីពីការធ្វើបត្យាប័នមានភាពលម្អិតខ្លាំង ដោយឆ្លុះបញ្ចាំងនូវអវត្តមាននៃការរៀបចំការធ្វើបត្យាប័នថ្នាក់តំបន់។ បទប្បញ្ញត្តិទាំងនេះមានរៀបរាប់នៅក្នុងតារាងដូចខាងក្រោម។

---

[២១៥] *UNTOC* មាត្រា ១៨(១០)។ ពិធីសារ អ.ស.ប ប្រឆាំងការជួញដូរមនុស្ស មាត្រា ៥។ គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប គោលការណ៍ណែនាំលេខ ១២។ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១៖ ផ្នែក ១៖ កថាខណ្ឌ ១.១ និង វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤ខ.២។

[២១៦] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ១៖ ផ្នែក ១៖ កថាខណ្ឌ ១.៧។ *UNTOC* មាត្រា ១៦។ អនុសញ្ញាអាស៊ានស្តីពីប្រឆាំងការជួញដូរមនុស្ស មាត្រា ១៩(១)។

[២១៧] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ៤ខ.២។

[២១៨] *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* វគ្គ ២៖ ផ្នែក ២៖ កថាខណ្ឌ ៤ឃ.១។ សូមមើលបន្ថែម UNTOC មាត្រា ១៦។

*តារាង ៩៖ ACTIP - បទប្បញ្ញត្តិសំខាន់/កាតព្វកិច្ចទាក់ទងនឹងការធ្វើបត្យាប័ន*

| អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ<br>បទប្បញ្ញត្តិសំខាន់/កាតព្វកិច្ចទាក់ទងនឹងការធ្វើបត្យាប័ន | |
|---|---|
| **គោលការណ៍ដើម្បីធ្វើបត្យាប័ន ឬចោទប្រកាន់៖** | |
| [ទាក់ទងនឹងការរារាំងដល់យុត្តិធម៌] ភាគីនីមួយៗត្រូវអនុម័តវិធានការនានាជាការចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន ទៅលើបទល្មើសនានាដែលគ្របដណ្តប់ដោយអនុសញ្ញានេះ នៅពេលជនល្មើសមានវត្តមាននៅលើទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាប័នជននោះដោយផ្អែកទៅលើមូលដ្ឋានតែមួយដែលថា ជននោះមានសញ្ជាតិរបស់រដ្ឋនោះ។<br><br>[ទាក់ទងនឹងបទល្មើសជួញដូរមនុស្ស] ភាគីនីមួយៗក៏អាចអនុម័តវិធានការដែលអាចមានភាពចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសនានាដែលគ្របដណ្តប់ដោយអនុសញ្ញានេះ នៅពេលជនល្មើសមានវត្តមាននៅលើទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាប័នជននោះ។ | មាត្រា ១០ |
| ភាគីមួយដែលបានរកឃើញជនល្មើសនៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើរដ្ឋនោះមិនធ្វើបត្យាប័នជននោះទាក់ទងនឹងបទល្មើសដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះអនុវត្តតែទៅលើមូលដ្ឋានដែលថា ជននោះមានសញ្ជាតិរបស់រដ្ឋនោះ ត្រូវមានកាតព្វកិច្ចដាក់សំណុំរឿងនេះដោយមិនពន្យារពេលទៅកាន់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណងធ្វើការចោទប្រកាន់ បន្ទាប់ពីមានសំណើពីភាគីដែលស្នើសុំធ្វើបត្យាប័ន។ | មាត្រា ១៩(៤) |
| បទល្មើស ACTIP ត្រូវបានចាត់បញ្ចូលទៅក្នុងសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នទាំងអស់ដែលមានស្រាប់ និងនាពេលអនាគត | |
| បទល្មើសដែលត្រូវបានបង្កើតឡើង [ក្រោម] អនុសញ្ញាត្រូវបានចាត់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាធ្វើបត្យាប័ននានាដែលមានស្រាប់រវាងភាគី។ ភាគីទទួលរ៉ាប់រងបញ្ចូលបទល្មើសទាំងនេះជាបទល្មើសដែលអាចធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័នទាំងអស់ដែលបានធ្វើឡើងរវាងរដ្ឋទាំងនោះ។ | មាត្រា ១៩(១) |
| ACTIP អាចត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នរវាងភាគី | |
| ប្រសិនបើភាគីដែលកំណត់លក្ខខណ្ឌចំពោះការធ្វើបត្យាប័នទៅលើអត្ថិភាពនៃសន្ធិសញ្ញាមួយ បានទទួលសំណើសុំធ្វើបត្យាប័នពីភាគីមួយទៀតដែលពុំមានសន្ធិសញ្ញាស្តីពីការធ្វើបត្យាប័ន រដ្ឋនោះអាចពិចារណាយកអនុសញ្ញានេះធ្វើជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នទាក់ទងនឹងបទល្មើស [ACTIP]។ | មាត្រា ១៩(២) |
| កាតព្វកិច្ចនៃកិច្ចសហប្រតិបត្តិការក្នុងការធ្វើបត្យាប័ន | |
| [ស្ថិតក្រោមច្បាប់ជាតិ និងកិច្ចព្រមព្រៀងពាក់ព័ន្ធ] រដ្ឋទទួលសំណើអាចឃាត់ខ្លួនជនដែលត្រូវបានស្នើសុំធ្វើបត្យាប័ន និងដែលមានវត្តមាននៅលើទឹកដីរបស់ខ្លួន ឬចាត់វិធានការសមស្របនានា ដើម្បីធានានូវវត្តមានរបស់ជននោះនៅពេលមានកិច្ចដំណើរការនីតិវិធីធ្វើបត្យាប័ន បន្ទាប់ពីយល់ឃើញថា កាលៈទេសៈទាំងនោះគាំទ្រឲ្យធ្វើបត្យាប័ន ឬមានភាពបន្ទាន់ និងនៅពេលមានសំណើពីភាគីដាក់សំណើ។ | មាត្រា ១៩(៣) |
| [ទាក់ទងនឹងការចោទប្រកាន់បន្ទាប់មកមានការបដិសេធន៍មិនធ្វើបត្យាប័នដោយផ្អែកលើមូលដ្ឋានសញ្ជាតិ] ភាគីពាក់ព័ន្ធអាចសហការជាមួយគ្នា ជាពិសេស ទៅលើទិដ្ឋភាពនីតិវិធី និងភស្តុតាង ដើម្បីធានានូវប្រសិទ្ធភាពនៃការចោទប្រកាន់នោះ។ | មាត្រា ១៩(៤) |

**អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស**
**ជាពិសេស ស្ត្រី និងកុមារ**
**បទប្បញ្ញត្តិសំខាន់/កាតព្វកិច្ចទាក់ទងនឹងការធ្វើបត្យាប័ន**

| **កាតព្វកិច្ចចាត់តាំងអាជ្ញាធរកណ្ដាល** | |
| --- | --- |
| សម្រាប់គោលបំណង [នៃបទប្បញ្ញត្តិនានានៃអនុសញ្ញា] ភាគីនីមួយៗត្រូវចាត់តាំងឲ្យមានអាជ្ញាធរកណ្ដាលដើម្បីទទួលការជូនដំណឹងពីការអនុវត្តន៍នូវអនុសញ្ញានេះ។ | មាត្រា ១៩(៥) |

គោលនយោបាយរបស់អាស៊ានមានភាពច្បាស់លាស់ថា សំណើសុំធ្វើបត្យាប័នពាក់ព័ន្ធនឹងការជួញដូរគួរតែផ្ដល់អាទិភាពខ្ពស់ និង**ត្រូវបានពន្លឿនយ៉ាងបានឆាប់**តាមដែលអាចធ្វើទៅបាន[២១៩]។ វិធានពាក់ព័ន្ធតម្រូវផងដែរឲ្យរដ្ឋដែលមិនបានធ្វើបត្យាប័នដោយសារមូលហេតុសញ្ជាតិ ត្រូវធ្វើការចោទប្រកាន់ទៅលើជនល្មើស (គោលការណ៍ "**ធ្វើបត្យាប័នឬចោទប្រកាន់**")[២២០]។ ច្បាប់អន្តរជាតិតម្រូវថា ត្រូវគោរព**សិទ្ធិមនុស្ស**នៅក្នុងដំណើរការធ្វើបត្យាប័ន។ រដ្ឋត្រូវធានាថា សំណើសុំ នីតិវិធី ឬលទ្ធផលនៃការធ្វើបត្យាប័នមិនត្រូវរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរួមទាំងគោលការណ៍ *មិនបញ្ជូនអ្នកសុំសិទ្ធិជ្រកកោន (non-refoulement)* ការហាមឃាត់លើការរើសអើង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការហាមឃាត់ទៅលើការធ្វើទារុណកម្ម និងការធ្វើបាប និងការផ្ដន្ទាទោសយ៉ាងសាហាវព្រៃផ្សៃ អមនុស្សធម៌ និងបន្ទាបបន្ថោក[២២១]។

អាចកើតមានស្ថានភាព ដែលជនជួញដូរមនុស្ស អាចត្រូវបានចោទប្រកាន់នៅក្នុងរដ្ឋពីរ ឬច្រើន។ ទាក់ទងនឹង**ការផ្ទេរកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ** *គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* ផ្ដល់អនុសាសន៍ថា នៅក្នុងសំណុំរឿងទាំងនោះ៖

> *មធ្យោបាយផ្សេងទៀតនៅកម្រិតអន្តរជាតិ ថ្នាក់តំបន់ ឬទ្វេភាគីអាចត្រូវបានយកមកពិចារណាដើម្បីវាយតម្លៃ និងសម្របសម្រួលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយក្នុងករណីសមស្រប ពិចារណាផ្ទេរកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទៅឲ្យរដ្ឋសក្តិសមបំផុត ដើម្បីជាប្រយោជន៍នៃរដ្ឋបាលយុត្តិធម៌សមស្រប*[២២២]។

គោលការណ៍ណែនាំផ្ដល់អនុសាសន៍បន្ថែមថា គួរផ្ដល់ការពិចារណា "ដល់ការបង្កើតបទប្បញ្ញត្តិច្បាប់ជាក់លាក់ដើម្បីសម្របសម្រួលកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងសំណុំរឿងឆ្លងដែននៅក្នុងតំបន់អាស៊ាន"[២២៣]។

[២១៩] *UNTOC* មាត្រា ១៦(១០)។ *គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប* គោលការណ៍លេខ ១១.៩។

[២២០] *UNTOC* មាត្រា ១៥(៣) និង ១៦(១០)។ គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤ខ.១។ អនុសញ្ញាអាស៊ានស្ដីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ១០, ១៩(៤)។

[២២១] UNTOC មាត្រា ១៦(១៣)។ គោលការណ៍ និងគោលការណ៍ណែនាំរបស់ អ.ស.ប គោលការណ៍លេខ ១៤។ សូមមើលបន្ថែម យោងនៅក្នុងសៀវភៅអាស៊ានស្ដីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស ទំព័រ ១០៩ ដើងទំព័រ ៣៦១។

[២២២] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤គ.២។

[២២៣] គោលការណ៍ណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន វគ្គ ២៖ ផ្នែក ៤៖ កថាខណ្ឌ ៤គ.៣។

## ៧.២ វឌ្ឍនភាពរបស់អាស៊ានឆ្ពោះទៅកិច្ចសហប្រតិបត្តិការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាព

ផ្នែកនេះសង្ខេបអំពីវឌ្ឍនភាពដែលបានធ្វើឡើងនៅក្នុង និងរវាងរដ្ឋសមាជិកអាស៊ាន ទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ វាផ្អែកទៅលើព័ត៌មានដែលមានជាសាធារណៈព្រមទាំងព័ត៌មានស៊ីជម្រៅបន្ថែមទៀតដែលរដ្ឋសមាជិកអាស៊ាននីមួយៗបានផ្តល់ឲ្យ។ នៅចំណុចនោះ ការងារដែលបានធ្វើឡើងសម្រាប់រៀបរៀងសៀវភៅ ស្តីពីកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិ នៅក្នុងសំណុំរឿងជួញដូរមនុស្សក្នុងអំឡុងឆ្នាំ២០០៩-២០១០ និងការធ្វើបច្ចុប្បន្ន (ឆ្នាំ២០១៧-២០១៨) មានសារៈសំខាន់ ជាពិសេស ដោយសារវាបានផ្តល់កាលានុវត្តភាពដល់អ្នកប្រតិបត្តិពីរដ្ឋសមាជិកអាស៊ានទាំងអស់ឲ្យចែករំលែកនូវព័ត៌មានស្តីពីការអភិវឌ្ឍន៍ និងបទពិសោធន៍នៅក្នុងវិស័យនេះ ដែលបានឆ្លុះបញ្ចាំងនៅក្នុងការវិភាគដូចខាងក្រោម។

វាជាការសំខាន់ដែលគួរកត់សម្គាល់តាំងពីដំបូងមកថា ក្រៅពីមានគំនិតផ្តួចផ្តើមមួយចំនួននៅក្នុងកិច្ចសហការរវាងមន្ត្រីនគរបាលនិងមន្ត្រីនគរបាល ការបោះជំហានឆ្ពោះទៅកិច្ចសហប្រតិបត្តិការជាអន្តរជាតិមានចំនួនតិចតួច ចាប់តាំងពី *របាយការណ៍វឌ្ឍនភាព* ពីមុនបានចេញផ្សាយនៅឆ្នាំ២០១១។ មានការអភិវឌ្ឍន៍មួយចំនួនជុំវិញក្របខ័ណ្ឌគតិយុត្តិសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន តែក្រៅពីចំណុចនោះ លិខិតូបករណ៍ទាំងពីរនៃកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិនេះហាក់ដូចជាកម្រយកមកប្រើប្រាស់ ឬសូម្បីតែយកមកគិត ដោយព្រះរាជអាជ្ញា និងមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតនៅក្នុងបរិបទនៃសំណុំរឿងជួញដូរ។ ចំណុចនេះកើតមាន ទោះបីមានការអំពាវនាវយ៉ាងច្បាស់នៅថ្នាក់តំបន់ ឲ្យមានកិច្ចសហប្រតិបត្តិការច្រើនជាងមុន និងកាន់តែប្រសើរ ដែលជាលក្ខខណ្ឌមូលដ្ឋាននៅក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរទៅកាន់កម្រិតខ្ពស់ជាងនេះក៏ដោយ។ ផ្នែកចុងក្រោយនៃជំពូកនេះផ្តល់នូវព័ត៌មានស៊ីជម្រៅជាក់លាក់នៅក្នុងតំបន់ អំពីមូលហេតុនានានៅពីក្រៅកិច្ចសហប្រតិបត្តិការជាអន្តរជាតិដែលមានភាពយឺតយ៉ាវ និងស្វែងរកការកំណត់អំពីកាលានុវត្តភាពដើម្បីកែលម្អស្ថានភាពបច្ចុប្បន្ន។

អាស៊ានបានបោះជំហានសំខាន់ៗមួយចំនួន ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពថ្នាក់តំបន់ នៅក្នុងវិស័យកិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ នៅឆ្នាំ២០១០ SOMTC បានបោះពុម្ពផ្សាយ ***សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស*** ជាឧបករណ៍មួយដែលបានបង្កើតឡើងដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអ្នកប្រតិបត្តិមកពីរដ្ឋសមាជិកអាស៊ានទាំងអស់។ សៀវភៅនេះមានគោលបំណង សម្រាប់អ្នកប្រតិបត្តិផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ជាចម្បងគឺ មន្ត្រីអនុវត្តន៍ច្បាប់ ព្រះរាជអាជ្ញា មេធាវីអាជ្ញាធរកណ្តាល និងអ្នកផ្សេងទៀតដែលអាចចូលរួមក្នុងការស៊ើបអង្កេត និងចោទប្រកាន់ក្នុងសំណុំរឿងជួញដូរមនុស្ស ឬនៅក្នុងដំណើរការដាក់សំណើ ឬពិចារណាទៅលើសំណើសុំជំនួយឆ្លងកាត់ព្រំដែន។ សៀវភៅនេះផ្តល់នូវសេចក្តីចំពោះឧបករណ៍សំខាន់ៗ នៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ជាពិសេស ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន និងការណែនាំលម្អិតស្តីពីរបៀបដែលឧបករណ៍ទាំងនេះអាចពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ឬការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរមនុស្ស។ ការចូលរួមរបស់អ្នកប្រតិបត្តិអាស៊ានបានធានាថា សៀវភៅនេះពាក់ព័ន្ធទៅនឹងស្ថានភាពរបស់រដ្ឋសមាជិកអាស៊ានទាំងអស់ ហើយវាបានដោះស្រាយវិធីជាក់ស្តែង នូវការប្រឈមសំខាន់ៗចំពោះកិច្ចសហប្រតិបត្តិការជាអន្តរជាតិដែលរដ្ឋនៅក្នុងតំបន់នេះកំពុងប្រឈម។ នៅឆ្នាំ២០១៧ អ្នកប្រតិបត្តិពីរដ្ឋសមាជិកអាស៊ានបានជួបប្រជុំគ្នាដើម្បីកែ

ប្រែ*សៀវភៅ* ដើម្បីឆ្លុះបញ្ចាំងដល់ការប្រែប្រួលនៅក្នុងច្បាប់ គោលនយោបាយ និងការអនុវត្តន៍នៅក្នុងវិស័យនៃការឆ្លើយតបទៅនឹងការជួញដូរ ជាពិសេស៖

- **ការប្រែប្រួលក្របខ័ណ្ឌគតិយុត្តិនៅថ្នាក់ជាតិ៖** ដោយគូសបញ្ជាក់នូវច្បាប់ស្តីពីការជួញដូរមនុស្ស ថ្មីៗនៅក្នុងប្រទេសមួយចំនួន (ឧទា. ប្រទេសសិង្ហបុរី និងឡាវ) និងការកែប្រែខ្លឹមសារនៅក្នុងក្របខ័ណ្ឌគតិយុត្តិដែលមានស្រាប់នៅក្នុងប្រទេសផ្សេងទៀត (ឧទា. ប្រទេសថៃ ម៉ាឡេស៊ី)។ ការប្រែប្រួលទាំងនេះជាទូទៅបាននាំឲ្យច្បាប់ជាតិនៅក្នុងតំបន់កាន់តែខិតទៅជិតបទដ្ឋាននានាដែលមានចែងនៅក្នុងពិធីសារ អ.ស.ប ប្រឆាំងការជួញដូរ និង *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ*។
- **ការប្រឆាំងនឹងការសម្អាតប្រាក់កាន់តែរឹងមាំនៅថ្នាក់ជាតិ៖** នៅក្នុងតំបន់ទាំងមូល មានការពង្រឹងក្របខ័ណ្ឌច្បាប់ដើម្បីដោះស្រាយការសម្អាតប្រាក់បានមកពីបទល្មើស។ ទោះបីមានការប្រែប្រួលមួយចំនួន ត្រូវបានជំរុញដោយការព្រួយបារម្ភផ្សេងទៀត (ឧទា. ជុំវិញការផ្តល់ហិរញ្ញប្បទានដល់ភេរវកម្ម) ក៏ដោយ តែការប្រែប្រួលទាំងអស់បានជួយពង្រឹងសមត្ថភាពរបស់រដ្ឋក្នុងការស្វែងរកចារនៃបទល្មើសជួញដូរ និងទ្រព្យសម្បត្តិរបស់ពួកគេ។
- **ការពង្រឹងក្របខ័ណ្ឌគតិយុត្តិថ្នាក់តំបន់ជុំវិញជំនួយផ្នែកច្បាប់ទៅវិញទៅមក៖** គិតមកត្រឹមឆ្នាំ២០១៣ AMLAT នៅដំណើរការរវាងរដ្ឋសមាជិកអាស៊ានទាំង ១០។ ទោះបី សន្ធិសញ្ញានេះមិនត្រូវបានប្រើប្រាស់ជារួមថាជាមូលដ្ឋានគតិយុត្តិសម្រាប់ MLA ក៏ដោយ តែវាត្រូវបានយកមកប្រើប្រាស់យ៉ាងហោចណាស់ម្តងដែរ ដើម្បីស្នើសុំជំនួយនៅក្នុងសំណុំរឿងជួញដូរ។
- **ការពង្រឹងក្របខ័ណ្ឌគតិយុត្តិថ្នាក់តំបន់ជុំវិញការជួញដូរមនុស្ស៖** *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* ដែលត្រូវបានអនុម័តនៅខែវិច្ឆិកា ឆ្នាំ២០១៥ បានចូលជាធរមាននៅខែមីនា ឆ្នាំ២០១៧ ក្នុងចំណោមរដ្ឋភាគីចំនួន ៦។ អនុសញ្ញាអះអាងយ៉ាងច្បាស់នូវកាតព្វកិច្ចនៃកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីទាក់ទងនឹងការស៊ើបអង្កេត (កិច្ចសហប្រតិបត្តិការមិនផ្លូវការ) និង ការចោទប្រកាន់ (កិច្ចសហប្រតិបត្តិការតាមផ្លូវច្បាប់) នៅក្នុងសំណុំរឿងជួញដូរ។ អនុសញ្ញានេះក៏មានចែងនូវបទប្បញ្ញត្តិលម្អិតស្តីពីការធ្វើបត្យាប័នជនសង្ស័យ ឬទណ្ឌិតនៃបទល្មើសជួញដូរផងដែរ។ ប្រការសំខាន់គឺថា អនុសញ្ញានេះដើរតួនាទីជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័នរវាងរដ្ឋភាគី។

សៀវភៅដែលបានកែប្រែ ត្រូវបានបោះពុម្ពផ្សាយ នៅពាក់កណ្តាលឆ្នាំ២០១៨ នឹងដើរតួនាទីជាឯកសារយោងចម្បង ឬ "អត្ថបទមេរៀន" សម្រាប់ កម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរ។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានបង្កើតឡើងក្រោយការដឹកនាំរបស់អ្នកជំនាញ ILC មកពីការិយាល័យអគ្គមេធាវីថៃ និងដោយមានការសហការរបស់អ្នកប្រតិបត្តិមកពីរដ្ឋសមាជិកអាស៊ានផ្សេងទៀតដូចជា ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា។ កម្មវិធីបណ្តុះបណ្តាល ILC គឺជាកម្មវិធីបណ្តុះបណ្តាលល្អិតល្អន់ និងអន្តរកម្ម ដែលនឹងជួយឲ្យអ្នកប្រតិបត្តិថ្មីកទៅនឹងលិខិតូបករណ៍គតិយុត្តិនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និងបង្កើតជំនាញក្នុងការអនុវត្តន៍ចាំបាច់ដើម្បីប្រើប្រាស់ឲ្យបានពេញលេញនូវលិខិតូបករណ៍គតិយុត្តិទាំងនោះនៅក្នុងសំណុំរឿងជួញដូរមនុស្ស ជាពិសេស នៅក្នុងតំបន់។ កម្មវិធីនេះត្រូវបានបង្កើតឡើងជាក់លាក់សម្រាប់មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌដែលចូលរួម ឬរំពឹងថានឹងចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរ។ កម្មវិធីនេះមានបញ្ចូលអ្នកប្រតិបត្តិអនុវត្តន៍ច្បាប់ អ្នកស៊ើបអង្កេត រដ្ឋអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំនុំជម្រះ ដែលតម្រូវឲ្យទទួលយក ឬដោះស្រាយតាមវិធីផ្សេងទៀតជាមួយ MLA និងសំណើសុំធ្វើបត្យាប័នទៅលើបញ្ហាការជួញដូរមនុស្ស ឬបញ្ហាពាក់ព័ន្ធផ្សេងទៀត នៅក្នុងកិច្ចការងារប្រចាំថ្ងៃរបស់ខ្លួន។ វគ្គបណ្តុះបណ្តាលនឹងពាក់ព័ន្ធជាពិសេសសម្រាប់មេធាវីនៅក្នុងអាជ្ញាធរកណ្តាលដែលទទួលខុសត្រូវគ្រប់គ្រង និងដោះស្រាយសំណើសុំកិច្ចសហប្រតិបត្តិការផ្លូវតុលាការជាអន្តរជាតិ។

## វឌ្ឍនភាពទាក់ទងនឹងដំណើរការកិច្ចសហប្រតិបត្តិការមិនផ្លូវការ

កិច្ចសហប្រតិបត្តិការមិនផ្លូវការរវាងទីភ្នាក់ងារអនុវត្តន៍ច្បាប់អាស៊ាន នៅកម្រិតប្រតិបត្តិការកំពុងបង្ហាញសញ្ញាណថាមានវឌ្ឍនភាពខ្លាំងនៅក្នុងវិស័យមួយចំនួន ហើយវឌ្ឍនភាពខ្សោយនៅក្នុងវិស័យផ្សេងទៀត។ នៅពេលសរសេររបាយការណ៍នេះ រូបភាពមិនស្មើគ្នានេះបានឆ្លុះបញ្ចាំងនូវការបន្តមានភាពខ្វះខាតនូវគំនិតផ្តួចផ្តើមខ្លាំងក្លា ក្នុងការអនុវត្តន៍ជាក់ស្តែង នៅក្នុងភ្នាក់ងារមួយចំនួនដើម្បីធ្វើឲ្យដំណើរការកិច្ចសហប្រតិបត្តិការមិនផ្លូវការ ក្លាយជាសកម្មភាពអនុវត្តន៍ច្បាប់ប្រចាំថ្ងៃនៅទូទាំងតំបន់ទាំងមូល។ ដោយមានការប្តេជ្ញាចិត្តនៅកម្រិតនយោបាយតាមរយៈការផ្តល់សច្ចាប័នលិខិតូបករណ៍គតិយុត្តិ (ដូចជា ACTIP) ជានិច្ចកាលមិនស៊ីចង្វាក់ទៅនឹងការប្តេជ្ញាចិត្តដែលមានកម្រិតដូចគ្នារបស់មេបញ្ជាការប្រតិបត្តិការ។

វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការមិនផ្លូវការនេះ មានការវិវត្តនមិនស្មើគ្នាទេ។ កង្វះនីតិវិធីរឹងមាំ និងការអនុវត្តន៍ជុំវិញកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនមានន័យថា ផលប្រយោជន៍ហាក់ដូចជាពុំមាននិរន្តរភាព។ មានតម្រូវការចាំបាច់ នៅក្នុងតំបន់ ដើម្បីឲ្យមេបញ្ជាការនគរបាលជាន់ខ្ពស់ និងប្រមុខទីភ្នាក់ទទួលបន្ទុកចោទប្រកាន់ដើម្បីបង្កើត***យន្តការដំណើរការមាននិរន្តរភាព*** ដើម្បីឲ្យកិច្ចសហប្រតិបត្តិការជាអន្តរជាតិមិនផ្លូវការក្លាយជានិយាម មិនមែនជាករណីលើកលែងទេ នៅក្នុងសំណុំរឿងជួញដូរមនុស្សជាអន្តរជាតិ។

### *ប្រអប់អត្ថបទ ៣២៖ ឧទាហរណ៍អនុវត្តន៍៖*
### *ការប្រឈមនៃនិរន្តរភាពក្នុងការស៊ើបអង្កេតការជួញដូរមនុស្សឆ្លងដែន*

**កិច្ចសហប្រតិបត្តិការរវាងប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី**

នៅក្នុងឧទាហរណ៍មួយដែលទាក់ទងនឹងប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ជនបង្គោលដែលត្រូវបានចាត់តាំងប្រចាំអង្គភាពប្រឆាំងការជួញដូររបស់ប្រទេសទាំងពីរ បានបង្កើតនូវយន្តការមិនផ្លូវការនៃការប្រាស្រ័យទាក់ទងការងារដោយផ្ទាល់រវាងនគរបាលនិងនគរបាល ដោយប្រើប្រាស់ទូរស័ព្ទចល័តផ្អែកលើកម្មវិធី WhatsApp។ ក្រោយពេលយន្តការប្រាស្រ័យទាក់ទងការងារនេះត្រូវបានបង្កើតឡើងភ្លាម មន្ត្រីប្រឆាំងការជួញដូររបស់ INP បានប្រើប្រាស់កម្មវិធីនេះដើម្បីបញ្ជូនព័ត៌មានសម្ងាត់ដោយផ្ទាល់ទៅសមភាគីម៉ាឡេស៊ី ដោយនាំឲ្យមានការជួយសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា និងការចាប់ខ្លួនជនសង្ស័យជាច្រើននាក់។

**កិច្ចសហប្រតិបត្តិការរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា**

ការប្រាស្រ័យទាក់ទងការងាររវាងជនបង្គោលនៅក្នុងអង្គភាពឯកទេសក៏បានបង្ហាញពីសារៈសំខាន់ នៅក្នុងសំណុំរឿងមួយដែលពាក់ព័ន្ធនឹងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសមីយ៉ាន់ម៉ា និងសមភាគីរបស់ខ្លួននៅក្នុងនគរបាលភូមិន្ទថៃដែរ។ បន្ទាប់ពីមានការប្រជុំទ្វេភាគីរវាងភ្នាក់ងារទាំងពីរ ដែលក្នុងពេលនោះមានការផ្លាស់ប្តូរឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់ជនបង្គោលរួចមក MPF បានប្រើប្រាស់យន្តការមិនផ្លូវការនៃការប្រាស្រ័យទាក់ទងការងារនគរបាលនិងនគរបាល ដើម្បីបញ្ជូនព័ត៌មានទៅ RTP អំពីទីតាំងមួយដែលអាចជាកន្លែងកេងប្រវ័ញ្ចនៅក្នុងប្រទេសថៃ។ ប្រការនេះបាននាំឲ្យមានការជួយសង្គ្រោះដល់អ្នកដែលអាចជាជនរងគ្រោះ និងចាប់បានជួនសង្ស័យម្នាក់។

ឧទាហរណ៍ទាំងនេះបង្ហាញពីតួនាទីយ៉ាងសំខាន់របស់ជនបង្គោល នៅក្នុងអង្គភាពក្នុងការបង្កើតបណ្តាញទំនាក់ទំនងដោយផ្ទាល់ និងមិនផ្លូវការរវាងមន្ត្រីប្រឆាំងការជួញដូរនៅជុំវិញតំបន់។ ក៏ប៉ុន្តែ ជាការសំខាន់ត្រូវទទួលស្គាល់ថាឧទាហរណ៍ទាំងនេះនៅតែកម្រនៅឡើយ។ ការប្រាស្រ័យទាក់ទងការងារដែលជោគជ័យនៅក្នុងតំបន់នេះនៅតែពឹងផ្អែកជាខ្លាំងទៅលើការប្តេជ្ញាចិត្តរបស់បុគ្គលម្នាក់ៗ និងទំនាក់ទំនងផ្ទាល់ខ្លួន។ ប្រព័ន្ធ និងដំណើរការជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការនៅតែមានភាពទន់ខ្សោយដដែល។

វាជាការសំខាន់ផងដែរដែលគួរទទួលស្គាល់ថា ព័ត៌មានសម្ងាត់ប្រតិបត្តិការដែលមានលក្ខណៈរសើបគួរតែបញ្ជូនតាមរយៈយន្តការមានសុវត្ថិភាពប៉ុណ្ណោះ។ នេះជាការសំខាន់ដើម្បីការពារជនរងគ្រោះ និងរក្សាសុចរិតភាពនៃការស៊ើបអង្កេត។ ទោះបីការផ្លាស់ប្តូរព័ត៌មានមិនផ្លូវការនាពេលបច្ចុប្បន្ននៅក្នុងតំបន់កំពុងជំរុញឲ្យមានសញ្ញានៃឆន្ទៈថ្មីដើម្បីសហការក៏ដោយ តែវាជាការសំខាន់ដែលរដ្ឋសមាជិកអាស៊ានត្រូវប្តេជ្ញាពង្រឹងប្រព័ន្ធសម្រាប់ផ្លាស់ប្តូរព័ត៌មានសម្ងាត់ឆ្លងកាត់ព្រំដែនឲ្យបានលឿន និងមានសុវត្ថិភាព រួមទាំង ការប្រើប្រាស់ឲ្យកាន់តែធំធេងនូវការវាយកាណ៍ផ្អែកព័ត៌មានសម្ងាត់ដែលមានបទដ្ឋានត្រឹមត្រូវ។

## ដំណើរការប្រធានអង្គភាពឯកទេសការជួញដូរ (HSU)

ដំណើរការ HSU ដែលបានលើកឡើងនៅក្នុងជំពូកទី ២ គឺជាយន្តការសំខាន់មួយសម្រាប់កិច្ចសហប្រតិបត្តិការរវាងនគរបាលនិងនគរបាលនៅក្នុងតំបន់អាស៊ាន។ ដំណើរការនេះប្រតិបត្តិការនៅក្រោមការឧបត្ថម្ភរបស់ SOMTC របស់អាស៊ាន និងពាក់ព័ន្ធដល់រដ្ឋសមាជិកអាស៊ានទាំងអស់។ ដំណើរការនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវមធ្យោបាយមួយដែលអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អង្គភាពឯកទេសការជួញដូរមនុស្សនៅក្នុងតំបន់ អាចប្រាស្រ័យទាក់ទងការងារជាមួយគ្នាបាន ដោយស្នើសុំ ឬផ្តល់ព័ត៌មានសម្ងាត់ដែលអាចជួយក្នុងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្សជាក់លាក់បាន។ កាលពីមុន កិច្ចសហប្រតិបត្តិការរវាងសមាជិក HSU បានចូលរួមចំណែកដល់ការកំណត់អត្តសញ្ញាណ ជួយសង្គ្រោះ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ និងមានតិចតួចដែរគឺការចាប់ខ្លួនជនសង្ស័យ។

ដំណើរការ HSU បានទទួលជោគជ័យផ្សេងទៀតដែរ។ វាមានសារៈសំខាន់ ក្នុងការបង្កើតបទដ្ឋាន ឧបករណ៍ធនធាន និងនីតិវិធីមួយចំនួនធំដែលមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងតំបន់អាស៊ាន។ ចំណុចទាំងនេះរួមមានដូចខាងក្រោម៖

- នីតិវិធីដើម្បីសម្របសម្រួល និងកំណត់អំពីដំណើរការកិច្ចសហប្រតិបត្តិការរវាងអង្គភាពនិងអង្គភាព និងការផលិតឧបករណ៍ដើម្បីគាំទ្រការអនុវត្តន៍នូវនីតិវិធីទាំងនេះ (សៀវភៅស្តីពីនីតិវិធីប្រតិបត្តិការ)
- ការបង្កើត និងអនុវត្តន៍នូវវិធីសាស្ត្រ និងប្រព័ន្ធ ដើម្បីសម្របសម្រួលការប្រាស្រ័យទាក់ទងការងារយ៉ាងមានសុវត្ថិភាពរវាងអង្គភាពនិងអង្គភាព (រួមទាំងកម្មវិធីបំប្លែងលេខកូដ PGP ជាដើម)
- ការណែនាំមួយស្តីពីការបង្កើតអង្គភាពឯកទេសប្រឆាំងការជួញដូរ
- ការផ្លាស់ប្តូរ និងការបង្កើតបច្ចេកទេសស៊ើបអង្កេតដែលជាឧត្តមានុវត្តន៍
- កិច្ចព្រមព្រៀងទ្វេភាគីដើម្បីពិភាក្សាពីបញ្ហាជួញដូរ និងការស៊ើបអង្កេតប្រតិបត្តិការជាក់លាក់
- បទដ្ឋាននីតិវិធីប្រតិបត្តិការអាស៊ានសម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរ។

នៅឆ្នាំ២០០៩ ដំណើរការ HSU ត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងរចនាសម្ព័ន្ធ SOMTC របស់អាស៊ាន។ នេះជាការវិវត្តន៍វិជ្ជមានមួយ ដោយលើកកម្ពស់ដល់និរន្តរភាពយូរអង្វែងនៃដំណើរការ HSU និងអះអាងនូវឋានៈរបស់វាក្នុងនាមជាយន្តការតំបន់ពិតប្រាកដមួយ។ ការអំពាវនាវនៅក្នុង*ផែនការសកម្មភាពអាស៊ាន* ដល់រដ្ឋសមាជិកអាស៊ានឲ្យបន្តគាំទ្រដល់ដំណើរការ HSU គឺជាភស្តុតាងនៃការទទួលស្គាល់យ៉ាងទូលំទូលាយនូវតួនាទីរបស់វាក្នុងការឆ្លើយតបទៅនឹងការជួញដូរ។

### *ប្រអប់អត្ថបទ ៣៣៖ ឧទាហរណ៍អនុវត្តន៍៖*
### *របៀបដែល HSU ត្រូវបានយកមកប្រើប្រាស់ដើម្បីជួយសម្រួលដល់ដំណើរការកិច្ចសហប្រតិបត្តិការ*

> រដ្ឋសមាជិកអាស៊ានជាច្រើនបានរាយការណ៍ថា HSU បានផ្តល់នូវចំណុចទំនាក់ទំនងសំខាន់មួយសម្រាប់មន្ត្រីដែលបំពេញការងារនៅក្នុងសំណុំរឿងជួញដូរ។ នៅក្នុងករណីជាច្រើន ទំនាក់ទំនងទាំងនេះ បាននាំទៅរកការរៀបចំកិច្ចប្រជុំទ្វេភាគីដែលមានការផ្លាស់ប្តូរព័ត៌មាន និងព័ត៌មានសម្ងាត់លម្អិត។

សំណៅឆ្នាំ២០១១ នៃ*របាយការណ៍វឌ្ឍនភាពអាស៊ាន* អាចរៀបចំជាឯកសារនូវសមិទ្ធផលប្រតិបត្តិការធំៗនៃដំណើរការ HSU។ ដូចបានលើកឡើងខាងលើ តាមរយៈការងាររបស់ខ្លួន ជនរងគ្រោះត្រូវបានជួយសង្គ្រោះ ហើយ (ពុំសូវញឹកញយ) ចារីត្រូវបានចាប់ខ្លួន។ ទោះបីការកែសម្រួលនេះនៃ*របាយការណ៍វឌ្ឍនភាព*មិនអាចរាយការណ៍ជាក់លាក់នូវទិន្នន័យជុំវិញកិច្ចសហប្រតិបត្តិការដែលសម្របសម្រួលដោយ HSU ក៏ដោយ តែការងាររបស់ HSU លើទិដ្ឋភាពនេះហាក់ដូចជាថយចុះជាខ្លាំងទៅតាមពេលវេលា។ ជាពិសេសក្នុងរយៈពេលជាង ៥ ឆ្នាំចុងក្រោយនេះ ដំណើរការ HSU បានងាកចេញជាខ្លាំងពីការពាក់ព័ន្ធនៅកម្រិតប្រតិបត្តិការ។ នាពេលបច្ចុប្បន្ន មេបញ្ជាការមួយចំនួនតូច ឬ "ប្រធាន" អង្គភាពឯកទេសបានចូលរួមប្រជុំ HSU អាចជាបុព្វហេតុ ឬជាលទ្ធផលនៃការប្រែប្រួលនេះ។ ការពិតការផ្លាស់ប្តូរនូវចំនួនអ្នកចូលរួម (នាពេលនេះអ្នករៀបចំគោលនយោបាយមានចំនួនច្រើនជាអ្នកប្រតិបត្តិ) ស្របទៅនឹងការផ្តោតយ៉ាងធំធេងទៅលើបញ្ហាពាក់ព័ន្ធនឹងគោលនយោបាយដោយមិនគិតដល់បញ្ហាប្រតិបត្តិការ។

## ដំណើរការកិច្ចសហប្រតិបត្តិការមិនផ្លូវការខាងក្រៅដំណើរការ HSU

ព័ត៌មានពេញលេញ និងអាចទុកចិត្តបានអំពីលក្ខណៈ និងវិសាលភាពនៃកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនរវាងភ្នាក់ងារអនុវត្តន៍ច្បាប់របស់រដ្ឋសមាជិកអាស៊ាន នៅតែមិនទាន់អាចរកបាននៅក្នុងតំបន់ទាំងមូល។ នោះភាគច្រើនដោយសារ ភ្នាក់ងារភាគច្រើនដែលចូលរួម នៅក្នុងកិច្ចសហប្រតិបត្តិការនេះ បន្តខ្វះខាតយន្តការថ្នាក់កណ្តាលសម្រាប់កត់ត្រាអន្តរកម្មនៃការឆ្លងកាត់ព្រំដែន។ នៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន មានកិច្ចខិតខំប្រឹងប្រែងបង្កើតប្រព័ន្ធទាំងនេះ ហើយជាលទ្ធផល គុណភាពទិន្នន័យដែលរកបានមានការកែលម្អ។ មានឧទាហរណ៍ដែលលើកឡើងនៅក្នុងប្រអប់អត្ថបទខាងក្រោម។

### *ប្រអប់អត្ថបទ ៣៤៖ ឧទាហរណ៍អនុវត្តន៍៖ កិច្ចសហប្រតិបត្តិការ និងការចែករំលែកទិន្នន័យ*

> នាពេលថ្មីៗ **នគរបាលជាតិហ្វីលីពីន** និង**នគរបាលភូមិន្ទម៉ាឡេស៊ី** បានចូលទៅក្នុងពេលវេលានៃកិច្ចសហប្រតិបត្តិការរួម ដែលក្នុងពេលនោះ ព័ត៌មានសម្ងាត់ទាំងអស់ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍នៃបទដ្ឋានព័ត៌មានសម្ងាត់ ហើយរាល់ព័ត៌មានសម្ងាត់ទាំងអស់ត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ។ នាពេលនេះ ព័ត៌មានសម្ងាត់ថ្មីៗត្រូវបាន

ចែករំលែកជាប្រចាំ ដែលនាំឲ្យធ្វើការកាន់តែជិតស្និទ្ធ និងការយល់ដឹងរួមគ្នាកាន់តែច្រើនឡើងនៃបទល្មើសជួញដូរមនុស្សដែលប៉ះពាល់ដល់រដ្ឋទាំងពីរ។

**ប្រទេសមីយ៉ាន់ម៉ា** កំពុងផ្តោតទៅលើកិច្ចសហប្រតិបត្តិការជាមួយតំបន់ព្រំដែន។ កិច្ចការនេះបានធ្វើចាប់តាំងពីឆ្នាំ២០១៥ មកម្ល៉េះ។ ឧទាហរណ៍ មីយ៉ាន់ម៉ាប្រគល់ ស៊ីមកាត ៥ សន្លឹក ទូរស័ព្ទម៉ាក Nokia ១ គ្រឿង និង ទូរស័ព្ទ iPhone ១ គ្រឿងទៅឲ្យនគរបាលភូមិន្ទថៃនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ដែលចាប់បានពីជនល្មើសជនជាតិថៃ ដើម្បីឲ្យពួកគេស៊ើបអង្កេត។ ក្រោយពេល RTP ស៊ើបអង្កេត ពួកគេបានផ្តល់ភស្តុតាងទាំងអស់នៅក្នុង CD មួយបន្ទះ ដែលមានព័ត៌មាននៃការស៊ើបអង្កេតដោយកងកម្លាំងនគរបាលមីយ៉ាន់ម៉ានៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥។ ជាងនេះទៀត កិច្ចប្រជុំសហប្រតិបត្តិការជាទៀងទាត់បានធ្វើឡើងរវាង MPF-RTP, MPF-DSI និង MPF-នគរបាលចិន ដើម្បីចែករំលែកព័ត៌មានសម្ងាត់ដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ និងផ្អែកលើចរន្តថ្មីនៃសំណុំរឿងជួញដូរមនុស្សរវាងមីយ៉ាន់ម៉ា និងតំបន់ព្រំដែនរបស់ខ្លួន។

មានឧទាហរណ៍ផ្សេងទៀតដែលបង្ហាញថា ផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនកាន់តែទូលំទូលាយកាន់តែលេចចេញជារូបរាងឡើងនៅជុំវិញតំបន់អាស៊ាន។ ដូចដែលនឹងបង្ហាញនៅក្នុងឧទាហរណ៍នៅក្នុងប្រអប់អត្ថបទ ៣៥ កិច្ចសហប្រតិបត្តិការរវាងកងកម្លាំងនគរបាល**មីយ៉ាន់ម៉ា** និងនាយកដ្ឋានស៊ើបអង្កេតពិសេសរបស់**ថៃ** កាន់តែមានភាពរឹងមាំក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ តែនាពេលថ្មីនេះ MPF បានបង្កើតទំនាក់ទំនងយ៉ាងប្រយោជន៍ជាមួយនគរបាលភូមិន្ទថៃ ជាទីភ្នាក់សំខាន់មួយទៀតដែលចូលរួមក្នុងការស៊ើបអង្កេតទៅលើបទល្មើសជួញដូរ។ ចំណុចនេះក៏បាននាំឲ្យមានលទ្ធផលវិជ្ជមានមួយចំនួនដែរ រួមទាំងការជួយសង្គ្រោះជនរងគ្រោះ និងការចាប់ខ្លួនជនល្មើស។ យើងអាចឃើញមានករណីស្រដៀងរវាង**ប្រទេសកម្ពុជា និងថៃ** និង**ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី** ដែរ ដោយផ្អែកលើការចែករំលែកព័ត៌មានសម្ងាត់តាមរយៈការប្រើប្រាស់បទដ្ឋាននៃការរាយការណ៍។

### *ប្រអប់អត្ថបទ ៣៥៖ ឧទាហរណ៍អនុវត្តន៍៖ កិច្ចសហប្រតិបត្តិការរវាងផ្នែកអនុវត្តន៍ច្បាប់ប្រទេសមីយ៉ាន់ម៉ា និងថៃ*

នៅខែមិថុនា ឆ្នាំ២០១៧ នាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) បានចាប់ផ្តើមការស៊ើបអង្កេតទៅលើស្ត្រីជនជាតិមីយ៉ាន់ម៉ា ដែលត្រូវបានជួញដូរមនុស្សនៅប្រទេសម៉ាឡេស៊ី ដោយឆ្លងកាត់ប្រទេសថៃ។ នៅពេលនោះ DSI ជួបប្រជុំជាមួយនាយដ្ឋានប្រឆាំងការជួញដូរមនុស្សមីយ៉ាន់ម៉ា (ATIPD) ជាផ្នែកនៃកិច្ចប្រជុំពីរឆ្នាំម្តងដើម្បីពិភាក្សាកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែននៃការស៊ើបអង្កេតពាក់ព័ន្ធនឹង TIP។ ក្នុងអំឡុងពេលប្រជុំនេះ ទិដ្ឋភាពនានានៃការស៊ើបអង្កេតរវាងថៃ/ម៉ាឡេស៊ីត្រូវបានពិភាក្សា ដោយលើកឡើងថា ជនរងគ្រោះមីយ៉ាន់ម៉ាបានវិលត្រឡប់ទៅប្រទេសថៃវិញ ហើយនាពេលថ្មីៗត្រូវបានដាក់ឲ្យស្ថិតនៅក្នុងមណ្ឌលគាំទ្រជនរងគ្រោះនៅក្រុងបាងកក។ គេបានទាក់ទងមណ្ឌលនោះដើម្បីឲ្យដឹងថាតើស្ត្រីមីយ៉ាន់ម៉ាទាំងនោះត្រៀមខ្លួននិយាយជាមួយសមាជិកម្នាក់ពី ATIPD ឬយ៉ាងណា។ ជាលទ្ធផល អ្នកស៊ើបអង្កេតស្ត្រីម្នាក់ពី ATIPD បានធ្វើដំណើរទៅនិយាយជាមួយស្ត្រីទាំងនោះដល់មណ្ឌលនោះ។ ស្ត្រីម្នាក់ៗបានរៀបរាប់យ៉ាងលម្អិតអំពីកាលៈទេសៈនានាដែលពួកគេរងការជួញដូរ ដែលពួកគេទាំងអស់គ្នាមកពីរដ្ឋ Shan។ ដោយផ្អែកលើព័ត៌មាននេះ ការស៊ើបអង្កេតមួយក៏បានចាប់ផ្តើមនៅរដ្ឋ Shan ប្រទេសមីយ៉ាន់ម៉ា។

មានការរៀបចំកិច្ចប្រជុំមិនអចិន្ត្រៃយ៍បន្ថែមទៀត រវាងអ្នកស៊ើបអង្កេត DSI និង ATIPD ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើវឌ្ឍនភាពនៃការស៊ើបអង្កេត និងការចែករំលែកព័ត៌មាន។ ជាលទ្ធផល អ្នកជ្រើសរើសពលករ និងឈ្មួញកណ្តាលជាច្រើននៅមូលដ្ឋានជាច្រើននាក់ត្រូវបានកំណត់អត្តសញ្ញាថាជាជនសមគំនិតនៅក្នុងការជួញដូរស្ត្រីក្មេងៗជាច្រើននាក់ពីប្រទេសមីយ៉ាន់ម៉ា។ ក្រៅពីនេះ មានការរកឃើញថាមន្ត្រីរដ្ឋាភិបាលថៃនៅមូលដ្ឋានបានគាំទ្រដល់ជនជួញដូរ ដោយផ្តល់ឯកសារក្លែងក្លាយ។ ការស៊ើបអង្កេតកំពុងបន្តធ្វើដោយមានការសម្របសម្រួល និងចែករំលែកព័ត៌មានតាមរយៈកិច្ចប្រជុំមិនអចិន្ត្រៃយ៍នៅកម្រិតឆ្លងកាត់ព្រំដែននៅមូលដ្ឋាន ហើយនៅថ្នាក់ជាតិមានកិច្ចប្រជុំទ្វេភាគីជាផ្លូវការផងដែរ។

រដ្ឋសមាជិកអាស៊ានដែលបានចំណាយធនធាន ក្នុងការដាក់មន្ត្រីទំនាក់ទំនងនៅក្នុងប្រទេសជិតខាង បានទទួលផលប្រយោជន៍ជាច្រើនត្រឡប់មកវិញ។ ឧទាហរណ៍ រដ្ឋាភិបាល**ថៃ**បានដាក់មន្ត្រីទំនាក់ទំនងនគរបាលនៅក្រុង Yangon ដែលមានប្រយោជន៍ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនគរបាលរវាងប្រទេសថៃ និងមីយ៉ាន់ម៉ា។ មានភាពជោគជ័យស្រដៀងគ្នាដែលទាក់ទងនឹងការដាក់មន្ត្រីមួយរូបពីនគរបាលជាតិ**ហ្វីលីពីន**នៅក្រុងគូឡាឡាំពួរ។ ទោះបីជំហរទាំងនេះមិនផ្តោតទាំងស្រុងទៅលើការជួញដូរមនុស្សក៏ដោយ តែការដាក់ឲ្យមានមន្ត្រីទំនាក់ទំនងនគរបាលនៅតាមបណ្តាប្រទេសដែលមានការប្រឈមផ្នែកជួញដូរមនុស្សយ៉ាងធំធេងបានបង្ហាញថាបានទទួលប្រយោជន៍ជាច្រើន។

ចាប់តាំងពីរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១១មក រដ្ឋសមាជិកអាស៊ានទាំងអស់បាន***កំណត់អត្តសញ្ញាណជនបង្គោលប្រតិបត្តិការ*** ដែលបំពេញការងារនៅក្នុងអង្គភាពប្រឆាំងការជួញដូរនៃនគរបាលជាតិ។ ជនបង្គោលអាចបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ផ្លាស់ប្តូរព័ត៌មាន និងផ្តល់ការគាំទ្រ និងដំបូន្មានដល់សហការីអន្តរជាតិទៅលើសំណុំរឿងជួញដូរ។ ការរក្សាបញ្ជីឈ្មោះជនបង្គោលគឺជាវិស័យសំខាន់នៃការងារសម្រាប់ភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងសហគមន៍អាស៊ាន។ នាពេលបច្ចុប្បន្ន បញ្ជីនេះត្រូវបានរក្សាទុកដោយកម្មវិធី AAPTIP តែការទទួលខុសត្រូវចំពោះកាតព្វកិច្ចនេះនឹងផ្តល់ឲ្យស្ថាប័ននគរបាលថ្នាក់តំបន់នាពេលអនាគត។

ដំណើរការកិច្ចសហប្រតិបត្តិការមិនផ្លូវការក៏អាចមានសារៈសំខាន់ ផងដែរនៅកន្លែងព្រំដែនរួម។ មានឧទាហរណ៍ជាច្រើនពីក្នុងតំបន់អាស៊ានដែលមន្ត្រីសហការមិនផ្លូវការជាមួយសមភាគីរបស់ខ្លួន នៅផ្នែកម្ខាងទៀតនៃព្រំដែន ជាចម្បងដើម្បីកំណត់ទីតាំង និងយកជនរងគ្រោះពីការជួញដូរមនុស្សចេញពីស្ថានភាពមានគ្រោះថ្នាក់ នៅពេលដែលគេដឹងពីទីកន្លែងរបស់អ្នកទាំងនោះ។ កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនប្រភេទនេះត្រូវបានសម្របសម្រួលដោយសារមានប៉ុស្តិ៍ទំនាក់ទំនងតាមព្រំដែនបំពេញការងារដោយមន្ត្រីដែលមានការយល់ដឹងពីការជួញដូរ។ ប៉ុស្តិ៍ទាំងនេះត្រូវបានបង្កើតឡើងនៅតំបន់ព្រំដែន ចិន/**មីយ៉ាន់ម៉ា** ចិន/**ឡាវ** និង ចិន/**វៀតណាម** ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងនគរបាលទៅលើសំណុំរឿងជួញដូរមនុស្ស[២២៤]។ ក្នុងអំឡុងឆ្នាំ២០១២-២០១៤ ការិយាល័យសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សតាមព្រំដែន (BCATIP) ត្រូវបានបង្កើតឡើងនៅទីកន្លែព្រំដែនចំនួន ៣ រវាង**ប្រទេសថៃ** និង**មីយ៉ាន់ម៉ា** ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនទៅលើការជួញដូរមនុស្សរវាងប្រទេសទាំង

---

[២២៤] ការិយាល័យទំនាក់ទំនងព្រំដែនចំនួន ៧ បានបើកដំណើរការនៅ Dongxing, Pingxiang និង Jingxi ក្នុងខេត្ត Guangxi និងក្រុង Hekou នៅខេត្ត Yunnan ក្នុងប្រទេសចិន (ដើម្បីសហការជាមួយវៀតណាម) នៅ Ruili និង Zhangfeng នៅខេត្ត Yunnan (ដើម្បីសហការជាមួយមីយ៉ាន់ម៉ា) ព្រមទាំងនៅ Mengla ក្នុងខេត្ត Yunnan (ដើម្បីសហការជាមួយឡាវ) ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងនគរបាលជាអន្តរជាតិ និងដើម្បីសម្របសម្រួលនូវការធ្វើមាតុភូមិនិវត្តន៍ដល់ជនរងគ្រោះពីការជួញដូរ និងដើម្បីចោទប្រកាន់ជនជួញដូរ។

ពីរ (Ranong និង Kawthaung; Tak និង Myawaddy; និង Mae Sai និង Tachileik)។ មានការរាយការណ៍ថា ចាប់ពីពេលនោះមក មន្ត្រីមកពីការិយាល័យ BCATIP បានជួបប្រជុំគ្នាជាទៀងទាត់ ពួកគេបានផ្តល់ជំនួយក្នុងការជួយសង្គ្រោះជនរងគ្រោះ និងធ្វើមាតុភូមិនិវត្តន៍ដល់ពួកគេដោយសុវត្ថិភាព ហើយ ពួកគេបានចូលរួមក្នុងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរមនុស្សឆ្លងដែន។

## វឌ្ឍនភាពទាក់ទងនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមក

ដូចបានលើកឡើងខាងលើ ការអភិវឌ្ឍន៍ធំៗទាក់ទងនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងតំបន់អាស៊ាននៅក្នុងវិស័យច្បាប់ និងគោលនយោបាយ ដោយបញ្ជាក់នូវការកើនឡើងនៃការយល់ដឹង (យ៉ាងហោចណាស់នៅកម្រិតខ្លះនៅក្នុងរដ្ឋាភិបាល) នៃតម្រូវការចាំបាច់ឱ្យមានកិច្ចសហប្រតិបត្តិការក្នុងការកែលម្អនៃការឆ្លើយតបរបស់តំបន់ទៅនឹងការជួញដូរមនុស្ស។ ការអនុវត្តន៍ជាក់ស្តែងនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿង TIP នៅតែកម្រ ទោះបីមានឧទាហរណ៍ជាច្រើន ដូចបានរៀបរាប់លម្អិតនៅក្នុង *សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស* (កែសម្រួលលើកទី ២ ឆ្នាំ២០១៨)។

ការអភិវឌ្ឍន៍ផ្នែកច្បាប់ និងគោលនយោបាយជុំវិញបញ្ហានេះមានភាពធំធេង។ នៅកម្រិតតំបន់ ការអភិវឌ្ឍន៍ទាំងនេះបណ្តាលឱ្យមានរបបច្បាប់ថ្នាក់តំបន់រឹងមាំ សម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមក រួមទាំងសំណុំរឿងជួញដូរ។ ចាប់តាំងពី*របាយការណ៍វឌ្ឍនភាព*មុនមក រដ្ឋសមាជិកអាស៊ានទាំង ១០ ក្លាយជាភាគីនៃ *MLAT* របស់អាស៊ាន។ ការអះអាងពីភាពអាចអនុវត្តន៍នៃសំណុំរឿងជួញដូរមនុស្សតាមរយៈមាត្រា ១៨ នៃ *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* (ដែលអំពាវនាវឱ្យរដ្ឋសមាជិកអាស៊ានផ្តល់ឱ្យគ្នាទៅវិញទៅមកឱ្យបានទូលំទូលាយបំផុតនូវ MLA នៅក្នុងសំណុំរឿងទាំងនោះ) ផ្តល់ការជំរុញសំខាន់ដល់ក្របខ័ណ្ឌគតិយុត្តិថ្នាក់តំបន់។

ជាទូទៅ ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងតំបន់អាស៊ានមានភាពប្រសើរ ដោយមានការបោះជំហាននាំមុខមួយចំនួនក្នុងរយៈពេលជាច្រើនឆ្នាំចុងក្រោយនេះ។ ចំណុចនេះជាការសំខាន់ដោយសារបទពិសោធន៍បញ្ជាក់ថា ច្បាប់ទាំងនេះមានសារៈសំខាន់ សម្រាប់រៀបចំដំណើរការផ្ទៃក្នុងសម្រាប់ MLA។ ដូចដែលនឹងបង្ហាញនៅក្នុងប្រអប់អត្ថបទខាងក្រោម រដ្ឋសមាជិកអាស៊ានភាគច្រើន (តែមិនទាំងអស់) បានអនុម័តច្បាប់គ្រប់គ្រងបញ្ហានេះ។ ច្បាប់ទាំងនេះភាគច្រើនលាតសន្ធឹងទៅគ្របដណ្តប់លើ MLA ក្នុងសំណុំរឿងជួញដូរមនុស្ស។

ការអភិវឌ្ឍន៍ថ្មីមួយដែលគួរឱ្យកត់សម្គាល់ គឺការតាក់តែងសេចក្តីព្រាងច្បាប់ថ្មីមួយស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅប្រទេសកម្ពុជា ដែលទទួលការគាំទ្រយ៉ាងសកម្មពីប្រទេសថៃ និងជំរុញយ៉ាងខ្លាំងក្លាពីភាពជាក់ស្តែងរួម នៃតម្រូវឱ្យមានការកែលម្អសមត្ថភាព ដើម្បីដោះស្រាយសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្ស។

*តារាង ១០៖ ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងរដ្ឋសមាជិកអាស៊ាន*

| រដ្ឋសមាជិកអាស៊ាន | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅថ្នាក់ជាតិ |
| --- | --- |
| ប្រ៊ុយណេ ដារូសាឡាម | បទបញ្ជាស្តីពីជំនួយទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ឆ្នាំ២០០៥) |
| កម្ពុជា | បច្ចុប្បន្នកំពុងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅថ្នាក់ជាតិ។ បទប្បញ្ញត្តិនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកមួយចំនួនមានដូចខាងក្រោម៖<br>• ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០<br>• ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ឆ្នាំ២០១៣<br>• ច្បាប់ស្តីពីអំពើភេរវកម្ម ឆ្នាំ២០០៧ |
| ឥណ្ឌូនេស៊ី | ច្បាប់ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ១ ឆ្នាំ ២០០៦) |
| ឡាវ | ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ធ្វើវិសោធនកម្មនៅឆ្នាំ២០១២) ផ្នែក XIV |
| ម៉ាឡេស៊ី | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌឆ្នាំ២០០២ [ច្បាប់លេខ ៦២១] |
| មីយ៉ាន់ម៉ា | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ៤/២០០៤) |
| ហ្វីលីពីន | គ្មានច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ក៏ប៉ុន្តែ មានបទប្បញ្ញត្តិមួយចំនួននៅក្នុងច្បាប់សាធារណរដ្ឋ (RA) លេខ ៩១៦០ ដែលស្គាល់ថាជាច្បាប់ប្រឆាំងការសម្អាតប្រាក់ឆ្នាំ២០០១ ដែលត្រូវបានធ្វើវិសោធនកម្មដោយ RA លេខ ១០៣៦៥ (សូមមើលប្រអប់អត្ថបទខាងក្រោម) |
| សិង្ហបុរី | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (Cap 190A សំណៅវិសោធនកម្ម ឆ្នាំ២០០១) |
| ថៃ | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ ព.ស ២៥៣៥ (ឆ្នាំ១៩៩២) ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (សំណៅលើកទី ២) ព.ស ២៥៥៩ (ឆ្នាំ២០១៦) (ថៃ) |
| វៀតណាម | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក (ច្បាប់លេខ ០៨/២០០៧/QH១២) |

ដូចបានកត់សម្គាល់ខាងលើ ជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាយាន្តមួយសំខាន់ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការដើម្បីស្វែងរកទ្រព្យបានមកពីបទល្មើសជួញដូរ។ ចាប់តាំងពី *របាយការណ៍វឌ្ឍនភាព* មុនមក ច្បាប់ថ្នាក់តំបន់ (រួមមាន *អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ*) និងគោលនយោបាយ (រួមមាន *សេចក្តីណែនាំសម្រាប់អ្នកប្រតិបត្តិអាស៊ាន* និង *ផែនការសកម្មភាពអាស៊ាន*) អះអាងច្បាស់អំពីតម្រូវការចាំបាច់ឲ្យកិច្ចសហប្រតិបត្តិការនេះទាក់ទងនឹងសំណុំរឿងជួញដូរ។

បទប្បញ្ញត្តិនៃជំនួយផ្នែកច្បាប់ទៅវិញទៅមក ដើម្បីស្វែងរកទ្រព្យបានពីបទល្មើសត្រូវបានកំណត់ដោយច្បាប់ជាតិនៅក្នុងរដ្ឋសមាជិកអាស៊ានភាគច្រើន (តែមិនទាំងអស់)។ ឧទាហរណ៍ ក្រោម*ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ* របស់**ប្រទេសថៃ** ថៃនឹងពិចារណាទៅលើសំណើពីរដ្ឋផ្សេងទៀតដែលសុំទម្រង់ផ្សេងៗនៃជំនួយ រួមមាន "ការបាត់បង់សិទ្ធិទ្រព្យសម្បត្តិ" និង "កិច្ចដំណើរការនីតិវិធីផ្សេងទៀតទាក់ទងនឹងបញ្ហាព្រហ្មទណ្ឌ"។ ឧទាហរណ៍មួយទៀត *ច្បាប់ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ* របស់**ប្រទេស**

**ឥណ្ឌូនេស៊ី** ចែងថា ជំនួយនេះអាចស្វែងរក ឬទទួលបានសម្រាប់គោលបំណងមួយចំនួន រួមមាន៖ ការបាត់បង់សិទ្ធិលើទ្រព្យបានមកពីបទល្មើស ការស្វែងរកទោសពិន័យជាប្រាក់ទាក់ទងនឹងបទល្មើស ការហាមឃាត់ការជួញដូរលើទ្រព្យសម្បត្តិ ការស្វែងរក និងបង្កកទ្រព្យសម្បត្តិដែលអាចរកឃើញ ឬរឹបអូស ឬដែលអាចចាំបាច់ដើម្បីបំពេញទៅតាមទោសពិន័យជាប្រាក់ដែលបានកំណត់ទាក់ទងនឹងបទល្មើស និង "ជំនួយផ្សេងទៀតអនុលោមតាមច្បាប់នេះ"[២២៥]។ នៅក្នុងរដ្ឋមួយចំនួន អាចមានមធ្យោបាយបន្ថែមទៀតសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយសារមានច្បាប់ប្រឆាំងការសម្អាតប្រាក់។

រដ្ឋសមាជិកអាស៊ានមួយចំនួនបានស្វែងរកការណែនាំសម្រាប់រដ្ឋដែលស្នើសុំកិច្ចសហប្រតិបត្តិការក្នុងការស្វែងរកទ្រព្យបានមកពីបទល្មើស។ ឧទាហរណ៍ ការិយាល័យអគ្គមេធាវីរបស់**ប្រទេសសិង្ហបុរី**បានបោះពុម្ពផ្សាយ*ការណែនាំដល់អ្នកប្រតិបត្តិក្នុងការស្វែងរកទ្រព្យសម្បត្តិនៅប្រទេសសិង្ហបុរី*[២២៦]។ ឯកសារនេះដើរតួនាទីជាការណែនាំជាជំហានៗសម្រាប់ប្រទេសដាក់សំណើ នៅពេលតាក់តែងសេចក្តីព្រាងនៃសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកទៅប្រទេសសិង្ហបុរី ក្នុងការស្វែងរកទ្រព្យសម្បត្តិដែលជាទ្រព្យបានមកពីបទល្មើស។

---

[២២៥] ច្បាប់ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ១ ឆ្នាំ២០០៦) (ឥណ្ឌូនេស៊ី)។

[២២៦] ការិយាល័យអគ្គមេធាវីរបស់សិង្ហបុរី (ឆ្នាំ២០១៦)។ ការណែនាំដល់អ្នកប្រតិបត្តិក្នុងការស្វែងរកទ្រព្យសម្បត្តិនៅប្រទេសសិង្ហបុរី។ ទាញយកពីគេហទំព័រ៖ https://www.agc.gov.sg/docs/default-source/our-roles-documents/international-law-adviser/practitioner's-guide-for-asset-recovery-in-singapore---13-september-2016.pdf?sfvrsn=2 ។

*តារាង ១១៖ ច្បាប់របស់រដ្ឋសមាជិកអាស៊ាន ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ដើម្បីស្វែងរកទ្រព្យបានមកពីបទល្មើស*

| រដ្ឋសមាជិកអាស៊ាន | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកដើម្បីស្វែងរកទ្រព្យដែលបានមកពីបទល្មើសនៅថ្នាក់ជាតិ |
|---|---|
| ប្រ៊ុយណេ ដារូសាឡាម | បទបញ្ជាស្តីពីជំនួយទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ឆ្នាំ២០០៥) និង បទបញ្ជាស្តីពីការស្វែងរកទ្រព្យសម្បត្តិបានមកពីបទល្មើសឆ្នាំ២០១២ |
| កម្ពុជា | បច្ចុប្បន្នកំពុងតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅថ្នាក់ជាតិ។ បទប្បញ្ញត្តិនៃជំនួយផ្នែកច្បាប់ទៅវិញទៅមកមួយចំនួនមានដូចខាងក្រោម៖<br>• ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០<br>• ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ឆ្នាំ២០១៣<br>• ច្បាប់ស្តីពីអំពើភេរវកម្ម ឆ្នាំ២០០៧ |
| ឥណ្ឌូនេស៊ី | វិធានការទប់ស្កាត់ និងលុបបំបាត់ការសម្អាតប្រាក់ (ច្បាប់លេខ ៨ ឆ្នាំ២០១០) និងច្បាប់ពាក់ព័ន្ធនឹងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ១ ឆ្នាំ២០០៦) |
| ឡាវ | ក្រឹត្យស្តីពីការសម្អាតប្រាក់ឆ្នាំ២០០៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ធ្វើវិសោធនកម្មនៅឆ្នាំ២០១២) ផ្នែក XIV៖ កិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ នៅក្នុង ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងទប់ស្កាត់ការផ្តល់ហិរញ្ញប្បទានដល់ភេរវកម្មឆ្នាំ២០១៥ ផ្នែក III៖ កិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុង AML/CFT |
| ម៉ាឡេស៊ី | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ៦២១) និង ច្បាប់ប្រឆាំងការសម្អាតប្រាក់ ប្រឆាំងហិរញ្ញប្បទានភេរវកម្ម និងទ្រព្យបានមកពីសកម្មភាពខុសច្បាប់ ឆ្នាំ ២០០១ (ច្បាប់លេខ ៦១៣) |
| មីយ៉ាន់ម៉ា | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (ច្បាប់លេខ ៤/២០០៤) |
| ហ្វីលីពីន | *ច្បាប់ប្រឆាំងការសម្អាតប្រាក់ឆ្នាំ២០០១* (ច្បាប់សាធារណរដ្ឋលេខ ៩១៦០ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់សាធារណរដ្ឋលេខ ១០៣៦៥ នៅឆ្នាំ២០១៣) |
| សិង្ហបុរី | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (Cap 190A សំណៅវិសោធនកម្ម ឆ្នាំ២០០១) |
| ថៃ | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ ព.ស ២៥៣៥ (ឆ្នាំ១៩៩២) ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងបញ្ហាព្រហ្មទណ្ឌ (សំណៅលើកទី ២) ព.ស ២៥៥៩ (ឆ្នាំ២០១៦) |
| វៀតណាម | ច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក (ច្បាប់លេខ ០៨/២០០៧/QH១២) ក្រមនីតិវិធីព្រហ្មទណ្ឌ (ក្រមលេខ ១០១/២០១៥/QH១៣) |

ជាសរុបមក រដ្ឋសមាជិកអាស៊ានអាចទទួលបានប្រយោជន៍ពីមូលដ្ឋានគតិយុត្តិជាច្រើន នៅពេលស្នើសុំ និងឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរ។ ក៏ប៉ុន្តែ *ការអនុវត្តន៍* MLA នៅក្នុងសំណុំរឿងទាំងនោះនៅតែកម្រ។

## វឌ្ឍនភាពទាក់ទងនឹងការធ្វើបត្យាប័ន

ដូចករណីជំនួយផ្នែកច្បាប់ទៅវិញទៅមកដែរ ការអភិវឌ្ឍន៍ចម្បងទាក់ទងនឹងការធ្វើបត្យាប័ននៅក្នុងតំបន់អាស៊ានគឺនៅក្នុងវិស័យច្បាប់ និងគោលនយោបាយ ដោយបញ្ជាក់នូវការកើនឡើងនៃការយល់ដឹង (យ៉ាងហោចណាស់នៅកម្រិតខ្លះនៅក្នុងរដ្ឋាភិបាល) នៃតម្រូវការចាំបាច់ឲ្យមានកិច្ចសហប្រតិបត្តិការក្នុងការកែលម្អនៃការឆ្លើយតបរបស់តំបន់ទៅនឹងការជួញដូរមនុស្ស។ ជំនួយផ្នែកច្បាប់ទៅវិញទៅមក (កែសម្រួលលើកទី ២ ឆ្នាំ២០១៨)។ ក្នុងចំណោមការកត់សម្គាល់ជាក់លាក់គឺការផ្តល់តួនាទីដ៏សំខាន់ដល់ការធ្វើបត្យាប័ននៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* និងការបង្កើតមូលដ្ឋានគតិយុត្តិថ្មីមួយសម្រាប់ការធ្វើបត្យាប័ននៅក្នុងសំណុំរឿងជួញដូរមនុស្ស រវាងរដ្ឋសមាជិកអាស៊ានតាមរយៈអនុសញ្ញា។

នៅក្នុងតំបន់នេះ ក៏ដូចជាតំបន់ទាំងអស់ផ្សេងទៀតដែរ ការអនុវត្តន៍ជាក់ស្តែងនៃការធ្វើបត្យាប័នៅក្នុងសំណុំរឿងជួញដូរមនុស្ស នៅតែកម្រណាស់ ទោះបីមានឧទាហរណ៍ជាច្រើនត្រូវបានរាយការណ៍*របាយការណ៍វឌ្ឍនភាពរបស់អាស៊ាន*ក៏ដោយ។

ក្រៅពីបទប្បញ្ញត្តិលម្អិតដែលមាននៅក្នុង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* និងបទប្បញ្ញត្តិស្មើគ្នាដែលបានរកឃើញនៅក្នុង*អនុញ្ញាប្រឆាំងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង* របស់អង្គការសហប្រជាជាតិ ក្របខ័ណ្ឌគតិយុត្តិជុំវិញការធ្វើបត្យាប័ន ក៏បញ្ចូលទៅក្នុងបណ្តាញនៃ**កិច្ចព្រមព្រៀងទ្វេភាគី**ដែលបានធ្វើឡើងរវាងរដ្ឋសមាជិកអាស៊ាន (សូមមើលតារាង ១៣ ខាងក្រោម) និងរវាងរដ្ឋសមាជិកអាស៊ាន និងប្រទេសនានានៅក្រៅតំបន់។ មានវឌ្ឍនភាពមួយចំនួនចាប់តាំងពីឆ្នាំ២០១១ មក នៅពេលសម្រេចបានកិច្ចព្រមព្រៀងទាំងនេះ។

*តារាង ១២៖ រដ្ឋសមាជិកអាស៊ាន៖ ម៉ាទ្រីសនៃការរៀបចំធ្វើបត្យាប័នទ្វេភាគី*

| រដ្ឋសមាជិកអាស៊ាន | ប្រ៊ុយណេ ដារូសាឡាម | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | មីយ៉ាន់ម៉ា | ហ្វីលីពីន | សិង្ហបុរី | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|---|
| ប្រ៊ុយណេ ដារូសាឡាម | - | × | × | × | × | × | × | × | × | × |
| កម្ពុជា | × | - | × | ✓ | × | × | × | × | ✓ | ✓ |
| ឥណ្ឌូនេស៊ី | × | × | - | × | ✓ | × | ✓ | × | ✓ | ✓ |
| ឡាវ | × | ✓ | × | - | × | × | × | × | ✓ | × |
| ម៉ាឡេស៊ី | × | × | ✓ | × | - | × | × | × | ✓ | × |
| មីយ៉ាន់ម៉ា | × | × | × | × | × | - | × | × | × | × |
| ហ្វីលីពីន | × | × | ✓ | × | × | × | - | × | ✓ | × |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សិង្ហបុរី | ✓ | × | × | × | ✓ | × | × | - | × | × |
| ថៃ | × | ✓ | ✓ | ✓ | ✓ | × | ✓ | × | - | × |
| វៀតណាម | × | ✓ | ✓ | × | × | × | × | × | × | - |

រដ្ឋសមាជិកអាស៊ានភាគច្រើនក៏មាន**ច្បាប់ជាតិ**ដែរ ដែលបញ្ជាក់នូវលក្ខខណ្ឌដែលជាមូលដ្ឋានសម្រាប់ស្នើសុំ និងអនុញ្ញាតឲ្យធ្វើបត្យាប័ន និងនីតិវិធីដែលត្រូវអនុវត្តតាម។ ច្បាប់ទាំងនេះភាគច្រើនអះអាងថា ការធ្វើបត្យាប័ននឹងត្រូវបានអនុញ្ញាត (ជួនកាលផ្អែកលើករណីជាក់ស្តែងនីមួយៗ) ដោយគ្មានសន្ធិសញ្ញាទ្វេភាគី ដោយសារបានបំពេញតាមលក្ខខណ្ឌរបស់ច្បាប់។

*តារាង ១៣៖ ក្របខ័ណ្ឌគតិយុត្តិ៖ ច្បាប់ស្តីពីបត្យាប័នរវាងរដ្ឋសមាជិកអាស៊ាន*

| រដ្ឋសមាជិកអាស៊ាន | ច្បាប់ជាតិស្តីពីការធ្វើបត្យាប័ន | ការធ្វើបត្យាប័នដោយគ្មានសន្ធិសញ្ញា? |
|---|---|---|
| ប្រ៊ុយណេ ដារូសាឡាម | បទបញ្ជាស្តីពីការធ្វើបត្យាប័ន ឆ្នាំ២០០៦<br><br>ច្បាប់ស្តីពីការធ្វើបត្យាប័ន (ម៉ាឡេស៊ី និងសិង្ហបុរី) (ជំពូកទី ១៥៤)<br>ច្បាប់ស្តីពីដីកាកោះ និងដីកានាំខ្លួន (បទប្បញ្ញត្តិពិសេស) (ជំពូកទី ១៥៥) | ✓<br><br>✓ |
| កម្ពុជា | ក្រមនីតិវិធីព្រហ្មទណ្ឌ<br>(គន្ថីទី ១ មាតិកាទី ១ ជំពូកទី ២ ផ្នែកទី ១) | ✓ |
| ឥណ្ឌូនេស៊ី | ច្បាប់ស្តីការធ្វើបត្យាប័ន<br>(ច្បាប់លេខ ១ ឆ្នាំ១៩៧៩) | ✓ |
| ឡាវ | ច្បាប់ស្តីនីតិវិធីព្រហ្មទណ្ឌ (ធ្វើវិសោធនកម្មនៅឆ្នាំ២០១២ ផ្នែក XIV ច្បាប់ស្តីការធ្វើបត្យាប័ន (ឆ្នាំ២០១២) | ✓ |
| ម៉ាឡេស៊ី | ច្បាប់ស្តីការធ្វើបត្យាប័នឆ្នាំ១៩៩២<br>[ច្បាប់លេខ ៤៧៩] | ✓ |
| មីយ៉ាន់ម៉ា | ច្បាប់ស្តីការធ្វើបត្យាប័ន (ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧) | ធ្វើឡើងតាមករណីជាក់ស្តែងនីមួយៗ |
| ហ្វីលីពីន | ច្បាប់ស្តីការធ្វើបត្យាប័នឆ្នាំ១៩៧៧<br>(ក្រឹត្យប្រធានាធិបតីលេខ ១០៦៩) | × |
| សិង្ហបុរី | ច្បាប់ស្តីការធ្វើបត្យាប័ន (ជំពូកទី ១០៣) | × |

| រដ្ឋសមាជិកអាស៊ាន | ច្បាប់ជាតិស្តីពីការធ្វើបត្យាប័ន | ការធ្វើបត្យាប័នដោយគ្មានសន្ធិសញ្ញា? |
|---|---|---|
| | | (លើកលែងតែចំពោះ "ប្រទេសអង់គ្លេសរួមសុង (commonwealth) ដែលបានប្រកាស") |
| ថៃ | ច្បាប់ស្តីការធ្វើបត្យាប័ន ព.ស ២៥៥១ (ឆ្នាំ ២០០៨) | ✓<br>(រដ្ឋស្នើសុំត្រូវផ្តល់ការបញ្ជាក់ច្បាស់លាស់ដើម្បីឆ្លើយតបវិញ) |
| វៀតណាម | ច្បាប់ស្តីជំនួយផ្នែកច្បាប់ទៅវិញទៅមក (ច្បាប់លេខ ០៨/២០០៧/QH១២) | ✓ |

## វឌ្ឍនភាពទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាផ្លូវការ៖ ធនធាន និង ការបណ្តុះបណ្តាល

ទោះបីការអនុវត្តន៍ជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការ តាមផ្លូវច្បាប់នៅក្នុងសំណុំរឿង TIP នៅក្នុងតំបន់អាស៊ានមិនទាន់ដំណើរការបានល្អ តែមានវឌ្ឍនភាពក្នុងការបង្កើតធនធាន និងការបណ្តុះបណ្តាល រួមជាមួយក្របខ័ណ្ឌគតិយុត្តិដែលមានសន្ទុះខ្លាំង រំពឹងថានឹងគាំទ្រនូវកិច្ចសហប្រតិបត្តិការតាមផ្លូវច្បាប់បានកាន់តែប្រសើរនាពេលអនាគត។

# ៧.៣ ការប្រឈម និងកាលានុវត្តភាពនាពេលអនាគត

កិច្ចសហប្រតិបត្តិការយ៉ាងមានប្រសិទ្ធភាព មានសារៈសំខាន់ ដើម្បីធានានូវការឆ្លើយតបនៃយុត្តិធម៌ព្រហ្មទណ្ឌដែលមានសន្ទុះទៅនឹងបទល្មើសជួញដូរ។ នៅក្នុងតំបន់អាស៊ាន ក្របខ័ណ្ឌគតិយុត្តិសម្រាប់កិច្ចសហប្រតិបត្តិការនេះមានភាពទូលំទូលាយ ដោយមានករណីលើកលែងមួយចំនួន។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរភស្តុតាង និងព័ត៌មានដែលឆ្លងកាត់ព្រំដែនពិតប្រាកដនៅកម្រិតអ្នកប្រតិបត្តិមានតិចតួច ជាពិសេសទាក់ទិននឹងការប្រើប្រាស់ឧបករណ៍ច្បាប់ផ្លូវការដែលអាចរកបាន។ របាំងផ្នែកភាសា ប្រព័ន្ធយុត្តិធម៌ វិធាន និងការអនុវត្តន៍ខុសគ្នា និងមិនស៊ាំ អំពើពុករលួយ និងការយល់ដឹងពីអំពើពុករលួយ កង្វះសមត្ថភាព និងកង្វះភាពជឿជាក់ និងទំនុកចិត្តទៅលើភ្នាក់ងារអនុវត្តន៍ច្បាប់បរទេស បានរួមចំណែកដល់ការបរាជ័យទូទៅនៃការប្រាស្រ័យទាក់ទងការងារ។ ប្រហែលកត្តាសំខាន់មួយគឺកង្វះការយល់ដឹងទូលំទូលាយពីអ្នកប្រតិបត្តិ មិនត្រឹមតែទៅលើបទប្បញ្ញត្តិច្បាប់ និងសន្ធិសញ្ញាជាធរមានប៉ុណ្ណោះទេ តែថែមទាំងដំណើរការផ្ទៃក្នុងនៅក្នុងរដ្ឋាភិបាល និងទីភ្នាក់ងារពីរបៀបរៀបចំ និងឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន។ នគរបាល និងព្រះរាជអាជ្ញាមិនដឹងពីវិធាន និងនីតិវិធីដើម្បីអនុវត្តនៅពេលប្រឈមនឹងបញ្ហាឆ្លងដែននៅក្នុងសំណុំរឿងរបស់ខ្លួន។

ផ្នែកផ្សេងទៀតនៃជំពូកនេះនឹងពិចារណាទៅលើការប្រឈម និងកាលានុវត្តភាពកាន់តែជាក់លាក់នានា។

# ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងកិច្ចសហប្រតិបត្តិការមិនផ្លូវការជាទូទៅ

ដូចបានកត់សម្គាល់នៅក្នុងជំពូកនេះរួចមកហើយ កម្រិតនៃវឌ្ឍនភាពផ្នែកច្បាប់ និងគោលនយោបាយថ្នាក់តំបន់មិនទាន់ស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង ក្នុងន័យនៃដំណើរការកិច្ចសហប្រតិបត្តិការក្រៅផ្លូវការ។ មានមូលហេតុជាច្រើនសម្រាប់ស្ថានភាពនេះ៖ ក្រៅពីឧបសគ្គនៃរបាំងភាសា ភាពទន់ខ្សោយនៃកិច្ចសហប្រតិបត្តិការផ្នែកអនុវត្តន៍ច្បាប់មានលេចឡើងដោយសារកង្វះចំណេះដឹងផ្នែកច្បាប់ នីតិវិធី និងការអនុវត្តន៍ជាក់ស្តែង ឆន្ទៈ និងសំណើពីអ្នកស៊ើបអង្កេតឯកទេស ដែលជារឿយៗជ្រើសយកវិធីសាស្ត្រមិនយកចិត្តទុកដាក់ចំពោះវិស័យឆ្លងដែននៃសំណុំរឿងរបស់ខ្លួន និងផ្តោតតែទៅលើធាតុផ្សំបទល្មើសក្នុងប្រទេស។ ទោះបីនៅពេលមានកិច្ចសហប្រតិបត្តិការក្រៅផ្លូវការក៏ដោយ តែគុណភាពរបស់វាអាចត្រូវប៉ះពាល់ដោយសារភាពទន់ខ្សោយដែលបន្តមាន ទាក់ទងនឹងការប្រាស្រ័យទាក់ទងផ្ទៃក្នុង និងការចែករំលែកព័ត៌មានសម្ងាត់បានទាន់ពេលវេលារវាងអ្នកស៊ើបអង្កេតនៅតាមខេត្ត និងសហការីនៅអង្គភាពឯកទេសកណ្តាលដែលបណ្តាលឲ្យមានការចែករំលែកព័ត៌មានសម្ងាត់ទៅសហការីនៅក្នុងរដ្ឋសមាជិកអាស៊ានដែលហួសសម័យ ឬមិនត្រឹមត្រូវ។

ក្នុងលក្ខខណ្ឌល្អប្រសើរ កិច្ចសហប្រតិបត្តិការក្រៅផ្លូវការជាមួយសហការីអាស៊ាន ក្នុងសំណុំរឿងជួញដូរគួរតែជាទម្លាប់ធម្មតា នៅពេលដែលការងារនៅកម្រិតឆ្លងកាត់ព្រំដែននៅក្នុងសំណុំរឿងជួញដូរក្លាយជាបទដ្ឋាននៃយុទ្ធសាស្ត្រស៊ើបអង្កេតទាំងអស់នៅក្នុងសំណុំរឿងឆ្លងដែន។ ផ្ទុយទៅវិញ វិធីសាស្ត្រនេះបែរជាពុំមានការជឿជាក់ មិនទុកចិត្តគ្នា និងការស្ទាក់ស្ទើរជាទូទៅក្នុងការអនុវត្តន៍នូវនីតិវិធីដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ និងមានការទទួលខុសត្រូវចំពោះការផ្លាស់ប្តូរប្រតិបត្តិការព័ត៌មានសម្ងាត់ និងការបង្កើតការស៊ើបអង្កេតស្របគ្នា ឬរួមគ្នា។ ការបំពេញការងារមិនស្របនឹងបទដ្ឋាននាពេលបច្ចុប្បន្នរបស់យន្តការជនបង្គោលសំខាន់ គឺជាករណីមួយដែលបញ្ជាក់នូវបញ្ហានេះ ដែលត្រូវបានចាត់ទុកថាជាសមាសធាតុសំខាន់មួយក្នុងការគ្រប់គ្រង ឲ្យមានប្រសិទ្ធភាពនូវការប្រាស្រ័យទាក់ទងការងារ និងការសម្របសម្រួលឆ្លងដែន ការចាត់តាំង និងលក្ខខណ្ឌការងារសម្រាប់យន្តការជនបង្គោលដែលត្រូវបានបង្កើតឡើង និងព្រមព្រៀងដោយអ្នកប្រតិបត្តិអាស៊ាននៅឆ្នាំ២០១៥។ តែវានៅតែជារឿងធម្មតាដែលការផ្លាស់ប្តូរព័ត៌មានទំនាក់ទំនងរបស់ជនបង្គោលមិនត្រូវបានរាយការណ៍រវាងអង្គភាពឯកទេសនៅក្នុងរដ្ឋសមាជិកអាស៊ាន ហើយបុគ្គលិកក៏មិនបានដឹងពីអត្ថិភាពនៃជនបង្គោលរបស់ខ្លួន កុំថាឡើយដល់ទៅជនបង្គោលរបស់អង្គភាពរបស់រដ្ឋសមាជិកអាស៊ានផ្សេងទៀត។

ទោះបីទំហំនៃការប្រឈមមានភាពធំធេងយ៉ាងណាក៏ដោយ ក៏មានឧទាហរណ៍ល្អៗដែលបង្ហាញពីអ្វីដែលសម្រេចបានតាមរយៈការបង្កើត និងការអនុវត្តន៍យន្តការក្រៅផ្លូវការដែលមានរចនាសម្ព័ន្ធត្រឹមត្រូវដែរ។ គំនិតផ្តួចផ្តើមនាពេលបច្ចុប្បន្ននៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួនដើម្បីកែលម្អមជ្ឈការនៃព័ត៌មានសម្ងាត់នៃការជួញដូរនៅថ្នាក់ជាតិ និងសម្រាប់ចែករំលែកនូវព័ត៌មានសម្ងាត់នេះទៅតាមទម្រង់ដែលមានបទដ្ឋានត្រឹមត្រូវ តាមរយៈជនបង្គោលដែលជាផ្នែកនៃកិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែនដែលកំពុងដំណើរការ ផ្តល់នូវភស្តុតាងអំពីការកែលម្អក្នុងការអនុវត្តន៍ និងជាគំរូសម្រាប់ការកែលម្អនាពេលអនាគត។ ក៏ប៉ុន្តែ ព័ត៌មានវិជ្ជមាននេះត្រូវបានធ្វើឲ្យប៉ះពាល់ដល់ភាពជាក់ស្តែងដែលថា វាកាន់តែពង្រឹងនូវកម្លាំងរបស់បុគ្គលថ្នាក់ដឹកនាំនៅក្នុងការផ្តួចផ្តើមទាំងនោះភាគច្រើន ជាជាងអនុវត្តន៍ឲ្យមានប្រសិទ្ធភាពនូវនីតិវិធីដែលមានស្រាប់ និងនិរន្តរភាពដែលបានផ្តល់នូវលទ្ធផលវិជ្ជមាន។ ស្រដៀងគ្នាដែរ ការជំរុញដល់ការប្រើប្រាស់ជនបង្គោលនៅក្នុងដំណើរការឧទាហរណ៍នៃឧត្តមានុវត្តន៍នៃកិច្ចសហប្រតិបត្តិការឆ្លងដែន ត្រូវរងផល

ប៉ះពាល់ដោយសារ ការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នភាពនៃបញ្ជីរាយនាមជនបង្គោលនៅតែបន្តធ្វើឡើងដោយម្ចាស់ជំនួយអន្តរជាតិ ពុំមែនជាស្ថាប័នរបស់អាស៊ាន។

ដោយផ្អែកលើបទពិសោធន៍ ដែលបានជួបប្រទះក្នុងអំឡុងពេលរៀបចំគំនិតផ្តួចផ្តើមស៊ើបអង្កេតទ្វេភាគីចំនួន ៣ នាពេលបច្ចុប្បន្ន មានការផ្តល់អនុសាសន៍ថា អ្នកតំណាងជាន់ខ្ពស់ពីអង្គភាពឯកទេសអាស៊ាន រួមជាមួយព្រះរាជអាជ្ញាដែលមានគុណសម្បត្តិសក្តិសម និងបទពិសោធន៍ និងមេធាវីនៅអាជ្ញាកណ្តាលពីប្រទេសនីមួយៗធ្វើការប្រជុំគ្នាដោយការឧបត្ថម្ភពីក្រុមការងារ SOMTC ទទួលបន្ទុកការជួញដូរមនុស្ស និងដំណើរការ HSU ដើម្បី៖

- បង្កើតបទដ្ឋាននីតិវិធីប្រតិបត្តិការអាស៊ានលម្អិតទូទៅសម្រាប់ការបង្កើត ការអនុវត្តន៍ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែន និង
- បំពេញទៅតាមលក្ខខណ្ឌតម្រូវនៃ*ផែនការសកម្មភាពអាស៊ាន* ឃ (ជ) (i) ដើម្បីពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តន៍នូវយន្តការជនបង្គោលក្រោមភាពជាម្ចាស់ និងការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋសមាជិកអាស៊ាន។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងដំណើរការ HSU អាស៊ាន

ការបង្កើតនូវរចនាសម្ព័ន្ធនៃដំណើរការ HSU អាស៊ាន នៅក្នុងក្បាលម៉ាស៊ីនប្រឆាំងការជួញដូរថ្នាក់តំបន់ដែលសម្រេចបាននូវគោលដៅនៃការដាក់ដំណើរការ HSU ក្នុងជំហរប្រកបដោយនិរន្តរភាព។ ផ្ទុយទៅវិញ ផលវិបាកក្លាយជាការកាត់បន្ថយយ៉ាងធ្ងន់ធ្ងរទៅលើប្រសិទ្ធភាពរបស់វា ក្នុងនាមជាវេទិកាថ្នាក់តំបន់សម្រាប់អ្នកគ្រប់គ្រងប្រតិបត្តិការជំនាញដើម្បីផ្លាស់ប្តូរព័ត៌មានសម្ងាត់ផ្អែកលើសំណុំរឿង និងបង្កើតគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការឆ្លងដែន។ ដំណើរការ HSU បានផ្លាស់ប្តូរជាបណ្តើរៗនូវទិសដៅឆ្ពោះទៅវិស័យការងារកម្រិតគោលនយោបាយទៅការបាត់បង់ការផ្តោតលើប្រតិបត្តិការខាងលើ ទោះដល់វិសាលភាពដែលភាពជាក់ស្តែងបច្ចុប្បន្នគឺថា កិច្ចសហប្រតិបត្តិការស៊ើបអង្កេតឆ្លងដែនជាញឹកញយត្រូវបានដំណើរការដោយផ្អែកលើមូលដ្ឋានទ្វេភាគី ជាជាងថ្នាក់តំបន់។ ថ្វីត្បិតតែយ៉ាងនេះក្តី ដំណើរការ HSU បន្តផ្តល់នូវវេទិកាពហុភាគីសំខាន់មួយសម្រាប់ឲ្យអ្នកតំណាងចូលរួមជាមួយគ្នា ដើម្បីពិភាក្សាអំពីការប្រឈម និងគំនិតផ្តួចផ្តើមរួមប្រឆាំងការជួញដូរ។

ដោយសារការអនុម័ត*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរ* បង្កើតនូវលក្ខខណ្ឌច្បាស់លាស់មួយដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ នៅក្នុងការស៊ើបអង្កេតទៅលើសំណុំរឿងជួញដូរ (មាត្រា ១២(ឃ)) ហើយ ជាពិសេស គឺថា *ផែនការសកម្មភាពអាស៊ាន* (ផ្នែក ឃ (ក)) អំពាវនាវឲ្យពង្រឹងដំណើរការ HSU នោះតែម្តង វាជាសំខាន់គឺថា តួនាទីរបស់ដំណើរការ HSU ត្រូវបានយកមកពិនិត្យឡើងវិញ និងកំណត់ឡើងវិញ ប្រសិនបើវាបំពេញទៅតាមការទទួលខុសត្រូវរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព។

នៅក្នុងការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយ SOMTC និងក្រោមការណែនាំរបស់ប្រធានក្រុមស្ម័គ្រចិត្ត SOMTC និងក្រុមការងារ SOMTC ទទួលបន្ទុកការជួញដូរមនុស្ស ប្រធានប្រតិបត្តិការអង្គការឯកទេសរបស់រដ្ឋសមាជិកអាស៊ាន គួរធ្វើការពិនិត្យរួមគ្នាទៅលើដំណើរការ HSU ក្នុងករណីដែលអាចធ្វើបាន ដើម្បី៖

- កំណត់អំពីតួនាទីរបស់ខ្លួននៅក្នុងហេដ្ឋារចនាសម្ព័ន្ធប្រឆាំងការជួញដូរអាស៊ាន ជាពិសេស ក្នុងន័យថាតើគេអាច ឬគួរតែរក្សាកម្រិតនៃការទទួលខុសត្រូវចំពោះសកម្មភាពប្រតិបត្តិការនានាដូចជាការផ្លាស់ប្តូរព័ត៌មានសម្ងាត់ និងកិច្ចសហប្រតិបត្តិការស៊ើបអង្កេតស្របគ្នា ឬរួមគ្នា

- ពិនិត្យ និងកែប្រែលក្ខខណ្ឌការងាររបស់ខ្លួនទៅតាមនោះ
- ពិនិត្យ និងកែប្រែផែនការងារប្រចាំឆ្នាំរបស់ខ្លួន និងបរិវេណនៃការរាយការណ៍
- កំណត់អំពីកិច្ចប្រជុំល្អបំផុតដើម្បីជួយឱ្យគេអាចអនុវត្តការងាររបស់ខ្លួន និង
- កំណត់ និងអនុវត្តកម្មវិធីបង្កើនការយល់ដឹង ដើម្បីធានាថា តួអង្គពាក់ព័ន្ធទាំងអស់នៅក្នុងរដ្ឋសមាជិកអាស៊ានយល់ដឹងយ៉ាងពេញលេញនូវតួនាទី គោលដៅ និងសមត្ថភាពរបស់ខ្លួន។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹងក្របខ័ណ្ឌគតិយុត្តិ និងជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន

ជាទូទៅ ក្របខ័ណ្ឌគតិយុត្តិជុំវិញកិច្ចសហប្រតិបត្តិការច្បាប់ជាអន្តរជាតិ គឺជាសន្ទុះនៅក្នុងតំបន់អាស៊ាន ត្រូវបានពង្រឹងដោយសន្ធិសញ្ញាអាស៊ានឯកទេសស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលអាចយកមកប្រើប្រាស់នៅក្នុងសំណុំរឿងជួញដូរ និងដោយអត្រាខ្ពស់នៃការប្រកាន់ខ្ជាប់របស់រដ្ឋសមាជិកអាស៊ានចំពោះលិខិតូបករណ៍អន្តរជាតិសំខាន់ៗ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិមិនទាន់គាំទ្រទាំងស្រុងដល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្សនៅឡើយទេ។ ឧទាហរណ៍ នៅ**ប្រទេសហ្វីលីពីន** ពុំមានច្បាប់ពិសេសគ្រប់គ្រងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកទេ។ ស្រដៀងគ្នាដែរ **ប្រទេសកម្ពុជា** មិនទាន់បញ្ចប់ការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅឡើយទេ។ នៅក្នុងករណីរបស់ហ្វីលីពីន និងកម្ពុជា គម្លាតផ្នែកច្បាប់ទាំងនេះអាចត្រូវបានបំពេញតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងសន្ធិសញ្ញានានាដូចជា UNTOC និង ASEAN MLAT។ ក៏ប៉ុន្តែ មកទល់នឹងពេលនេះ ហាក់ដូចជាពុំមានលិខិតូបករណ៍ណាមួយត្រូវបានយកមកប្រើប្រាស់ដើម្បីសម្រេចទៅតាមវត្ថុបំណងនោះនៅឡើយទេ។

ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិជុំវិញការធ្វើបត្យាប័នពុំមានភាពច្បាស់លាស់ទេនៅក្នុងរដ្ឋសមាជិកអាស៊ានជាច្រើន។ នៅ**ប្រទេសមីយ៉ាន់ម៉ា** អនុលោមតាម*ច្បាប់សភាសហភាពលេខ ១៦ ច្បាប់ស្តីពីការធ្វើបត្យាប័នឆ្នាំ២០១៧* ត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីពេលដែលច្បាប់នេះត្រូវបានចុះហត្ថលេខាប្រកាសឱ្យប្រើ។ មីយ៉ាន់ម៉ាក៏បានបង្កើតឧបម្រុងមួយនៅពេលផ្តល់សច្ចាប័នដល់ UNTOC ដែលថា ប្រទេសនេះមិនជាប់កាតព្វកិច្ចពាក់ព័ន្ធនឹងការធ្វើបត្យាប័នទេ។ ក៏ប៉ុន្តែ វាជាការពាក់ព័ន្ធដែលគួរកត់សម្គាល់ថា ឧបម្រុងស្រដៀងគ្នាមួយមិនត្រូវបានធ្វើឡើងទាក់ទងនឹង*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស* ទេ ដែលមានបទប្បញ្ញត្តិស្ទើរតែដូចគ្នាបេះបិទ។

សូម្បីតែមានមូលដ្ឋានគតិយុត្តិផ្សេងទៀត (ឧទា. *ASEAN AMLAT* ឬ*អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងការជួញដូរមនុស្ស*) ក៏ដោយ តែកង្វះភាពច្បាស់លាស់ផ្នែកច្បាប់ស្តីពីការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្រោមច្បាប់ជាតិ ធ្វើឱ្យប្រទេសនានាហាក់ដូចនឹងមិនស្នើសុំកិច្ចសហប្រតិបត្តិការជាអន្តរជាតិទេ ឬពួកគេនឹងមិនបង្កើតគោលការណ៍ណែនាំដែលជួយឱ្យមន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌអាចចូលរួមទៅក្នុងកិច្ចសហប្រតិបត្តិការជាអន្តរជាតិទេ។ ក្រៅពីការកើនឡើងនូវភាពអល់អែកក្នុងការធ្វើសកម្មភាព ការណ៍ដែលពុំមានគោលការណ៍ណែនាំថ្នាក់ជាតិច្បាស់លាស់ស្តីពីរបៀបដាក់សំណើ និងឆ្លើយតបក៏កាត់បន្ថយនូវក្តីរំពឹងពីភាពជោគជ័យនៃសំណើសុំ និងហាក់ដូចជាកាន់តែមានការពន្យារពេលទៀតផង។

ក្នុងការស្វែងរកការធានាឲ្យមានក្របខ័ណ្ឌខ្លាំងក្លាមួយសម្រាប់កិច្ចសហប្រតិបត្តិការផ្លូវច្បាប់ជាអន្តរជាតិ រដ្ឋសមាជិកអាស៊ានគួរពិចារណា៖

- ធានាថា ពួកគេបានបំពេញចំនុចខ្វះខាតនូវគម្លាតនៃការផ្តល់សច្ចាប័នទាក់ទងនឹងសន្ធិសញ្ញាអន្តរជាតិ និងថ្នាក់តំបន់ធំៗ (សូមមើលតារាង ២ ក្នុងជំពូកទី ១)
- ពិនិត្យឡើងវិញនូវច្បាប់ជាតិដែលពាក់ព័ន្ធ និងសន្ធិសញ្ញាទ្វេភាគីក្នុងគោលបំណងកំណត់អំពីភាពមិនប្រក្រតី គម្លាត និងភាពទន់ខ្សោយដែលអាចរារាំងមិនឲ្យរដ្ឋដាក់សំណើ ឬឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរមនុស្ស។

## ការប្រឈម និងកាលានុវត្តភាពទាក់ទងនឹង*ការអនុវត្តន៍ជាក់ស្តែង*នូវកិច្ចសហប្រតិបត្តិការផ្លូវការ

ដូចបានកត់សម្គាល់ខាងលើ ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ននៅក្នុងសំណុំរឿងជួញដូរ មានភាពកម្រជាខ្លាំង ទោះបីមានសំណុំរឿងជួញដូរជាច្រើន នៅក្នុងតំបន់នេះមានលក្ខណៈឆ្លងដែនក៏ដោយ។ ប៉ុន្តែកិច្ចសហប្រតិបត្តិការនេះមិនបានកំហិតត្រឹមតែការជួញដូរទេ។ នៅក្នុងករណីដែលពាក់ព័ន្ធនឹងបញ្ហាឆ្លងដែន ព្រះរាជអាជ្ញាហាក់ដូចជាមិនទាក់ទងសមភាគីរបស់ខ្លួននៅក្នុងប្រទេសពាក់ព័ន្ធផ្សេងទៀត ឬសូម្បីតែមេធាវីនៅអាជ្ញាធរបណ្តាលនៅក្នុងប្រទេសរបស់ខ្លួន ជាលក្ខណៈផ្លូវការ ឬតាមមធ្យោបាយផ្សេងទៀត ដើម្បីទទួលបានភស្តុតាង ស្នើសុំការធ្វើបត្យាប័ន ឬផ្តល់ព័ត៌មាន។

នៅក្នុងសំណុំរឿងជាច្រើន ដែលត្រូវបានយកមកពិនិត្យសម្រាប់ *របាយការណ៍វឌ្ឍនភាពអាស៊ាន* ឆ្នាំ២០១១ មន្ត្រីនគរបាល ព្រះរាជអាជ្ញា និងចៅក្រមដែលចូលរួមនៅក្នុងសំណុំរឿងជួញដូរ មិនបានដឹងពីសន្ធិសញ្ញា និងច្បាប់ជាតិស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន និងមិនបានដឹងពីរបៀបស្វែងរកជំនួយអនុលោមតាមសន្ធិសញ្ញា និងច្បាប់ទាំងនោះទេ។ ជាពិសេស ព្រះរាជអាជ្ញាហាក់ដូចជាមិនបានដឹងពីបទដ្ឋាន ASEAN MLAT មិនច្បាស់លាស់ពីរបៀប និងថាតើពួកគេទទួលបានអនុញ្ញាតឲ្យធ្វើការទំនាក់ទំនងជាមួយសមភាគីបរទេស និងមិនច្បាស់អំពីបែបបទផ្ទៃក្នុងសម្រាប់ស្នើសុំជំនួយពីអាជ្ញាធរកណ្តាល។ ទោះបីការយល់ដឹងអាចមានការកើនឡើងក្នុងរយៈពេល ៧ ឆ្នាំមកនេះនៅក្នុងទីភ្នាក់នៅក្នុងប្រទេសមួយចំនួនក៏ដោយ តែស្ថានភាពនេះនៅតែមិនមានការផ្លាស់ប្តូរដដែល៖ ព្រះរាជអាជ្ញានៅបន្តចាត់ទុកបញ្ហាព្រំដែនថាមានលំបាកជាខ្លាំងមិនអាចដោះស្រាយបាន និងមិនស្ថិតក្នុងវង្វង់នៃការទទួលខុសត្រូវរបស់ខ្លួនទេ។ ហេតុនេះ ពុំបានទទួលភស្តុតាងចាំបាច់ ហើយក៏ពុំបានចែករំលែកនូវព័ត៌មានដែលអាចនាំឲ្យមានការចោទប្រកាន់ថែមទៀតទេ។

ដើម្បីពង្រឹងការអនុវត្តន៍កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងតំបន់អាស៊ាន រដ្ឋសមាជិកអាស៊ានគួរពិចារណាជំហាននានាដើម្បី៖

- កែលម្អការយល់ដឹងរបស់អ្នកប្រតិបត្តិអំពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិ រួមមានឧបករណ៍ដែលពួកគេអាចរកបានដូចជា *សៀវភៅអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស* ដែលបានកែប្រែ ជាដើម

- បង្កើតគោលការណ៍ណែនាំផ្ទៃក្នុងដើម្បីឱ្យព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ដោយមានជំនួយងាយៗ ជាជំហានៗស្តីពីការឆ្លើយតប និងទំនាក់ទំនងជាមួយអាជ្ញាធរកណ្តាលនៅពេលប្រឈមនឹងបញ្ហាឆ្លងដែន
- ចាត់តាំងជនបង្គោលមួយរូប នៅក្នុងអាជ្ញាធរកណ្តាល ដើម្បីដោះស្រាយសំណើដែលបានទទួល និង ដែលបានស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន
- ជំរុញភាពស៊ាំ និងការប្រើប្រាស់គំរូផ្នែកលើគេហទំព័រសម្រាប់ដាក់សំណើ និងទទួលសំណើសុំ ជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន
- ពង្រឹងសមត្ថភាពរបស់ស្ថាប័ន/មន្ត្រីពាក់ព័ន្ធ ដើម្បីទទួលខុសត្រូវផ្នែកជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន រួមទាំង តាមរយៈការសំអាងទៅលើ*គំរូកម្មវិធីបណ្តុះបណ្តាលអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្ស*
- បង្កើតបណ្តាញមិនផ្លូវការនៃព្រះរាជអាជ្ញា/មន្ត្រីអាជ្ញាធរកណ្តាលឯកទេស ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិ។

| ជំពូកទី ៧ បញ្ជីត្រួតពិនិត្យ៖<br>ការបង្កើតប្រព័ន្ធដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការស៊ើបអង្កេត និងផ្នែកតុលាការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាពទៅលើសំណុំរឿងជួញដូរ | |
|---|---|
| លេខយោង | បទដ្ឋានគុណភាព |
| ៧.១ | ភ្នាក់ងារអនុវត្តន៍ច្បាប់សហការយ៉ាងមានប្រសិទ្ធិភាពនៅកម្រិតទ្វេភាគី និងថ្នាក់តំបន់ |
| ៧.១.១ | ក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីអនុញ្ញាត និងសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការឆ្លងដែន រួមទាំងដំណើរការស៊ើបអង្កេតរួមគ្នា ឬស្របគ្នារវាងកងកម្លាំងនគរបាលជាតិ |
| ៧.១.២ | អង្គភាពឯកទេសប្រឆាំងការជួញដូរមានបុគ្គលិកដែលទទួលការបណ្តុះបណ្តាល និងមានជំនាញ ដែលមានសមត្ថភាពផ្នែកច្បាប់ និងប្រតិបត្តិការ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដោយប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតក្រោយពេលកើតហេតុ ឬមុនពេលកើតហេតុ នៅក្នុងក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីដែលស៊ីចង្វាក់យ៉ាងទូលំទូលាយ (សូមមើលផងដែរ បញ្ជីត្រួតពិនិត្យនៅក្នុង ជំពូកទី ១ និង ទី២) |
| ៧.១.៣ | មានការបង្កើតបណ្តាញបុគ្គលិកអង្គភាពឯកទេសទ្វេភាគី ថ្នាក់តំបន់ និងជាអន្តរជាតិ ដែលសហការរវាងប្រទេសដែលទទួលរងផលប៉ះពាល់ទៅវិញទៅមក ដោយមានការចែករំលែកនូវព័ត៌មាន និងឧត្តមានុវត្តន៍ និង បោះជំហានទៅមុខនូវការស៊ើបអង្កេតប្រតិបត្តិការជាក់លាក់ |
| ៧.១.៤ | អង្គភាពឯកទេសដែលធ្វើកិច្ចសហប្រតិបត្តិការបានចាត់តាំងឲ្យមានការទាក់ទងទៅជនបង្គោល ២៤ ម៉ោងលើ ២៤ ម៉ោង និងធានានូវសមត្ថភាពទំនាក់ទំនងការងារដែលធ្វើជាលេខសម្ងាត់ ដើម្បីគ្រប់គ្រងដំណើរការកិច្ចសហប្រតិបត្តិការនៅក្នុងការអនុវត្តន៍ជាក់ស្តែងនៃទំនាក់ទំនងការងារ ដែលបញ្ចូលទិន្នន័យសើបពាក់ព័ន្ធជនរងគ្រោះ តាមរយៈប្រព័ន្ធទំនាក់ទំនងការងារដែលជាលេខសម្ងាត់មានសុវត្ថិភាព |
| ៧.១.៥ | អង្គភាពឯកទេសប្រឆាំងការជួញដូររបស់ប្រទេសដែលទទួលរងផលប៉ះពាល់ទៅវិញទៅមក ផ្តល់នូវការគាំទ្រប្រតិបត្តិការ និងការស៊ើបអង្កេតទាន់ពេលវេលាដល់គ្នាទៅវិញទៅមក សម្រាប់គោលបំណងនានាដូចខាងក្រោម៖ ដើម្បីផ្តួចផ្តើមសកម្មភាពបន្ទាន់ដើម្បីជួយសង្គ្រោះជនរងគ្រោះ ឬឆ្លើយតបទៅនឹងបទល្មើសជួញដូរជាក់ស្តែង។<br>• ដើម្បីផ្លាស់ប្តូរ និងបង្កើតព័ត៌មានសម្ងាត់នៃការជួញដូរឆ្លងដែន។<br>• ដើម្បីបង្កើតនូវអត្តិភាព និងភាពអាចរកបាននៃភស្តុតាងមុនពេលស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ឬស្វែងរកវឌ្ឍនភាពនៃសំណើនេះ។<br>• ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតឆ្លងដែនរួមគ្នា ឬស្របគ្នា។<br>• ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុឆ្លងដែនស្របគ្នា។ |
| ៧.១.៦ | សកម្មភាពកិច្ចសហប្រតិបត្តិការនានាដែលបានរៀបរាប់ខាងលើ ត្រូវធ្វើឡើងស្របទៅនឹងលក្ខខណ្ឌនៅក្នុងសន្ធិសញ្ញាពាក់ព័ន្ធ និងឧត្តមានុវត្តន៍នៃការស៊ើបអង្កេតដែលត្រូវបានទទួលយក។ |
| ៧.១.៧ | អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាជំនាញនៅក្នុងប្រទេសដែលបានចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការឆ្លងដែនជាអ្នកប្រាស្រ័យទាក់ទង និងសម្របសម្រួលជាមួយគ្នា នៅពេលចាប់ផ្តើមដំណើរការកិច្ចសហប្រតិបត្តិការ |
| **៧.២** | **ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិអាចជួយ និងគាំទ្រដល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងការជួញដូរមនុស្ស និងសំណុំរឿងពាក់ព័ន្ធ** |

| ជំពូកទី ៧ បញ្ជីត្រួតពិនិត្យ៖<br>ការបង្កើតប្រព័ន្ធដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការស៊ើបអង្កេត និងផ្នែកតុលាការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាពទៅលើសំណុំរឿងជួញដូរ | |
|---|---|
| ៧.២.១ | រដ្ឋជាភាគីនៃសន្ធិសញ្ញាថ្នាក់តំបន់ និងអន្តរជាតិទាំងនោះដែលផ្តល់មូលដ្ឋានគតិយុត្តិសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកនៅក្នុងសំណុំរឿងជួញដូរ |
| ៧.២.២ | បទល្មើសជួញដូរនិងបទល្មើសពាក់ព័ន្ធស្ថិតក្រោមវិសាលភាពនៃការអនុវត្តន៍ច្បាប់ជាតិដែលគ្រប់គ្រងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ព្រមទាំងសន្ធិសញ្ញាទ្វេភាគី និងពហុភាគីពាក់ព័ន្ធដែលរដ្ឋជាភាគី។ |
| ៧.២.៣ | ច្បាប់ និងនីតិវិធី ដែលអាចឲ្យរដ្ឋផ្តល់នូវទម្រង់ទូលំទូលាយបំផុត នៃជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលចាំបាច់សម្រាប់ការចោទប្រកាន់ទៅលើសំណុំរឿងជួញដូរយ៉ាងមានប្រសិទ្ធភាព។ |
| **៧.៣** | **ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិជួយ និងគាំទ្រដល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកពាក់ព័ន្ធនឹងការស្វែងរកទ្រព្យបានមកពីការជួញដូរមនុស្ស និងសំណុំរឿងពាក់ព័ន្ធ** |
| ៧.៣.១. | ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិអនុញ្ញាតឲ្យមានជំនួយផ្នែកច្បាប់ទៅវិញទៅមក ក្នុងការគាំទ្រដល់សកម្មភាពនានាទាក់ទងនឹងទ្រព្យពាក់ព័ន្ធការជួញដូរដូចជា៖ (១) ការតាមដាន និងការកំណត់អត្តសញ្ញាណ (២) ការបង្កក និងការចាប់យក (៣) ការរឹបអូស (៤) ការធ្វើមាតុភូមិនិវត្តន៍នៃទ្រព្យទាំងនោះ។ |
| **៧.៤** | **ក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិជួយ និងគាំទ្រដល់ការធ្វើបត្យាប័ននៅក្នុងការជួញដូរមនុស្ស និងសំណុំរឿងពាក់ព័ន្ធ** |
| ៧.៤.១ | រដ្ឋបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាទាំងនោះដែលផ្តល់ជាមូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើបត្យាប័ននៅក្នុងសំណុំរឿងជួញដូរ ឬផ្តល់តាមវិធីផ្សេងទៀតនូវមូលដ្ឋានគតិយុត្តិផ្សេងទៀតដែលពេញលេញសម្រាប់ការធ្វើបត្យាប័ននេះ។ |
| ៧.៤.២ | បទល្មើសជួញដូរ និងបទល្មើសពាក់ព័ន្ធជាបទល្មើសអាចធ្វើបត្យាប័នបាននៅក្នុងច្បាប់ជាតិដែលពាក់ព័ន្ធ ព្រមទាំងសន្ធិសញ្ញាទ្វេភាគី និងពហុភាគីដែលរដ្ឋជាភាគី។ |
| ៧.៤.៣ | ច្បាប់ និងនីតិវិធីពាក់ព័ន្ធ អាចជួយឲ្យរដ្ឋដំណើរការចោទប្រកាន់ ទៅលើសំណុំរឿងទាំងនោះដែលទាក់ទងនឹងការបដិសេធមិនធ្វើបត្យាប័នតាមផ្លូវច្បាប់។ |
| **៧.៥** | **ភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌថ្នាក់ជាតិបង្ហាញសមត្ថភាពក្នុងការចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិ និងការធ្វើបត្យាប័ន** |
| ៧.៥.១ | ឲ្យដំណើរការអាជ្ញាធរជាតិមានសមត្ថកិច្ច |
| ៧.៥.២ | អាជ្ញាធរជាតិមានសមត្ថភាពក្នុងការរៀបចំ និងឆ្លើយតបសំណើសុំជំនួយនៅក្នុងសំណុំរឿងជួញដូរមនុស្ស និងទាក់ទងការងារដោយផ្ទាល់ និងមានសុវត្ថិភាពជាមួយអាជ្ញាធរសមភាគីនៅក្នុងរដ្ឋសមាជិកអាស៊ានផ្សេងទៀត។ |
| ៧.៥.៣ | ព្រះរាជអាជ្ញា មេធាវីអាជ្ញាធរកណ្តាល និងមន្ត្រីផ្សេងទៀតដែលចូលរួម ឬអាចចូលរួមក្នុងការដាក់សំណើ និងទទួលសំណើសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរ បានទទួលការបណ្តុះបណ្តាលពេញលេញស្របទៅនឹងការទទួលខុសត្រូវរបស់ខ្លួន។ |
| ៧.៥.៤ | ព្រះរាជអាជ្ញា មេធាវីអាជ្ញាធរកណ្តាល និងមន្ត្រីផ្សេងទៀតដែលបានទទួលការចាត់តាំងពិសេស សហការយ៉ាងជិតស្និទ្ធក្នុងការរៀបចំ និងអនុវត្តសំណើសុំជំនួយ។ |

| ជំពូកទី ៧ បញ្ជីត្រួតពិនិត្យ៖<br>ការបង្កើតប្រព័ន្ធដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការស៊ើបអង្កេត និងផ្នែកតុលាការជាអន្តរជាតិយ៉ាងមានប្រសិទ្ធភាពទៅលើសំណុំរឿងជួញដូរ | |
|---|---|
| ៧.៥.៥ | ព្រះរាជអាជ្ញា មេធាវីអាជ្ញាធរកណ្តាល និងមន្ត្រីផ្សេងទៀតដែលបានទទួលការចាត់តាំងពិសេស ជួបប្រជុំជាទៀងទាត់ជាមួយសមភាគីនៅកម្រិតទ្វេភាគី ថ្នាក់តំបន់ និងពហុភាគី ដើម្បីផ្លាស់ប្តូរព័ត៌មាន និងឧត្តមានុវត្តន៍។ |
| ៧.៥.៦ | ក្នុងការកំណត់ថាតើគួរស្នើសុំ ឬផ្តល់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរ ឬយ៉ាងណា ព្រះរាជអាជ្ញា និង/ឬ អាជ្ញាធរកណ្តាលគួរពិគ្រោះយោបល់ដើម្បីកំណត់ថា តើ៖<br>• ការប្រើប្រាស់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិជាការចាំបាច់ ឬទេ ឬថាតើ កម្មវត្ថុទាំងនេះអាចសម្រេចបានតាមមធ្យោបាយផ្សេងទៀត ឬទេ<br>• វានឹងជួយឱ្យសំណុំរឿងមានភាពរឹងមាំ ឬទេ<br>• កិច្ចសហប្រតិបត្តិការនេះស្របច្បាប់ ឬទេ ហើយ បើស្របច្បាប់ តើមានលិខិតូបករណ៍នៃកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ណាដែលសក្តិសមជាងគេ ដែលយកមកប្រើ<br>• តើផលប៉ះពាល់អ្វីខ្លះដែលអាចមាន (រួមទាំងទៅលើជនរងគ្រោះ) ពីការពន្យារពេល ឬមិនអនុវត្តតាមសំណើណាមួយទៅលើសំណុំរឿងនោះ<br>• លទ្ធផលដែលរំពឹងទុកមានទម្ងន់ជាងហានិភ័យដែលបានរកឃើញ ឬទេ។ |
| ៧.៥.៧ | សិទ្ធិមនុស្សត្រូវបានគោរពនៅក្នុងដំណើរការសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក និងការធ្វើបត្យាប័ន រួមទាំងទាក់ទងនឹងសំណើសុំ នីតិវិធី និងលទ្ធផល។ អាជ្ញាធរជាតិត្រូវធានាថា សំណើសុំ កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាអន្តរជាតិនៅក្នុងសំណុំរឿងជួញដូរមនុស្សត្រូវបានទទួលស្គាល់ ផ្តល់ជាអាទិភាព និងពន្លឿនដោយរដ្ឋទទួលសំណើ។ |

# របាយការណ៍វឌ្ឍនភាព

ស្តីពីការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅនឹងការជួញដូរមនុស្សនៅតំបន់អាស៊ាន